# ការលើកទឹកចិត្តខ្លះៗសម្រាប់ សៀវភៅណែនាំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ

ខ្ញុំសូមណែនាំលោកអ្នក ដោយក្ដីរីករាយយ៉ាងខ្លាំង ឲ្យអានសៀវភៅណែនាំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ : ដឹកនាំពួកជំនុំរបស់អ្នក ក្នុងការថ្វាយបង្គំដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ដែលលោកគ្រូ Kenny Lamm បាននិពន្ធ។ ក្នុងនាមលោកគ្រូ Lamm ជាអ្នកជំនាញផ្នែកការថ្វាយបង្គំដែលមានឥទ្ធិពល និងទទួលបានការគោរពយ៉ាងទូលំទូលាយម្នាក់ ក្នុងពេលសព្វថ្ងៃ គាត់បានប្រើបទពិសោធន៍ដ៏សម្បូរបែបរបស់គាត់ ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ គ្រូឱវាទ គ្រូបង្រៀន និងអ្នកប្រឹក្សា ដើម្បីផ្ដល់នូវការណែនាំ តាមទិដ្ឋភាពជាក់ស្ដែងយ៉ាងខ្លាំង និងឈរលើមូលដ្ឋានព្រះគម្ពីរយ៉ាងរឹងមាំ។ គាត់ក៏មានភាពល្អិតល្អន់ ក្នុងការនិពន្ធសៀវភៅនេះផងដែរ ដោយការណែនាំអំពីចំណុចសំខាន់ៗជាច្រើន រាប់ចាប់តាំងពីគ្រឹះនៃការថ្វាយបង្គំ និងភាពជាអ្នកដឹកនាំការថ្វាយបង្គំ រហូតដល់ការរៀបចំផែនការសម្រាប់កម្មវិធីថ្វាយបង្គំ ការដឹកនាំកម្មវិធីថ្វាយបង្គំ និងការវាយតម្លៃកម្មវិធីថ្វាយបង្គំ។ មិនថាអ្នកទើបតែចាប់ផ្ដើម ឬជាអ្នកមានបទពិសោធន៍យូរឆ្នាំក៏ដោយ សៀវភៅនេះនឹងក្លាយជាធនធានដ៏មានតម្លៃសម្រាប់អ្នក និងកិច្ចការបម្រើរបស់អ្នក ក្នុងរយៈពេលជាច្រើនឆ្នាំខាងមុខ។

— Scott Shepherd, អ្នកជំនាញផ្នែកថ្វាយបង្គំ និងតន្ត្រី, Tennessee Baptist Mission Board

សៀវភៅណែនាំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ គឺជាធនធានដ៏អស្ចារ្យសម្រាប់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំក្នុងពេលបច្ចុប្បន្ន ហើយក៏ជាឧបករណ៍ដ៏ពិសេសសម្រាប់បណ្ដុះបណ្ដាលអ្នកដឹកនាំកម្មវិធីថ្វាយបង្គំជំនាន់ថ្មីផងដែរ។ ខ្ញុំតែងតែកោតសរសើរការងារ និងកិច្ចការបម្រើរបស់លោកគ្រូ Kenny Lamm ប៉ុន្តែ សៀវភៅនេះពិតជាមានតម្លៃដូចមាស! វាជាការប្រមូលផ្ដុំនូវប្រាជ្ញាពីអ្នកជំនាញផ្នែកកម្មវិធីថ្វាយបង្គំល្អបំផុតជាច្រើនរូប ដោយបញ្ចូលជាមួយបទពិសោធន៍ និងការណែនាំរបស់ លោកគ្រូ Kenny បង្កើតទៅជាសៀវភៅដែលងាយអាន និងងាយចងចាំ។ ខ្ញុំមានគម្រោងប្រើសៀវភៅនេះជាមួយសិស្សរបស់ខ្ញុំ! ខ្ញុំជឿថា គ្រប់គ្រូគង្វាលផ្នែកកម្មវិធីថ្វាយបង្គំដែលកំពុងបម្រើក្នុងព្រះវិហារ មិនថាព្រះវិហារមានទំហំ ឬរចនាបថបែបណាក៏ដោយ ក៏ដូចជាអ្នកដែលកំពុងត្រៀមខ្លួនចូលបម្រើ ពួកគេនឹងទទួលបានការលើកទឹកចិត្ត និងបំពាក់ដោយប្រាជ្ញា ដែលជួយឱ្យពួកយើងទាំងអស់គ្នាជោគជ័យក្នុងការដើរតាមការត្រាស់ហៅរបស់ព្រះ។

— Larry Grayson
ប្រធាននាយកដ្ឋានសិក្សាអំពីកម្មវិធីថ្វាយបង្គំ
Ouachita Baptist University

តើសៀវភៅនេះនៅឯណា នៅពេលដែលខ្ញុំទើបតែចាប់ផ្ដើមកិច្ចការបម្រើ? និយាយដោយស្មោះត្រង់ អ្នកបម្រើផ្នែកតន្ត្រី អ្នកដឹកនាំការថ្វាយបង្គំ និងគ្រូគង្វាលគ្រប់រូប នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនពីសៀវភៅណែនាំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ។ លោកគ្រូ Kenny Lamm បានចែករំលែកដំណើរជីវិត និងចិត្តស្រឡាញ់របស់គាត់ចំពោះកិច្ចការបម្រើ ហើយផ្ដល់នូវដំបូន្មានដ៏រឹងមាំ និងអាចអនុវត្តជាក់ស្ដែង សម្រាប់អ្នកដែលកំពុងបម្រើក្នុងកម្មវិធីថ្វាយបង្គំ និងតន្ត្រី មិនថាព្រះវិហាររបស់អ្នកមានរចនាបថ ឬទំហំបែបណាក៏ដោយ។ សៀវភៅនេះសមស្របសម័យបច្ចុប្បន្ន គួរឱ្យ

ចាប់អារម្មណ៍ និងមានប្រយោជន៍គ្រប់ផ្នែក។ អ្នកគួរតែមានវានៅលើតុរបស់អ្នក មិនមែននៅលើធ្នើសៀវភៅនោះទេ។

— Dr. Randy C. Lind

ដៃគូកិច្ចការបម្រើផ្នែកការថ្វាយបង្គំ និងតន្ត្រី Oklahoma Baptists

នាយកនៃ Singing Churchmen and Singing Churchwomen of Oklahoma

កាលខ្ញុំនៅវ័យក្មេង ក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំ ខ្ញុំតែងតែអានអត្ថបទនៅលើរេបសាយរបស់លោកគ្រូ Kenny ដើម្បីទទួលបានការលើកទឹកចិត្ត និងដំបូន្មាន ដែលបានជួយឲ្យខ្ញុំមានការរីកចម្រើនយ៉ាងខ្លាំង។ ការមានធនធានដែលមានភាពលម្អិតបែបនេះ គឺជាឧបករណ៍ដ៏មានតម្លៃសម្រាប់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំគ្រប់រូប មិនថាព្រះវិហារមានទំហំ ឬរចនាបថបែបណាក៏ដោយ។

— Kevin Ferstl

នាយកផ្នែកកម្មវិធីថ្វាយបង្គំ និងទំនាក់ទំនង Church Forward

សៀវភៅនេះពិតជាឆ្លើយតបបានល្អក្រៃលែង ចំពោះតម្រូវរបស់ពួកជំនុំក្នុងពេលសព្វថ្ងៃ។ លោកគ្រូ Kenny Lamm បានចំណាយពេលពេញមួយជីវិត ក្នុងការបណ្ដុះបណ្ដាលអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ហើយឥឡូវនេះគាត់បាននិពន្ធសៀវភៅនេះឡើង ផ្អែកទៅលើអ្វីៗដែលបានជួយឲ្យគាត់ទទួលបានជោគជ័យក្នុងកិច្ចការនេះ។ ខ្ញុំជឿថា គ្រូគង្វាល អ្នកបម្រើក្នុងកម្មវិធីថ្វាយបង្គំ ឬអ្នកដឹកនាំព្រះវិហារគ្រប់រូប នឹងទទួលបានការយល់ដឹង និងដំបូន្មានដ៏មានតម្លៃសម្រាប់ការដឹកនាំពួកជំនុំក្នុងកម្មវិធីថ្វាយបង្គំ។ ការបង្រៀនរបស់គាត់មានអត្ថប្រយោជន៍យ៉ាងខ្លាំង ភាគច្រើនដោយសារលោកគ្រូ Kenny មានការចេះដឹងព្រះគម្ពីរ និងមានការអនុវត្តច្បាស់លាស់។ ខ្ញុំនឹងប្រើសៀវភៅនេះជាធនធានសម្រាប់ព្រះវិហាបាទីស្ទ Kentucky ទាំងអស់។

— Jason "Bubba" Stewart

ទីប្រឹក្សាផ្នែកកម្មវិធីថ្វាយបង្គំ និងតន្ត្រី

Kentucky Baptist Convention

ការធ្វើផែនការ ការរៀបចំខ្លួន និងការដឹកនាំកម្មវិធីថ្វាយបង្គំ ត្រូវការទាំងជំនាញ និងចិត្តដែលស្រឡាញ់ព្រះ។ សៀវភៅនេះផ្ដល់នូវការយល់ដឹងដ៏មានតម្លៃ គន្លឹះអនុវត្តជាក់ស្ដែង និងជាឧបករណ៍ដ៏មានប្រយោជន៍ ដើម្បីជួយអ្នកដឹកនាំកម្មវិធីថ្វាយបង្គំបង្កើតនូវបទពិសោធន៍នៃការថ្វាយបង្គំដែលមានន័យ និងនាំមកនូវការផ្លាស់ប្ដូរជីវិត។ មិនថាអ្នកជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំដែលមានបទពិសោធន៍ ឬទើបតែចាប់ផ្ដើមក៏ដោយ សៀវភៅនេះនឹងលើកទឹកចិត្ត និងបំពាក់សមត្ថភាពដល់អ្នកឱ្យដឹកនាំដោយឧត្តមភាព និងភាពស្មោះត្រង់។

— Rhon Carter

អ្នកជំរុញកិច្ចការថ្វាយបង្គំ និងតន្ត្រី

Georgia Baptist Mission Board

លោកគ្រូ Kenny ប្រៀបដូចជាគ្រូពេទ្យវះកាត់ដែលមានជំនាញខ្ពស់ និងមានទឹកដៃច្បាស់លាស់ បានពន្យល់យ៉ាងក្បោះក្បាយ អំពីភាពស្មុគស្មាញនៃការយល់ដឹង ពីការថ្វាយបង្គំតាមព្រះ

គម្ពីរ និងតួនាទីរបស់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំ។ រាប់ចាប់ពីរចនាបថនៃការថ្វាយបង្គំ រហូតដល់ការនាំពួកជំនុំច្រៀងបទចម្រៀងថ្មីៗ គ្មានប្រធានបទណាមួយដែលគាត់បានមើលរំលងឡើយ។ ការអានសៀវភៅនេះនឹងជួយដល់អ្នកបម្រើផ្នែកការថ្វាយបង្គំគ្រប់រូប ឱ្យរៀនសូត្រពីរបៀបនាំក្រុមជំនុំចូលរួមក្នុងការថ្វាយបង្គំ ដែលនាំទៅដល់ការផ្លាស់ប្តូរជីវិតពិតប្រាកដ។

— Matt Freeman
នាយកផ្នែកកម្មវិធីថ្វាយបង្គំ និងតន្ត្រី
South Carolina Baptist Convention

ការចូលរួមរបស់ពួកជំនុំក្នុងកម្មវិធីថ្វាយបង្គំ ស្ថិតក្នុងចំណោមរឿងសំខាន់បំផុត ក្នុងដំណើរការរបស់ពួកជំនុំ ។ វាជាការឆ្លុះបញ្ចាំងដោយផ្ទាល់ អំពីសុខុមាលភាពរបស់ព្រះវិហារ។ លោកគ្រូ Kenny Lamm គឺជាមិត្តភក្តិរបស់ខ្ញុំ ក្នុងសៀវភៅនេះ គាត់បានលើកឡើងចំៗអំពីបញ្ហាប្រឈមក្នុងការនាំពួកជំនុំចូលរួម ក្នុងកម្មវិធីថ្វាយបង្គំ។ សៀវភៅណែនាំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ គឺជាធនធានដ៏សំខាន់សម្រាប់គ្រូគង្វាលផ្នែកកម្មវិធីថ្វាយបង្គំទាំងអស់។ នៅក្នុងក្រុមតូចដែលសមាជិកសុទ្ធសឹងជានាយកផ្នែកកម្មវិធីថ្វាយបង្គំរបស់ព្រះវិហារបាទីស្ទ នៅតាមរដ្ឋផ្សេងៗ យើងហៅលោកគ្រូ Kenny ថា "ប្រធាន" របស់យើង ដោយក្តីស្រឡាញ់ ដោយហេតុផលដ៏ល្អ។ លោកគ្រូ Kenny បាននាំមកនូវធនធានដ៏អស្ចារ្យសម្រាប់គ្រូគង្វាលផ្នែកការថ្វាយបង្គំ ហើយគាត់មានគន្លឹះអនុវត្តជាច្រើន រួមទាំងគ្រឹះសំខាន់ៗសម្រាប់ការជ្រើសរើស និងការបង្រៀនបទចម្រៀងដល់ក្រុមជំនុំ ។ ខ្ញុំពិតជាសូមលើកទឹកចិត្តលោកអ្នកឲ្យអានសៀវភៅនេះ បើសិនជាលោកអ្នកគឺអ្នកដឹកនាំកម្មវិធីថ្វាយបង្គំក្នុងពេលបច្ចុប្បន្ន និងអនាគត។

— Tom Tillman
នាយកផ្នែកតន្ត្រី និងកម្មវិធីថ្វាយបង្គំ
Texas Baptists

សៀវភៅនេះមានអត្ថបទល្អយ៉ាងខ្លាំង និងមានភាពចាំបាច់ សម្រាប់កិច្ចបម្រើផ្នែកកម្មវិធីថ្វាយបង្គំ នៅសម័យបច្ចុប្បន្ន! លោកគ្រូ Kenny Lamm បាននិពន្ធសៀវភៅនេះដោយប្រាជ្ញា និងភាពច្បាស់លាស់ ហើយមិនរំលងភាពលម្អិតណាមួយឡើយ។ យើងចាំបាច់ត្រូវយល់អំពីចិត្តដែលគាត់មានសម្រាប់ពួកជំនុំរបស់ព្រះអម្ចាស់ ពោលគឺយល់អំពីទស្សនៈរបស់អ្នកដឹកនាំមានបទពិសោធន៍ ដែលទទួលបានការគោរព និងផ្តោតលើបេសកកម្ម និងមនុស្សជំនាន់ក្រោយ។

— Dr. Slater Murphy
នាយកផ្នែកកិច្ចការថ្វាយបង្គំ
Mississippi Baptist Convention

សៀវភៅនេះត្រូវបាននិពន្ធឡើង ដោយការពិចារណាយ៉ាងល្អិតល្អន់ មានការសង្ខេបឲ្យខ្លី អាចអនុវត្តជាក់ស្តែងបាន និងងាយស្រួលអាន!

— Karen Gosselin
អ្នកសម្របសម្រួល និងអ្នកផ្សព្វផ្សាយរដ្ឋ
ផ្នែកធនធានកម្មវិធីថ្វាយបង្គំ
Alabama State Board of Missions

# សៀវភៅណែនាំ
# សម្រាប់ការ
# ដឹកនាំកម្មវិធី
# ថ្វាយបង្គំ

ដឹកនាំពួកជំនុំរបស់អ្នក ក្នុងការថ្វាយ
បង្គំដែលធ្វើឲ្យជីវិតផ្លាស់ប្រែ

**KENNY LAMM**

WorshipLink PUBLISHING

សៀវភៅណែនាំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ
The Worship Ministry Guidebook
រក្សាសិទ្ធិ © ២០២៣, ២០២៦ by Kenny Lamm
English version originally published by Kenny Lamm
WorshipMinistryGuidebook.com
Khmer version copyright ©2026 by WorshipLink Publishing
This Edition in Khmer copyright ©2026 by ACTION Cambodia
រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ ចតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ ឬចែកចាយបន្តរួមបញ្ចូលទាំងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក បច្ចេកទេសចតចម្លង ការចតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើមដែលនៅប្រទេសអាមេរិកឡើយ។
ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
និពន្ធដោយ៖ លោក Kenny Lamm
បកប្រែដោយ៖ លោក លី ប៊ុនថា
ជំនួយការបកប្រែ៖ លោក ឯក សត្យា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ហុង សម្ភស, លោក ទេព រ៉ូ, លោក អន លីម៉ា, លោក ខែម បូឡុង, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរ័ត្ន, លោក ឈាង បូរ៉ា, លោកJosiah Baker និងលោកស្រី ពុន ចន្ថា
អ្នករចនាជាភាសាអង់គ្លេស៖ លោក Carlee Hoopes, www.carleealexandria.com
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វណ្ណដ្ឋា សុតរ៉ាប៊ី
យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។
បោះពុម្ពលើកទីមួយចំនួន ១០០០ក្បាល

# មាតិកា


សេចក្ដីផ្ដើម ១១

មុនពេលអ្នកមុជចូលជ្រៅ ១៦

**I.ការយល់ដឹងអំពីការថ្វាយបង្គំ** ១៩

អ្វីទៅជាការថ្វាយបង្គំ? ១៩

ការថ្វាយបង្គំរបស់យើងត្រូវតែថ្វាយចំពោះព្រះត្រៃឯកតែយកព្រះគ្រីស្ទជាគោល ២៧

ការថ្វាយបង្គំផ្ទាល់ខ្លួន និង ការថ្វាយបង្គំរួមគ្នា ៣០

បរិបទ៤នៃការថ្វាយបង្គំ ៣៤

អ្នកទស្សនាការថ្វាយបង្គំ ឬអ្នកចូលរួមការថ្វាយបង្គំ? ៤២

ព្រះជាទស្សនិកជន-ជាទស្សនិកជនតែមួយអង្គគត់ ៤៣

របៀបលើកទឹកចិត្តការសម្ដែងខាងរូបកាយ និងសេរីភាពក្នុងការថ្វាយបង្គំ ៤៦

រចនាបថនៃការថ្វាយបង្គំ ៤៩

ផ្ដត់គំនិតបេសកកម្ម ៥៣

ខ្លឹមសារ និងការបង្ហាញនៃការថ្វាយបង្គំ ៥៦

ភាពមិនចាំបាច់ និងភាពចាំបាច់នៃការថ្វាយបង្គំ ៥៧

ការថ្វាយបង្គំដែលបង្រួបបង្រួម ៦០

ការដឹកនាំការផ្លាស់ប្ដូរប្រកបដោយសុខភាពល្អ ៦៨

**II. ការយល់ដឹងអំពីភាពជាអ្នកដឹកនាំការថ្វាយបង្គំ** ៨១

ការត្រាស់ហៅឲ្យដឹកនាំការថ្វាយបង្គំ ៨១

និយមន័យនៃការដឹកនាំការថ្វាយបង្គំ ៩៦

វិន័យខ្លះៗសម្រាប់អ្នកដឹកនាំការថ្វាយបង្គំ ៩៨

ចូរបង្កើតបរិយាកាសនៃក្ដីស្រឡាញ់តតលក្ខខណ្ឌសម្រាប់ក្រុមថ្វាយបង្គំរបស់អ្នក ១០៣

ការថ្វាយបង្គំរួមគ្នា និងការបង្កើតសិស្ស ១០៦

កសាងព័ន្ធកិច្ចថ្វាយបង្គំដែលបង្កើតសិស្ស ១០៨
ការផ្តល់ឱវាទដល់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ១១០
ការបង្កើតផ្នត់គំនិតផ្នែកបេសកកម្មក្នុងព័ន្ធកិច្ចថ្វាយបង្គំរបស់អ្នក ១១១
អភិវឌ្ឍន៍ឲ្យមានកំរិតខ្ពស់នៃភាពល្អប្រសើរក្នុងក្រុមថ្វាយបង្គំរបស់អ្នក ១១៤
អ្នកស្ម័គ្រចិត្ត ឬមនុស្សដែលព្រះបានត្រាស់ហៅ? ១១៥
ការបណ្តុះវប្បធម៌ដែលនាំឲ្យមានការហាត់សមកាន់តែប្រសើរ ១១៦

**III. ការរៀបចំផែនការនៃការថ្វាយបង្គំ** ១២៩
ទម្រង់នៃការថ្វាយបង្គំ ១២៩
បទចម្រៀងថ្វាយបង្គំ ១៣៦
ចម្រៀងសម័យទំនើបសម្រាប់ការថ្វាយបង្គំអន្តរជំនាន់ ១៤៤
បទចម្រៀងថ្មី៖ លើកស្ទួយការថ្វាយបង្គំ ឬក៏សម្លាប់ការថ្វាយបង្គំ ១៤៦
តើយើងគួរច្រៀងចម្រៀងថ្មីប៉ុន្មានបទ? ១៤៦
ការណែនាំបទចម្រៀងថ្មី ១៤៧
ការភ្ជាប់បទចម្រៀងថ្វាយបង្គំ៖ ការពិចារណាលើអត្ថបទ ១៦៣
ធាតុមិនមែនជាតន្ត្រីនៃការថ្វាយបង្គំ ១៦៤
តួនាទីនៃបទបង្ហាញ/តន្ត្រីតំណាង ១៦៤
ក្រុមរៀបចំផែនការថ្វាយបង្គំ ១៦៦
ការរក្សាគុណភាពខាងវិញ្ញាណ និងសេចក្តីពិត ១៦៨
ការរៀបចំផែនការកម្មវិធីថ្វាយបង្គំ ១៧២

**IV. ការរៀបចំខ្លួនសម្រាប់ការថ្វាយបង្គំ** ១៨១
ការរៀបចំក្រុមចម្រៀង ១៨២
ការរៀបចំក្រុមភ្លេង និងក្រុមច្រៀង ១៩១
ការរៀបចំប្រព័ន្ធផ្សព្វផ្សាយ ១៩៥
ការរៀបចំក្រុមជំនុំសម្រាប់កម្មវិធីថ្វាយបង្គំ ២០១
ការរៀបចំផ្ទាល់ខ្លួនសម្រាប់ការថ្វាយបង្គំ ២០៥

**V. ការដឹកនាំការថ្វាយបង្គំ** ២១១
ហេតុផលប្រាំបួនយ៉ាងដែលពួកជំនុំមិនច្រៀងក្នុងការថ្វាយបង្គំ និងអ្វីដែលយើងត្រូវធ្វើ ២១២

ការនិយាយនៅចន្លោះបទចម្រៀង និងធាតុផ្សំផ្សេងទៀតនៃការថ្វាយបង្គំ ២១៨
វត្តមាននៅលើវេទិកា ២២៧
ការដកឧបសគ្គដែលរារាំងការតភ្ជាប់ជាមួយក្រុមជំនុំ ២៣០
ការរៀបផែនការកម្មវិធីថ្វាយបង្គំសម្រាប់មនុស្សមកពីព្រះវិហារផ្សេងគ្នា
និងមានរចនាបថថ្វាយបង្គំផ្សេងៗគ្នា ២៣២

**VI. ការវាយតម្លៃកម្មវិធីថ្វាយបង្គំ** ២៣៧
បញ្ជីវាយតម្លៃការថ្វាយបង្គំ ២៣៩

អវសានកថា ២៥៥

ការថ្លែងអំណរគុណ ២៦១

កំណត់យោង ២៦៧

# សេចក្ដីផ្ដើម

តើអ្នកមានការខកចិត្តដោយសារភាពខ្វះការចូលរួមក្នុងការថ្វាយបង្គំនៃក្រុមជំនុំរបស់អ្នកមែនទេ? តើអ្នកមានអារម្មណ៍ថា មនុស្សកំពុងតែមានកាយវិការដោយមិនមានទំនាក់ទំនងជាមួយព្រះក្នុងការថ្វាយបង្គំមែនទេ? មិនមែនមានតែអ្នកម្នាក់ឯងទេ៖ ក្រុមជំនុំនៅជុំវិញពិភពលោកកំពុងឆ្លងកាត់នូវអារម្មណ៍ជាអ្នកទស្សនាការថ្វាយបង្គំផងដែរ។ តើយើងដែលជាអ្នកដឹកនាំការថ្វាយបង្គំអាចធ្វើអ្វីខ្លះ ដើម្បីប្រឆាំងនឹងនិន្នាការទាំងនេះ? តើយើងអាចដឹកនាំក្រុមជំនុំរបស់យើងទៅកាន់ការថ្វាយបង្គំដ៏ក្លៀវក្លា អស់ពីចិត្ត និងមានការចូលរួមដោយរបៀបណា?

នៅក្នុងសៀវភៅនេះ ខ្ញុំសង្ឃឹមថានឹងជួយនាំអ្នកទៅកាន់ការឆ្លើយតបទៅនឹងសំណួរទាំងនេះ ហើយនិងសេចក្ដីជាច្រើនផ្សេងទៀត។ តើយើងពិតជាចូលរួមក្នុងក្រុមជំនុំរបស់យើងក្នុងការថ្វាយបង្គំដើម្បីទទួលអំណាចនៃការផ្លាស់ប្រែ—ការថ្វាយបង្គំដែលបង្កើតសិស្សយ៉ាងដូចម្ដេច?

តើអ្នកសង្កេតឃើញថា ចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់ខ្លួនឯង កំពុងជៀតជ្រែកក្នុងការរួបរួមនៃរូបកាយនៅពេលថ្វាយបង្គំឬទេ? ព្រះសព្វព្រះទ័យឲ្យមានការឯកភាពក្នុងការថ្វាយបង្គំ ប៉ុន្តែក្រុមជំនុំជាច្រើនមានជម្លោះពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ ជុំវិញទម្រង់នៃការថ្វាយបង្គំ។

ខ្ញុំមានឱកាសដ៏អស្ចារ្យដែលបានធ្វើការជាមួយក្រុមជំនុំនៅសហរដ្ឋអាមេរិក និងអន្តរជាតិអស់រយៈពេលជាង២០ឆ្នាំមកហើយ។ មុនពេលខ្ញុំចាប់ផ្ដើមធ្វើដំណើរយ៉ាងទូលំទូលាយជាមួយក្រុមជំនុំទូទាំងពិភពលោក ខ្ញុំបានសន្មតថាបញ្ហានៃការថ្វាយបង្គំរបស់ក្រុមជំនុំអាមេរិកប្រហែលមិនមែនជាបញ្ហាសកលទេ។ ប្រាកដណាស់ ក្រុមជំនុំនៅប្រទេសចិន ម៉ាឡេស៊ី គុយបា កម្ពុជា សិង្ហបុរី អាហ្សង់ទីន ប្រ៊ុយណេ ប្រទេសផ្សេងទៀតនឹងមិនជួបប្រទះនូវជម្លោះក្នុងការថ្វាយបង្គំ ឬភាព

ខុសគ្នារវាងអន្តរជំនាន់នោះទេ។ ប្រាកដណាស់ នឹងមិនមានជម្លោះលើឧបករណ៍ដែលប្រើក្នុងការថ្វាយបង្គំឡើយ។ ពិតណាស់ វានឹងមិនមានទិន្នាការឆ្ពោះទៅរកការបង្កើតឲ្យមានអ្នកទស្សនានៅក្នុងព្រះវិហារនោះទេ។

នៅពេលដែលខ្ញុំបានជួបជាមួយបងប្អូនប្រុសស្រីនៅជុំវិញសហរដ្ឋអាមេរិក និងអន្តរជាតិ ខ្ញុំបានរកឃើញថា យើងមានភាពដូចគ្នាគួរឲ្យកត់សម្គាល់នៅក្នុងបញ្ហានៃការថ្វាយបង្គំរបស់យើង។ ចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរីករាលដាល បង្កជាការលំបាកអំពីរបៀបដែលក្រុមជំនុំអនុវត្តការថ្វាយបង្គំក្នុងក្រុមជំនុំរបស់ពួកគេ។

ខ្ញុំឃើញក្រុមជំនុំដែលមិនបានផ្លាស់ប្ដូរក្នុងរយៈពេលជាច្រើនទសវត្សរ៍មកហើយ។ មានជាច្រើនពួកជំនុំក្នុងចំណោមនោះកំពុងស្លាប់បណ្ដើរៗដោយសារតែអ្វីដែលធ្លាប់មានន័យដែលភ្ជាប់បេះដូងនៃការថ្វាយបង្គំ តែឥឡូវនេះបានត្រឡប់ទៅជាពិធីសាសនាដែលគ្មានជីវិត។

នៅក្នុងក្រុមជំនុំទំនើបជាច្រើនខ្ញុំបានឃើញការបង្កាត់ពូជនៃវប្បធម៌អ្នកទស្សនាដោយផ្ដល់នូវព្រឹត្តិការណ៍ដែលផ្អែកលើការសម្ដែងជាជាងការថ្វាយបង្គំពិត។ ជារឿយៗមនុស្សឈរមើលអ្វីដែលកំពុងកើតឡើង នៅលើឆាកដោយមិនមានការចូលរួមយ៉ាងសកម្មក្នុងការថ្វាយបង្គំឡើយ។

ក្រុមជំនុំខ្លះចូលរួមក្នុងអ្វីដែលបានក្លាយទៅជាទម្រង់លេងស្រាប់នៃការថ្វាយបង្គំ។ ពួកគេជ្រើសរើសបទចម្រៀងពេញនិយមចំនួនបីបទហើយដាក់បញ្ចូលគ្នានូវការរៀបចំដ៏អស្ចារ្យរបស់ពួកគេ។ នៅក្នុងកម្មវិធីនោះពួកគេស្វាគមន៍មនុស្ស «បើកកម្មវិធី» (Audio) ចាក់ភ្លេងតាមទម្រង់លេងស្រាប់ដើម្បីដំណើរការបទចម្រៀងទាំងបីបទនោះហើយបន្ទាប់មកប្រគល់កម្មវិធីទៅកាន់គ្រូគង្វាលសម្រាប់ធ្វើការអធិប្បាយ។ ញឹកញាប់ណាស់ ដែលមានការបាត់បង់ខ្លឹមសារជាច្រើន—ដោយមិនមានបំណងក្នុងការបង្កើតសិស្ស គ្មានទិសដៅ គ្មានលំហូរ ហើយកម្មវិធីទាំងនេះក្លាយជាសាមញ្ញពេក ដដែលៗពេក និងគ្រាន់តែជាយន្តការសុទ្ធសាធ។

នៅក្នុងក្រុមជំនុំជាច្រើនដែលស្វែងរកការបង្រួបបង្រួមគ្រប់ជំនាន់ ខ្ញុំឃើញមានជម្លោះលើអ្វីដែលមិនសំខាន់ក្នុងការថ្វាយបង្គំ (ដូចជា វេទិកា ឬសំលៀកបំពាក់) និងការឈ្លោះប្រកែកគ្នាអំពីប្រភេទ (Style) តន្ត្រី។

ខ្ញុំជឿថាបេសកកម្មដ៏ធំមួយសម្រាប់អ្នកដឹកនាំការថ្វាយបង្គំជុំវិញពិភពលោកគឺជួយក្រុមជំនុំឲ្យដើរលើផ្លូវត្រូវជាមួយនឹងការថ្វាយបង្គំព្រះអម្ចាស់ ដោយរៀបចំបរិយាកាសដែលជួយមនុស្សឲ្យទទួលបានជួបនឹងអំណាចនៃការផ្លាស់ប្ដូររបស់ព្រះ—បរិយាកាសដែលផ្លាស់ប្ដូរអ្នកទស្សនាការថ្វាយបង្គំទៅជាអ្នកចូលរួមថ្វាយបង្គំ។

សៀវភៅដែលអ្នកកាន់នៅក្នុងដៃរបស់អ្នក នឹងជួយស្វែងរកដោះស្រាយអំពីបញ្ហានៃក្រុមថ្វាយបង្គំនេះនាពេលខាងមុខ។

ការថ្វាយបង្គំ និងបេសកកម្ម គឺជាអាទិភាពនៃក្រុមជំនុំ! ការទាំងពីរនេះគឺជារឿងសំខាន់បំផុតដែលយើងត្រូវធ្វើ។ ចំណង់ចំណូលចិត្តដ៏ធំបំផុតពីររបស់ខ្ញុំក្នុងការបម្រើ គឺការថ្វាយបង្គំ និងបេសកកម្ម។ ខ្ញុំមានឯកសិទ្ធិបម្រើជាគ្រូគង្វាលបេសកកម្ម និងការថ្វាយបង្គំអស់រយៈពេលជាច្រើនឆ្នាំជាការរួមបញ្ចូលគ្នាដ៏អស្ចារ្យដោយសារវិស័យទាំងពីរនេះធ្វើការជាមួយគ្នា។ លោកគ្រូ ចន ផាបភ័រ (John Piper) ចង្អុលបង្ហាញថា «ការថ្វាយបង្គំគឺជាគោលដៅ និងជាប្រេងតាំងនៃបេសកកម្ម»

ហេតុដែលមានបេសកកម្ម ព្រោះមិនមានការថ្វាយបង្គំ។ បេសកកម្មគឺជារបៀបនៃការនិយាយរបស់យើង៖ សេចក្ដីអំណរនៃការស្គាល់ព្រះគ្រីស្ទមិនមែនជាកម្មសិទ្ធិឯកជន ឬកុលសម្ព័ន្ធ ឬឯកសិទ្ធិរបស់ប្រទេសជាតិ ឬជាតិសាសន៍ណានោះទេ។ ការថ្វាយបង្គំគឺសម្រាប់ទាំងអស់គ្នា។ នោះហើយជាមូលហេតុដែលយើងចេញទៅ។ ដោយសារយើងបានភ្លក់នូវសេចក្ដីអំណរនៃការថ្វាយបង្គំព្រះយេស៊ូវ ហើយយើងចង់ឲ្យក្រុមគ្រួសារទាំងអស់នៅលើផែនដីត្រូវរួមបញ្ចូលក្នុងការថ្វាយបង្គំដែរ។

> *គ្រប់ទាំងទីបំផុតនៃផែនដី នឹងនឹកដល់ព្រះយេហូវ៉ា ហើយត្រឡប់បែរមកឯទ្រង់ អស់ទាំងពូជពង្សនៃនគរទាំងឡាយ នឹងថ្វាយបង្គំនៅចំពោះទ្រង់។ (ទំនុកដំកើង ២២:២៧)*
>
> *ការស្វែងរកការថ្វាយបង្គំនៃប្រជាជាតិនានាត្រូវបានជំរុញដោយអំណរនៃការថ្វាយបង្គំរបស់យើង។ អ្នកមិនអាចសរសើរអ្វីដែលអ្នកមិនពេញចិត្តទេ។ អ្នកមិនអាចសរសើរអ្វីដែលអ្នកមិនចូលចិត្តនោះទេ។ ការថ្វាយបង្គំគឺជាឥន្ធនៈ និងជាគោលដៅនៃបេសកកម្ម។*

ព្រះបានបង្កើតយើងសម្រាប់អាទិភាពធំបំផុត គឺការថ្វាយបង្គំទ្រង់។ សៀវភៅសំណួរចម្លើយអំពីគោលជំនឿ ( Westminster Shorter Catechism ) ចែងថា «គោលបំណងចម្បងរបស់មនុស្សជាតិ គឺដើម្បីលើកតម្កើងព្រះជាម្ចាស់ ហើយស្វែងរកអំណរសប្បាយនៅក្នុងព្រះវត្តមានទ្រង់ជារៀងរហូត»។ ខ្ញុំជឿថាការថ្វាយបង្គំដ៏មានសារៈសំខាន់គឺជាអ្វីដែលជំរុញអ្វីៗផ្សេងទៀតដែលក្រុមជំនុំធ្វើ។ លុះត្រាតែយើងធ្វើឲ្យការថ្វាយបង្គំនៅចំកន្លែងដែលមានសុខភាពល្អ ពុំនោះទេយើង

គ្រាន់តែជាសំឡេងឈឺង និងស្គរដែលឥតន័យប៉ុណ្ណោះ។ នៅពេលដែលយើងធ្វើឲ្យការថ្វាយបង្គំរបស់យើងមានភាពត្រឹមត្រូវទើបមុខងារផ្សេងទៀតនៃក្រុមជំនុំគួរតែចាប់ផ្តើមចូលតាមលំដាប់លំដោយ។

*ជារឿងគួរឲ្យសោកស្តាយ នៅក្នុងក្រុមជំនុំរបស់យើងជាច្រើនអ្វីដែលព្រះបានរៀបចំឡើងសម្រាប់សិរីល្អរបស់ទ្រង់ហើយសម្រាប់ការរីកចម្រើនរួមគ្នាផ្នែកព្រលឹងវិញ្ញាណ និងផ្ទាល់ខ្លួនរបស់យើង—ការថ្វាយបង្គំ—ត្រូវបានបំប្លែងពីការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅទៅជាការប្រយុទ្ធខាងសាច់ឈាមដ៏អាក្រក់ទៅវិញ។*[១]

ការធ្វើដំណើរដែលយើងនឹងចូលរួមជាមួយគ្នាតាមរយៈសៀវភៅនេះ ខ្ញុំជឿថានឹងជួយអ្នកក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំដើម្បីផ្លាស់ប្តូរការថ្វាយបង្គំនៅក្នុងព្រះវិហាររបស់អ្នក—ផ្លាស់ប្តូរការថ្វាយបង្គំពីទិសដៅអ្នកទស្សនាទៅកន្លែងមួយដែលមនុស្សចូលរួមដោយអស់ពីចិត្ត ក្នុងការថ្វាយបង្គំដែលបំផ្លាស់បំប្រែពួកសិស្ស។

មានបំណែកធាតុផ្សំជាច្រើនដែលត្រូវដាក់បញ្ចូលគ្នា ដោយចាប់ផ្តើមពីមូលដ្ឋានគ្រឹះនៃការថ្វាយបង្គំ និងការដឹកនាំការថ្វាយបង្គំ។ នៅពេលដែលគ្រឹះទាំងនោះត្រូវបានបង្កើតឡើង យើងនឹងសាងសង់លើសេចក្តីទាំងនោះនូវការយល់ដឹងអំពីអ្វីទាំងអស់ដែលចូលទៅក្នុងការរៀបកម្មវិធីថ្វាយបង្គំ ដែលពិតជាជួយមនុស្សឲ្យចូលរួមបង្កើតសិស្ស ហើយនាំមកនូវសិរីរុងរឿងថ្វាយដល់ព្រះ។ បន្ទាប់មក យើងនឹងសិក្សាយ៉ាងស៊ីជម្រៅទៅលើរបៀបដែលយើងអនុវត្តផែនការថ្វាយបង្គំដោយការដឹកនាំការថ្វាយបង្គំ និងការរៀបចំយ៉ាងហ្មត់ចត់ ។ យើងមិនអាចធ្វើឲ្យប្រសើរឡើងបានទេ ប្រសិនបើមិនមានផែនការក្នុងការវាយតម្លៃការថ្វាយបង្គំ ដូច្នេះយើងនឹងពិភាក្សាអំពីជំហានទីមួយៗដែលយើងត្រូវធ្វើ ដើម្បីបន្តរីកចម្រើនក្នុងភាពជាអ្នកដឹកនាំរបស់យើង ដោយប្រើឧបករណ៍វាយតម្លៃដ៏សំខាន់មួយចំនួន។

សៀវភៅដែលអ្នកកំពុងកាន់នៅក្នុងដៃគឺជាលទ្ធផលនៃការកែប្រែកាលពីជាង ២០ឆ្នាំមុននៃការកែសម្រួលកម្មវិធីសិក្សាសកលសម្រាប់អ្នកដឹកនាំការថ្វាយបង្គំ ដើម្បីជួយពួកគេបំពេញការត្រាស់ហៅរបស់ព្រះ ដែលបានដាក់ក្នុងជីវិតរបស់ពួកគេ។ ទំព័រជាច្រើននៃសៀវភៅនេះអ្នកនឹងឃើញមានសំណួរឆ្លុះបញ្ចាំងជាច្រើនទាក់ទងនឹងសៀវភៅដែលអ្នកទើបតែបានអាន។ វាពិតជាសំខាន់ណាស់ក្នុងការបង្អង់សិនហើយឆ្លើយនឹងសំណួរទាំងនោះ។អ្នកអាចនឹងត្រូវបានល្បួងឲ្យរំលងវាដើម្បីបន្ត

១ លោក Chuck Swindoll, The Church Awakening: An Urgent Call for Renewal (United States: FaithWords, ឆ្នាំ២០១០), Kindle.

ការអាន ប៉ុន្ដែការនេះអាចធ្វើឲ្យអ្នកខកខាននូវអ្វីដែលព្រះចង់បើកបង្ហាញទៅកាន់អ្នក។ សំណួរទាំងនេះនឹងជួយតភ្ជាប់ជីវិតផ្ទាល់ខ្លួនរបស់អ្នកទៅនឹងការបម្រើព័ន្ធកិច្ចរបស់អ្នក។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា បញ្ហាជាច្រើននៃការថ្វាយបង្គំរបស់ក្រុមជំនុំនាពេលបច្ចុប្បន្ននេះ អាចជាកំហុសដោយអចេតនារបស់អ្នកដឹកនាំការថ្វាយបង្គំដែលទោះជាមានបំណងល្អ ប៉ុន្តែមិនបានដឹងថាការអនុវត្តរបស់ពួកគេកំពុងធ្វើឲ្យប៉ះពាល់ដល់ការថ្វាយបង្គំ។ ទំព័រទាំងនេះនឹងជួយកំណត់បញ្ហាទាំងនោះ ហើយណែនាំពីដំណោះស្រាយ។

សព្វថ្ងៃនេះ មនុស្សមួយចំនួនគ្រាន់តែទៅព្រះវិហារតាមទម្លាប់ ដោយមិនបានថ្វាយបង្គំព្រះពិតប្រាកដ។ ដូច្នេះ តើអ្វីជាភាពខុសគ្នារវាងការដែលគ្រាន់តែទៅព្រះវិហារ និងការមកថ្វាយបង្គំព្រះរបស់យើង? នៅក្នុងសៀវភៅមានចំណងជើងថា អ្នករៀបចំការថ្វាយបង្គំ (The Worship Architect) អ្នកនាង ខន់ស្ដាន ឆឺរី (Constance Cherry) សរសេរថា:

> *ការថ្វាយបង្គំគឺអំពីការជួបជាមួយព្រះដ៏មានព្រះជន្មរស់។ ការជួបជាមួយព្រះជាម្ចាស់ គឺជាការចូលរួមក្នុងការសន្ទនាជាមួយព្រះ។ វាពិតជាខុសគ្នាពី «ការទៅព្រះវិហារ»។ គ្រាន់តែទៅព្រះវិហារបង្ហាញនូវការថ្វាយបង្គំអសកម្ម។ ផ្ទុយទៅវិញ ការមកថ្វាយបង្គំបង្ហាញថាមានការចូលរួមយ៉ាងសកម្មជាមួយនឹងព្រះដែលរង់ចាំវត្តមានរបស់អ្នក។ អ្នកនិពន្ធ អានី ឌីលឡាត (*Annie Dillard*) និង ចេមស៍ ម៉ាហ្គាវ (*James Magaw*) ប្រើប្រាស់ពាក្យបានយ៉ាងល្អ៖* [២]
>
> - *ដើម្បីមានអារម្មណ៍ល្អ*
> - *ដើម្បីចំណាយពេលជាមួយមនុស្សដែលខ្ញុំពេញចិត្ត*
> - *ដើម្បីរៀនអំពីព្រះយេស៊ូវ*
> - *ដើម្បីបង្ហាញថាខ្ញុំនៅខាងណា*
> - *ដើម្បីកុំឲ្យគេសួរថាហេតុអ្វីខ្ញុំខកខានមិនបានមក*
> - *ដើម្បីច្រៀងចម្រៀងទំនុកតម្កើងបុរាណដែលខ្ញុំចូលចិត្ត*
>
> *ប៉ុន្តែ ប្រសិនបើអ្នកសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំថ្វាយបង្គំ សំណួរនោះនឹង*

---

២ លោក Constance M. Cherry, The Worship Architect: A Blueprint for Designing Culturally Relevant and Biblically Faithful Services (Grand Rapids: Baker, ឆ្នាំ២០១០), ទំព័រ ២៧០។

*នាំឲ្យមានការពិភាក្សាកាន់តែស៊ីជម្រៅថែមទៀត។ វារំឭកខ្ញុំឲ្យចងចាំពាក្យរបស់ អានី ឌីឡាដ (Annie Dillard) នៅពេលដែលនាងសរសេរអំពីការថ្វាយបង្គំថា «តើមាននរណាម្នាក់យល់អំពីអំណាចបន្តិចបន្តួចដែលយើងស្វែងរកដោយឥតលាក់លៀម? នៅព្រះវិហារគឺដូចជាកន្លែងមួយដែលក្រុមក្មេងៗកំពុងតែលេងជាមួយកាំភ្លើង និងសារធាតុផ្ទុះ (TNT) ដើម្បីបង្ហាញនៅព្រឹកថ្ងៃអាទិត្យ ដោយមិនដឹងថាវាអាចសម្លាប់ពួកគេបាន។ នោះជារឿងលីលាខ្លាំងណាស់ដែលពួកគេចំណាយពេលមើលតែសំបកក្រៅ តែគួរតែមានប្រាជ្ញាជាងបើពួកគេបំពាក់ឈុតគ្រឿងសឹកដល់ពួកជំនុំវិញ ដើម្បីកុំឲ្យព្រះអម្ចាស់មិនសព្វព្រះហឫទ័យ ហើយវាយផ្ចាលយើង»។[៣]*

មិនត្រូវមើលស្រាលអំណាចនៃការថ្វាយបង្គំ ក្នុងការបំផ្លាស់បំប្រែជីវិត។ កុំដាក់ការថ្វាយបង្គំក្នុងប្រអប់មួយ ហើយព្យាយាមគ្រប់គ្រងវា—ត្រូវបត់បែន និងសម្របខ្លួនទៅតាមរបៀបដែលព្រះធ្វើការក្នុងកម្មវិធីថ្វាយបង្គំរបស់ក្រុមជំនុំអ្នក។ លោក ចេមស៍ ម៉ាហ្គោរ (James Magaw) និយាយបែបនេះថា

*នៅពេលខ្ញុំថ្វាយបង្គំ ខ្ញុំលាតត្រដាងខ្លួនឯងទៅនឹងអំណាចនៃព្រះដោយគ្មានការគ្រប់គ្រងផ្ទាល់ខ្លួនចំពោះលទ្ធផលនោះទេ។ ពេលខ្លះវានាំមកនូវការព្យាបាល សេចក្ដីសុខសាន្ត ការអត់ទោស ការប្រឈមមុខដាក់គ្នា ឬក្ដីសង្ឃឹម។ វាតែងតែហៅខ្ញុំឲ្យផ្លាស់ទីហួសពីកន្លែងឆ្ងាយបំផុតដែលខ្ញុំអាចទៅដល់ ហើយរុញច្រានខ្ញុំចូលទៅក្នុងទឹកដីដែលមិនទាន់បានកំណត់។ ការទៅព្រះវិហារជាផ្នែកមួយដែលងាយសម្រាប់ខ្ញុំព្រោះក្លាយជាទម្លាប់ទៅហើយប៉ុន្តែពេលខ្លះការចូលរួមថ្វាយបង្គំគឺជារឿងដែលពិបាក។ វាជារឿងដ៏អស្ចារ្យមួយដែលដឹងថា ខ្លួនបានធ្លាក់ទៅក្នុងកណ្ដាប់ព្រះហស្តនៃព្រះដ៏មានព្រះជន្មរស់នៅ។[៤]*

## មុនពេលអ្នកមុជចូលជ្រៅ

ចំណាយពេលអធិស្ឋានមុនពេលអ្នកអានផ្នែកនីមួយៗនៃសៀវភៅនេះ។ ចូរទូលសូមឲ្យព្រះបើកសម្ដែងដល់អ្នកនូវរបៀបដែលទ្រង់នឹងឲ្យអ្នកផ្លាស់ប្ដូរ ឬរបៀប

---

៣ លោក Constance M. Cherry, The Worship Architect: A Blueprint for Designing Culturally Relevant and Biblically Faithful Services (Grand Rapids: Baker, ឆ្នាំ២០១០), ទំព័រ ២៧០។

៤ លោក James Magaw, "The Power We Invoke," Alive Now (May-June ឆ្នាំ១៩៨៨) ទំព័រ៦០-៦១។ ការយល់ដឹងអំពីការថ្វាយបង្គំ

ដែលអ្នកត្រូវការរៀបចំការថ្វាយបង្គំនៃក្រុមជំនុំរបស់អ្នក។ គូសចំណាំក្នុងសៀវភៅនេះ។ ចូរកត់ចំណាំនូវអ្វីគ្រប់យ៉ាងដែលព្រះដាក់ក្នុងចិត្តគំនិតរបស់អ្នកដែលត្រូវការការដោះស្រាយ។ រាល់ពេលដែលខ្ញុំបង្រៀនសៀវភៅនេះព្រះជាម្ចាស់បង្ហាញខ្ញុំនូវកន្លែងដែលខ្ញុំបានបរាជ័យ ឬជ្រើសរើសយកផ្លូវកាត់ជាជាងការខិតខំបង្កើតកម្មវិធីថ្វាយបង្គំដ៏ល្អបំផុតដើម្បីជួយឲ្យក្រុមជំនុំចូលរួម។ យើងទាំងអស់គ្នាកំពុងរីកចម្រើន និងកែលម្អជាបន្តបន្ទាប់។

ខ្ញុំបានអធិស្ឋាន ហើយបន្តអធិស្ឋានថា ព្រះនឹងមានឥទ្ធិពលដល់អស់អ្នកណាដែលជួបនឹងសៀវភៅនេះ។ កុំប្រញាប់អានឲ្យឆាប់ចប់សៀវភៅនេះឡើយ។ សញ្ជឹងគិតផ្នែកនីមួយៗឲ្យបានពេញលេញ ហើយកំណត់ពីរបៀបដែលសៀវភៅនោះអាចជួយអ្នកធ្វើជាអ្នកដឹកនាំការថ្វាយបង្គំ ដែលព្រះបានត្រាស់ហៅអ្នកឲ្យធ្វើ។

ខ្ញុំឲ្យតម្លៃយ៉ាងជ្រាលជ្រៅនូវពេលវេលាដែលខ្ញុំអាចចំណាយជាមួយក្រុមជំនុំកម្ពុជានៅឆ្នាំ២០២២ ហើយទន្ទឹងរង់ចាំឱកាសនាពេលអនាគតដើម្បីមកជួយគាំទ្រអ្នក ហើយនិងបេសកកម្មរបស់អ្នកក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រជាជាតិមួយដែលស្រឡាញ់ ហើយគោរពថ្វាយបង្គំព្រះ។

ខ្ញុំអរព្រះគុណដល់ព្រះសម្រាប់អ្នក!

# I.ការយល់ដឹងអំពីការថ្វាយបង្គំ

ដើម្បីក្លាយជាអ្នកដឹកនាំការថ្វាយបង្គំប្រកបដោយប្រសិទ្ធភាព ជាដំបូងយើងត្រូវកំណត់មូលដ្ឋានគ្រឹះដែលយើងនឹងកសាងជំនាញជាក់ស្តែងទាំងអស់របស់យើងក្នុងការរៀបចំផែនការ និងការដឹកនាំថ្វាយបង្គំ។ យើងត្រូវតែយល់ឲ្យបានហ្មត់ចត់នូវមូលដ្ឋាននៃការថ្វាយបង្គំទាំងនេះ និងគោលការណ៍នៃការដឹកនាំថ្វាយបង្គំមុនពេលយើងអាចរៀបចំផែនការ ហើយដឹកនាំការថ្វាយបង្គំដើម្បីជំរុញនិងបំផ្លាស់បំប្រែក្រុមជំនុំឲ្យមានប្រសិទ្ធភាព នៅខណៈពេលជាមួយគ្នានេះបង្រៀនពួកគេឲ្យកាន់តែដូចព្រះគ្រីស្ទ។

## អ្វីទៅជាការថ្វាយបង្គំ?

តាមវចនានុក្រម មើររៀម វេបស្ទ័រ (Merriam-Webster) និយមន័យការថ្វាយបង្គំសាមញ្ញបំផុតគឺ «ផ្តល់ការគោរព កិត្តិយស ឬការបូជាចំពោះ ឬការលះបង់ដ៏អស្ចារ្យ»។1

យើងត្រូវតែដឹងថា មនុស្សគ្រប់គ្នាគឺជាអ្នកចូលរួមថ្វាយបង្គំ។ យើងទាំងអស់គ្នាផ្តោតលើការគោរព ផ្តល់កិត្តិយស ឬការគោរពឲ្យតម្លៃខ្លាំងរបស់យើងលើអ្វីមួយនៅក្នុងជីវិត។ ការថ្វាយបង្គំគឺអំពីការនិយាយថា បុគ្គលនេះ វត្ថុនេះ ឬបទពិសោធន៍នេះមានតម្លៃខ្ពស់បំផុតក្នុងជីវិតរបស់ខ្ញុំ។ «វត្ថុ» នោះអាចជាការទំនាក់ទំនងមួយអាចជាគោលដៅមួយដែលខ្ញុំកំពុងតាមរក ស្ថានភាពមួយដែលខ្ញុំប្រាថ្នាចង់បាន ឬមានរួចហើយ អាចជាកម្មសិទ្ធិមួយដែលខ្ញុំស្រឡាញ់ជាអាជីពមួយដែលខ្ញុំបានដាក់ខ្លួនចូលទៅក្នុងរាជាភាពរីករាយខ្លះដែលខ្ញុំប្រាថ្នាចង់បានជាខ្លាំង ឬប្រហែលជាការញៀន ដូចជារូបអាសអាភាសគ្រឿងស្រវឹង ល្បែងស៊ីសង ឬប្រព័ន្ធផ្សព្វផ្សាយក្នុងបណ្តាញសង្គមនានា។ វាអាចជាគ្រួសាររបស់ខ្ញុំ។ អ្វីក៏ដោយដែល

ថែរក្សាការលះបង់របស់ខ្ញុំ វាគឺជាអ្វីដែលខ្ញុំបានកំណត់នៅក្នុងចិត្តរបស់ខ្ញុំ ថាមានតម្លៃខ្ពស់បំផុតសម្រាប់ខ្ញុំ។

មនុស្សគ្រប់រូប—ទាំងគ្រីស្ទបរិស័ទ និងអ្នកមិនមែនជាគ្រីស្ទបរិស័ទ គឺដូចគ្នា—ពួកគេសុទ្ធតែជាអ្នកថ្វាយបង្គំ។ អ្វីក៏ដោយដែលមនុស្សម្នាក់ឲ្យតម្លៃបំផុត តំណាងឲ្យអ្វីដែលពួកគេកំពុងថ្វាយបង្គំ។ អ្នកអាចតាមដានពីរបៀបដែលមនុស្សម្នាក់ចំណាយពេលវេលាការយកចិត្តទុកដាក់លុយកាក់ការគិត ការសន្ទនា។ល។ ដើម្បីមើលពីអ្វីដែលពួកគេថ្វាយបង្គំពិតយ៉ាងប្រាកដ។

អ្នកអាចសង្កេតឃើញការថ្វាយបង្គំដែលបង្ហាញរស់រវើកនៅក្នុងការប្រកួតបាល់ទាត់ ឬការប្រគំតន្ត្រី។ អ្នកអាចទៅវត្តព្រះពុទ្ធសាសនា ឬពហុកីឡាដ្ឋាន ហើយមើលការថ្វាយបង្គំដ៏អស្ចារ្យ។ អ្នកអាចមើលឃើញការថ្វាយបង្គំដ៏ឆេះឆួលត្រូវបានបង្ហាញនៅកន្លែងផ្សេងៗគ្នា។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំសោកស្តាយយ៉ាងខ្លាំងនោះគឺថា វាហាក់ដូចជាមនុស្សនៅក្នុងកន្លែងទាំងនោះមានការរំជួលចិត្តយ៉ាងខ្លាំងចំពោះព្រះតូចៗដែលពួកគេកំពុងគោរពជាជាង នៅពេលដែលគ្រីស្ទបរិស័ទថ្វាយបង្គំព្រះពិត ជាព្រះអង្គដែលសង្គ្រោះព្រលឹងរបស់យើង និងជាព្រះដែលបង្កើតសកលលោកទាំងមូល។

អ្នកឃើញស្រាប់ហើយថា ជាទូទៅ មនុស្សសុទ្ធតែជាអ្នកថ្វាយបង្គំដ៏អស្ចារ្យ។ វាគ្រាន់តែថា កម្មវត្ថុនៃការថ្វាយបង្គំរបស់ពួកគេជារឿយៗត្រូវបានបង្វែរខុសទិសដៅ។ យើងត្រូវសួរថា “តើយើងថ្វាយបង្គំអ្វី ឬនរណា?

ការថ្វាយបង្គំខុសគោលដៅគឺជាការផ្តោតលើរូបព្រះនៅក្នុងជីវិតរបស់យើង។ លោកធីម ខេល័រ (Tim Keller) មានប្រសាសន៍អំពីរូបព្រះបែបនេះ៖

> *រូបព្រះគឺជាអ្វីដែលសំខាន់សម្រាប់អ្នកជាជាងព្រះពិត ជាអ្វីដែលស្រូបយកចិត្តគំនិត និងការស្រមើស្រមៃរបស់អ្នកជាជាងព្រះពិត ឬជាអ្វីៗគ្រប់យ៉ាងដែលអ្នកស្វែងរកដើម្បីផ្តល់ឲ្យអ្នកដែលមានតែព្រះពិតមួយអង្គប៉ុណ្ណោះដែលអាចផ្តល់ឲ្យបាន។*
>
> *ព្រះក្លែងក្លាយគឺជាអ្វីមួយដែលសំខាន់ និងចាំបាច់សម្រាប់ជីវិតរបស់អ្នក ដូច្នេះប្រសិនបើអ្នកបាត់បង់វា ជីវិតរបស់អ្នកនឹងមានអារម្មណ៍ថាពិបាករស់នៅណាស់។ រូបព្រះមានការលេចធ្លោនៅក្នុងចិត្តគំនិតរបស់អ្នកដែលអ្នកអាចលះបង់ពេលវេលាភាគច្រើន និងថាមពលរបស់អ្នក ធនធានផ្លូវចិត្ត និងហិរញ្ញវត្ថុរបស់អ្នកទៅលើវាដោយមិនមានការស្ទាក់ស្ទើរ។*

*រូបព្រះគឺជាអ្វីៗដែលអ្នកក្រឡេកមើលទៅវា ហើយនិយាយនៅក្នុងចិត្តគំនិតរបស់អ្នកថា «ប្រសិនបើខ្ញុំមានវានោះខ្ញុំនឹងមានអារម្មណ៍ថាជីវិតរបស់ខ្ញុំមានន័យ នោះខ្ញុំនឹងដឹងថាខ្ញុំមានតម្លៃ នោះខ្ញុំនឹងមានអារម្មណ៍ថាសំខាន់ និងមានសុវត្ថិភាព»។ មានវិធីជាច្រើនដើម្បីពិពណ៌នាអំពីទំនាក់ទំនងប្រភេទនោះទៅនឹងអ្វីមួយ ប៉ុន្តែប្រហែលជាវិធីដែលល្អបំផុតនោះគឺការ «ថ្វាយបង្គំ»។[១]*

ហារ៉ូល ប៊េសថ៍ (Harold Best) ឲ្យនិយមន័យការថ្វាយបង្គំក្នុងន័យទូលំទូលាយបែបនេះថាជា «ការទទួលស្គាល់ថានរណាម្នាក់ ឬអ្វីផ្សេងទៀតគឺធំជាង–មានតម្លៃជាង–ហើយជាលទ្ធផលក៏ត្រូវបានស្តាប់បង្គាប់ កោតខ្លាច និងស្រឡាញ់...ការថ្វាយបង្គំគឺជាសញ្ញាដែលបង្ហាញដោយការប្រគល់ខ្លួនខ្ញុំទាំងស្រុងទៅនរណាម្នាក់ ឬអ្វីមួយដែលខ្ញុំចង់ឲ្យធ្វើជាម្ចាស់លើខ្ញុំ»។1

ពិតណាស់ អ្វីក៏ដោយដែលគ្រប់គ្រងចិត្តគំនិត និងជីវិតរបស់យើង វានឹងធ្វើជាម្ចាស់លើយើង។ ព្រះយេស៊ូវមានព្រះបន្ទូលយ៉ាងច្បាស់នៅក្នុង ម៉ាថាយ ៦:២១ ថា «ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ»។

អ្វីដែលយើងស្រឡាញ់របស់យើង សូនច្នៃយើងទៅជានរណាដែលយើងនឹងក្លាយទៅជា។ ការថ្វាយបង្គំគឺមានអំណាចក្នុងការបំផ្លាស់បំប្រែ។

**ចំណាយពេលបន្តិច ដើម្បីពិនិត្យមើលជីវិតខ្លួនឯង។ តើសេចក្តីស្រឡាញ់របស់អ្នកណា? តើអ្នកកំពុងបម្រើ រូបព្រះឬទេ? តើអ្នកត្រូវការផ្លាស់ប្តូរជីវិតរបស់អ្នក ដើម្បីដាក់ព្រះគ្រីស្ទនៅក្នុងកន្លែងត្រឹមត្រូវរបស់ទ្រង់ម្តងទៀតឬទេ?**

និយមន័យទីពីរនៃការថ្វាយបង្គំគឺផ្តោតលើអង្គខាងវិញ្ញាណដែលទទួលការស្រឡាញ់ពីយើងច្រើនជាង៖

«គឺគោរព ឬបង្ហាញការគោរពយ៉ាងជ្រាលជ្រៅចំពោះតួអង្គទេវភាព ឬអំណាចលើសធម្មជាតិ»។ [២]

ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ យើងមិនត្រឹមតែត្រូវរៀបចំចិត្តគំនិតរបស់យើងដើម្បីឲ្យផ្តោតលើការថ្វាយបង្គំរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវខិតខំ

---

១ លោក Harold Best, Music Through the Eyes of Faith (HarperOne, ឆ្នាំ១៩៩៣), ទំព័រ១៨៣។
២ “Worship,” Merriam-Webster Online Dictionary.

បង្កើត និងដឹកនាំកម្មវិធីថ្វាយបង្គំដែលនឹងលើកទឹកចិត្តមនុស្សផ្សេងទៀតឲ្យរៀបចំចិត្តគំនិតរបស់ពួកគេឡើងវិញ — ដើម្បីជួយពួកគេដាក់ព្រះយេស៊ូវលើបល្ល័ង្កនៃជីវិតរបស់ពួកគេ ដើម្បីធ្វើឲ្យព្រះជាម្ចាស់ក្លាយជាកម្មវត្ថុនៃសេចក្តីស្រឡាញ់របស់ពួកគេ។ នេះគឺជាការថ្វាយបង្គំដែលបំផ្លាស់បំប្រែ។ យើងនឹងស្វែងយល់ការនេះបន្ថែមទៀតនៅពេលយើងបន្តទៅមុខ។

នៅពេលដែលយើងចាប់ផ្តើមយល់ដឹងនិយមន័យដ៏ល្អនៃការថ្វាយបង្គំស្របតាមព្រះគម្ពីរយើងត្រូវយល់ស្របថា ព្រះគម្ពីរមិនបានផ្តល់ឲ្យយើងនូវនិយមន័យផ្លូវការនៃការថ្វាយបង្គំនោះទេ។

ពាក្យជាភាសាអង់គ្លេស "Worship" (ការថ្វាយបង្គំ) មកពីពាក្យ Anglo-Saxon, "weorthscipe" មានន័យថា «មានតម្លៃ» ឬ «ការសន្មតថា»«មានតម្លៃ» ។ ដូច្នេះ ក្នុងការថ្វាយបង្គំរបស់យើង យើងប្រកាសពីតម្លៃរបស់ព្រះ—យើងសរសើរតម្កើងទ្រង់ គោរពទ្រង់ ហើយនិយាយអំពីលក្ខណសម្បត្តិរបស់ព្រះអង្គ។ យើងយល់ឃើញពីគោលបំណងនេះនៅក្នុង ១ពេត្រុស ២:៩ ថា៖

> *តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានសំដែងចេញ ឲ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់។*

យើងប្រកាសពីតម្លៃនៃព្រះ—ថាទ្រង់តែមួយអង្គគត់ជាដើមចមនៃការថ្វាយបង្គំរបស់យើង។ ការថ្វាយបង្គំគឺជាការបើកសម្តែងថាតើព្រះជានរណា ហើយជាការឆ្លើយតបរបស់យើងចំពោះការបើកសម្តែងនោះ។

ទោះបីជាព្រះគម្ពីរមិនបានផ្តល់ឲ្យយើងនូវនិយមន័យនៃការថ្វាយបង្គំក៏ដោយ ក៏មានពាក្យពីរប្រភេទសំខាន់ៗសម្រាប់ការថ្វាយបង្គំដែលពិពណ៌នាដោយលោកបណ្ឌិត ម៉ៃឃើល ម៉ូរីសុនថា (Michael Morrison)៖

> *ទីមួយ ការថ្វាយបង្គំ មានន័យថា ក្រាបចុះ លុតជង្គង់ ដាក់មុខចុះ ជាទង្វើនៃការគោរព និងចុះចូល។ ភាសាកាយវិការរបស់យើងនិយាយថា ខ្ញុំនឹងធ្វើអ្វីដែលទ្រង់ចង់ឲ្យខ្ញុំធ្វើ។ ខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីស្តាប់ការណែនាំរបស់ទ្រង់ ហើយខ្ញុំសុខចិត្តគោរពតាម។ ប្រភេទនៃពាក្យព្រះគម្ពីរផ្សេងទៀតមានន័យថាបម្រើ។ ប្រហែលពាក់កណ្តាលនៃពាក្យទាំងនេះត្រូវបានបកប្រែថា ការថ្វាយបង្គំ ហើយពាក់កណ្តាលទៀតបកប្រែថាគឺបម្រើ។ វាបង្ហាញ*

*អំពីគំនិតនៃការធ្វើអ្វីមួយសម្រាប់ព្រះ — មិនថាការលះបង់ ឬធ្វើតាមសេចក្តីបង្រៀនរបស់ទ្រង់។*[៣]

យើងអាចពិចារណាប្រភេទទាំងពីរនេះគឺ ទង្វើនៃការគោរព និងសកម្មភាពទាំងអស់នៃការបម្រើ។ នៅពេលសិក្សាឲ្យកាន់តែស៊ីជម្រៅ អ្នកនឹងកត់សម្គាល់ឃើញថាពាក្យក្នុងអត្ថបទព្រះគម្ពីរបង្ហាញថាការថ្វាយបង្គំគឺរួមទាំងរូបរាងកាយដូចជា—ការក្រាបឱនចុះ ឈរជើងទាប លុតជង្គង់។ល។

ពាក្យទូទៅបំផុតសម្រាប់ការថ្វាយបង្គំជាភាសាក្រិកគឺ (proskuneó) ។ វាមានន័យថា «ដោយការលុតជង្គង់ ឬក្រាបថ្វាយបង្គំ (ដល់នរណាម្នាក់) ឬគោរពបូជា ដើម្បីសម្តែងការគោរព ឬទូលអង្វរក៏ដោយ»។[៤]

ពាក្យទូទៅបំផុតជាភាសាហេព្រើរសម្រាប់ការថ្វាយបង្គំនៅក្នុងព្រះគម្ពីរគឺ "shachah" ។ វាមានន័យថា «ក្រាបថ្វាយឱនចុះ... នៅចំពោះព្រះក្នុងការថ្វាយបង្គំ»។[៥]

ទាំងពាក្យភាសាហេព្រើរ និងភាសាក្រិកជាទូទៅបំផុតបង្ហាញពីសកម្មភាពរូបរាងកាយក្នុងការថ្វាយបង្គំ។

លោក ចន ផាបភ័រ (John Piper) ពិពណ៌នាអំពីការថ្វាយបង្គំដោយរបៀបនេះ៖

> *ខ្លឹមសារខាងក្នុងនៃការថ្វាយបង្គំគឺជាការស្គាល់ព្រះយ៉ាងពិតប្រាកដ ហើយបន្ទាប់មកឆ្លើយតបចេញពីបេះដូងចំពោះការស្គាល់នោះដោយឲ្យតម្លៃដល់ព្រះ រក្សាព្រះទុកដូចជាកំណប់ទ្រព្យ ហើយព្រះអម្ចាស់គឺជារង្វាន់នោះឯង ចូរត្រេកអរចំពោះព្រះ ស្កប់ចិត្តនឹងព្រះ លើសអ្វីៗទាំងអស់នៅលើផែនដី។ ហើយបន្ទាប់មក ការពេញចិត្តដ៏ជ្រាលជ្រៅ ភាពត្រេកអរ ហើយនិងសេចក្តីអំណរនៅក្នុងព្រះនោះ ហូរហៀរនៅក្នុងទង្វើនៃការសរសើរពីបបូរមាត់ និងការបង្ហាញនូវទង្វើនៃសេចក្តីស្រឡាញ់ក្នុងការបម្រើអ្នកដទៃដោយយល់ដល់ព្រះគ្រីស្ទ។* [៦]

---

៣ លោក Michael Morrison, "What is Worship? A Survey of the Bible," Grace Communion Seminary, https://learn.gcs.edu/mod/page/view.php? id=4256.

៤ "Proskuneo," Bible Study Tools, https://www.biblestudytools.com/lexicons/greek/kjv/proskuneo.html

៥ "Shachah," Bible Tools, https://www.bibletools.org/index.cfm/fuseaction/lexicon.show/ID/h7812/page/2

៦ លោក John Piper, "What Is Worship," Desiring God, https://www.desiringgod.org/interviews/what-is-worship

ដូចដែលលោក ផាបភ័រ (Piper) បង្ហាញការថ្វាយបង្គំគួរតែជាបទពិសោធន៍នៃការបើកសម្ដែង និងការឆ្លើយតប។ លោក វ័ររ៉េន វារស្ពី (Warren Wiersbe) សរសេរថា៖

*ការថ្វាយបង្គំគឺជាការឆ្លើយតបរបស់អ្នកជឿចំពោះអ្វីៗទាំងអស់ដែលពួកគេមាន - ទាំងចិត្តគំនិត អារម្មណ៍ ឆន្ទៈ រូបរាងកាយ - ចំពោះអ្វីដែលព្រះមាន ហើយមានបន្ទូល និងចំពោះអ្វីដែលទ្រង់ធ្វើ។*[៧]

យើងឆ្លើយតបទាំងស្រុងចំពោះការបើកសម្ដែងនៃព្រះ។ ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ យើងត្រូវប្រាកដថា យើងកំពុងបង្ហាញការបើកសម្ដែងដ៏ត្រឹមត្រូវដ៏ប្រពៃរបស់ព្រះក្នុងកម្មវិធីដែលយើងដឹកនាំ និងរៀបចំផែនការ។ ការបើកសម្ដែងព្រះនៅក្នុងសេចក្ដីពេញលេញរបស់ទ្រង់ពិតជាចាំបាច់ណាស់សម្រាប់ការថ្វាយបង្គំដែលបំផ្លាស់បំប្រែ។

រ៉ូបឺត សេភ័រ (Robert Schaper) ពន្យល់បន្ថែមទៅលើគំនិតនៃការបើកសម្ដែង ហើយនិងការឆ្លើយតបនេះ៖:

ការថ្វាយបង្គំគឺជាការបង្ហាញពីទំនាក់ទំនងដែលព្រះជាព្រះវរបិតាបង្ហាញអង្គទ្រង់ និងសេចក្ដីស្រឡាញ់របស់ព្រះអង្គនៅក្នុងព្រះគ្រីស្ទ ហើយដោយព្រះវិញ្ញាណបរិសុទ្ធ ទ្រង់អនុវត្តព្រះគុណដែលយើងឆ្លើយតបដោយសេចក្ដីជំនឿ ការដឹងគុណ និងការស្ដាប់បង្គាប់។ [៨]

លោក ស្ទេវិន ប្រ៊ូក (Steven Brooks) ពន្យល់អំពីសម្រង់សម្ដីរបស់ សេភើរ (Schaper) ថា៖

*ជាដំបូង សូមកត់សម្គាល់ថា ក្នុងការថ្វាយបង្គំរបស់យើង ព្រះចង់មានទំនាក់ទំនងជាមួយយើង។ ទ្រង់សព្វព្រះហឫទ័យឲ្យយើងនៅក្នុងវត្តមានរបស់ទ្រង់។ បន្ទាប់មកលោក សេភើរ (*Schaper*) និយាយយ៉ាងត្រឹមត្រូវអំពីការបើកសម្ដែង និងការឆ្លើយតបនៃការថ្វាយបង្គំ។ ព្រះបន្ទូលរបស់ព្រះត្រូវបានប្រកាសដល់សហគមន៍គ្រីស្ទបរិស័ទ ជាការបង្ហាញដោយចេតនានៃការពិតអំពីព្រះបីអង្គ-ព្រះវរបិតា ព្រះរាជបុត្រា ព្រះវិញ្ញាណបរិសុទ្ធ និងទំនាក់ទំនង*

---

៧ លោក Warren Wiersbe, Real Worship: It Will Tranform Your Life (United States, Baker Publishing Group, ឆ្នាំ២០០០), ទំព័រ២៦។

៨ លោក Robert Schaper, In His Presence: Appreciating Your Worship Tradition (Nashville: T. Nelson Publishers), ទំព័រ១៥-១៦។

*របស់ព្រះជាមួយរាស្ត្រទ្រង់ (ការបើកសម្តែង)។ ហើយមានការឆ្លើយតបរបស់រាស្ត្ររបស់ព្រះចំពោះសេចក្តីពិតដែលបានប្រកាសបង្ហាញនោះដោយឱកាសដែលបានរៀបចំមុន មិនមែនដោយឯកឯង សម្រាប់អ្នកថ្វាយបង្គំក្នុងការឆ្លើយតប ឬប្រតិកម្ម ។ ការថ្វាយបង្គំរបស់យើងគួរតែជាការឆ្លើយតបទៅនឹងអ្វីដែលព្រះបានធ្វើ កំពុងតែធ្វើ ហើយនឹងធ្វើនៅក្នុងជីវិតរបស់យើង។* [៩]

ព្រះទ្រង់ផ្តួចផ្តើមការថ្វាយបង្គំតាមរយៈការបើកសម្តែងអង្គទ្រង់ដល់យើង។ លោក ម៉ៃឃើល ម៉ូរីសុន (Michael Morrison) សរសេរអំពីរបៀបដែលយើងឆ្លើយតបទៅនឹងការបើកសម្តែងនោះ៖

*ការថ្វាយបង្គំរបស់យើងគឺជាការឆ្លើយតបចំពោះអ្វីដែលព្រះបានបើកសម្តែងឲ្យឃើញអំពីអង្គទ្រង់ មិនត្រឹមតែអំពីថាទ្រង់ជានរណាប៉ុណ្ណោះទេ ប៉ុន្តែក៏អំពីអ្វីដែលទ្រង់បានធ្វើ និងកំពុងធ្វើ ហើយនឹងធ្វើនាពេលអនាគតផងដែរ។ ការថ្វាយបង្គំរួមបញ្ចូលរាល់ការឆ្លើយតបរបស់យើងចំពោះព្រះ – រួមទាំងការឆ្លើយតបជាមួយនឹងគំនិតរបស់យើង ដូចជាជំនឿរបស់យើងលើភាពស័ក្តិសមជារបស់ព្រះ អារម្មណ៍របស់យើង ដូចជាសេចក្តីស្រឡាញ់ ការជឿទុកចិត្ត សកម្មភាព ហើយនិងពាក្យសម្តីរបស់យើង។ ចិត្តគំនិតរបស់យើងបង្ហាញចេញជាពាក្យសម្តី និងបទចម្រៀង។ ចិត្តរបស់យើងសកម្មនៅពេលដែលយើងចង់រៀនពីអ្វីដែលព្រះចង់ឲ្យយើងធ្វើ ហើយរូបកាយ និងកម្លាំងរបស់យើងពាក់ព័ន្ធនៅពេលយើងស្តាប់បង្គាប់ និងពេលយើងបម្រើ។* [១០]

លោក បប់ ខូហ្វលីន (Bob Kauflin) បានសរសេរនិយមន័យដ៏ល្អមួយអំពីការថ្វាយបង្គំរួមជាមួយនឹងមូលដ្ឋានបទគម្ពីរលម្អិត ជាសំណេរដ៏ស័ក្តិសមនឹងការសិក្សារបស់យើង។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យចំណាយពេលខ្លះដើម្បីពិនិត្យមើលចំណុចនេះឲ្យបានដិតដល់៖

*ការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទគឺជាការឆ្លើយតបរបស់មនុស្សដែលព្រះបានប្រោសលោះ ចំពោះការបើកសម្តែងអង្គទ្រង់ដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះនៅក្នុងព្រះគ្រីស្ទក្នុងគំនិតការស្រឡាញ់ និងឆន្ទៈរបស់យើងដោយនូវអំណាចព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។*

---

៩ លោក Stephen Brooks, Worship Quest: An Exploration of Worship Leadership (United States: Wipf and Stock Publishers, ឆ្នាំ២០១៥), Kindle.

១០ Michael Morrison.

**ការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទ...**ខុសគ្នាពីការថ្វាយបង្គំ គ្រប់ប្រភេទ ព្រោះការនេះ ត្រូវបានធ្វើឲ្យដំណើរការទៅបានតាមរយៈ ព្រះយេស៊ូវគ្រីស្ទ (វិវរណៈ ៥:៩-១០)។

**ការឆ្លើយតប...** ព្រះបានធ្វើរួចរាល់នូវការដែលនៅខាងក្រៅ និងនៅខាងក្នុងយើងដែលផ្តល់លទ្ធភាពយើងឲ្យថ្វាយបង្គំទ្រង់។ យើងមិនមែនជាអ្នកផ្តួចផ្តើមនៃការថ្វាយបង្គំទេ តែគឺជាព្រះវិញ (កិច្ចការ ១៧:២៤-៣១)។

**រាស្ត្រដែលព្រះបានប្រោសលោះ...** ដូចជាព្រះដែលបានរំដោះជាតិសាសន៍អ៊ីស្រាអែលពីអេស៊ីព្ទដើម្បីថ្វាយបង្គំទ្រង់ (និក្ខមនំ ៨:១) ទ្រង់ក៏បានប្រោសលោះយើងទុកជាជាតិសាសន៍បរិសុទ្ធ ដើម្បីប្រកាសសេចក្តីសរសើរដល់ទ្រង់ (១ពេត្រុស ២:៩)។ ការថ្វាយបង្គំព្រះត្រូវបានតម្រូវឲ្យធ្វើរួមគ្នាមិនមែនគ្រាន់តែជាលក្ខណៈផ្ទាល់ខ្លួនប៉ុណ្ណោះទេ។

**ការបើកសម្តែងអង្គទ្រង់...** យើងមិនអាចស្គាល់ព្រះក្រៅពីការដែលទ្រង់បើកសម្តែងអង្គទ្រង់ដល់យើងទេ។ ទ្រង់បានបង្ហាញអង្គទ្រង់ដល់យើងក្នុងការបង្កើតរបស់ទ្រង់ព្រះបន្ទូលទ្រង់ និងចុងក្រោយគឺក្នុងព្រះរាជបុត្រាទ្រង់ (រ៉ូម ១:២០; ហេព្រើរ ១:១-៤)។

**ដែលលើកតម្កើង...** ខ្លឹមសារនៃការថ្វាយបង្គំគឺការសរសើរតម្កើង–ការលើកតម្កើង ការលើកកម្ពស់ ការចុះចូលចំពោះ ការសម្តែងឲ្យឃើញច្បាស់ ការថ្វាយការយកចិត្តទុកដាក់ឲ្យបានច្រើនចំពោះ ការគោរពប្រតិបត្តិ ការគោរពកោតខ្លាច ការអបអរសាទរដល់ – ព្រះត្រៃឯក (ទំនុកតម្កើង ៧១:១៩)។

**សិរីរុងរឿងរបស់ព្រះនៅក្នុងព្រះគ្រីស្ទ...** លោកម៉ូសេបានទូលសុំព្រះឲ្យបង្ហាញដល់គាត់នូវសិរីរុងរឿងនៃព្រះ ហើយព្រះទ្រង់ក៏យាងកាត់មុខគាត់ព្រមទាំងបានប្រកាសលក្ខណៈរបស់ទ្រង់ (និក្ខមនំ ៣៤:៦-៧)។ ព្រះបានប្រទានលទ្ធភាពឲ្យយើងឃើញសិរីល្អទ្រង់ក្នុងព្រះភក្ត្រនៃព្រះគ្រីស្ទ (២កូរិនថូស ៤:៦)។

**គំនិតរបស់យើង...** ការថ្វាយបង្គំរួមបញ្ចូលការគិត ការសញ្ជឹងគិត ការឆ្លុះបញ្ចាំង ដំណើរការណ៍ ការវាយតម្លៃ និងការយល់អ្វីដែលព្រះបានបើកសម្តែងអង្គទ្រង់ដល់យើង (រ៉ូម ១២:១-២; ទំនុកតម្កើង ១១១:២)។

**ចិត្តស្រឡាញ់...** ការថ្វាយបង្គំពិតរួមបញ្ចូលទាំងបេះដូង និងខួរក្បាល។ យើងថ្វាយបង្គំអ្វីដែលយើងស្រឡាញ់ និងឲ្យតម្លៃបំផុត (ម៉ាថាយ ២២:៣៧-

៣៨)។

**និងឆន្ទៈរបស់យើង...**បើយើងពិតជាថ្វាយបង្គំព្រះ យើងពិតជាត្រូវបានបំផ្លាស់បំប្រែ (២កូរិនថូស ៣:១៧-១៨)។ ការជ្រើសរើសរបស់យើងនឹងឆ្លុះបញ្ចាំងជាការថ្លែងប្រាប់របស់យើងថា ព្រះទ្រង់ធំឧត្ដមនៅក្នុងជីវិតរបស់យើង (១២:១-២)។

**ដោយនូវព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ...** យើងគឺជាអ្នកដែលថ្វាយបង្គំដោយវិញ្ញាណនៃព្រះ ហើយពឹងផ្អែកលើការដឹកនាំ និងការប្រទានលទ្ធភាពពីទ្រង់ (ភីលីព ៣:៣)។

**សូមចំណាយពេលសិក្សាអំពីនិយមន័យនៃការថ្វាយបង្គំទាំងនេះម្ដងទៀត។ បន្ទាប់មក ចូរសរសេរនិយមន័យរបស់ "ការថ្វាយបង្គំ" ដែលអ្នកអាចពន្យល់ដល់អ្នកដទៃបាន នៅពេលពួកគេសួរថា៖ «តើការថ្វាយបង្គំគឺជាអ្វី?»**

## ការថ្វាយបង្គំរបស់យើងត្រូវតែថ្វាយចំពោះព្រះត្រៃឯកតែយកព្រះគ្រីស្ទជាគោល

ការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទត្រូវតែថ្វាយព្រះកិត្តិនាមព្រះបិតាខណៈពេលដែលយើងថ្វាយបង្គំព្រះរាជបុត្រាដោយសារព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។ គោលគំនិតនៃការថ្វាយបង្គំព្រះត្រៃឯកអាចមានភាពពិបាកយល់បន្តិចដោយសារតែភាពស្មុគស្មាញនៃការយល់ដឹងអំពីព្រះត្រៃឯក។ ចម្រៀងជាច្រើនរបស់យើងនិយាយអំពីព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ការអធិស្ឋានរបស់យើងសំដៅដល់ព្រះត្រៃឯក។ ការប្រកាសគោលជំនឿ (creeds) និយាយអំពីព្រះត្រៃឯក។ ប៉ុន្តែ សំខាន់បំផុត កម្មវិធីថ្វាយបង្គំរបស់យើងគឺមានព្រះគ្រីស្ទជាគោល។ ការថ្វាយបង្គំរបស់យើងគួរតែប្រាប់រឿងដំណឹងល្អ ដ្បិតដំណឹងល្អនាំឲ្យផ្លាស់ប្រែ។

លោក ប្រាយអិន ឆាផិល (Bryan Chapell) នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា ការថ្វាយបង្គំដែលយកព្រះគ្រីស្ទជាគោល (Christ-Centered Worship) ធ្វើឲ្យគោលគំនិតនេះកាន់តែច្បាស់លាស់ថែមទៀត៖

*យើងធ្វើឲ្យការថ្វាយបង្គំរបស់យើងផ្ដោតលើព្រះគ្រីស្ទមិនមែនដោយខកខានក្នុងការលើកតម្កើងទ្រង់ ប៉ុន្តែដោយការថ្វាយព្រះកិត្តិនាម ព្រះវរបិតា ឬព្រះវិញ្ញាណបរិសុទ្ធ ជាមួយនឹងគំរូនៃដំណឹងល្អដែលឆ្លុះបញ្ចាំងពីបំណងព្រះហឫទ័យរបស់ទ្រង់។ យើងថ្វាយព្រះកិត្តិនាមដល់ព្រះអម្ចាស់ ពេលយើងច្រៀងពីភាពអស្ចារ្យរបស់ទ្រង់ដល់ដួងចិត្តទន់ទាប ហើយរៀបចំដួងចិត្តដើម្បីទទួលព្រះគុណដែលព្រះគ្រីស្ទប្រទានមក។ ហើយប្រសិនបើយើងមិននិយាយអំពីការប្រទានមករបស់ព្រះគ្រីស្ទទេនោះយើងនឹងបង្អាប់ព្រះដែលបានចាត់ឲ្យទ្រង់មកមិនថាយើងសរសើរតម្កើងព្រះបិតាកាន់តែច្រើនប៉ុណ្ណានោះទេ។ ស្រដៀងគ្នា ដែរយើងថ្វាយព្រះកិត្តិនាមព្រះវិញ្ញាណ ពេលយើងអំពាវនាវដល់ទ្រង់ឲ្យជួយយើងយល់ពីទីបន្ទាល់នៃបទគម្ពីរអំពីកិច្ចការរបស់ព្រះគ្រីស្ទ។ ហើយយើងនឹងធ្វើឲ្យព្រះវិញ្ញាណព្រួយព្រះទ័យដែលព័ន្ធកិច្ចរបស់ទ្រង់គឺដើម្បីធ្វើបន្ទាល់អំពីព្រះគ្រីស្ទ ប្រសិនបើយើងយកទ្រង់ជាកម្មវត្ថុសំខាន់នៃការថ្វាយបង្គំរបស់យើង ... យើងធ្វើការថ្វាយបង្គំរបស់យើងដោយព្រះគ្រីស្ទជាគោលមិនមែនដោយគ្រាន់តែនិយាយអំពីព្រះនាមព្រះយេស៊ូវទេ ហើយប្រាកដណាស់ក៏មិនមែនដោយការមិនគោរពដល់ព្រះវរបិតា និងព្រះវិញ្ញាណនោះដែរ។ យើងធ្វើឲ្យការថ្វាយបង្គំរបស់យើងផ្ដោតលើព្រះគ្រីស្ទ ដោយរៀបចំដើម្បីជួយប្រជារាស្ត្ររបស់ព្រះឲ្យយល់ និងដឹងគុណចំពោះព្រះគុណនៅក្នុងបទគម្ពីរទាំងអស់ដែលព្រះអង្គបានរួមគ្នាក្នុងព័ន្ធកិច្ចការសង្គ្រោះរបស់ព្រះអង្គ។* [១១]

ប្រសិនបើកម្មវិធីថ្វាយបង្គំរបស់យើងគឺផ្ដោតលើព្រះគ្រីស្ទនោះបណ្ដាលឲ្យមានភាពតានតឹងនៅពេលយើងគិតពីវិធីដែលជារឿយៗយើងងាកចេញពីការផ្ដោតលើព្រះយេស៊ូវ នៅក្នុងកម្មវិធីថ្វាយបង្គំរបស់យើង។ មានពេលខ្លះដែលយើងប្រារព្ធទិវាដឹងគុណម្ដាយ ទិវាដឹងគុណឪពុក ថ្ងៃឈប់សម្រាកជាតិជាដើម។ ករណីនេះមិនគួរកើតឡើងនៅក្នុងកម្មវិធីថ្វាយបង្គំរួមគ្នារបស់យើងទេ។ យើងគួរតែស្វះស្វែងយកព្រះគ្រីស្ទជាចំណុចកណ្ដាលនៃពេលវេលាទាំងនេះ ដោយមិនងាកចេញពីការថ្វាយបង្គំរួមគ្នា និងរក្សាការប្រារព្ធពិធីដែលមិនមានចែងក្នុងព្រះគម្ពីរទាំងនេះត្រឹមអប្បបរមា។

សូមធ្វើការពិនិត្យមើលការថ្វាយបង្គំជាច្រើនសប្ដាហ៍កន្លងមក។ តើអ្នកឃើញ

---

១១ លោក Bryan Chapell, Christ-Centered Worship: Letting the Gospel Shape Our Practice (United States: Baker Academic, ឆ្នាំ២០១៧), ទំព័រ១១៤-១១៥។

ថាកម្មវិធីទាំងនេះគឺថ្វាយដល់ព្រះត្រៃឯក ប៉ុន្តែយកព្រះគ្រីស្ទជាគោលឬទេ? តើអ្នកចំណាយពេលច្រើនពេកក្នុងការផ្តោតទៅលោកីយ៍ដែរឬទេ?

**សូមពិនិត្យមើលកម្មវិធីថ្វាយបង្គំក្នុងរយៈពេលប៉ុន្មានសប្តាហ៍កន្លងមក ។ តើអ្នកឃើញថា កម្មវិធីទាំងនោះមានលក្ខណៈផ្តោតលើព្រះត្រៃឯក (Trinitarian) ប៉ុន្តែ មានព្រះគ្រីស្ទជាចំណុចស្នូលដែរឬទេ? តើអ្នកចំណាយពេលច្រើនពេក ក្នុងការធ្វើកម្មវិធីតាមលំនាំលោកិយឬ?**

ម៉ូរីសុន (Morrison) ពណ៌នាអំពីការថ្វាយបង្គំបីប្រភេទ—ការថ្វាយបង្គំដែលពាក់ព័ន្ធនឹងការនិយាយ ការស្តាប់ និងការធ្វើសកម្មភាព។ ផ្នែកទាំងបីមានសារៈសំខាន់សម្រាប់កម្មវិធីថ្វាយបង្គំរួមគ្នា។ នេះបង្ហាញបន្ថែមទៀតអំពីឥទ្ធិពលពេញមួយជីវិតនៃការថ្វាយបង្គំរួមគ្នាដែលគួរផ្តល់លទ្ធផលនៃការថ្វាយបង្គំក្នុងរបៀបរស់នៅពោលគឺការថ្វាយបង្គំ និងការបម្រើព្រះពេញមួយជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។

មានការថ្វាយបង្គំដែលបង្ហាញពីចិត្ត និងការថ្វាយបង្គំដែលរួមចំណែកទាំងគំនិត និងការថ្វាយបង្គំដែលរួមចំណែកទាំងរូបកាយ។ មានការថ្វាយបង្គំដែលសរសើរតម្កើងឡើង ការថ្វាយបង្គំដែលទទួលការណែនាំពីស្ថានលើ និងការថ្វាយបង្គំដែលធ្វើការណែនាំក្នុងលោកជុំវិញខ្លួនយើង។ យើងត្រូវការថ្វាយបង្គំទាំងបីប្រភេទនេះ។ មនុស្សខ្លះផ្តោតសំខាន់លើការនិយាយ ឬច្រៀងសរសើរព្រះ។ ការសរសើរតម្កើងគឺជាការល្អ ប៉ុន្តែប្រសិនបើការទាំងអស់ដែលយើងធ្វើសុទ្ធតែជាការសរសើរតម្កើងព្រះជាម្ចាស់ ដោយមិនបានស្តាប់នូវអ្វីដែលទ្រង់មានបន្ទូលទេ យើងត្រូវសួរថាតើយើងជឿពាក្យដែលយើងកំពុងនិយាយដែរឬទេ។ ប្រសិនបើទ្រង់ពិតជាមានប្រាជ្ញា ហើយស្រឡាញ់ទាំងអស់នោះ យើងត្រូវយកចិត្តទុកដាក់នូវអ្វីដែលទ្រង់កំពុងមានបន្ទូលមកកាន់យើង ព្រោះទ្រង់ស័ក្តិសមឲ្យយើងស្តាប់តាម។

ស្រដៀងគ្នាដែរ ការនិយាយដោយគ្មានសកម្មភាពណាមួយមិនបង្ហាញព្រះអំពីការគោរពដែលទ្រង់សមនឹងទទួលទេ។ សកម្មភាពនិយាយឮខ្លាំងជាងពាក្យសម្តី ហើយប្រសិនបើអាកប្បកិរិយារបស់យើងមិនត្រូវបានផ្លាស់ប្តូរដោយសារព្រះទេ នោះសកម្មភាពរបស់យើងកំពុងនិយាយថាព្រះមិនសំខាន់ — ទ្រង់គ្រាន់តែជាគំនិតដ៏ល្អ ប៉ុន្តែមិនពាក់ព័ន្ធនឹងជីវិតប្រចាំថ្ងៃរបស់យើងទេ។ នៅពេលដែលយើងពិតជាជឿថា ព្រះទ្រង់ស័ក្តិសមសម្រាប់ការសរសើរពីយើងគ្រប់ៗគ្នា នោះយើង

នឹងសុខចិត្តស្តាប់ ហើយនិងផ្លាស់ប្តូររបៀបរស់នៅ ដើម្បីឆ្លើយតបទៅនឹងព្រះដ៏ស័ក្តិសមបែបនេះ។ យើងនឹងទុកចិត្តទ្រង់ ហើយស្វែងរកទ្រង់ ហើយចង់បំពេញចិត្តទ្រង់តាមដែលអាចធ្វើទៅបាន។ ការថ្វាយបង្គំគួរតែប៉ះពាល់ដល់អាកប្បកិរិយារបស់យើង។ [១២]

# ការថ្វាយបង្គំផ្ទាល់ខ្លួន និង ការថ្វាយបង្គំរួមគ្នា

ការថ្វាយបង្គំអាចមានបទពិសោធន៍តាមវិធីពីរយ៉ាង—(១) ការថ្វាយបង្គំផ្ទាល់ខ្លួន និង (២) ការថ្វាយបង្គំរួមគ្នា ។ ការថ្វាយបង្គំផ្ទាល់ខ្លួនគឺជាពេលវេលាដ៏ស្និទ្ធស្នាលនៃការថ្វាយបង្គំដែលមានតែអ្នកម្នាក់ឯង និងព្រះប៉ុណ្ណោះ។ ការថ្វាយបង្គំរួមគ្នាគឺជាការថ្វាយបង្គំដែលមានទាំងអ្នក និងមនុស្សម្នាក់ ឬច្រើននាក់ផ្សេងទៀត។

## ការថ្វាយបង្គំផ្ទាល់ខ្លួន

ការថ្វាយបង្គំផ្ទាល់ខ្លួនអាចមានបទពិសោធន៍តាមវិធីពីរយ៉ាងគឺ

### ១.ការថ្វាយបង្គំម្នាក់ឯង៖

នៅពេលដែលយើងនៅដោយឡែកម្នាក់ឯងជាមួយព្រះ ដើម្បីទាក់ទងជាមួយទ្រង់ អានព្រះបន្ទូលរបស់ទ្រង់ ហើយអធិស្ឋាន យើងអាចពណ៌នាថាជាការថ្វាយបង្គំដោយឡែក។ ព្រះយេស៊ូវបានបង្ហាញយ៉ាងខ្ជាប់ខ្ជួននូវភាពចាំបាច់នៃការចំណាយពេលតែម្នាក់ឯងជាមួយនឹងព្រះវរបិតាទ្រង់ ។ នេះជាផ្នែកមួយដ៏ចាំបាច់នៃជីវិតរបស់គ្រីស្ទបរិស័ទ ដើម្បីថ្វាយដួងចិត្ត និងក្តីស្រឡាញ់របស់យើងចំពោះព្រះតាមរបៀបការចំណាយពេលជារៀងរាល់ថ្ងៃ ដោយអនុញ្ញាតឲ្យព្រះមានបន្ទូលមកកាន់យើងតាមរយៈព្រះបន្ទូល និងការអធិស្ឋានទៅរកទ្រង់។ ពេលវេលាតែម្នាក់ឯងជាមួយនឹងព្រះបានបញ្ឆេះជីវិតរបស់យើងជាមួយនឹងព្រះគ្រីស្ទ។

### ២.ការថ្វាយបង្គំតាមរបៀបនៃការរស់នៅ

ដូចដែល ម៉ូរីសុន (Morrison) បានចង្អុលបង្ហាញនៅក្នុងការថ្វាយបង្គំបីប្រភេទថា ការថ្វាយបង្គំមួយប្រភេទទាក់ទងនឹងជីវិតប្រចាំថ្ងៃរបស់យើង ការទុកចិត្តលើព្រះស្វែងរកទ្រង់ និងចង់ផ្គាប់ព្រះហឫទ័យទ្រង់ក្នុងគ្រប់កិច្ចការដែលយើងធ្វើ។ វិធីទីពីរដែលយើងមានបទពិសោធន៍ការថ្វាយបង្គំផ្ទាល់ខ្លួនអាចត្រូវបានគេហៅថាការថ្វាយបង្គំក្នុងរបៀបរស់នៅ។ ១កូរិនថូស ១០:៣១ និយាយអំពីរឿងនេះ៖

១២ លោក Michael Morrison.

ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយនោះចូរធ្វើទាំងអស់សំរាប់ចំរើនសិរីល្អដល់ព្រះចុះ។

ហើយកណ្ឌគម្ពីរ មីកា ៦:៨ ក៏ចែងផងដែរថា

*ឱមនុស្សអើយ ព្រះបានបង្ហាញឲ្យឯងស្គាល់សេចក្ដីដែលល្អ តើព្រះយេហូវ៉ាសព្វព្រះហឫទ័យឲ្យឯងប្រព្រឹត្តដូចម្ដេច បើមិនមែនឲ្យប្រព្រឹត្តដោយសុចរិត ឲ្យស្រឡាញ់សេចក្ដីសប្បុរស ហើយឲ្យដើរជាមួយនឹងព្រះនៃខ្លួនដោយសុភាពរាបទាបប៉ុណ្ណោះ។*

លោក រីឆាដ ហ្វូសធើរ (Richard Foster) នៅក្នុងសៀវភៅដែលមានចំណងជើងថា ការអបអរនៃការប្រៀនប្រដៅ (Celebration of Discipline) មានប្រសាសន៍អំពីការថ្វាយបង្គំក្នុងរបៀបរស់នៅនេះថា៖ «ពេលណាការថ្វាយបង្គំចាប់ផ្ដើមដោយក្ដីសង្ឃឹមដ៏បរិសុទ្ធ ដូច្នេះវាក៏បញ្ចប់ដោយការស្ដាប់បង្គាប់ដ៏បរិសុទ្ធ។ បើសិនការថ្វាយបង្គំមិនជំរុញយើងឲ្យមានការស្ដាប់បង្គាប់កាន់តែខ្លាំងទេ នោះវាមិនមែនជាការថ្វាយបង្គំដ៏ពិតទេ»។[១៣]

ក្នុងនាមជាពួកសិស្សរបស់ព្រះគ្រីស្ទដែលកំពុងរីកចម្រើនជីវិតរបស់យើងគួរតែមើលទៅដូចជាព្រះយេស៊ូវជាងពីមុនជារៀងរាល់ថ្ងៃ។ នេះគឺជាជីវិតដែលត្រូវបានបង្ហាញឲ្យឃើញក្នុងការថ្វាយបង្គំ និងការបម្រើរបស់យើង។

## ការថ្វាយបង្គំរួមគ្នា

ការថ្វាយបង្គំរួមគ្នា គឺជាពេលដែលបុគ្គលម្នាក់ៗមកជុំគ្នាជាមួយអ្នកដទៃទៀតដើម្បីថ្វាយបង្គំដល់ព្រះ។ ម៉ាធិន លូសើរ (Martin Luther) បានមានប្រសាសន៍ថា «ការប្រមូលផ្ដុំជាមួយនឹងរាស្ដ្ររបស់ព្រះក្នុងការថ្វាយបង្គំព្រះវរបិតាដោយរួបរួមគ្នា គឺជាការចាំបាច់ចំពោះជីវិតគ្រីស្ទានដូចជាការអធិស្ឋានដែរ»។

លោក ស្ទេវិន ប្រ៊ូក (Steven Brooks) មានប្រសាសន៍អំពីការថ្វាយបង្គំរួមគ្នាថា

*«នៅក្នុងការថ្វាយបង្គំរួមគ្នា គ្រីស្ទបរិស័ទដែលបានប្រមូលផ្ដុំគ្នាឆ្លុះបញ្ចាំងពីធម្មជាតិនៃព្រះត្រៃឯក ក្នុងពេលដំណាលគ្នាជាឯកវចនៈ និងពហុវចនៈ ហើយទទួលបទពិសោធន៍ពីព្រះរួមគ្នា តាមរយៈព្រះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធ និងតាមរយៈគ្នាទៅវិញទៅមក។ ហើយក៏មានទស្សនិកជន*

---

១៣ លោក Richard Foster, Celebration of Discipline: The Path to Spiritual Growth (New York: HarperCollins, ឆ្នាំ១៩៩៨) ទំព័រ១៧៣។

*ពីរភាគីនៅក្នុងការថ្វាយបង្គំរួមគ្នាផងដែរ ការឆ្លុះបញ្ចាំងនៅក្នុងសំណេររបស់ប៉ុលទៅកាន់អ្នកក្រុងអេភេសូរ៖ «ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ នឹងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតាជាដរាប ក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ» (អេភេសូរ ៥:១៩-២០)។ យើងច្រៀងថ្វាយព្រះ និងដល់គ្នាទៅវិញទៅមក»។[១៤]*

អត្ថបទព្រះគម្ពីរនេះលើកឡើងនូវចំណុចសំខាន់មួយដែលត្រូវបានគេមើលរំលងយ៉ាងខ្លាំងនាពេលបច្ចុប្បន្ននេះ។ ការថ្វាយបង្គំរបស់យើងមិនត្រឹមតែចំពោះព្រះប៉ុណ្ណោះទេ (បន្ទាត់ផ្ដេក) នៅពេលយើងថ្វាយការសរសើរ និងថ្វាយបង្គំដល់ទ្រង់ដោយអរព្រះគុណចំពោះអ្វីៗទាំងអស់ដែលទ្រង់បានធ្វើ។ ការនោះក៏តម្រូវឲ្យយើង «និយាយគ្នាទៅវិញទៅមក» (បន្ទាត់បញ្ឈរ) ក្នុងការប្រកាសពីភាពប្រសើរឧត្ដមរបស់ទ្រង់ ថ្លែងទីបន្ទាល់អំពីសេចក្ដីមេត្តាករុណារបស់ព្រះអង្គ។ល។ លើសពីនេះ ខ្ញុំបានរកឃើញថា ការទទួលនូវបទពិសោធន៍ពីមនុស្សជុំវិញខ្លួនក្នុងការថ្វាយបង្គំ ខ្ញុំអាចទទួលបានការលើកទឹកចិត្តឲ្យខ្ញុំថ្វាយបង្គំដោយអស់ពីចិត្តថែមទៀត។ វាពិតជាប៉ះពាល់ចិត្តដែលបានមកថ្វាយបង្គំ និងឃើញវត្តមានគ្រួសារដែលទើបតែបាត់បង់មនុស្សជាទីស្រឡាញ់ ហើយឃើញពួកគេថ្វាយបង្គំដោយអស់ពីកម្លាំង។ វាពិតជាលើកទឹកចិត្តអ្នកជុំវិញខ្លួន។ ដោយឃើញលោកយាយ កូនស្រី និងចៅស្រីឈរក្បែរគ្នា ច្រៀងចម្រៀងថ្វាយព្រះអម្ចាស់រួមគ្នាជំរុញទឹកចិត្តអ្នកដទៃឲ្យថ្វាយបង្គំដោយអស់ពីចិត្ត។ ប្រយោជន៍ដែលទទួលបានពីការថ្វាយបង្គំរួមគ្នាមានភាពធំធេងយ៉ាងខ្លាំង។ វាពិតជាសំខាន់ណាស់សម្រាប់ជីវិតរបស់យើងដែលមានឱកាសធ្វើការប្រាស្រ័យទាក់ទងគ្នាបែបនោះនៅក្នុងការថ្វាយបង្គំ។

## ការផ្លាស់ប្ដូរយ៉ាងខុសឆ្គង ពីការថ្វាយបង្គំរួមគ្នាទៅជាការថ្វាយបង្គំផ្ទាល់ខ្លួន

គួរឲ្យសោកស្ដាយពេកហើយនៅក្នុងករណីជាច្រើននៃ «ការថ្វាយបង្គំសហសម័យ» ក្រុមជំនុំបានផ្លាស់ប្ដូរពេលវេលានៃការថ្វាយបង្គំជុំគ្នាទៅជាការថ្វាយបង្គំផ្ទាល់ខ្លួនសម្រាប់ក្រុមជំនុំទៅវិញ។ ដោយការបិទភ្លើង អ្នកមិនអាចឃើញនរណាម្នាក់នៅជុំវិញអ្នកទេ ហើយដោយសម្លេងខ្លាំងពេកអ្នកមិនអាចឮសម្លេងមនុស្សជុំវិញអ្នកបានទេ។ ជាការសរុបមកវាបដិសេធវត្តមានភាពនៃការប្រជុំគ្នារបស់រូប

១៤ លោក Steven Brooks.

កាយដែលធ្វើដំណើរជាមួយគ្នានៅក្នុងសកម្មភាពនៃការថ្វាយបង្គំនេះនៅពេលដែលអ្នកមិនអាចមើលឃើញ ឬស្តាប់អ្នកថ្វាយបង្គំរួមគ្នាជាមួយអ្នក។ មានពេលខ្លះដែលខ្ញុំឃើញក្រុមជំនុំបែរមុខរកគ្នាទៅវិញទៅមកនៅពេលពួកគេច្រៀងបទចម្រៀងទីបន្ទាល់ដោយប្រកាសពីតម្លៃរបស់ព្រះដល់គ្នាទៅវិញទៅមកដើម្បីជួយពួកគេឲ្យទទួលស្គាល់ថា យើងនៅជាមួយគ្នា។ យើងទទួលបានការដាស់តឿន លើកទឹកចិត្តកម្សាន្តចិត្ត និងអ្វីៗជាច្រើនទៀតនៅក្នុងពេលថ្វាយបង្គំជួបជុំគ្នា។

**ញឹកញាប់ពេកហើយ ដែលអ្នកថ្វាយបង្គំបែរជាធ្វើការថ្វាយបង្គំផ្ទាល់ខ្លួននៅក្នុងស្ថានភាពនៃការថ្វាយបង្គំជុំគ្នាទៅវិញ។ តើយើងដែលជាអ្នកដឹកនាំការថ្វាយបង្គំបង្កឲ្យមានបញ្ហានេះកើតឡើងដោយរបៀបណា? តើយើងអាចដោះស្រាយបញ្ហានេះដោយរបៀបណា?**

## របៀបដែលការថ្វាយបង្គំផ្ទាល់ខ្លួនជួយដល់ការថ្វាយបង្គំរួមគ្នា

ខ្ញុំត្រូវតែផ្អាកនៅត្រង់នេះសិន ដើម្បីចង្អុលបង្ហាញរឿងមួយចំនួនអំពីការថ្វាយបង្គំផ្ទាល់ខ្លួនដែលទាក់ទងនឹងការថ្វាយបង្គំរួមគ្នា ។

សមត្ថភាពរបស់យើងក្នុងការដឹកនាំការថ្វាយបង្គំរួមគ្នា ពឹងផ្អែកយ៉ាងខ្លាំងលើការដើរផ្ទាល់ខ្លួនរបស់យើងជាមួយព្រះ។ យើងមិនអាចនាំមនុស្សទៅកន្លែងដែលយើងមិនធ្លាប់ទៅនៅទីនោះនោះទេ។ យើងត្រូវតែមានបទពិសោធន៍ជាមួយនឹងព្រះក្នុងការថ្វាយបង្គំពេញមួយសប្តាហ៍ នោះទើបយើងអាចដឹកនាំចេញពីការនៅជាមួយព្រះអម្ចាស់របស់យើង។ យើងអាចបង្ហាញមនុស្សពីភាពអស្ចារ្យរបស់ព្រះបានលុះត្រាតែយើងបានពិសោធភាពអស្ចារ្យនោះដោយខ្លួនឯងជាមុនសិន។

ដើម្បីពន្យល់បង្ហាញពីចំណុចនេះបន្ថែមទៀតជារឿយៗខ្ញុំបង្ហាញការដកស្រង់វីដេអូសុវត្ថិភាពរបស់ក្រុមហ៊ុនអាកាសចរណ៍ អំពីរបាំងអុកស៊ីហ្សែនដែលទម្លាក់ចុះក្រោមក្នុងករណីមានអាសន្ននៅក្នុងយន្តហោះ។ អ្នកបម្រើការលើយន្តហោះនិយាយថា «អ្នកត្រូវដាក់របាំងអុកស៊ីហ្សែនរបស់អ្នកជាមុនសិន មុននឹងព្យាយាមជួយអ្នកដែលនៅជុំវិញអ្នក»។ យើងជាអ្នកដឹកនាំការថ្វាយបង្គំត្រូវតែបានបំពាក់ចូលទៅក្នុងអុកស៊ីហ្សែន-អំណាចនៃព្រះ-តាមរយៈការថ្វាយបង្គំមុនពេលយើងអាចជួយអ្នកដទៃពាក់របាំងអុកស៊ីហ្សែនរបស់ពួកគេ-បទពិសោធន៍របស់ពួកគេក្នុងការថ្វាយបង្គំដែលជួបជុំគ្នា។

ការថ្វាយបង្គំផ្ទាល់ខ្លួនគឺជាតម្រូវការជាមុនសម្រាប់ការថ្វាយបង្គំរួមគ្នា។ ការពន្យល់ពីមុនពិភាក្សាអំពីរបៀបដែលនេះជាការពិតសម្រាប់អ្នកដឹកនាំថ្វាយបង្គំប៉ុន្តែសូមយល់ថាវាសំខាន់ណាស់សម្រាប់ក្រុមជំនុំ។ ប្រសិនបើពួកគេមិនបានជួបជាមួយព្រះតាមរយៈពេលវេលានៃការថ្វាយបង្គំផ្ទាល់ខ្លួនពេញមួយសប្ដាហ៍ទេ នោះពួកគេទំនងជានឹងមិនអាចនាំមកនូវការសរសើរតម្កើងហើយនិងការថ្វាយបង្គំព្រះរួមគ្នាជារៀងរាល់សប្ដាហ៍នោះទេ។ ការនេះនាំឲ្យមានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម៖

អ្នកគួរតែថ្វាយបង្គំព្រះរួចស្រេច មិនមែនមកព្រះវិហារដើម្បីរៀបចំចាប់ផ្ដើមការថ្វាយបង្គំនោះទេ។ លុះត្រាតែយើងមានពេលមួយសប្ដាហ៍ដែលពោរពេញដោយការថ្វាយបង្គំ យើងមកដល់ព្រះវិហារត្រៀមខ្លួនរួចជាស្រេចដើម្បីចូលរួមក្នុងពេលវេលាដ៏អស្ចារ្យនៃការសរសើរតម្កើង និងថ្វាយបង្គំព្រះរបស់យើង។ ម្យ៉ាងវិញទៀតនៅពេលដែលយើងចេញពីដំណាក់កាលដែលមិនមានពេលវេលាផ្ទាល់ខ្លួនជាមួយព្រះទេ នោះយើងក៏មានអារម្មណ៍ថាទទេ ហើយមិនមានអ្វីផ្ដល់ឲ្យក្នុងអំឡុងពេលថ្វាយបង្គំរួមគ្នា។

**តើជីវិតថ្វាយបង្គំផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗនៅក្នុងក្រុមជំនុំរបស់អ្នកមានឥទ្ធិពលយ៉ាងណាទៅលើពេលវេលានៃការថ្វាយបង្គំរួមគ្នា? តើជីវិតថ្វាយបង្គំផ្ទាល់ខ្លួនរបស់អ្នកប៉ះពាល់ដល់សមត្ថភាពដឹកនាំការថ្វាយបង្គំយ៉ាងដូចម្ដេច? ប្រសិនបើក្រុមជំនុំរបស់អ្នកអាចជួយមនុស្សឲ្យប្រសើរឡើងនូវជីវិតនៃការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេ តើវានឹងផ្ដល់អត្ថប្រយោជន៍យ៉ាងណាចំពោះការថ្វាយបង្គំរួមគ្នានៃពួកជំនុំរបស់អ្នក?**

# បរិបទ៤នៃការថ្វាយបង្គំ

ការថ្វាយបង្គំកើតឡើងនៅក្នុងចំណោមក្រុមមនុស្សផ្សេងគ្នាដែលយើងនឹងហៅថា «បរិបទ» ។ យើងនឹងពិនិត្យមើលបរិបទទាំងបួនខាងក្រោមនេះ ហើយកំណត់ពីរបៀបដែលវាផ្ដល់ប្រយោជន៍ដល់ជីវិតនៃការថ្វាយបង្គំរួមគ្នា និងផ្ទាល់ខ្លួនរបស់យើង។ បរិបទនីមួយៗមានភាពខុសពីគ្នា ហើយអ្នកដឹកនាំការថ្វាយបង្គំគួរតែដឹងយ៉ាងច្បាស់អំពីអត្ថប្រយោជន៍ និងលក្ខណៈរបស់វាដែលធ្វើឲ្យវាមានលក្ខណៈ

ពិសេស។ (គំនិតទាំងនេះត្រូវបានរៀបរៀងឡើងជាលើកដំបូងដោយ ស៊ីដ ហៀលេម៉ា (Syd Hielema) ហើយបន្ទាប់មកត្រូវបានពន្យល់ពង្រីកបន្ថែមទៀតដោយលោក ប៉ូល ខ្លាក (Paul Clark, Jr.)។ ខ្ញុំបានធ្វើការសម្របវាផងដែរ។ សម្រាប់ការពង្រីកដ៏ល្អលើបរិបទទាំងនេះ សូមពិនិត្យមើលសៀវភៅរបស់ លោក ស្ទីវិន ប្រ៊ូក (Steven Brooks) ដែលមានចំណងជើងថា ស្វែងរកការថ្វាយបង្គំ (Worship Quest)។[១៥] )

## ១.ការថ្វាយបង្គំឯកជន (ការថ្វាយបង្គំតែឯង)

ការថ្វាយបង្គំឯកជនគឺជាពេលវេលាដែលមានតែអ្នក ហើយនឹងព្រះចំណាយពេលជាមួយគ្នាក្នុងការថ្វាយបង្គំ។ នេះជាបរិបទដែលការថ្វាយបង្គំផ្ទាល់ខ្លួនក្នុងភាពដាច់ដោយឡែកកើតឡើង។ ការថ្វាយបង្គំបែបនេះអាចបង្ហាញចេញនៅក្នុងពេលវេលាដែលបានកំណត់ពេលនៃការអធិស្ឋាន និងអានព្រះគម្ពីររៀងរាល់ព្រឹក ច្រៀងចម្រៀងថ្វាយបង្គំក្នុងអំឡុងពេលធ្វើដំណើរពេលព្រឹករបស់អ្នក ឬក្នុងការឡើងលើភ្នំ ទាំងទំនាក់ទំនងជាមួយព្រះនៅពេលអ្នករកពេលវេលានៅឆ្ងាយពីភាពមមាញឹកនៃជីវិត។ នៅក្នុងការថ្វាយបង្គំឯកជនអ្នកកំពុងធ្វើឲ្យពេលវេលាជាមួយព្រះជាអាទិភាពជាពេលវេលាដើម្បីជំរុញព្រលឹងរបស់អ្នកឲ្យនៅជាប់ជាមួយនឹងវត្តមានរបស់ទ្រង់។ គម្ពីរ ទំនុកតម្កើង ៤៦:១០ ចែងថា៖ «ចូរនៅស្ងៀម ហើយដឹងថាយើងជាព្រះ»។ គួរឲ្យស្តាយជីវិតសព្វថ្ងៃនេះគឺស្ថិតក្នុងល្បឿនមួយដែលគ្រីស្ទបរិស័ទជាច្រើនមិនអើពើនឹងបរិបទសំខាន់នៃការថ្វាយបង្គំព្រះអម្ចាស់។ ដូចដែលខ្ញុំបាននិយាយនៅក្នុងផ្នែកស្តីពីការថ្វាយបង្គំផ្ទាល់ខ្លួន ការថ្វាយបង្គំឯកជនជួយយើងរៀបចំខ្លួនសម្រាប់ពេលវេលានៃការថ្វាយបង្គំជាមួយអ្នកជឿដទៃទៀត។

**តើអ្នកបានចូលរួមជាប្រចាំក្នុងពេលថ្វាយបង្គំតែឯងឬទេ? តើអ្នកកំពុងលើកទឹកចិត្តអ្នកក្រោមការយកចិត្តទុកដាក់របស់អ្នកឲ្យធ្វើដូចគ្នាដែរទេ?**

---

១៥ ជាចម្បង ការយល់ដឹងអំពីបរិបទទាំងបួននេះគឺដកចេញពីការនិពន្ធរបស់លោក Syd Hielema និងលោក Paul Clark, Jr., និងលោក Steven Brooks. លោកអ្នកនឹងឃើញព័ត៌មានបន្ថែមអំពីធនធានយ៉ាងនេះនៅក្នុងការនិពន្ធ។

## ២.ការថ្វាយបង្គំក្រុមតូច

នៅក្នុងបរិបទនេះ មនុស្សមួយចំនួនតូចដែលស្គាល់គ្នាទៅវិញទៅមកបានមកជួបជុំគ្នា ហើយថ្វាយបង្គំ ទោះជាគោលបំណងចម្បង ឬជាផ្នែកមួយនៃការជួបជុំផ្សេងទៀតក៏ដោយ។ ជាឧទាហរណ៍ អ្នកជាក្រុមមនុស្សដែលប្រមូលផ្តុំគ្នាសម្រាប់យប់លេងហ្គេមកម្សាន្តនៅផ្ទះរបស់អ្នក ហើយមនុស្សដែលមានពេលអធិស្ឋាន ឬច្រៀងជាមួយគ្នា មិត្តរួមការងារប្រមូលផ្តុំគ្នា៣០នាទី មុនពេលចាប់ផ្តើមនៃថ្ងៃធ្វើការសម្រាប់ពេលវេលាជញ្ជឹងគិតព្រះបន្ទូលជាមួយគ្នា ក្រុមគ្រួសារជួបជុំគ្នាសម្រាប់ការអានព្រះគម្ពីរ និងការអធិស្ឋានជារៀងរាល់ថ្ងៃ ហើយក្រុមជំនុំមួយក្រុមតូចប្រមូលផ្តុំគ្នាសម្រាប់ការសិក្សាព្រះគម្ពីរ ការអធិស្ឋាន និងការច្រៀងជាដើម។ មានបរិបទនៃការថ្វាយបង្គំជាក្រុមតូចៗជាច្រើននៅក្នុងព្រះវិហាររបស់អ្នក ដូចជាក្រុមបុរស ឬស្ត្រី ក្រុមថ្នាក់ថ្ងៃអាទិត្យ ក្រុមបង្កើតសិស្ស ក្រុមព្រឹក្សាយោបល់ដើម្បីដោះស្រាយបញ្ហាជាដើម។ យើងដែលជាអ្នកដឹកនាំនៃការថ្វាយបង្គំមានឱកាសដើម្បីលើកទឹកចិត្តដល់ការថ្វាយបង្គំជាក្រុមតូចៗក្នុងផ្នែកបន្ថែមជាច្រើននៃព័ន្ធកិច្ចថ្វាយបង្គំ ដូចជាក្រុមថ្វាយបង្គំ ក្រុមចម្រៀង និងក្រុមបច្ចេកទេសជាដើម។ ដូចនឹងការថ្វាយបង្គំឯកជនដែលជួយមនុស្សរៀបចំខ្លួនសម្រាប់ការថ្វាយបង្គំរួមគ្នាដែរ ការថ្វាយបង្គំជាក្រុមតូចក៏ដូចគ្នាដែរ។ ក្រុមតូចៗទាំងនេះផ្តល់ឱកាសសម្រាប់ការអធិស្ឋាន ការសិក្សា និងការច្រៀងដ៏ស្និទ្ធស្នាល ហើយក៏ជាបរិយាកាសដ៏ល្អសម្រាប់ភាពមានទំនួលខុសត្រូវ និងភាពជាសិស្សផងដែរ។

លោក ស៊ីដ ហៀលេម៉ា (Sid Hielema) ធ្វើការសង្កេតទាំងនេះអំពីបរិបទនៃការថ្វាយបង្គំនេះ៖

> *លក្ខណៈសម្គាល់ចម្បងនៃការថ្វាយបង្គំ (ក្រុមតូច) គឺសមត្ថភាពក្នុងការធ្វើឲ្យទំនាក់ទំនងរវាងបុគ្គលម្នាក់ៗកាន់តែស៊ីជម្រៅ។ វាងាយស្រួលឲ្យមនុស្សវង្វេងនៅក្នុងក្រុមជំនុំដែលមានសមាជិក ២៥០នាក់នៅព្រឹកថ្ងៃអាទិត្យ ប៉ុន្តែគ្មាននរណាម្នាក់ត្រូវបានគេមើលរំលងនៅក្នុងការកំណត់ (ក្រុមតូច) ណាមួយនោះទេ។ បរិយាកាសទាំងនេះអនុញ្ញាតឲ្យយើងក្លាយជាមានតម្លាភាព និងងាយទទួលយកគ្នា។ នៅក្នុងតម្លាភាពនោះយើងមើលកាន់តែច្បាស់ក្នុងព្រះវត្តមាននៃព្រះគុណរបស់ព្រះដោយនាំមកទាំងការឈឺចាប់ និងការបែកបាក់នៅក្នុងជីវិតរបស់យើងម្នាក់ៗ។ នៅពេលដែលយើងម្នាក់ៗបើកចំហចិត្តនៅក្នុងក្រុមតូចនោះបង្កើតឲ្យមានភាពជិតស្និតគ្នាជាងមុន ហើយ*

*មានទំនាក់ទំនងកាន់តែល្អប្រសើរ។ នៅពេលដែលយើងថ្វាយបង្គំព្រះរួមគ្នា គឺមានព្រះវត្តមានរបស់ព្រះនៅក្នុងគ្រប់សកម្មភាពនៃក្រុមរបស់យើង។ ខ្ញុំចាំបានថា មានពេលមួយខណៈកំពុងដឹកនាំក្រុមចម្រៀងនៃក្រុមជំនុំរបស់យើង នៅពេលយើងកំពុងហាត់សមច្រៀងបទ្ទរពីរបទក្នុងទំនុកព្រះមេស្ស៊ីរបស់ ហានដែល (*Handel's Messiah*) នៅក្នុងខែធ្នូមួយ ខណៈពេលដែលយើងច្រៀងមានស្ត្រីម្នាក់នៅជួរទីពីរបានចាប់ផ្តើមយំដោយស្ងៀមស្ងាត់ ហើយយើងបានដឹងពីមូលហេតុះ កាលបីសប្តាហ៍មុន ប្អូនប្រុសរបស់នាងបានស្លាប់ទាំងវ័យក្មេង ហើយតន្ត្រីបានអនុញ្ញាតឲ្យទុក្ខសោករបស់នាងលេចចេញមក។ នៅពេលយើងបន្តច្រៀងដោយដាក់ដៃនៅជាប់នឹងនាង ហើយទប់កាន់នាង ខណៈពេលដែលភ្នែកផ្សេងទៀតនៅជុំវិញបន្ទប់សុទ្ធតែបង្ហូរទឹកភ្នែកដោយក្តីមេត្តាចំពោះទុក្ខសោករបស់នាង ហើយពួកគេយំព្រោះនឹកចាំពីទុក្ខសោកអតីតកាលរបស់គេ។ យើងជាក្រុមចម្រៀងបន្តក្នុងការហាត់សម ប៉ុន្តែនៅទីនោះយើងក៏បានក្លាយជា (ក្រុមតូច) ដែលកំពុងថ្វាយបង្គំ។ [១៦]*

> តើអ្នកបានចូលរួមជាទៀងទាត់ក្នុងការជួបជុំជាក្រុមតូចដើម្បីថ្វាយបង្គំឬទេ? ការនេះគឺសំខាន់សម្រាប់ការលូតលាស់ខាងវិញ្ញាណរបស់អ្នក។ តើអ្នកកំពុងបង្កើតសម្រាប់ការថ្វាយបង្គំលើសពីគ្រាន់តែការរៀបចំដឹកនាំអ្នកដទៃ។ ម្យ៉ាងទៀតតើអ្នកកំពុងដឹកនាំក្រុមតូចទាំងនេះឲ្យមានពេលថ្វាយបង្គំជាផ្លូវការ ឬមិនផ្លូវការឬទេ?

## ៣.ការថ្វាយបង្គំក្នុងក្រុមជំនុំ

ការថ្វាយបង្គំជាក្រុមជំនុំគឺជាការជុំគ្នាថ្វាយបង្គំប្រចាំសប្តាហ៍។ ការកំណត់ទីតាំងទាំងនេះទំនងជាត្រូវបានចូលរួមដោយមនុស្សជាច្រើនជំនាន់ និងប្រហែលជាជនជាតិផ្សេងៗគ្នាផងដែរ។ មានមនុស្សដែលមានលក្ខណៈដូចគ្នាច្រើន និងមនុស្សដែលមានលក្ខណៈដូចគ្នាតិចតួច។ មានមិត្តភក្តិជិតស្និទ្ធ និងខ្លះទៀតដែលអ្នកមិនចូលចិត្តមិនអាចចូលរួមជាមួយ។ ការថ្វាយបង្គំជាក្រុមគឺជាការផ្តោតអារម្មណ៍របស់

---

១៦ លោក Syd Hielema, “The Festival-Envy Syndrome: Four Contexts of Worship”, Reformed Worship 71 (ឆ្នាំ២០០៤). Worship Ministries of the Reformed Church. ប្រើប្រាស់ដោយមានការអនុញ្ញាត។

អ្នកដឹកនាំការថ្វាយបង្គំភាគច្រើនក្នុងការបង្កើតការជួបជុំធំប្រចាំសប្តាហ៍។ ព្រះវិហារមួយចំនួនសាងសង់កន្លែងប្រជុំពិសេសសម្រាប់បរិបទនៃការថ្វាយបង្គំនេះ ហើយចំណាយពេល និងធនធានជាច្រើន ដើម្បីធ្វើឲ្យកម្មវិធីថ្វាយបង្គំប្រចាំសប្តាហ៍នេះកើតមានឡើង។ យើងឃើញក្រុមជំនុំដំបូងប្រមូលផ្តុំសម្រាប់ការថ្វាយបង្គំជាក្រុមជំនុំ ហើយការអនុវត្តបានបន្តពេញមួយសតវត្ស។

ភាពចម្រុះគ្នានៃមនុស្ស និងបញ្ហាប្រឈមក្នុងជីវិត និងការអបអរសាទររបស់ពួកគេធ្វើឲ្យការថ្វាយបង្គំជាក្រុមជំនុំប្រហែលជាពិបាកបំផុត ក្នុងចំណោមបរិបទនៃការថ្វាយបង្គំទាំងអស់។ អ្នកដឹកនាំការថ្វាយបង្គំព្យាយាមនិយាយទៅកាន់មនុស្សគ្រប់គ្នាដើម្បីជួយពួកគេក្នុងដំណើរនៃការថ្វាយបង្គំរបស់ពួកគេ ទោះបីជាមានចំណង់ចំណូលចិត្តចំពោះរចនាបថតន្ត្រី និងស្ថានភាពជីវិតបច្ចុប្បន្នខុសៗគ្នាក៏ដោយ។ មនុស្សមួយចំនួនត្រៀមខ្លួនដើម្បីអបអរនូវអ្វីដែលព្រះកំពុងធ្វើនៅក្នុងជីវិតរបស់ពួកគេខណៈពេលដែលអ្នកផ្សេងទៀតកំពុងឆ្លងកាត់ការឈឺចាប់ខ្លាំង ហើយត្រូវការការកម្សាន្តចិត្តដែលមានតែព្រះមួយអង្គប៉ុណ្ណោះទើបអាចនាំប្រទានមកបាន។ ខ្ញុំចូលចិត្តការពិពណ៌នាដោយលោក ជីម អាល់ថៃស៊ើរ (Jim Altizer) ដូច្នេះ៖

> *សាវ័កប៉ុលបានពណ៌នាអំពីរូបកាយរបស់ព្រះគ្រីស្ទមិនមែនថាមានច្រើនដូចគ្នាទេ ប៉ុន្តែត្រូវបានផ្សំឡើងដោយមនុស្សចាស់ និងក្មេង (ទីតុស ២:២–៦); អ្នកមាន និងអ្នកក្រ (១កូរិនថូស ១១:២១-២២) អំណោយទានផ្សេងៗគ្នា (១កូរិនថូស ១២:៤); លាយឡំក្នុងពូជសាសន៍ ភេទ និងឋានៈ (កាឡាទី ៣:២៨; ១កូរិនថូស ១២:១៣)។ វាគឺជាការងាយស្រួលជាងដែលអ្នកផ្តោតលើការបម្រើក្នុងព្រះវិហារនៅក្នុងក្រុមណាមួយជាក់លាក់ ប៉ុន្តែសាវ័កប៉ុលធ្វើឲ្យករណីនេះទៅជាភាពដូចគ្នា ពិតជាធ្វើឲ្យរូបកាយរបស់ព្រះគ្រីស្ទចុះខ្សោយ (១កូរិនថូស ១២:១៩)។ ម្យ៉ាងវិញទៀត ការរួបរួមគ្នាបញ្ជាក់ទាំងសេចក្តីពិត និងសេចក្តីស្រឡាញ់របស់ព្រះ។ ការរួបរួមក្នុងភាពចម្រុះគឺជាមាគ៌ារបស់ព្រះគ្រីស្ទ។ ហេតុដូច្នេះហើយនៅពេលដែលអ្នកខាងក្រៅបានឃើញអ្នករាំរបាំបុរាណ ក្រុមក្មេងជំទង់ គ្រូពេទ្យ និងអ្នកធ្វើការងារផ្សេងៗទាំងអស់ដែលមកថ្វាយបង្គំរួមគ្នាពួកគេជឿជាក់លើព្រះយេស៊ូវថាទ្រង់ជាព្រះពិត ហើយនិងសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះប្រជារាស្ត្ររបស់ព្រះអង្គ។ ពួកគេដឹងថា*

*មានរឿងអព្ភូតហេតុកំពុងកើតឡើង។* [១៧]

យើងនឹងពិភាក្សាបន្ថែមទៀតអំពីការស្វែងរកការរួបរួមក្នុងចំណោមភាពចម្រុះគ្នាប្រភេទនេះនៅពេលក្រោយក្នុងសៀវភៅនេះខណៈដែលខ្ញុំនិយាយអំពីការថ្វាយបង្គំដែលបង្រួបបង្រួម។

## ៤.ការថ្វាយបង្គំក្នុងកម្មវិធីធំៗ

ការថ្វាយបង្គំក្នុងកម្មវិធីធំៗគឺជាការជួបជុំគ្នាដែលមានមនុស្សច្រើនទាក់ក្នុងគោលបំណងជាក់លាក់ណាមួយដែលមិនកើតឡើងជាទៀងទាត់នោះទេ។ ការថ្វាយបង្គំនៃការបោះជំរុំយុវជនមួយ ការជួបជុំគ្រីស្ទបរិស័ទពេញពហុកីឡដ្ឋានបាល់ទាត់កម្មវិធីសិក្ខាសាលាការថ្វាយបង្គំដ៏ឆេះឆួល និងការជួបជុំស្រដៀងគ្នាផ្សេងទៀត ឆ្លុះបញ្ចាំងពីការជួបជុំគ្នាក្នុងពិធីធំៗ។ លោក ប៉ូល ក្លាក ជុនយើរ (Paul Clark, Jr.) ពណ៌នាបែបនេះថា៖

> *. . . មានស្ថានភាពល្បីល្បាញនៃបុគ្គលជាច្រើននៅលើវេទិកា។ នៅក្នុងព្រឹត្តិការណ៍នីមួយៗវាទំនងណាស់ថាអ្នកចូលរួមភាគច្រើនមិនបានស្គាល់គ្នានោះទេ ប៉ុន្តែបានចែករំលែកការផ្តោតអារម្មណ៍រួមគ្នា ដែលរៀបចំពួកគេសម្រាប់ថាមពលខ្ពស់ អារម្មណ៍ពុះកញ្ជ្រោលខ្ពស់ដែលកំណត់លក្ខណៈនៃការជួបជុំបែបនេះ ហើយប្រហែលជាកម្មវិធីបោះជំរុំធំៗប្រភេទនេះធ្វើឲ្យពួកគេនឹកចាំក្នុងចិត្តក្រោយពេលគ្រប់យ៉ាងត្រូវបញ្ចប់ . . . នៅក្នុងការជួបជុំបែបនេះ (ភាគច្រើន) មនុស្សដែលបានជួបជុំគ្នា គឺជាមនុស្សដែលស្គាល់គ្នាពីមុនមក ហើយបែបនេះគឺមានរឿងរ៉ាវដែលទាក់ទងគ្នាតិចតួចណាស់។ អ្នកចូលរួមស្គាល់អ្នកដឹកនាំល្បីដោយសារកេរ្តិ៍ឈ្មោះ ដែលបន្ថែមលើការរំពឹងទុក និងថាមពលនៃហ្វូងមនុស្សដែលបានប្រមូលផ្តុំ ដូច្នេះប៉ះពាល់ដល់អ្នកចូលរួមម្នាក់ៗផងដែរ. . .*
>
> *ការជួបជុំថ្វាយបង្គំក្នុងពិធីធំៗជួនកាលត្រូវបានស្គាល់ដោយបទចម្រៀងដែលកំពុងល្បី ឬរចនាបថតន្ត្រី។ អ្នកចូលរួមរំពឹងថា នឹងចូលរួមក្នុងការច្រៀងបទភ្លេងទាំងនេះជាផ្នែកនៃបទពិសោធន៍ ហើយជារឿយៗចេញពីព្រឹត្តិការណ៍នានាជាមួយនឹងតន្ត្រីដែលបន្លឺសំឡេងរោទ៍នៅក្នុងត្រចៀករបស់ពួកគេ ហើយជាប់គាំងនៅក្នុងក្បាលរបស់ពួកគេ រហូតដល់ពេលដែលឮ អំពីវា*

---

១៧ លោក Jim Altizer, The Making of a Worship Leader (United States: Sound & Light Publishing, ឆ្នាំ២០១៣), ទំព័រ៥២

*ក៏រំឭកពួកគេពីការជួបជុំ ហើយសង្ឃឹមថានឹងរំឭកពួកគេពីការប្តេជ្ញាចិត្តផ្ទាល់ខ្លួនតាមដែលបានធ្វើនៅទីនោះ។ ការឈ្លោះប្រកែកគ្នានៅក្នុងក្រុមជំនុំជុំវិញរចនាបថតន្ត្រី ជារឿយៗចង្អុលទៅរចនាបថដែលបានយកមកប្រើចេញពីព្រឹត្តិការណ៍បែបនេះ «ដែលកំពុងឈ្លានពាន» របៀបរបបនៃក្រុមជំនុំរបស់យើង ការពិតគឺថា ការជួបជុំគ្នាក្នុងពិធីធំៗបានជះឥទ្ធិពលដល់ការថ្វាយបង្គំក្នុងក្រុមជំនុំអស់រយៈពេលរាប់ឆ្នាំ។* [១៨]

## ផលប៉ះពាល់នៃបរិបទទាំងបួនក្នុងការថ្វាយបង្គំ

លោក ហៀលេម៉ា (Hielema) និយាយអំពី «រោគសញ្ញាច្រណែនក្នុងពិធីធំៗ» ដែលមនុស្សស្វែងរកបទពិសោធន៍នៃការថ្វាយបង្គំក្នុងពិធីធំៗនៅក្នុងបរិបទផ្សេងទៀត។ មានការបញ្ចូលបន្ថែមពីរបៀបផ្សេងទៀតដែលធ្វើឲ្យមានភាពស្រពេចស្រពិលរវាងបរិបទទាំងបួនប្រភេទនេះផងដែរ។

### ១.បរិបទនីមួយៗក្នុងចំណោមបរិបទទាំងបួន មានការរួមចំណែក មានប្រយោជន៍ ពិសេស និងចាំបាច់ដែលត្រូវធ្វើ។

លក្ខណៈសម្គាល់សំខាន់នៃបរិបទនីមួយៗ មិនផ្តាច់មុខចំពោះតែបរិបទនោះទេ៖ សកម្មភាពក្នុងក្រុមតូចទាមទារភាពស្មោះត្រង់ ការថ្វាយបង្គំក្នុងក្រុមជំនុំផ្តល់នូវការបំផុសគំនិតហើយពិធីធំៗបង្កើតកន្លែងសម្រាប់ការងារព្រះជាអត្តភាព។ ទោះជាយ៉ាងណាក៏ដោយបរិបទនីមួយៗអាចផ្តល់អំណោយទានមួយដល់អ្នកចូលរួមតាមរបៀបដែលរឹងមាំជាង ផ្តោតអារម្មណ៍ជាង និងជាប់លាប់ក្នុងបរិបទផ្សេងទៀត។ គឺជាបរិបទមួយក្នុងចំណោមទាំងបួននោះដែលសមស្របនៅក្នុងជីវិតថ្វាយបង្គំរបស់គ្រីស្ទបរិស័ទ។ បរិបទនីមួយៗមិនអាចជំនួសគ្នាបាន និងមិនអាចកាត់ថ្លៃបានទេ។

### ២.បរិបទនីមួយៗមានគោលបំណង ពង្រឹងការថ្វាយបង្គំរបស់មនុស្សក្នុងបរិបទបីផ្សេងទៀត។

«រោគសញ្ញាច្រណែននៃពិធីធំៗ» ចង្អុលទៅកាន់ការប្រកួតប្រជែងរវាងបរិបទទាំងនេះ។ យើងក៏ឃើញមានការប្រកួតប្រជែងនេះកើតឡើងតាមរបៀបផ្សេងទៀតផងដែរ៖ អ្នកជឿនឹងនិយាយថា «ខ្ញុំមិនថ្វាយបង្គំនៅព្រះវិហារនៅថ្ងៃអាទិត្យទេ។ ខ្ញុំទៅដើរលេងក្នុងព្រៃ»។ ម្នាក់ទៀតនឹងនិយាយថា៖ «ក្រុមជំនុំ

---

១៨ លោក Syd Hielema.

ពិតរបស់ខ្ញុំគឺក្រុមអធិស្ឋានរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ដូចជាមនុស្សមិនសំខាន់ក្នុងក្រុមជំនុំនៅថ្ងៃអាទិត្យ»។ ការយល់ច្រឡំគ្នារវាងបរិបទទាំងបួនអនុញ្ញាតឲ្យការប្រកួតប្រជែងបែបនេះចម្រើនឡើង។

ផ្ទុយទៅវិញបរិបទនីមួយៗពង្រឹងអ្នកចូលរួមឲ្យថ្វាយបង្គំកាន់តែពេញលេញក្នុងបរិបទបីផ្សេងទៀត។ តម្លាភាពនៅក្នុងរវាងក្រុមតូចរំឭកយើងថាអស់អ្នកដែលយើងថ្វាយបង្គំជាមួយនៅព្រឹកថ្ងៃអាទិត្យ គឺជាកូនព្រះរួមគ្នាដែលនាំការខូចចិត្តរបស់ពួកគេមកចំពោះព្រះគុណរបស់ព្រះ ទោះបីជាវាមិនច្បាស់សម្រាប់យើងក្នុងបរិបទនោះក៏ដោយ។ ពេលវេលានៃការនៅដោយឡែករបស់យើង (ឯកជន) ដោះលែងយើងឲ្យមានតម្លាភាពកាន់តែច្រើននៅក្នុងក្រុមតូចរបស់យើង ។ ការបំផុសគំនិតដែលយើងទទួលបាននៅពិធីធំៗនានាចិញ្ចឹមយើងដោយក្ដីសង្ឃឹម និងថាមពលដើម្បីបន្តដំណើរដោយស្មោះត្រង់ក្នុងបរិបទបីផ្សេងទៀតពេលត្រឡប់ទៅផ្ទះវិញ។ បរិបទទាំងបួននេះមានទំនាក់ទំនងគ្នាទាំងស្រុង និងពង្រឹងគ្នាទៅវិញទៅមក។

### ៣. អ្នកថ្វាយបង្គំមានទំនោរជាអ្នកផ្ដោតអារម្មណ៍តិចតួចបំផុត ហើយរៀបចំតិចតួចបំផុតដើម្បីថ្វាយបង្គំក្នុងបរិបទនៃក្រុមជំនុំ។

ភាពផ្ទុយគ្នាដោយឡែកមួយដែលហូរចេញពីការពិភាក្សាអំពីបរិបទនៃការថ្វាយបង្គំទាំងបួននេះគឺថា ការថ្វាយបង្គំក្នុងក្រុមជំនុំមានការចូលរួមរៀងរាល់សប្ដាហ៍ច្រើនជាងបរិបទបីផ្សេងៗទៀត ប៉ុន្តែវាក៏ងាយនឹងចេញមកអាក្រក់បំផុតនៅពេលដែលមនុស្សមានការភាន់ច្រឡំនូវគោលបំណងនៃបរិបទនេះ។ ជារឿយៗអ្នកថ្វាយបង្គំសង្ឃឹមថា នឹងទទួលបាននូវការបំផុសគំនិតដូចក្នុងពិធីធំៗ ភាពស្និទ្ធស្នាលដូចក្រុមគ្រួសារ និងភាពឯកោតាមរយៈការថ្វាយបង្គំថ្ងៃអាទិត្យរបស់ពួកគេ។ សេចក្ដីសង្ឃឹមនេះត្រូវបានបន្តដោយសារ ពេលខ្លះការថ្វាយបង្គំក្នុងក្រុមជំនុំផ្ដល់នូវអត្ថប្រយោជន៍មួយចំនួនដល់កម្រិតផ្សេងៗគ្នា។ 1

**តើបរិបទទាំងនេះមានន័យយ៉ាងណាចំពោះអ្នកដឹកនាំការថ្វាយបង្គំ? តើយើងជួយក្រុមជំនុំឲ្យយល់អំពីបរិបទផ្សេងៗនៃការថ្វាយបង្គំ និងគោលបំណងរបស់បរិបទទាំងនោះយ៉ាងដូចម្តេច? តើយើងកាត់បន្ថយភាពច្របូកច្របល់ដែលយើងជាអ្នកដឹកនាំការថ្វាយបង្គំកំពុងតែបង្កឡើងតាមរយៈការដឹកនាំរបស់យើងដោយរបៀបណា (ជាពិសេសក្នុងការបង្កើតភាពមិនច្បាស់រវាងការថ្វាយបង្គំពិធីធំៗ និងការថ្វាយបង្គំក្នុងក្រុមជំនុំ)?**

## អ្នកទស្សនាការថ្វាយបង្គំ ឬអ្នកចូលរួមការថ្វាយបង្គំ?

សព្វថ្ងៃនេះជាញឹកញយក្រុមជំនុំរបស់យើងធ្វើដូចជាអ្នកសម្តែង ដោយមានអារម្មណ៍ថាក្រុមជំនុំគឺជាក្រុមអ្នកទស្សនា ដែលកំពុងមើលអ្វីដែលកំពុងកើតឡើងនៅលើឆាក។ លោក រ៉ូរី ណូឡែន (Rory Noland) សរសេរនៅក្នុងសៀវភៅរបស់គាត់មានចំណងជើងថា ការថ្វាយបង្គំនៅលើផែនដីដូចនៅស្ថានសួគ៌ (Worship on Earth as It Is in Heaven) ថា៖

> *មនុស្សទៅព្រះវិហារសម័យទំនើបនេះមានលក្ខណៈវប្បធម៌ និងមានការរអ៊ូរទាំជំនួសឲ្យការចូលរួមយ៉ាងសកម្មក្នុងការថ្វាយបង្គំ .... ការថ្វាយបង្គំបានក្លាយជាកីឡាសម្រាប់អ្នកទស្សនា។ ជាអកុសលពួកយើងជាច្រើននាក់ក៏ចូលទៅព្រះវិហារតាមរបៀបដូចគ្នានោះដែរ — ជាអ្នកសង្កេតការណ៍ធម្មតាជំនួសឲ្យការធ្វើជាអ្នកចូលរួមយ៉ាងសកម្ម។ យើងមកស្តាប់តន្ត្រី។ យើងនឹងចូលរួម ហើយច្រៀងនៅត្រង់នេះបន្តិច និងត្រង់នោះបន្តិច ប៉ុន្តែភាគច្រើនយើងមិនចូលរួមទៅវិញ ដូចជាយើងកំពុងមើលការសំដែង។ យើងធ្វើដូចជាអ្នកក្រៅ និងជាអ្នកថ្មី ដូចជាមិនមែនកូនជាទីស្រឡាញ់របស់ព្រះសោះ។ យើងរង់ចាំអ្នកណាម្នាក់ប្រាប់យើងឲ្យធ្វើបែបនោះ។ លទ្ធផលដែលច្រើនដងជាងនេះ គឺការថ្វាយបង្គំក្លាយជាងងុយដេក ដែលផ្ទុយពីការថ្វាយបង្គំដោយឆេះឆួលចំពោះព្រះ។*[១៩]

---

១៩ លោក Rory Noland, Worship on Earth As It Is in Heaven: Exploring Worship as a Spiritual

ព្រះគម្ពីរប្រាប់យើងឲ្យ «ច្រៀងចម្រៀងក្នុងចិត្តយើងថ្វាយព្រះអម្ចាស់» ហើយប្រាប់យើងអំពីឧបករណ៍ភ្លេងផ្សេងៗដែលយើងអាចប្រើបាន យើងត្រូវលើកដៃទះដៃ ព្រះគម្ពីរប្រាប់យើងឲ្យលុតជង្គង់ ឱនចុះ ក្រាបចុះ ហើយស្រែកថ្វាយបង្គំ។ យើងត្រូវបានប្រាប់ឲ្យរាំជាការបង្ហាញពីការថ្វាយបង្គំរបស់យើង។ ព្រះគម្ពីរបានចែងថា ឲ្យយើងចូលរួមក្នុងការថ្វាយបង្គំមិនមែនជាជម្រើសទេ ប៉ុន្តែជាការបង្គាប់។ ប៉ុន្តែនៅក្នុងក្រុមជំនុំជាច្រើនការថ្វាយបង្គំហាក់ដូចជាគ្រាន់តែច្រៀងមិនបានចូលដល់ក្នុងចិត្ត។ គ្មានការបង្ហាញកាយវិការ ក្រៅពីប្រហែលជាច្រៀង និងឱនក្បាលពេលអធិស្ឋាន។ សូម្បីតែនៅក្នុងការច្រៀង ក៏មានមនុស្សជាច្រើនបដិសេធមិនចូលរួម ឬច្រៀងតិចតួច។

នេះត្រឡប់ទៅការពិភាក្សាមុនអំពីកម្មបទនៃការថ្វាយបង្គំរបស់យើង។ ប្រសិនបើយើងថ្វាយបង្គំក្រុមបាល់បោះនៅពេលយើងនៅក្នុងកីឡាដ្ឋានយើងទទួលបានកាយសម្បទារឹងមាំក្នុងការបង្ហាញពីភាពស្មោះត្រង់ និងការឆេះឆួលរបស់យើង។ សេចក្តីប៉ងប្រាថ្នារបស់យើងត្រូវបានបង្ហាញជាញឹកញាប់នៅក្នុងសកម្មភាពរាងកាយរបស់យើង។ បញ្ហាគឺថាយើងតែងតែរក្សាទុកការឆេះឆួលរបស់យើងសម្រាប់រឿងផ្សេងទៀត។

## ព្រះជាទស្សនិកជន-ជាទស្សនិកជនតែមួយអង្គគត់

នៅក្នុងផ្នត់គំនិតអ្នកប្រើប្រាស់នាពេលបច្ចុប្បន្ននេះជាញឹកញាប់យើងឃើញការថ្វាយបង្គំរួមគ្នានៅក្នុងតួនាទីទាំងនេះ៖

- **មនុស្សនៅក្នុងក្រុមជំនុំគឺជាទស្សនិកជន។** ពួកគេនៅទីនោះដើម្បីសង្កេតមើលអ្វីដែលកំពុងកើតឡើងនៅលើឆាក។ ពួកគេបានក្លាយទៅជាអសកម្មដោយគ្រាន់តែសង្កេតមើល «ការសម្តែង» ដែលផលិតដោយអ្នកដឹកនាំការថ្វាយបង្គំ។
- **អ្នកដឹកនាំការថ្វាយបង្គំគឺជាតារាសម្តែង។** ពួកគេកំពុងតែសម្តែងសម្រាប់ក្រុមជំនុំដោយផ្តល់ឲ្យពួកគេនូវការសម្តែងដែលមានគុណភាព។ តន្ត្រីដ៏ពីរោះ និងការអធិប្បាយដ៏អស្ចារ្យគឺជាបទដ្ឋាន។
- **ព្រះគឺជាអ្នកជំរុញនៃការថ្វាយបង្គំ។** ទ្រង់កំពុងជួយអ្នកដឹកនាំការថ្វាយបង្គំឲ្យដឹងថា បទចម្រៀងណាដែលត្រូវច្រៀង ហើយគ្រូគង្វាលត្រូវពន្យល់អំពីអ្វី។ ទ្រង់ដឹកនាំតួអង្គ/អ្នកដឹកនាំការថ្វាយបង្គំតាមរយៈកម្មវិធីថ្វាយបង្គំ។

Discipline. (United States: Zondervan, ឆ្នាំ២០១១), Kindle.

កៀក ហ្គាដ (Kierkegaard) ត្រឡប់ទៅវិញដើម្បីនិយាយអំពីការថ្វាយបង្គំតាមព្រះគម្ពីរដែលគួរតែមើលទៅដូចនេះ៖

- **មនុស្សក្នុងក្រុមជំនុំគឺជាអ្នកសម្តែង ឬអ្នកធ្វើការថ្វាយបង្គំ។** ពួកគេគឺជាអ្នកចូលរួមយ៉ាងសកម្ម ដែលកំពុងថ្វាយដល់ព្រះនូវការថ្វាយបង្គំគ្រប់ជ្រុងជ្រោយទាំង—ដួងចិត្ត ព្រលឹង គំនិត និងកម្លាំងរបស់ពួកគេ។
- **អ្នកដឹកនាំការថ្វាយបង្គំគឺជាព្រះទ្រង់ជំរុញឲ្យធ្វើការថ្វាយបង្គំ។** ពួកគេណែនាំដំណើរការថ្វាយបង្គំនេះដោយរៀបចំផែនការ និងដឹកនាំបទចម្រៀង ការអធិស្ឋាន ការអានព្រះគម្ពីរ ពេលវេលានៃការធ្វើព័ន្ធកិច្ច ការអធិប្បាយ ពិធីលៀងព្រះអម្ចាស់។ល។ គោលបំណងចម្បងរបស់ពួកគេគឺត្រូវដឹកនាំក្រុមជំនុំឲ្យបានល្អដើម្បីបញ្ចេញសំឡេងថ្វាយបង្គំ និងការសរសើរដោយគ្មានការរារាំង។
- **ព្រះជាទស្សនិកជន—ជាទស្សនិកជនតែមួយអង្គគត់។** ទ្រង់កំពុងទទួលយកការថ្វាយបង្គំ និងការសរសើររបស់យើង។ ការសរសើររបស់យើងគឺជាក្លិនក្រអូបសម្រាប់ទ្រង់។

ការប្រៀបធៀបនេះរាងដាច់បន្តិចនៅទីនេះពីព្រោះព្រះទ្រង់មិនមែនគ្រាន់តែជាទស្សនិកជន-តែព្រះទ្រង់ចូលរួមជាមួយអ្នកថ្វាយបង្គំ។ អ្វីដែលការប្រៀបធៀបនេះបង្ហាញថាត្រឹមត្រូវ គឺជួយយើងឲ្យឃើញថាក្រុមជំនុំគឺជាអ្នកចូលរួមយ៉ាងសកម្មក្នុងការថ្វាយបង្គំ ហើយអ្នកដឹកនាំការថ្វាយបង្គំ (ខណៈពេលដែលថ្វាយបង្គំផងនោះ) មានកាតព្វកិច្ចចម្បងក្នុងការដឹកនាំដំណើរនៃការថ្វាយបង្គំដើម្បីជួយក្រុមជំនុំឲ្យថ្វាយបង្គំពិត។

លោក ប្រាយអិន ក្រោះប៊ី (Brian Crosby) មកពីក្រុមជំនុំវេសាយជ្រេសបាយធីរៀន (Wayside Presbyterian Church) នៅទីក្រុង ស៊ីកណល ម៉ោនធិន (Signal Mountain) រដ្ឋថែនទេស៊ី សហរដ្ឋអាមេរិក មានប្រសាសន៍យ៉ាងល្អថា៖

> *«ការថ្វាយបង្គំគឺជាការសន្ទនា-ព្រះមានបន្ទូលហើយរាស្ត្រទ្រង់ឆ្លើយតប។ ហេតុដូច្នេះហើយ ក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្មក្នុងការថ្វាយបង្គំ យើងឮការត្រាស់ហៅរបស់ព្រះឲ្យថ្វាយបង្គំទ្រង់។ យើងចូលរួមក្នុងការអានឆ្លើយឆ្លងផ្សេងៗពីបទគម្ពីរ ឬការប្រកាសនៃសេចក្តីជំនឿ។ យើងធ្វើតាមនៅក្នុងការអានព្រះបន្ទូលរបស់ព្រះនៅក្នុងព្រះគម្ពីររបស់យើងផ្ទាល់។ យើង*

*ចូលរួមដួងចិត្តរបស់យើងនៅក្នុងការអធិស្ឋានដែលត្រូវបានដឹកនាំផ្តល់មក។ យើងកត់ត្រា (ផ្លូវចិត្ត ឬជាក់ស្តែង) នៃចំណុចដែលបានបង្ហាញនៅក្នុងការអធិប្បាយ។ យើងច្រៀងទំនុកតម្កើងទំនុកបរិសុទ្ធ និងចម្រៀងខាងវិញ្ញាណដោយការគិត និងរីករាយត្រេកអរចំពោះព្រះគុណនៅក្នុងដួងចិត្តរបស់យើង។ យើងសារភាពអំពើបាបរបស់យើងដោយការយល់ដឹងដោយស្មោះអំពីភាពខូចអាក្រក់របស់យើង។ យើងនឹកចាំដើម្បីកែលម្អលើពិធីបុណ្យជ្រមុជទឹកផ្ទាល់ខ្លួនរបស់យើង នៅពេលយើងចូលរួមក្នុងពិធីបុណ្យជ្រមុជទឹករបស់អ្នកដទៃ។ យើងចូលរួមនៅក្នុងរូបកាយ និងព្រះលោហិតរបស់ព្រះយេស៊ូវនៅក្នុងពិធីលៀងព្រះអម្ចាស់ដោយចងចាំដោយសេចក្តីជំនឿការលះបង់តង្វាយធួនរបស់ទ្រង់សម្រាប់អំពើបាបរបស់យើង។ យើងទទួលយកការកម្សាន្តចិត្តយ៉ាងសកម្ម ហើយមានទំនុកចិត្តលើព្រះគុណនៃការអត់ទោសរបស់ទ្រង់។ យើងថ្វាយតង្វាយមួយភាគដប់ ហើយតង្វាយរបស់យើងជាការបង្ហាញពីការអរព្រះគុណរបស់យើងចំពោះព្រះ និងការពឹងផ្អែកលើទ្រង់។ ហើយយើងរស់នៅជាមួយនឹងសុខសាន្តដែលព្រះបានសន្យាក្នុងការប្រទានសេចក្តីមេត្តាករុណារបស់ទ្រង់។ ដូច្នេះនៅក្នុងគ្រប់ធាតុផ្សំទាំងអស់ យើងមានវត្តមាន និងយកចិត្តទុកដាក់យ៉ាងពេញលេញ»។*

*«ក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្មក្នុងការថ្វាយបង្គំ ប្រហែលជាមានការអង្គុយ ឬចលនាសមរម្យមួយចំនួនដែលត្រូវបង្ហាញ។ វាមិនមែនជារឿងចម្លែកទេក្នុងការឈរសម្រាប់ការអានព្រះបន្ទូលរបស់ព្រះដោយការគោរព (នេហេមា ៨:៥) ការឱនក្បាលដោយការអធិស្ឋានដោយរាបទាប (ទំនុកតម្កើង ៣៥:១៣) ឬលាតសន្ធឹងដៃដើម្បីទទួលការអធិស្ឋានប្រទានពរ (ជនគណនា ៦:២៤-២៦; នេហេមា ៨:៦)។ ទាំងអស់នេះគឺជាវិធីដើម្បីបង្កើនការចូលរួមទាំងបុគ្គល និងសហគមន៍ក្នុងការថ្វាយបង្គំ»។*

*«ជាជាងគ្រាន់តែជាអ្នកអង្កេតការណ៍ ឬអ្នកចូលរួមអសកម្មក្នុងការថ្វាយបង្គំព្រះត្រៃឯករបស់យើង សូមឲ្យយើងរៀបចំខ្លួនយើងសម្រាប់ការថ្វាយបង្គំដោយប្រុងប្រយ័ត្នដោយរំពឹងថាព្រះនឹងធ្វើការនៅក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់ក្នុងការថ្វាយបង្គំ ហើយចូលរួមយ៉ាងសកម្មក្នុងចិត្ត គំនិត ព្រលឹង និងកម្លាំងរបស់យើងនៅក្នុងធាតុផ្សំនីមួយៗនៃការថ្វាយបង្គំ។ ហើយនៅពេលដែលយើងក្លាយជាអ្នកចូលរួមយ៉ាងសកម្ម សូមឲ្យព្រះធ្វើការនៅក្នុងយើងនូវអ្វីដែលគាប់ព្រះហឫទ័យ នៅចំពោះព្រះនេត្រ*

*របស់ទ្រង់តាមរយៈព្រះយេស៊ូវគ្រីស្ទដែលទ្រង់បានសិរីរុងរឿងជារៀងរហូត (ហេព្រើរ ១៣:២១)»។* [២០]

**តើអ្នកមានអារម្មណ៍ថា មនុស្សក្នុងព្រះវិហាររបស់អ្នកទទួលតួនាទីជាអ្នកទស្សនាច្រើនជាងអ្នកថ្វាយបង្គំមែនទេ? ចុះអ្នកវិញ? តើយើងអាចជួយក្រុមជំនុំរបស់យើងយ៉ាងដូចម្ដេចដើម្បីឲ្យអាចបង្ហាញកាន់តែច្រើនក្នុងការសម្ដែងខាងរូបកាយនៃការថ្វាយបង្គំ?**

## របៀបលើកទឹកចិត្តការសម្ដែងខាងរូបកាយ និងសេរីភាពក្នុងការថ្វាយបង្គំ

អ្នកថ្វាយបង្គំជាច្រើនមានការស្ទាក់ស្ទើរ ក្នុងការបង្ហាញកាយវិការក្នុងការថ្វាយបង្គំដោយហេតុផលជាច្រើន រួមមាន៖

១. ការភ័យខ្លាចចំពោះអ្វីដែលអ្នកដទៃនឹងគិតចំពោះពួកគេ
២. ការមិនដឹងអំពីអត្ថបទព្រះគម្ពីរសម្រាប់ការសម្ដែងចេញខាងរូបកាយ
៣. ការធំឡើងនៅក្នុងព្រះវិហារដែលមិនបានធ្វើគំរូ ឬថែមទាំងរារាំងការសម្ដែងចេញខាងរូបកាយ
៤. ការមានអារម្មណ៍ថា ការថ្វាយបង្គំគួរតែឆ្លុះបញ្ចាំងពីការគោរព និងការកោតស្ញប់ស្ញែងប៉ុណ្ណោះ
៥. ពួកគេកំពុងចូលរួមជាមួយក្រុមជំនុំដែលមានទស្សនៈខាងគោលលទ្ធិខុសគ្នាខ្លាំង
៦. គ្មានចិត្តឆេះឆួលក្នុងការថ្វាយបង្គំរបស់ពួកគេប្រហែលជាគ្មានទំនាក់ទំនងជាមួយព្រះសោះតែម្ដង

មានវិធីជាច្រើនដែលអ្នកដឹកនាំ/គ្រូគង្វាលផ្នែកថ្វាយបង្គំអាចលើកទឹកចិត្តការសម្ដែងចេញខាងរូបកាយ ក្នុងការថ្វាយបង្គំ៖

១. **អធិប្បាយ/បង្រៀនអំពីការថ្វាយបង្គំ។** មិនថាមានសេចក្ដីអធិប្បាយពេញលេញ ឬគ្រាន់តែជាសំឡេងរំឭកញឹកញាប់នៅក្នុងកម្មវិធីនោះទេ

២០ លោក Brian Crosby, “Participation in Worship”, TableTalk Magazine, https://tabletalkmagazine.com/article/2022/01/participation-in-worship.

អ្នកដឹកនាំការថ្វាយបង្គំអាចចង្អុលប្រាប់អំពីអត្ថបទគាំទ្រក្នុងព្រះគម្ពីរដើម្បីជំរុញការចូលរួមក្នុងការថ្វាយបង្គំ។ មនុស្សជាច្រើនមិនបានដឹងអំពីភាពចាំបាច់ក្នុងគម្ពីរទេ ហើយប្រហែលជាមានអារម្មណ៍ថា ការនៅស្ងៀម និងមានការគោរពគឺជាវិធីដ៏ស័ក្តិសមក្នុងការថ្វាយបង្គំ។ ដូច្នេះចូរបង្រៀនពីភាពសមស្របនៃការសម្តែងចេញខាងរូបកាយក្នុងការថ្វាយបង្គំ និងរបៀបដែលការសម្តែងចេញនោះគួរតែហូរចេញពីបេះដូង។ ទោះបីជាភាពស្ងៀមស្ងាត់ និងការនៅស្ងៀមក៏ត្រូវបានបង្គាប់ដោយព្រះគម្ពីរមែន តែការសម្តែងចេញខាងរូបកាយក្នុងការថ្វាយបង្គំក៏គួរតែជាការអនុវត្តឲ្យបានទូលំទូលាយផងដែរ។

២. **ការអនុវត្តផ្ទាល់ខ្លួន។** មនុស្សជាច្រើនមិនបានធំឡើងនៅក្នុងក្រុមជំនុំដែលធ្វើគំរូការចូលរួមក្នុងការថ្វាយបង្គំទេហើយពួកគេអាចមានអារម្មណ៍មិនស្រួលទាក់ទងនឹងកាយវិការរបស់ពួកគេ ក្នុងការថ្វាយបង្គំ។ ការលើកទឹកចិត្តមនុស្សឲ្យមានការអនុវត្តថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេដាច់ដោយឡែកផ្តល់ឲ្យពួកគេនូវវិធីដើម្បីទទួលបានបទពិសោធន៍ផ្នែកខាងរូបកាយនៃការថ្វាយបង្គំដោយមិនភ័យខ្លាចមនុស្សជុំវិញពួកគេវិនិច្ឆ័យពួកគេ។ នៅពេលដែលពួកគេរកឃើញតម្លៃនៃការចូលរួមការថ្វាយបង្គំជាលក្ខណៈឯកជនពួកគេនឹងឃើញថា ពួកគេកាន់តែមានភាពងាយស្រួលក្នុងការសម្តែងកាយវិការនៅក្នុងកន្លែងថ្វាយបង្គំរួម។

៣. **លើកទឹកចិត្តការបញ្ចេញមតិ។** អ្នកដឹកនាំការថ្វាយបង្គំអាចអានបទគម្ពីរមួយទៅកាន់ក្រុមជំនុំ ជាឧទាហរណ៍ ការដាស់តឿនការលើកដៃជាការបង្ហាញពីការថ្វាយបង្គំហើយបន្ទាប់មកលើកទឹកចិត្តអ្នកថ្វាយបង្គំនៅពេលពួកគេច្រៀងបន្ទរនៃបទចម្រៀងសមរម្យមួយដើម្បីលើកដៃឡើងតាមការលើកទឹកចិត្តក្នុងព្រះគម្ពីរ។ ជារឿយៗការធ្វើបែបនេះនឹងផ្តល់ឲ្យមនុស្សនូវសេរីភាពក្នុងការសាកល្បងការសម្តែងចេញខាងរូបកាយរួមជាមួយនឹងក្រុមជំនុំដោយមិនមានអារម្មណ៍ថាពួកគេនឹងលេចធ្លោ។ នេះមិនគួរជាការអនុវត្តជាប្រចាំទេ ប៉ុន្តែក្នុងឱកាសម្តងម្កាលដែលរួមផ្សំនឹងការបង្រៀនអាចមានប្រសិទ្ធភាពគួរសម។

៤. **អ្នកដឹកនាំការថ្វាយបង្គំគួរតែធ្វើគំរូការថ្វាយបង្គំខាងរូបកាយ។** នៅពេលដែលក្រុមថ្វាយបង្គំ និងក្រុមចម្រៀងក្លាយជាការបង្ហាញក្នុងអនុវត្តការថ្វាយបង្គំរបស់ពួកគេក្រុមជំនុំនឹងកាន់តែមានភាពងាយស្រួលក្នុងការបង្ហាញការថ្វាយបង្គំរបស់ពួកគេកាន់តែខ្លាំង។ ផ្ទុយទៅវិញនៅពេល

ដែលអ្នកដឹកនាំការថ្វាយបង្គំកាន់តែមានជំហររឹងប៉ឹងក្នុងការដឹកនាំការថ្វាយបង្គំនោះក្រុមជំនុំនឹងឆ្លុះបញ្ចាំងពីភាពខ្ទះការចូលរួមរបស់ពួកគេ។ ខ្ញុំនឹងពិភាក្សាលម្អិតអំពីរឿងនេះនៅពេលក្រោយនៅក្នុងសៀវភៅនេះ។

៥. **គ្រូគង្វាលដឹកនាំជាគំរូនៃសេរីភាពក្នុងការថ្វាយបង្គំ។** ក្រុមជំនុំមើលឃើញថា គ្រូគង្វាលជាន់ខ្ពស់របស់ពួកគេជាអ្នកដឹកនាំការថ្វាយបង្គំចម្បងនៃក្រុមជំនុំតាមវិធីជាច្រើន។ ប្រសិនបើគ្រូគង្វាលមិនបានបង្ហាញអារម្មណ៍ក្នុងការថ្វាយបង្គំរបស់គាត់ ក្រុមជំនុំទំនងជាធ្វើតាម។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើគាត់បង្ហាញគំរូនៃការសម្តែងចេញខាងរូបកាយនោះក្រុមជំនុំនឹងមានអារម្មណ៍ថាមានសេរីភាពច្រើនជាងក្នុងការថ្វាយបង្គំ។ ខ្ញុំបានឃើញគ្រូគង្វាលដែលរវល់អានសំណេរអធិប្បាយរបស់ពួកគេអំឡុងពេលនៃការប្រគំតន្ត្រីបង្គំ។ នេះទាក់ទងទៅក្រុមជំនុំថា ផ្នែកនៃការថ្វាយបង្គំនេះមិនសំខាន់ទេ។ គ្រូគង្វាលដែលខ្ញុំបានបម្រើជាមួយអស់ជាច្រើនឆ្នាំ គឺជាអ្នកថ្វាយបង្គំដ៏ឆេះឆួលម្នាក់ដែលបង្ហាញអំពីការថ្វាយបង្គំរបស់គាត់យ៉ាងពិតប្រាកដ។ នេះបាននិយាយដល់ក្រុមជំនុំដែលរកឃើញសេរីភាពកាន់តែច្រើនក្នុងការថ្វាយបង្គំរបស់ពួកគេ ដោយសារគ្រូគង្វាលធ្វើគំរូក្នុងការអនុវត្តការថ្វាយបង្គំ។

៦. **ចូលរួមចលនាកាយវិការ ឬក្រុមរាំក្នុងការថ្វាយបង្គំ។** មនុស្សដែលមានអំណោយទានក្នុងរឿងនេះអាចជួយឲ្យការថ្វាយបង្គំមានជីវិតរស់រវើកនៅពេលពួកគេបកស្រាយពាក្យដោយប្រើកាយវិការ។ ការមើលឃើញការថ្វាយបង្គំតាមរបៀបនេះអាចនាំឲ្យក្រុមជំនុំមានសេរីភាពកាន់តែច្រើន។

៧. **ចលនារាងកាយអាចជាផ្នែកមួយនៃការថ្វាយបង្គំតាមរយៈការថ្វាយដង្វាយពិធីលៀងព្រះអម្ចាស់ ឬពេលបំពេញព័ន្ធកិច្ចនៅពេលដែលមនុស្សត្រូវបានអញ្ជើញឲ្យផ្លាស់ទីពីកន្លែងអង្គុយរបស់ពួកគេដើម្បីចូលរួម និងទទួលយកបទពិសោធន៍ផ្សេងៗនៃការថ្វាយបង្គំ។** ការផ្តល់ឱកាសឲ្យអ្នកថ្វាយបង្គំធ្វើចលនារាងកាយដើម្បីអនុវត្តការថ្វាយបង្គំនោះរួមបញ្ចូលរាងកាយរបស់ពួកគេបន្ថែមទៀតនៅក្នុងការថ្វាយបង្គំដោយមានការចូលរួម។

**តើមានយោបល់ណាខ្លះ ដែលអ្នកគិតថា អ្នកអាចអនុវត្តបាន ក្នុងព្រះវិហាររបស់អ្នក?**

## រចនាបថនៃការថ្វាយបង្គំ

បច្ចុប្បន្ននេះ ក្រុមជំនុំជាច្រើនផ្តល់ជូននូវរចនាបថថ្វាយបង្គំពីរបែប ឬច្រើនជាងនេះ (ជាទូទៅផ្អែកលើចំណង់ចំណូលចិត្តរចនាបថតន្ត្រី)។ លើសពីនេះទៅទៀតក្រុមជំនុំជាច្រើនមានកម្មវិធីថ្វាយបង្គំដំណាលគ្នាសម្រាប់ក្រុមអាយុផ្សេងៗគ្នា ដោយបែងចែកកុមារ ក្មេងជំទង់ និងមនុស្សពេញវ័យក្នុងការថ្វាយបង្គំ។ ខ្ញុំហៅការថ្វាយបង្គំបែបនេះថា ដូចជាហាងអាហារដែលសំបូរបែប។ នៅក្នុងទីធ្លាអាហារដ្ឋាននៅផ្សារទំនើប ឬនៅមជ្ឈមណ្ឌលទិញលក់/តូបលក់អាហារ អ្នកអាចបែងចែកគ្នារវាងខ្លួនអ្នក និងក្រុមគ្រួសារ ឬមិត្តភក្តិរបស់អ្នកដើម្បីទៅរកអ្នកលក់អាហារណាដែលបំពេញតាមចំណូលចិត្តអាហារបច្ចុប្បន្នរបស់អ្នកដើម្បីឲ្យមនុស្សគ្រប់គ្នាសប្បាយចិត្តចំពោះការជ្រើសរើសរបស់ពួកគេជាជាងការទៅភោជនីយដ្ឋានតែមួយដែលមានអាហារតែមួយមុខ។ ដូច្នេះប្រសិនបើមនុស្សម្នាក់ចូលចិត្តសម្លការី ម្នាក់ទៀតចូលចិត្តគុយទាវ អ្នកផ្សេងទៀតចូលចិត្តស៊ុប ពួកគេអាចស្វែងរកការបំពេញតម្រូវការនៅក្នុងអាហារដ្ឋានដែលផ្តល់ជម្រើសទាំងអស់នោះ (ប៊ូហ្វេ)។ ដូចគ្នានេះដែរក្រុមជំនុំមួយអាចផ្តល់កម្មវិធីថ្វាយបង្គំបែបប្រពៃណីសម្រាប់អ្នកដែលចូលចិត្តបទចម្រៀងគ្រីស្ទបរិស័ទប្រពៃណីខ្មែរ និងមួយទៀតមានក្រុមថ្វាយបង្គំសម័យទំនើបនាំមុខបទចម្រៀងថ្វាយបង្គំល្បីៗទាន់សម័យនោះសម្រាប់អ្នកដែលចូលចិត្តការថ្វាយបង្គំបែប «សហសម័យ»។

មានពេលខ្លះដែលការបែងចែកក្រុមជំនុំតាមរចនាបថដែលមានចំណូលចិត្តផ្ទាល់ខ្លួន ប្រហែលជាត្រូវការ—ជាពិសេសនៅក្នុងករណីទាំងនោះដែលក្រុមជំនុំនឹងនៅតែបម្រើបេសកកម្មក្នុងទីតាំងរបស់ពួកគេដោយផ្តល់ជូននូវរចនាបថនៃការថ្វាយបង្គំដែលខុសពីអ្វីដែលបានផ្តល់ឲ្យនាពេលបច្ចុប្បន្ន ហើយអ្នកចូលរួមមិនមានឆន្ទៈក្នុងការលះបង់ការមានចំណូលចិត្តផ្ទាល់ខ្លួន។ ទោះជាយ៉ាងណានៅក្នុងព្រះវិហាររបស់លោកអ្នកសព្វថ្ងៃមានរចនាបថនៃការថ្វាយបង្គំផ្សេងៗគ្នា តែខ្ញុំសង្ឃឹមថាថ្ងៃអនាគតព្រះវិហាររបស់អ្នកនឹងមានការពិចារណាប្រើប្រាស់រចនាបថនៃការថ្វាយបង្គំឯកភាពគ្នាមួយ ហើយចំណុចនេះនឹងមានការពន្យល់បន្ថែមនៅ

ពេលក្រោយទៀត។

ក្នុងការធ្វើការជាមួយក្រុមជំនុំរាប់ពាន់ក្នុងរយៈពេល១២ឆ្នាំចុងក្រោយមកនេះខ្ញុំបានឃើញក្រុមជំនុំជាច្រើនដែលបានថ្វាយបង្គំបែបសហសម័យ និងបែបប្រពៃណីដែលឥឡូវនេះចង់ត្រឡប់មកវិញជាមួយមនុស្សគ្រប់គ្នាដែលថ្វាយបង្គំក្នុងរចនាបថតែមួយ។ មានការផ្លាស់ប្តូរយ៉ាងខ្លាំងចេញពីយុគសម័យ ឆ្ងាយពីការបំបែកគ្នា និងការបែងចែកគ្នាត្រឡប់ទៅការថ្វាយបង្គំដែលមានចម្រុះជំនាន់។

## សង្គ្រាមការថ្វាយបង្គំ

សូមក្រឡេកមើលការដកស្រង់នេះពីកាសែតអាមេរិកដែលជំទាស់នឹងនិន្នាការថ្មីនៅក្នុងតន្ត្រីក្រុមជំនុំ (ប្រភពមិនស្គាល់)៖

មានហេតុផលជាច្រើនសម្រាប់ការទាស់ប្រឆាំងនឹងវា។
ទីមួយ វាថ្មីពេក។
ទីពីរ វាច្រើនតែបែបជាលោកីយ៍ ថែមទាំងប្រមាថព្រះទៀតផង។
តន្ត្រីគ្រីស្ទានថ្មីមិនសូវសប្បាយចិត្តដូចរចនាបថដែលបានបង្កើតឡើងមុនជាងនេះទេ។
ដោយសារមានបទចម្រៀងច្រើន ដូច្នេះអ្នកមិនអាចរៀនចេះបានទាំងអស់។
វាដាក់ការសង្កត់ធ្ងន់ទៅលើតន្ត្រីឧបករណ៍ពេកជាជាងទំនុកច្រៀងថ្វាយព្រះ។
តន្ត្រីថ្មីនេះបង្កើតការរំខានធ្វើឲ្យមនុស្សប្រព្រឹត្តមិនសមរម្យ និងគ្មានសណ្តាប់ធ្នាប់។
ជំនាន់មុនធ្វើបានដោយគ្មានវា។
វាជាគម្រោងរកប្រាក់ចំណេញ ហើយតន្ត្រីថ្មីមួយចំនួន ដែលចាប់ផ្តើមឡើងទាំងនេះគឺដើម្បីតែឡូយឆាយគ្មានសីលធម៌។

តើនេះស្តាប់ទៅដូចជាមតិត្រឡប់ខ្លះដែលអ្នកទទួលបាននៅសប្តាហ៍កន្លងទៅបន្ទាប់ពីអ្នកបានព្យាយាមជំរុញការថ្វាយបង្គំជាមួយនឹងបទចម្រៀងថ្វាយបង្គំថ្មីៗមួយចំនួនមែនទេ?

មតិនេះត្រូវបានសរសេរដោយគ្រូគង្វាលម្នាក់នៅឆ្នាំ១៧២៣ ដែលបានវាយប្រហារលោក អ៊ីសាក់ វ៉ាត់ (Isaac Watts) ជាអ្នកនិពន្ធទំនុកតម្កើងភាសាអង់គ្លេសដ៏អស្ចារ្យដូចជា ពេលដែលខ្ញុំសញ្ជឹងគិតពីឈើឆ្កាង ខ្ញុំមានអំណរសម្រាប់ពិភពលោក (When I Survey the Wondrous Cross, Joy to the

World,) និងឱព្រះអម្ចាស់អើយ ទ្រង់ជាជំនួយរបស់យើងគ្រប់គ្នាគ្រប់ពេលវេលា (O God, Our Help in the Age Past)។ អ្នកឃើញហើយ «សង្គ្រាមការថ្វាយបង្គំ» គឺគ្មានអ្វីថ្មីសម្រាប់ទសវត្សរ៍របស់យើងទេ។ ដរាបណាយើងមានក្រុមជំនុំដែលមានការរៀបចំរឹងមាំ ហើយមនុស្សដែលមានចំណង់ចំណូលចិត្តផ្ទាល់ខ្លួននោះគឺមានជម្លោះជានិច្ច។ ដូចព្រះគម្ពីរយ៉ាកុប ៤:១ ចែងថា ឯសេចក្តីទាស់ទែងនិងសេចក្តីឈ្លោះប្រកែកក្នុងពួកអ្នករាល់គ្នានោះមកពីណា តើមិនមែនមកពីសេចក្តីសម្រើបដែលច្បាំងក្នុងអវយវៈរបស់អ្នករាល់គ្នាទេអី?

សង្គ្រាមការថ្វាយបង្គំបានផ្ទុះឡើងពេញពិភពលោករបស់យើងយ៉ាងហោចណាស់ចាប់តាំងពីប្រហែលឆ្នាំ ៧០០នៃគ.ស.។ នេះគឺជាការរំលេចឲ្យឃើញមួយចំនួនដែលត្រូវបានរៀបរាប់ដោយមិត្តរបស់ខ្ញុំឈ្មោះ ស្ទីវ ហាំរីក (Steve Hamrick)៖[២១]

- នៅពេលដែល ហ្គ្រេគ័រាន ចាន់ (Gregorian Chant) បានក្លាយជាតន្ត្រីផ្លូវការនៃក្រុមជំនុំ វាត្រូវបានកំណត់លក្ខណៈដោយបទភ្លេងទោល ពោលគឺភ្លេងមិនមានអ្វីអបសម្រាប់ច្រៀងដោយបុរសប៉ុណ្ណោះ។ ក្រោយមក ក្មេងប្រុសៗដែលមានសំឡេងមិនអាចផ្លាស់ប្តូរបានចាប់ផ្តើមច្រៀងជាមួយបុរស ប៉ុន្តែសំឡេងរបស់ពួកគេត្រូវបានប្តូរជំនួសដោយមួយអុកតាវ (Octave) ។ មានមនុស្សជាច្រើនបានជំទាស់។ ក្រោយមកទៀតក៏ត្រូវបានគេបញ្ចូលហាំម៉ូនីទៅក្នុងតន្ត្រីនៃក្រុមជំនុំ ប៉ុន្តែមនុស្សជាច្រើនបានប្រឆាំង។
- នៅពេលដែល លូសើរ ចាប់ផ្តើមសរសេរទំនុកតម្កើងសម្រាប់ក្រុមជំនុំនៅឆ្នាំ១៥១៧ក៏មានការបះបោរយ៉ាងខ្លាំងមួយបានកើតឡើង។
- នៅឆ្នាំ១៥៤០លោក ខាល់វីន (Calvin) បាននិយាយថាមានតែទំនុកតម្កើងគម្ពីរសញ្ញាចាស់ប៉ុណ្ណោះដែលច្រៀងក្នុងចង្វាក់ភ្លេងទើបសមរម្យសម្រាប់ការថ្វាយបង្គំ ទីក្រុងហ្សឺណែវ (The Genevan Psalter)។ ការនេះបានបណ្តាលឲ្យមានការបែកបាក់ដ៏ធំនៅក្នុងក្រុមជំនុំរវាងអ្នកដើរតាមលោក ខាល់វីន (Calvin) និងអ្នកដើរតាមលោក លូសើរ (Luther's)។
- ជិតឆ្នាំ១៧៥០បងប្អូន វេសលី (Wesley) បានសរសេរទំនុកតម្កើង ដែលបង្រៀនអំពីទេវសាស្ត្រ និងគោលលទ្ធិ។ វាបានបង្កឲ្យមានការលំបាកយ៉ាងខ្លាំងក្នុងចំណោមអ្នកដឹកនាំក្រុមជំនុំម្តងទៀត។

---

២១ លោក Steve Hamrick, Associate Pastor of Worship & Media, FBC Greenville, MS, សាស្ត្រាចារ្យក្រៅម៉ោងនៅ William Carey University.

- តន្ត្រីនៃទសវត្សរ៍ឆ្នាំ១៨៨០យុគសម័យថ្នាក់ថ្ងៃអាទិត្យ (Sunday School Era) ត្រូវបានមនុស្សជាច្រើនមើលងាយ ដោយសារតែបទចម្រៀងទំនុកតម្កើង និងទីបន្ទាល់ដែលកំពុងត្រូវបានគេ សរសេរជាប្រធានបទ (ផ្ទាល់ខ្លួន) និងមិនមានគោលបំណង (តម្រង់ទៅរកព្រះ)។ មនុស្សជាច្រើនបានគិតថាគ្មានកន្លែងសម្រាប់តន្ត្រីបែបនោះនៅក្នុងក្រុមជំនុំទេ។
- តទ្ធិពលចង្វាក់ហ្សាក់ (Jazz) នៃដើមសតវត្សទី២០បានចេញសេចក្តីប្រកាសពីសម្តេច ប៉ាប ថា ព្យាណូត្រូវបានហាមឃាត់នៅក្នុងព្រះវិហារកាតូលិក ដោយសារតែតទ្ធិពលលោកីយ៍របស់វា។
- មិនយូរប៉ុន្មានចលនាព្រះយេស៊ូវបានមកជាមួយនឹងស្គរ បាស់ ហ្គីតា និងឧបករណ៍ផ្សេងទៀត។ ការច្រៀងបន្ទរ និងចម្រៀងសរសើរតម្កើងបានដើរតាមក្រោយ ហើយទាំងអស់នោះត្រូវបានយកមកពិភាក្សាតស៊ូមតិគ្នាយ៉ាងក្តៅគគុកនៅក្នុងក្រុមជំនុំ។

បញ្ជីនេះអាចចេះតែមានបន្តវែងអន្លាយថែមទៀត ដោយពណ៌នាអំពីជម្លោះជាច្រើនឆ្នាំ។

ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ដោយសារសក្តានុពលនៃជម្លោះ ក្នុងការណែនាំមនុស្សឲ្យស្គាល់តន្ត្រីដែលខុសពីចំណង់ចំណូលចិត្តផ្ទាល់ខ្លួនបច្ចុប្បន្នរបស់ពួកគេ ជារឿយៗក្រុមជំនុំបានបន្ថែមកម្មវិធីថ្វាយបង្គំមួយផ្សេងទៀតដើម្បីបំពេញតម្រូវការអាទិភាពទាំងនោះ—ដូច្នេះក៏មានការកើនឡើងនៃ «កម្មវិធីថ្វាយបង្គំសហសម័យ» នៅក្នុងទសវត្សរ៍ចុងក្រោយនៃសតវត្សទី២០រហូតមកដល់សព្វថ្ងៃនេះ នៅក្នុងតំបន់ជាច្រើននៃពិភពលោក។ កត្តានេះបានរារាំងក្រុមជំនុំជាច្រើនមិនឲ្យប្រឈមមុខដាក់គ្នាក្នុងសង្គ្រាមការថ្វាយបង្គំ ពីព្រោះជាជាងបង្កការប្រជែងនឹងស្ថានភាពបច្ចុប្បន្ន ជាមួយនឹងការផ្លាស់ប្តូរកម្មវិធីថ្វាយបង្គំមួយផ្សេងទៀតត្រូវបានបន្ថែមតែម្តងដោយសង្ឃឹមថានឹងរក្សាការពេញចិត្តសម្រាប់អ្នកគ្រប់គ្នា។ ត្រឹមតែប៉ុន្មានឆ្នាំក្រោយមកលទ្ធផលអវិជ្ជមានដែលចាប់ផ្តើមបង្ហាញនៅក្នុងក្រុមជំនុំបង្កើតឲ្យមានបំណងប្រាថ្នាដើម្បីនាំមកនូវការរួបរួមក្នុងការថ្វាយបង្គំនៅក្នុងក្រុមជំនុំក្នុងតំបន់។ ទោះបីជាការនេះប្រហែលជាមិនមែនជាបញ្ហាដែលត្រូវគ្នានៅក្នុងក្រុមជំនុំខ្មែរណាមួយក៏ដោយ ខ្ញុំសូមដាស់តឿនអ្នក កុំឲ្យពិចារណាដើរតាមមាគ៌ានៃការថ្វាយបង្គំបំបែកគ្នានេះឡើយ។

ដូចដែលខ្ញុំបានពណ៌នា ចំណង់ចំណូលចិត្តផ្ទាល់ខ្លួន គឺជាឫសគល់នៃសង្គ្រាមការថ្វាយបង្គំ។ ពាក្យចាស់និយាយត្រូវណាស់ត្រង់ចំណុចនេះ៖ «យើង

ចូលចិត្តអ្វីដែលយើងដឹង ហើយយើងដឹងពីអ្វីដែលយើងចូលចិត្ត»។ ខណៈដែលចំណង់ចំណូលចិត្តផ្ទាល់ខ្លួនមិនមែនមិនសំខាន់ វាក៏មិនមែនជាអ្វីដែលគួរជំរុញការសម្រេចចិត្តរបស់យើងដែរ។

ចំណូលចិត្តផ្ទាល់ខ្លួនគឺជារបស់ដែលធ្វើឲ្យយើងមានអារម្មណ៍ដូចនៅផ្ទះមានផាសុកភាព និងភាពសុខស្រួល។ ដូចដែលយើងចូលចិត្តគិតថា ខ្លួនយើងមិនលំអៀងតែគួរឲ្យសោកស្តាយចំណូលចិត្តរបស់យើងបានធ្វើឲ្យប៉ះពាល់ការសម្រេចចិត្ត។ សុភាសិត ២១:២ ចែងថា៖ «គ្រប់ទាំងផ្លូវរបស់មនុស្សគឺសុទ្ធតែត្រឹមត្រូវនៅចំពោះភ្នែករបស់ខ្លួន»។ ដូច្នេះយើងមានទំនោរចាត់ទុកមនុស្សដែលមានការចូលចិត្ត ឬទស្សនៈខុសគ្នា ថាអន់ ឬខុស។ លើសពីនេះទាក់ទងនឹងការថ្វាយបង្គំ យើងមានទំនោរវាយស្មើរវាងចំណូលចិត្តរបស់យើងជាមួយនឹងចំណូលចិត្តរបស់ព្រះ។ ដូច្នេះអ្នកដែលចូលចិត្តច្រៀងភ្លេងប្រពៃណីប្រហែលជាមានអារម្មណ៍ថា ក្រុមជំនុំដែលដឹកនាំដោយក្រុមតន្ត្រី និងច្រៀងបទថ្វាយបង្គំសម័យទំនើបមានភ្លើងពណ៌ចម្រុះនោះមិនមែនជាអ្វីដែលជាព្រះហឫទ័យរបស់ព្រះទេ។

គួរឲ្យស្តាយខ្ញុំឃើញរឿងនេះកើតឡើង សូម្បីតែនៅក្នុងចំណោមអ្នកដឹកនាំក្រុមជំនុំ។ ខ្ញុំបានចូលរួមសិក្ខាសាលាមួយកាលពីប៉ុន្មានឆ្នាំមុនដែលមានទំនោរទៅរកការថ្វាយបង្គំបែបប្រពៃណីច្រើនជាងខ្ញុំមានស្តង់មួយនៅទីនោះដើម្បីផ្តល់ព័ត៌មានអំពីការបណ្តុះបណ្តាលអ្នកដឹកនាំការថ្វាយបង្គំ និងអ្វីផ្សេងទៀតដែលព័ន្ធកិច្ចរបស់យើងផ្តល់ជូន។ ខ្ញុំកំពុងស្តាប់គ្រូនៅក្នុងថ្នាក់នៅជាប់គ្នាដែលបាននិយាយដោយមើលងាយ ហើយមានការរិះគន់យ៉ាងខ្លាំងចំពោះក្រុមជំនុំដែលបានយល់ព្រមដល់ការអនុវត្តការថ្វាយបង្គំសម័យទំនើបណាមួយ។ វាច្បាស់ណាស់ពីសម្តីរបស់គ្រូនោះដែលគាត់មានអារម្មណ៍ថាវាគួរឲ្យស្អប់ខ្ពើម!

យ៉ាកុប ៤:១ ចែងថា «ឯសេចក្តីទាស់ទែង និងសេចក្តីឈ្លោះប្រកែកក្នុងពួកអ្នករាល់គ្នានោះមកពីណា តើមិនមែនមកពីសេចក្តីសម្រើបដែលច្បាំងក្នុងអវយវៈរបស់អ្នករាល់គ្នាទេអី?» ដួងចិត្តឆេះឆួល/ចំណូលចិត្តផ្ទាល់ខ្លួនរបស់យើង គឺជាឫសគល់នៃជម្លោះនៅក្នុងរចនាបថថ្វាយបង្គំ។ ខ្ញុំនឹងប្រឈមមុខនឹងបញ្ហានេះនៅពេលយើងបន្តក្នុងសៀវភៅនេះ។

## ផ្នត់គំនិតបេសកកម្ម

ក្នុងនាមជាអ្នករៀបចំផែនការ និងជាអ្នកដឹកនាំការថ្វាយបង្គំ យើងត្រូវគិតដូចបេសកជននៅពេលដែលយើងជ្រើសរើសបទចម្រៀង រៀបចំតន្ត្រី។ល។ ប៉ុន្តែ តើវា

មានន័យយ៉ាងណា?

នៅក្នុងព្រឹត្តិការណ៍បណ្តុះបណ្តាលអ្នកដឹកនាំការថ្វាយបង្គំរបស់ខ្ញុំ ខ្ញុំសុំឲ្យមនុស្សស្រមៃថា យើងបានប្រមូលផ្តុំគ្នាជាក្រុមគ្រីស្ទបរិស័ទមកពីតំបន់ផ្សេងៗគ្នាជុំវិញពិភពលោកដែលមានបំណងចង់បង្កើតក្រុមជំនុំ។ នៅក្នុងឆ្នាំដំបូងនៃអង្គការរបស់យើង យើងជ្រើសរើសក្រុមជំនុំមួយនៅអឺរ៉ុបខាងកើត។ ខ្ញុំពណ៌នាអំពីប្រទេស និងបញ្ហាប្រឈមសម្រាប់ការផ្សាយដំណឹងល្អ និងការបង្កើតក្រុមជំនុំ ហើយបន្ទាប់មកប្រាប់ពួកគេថាតើទីក្រុងណាដែលយើងនឹងបង្កើត។ ក្រុមជំនុំមួយក្នុងសហរដ្ឋអាមេរិកជាតំណាង នៅក្នុងក្រុមរបស់យើងកំពុងរីកចម្រើនយ៉ាងខ្លាំង ហើយព្រះជាម្ចាស់កំពុងធ្វើការយ៉ាងខ្លាំងក្លា។ ដូច្នេះ ខ្ញុំស្នើឲ្យយើងបង្កើតក្រុមជំនុំមួយដូចជារចនាបថការថ្វាយបង្គំ និងអ្វីៗគ្រប់យ៉ាង — នៅក្នុងទីក្រុងនៅអឺរ៉ុបខាងកើតនោះ។ អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនិយាយភ្លាមថា វាមិនមែនជាគំនិតល្អទេ។ ខ្ញុំសួរថា «ហេតុអ្វី?» ពួកគេនិយាយថា យើងត្រូវសិក្សាវប្បធម៌ជាមុនសិន ដើម្បីមើលពីរបៀបភ្ជាប់ទំនាក់ទំនងជាមួយពួកគេ។ បន្ទាប់មក ខ្ញុំរាយការណ៍អំពីការរកឃើញរបស់ខ្ញុំ កាលកំពុងធ្វើដំណើរទៅទីក្រុងនោះ ហើយចែកចាយវីដេអូអំពីយុវជនដែលថ្វាយបង្គំក្នុងទីក្រុងនោះ។ ខណៈពេលដែលការរំពឹងទុករបស់យើង នឹងក្លាយជាក្រុមតន្រ្តីដែលមានតន្រ្តីថ្វាយបង្គំទំនើប ការប្រមូលផ្តុំសិស្សដ៏ធំនេះ ត្រូវបានដឹកនាំដោយក្រុមចម្រៀង ព្យ៉ាណូ ឃីបត និងឧបករណ៍ខ្សែ។ ជាការពិត កន្លែងថ្វាយបង្គំភាគច្រើននៅជុំវិញទីក្រុងហាក់ដូចជាភ្ជាប់ជាមួយមនុស្សពហុជំនាន់ជាមួយនឹងរចនាបថមូលដ្ឋានដូចគ្នានេះ។ ដូច្នេះ យើងសម្រេចចិត្តដាំក្រុមជំនុំដោយផ្អែកលើព័ត៌មាននេះ។ មួយឆ្នាំក្រោយមក យើងរកឃើញថា ព្រះវិហារកំពុងរីកចម្រើនយ៉ាងខ្លាំង!

ឥឡូវនេះយើងប្រមូលផ្តុំគ្នាដើម្បីបង្កើតក្រុមជំនុំទីពីរ។ មួយនេះស្ថិតក្នុងផ្នែកជនបទនៃប្រទេសក្នុងទ្វីបអាហ្វ្រិក។ ខ្ញុំធ្វើអធិប្បាយថា យើងបានទទួលជោគជ័យដ៏អស្ចារ្យពីក្រុមជំនុំអឺរ៉ុបរបស់យើង ដូច្នេះក្នុងស្មារតីនៃការចម្លងអ្វីដែលជោគជ័យ យើងគួរតែបង្កើតក្រុមជំនុំថ្មីមួយទៀត ដូចគ្នាបេះបិទនឹងក្រុមជំនុំមុននោះ នៅជនបទក្នុងប្រទេសអាហ្វ្រិក។ នោះតែងតែមានការប្រឆាំងយ៉ាងខ្លាំងពីអ្នកដែលចូលរួមក្នុងព្រឹត្តិការណ៍បណ្តុះបណ្តាល។ ពួកគេស្នើឲ្យមានការរាំ និងចង្វាក់សមរម្យ។ យើងពិភាក្សាអំពីភាពខុសគ្នានៃវប្បធម៌រវាងក្រុមមនុស្សទាំងពីរ។ បន្ទាប់មកខ្ញុំបង្ហាញវីដេអូពីការថ្វាយបង្គំនៅក្នុងតំបន់នោះ ដែលខុសពីឧទាហរណ៍ការថ្វាយបង្គំនៅអឺរ៉ុប។ ពិតជាមានការចូលរួមផ្នែករាងកាយជាច្រើន និងការរាំអមតាមចង្វាក់។

បន្ទាប់មកយើងពិភាក្សាអំពីការបង្កើតក្រុមជំនុំទីបី។ ទីកន្លែងនេះមានទីតាំងនៅអាសយដ្ឋានជាក់លាក់នៃព្រះវិហាររបស់អ្នកក្នុងប្រទេសកម្ពុជា។ ការរំពឹកមួយបានកើតឡើងភ្លាមៗ តើនេះមិនធ្វើឲ្យអ្នកគិតអំពីអ្វីដែលការថ្វាយបង្គំរបស់ក្រុមជំនុំរបស់អ្នកគួរមានរូបរាងយ៉ាងណាទេឬអី? តើរបៀបថ្វាយបង្គំនៃក្រុមជំនុំរបស់យើងឆ្លុះបញ្ចាំងពីអ្វីដែលបេសកជនអាចរកឃើញថាជាវិធីដ៏ល្អបំផុតដើម្បីឈោងចាប់ដល់ទីវាលដែលព្រះមានសម្រាប់ក្រុមជំនុំរបស់អ្នក? បើមិនដូច្នោះទេ ប្រហែលជាមានការផ្លាស់ប្តូរដែលនឹងត្រូវធ្វើឡើង។ យើងនឹងពិភាក្សាអំពីវិធីដែលមានសុខភាពល្អដើម្បីធ្វើវានៅពេលក្រោយ។

អេដ ស្តេតហ្សើរ (Ed Stetzer) និង ថម រ៉េន័រ (Thom Rainer) នៅក្នុងសៀវភៅមានចំណងជើងថា ក្រុមជំនុំផ្លាស់ប្រែ (Transformational Church) បានថ្លែងថា៖

> *«អ្នកដឹកនាំត្រូវរៀបចំផែនការថ្វាយបង្គំមិនមែនតែនៅក្នុងខួរក្បាលរបស់ពួកគេទេ ប៉ុន្តែនៅក្នុងសហគមន៍របស់ពួកគេ។ ប្រើចិត្តគំនិតបេសកកម្ម និងស្វែងយល់ពីភាសាបេះដូងនៃសហគមន៍របស់អ្នក។ ជម្រើសតន្ត្រីត្រូវតែសមស្របនឹងបរិបទ»។* [២២]

យើងត្រូវស្វែងរកវិធីនិយាយភាសាដែលមនុស្សនៅក្នុងសហគមន៍របស់យើងអាចយល់បាន។ ព្រះរាជសារមិនផ្លាស់ប្តូរទេ ហើយក៏មិនធ្លាក់ចុះដែរ ប៉ុន្តែប្រព័ន្ធបញ្ជូនសារនោះត្រូវតែមានទំនាក់ទំនងដើម្បីបញ្ជូនទៅដល់មនុស្សសព្វថ្ងៃនេះ។

**ការថ្វាយបង្គំរបស់យើងមិនគួរដូចជាចម្លែកពេក ដែលពួកគេមិនអាចយល់បាន។ តើនេះប៉ះពាល់ដល់ការសម្រេចចិត្តនាពេលអនាគតអំពីការថ្វាយបង្គំរួមគ្នានៅឯព្រះវិហាររបស់អ្នកយ៉ាងដូចម្តេច?**

២២ លោក Ed Stetzer និង Thom Rainer, Transformational Church: Creating a New Scorecard for Congregations (United States: B&H Publishing Group, ឆ្នាំ២០១០), ទំព័រ១៦១។

## ខ្លឹមសារ និងការបង្ហាញនៃការថ្វាយបង្គំ

នៅក្នុងសៀវភៅរបស់គាត់មានចំណងជើងថា ក្រុមជំនុំភ្ញាក់ឡើង (The Church Awakening) លោក ឆឹក ស្វីនដុល (Chuck Swindoll) ប្រើពាក្យពីរដើម្បីជួយយើងឲ្យស៊ីជម្រៅក្នុងការពិភាក្សានេះគឺពាក្យ—ខ្លឹមសារ និងការបង្ហាញ។ គាត់និយាយថា៖ «ខ្លឹមសារនៃការថ្វាយបង្គំទាក់ទងនឹងក្ដីស្រឡាញ់ខាងក្នុងខ្លួនរបស់យើងផ្ទាល់។ វាគឺជាទំនាក់ទំនងច្បាស់លាស់ ពិតប្រាកដ និងដឹងខ្លួនជានិច្ចជាមួយនឹងព្រះដ៏មានព្រះជន្មគង់នៅ»។[២៣]

ដូច្នេះ នៅក្នុងឧទាហរណ៍ខាងលើនៃការបង្កើតក្រុមជំនុំនៅអឺរ៉ុប និងអាហ្វ្រិក យើងអាចនិយាយបានថា ខ្លឹមសារនៃការថ្វាយបង្គំរបស់ពួកគេគឺដូចគ្នា។ ការថ្វាយបង្គំ សេចក្ដីស្រឡាញ់ និងដួងចិត្តឆេះឆួលរបស់ពួកគេចំពោះព្រះអាចដូចគ្នា។ វាស្ទើរតែមិនអាចទៅរួចសម្រាប់ពួកយើងក្នុងការវិនិច្ឆ័យចិត្តរបស់ពួកគេ ប៉ុន្តែសម្រាប់ជាប្រយោជន៍ដល់ការពិភាក្សានេះ យើងអាចសន្មតថា ក្រុមទាំងពីរមានសេចក្ដីស្រឡាញ់ចំពោះព្រះក្នុងកម្រិតស្មើគ្នា។

ស្វីនដុល បន្តថា «ការបង្ហាញការថ្វាយបង្គំជំរុញយើងឲ្យចូលទៅក្នុងទម្រង់នៃការថ្វាយបង្គំខាងក្រៅ... វិធីដែលយើងបង្ហាញការសរសើរដល់ព្រះ។ វាអាចនឹងមានភាពខុសគ្នាស្របទៅតាមវប្បធម៌ដែលកំពុងបង្ហាញវា»។[២៤]

ការបង្ហាញ នៃការថ្វាយបង្គំរវាងការបង្កើតក្រុមជំនុំនៅអឺរ៉ុប និងអាហ្វ្រិក គឺខុសគ្នាយ៉ាងខ្លាំង។ វាទាក់ទងទៅនឹងវប្បធម៌របស់ប្រជាជននៅទីនោះ។

ស្វីនដុល កត់សម្គាល់ថាសង្គ្រាមការថ្វាយបង្គំ គឺនៅពេលដែលមនុស្សប៉ះទង្គិចគ្នា ក្នុងអំឡុងនៃការថ្វាយបង្គំ។ ខ្ញុំយល់ឃើញថា នេះជាការពិតណាស់។ ខ្ញុំមិនដែលធ្វើការជាមួយក្រុមជំនុំក្នុងជម្លោះនៃការថ្វាយបង្គំដែលបញ្ហាគឺថាមនុស្សត្រូវបានគេរិះគន់ថា បានស្រឡាញ់ព្រះយេស៊ូវច្រើនជាងអ្នកឯទៀត។ វាស្ទើរតែគ្រប់ពេលទាំងអស់គឺពាក់ព័ន្ធនឹងការបង្ហាញនៃការថ្វាយបង្គំ ដែលទាក់ទាញយ៉ាងខ្លាំងទៅលើចំណូលចិត្តផ្ទាល់ខ្លួន។ តើឧបករណ៍អ្វីខ្លះដែលខ្ញុំប្រើក្នុងការថ្វាយបង្គំ? តើរចនាបថតន្ត្រីអ្វីខ្លះ? តើក្នុងការថ្វាយបង្គំខ្ញុំបង្ហាញកាយវិការដូចម្ដេចខ្លះ? តើអ្នកដឹកនាំការថ្វាយបង្គំស្លៀកពាក់អ្វី? បញ្ជីនៅមានបន្តរហូត។

---

២៣ លោក Chuck Swindoll, The Church Awakening: An Urgent Call for Renewal (United States: FaithWords, ឆ្នាំ២០១០), Kindle.

២៤ ក្នុងសៀវភៅដូចគ្នា។

## ភាពមិនចាំបាច់ និងភាពចាំបាច់នៃការថ្វាយបង្គំ

ចំណុចមួយទៀតដែលចំណង់ចំណូលចិត្តផ្ទាល់ខ្លួនអាចលុកលុយ និងបង្កើតជាជម្លោះក្នុងក្រុមជំនុំនោះគឺនៅក្នុងចំណុចនៃភាពមិនសំខាន់។ វាជាការចាំបាច់ណាស់ដែលក្រុមជំនុំត្រូវពិចារណាអ្វីៗគ្រប់យ៉ាង ដែលពួកគេធ្វើដោយប្រុងប្រយ័ត្ន ហើយកំណត់ថាតើការអនុវត្តទាំងនេះ (គ្រឿងសង្ហារិម សំលៀកបំពាក់ ឬអ្វីក៏ដោយ) ត្រូវបានកំណត់តាមព្រះគម្ពីរ ឬគ្រាន់តែជាជម្រើសវប្បធម៌ ឬអាទិភាពដែលបានចូលក្នុងក្រុមជំនុំនាពេលកន្លងមក។

តើអ្វីខ្លះដែលមិនសំខាន់? វេទិកា។ ព្យាណូ។ ក្រុមតន្ត្រី។ កៅអីសម្រាប់អង្គុយ។ រចនាបថនៃតន្ត្រីបែបណាមួយ។ បញ្ជីនេះនៅមានបន្តទៅទៀត ប៉ុន្តែនៅពេលដែលអ្នកបានអានពាក្យទាំងនេះខ្ញុំប្រាកដថា មនុស្សជាច្រើនបានគិតភ្លាមៗអំពីជម្លោះនៅក្នុងក្រុមជំនុំក្នុងតំបន់មួយ ឬច្រើនអំពីផ្នែកទាំងនេះ។

គួរឲ្យស្តាយ អ្វីដែលមិនសំខាន់អាចជាឧបសគ្គក្នុងការឈោងចាប់សហគមន៍របស់យើងសម្រាប់ព្រះគ្រីស្ទ។ ខ្ញុំសូមលើកឧទាហរណ៍មួយចំនួនដែលខ្ញុំបានជួបប្រទះ។

ឧទាហរណ៍ទី១៖ ខ្ញុំកំពុងធ្វើការជាមួយក្រុមជំនុំមួយ ដែលកំពុងស្វែងរកការផ្លាស់ប្តូរដោយសុខភាពល្អនៃការថ្វាយបង្គំដែលមានពីររបៀបផ្សេងគ្នាដើម្បីរួមគ្នាតែមួយវិញ។ យើងបានជួបគ្នាជាច្រើនម៉ោងនៅថ្ងៃសៅរ៍ដើម្បីធ្វើការតាមរយៈសម្ភារៈជាច្រើនដែលអ្នកមាននៅក្នុងដៃរបស់អ្នកនៅថ្ងៃនេះ។ ប្រធានបទនៃវេទិកាអធិប្បាយបានកើតឡើង។ ស្ត្រីវ័យចំណាស់ម្នាក់បាននិយាយដោយរំភើបចិត្តអំពីសារៈសំខាន់នៃ «តុពិសិដ្ឋ» ដែលភាពលេចធ្លោ និងសំណង់តំណាងឲ្យសិទ្ធិអំណាច និងចំណុចកណ្តាលនៃព្រះបន្ទូលនៃព្រះក្នុងជីវិតរបស់យើង។ នាងបាននិយាយអំពីរបៀបដែលចាំបាច់ សម្រាប់ការថ្វាយបង្គំនៅក្នុងព្រះវិហាររបស់ពួកគេ។ អំណះអំណាងរបស់នាងតាមវិធីជាច្រើនគឺទាក់ទាញ។ បន្ទាប់មកខ្ញុំបានសួរនារីវ័យក្មេងដែលគួរឲ្យគោរពម្នាក់ថា នាងគិតយ៉ាងណាចំពោះវេទិកាអធិប្បាយ។ នាងបាននិយាយអំពីរបៀបដែលវេទិកាហាក់ដូចជារនាំងរវាងនាង និងគ្រូគង្វាល—នៅពេលដែលគាត់បានអធិប្បាយពីខាងក្រោយគ្រឿងសង្ហារិមដ៏ធំនោះវាហាក់ដូចជាមិនមានទំនាក់ទំនង ដែលនាងមាននៅពេលគាត់ចេញពីខាងក្រោយនោះទេ។ នាងបានបញ្ចេញយោបល់ដែលពិបាកពន្យល់ ប៉ុន្តែអំពីវេទិកានោះនាងមានអារម្មណ៍មិនល្អក្នុងការទំនាក់ទំនង។

ជាលើកដំបូងស្ត្រីវ័យចំណាស់រូបនេះបានឃើញថា ចំណង់ចំណូលចិត្តរបស់

នាងពិតជាធ្វើជាឧបសគ្គចំពោះដំណឹងល្អសម្រាប់អ្នកដទៃ ហើយបន្ទាប់មកនាងសុខចិត្តលះបង់វាចោល។ នាងបានដឹងថា ចំណង់ចំណូលចិត្តរបស់នាងមិនផ្អែកលើតម្រូវការបទគម្ពីរសម្រាប់ការថ្វាយបង្គំទេ ហើយវេទិកាអធិប្បាយមិនសំខាន់ចាំបាច់សម្រាប់ការថ្វាយបង្គំនោះទេ។ ជាញឹកញាប់ គ្រាន់តែឮភាគីផ្សេងទៀតនៃបញ្ហាធ្វើឲ្យមានភាពខុសគ្នាយ៉ាងខ្លាំងក្នុងការសម្រេចបាននូវឯកភាព។

ឧទាហរណ៍ទី២៖ ក្រុមជំនុំមួយនៅសហរដ្ឋអាមេរិក មិនមានសំលៀកបំពាក់ជាឯកសណ្ឋានទេ តែអ្នកគួរស្លៀកពាក់ស្អាតៗឲ្យបានសមរម្យសម្រាប់ការថ្វាយបង្គំ—គឺរ៉ូបសម្រាប់ស្ត្រី និងឈុតអាវធំសម្រាប់បុរស។ នៅពេលពួកគេចាប់ផ្ដើមឈោងទៅកាន់សហគមន៍ជិតខាងរបស់ពួកគេ ហើយអញ្ជើញមនុស្សឲ្យមកចូលរួមក្នុងការថ្វាយបង្គំនៅព្រឹកថ្ងៃអាទិត្យ ពួកគេបានរកឃើញយ៉ាងឆាប់រហ័សថាសហគមន៍ជាញឹកញាប់បានឃើញបញ្ហា «សំលៀកបំពាក់ ឬឯកសណ្ឋាន» ជាឧបសគ្គដល់ការចូលរួមរបស់ពួកគេព្រោះមិនមានសំលៀកបំពាក់សមរម្យបែបនោះដើម្បីទៅព្រះវិហារ។ សំលៀកបំពាក់ប្រណិតដែលក្រុមជំនុំបានកំណត់នោះអាចជារនាំងនៃដំណឹងល្អ ហើយគ្មានមូលដ្ឋានគ្រឹះតាមព្រះគម្ពីរសម្រាប់ភាពចាំបាច់នោះទេ។ ដូច្នេះមនុស្សជាច្រើនក្នុងក្រុមជំនុំបានកំណត់ថា សំលៀកបំពាក់មិនមែនជារឿងសំខាន់។

ក្រោយមកខ្ញុំកំពុងប្រាប់រឿងនេះទៅក្រុមជំនុំផ្សេងទៀតដែលមានជម្លោះ។ មិនយូរប៉ុន្មានក្រោយមក មានគេមកប្រាប់ខ្ញុំថា ព្រះវិហាររបស់ពួកគេកាលពីប៉ុន្មានឆ្នាំមុនមានដំណោះស្រាយសម្រាប់បញ្ហានោះហើយ។ ប្រសិនបើនរណាម្នាក់បង្ហាញខ្លួននៅព្រះវិហាររបស់ពួកគេដោយស្លៀកសំលៀកបំពាក់ដែលមិនស្របតាមសំលៀកបំពាក់ដែលសមរម្យនោះពួកគេបាននាំអ្នកទៅកាន់កន្លែងបរិច្ចាគសំលៀកបំពាក់ ដើម្បីជួយពួកគេស្វែងរកអ្វីដែលសមរម្យ។ ខ្ញុំប្រាកដថា ធ្វើបែបនោះក្រុមជំនុំនៅតែមានបញ្ហាក្នុងការឈោងចាប់សហគមន៍របស់ពួកគេដដែល!

ឧទាហរណ៍ទី៣៖ នេះប្រហែលជារឿងដ៏សោកសៅបំផុតមួយ។ ខ្ញុំបានដឹកនាំការបណ្ដុះបណ្ដាលការថ្វាយបង្គំដល់មនុស្សនៅក្នុងប្រទេសអាស៊ីបូព៌ាដែលបិទជិតអស់រយៈពេលជាច្រើនថ្ងៃ។ នៅថ្ងៃចុងក្រោយ ខ្ញុំបានបើកវគ្គសំណួរ-ចម្លើយ។ ស្ត្រីម្នាក់ដែលប្រហែលជាមានអាយុ៨០ឆ្នាំបានសួរថា តើព្រះវិហាររបស់គាត់អាចថ្វាយបង្គំបានឬអត់ បើពួកគេមិនមានក្រុមតន្ត្រី។ គាត់មានភាពស្មោះត្រង់ ហើយបានឃើញការកើនឡើងនៃក្រុមតន្ត្រីសម្រាប់ការថ្វាយបង្គំ ហើយបានដឹងថា ព្រះវិហាររបស់គាត់មិនមានអ្នកភ្លេង ដើម្បីដឹកនាំរបៀបនោះទេ។ ខ្ញុំបានឆ្លើយតប

ទាំងទឹកភ្នែកប្រាប់ដល់ពួកបរិសុទ្ធជាទីស្រឡាញ់នោះថា នៅពេលដែលមនុស្ស នៅសហរដ្ឋអាមេរិកសួរខ្ញុំសំណួរនោះ ខ្ញុំបានចង្អុលពួកគេទៅកាន់ប្រទេសរបស់ គាត់ដែលពួកគ្រីស្ទានត្រូវថ្វាយបង្គំដោយស្ងាត់ស្ងៀមអស់រយៈពេលជាច្រើនឆ្នាំ។ ខ្ញុំបានប្រាប់គាត់ថា ការថ្វាយបង្គំរបស់ពួកគេប្រហែលជាធំជាងការថ្វាយបង្គំណា មួយនៅក្នុងពិភពលោក ដែលដឹកនាំដោយក្រុមតន្ត្រីពេញលេញដែលមានអ្នក ចម្រៀងដ៏អស្ចារ្យ។ ជាថ្មីម្តងទៀតការមានអារម្មណ៍ថាមានអ្វីមួយសំខាន់នៅពេល ដែលគ្មានមូលដ្ឋានតាមព្រះគម្ពីរសម្រាប់ការនោះអាចបង្កឲ្យមានជម្លោះដែលមិនចាំ បាច់ក្នុងក្រុមជំនុំ និងប៉ះពាល់ដល់វិធីសាស្ត្របេសកកម្មរបស់ក្រុមជំនុំ។

ស្វីនដុល ក្នុងការពិភាក្សាអំពីភាពចាំបាច់ និងមិនចាំបាច់និយាយថា៖ «នៅ ពេលអ្វីមួយដែលមានភាពមិនចាំបាច់គំរាមកំហែងដល់ការរួបរួមនោះពួកគេគួរ តែលុបបំបាត់ចោល»។[២៥] ការលុបបំបាត់ចោលអ្វីដែលមិនចាំបាច់ គឺងាយស្រួល និយាយជាងការធ្វើ។ យើងនឹងពិភាក្សាអំពីមធ្យោបាយ ផ្តល់ការផ្លាស់ប្តូរក្នុង លក្ខណៈដែលមានសុខភាពល្អនៅពេលក្រោយ។

ក្រុមជំនុំអាមេរិកមួយនៅទីក្រុង ឌីហែម (Durham) រដ្ឋណសខូរ៉ូឡាយ ណា (NC) បានចំណាយពេលវេលាយ៉ាងសន្ធឹកសន្ធាប់ក្នុងការស្វែងរកមើល អ្វីដែលចាំបាច់ ហើយនិងអ្វីដែលមិនចាំបាច់ នៅក្នុងវិស័យនៃការថ្វាយបង្គំ។ ពួក គេបានកំណត់សម្គាល់វិស័យទាំងពីរថាមិនចេះចប់ (ភាពចាំបាច់) និងបណ្តោះ អាសន្ន (ភាពមិនចាំបាច់)។ ពួកគេបានកំណត់តម្លៃស្នូលនៃការថ្វាយបង្គំដែលពួក គេរកឃើញក្នុងព្រះគម្ពីរ។ នេះជាអ្វីដែលពួកគេបាននិយាយអំពីរបៀបដែលពួកគេ នឹងធ្វើការជាមួយចំណុចទាំងនោះដែលត្រូវបានចាត់ទុកថាគ្មានដែនកំណត់ ហើយ ចំណុចទាំងនោះដែលជាបណ្តោះអាសន្ន៖

គ្រោះថ្នាក់ដូចគ្នា និងផ្ទុយគ្នាពីរដែលជាបញ្ហាប្រឈមមុខនៃក្រុមជំនុំនៅគ្រប់ ជំនាន់កំពុងស្វែងរកការរក្សាការថ្វាយបង្គំរួមគ្នាដែលមានសុខភាពល្អ៖ ម្យ៉ាងទៀត យើងត្រូវបានល្បួងឲ្យផ្លាស់ប្តូរអ្វីដែលមិនចេះចប់។ ម្យ៉ាងវិញទៀតយើងត្រូវបាន ល្បួងឲ្យបដិសេធមិនឲ្យផ្លាស់ប្តូរអ្វីដែលជាបណ្តោះអាសន្ន។

អ្នកដឹកនាំដែលកោតខ្លាចព្រះ ត្រូវតែយល់ច្បាស់អំពីអ្វីដែលមិនចេះចប់នៅ ក្នុងការថ្វាយបង្គំរួមគ្នា—បទគម្ពីរ ព្រះគ្រីស្ទ អំពើបាបរបស់មនុស្ស ដំណឹងល្អ និង អ្វីៗផ្សេងទៀត។ អ្នកដឹកនាំដែលកោតខ្លាចព្រះ ក៏ត្រូវតែទទួលស្គាល់ដែរថា គ្រប់ ជំនាន់ និងគ្រប់វប្បធម៌ទាំងអស់មានភាសាបេះដូងដែលអាចឲ្យមនុស្សថ្វាយបង្គំ

---

២៥ ក្នុងសៀវភៅដូចគ្នា។

ដោយចិត្តឆេះឆួល ហើយថាភាសាបេះដូងនោះកំពុងវិវត្តន៍តតឈប់ឈរ ក្នុងទម្រង់ខាងក្រៅរបស់វា។

ប្រសិនបើចង់ផ្លាស់ប្ដូររឿងមិនចេះចប់នៃជំនឿគ្រីស្ទបរិស័ទគឺស្មើនឹងការក្បត់ដំណឹងល្អដោយខ្លួនឯង ហើយក្លាយជាដើមត្រែងដែលបក់បោកដោយខ្យល់នៃមតិសាធារណៈ។ ការប្រកាន់ខ្ជាប់នូវទម្រង់បណ្ដោះអាសន្ននៅពេលដែលពេលវេលារបស់វាត្រូវបានបញ្ចប់គឺស្មើនឹងក្លាយជាអ្នកប្រពៃណីនិយមរឹងរូសដែលក្រុមជំនុំក្នុងតំបន់នឹងលែងប្រើបានទៀតក្នុងពេលឆាប់ៗនេះ—ចង់ស្បែកចាស់ ដែលមិនអាចបត់បែនបាន នឹងប្រេះឆ្លាយដោយសារស្រាថ្មីនៃព្រះវិញ្ញាណ។

កម្លាំងតែមួយដែលជំរុញអ្នកដឹកនាំក្រុមជំនុំឲ្យធ្លាក់ទៅក្នុងគ្រោះថ្នាក់ផ្ទុយគ្នាទាំងនេះគឺ៖ ការភ័យខ្លាចចំពោះមនុស្ស។ មធ្យោបាយដោះស្រាយគឺត្រូវទទួលបានភាពច្បាស់លាស់ពីបទគម្ពីរនិងភាពក្លាហានពីព្រះវិញ្ញាណដើម្បីឈរយ៉ាងរឹងមាំលើអ្វីដែលមិនចេះចប់ និងការផ្លាស់ប្ដូរដោយក្ដីស្រឡាញ់ក្នុងពេលកំណត់នូវអ្វីដែលត្រូវផ្លាស់ប្ដូរ។[២៦]

**តើអ្វីខ្លះដែលជាភាពមិនចាំបាច់នៃការថ្វាយបង្គំ?**
**តើអ្នកឃើញមានឧទាហរណ៍ជាក់ស្ដែងអ្វីដែលបង្កជម្លោះក្នុងក្រុមជំនុំរបស់អ្នក?**

## ការថ្វាយបង្គំដែលបង្រួបបង្រួម

ភាគច្រើននៃអ្វីដែលខ្ញុំពិភាក្សានៅក្នុងសៀវភៅនេះ នាំយើងទៅរកគោលគំនិតនៃការថ្វាយបង្គំដែលបង្រួបបង្រួម។ វាមិនមែនជាការថ្វាយបង្គំសហសម័យទេ។ វាក៏មិនមែនជាការថ្វាយបង្គំប្រពៃណីដែរ។ វាមិនមែនជាការថ្វាយបង្គំដែលលាយបញ្ចូលគ្នាដូចជាបទពិសោធច្រើននោះទេ—អ្នកដឹងហើយថា មួយភាគពីរនៃបទចម្រៀងរបស់អ្នកជាបទប្រពៃណី ហើយមួយភាគពីរទៀតជាបទសម័យទំនើប ហើយអ្នកនឹងធ្វើឲ្យមនុស្សវិលវល់ពេញមួយម៉ោង! ខ្ញុំឃើញបទពិសោធន៍លាយបញ្ចូលនេះជាញឹកញាប់នៅក្នុងក្រុមជំនុំ។ នៅពេលអ្នកច្រៀងចម្រៀងប្រពៃណី មនុស្សជាច្រើនក្នុងក្រុមជំនុំហាក់ដូចជាផ្ដាច់ទំនាក់ទំនង ខណៈដែលអ្នកផ្សេង

២៦ ដកស្រង់ចេញពី First Baptist Church, Durham, NC. ប្រើប្រាស់ដោយមានការអនុញ្ញាត។

ទៀតកំពុងច្រៀង និងចូលរួម។ បន្ទាប់មកពេលអ្នកច្រៀងបទថ្វាយបង្គំសម័យនេះ មនុស្សជាច្រើនលើកដៃដោយក្ដីមិនពេញចិត្តដោយគ្រាន់តែទ្រាំស្ដាប់បទចម្រៀងនោះ។ អ្នកខ្លះទៀតនៅពេលជាមួយគ្នានោះកំពុងច្រៀងយ៉ាងរំភើបជាមួយនឹងការបញ្ចេញអារម្មណ៍យ៉ាងខ្លាំង។ នេះមិនមែនជាការថ្វាយបង្គំបង្រួបបង្រួមទេ។ នេះជាការថ្វាយបង្គំដោយការបែងចែកយ៉ាងធំតាមចំណង់ចំណូលចិត្តដោយមិនមានការលះបង់សម្រាប់ការរួបរួមតាមដែលអាចផ្ដល់ឲ្យឡើយ។

បើមើលលំដាប់លំដោយនៃការថ្វាយបង្គំអ្នកនឹងមិនអាចប្រាប់បានច្បាស់ថា តើក្រុមជំនុំមានការរួបរួមក្នុងការថ្វាយបង្គំនោះទេ? ការសម្រេចបាននូវគោលដៅនេះគឺមានរឿងច្រើនជាងសិល្បៈតាមកម្មវិធីទៅទៀត។ ចូរជីកឲ្យជ្រៅជាងនេះទៀត។

ក្នុងសៀវភៅរបស់ ស្វីនដុល បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា៖

សេចក្ដីស្រឡាញ់របស់គ្រីស្ទបរិស័ទចំពោះគ្នាទៅវិញទៅមកគួរតែសំខាន់នាំមុខ។ ការរួបរួមនៃគ្រីស្ទបរិស័ទ និងការថ្វាយបង្គំពិតប្រាកដអាចកើតឡើងបានតែក្នុងបរិបទនៃសេចក្ដីស្រឡាញ់ប៉ុណ្ណោះ។[២៧]

នេះជាសមាសធាតុដ៏សំខាន់សម្រាប់ការថ្វាយបង្គំរួម។ ត្រូវតែមានសេចក្ដីស្រឡាញ់រវាងមនុស្សក្នុងក្រុមជំនុំ។ បើគ្មានសេចក្ដីស្រឡាញ់ទេ នឹងមិនមានការលះបង់ឡើយ។ បើគ្មានសេចក្ដីស្រឡាញ់ទេ នោះនឹងមិនមានការរួបរួមគ្នាឡើយ។ ស្វីន ដុល (Swindoll) បន្តថា៖

> ***នៅពេលដែលសេចក្ដីប៉ងប្រាថ្នា ដែលគិតតែពីខ្លួនឯងបានសោយរាជ្យជាកំពូលនោះនឹងមិនមានការរួបរួមនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទទេ កុំថាឡើយតែនៅក្នុងការថ្វាយបង្គំ។ ប៉ុន្តែនៅពេលដែលការលះបង់ខ្លួនឯងគឺជាអាទិភាព នោះការរួបរួមនឹងកើតឡើង។*** [២៨]

**ពិភាក្សាអំពីសម្រង់សម្ដីរបស់ ស្វីនដុល (Swindoll) អំពីការគិតតែពីខ្លួនឯងធៀបនឹងការលះបង់ខ្លួនឯងទាក់ទងនឹងការថ្វាយបង្គំរួមគ្នាក្នុងក្រុមជំនុំរបស់អ្នក។**

---

២៧ លោក Chuck Swindoll.
២៨ ក្នុងសៀវភៅដូចគ្នា។

គោលគំនិតនេះមានសារៈសំខាន់ក្នុងការយល់ដឹងអំពីការថ្វាយបង្គំដែលបង្រួបបង្រួម។ ការលះបង់ខ្លួនឯង និងសេចក្តីស្រឡាញ់ គឺជាគន្លឹះក្នុងការសម្រេចបានតាមឧត្តមគតិនៃព្រះគម្ពីរនេះ។ ខ្ញុំសូមលើកឧទាហរណ៍អំពីក្រុមជំនុំមួយដែលមានការថ្វាយបង្គំដែលបង្រួបបង្រួម។

សាកស្រមៃថា អ្នកកំពុងទៅក្រុមជំនុំមួយដែលអ្នកមិនដែលបានចូលរួមពីមុនមក។ ពេលអ្នកចូលទៅក្នុងសាលព្រះវិហារ តន្ត្រីដែលបានថតទុកក្នុងទីនោះកំពុងចាក់ ហើយក្រុមជំនុំមិនមានភាពអៀនខ្មាសនឹងការសន្ទនានៅពេលដែលមនុស្សមកពីផ្ទះរបស់ពួកគេ ឬថ្នាក់សិក្សាព្រះគម្ពីរ។ អ្នកកត់សម្គាល់ថាមនុស្សគ្រប់ជំនាន់មកជួបជុំគ្នា—កុមារតូចៗ ជីដូនជីតា គូស្វាមីភរិយាវ័យកណ្តាល យុវវ័យ ក្មេងជំទង់—ជាល្បាយនៃអាយុដែលមានសុខភាពល្អប្រពៃណាស់។ អ្នកត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅដោយស្ត្រីនៅមាត់ទ្វារ ហើយត្រូវបានផ្តល់ជំនួយក្នុងការស្វែងរកកន្លែងអង្គុយ។ អ្នកអរគុណនាង ហើយចូលទៅដោយខ្លួនឯង។

ក្រុមតន្ត្រីមួយលើវេទិកាចូលទៅក្នុងកន្លែងរបស់ពួកគេដើម្បីត្រៀមខ្លួននៅពេលដែលកម្មវិធីចាប់ផ្តើម។ មានបរិយាកាសនៃការរំពឹងទុក និងភាពរំភើបនៅក្នុងបរិយាកាសនោះ។ អ្នកអង្គុយនៅជួរកណ្តាលសឹងតែនៅកណ្តាលគេ។ នៅពេលអ្នកផ្លាស់ទីទៅកន្លែងអង្គុយរបស់អ្នក តើមានសម្គាល់ឃើញក្មេងវ័យជំទង់រាងធំម្នាក់អង្គុយពីរជួរនៅខាងស្តាំ។ គាត់មើលទៅខុសពីអ្នកផ្សេងទៀតភាគច្រើន-ច្បាស់ណាស់ វាបានផ្សារភ្ជាប់ទៅនឹងវប្បធម៌ផ្សេងគ្នាដែលអ្នកមិនអាចកំណត់អត្តសញ្ញាណបាន។ គាត់កំពុងនិយាយជាមួយនឹងប្តីប្រពន្ធវ័យកណ្តាលមួយគូដែលនៅចំពោះមុខគាត់ ហើយពួកគេហាក់ដូចជាស្គាល់គ្នាពីមុនមក។ គាត់ក៏ដូចជាមានមិត្តម្នាក់ជាមួយគាត់ផងដែរ។ អ្នកបែរទៅខាងឆ្វេង ហើយឃើញស្ត្រីចំណាស់ម្នាក់អង្គុយនៅជួរជាមួយគ្នា។ នាងមានពន្លឺនៃសេចក្តីអំណរអំពីខ្លួននាង។ តើអ្នកឆ្ងល់ថា នាងកំពុងធ្វើអ្វីនៅក្នុងព្រះវិហារដែលហាក់ដូចជា «ទំនើប» នៅក្នុងរបៀបនៃការថ្វាយបង្គំបែបនោះ។

*បន្តិចក្រោយមកនៅក្នុងកម្មវិធីថ្វាយបង្គំ ក្រុមតន្ត្រីនេះទទួលបានរសជាតិសូរស័ព្ទកាន់តែច្រើន ហើយពួកគេដឹកនាំបទចម្រៀងប្រពៃណីចាស់ៗ (*Acoustic*)។ បងស្រី* Mable *ច្រៀងចម្រៀងដែលគាត់ចូលចិត្ត*

*នេះ ហើយចាប់ផ្តើមរំឭកពីពេលវេលាមួយនៅក្នុងជីវិតរបស់គាត់ និងប្តីរបស់គាត់ដែលបានទទួលមរណភាពទៅ នៅពេលដែលព្រះបានប្រទានឲ្យពួកគេដែលភ្ជាប់ជាមួយនឹងបទចម្រៀងនេះ ហើយគាត់ចាប់ផ្តើមយំ ហើយច្រៀងជាមួយនឹងអារម្មណ៍ជាច្រើន។ តទ្បូវនេះ ប្រាដ (*Brad*) មានអារម្មណ៍ថាពាក្យពេចន៍ និងតន្ត្រីនៃបទចម្រៀងនេះមានលក្ខណៈបុរាណខ្លះ ហើយពួកគេមិនសមនឹងចំណូលចិត្តតន្ត្រីរបស់គាត់នៅឡើយទេ ប៉ុន្តែគាត់មើលឃើញពីរបៀបដែល មេប៊ឹល (*Mable*) ត្រូវបានរំជួលចិត្តដោយបទចម្រៀង និងចូលរួមក្នុងការថ្វាយបង្គំ។ មេប៊ឹល (*Mable*) បានចំណាយពេលជាច្រើនខែចុងក្រោយនេះនិយាយជាមួយ ប្រាដ (*Brad*) ហើយហាក់ដូចជាមានអារម្មណ៍ថាស្រឡាញ់ពេញចិត្តគាត់ណាស់។គាត់ចាប់ផ្តើមច្រៀងបទនេះចេញពីក្តីស្រឡាញ់ ហើយនឹងការគោរពចំពោះនាង។ ពេលចូលដល់បទបន្ទរ គាត់ច្រៀងយ៉ាងអស់ពីចិត្តដែលស័ក្តិសម។*

*បន្តិចក្រោយមកនៅក្នុងកម្មវិធីថ្វាយបង្គំ ក្រុមតន្ត្រីនេះទទួលបានរសជាតិសូរស័ព្ទកាន់តែច្រើន ហើយពួកគេដឹកនាំបទចម្រៀងប្រពៃណីចាស់ៗ (*Acoustic*)។ បងស្រី *Mable* ច្រៀងចម្រៀងដែលគាត់ចូលចិត្តនេះ ហើយចាប់ផ្តើមរំឭកពីពេលវេលាមួយនៅក្នុងជីវិតរបស់គាត់ និងប្តីរបស់គាត់ដែលបានទទួលមរណភាពទៅ នៅពេលដែលព្រះបានប្រទានឲ្យពួកគេដែលភ្ជាប់ជាមួយនឹងបទចម្រៀងនេះ ហើយគាត់ចាប់ផ្តើមយំ ហើយច្រៀងជាមួយនឹងអារម្មណ៍ជាច្រើន។ តទ្បូវនេះ ប្រាដ (*Brad*) មានអារម្មណ៍ថាពាក្យពេចន៍ និងតន្ត្រីនៃបទចម្រៀងនេះមានលក្ខណៈបុរាណខ្លះ ហើយពួកគេមិនសមនឹងចំណូលចិត្តតន្ត្រីរបស់គាត់នៅឡើយទេ ប៉ុន្តែគាត់មើលឃើញពីរបៀបដែល មេប៊ឹល (*Mable*) ត្រូវបានរំជួលចិត្តដោយបទចម្រៀង និងចូលរួមក្នុងការថ្វាយបង្គំ។ មេប៊ឹល (*Mable*) បានចំណាយពេលជាច្រើនខែចុងក្រោយនេះនិយាយជាមួយ ប្រាដ (*Brad*) ហើយហាក់ដូចជាមានអារម្មណ៍ថាស្រឡាញ់ពេញចិត្តគាត់ណាស់។ គាត់ចាប់ផ្តើមច្រៀងបទនេះចេញពីក្តីស្រឡាញ់ ហើយនឹងការគោរពចំពោះនាង។ ពេលចូលដល់បទបន្ទរ គាត់ច្រៀងយ៉ាងអស់ពីចិត្តដែលស័ក្តិសម។*

អ្នកឃើញទេ? មានការលះបង់ឲ្យគ្នាទៅវិញទៅមកនូវចំណង់ចំណូលចិត្តផ្ទាល់ខ្លួនសម្រាប់ការរួបរួមនៃរូបកាយរបស់ព្រះគ្រីស្ទ។ ប្រាដ (Brad) និង មេប៊ឹល

(Mable) មានឆន្ទៈក្នុងការព្បួរចោលនូវចំណូលចិត្តផ្ទាល់ខ្លួនរបស់ពួកគេ ហើយចូលរួមក្នុងបទចម្រៀងដែលមិនសូវចូលចិត្តទាំងនេះដោយសារការស្រឡាញ់ និងការគោរពគ្នាទៅវិញទៅមក។ ខ្ញុំជឿថា នៅពេលពួកគេធ្វើការលះបង់នេះសម្រាប់ការរួបរួមនៃរូបកាយនោះព្រះវិញ្ញាណពិតជាជួយពួកគេឲ្យថ្វាយបង្គំពេញទីជាមួយនឹងបទចម្រៀងទាំងនេះ។ បើការនេះកើតឡើងការរួបរួមពិតក្នុងការថ្វាយបង្គំក៏កើតឡើង។

លោក ឡឺវីស (C.S. Lewis) បានសន្ទតបែបនេះថា៖

> *ខ្ញុំពិតជាមិនចូលចិត្តទំនុកតម្កើងរបស់ពួកគេដែលខ្ញុំចាត់ទុកថាជាកំណាព្យកម្រិតទីប្រាំ ហើយកំណត់ទៅជាតន្ត្រីកម្រិតសម្លេងទាប។ ប៉ុន្តែនៅពេលខ្ញុំសង្កេតបន្តទៅមុខទៀតខ្ញុំបានមើលឃើញពីអត្ថប្រយោជន៍ដ៏ធំធេងរបស់វា... ខ្ញុំបានដឹងថា ទំនុកតម្កើង គឺទោះជាយ៉ាងណាត្រូវបានច្រៀងដោយភក្តីភាព និងទទួលបានអត្ថប្រយោជន៍ដោយពួកបរិសុទ្ធចំណាស់ម្នាក់ដែលពាក់ស្បែកជើងកវែង អង្គុយលើបង់ទល់មុខនោះ ហើយបន្ទាប់មកអ្នកដឹងថាអ្នកមិនសមនឹងសម្អាតស្បែកជើងកវែងទាំងនោះទេ។ វានាំអ្នកចេញពីការគិតដោយខ្លួនឯងតែម្ខាង។*

វាគឺជាការលះបង់ទៅវិញទៅមកនូវចំណង់ចំណូលចិត្តផ្ទាល់ខ្លួនសម្រាប់ការរួបរួមនៃរូបកាយ។

ព្រះយេស៊ូវអធិស្ឋានថា ដើម្បីឲ្យទាំងអស់បានរួមមកតែមួយ ឱព្រះវរបិតាអើយ ដូចជាទ្រង់គង់ក្នុងទូលបង្គំ ហើយទូលបង្គំនៅក្នុងទ្រង់ដែរ គឺឲ្យអ្នកទាំងនោះបានរួមគ្នាតែមួយនៅក្នុងយើងប្រយោជន៍ឲ្យលោកីយ៍បានជឿថា ទ្រង់ចាត់ឲ្យទូលបង្គំមកពិត (យ៉ូហាន ១៧:២១)

ការអធិស្ឋានសម្រាប់ក្រុមជំនុំនេះបានបង្ហាញពីបំណងព្រះហឫទ័យរបស់ព្រះគ្រីស្ទដែលចង់ឲ្យយើងក្លាយជារួមមកតែមួយនៅក្នុងការថ្វាយបង្គំរបស់យើងដើម្បីឲ្យពិភពលោកអាចជឿលើទ្រង់។ សូមគិតអំពីការនេះ។ នៅក្នុងពិភពលោកដែលផ្តោតលើចំណូលចិត្តជាបុគ្គល—សម្រាប់មនុស្សម្នាក់ដែលចូលទៅក្នុងព្រះវិហារហើយឃើញមនុស្សច្រើនជំនាន់ និងពហុជាតិសាសន៍ ដែលមានចំណង់ចំណូលចិត្តខុសៗគ្នា ថ្វាយបង្គំរួមគ្នាដោយឯកភាពគ្នាដែលបង្ហាញពីអំណាចនៃដំណឹងល្អ ក្នុងការប្រជែងនឹងប្រាជ្ញារបស់លោកីយ៍ដើម្បីប្រមូលផ្តុំមនុស្សចម្រុះគ្នាចូលមកក្នុងការរួបរួមគ្នាតែមួយ។

ខ្ញុំបានធ្វើការជាមួយក្រុមអ្នកដឹកនាំក្រុមជំនុំដែលកំពុងស្វែងរកការផ្លាស់ប្តូរពីរចនាបថនៃការថ្វាយបង្គំពីរផ្សេងគ្នាទៅជារចនាបថបង្រួបបង្រួមវិញ។ នៅពេលយើងកំពុងពិភាក្សាអំពីការលះបង់ឲ្យគ្នាទៅវិញទៅមកនូវចំណង់ចំណូលចិត្តផ្ទាល់ខ្លួន ស្ត្រីវ័យចំណាស់ម្នាក់បាននិយាយឡើងថា "ខ្ញុំសុខចិត្តលះបង់អ្វីក៏ដោយដែលចាំបាច់ដើម្បីស្វែងរកការរួបរួមក្នុងការថ្វាយបង្គំ... ដរាបណាក្មេងជំនាន់ក្រោយលះបង់ឲ្យបានច្រើនដូចដែលយើងបានធ្វើ!" ខ្ញុំស្ទើរតែមិនជឿនូវអ្វីដែលខ្ញុំបានឮ ហើយកំពុងរៀបចំការឆ្លើយតបសម្រាប់នាងនៅក្នុងខួរក្បាលរបស់ខ្ញុំ។ មុនពេលដែលខ្ញុំអាចនិយាយអ្វីបាន ស្ត្រីចំណាស់ម្នាក់ទៀតបាននិយាយឡើងថា "ក្នុងជីវិតដ៏យូរអង្វែងរបស់ខ្ញុំជាមួយព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ខ្ញុំ ខ្ញុំបានលះបង់ជាច្រើន ហើយរាល់ពេលដែលខ្ញុំបានលះបង់ នោះខ្ញុំបានរកឃើញនូវសេចក្តីអំណរ និងការស្កប់ស្កល់ដ៏ពោរពេញ។ ការនិយាយបែបនេះគឺគ្រប់គ្រាន់ ។

ក្រុមជំនុំរបស់យើងជាច្រើនអនុវត្តការប្រកាន់អាយុ។ ពួកគេបានបែងចែកក្រុមជំនុំ ទៅជាក្រុមថ្វាយបង្គំដាច់ដោយឡែក ដោយសារពួកគេម្នាក់ៗចូលចិត្តតន្ត្រីខុសៗគ្នា។ ពិតមែនហើយ មានហេតុផលសំខាន់ៗមួយចំនួនសម្រាប់ការបំបែកក្រុមជំនុំទៅជាបំណែកផ្សេងៗ។ ទោះយ៉ាងណាក៏ដោយ យើងក៏ត្រូវពិចារណាផងដែរអំពីការបង្រៀននៃព្រះគម្ពីរ៖

*«កុំឲ្យស្តីបន្ទោសដល់មនុស្សចាស់ៗឡើយ ចូរទូន្មានគាត់ទុកដូចជាឪពុកចុះ ហើយមនុស្សដែលក្មេងជាងអ្នក នោះទុកដូចជាប្អូនវិញ ឯស្ត្រីចាស់ៗ ទុកដូចម្តាយ ហើយពួកស្ត្រីដែលក្មេងជាងអ្នក ទុកដូចជាប្អូនដែរ ដោយសេចក្តីបរិសុទ្ធសព្វគ្រប់ ចូរគោរពដល់ពួកស្ត្រីដែលពិតជាមេម៉ាយមែន» (១ធីម៉ូថេ ៥:១-៣)*

*«កុំឲ្យអ្នកណាមើលងាយអ្នក ដោយព្រោះនៅក្មេងនោះឡើយ ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសំដី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ» (១ធីម៉ូថេ ៤:១២)*

*«មនុស្សដំណ១នឹងសរសើរស្នាដៃរបស់ទ្រង់ដល់ដំណ១ទៀតព្រមទាំងប្រកាសប្រាប់ពីការឥទ្ធិឫទ្ធិរបស់ទ្រង់ផង» (ទំនុកតម្កើង ១៤៥:៤)*

**តើអ្វីខ្លះដែលជាឧបសគ្គរាំងមិនឲ្យសម្រេចបាននូវការថ្វាយបង្គំដែលបង្រួបបង្រួមគ្នា? តើក្រុមជំនុំរបស់អ្នកអាចធ្វើការជាមួយគ្នាដោយរបៀបណាដើម្បីយកឈ្នះឧបសគ្គរាំងទាំងនោះ?**

ដូចដែលអ្នកបានឃើញការជ្រើសរើសបទចម្រៀងមិនកំណត់ថាតើកម្មវិធីថ្វាយបង្គំនេះនឹងត្រូវបានចាត់ថ្នាក់ថាជាការបង្រួបបង្រួម ឬការបញ្ចូលគ្នាទេ។ វាគឺជាបញ្ហានៃចិត្តគំនិត អាកប្បកិរិយានៃសេចក្ដីស្រឡាញ់ និងការលះបង់ខ្លួនឯងដែលច្រើនជាងនេះទៅទៀតដែលនៅក្នុងការផ្ដល់ឲ្យនោះ យើងពិតជាអាចថ្វាយបង្គំក្នុងទម្រង់ផ្សេងទៀតជាងការប្រាថ្នារបស់យើងតាមការកំណត់។ ឥឡូវនេះខ្ញុំនឹងព្យាយាមពណ៌នាសង្ខេបនៃការថ្វាយបង្គំបង្រួបបង្រួម៖

> *មនុស្សគ្រប់ជំនាន់ គ្រប់ជំនាន់ និង/ឬគ្រប់វប្បធម៌ តែងតែមានចំណង់ចំណូលចិត្តខុសៗគ្នា។ **ការថ្វាយបង្គំបង្រួបបង្រួម**ត្រូវបានសម្រេច នៅពេលដែលពួកគេថ្វាយបង្គំព្រះរួមគ្នា ដោយទុកចោលនូវចំណូលចិត្តតាមរយៈអំណាចនៃការបំផ្លាស់បំប្រែនៃដំណឹងល្អ។ ដោយការឯកភាពគ្នាការថ្វាយបង្គំពិតប្រាកដនឹងមានកើតឡើង។*

ប្រសិនបើអ្នកកត់សម្គាល់នៅក្នុងរឿងដែលខ្ញុំបានចែកចាយប្រាប់មានទំនាក់ទំនងរវាង ប្រាដ (Brad) និង បងស្រី មេប៊ឹល (Sister Mable)។ វាពិបាកក្នុងការបង្កើតចំណងក្ដីស្រឡាញ់រវាងមនុស្សដែលអ្នកមិនមានទំនាក់ទំនង។ ដូច្នេះក្នុងនាមជាអ្នកដឹកនាំក្រុមជំនុំដែលចង់បង្កើតការរួបរួមក្នុងការថ្វាយបង្គំ (ក៏ដូចជាក្រុមជំនុំទាំងមូល) យើងត្រូវគិតអំពីរបៀបដែលយើងសម្របសម្រួលសេចក្ដីស្រឡាញ់ និងការលះបង់ខ្លួនឯងក្នុងបណ្ដាមនុស្ស។ អ្នកត្រូវតែអញ្ជើញមនុស្សក្នុងក្រុមជំនុំរបស់អ្នកឲ្យរស់នៅជីវិតជាក់ស្ដែងជាមួយគ្នាតាមវិធីផ្សេងៗដូចជា៖

- គម្រោងបេសកកម្មមួយ មានចេតនាដាក់យុវជន និងមនុស្សចាស់ឲ្យធ្វើការរួមគ្នា
- មនុស្សវ័យចំណាស់កាន់តែច្រើន «ទទួលយក» មនុស្សវ័យក្មេងឲ្យចំណាយពេលជាមួយ និងការអធិស្ឋានឲ្យ។ល។
- ពេលវេលានៃការប្រកប និងពេលវេលាសប្បាយៗជាមួយក្រុមមនុស្សអន្តរជំនាន់
- ក្រុមតូចដែលមានអាយុខុសគ្នាកំពុងសិក្សាព្រះគម្ពីរ ឬប្រធានបទមួយ។
- ក្មេង និងចាស់ដែលបម្រើជាមួយគ្នាក្នុងក្រុមព័ន្ធកិច្ចដូចជា អ្នកស្វាគមន៍ ក្រុមបច្ចេកទេស ឬក្រុមថ្វាយបង្គំ

- បង្កើតដៃគូអធិស្ឋានដែលភ្ជាប់ទាំងក្មេង និងចាស់
- បង្កើតក្រុមចម្រៀងអន្តរជំនាន់ ហើយឲ្យពួកគេអង្គុយជាមួយមនុស្សជំនាន់ផ្សេងទៀត។
- សកម្មភាព ឬគម្រោងព័ន្ធកិច្ចដែលប្រមូលផ្តុំគ្នាទាំងក្មេងទាំងចាស់

អ្នកយល់អំពីគំនិតនេះ។ ការឲ្យពួកគេអនុវត្តជីវិតរស់នៅជាមួយគ្នា នឹងនាំឲ្យមានការស្គាល់គ្នាខណៈពេលដែលបានបំបែករបាំងជំនាន់។ ជាលទ្ធផល ពួកគេចាប់ផ្តើមស្រឡាញ់ និងគោរពគ្នាទៅវិញទៅមក ដូច្នេះហើយក៏សុខចិត្តលះបង់ចំណង់ចំណូលចិត្តផ្ទាល់ខ្លួនសម្រាប់អ្នកដទៃ។

ខ្ញុំបានរកឃើញប្រសាសន៍មួយរបស់លោក បណ្ឌិត ជីម ប្រេដហ្វត (Jim Bradford, Ph.D.) គ្រូគង្វាលរៀមច្បងនៃ ក្រុមជំនុំព្រះជាម្ចាស់ (Church of God) នៅ ស្ព្រីងហ្វៀល (Springfield) រដ្ឋ មីសសួរី (Missouri) ត្រង់ចំណុចដែលគាត់និយាយទាក់ទងទៅនឹងគំនិតនេះ៖

> *នៅពេលយើងជួបពេលវេលានៃភាពតានតឹង ខ្ញុំអាចនិយាយទៅកាន់មនុស្សវ័យចំណាស់ថា «ខ្ញុំប្រហែលជាមិនអាចផ្តល់ឲ្យអ្នកនូវអ្វីទាំងអស់ដែលអ្នកចង់បានក្នុងកម្មវិធីនេះជាចម្បងនោះទេ—ទំនុកតម្កើង និងការបន្ទរចាស់ៗពីដើមដល់ចប់។ កម្មវិធីថ្វាយបង្គំប្រហែលជាមិនបំពេញចិត្តអ្នកទាំងស្រុងបានទេ ប៉ុន្តែតើអ្នកមិនចង់បានក្រុមជំនុំដែលកូនៗ និងចៅៗរបស់អ្នកចង់មកថ្វាយបង្គំទេឬ? តាមរបៀបនេះ ខ្ញុំនិយាយជាមួយមនុស្សចាស់អំពីការថ្វាយបង្គំតាមរបៀបដែលពួកគេយល់។ មនុស្សចាស់ចង់ឲ្យកូនៗ និងចៅៗរបស់ពួកគេ—ក្មេងជំនាន់ក្រោយ—រីករាយនឹងការមកព្រះវិហារ ហើយថ្វាយបង្គំព្រះអម្ចាស់។ ដូច្នេះខ្ញុំសុំយោគយល់ដល់ពួកគេលើកទឹកចិត្តឲ្យចេះទ្រាំទ្រដើម្បីរីកចម្រើនជាមួយយើងក្នុងរឿងនេះ។ នៅឯក្រុមជំនុំព្រះជាម្ចាស់ (Church Of God) យើងមានមនុស្សចាស់ទុំមួយចំនួនធំ ដូច្នេះហើយយើងមានច្រៀងបទទំនុកតម្កើង នៅពេលយប់ហើយលើកទឹកចិត្តឲ្យមានការច្រៀងចម្រៀងនៅក្នុងថ្នាក់ថ្ងៃអាទិត្យរបស់យើងវិញម្តង។*
>
> *ប៉ុន្តែប្រសិនបើតន្ត្រីជាភាសាសម្រាប់មនុស្សមួយជំនាន់ៗ យើងមិនអាចស្អាងក្រុមជំនុំដោយប្រើភាសាតែមួយបានទេ។ ពេលខ្ញុំនិយាយជាមួយក្មេងជំនាន់ក្រោយ ខ្ញុំប្រាប់ពួកគេថា យើងត្រូវការទំនុកតម្កើង។ ខ្ញុំអាចនិយាយមួយចំណុចភ្ជាប់ទំនាក់ទំនងតន្ត្រី ជាមួយនឹងការអធិប្បាយនៃព្រះបន្ទូល។ ខ្ញុំនឹងបង្ហាញដោយទំនុកតម្កើង ឬនិយាយអំពីបទគម្ពីរនៅពីក្រោយទំនុកតម្កើង*

*មួយចំនួន ហើយបន្ទាប់មកច្រៀងតាមបទគម្ពីរ។ ប៉ុន្តែសំខាន់ជាងនេះទៅទៀតខ្ញុំណែនាំពួកគេ ហើយដើរតាមការថ្វាយបង្គំពិត។*

*យើងត្រូវមានប្រភេទនៃការថ្វាយបង្គំរបស់យើង។ យើងអាចថ្វាយបង្គំជាភាសាតន្ត្រីបាន។ ប៉ុន្តែ យើងក៏ត្រូវការការចេះអត់ឱនដែលរស់នៅដោយចិត្តទូលាយចំពោះគ្នាទៅវិញទៅមក។ តាមគំនិតខ្ញុំ មនុស្សជំនាន់ចាស់មានទំនួលខុសត្រូវខ្ពស់ជាងក្នុងការដែលបានបង្ហាប់មនុស្សជំនាន់ក្រោយ។ ក្នុងនាមជាអ្នកដែលមានភាពចាស់ទុំជាងពួកគេគួរតែឆាប់សម្របទៅតាមតម្រូវការរបស់មនុស្សវ័យក្មេងជាង ដូចជាឪពុកម្ដាយធ្វើចំពោះកូន។* [២៩]

ខ្ញុំចូលចិត្តកន្លែងដែលគាត់ចង្អុលបង្ហាញថា អ្នកដែលមានភាពចាស់ទុំជាងគួរតែរហ័សធ្វើតាមតម្រូវការរបស់អ្នកដែលក្មេងជាង។ នេះមិនត្រឹមតែធ្វើឲ្យយល់ស្របតាមបន្ទាត់នៃភាពចាស់ទុំខាងវិញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងអនុញ្ញាតឲ្យមានការផ្លាស់ប្ដូរដែលត្រូវការនៅពេលក្រុមជំនុំផ្លាស់ប្ដូររីកចម្រើនទៅអនាគត។

## ការដឹកនាំការផ្លាស់ប្ដូរប្រកបដោយសុខភាពល្អ

នៅទីបំផុត ការផ្លាស់ប្ដូរក្នុងការថ្វាយបង្គំគួរតែកើតឡើងបន្ទាប់ពីស្វែងរកព្រះហឫទ័យរបស់ព្រះ ដើម្បីកំណត់ការកែតម្រូវតាមដែលត្រូវការ។ អ្នកដឹកនាំខ្លះជំរុញឲ្យមានការផ្លាស់ប្ដូរដោយហេតុផលខុស ដូចជាការធ្វើត្រាប់តាមក្រុមជំនុំដែលរីកចម្រើននៅក្នុងទីក្រុង ឬមួយពួកគេបានឃើញនៅលើអ៊ីនធឺណិត ហើយចង់ធ្វើតាមវិធីសាស្ត្ររបស់មនុស្សជំនាន់ក្រោយទាំងស្រុង ឬដេញតាមចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់ពួកគេ។ ការផ្លាស់ប្ដូរត្រូវតែជាលទ្ធផលនៃការតម្រង់ផ្លូវមកពីព្រះ។

**តើអ្នកធ្លាប់ឃើញពួកជំនុំជួបបទពិសោធន៍មិនល្អ នៅពេលដែលពួកគេឆ្លងកាត់ការផ្លាស់ប្ដូរក្នុងកម្មវិធីថ្វាយបង្គំឬទេ? ហេតុអ្វីអ្នកគិតថា ការផ្លាស់ប្ដូរនោះមិនមានដំណើរការល្អ?**

២៩ លោក Jim Bradford, ក្នុងសំបុត្រដែលគាត់បានសរសេរជូនទៅកាន់ក្រុមជំនុំគាត់នៅ Central Assembly of God in Springfield, Missouri. លោកបណ្ឌិត Bradford បានអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់សំបុត្រនេះនៅក្នុងសៀវភៅរបស់ខ្ញុំ។

## ហេតុអ្វីត្រូវផ្លាស់ប្តូរ?

ហេតុអ្វីបានជាក្រុមជំនុំត្រូវផ្លាស់ប្តូរការថ្វាយបង្គំរបស់ខ្លួន? ដូចដែលខ្ញុំបានរៀបរាប់នៅក្នុងសេចក្តីណែនាំនេះ ក្រុមជំនុំមួយចំនួនបានជាប់គាំងទៅនឹងទម្រង់នៃការថ្វាយបង្គំចាស់ដែលលែងមានទំនាក់ទំនងជាមួយមនុស្ស ហើយបែបនោះក្រុមជំនុំកំពុងស្លាប់។ ការថ្វាយបង្គំបានក្លាយទៅជាគ្មានជីវិត។ ខ្ញុំបានចំណាយពេលជាមួយបេសកជននៅក្នុងតំបន់មួយដែលខ្ញុំរស់នៅ ដែលធ្វើការជាមួយក្រុមជំនុំប្រហែល៥០។ គាត់បានចែករំលែកជាមួយខ្ញុំថា គាត់គិតថា ក្រុមជំនុំរហូតដល់ទៅ៣០ នឹងត្រូវឈប់ដំណើរការក្នុងរយៈពេល១០ឆ្នាំខាងមុខដោយសារខ្វះការជាប់ទំនាក់ទំនង និងមិនចង់ធ្វើការផ្លាស់ប្តូរ។ ក្រុមជំនុំខ្លះបរាជ័យក្នុងការប្រាស្រ័យទាក់ទងជាភាសានាពេលសព្វថ្ងៃនេះ។ វីដេអូ ប្រហែលជាឧបករណ៍ដ៏អស្ចារ្យបំផុតសម្រាប់ការប្រាស្រ័យទាក់ទង ប៉ុន្តែក្រុមជំនុំខ្លះនៅតែទប់ទល់នឹងការបន្ថែមរបាំង។ ហេតុអ្វីបានជាយើងមិនចង់ប្រើវីដេអូដ៏មានអានុភាពដើម្បីចែករំលែករឿងដ៏អស្ចារ្យបំផុតដែលមិនធ្លាប់មានប្រាប់ និងភ្ជាប់ទំនាក់ទំនងដ៏មានឥទ្ធិពលជាមួយក្រុមជំនុំក្នុងការថ្វាយបង្គំ? ក្រុមជំនុំខ្លះមិនទទួលយកផ្នត់គំនិតបេសកកម្មទាក់ទងនឹងការថ្វាយបង្គំរបស់ពួកគេទេ។

ក្រុមជំនុំជាច្រើនដែលខ្ញុំជួបផ្ទាល់គឺចង់នៅដដែល។ ពួកគេសុខស្រួលក្នុងការធ្វើអ្វីៗតាមរបៀបដែលគេតែងតែធ្វើ។ នៅក្នុងសៀវភៅ ហ្វ្លីខឺរីងលេមភ៍: ព្រះគ្រីស្ទ និងពួកជំនុំ (Flickering Lamps: Christ and His Church) លោក ហេនរី (Henry) និង រីឆាត ប្លាកាប៊ី (Richard Blackaby) សរសេរថា៖

> *ក្រុមជំនុំជាច្រើនជួបការលំបាកហើយបានធ្លាក់ចុះ គឺដោយសារការយល់ខុសថា ពួកគេមិនចាំបាច់ធ្វើការផ្លាស់ប្តូរការធំដុំណាមួយឡើយ។ ពួកគេគ្រាន់តែត្រូវការគ្រូគង្វាលម្នាក់ដើម្បីជួយពួកគេបន្តធ្វើអ្វីដែលពួកគេតែងតែធ្វើកន្លងមក។*[៣០]
>
> *ជាការពិតការផ្លាស់ប្តូរការថ្វាយបង្គំគឺជាការចាំបាច់នៅក្នុងក្រុមជំនុំភាគច្រើនដែលខ្ញុំបានជួបផ្ទាល់ប៉ុន្តែ តើយើងធ្វើការផ្លាស់ប្តូរការទាំងនោះតាមរបៀបណាដើម្បីឲ្យសមស្រប?*

ជាការពិតការផ្លាស់ប្តូរការថ្វាយបង្គំគឺជាការចាំបាច់នៅក្នុងក្រុមជំនុំភាគច្រើន

---

៣០ លោក Henry Blackaby, Richard Blackaby. Flickering Lamps: Christ and His Church. (United States: Blackaby Ministries International), ឆ្នាំ២០១៥។

ដែលខ្ញុំបានជួបផ្ទាល់ប៉ុន្តែតើយើងធ្វើការផ្លាស់ប្តូរការទាំងនោះតាមរបៀបណាដើម្បីឲ្យសមស្រប?

## ហេតុអ្វីមានជម្លោះក្នុងការផ្លាស់ប្តូរ?

ជាអកុសល អ្នកដឹកនាំក្រុមជំនុំពេលខ្លះជំរុញឲ្យមានការផ្លាស់ប្តូរក្នុងអាកប្បកិរិយាមិនល្អ ដែលនាំមកនូវការបែងចែកបែកបាក់យ៉ាងធំ។ ការផ្លាស់ប្តូរលឿនពេក អាចជាមូលហេតុចម្បងសម្រាប់ជម្លោះនៅក្នុងក្រុមជំនុំ។ យើងច្រើនតែចង់បានការផ្លាស់ប្តូរ ហើយយើងចង់បានវាឥឡូវនេះភ្លាម។ ប៉ុន្តែ វិធីសាស្ត្រដ៏ឈ្លាសវៃមួយ គឺផ្លាស់ទីទៅមុខយឺតៗដោយទទួលបានការគាំទ្រ និងជួយមនុស្សឲ្យយល់ពីហេតុផលនៅពីក្រោយការផ្លាស់ប្តូរ។ ការខកខានក្នុងការជួយមនុស្សឲ្យយល់អំពីហេតុផលនៃការផ្លាស់ប្តូរ និងទទួលបានការគាំទ្រ អាចបណ្តាលឲ្យមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំង។

ឆាក់ ឡូលេស (Chuck Lawless) នៃសាលាព្រះគម្ពីរ Southeastern Baptist Theological Seminary នៅសហរដ្ឋអាមេរិក រៀបរាប់ក្នុងបញ្ជីកំហុសជាច្រើនដែលអ្នកដឹកនាំធ្វើក្នុងការផ្លាស់ប្តូរការថ្វាយបង្គំក្រុមជំនុំ៖ [៣១]

១. **ទំនាក់ទំនងមិនល្អជាមួយសមាជិកក្រុមជំនុំ។** ខ្ញុំជឿជាក់ថា សមាជិកក្រុមជំនុំជាច្រើនទៀតនឹងគាំទ្រ ប្រសិនបើពួកគេយល់ពី «មូលហេតុ» ដែលនៅពីក្រោយនៃការផ្លាស់ប្តូរ។ នៅពេលដែលយើងផ្តល់តែ «អ្វី» ដោយគ្មាន «ហេតុអ្វី» មនុស្សរបស់យើងទំនងជានឹងខ្វះការលើកទឹកចិត្តក្នុងការផ្លាស់ប្តូរ។

២. **ការឆ្លើយតបមិនគ្រប់គ្រាន់ចំពោះមនុស្សដែលតតាំង។** មនុស្សដែលតតាំងមិនមែនជាមនុស្សអាក្រក់នោះទេ។ ពេលខ្លះ និយាយដោយត្រង់ទៅចុះ ការឲ្យគំនិតរបស់ពួកគេនឹងជួយយើងឲ្យរួចពីបញ្ហា។ គ្រាន់តែស្តាប់ការព្រួយបារម្ភរបស់ពួកគេធម្មតាៗអាចឈានទៅរកការទទួលបានការគាំទ្រដ៏យូរអង្វែង។

៣. **វាច្រើនពេក ឆាប់រហ័សពេក។** អ្នកដឹកនាំដែលចង់បានការផ្លាស់ប្តូរ «មីក្រូវ៉េវ» ច្រើនតែមើលរំលងមនុស្សដែលនៅតែចូលចិត្តចង្ក្រាន។ មីក្រូ

៣១ លោក Chuck Lawless, “10 Leadership Mistakes in Transitioning a Church,” Chuck Lawless: Evangelism, Leadership, Missiology, Church Health, https://chucklawless.com/2015/10/10-leadership-mistakes-in-transitioning-a-church.

រេរអាចមានប្រសិទ្ធភាពជាង ប៉ុន្តែអ្នកដឹកនាំដ៏ឈ្លាសវៃដឹងថាគាត់ត្រូវតែស្វែងរកល្បឿនត្រឹមត្រូវដើម្បីផ្លាស់ទីទៅកាន់ទិសដៅនោះ។

៤. ការពឹងផ្អែកខ្លាំងពេកលើវិធីសាស្ត្រ។ វិធីសាស្ត្រមិនសំខាន់ទេ។ តាមពិតទៅ បេសកកម្មល្អនាំឲ្យយើងសួរអំពីវិធីសាស្ត្រសមស្របបំផុតសម្រាប់បរិបទដែលបានផ្តល់ឲ្យ។ វិធីសាស្ត្រមិនមែនចម្លើយក្នុងខ្លួនគេទេ។ ការផ្លាស់ប្តូរវិធីសាស្ត្រតតឈប់ឈរ ដោយគ្មានភាពប្រុងប្រយ័ត្នយកចិត្តទុកដាក់សម្រាប់មនុស្ស អាចធ្វើឲ្យក្រុមជំនុំនឿយហត់អស់កម្លាំង។

៥. **ចក្ខុវិស័យក្មេងខ្ចី។** វាជាការល្អក្នុងការរៀនពីក្រុមជំនុំផ្សេងទៀត ហើយអ៊ីនធឺណិតផ្តល់ឲ្យយើងនូវឱកាសច្រើនជាងពេលណាៗទាំងអស់ ដើម្បីធ្វើដូច្នេះ។ បើយើងគ្រាន់តែចម្លងពីក្រុមជំនុំផ្សេងទៀតយើងប្រថុយគ្រោះថ្នាក់កាត់បន្ថយក្រុមជំនុំរបស់យើងទៅជាគម្រោងមួយ។ ក្រុមជំនុំនីមួយៗមានភាពខុសប្លែកគ្នា ហើយគ្រប់គ្នាគួរតែស្វែងរកតាមព្រះហឫទ័យរបស់ព្រះ។

៦. **ការប្តេជ្ញាចិត្តរយៈពេលខ្លី។** គ្រូគង្វាលដែលចង់ដឹកនាំក្រុមជំនុំតាមរយៈការផ្លាស់ប្តូរឆ្ពោះទៅរកភាពរីកចម្រើនត្រូវតែរក្សាការតាំងចិត្តនោះមួយរយៈពេល។ ជាការពិតណាស់គ្រូគង្វាលដែលមានការតាំងចិត្តរយៈពេលខ្លី ទំនងជាមានចក្ខុវិស័យរយៈពេលខ្លីប៉ុណ្ណោះ ។

៧. **ភាពជាអ្នកដឹកនាំគ្មានកញ្ចក់។** អ្នកដឹកនាំខ្លះដែលកំពុងផ្លាស់ប្តូរប្រើកញ្ចក់កែវពង្រីកដើម្បីមើលកំហុសនៅក្នុងក្រុមជំនុំរបស់ពួកគេប៉ុន្តែពួកគេមិនប្រើកញ្ចក់ដើម្បីមើលចំណុចខ្វះខាតរបស់ពួកគេទេ។ ទំនោររបស់ពួកគេក្នុងការស្តីបន្ទោសក្រុមជំនុំចំពោះបញ្ហាទាំងអស់ ធ្វើឲ្យកាន់តែពិបាកផ្លាស់ប្តូរ។

៨. **ការអធិស្ឋានដែលមានប្រតិកម្ម។** ទំនោរនៃក្រុមជំនុំជាច្រើនដែលធ្វើការតាមរយៈការផ្លាស់ប្តូរ គឺធ្វើការសម្រេចចិត្ត និងអនុវត្តផែនការ-ហើយបន្ទាប់មកសុំឲ្យព្រះប្រទានពរដល់ផែនការទាំងនោះ។ យើងមិនគួរភ្ញាក់ផ្អើលទេ ប្រសិនបើផែនការរបស់យើងមិនដំណើរការព្រោះយើងមិនស្វែងរកការណែនាំពីព្រះរហូតដល់ពេលដែលយើងអនុវត្តវានោះ ។

៩. **ការធ្វើជាអ្នកគង្វាលគ្មានក្តីស្រឡាញ់។** ខ្ញុំចង់បាន គឺយើងមិនចាំបាច់បន្ថែមកំហុសនេះទេ ប៉ុន្តែ យើងឃើញវាច្រើនករណីពេក ដែលមិនអាចធ្វើមិនដឹងមិនឮបានទេ។ អ្នកដឹកនាំជាច្រើនចង់ផ្លាស់ប្តូរក្រុមជំនុំដែលពួក

គេមិនធ្លាប់មានសេចក្តីស្រឡាញ់ ហើយការខ្វះសេចក្តីស្រឡាញ់នោះ ធ្វើឲ្យវាកាន់តែងាយស្រួលក្នុងការ «មើលរំលង» មនុស្សដែលហាក់ដូចជានៅរាំងផ្លូវ។

១០. **បោះបង់ដោយងាយពេក។** ការផ្លាស់ប្តូរក្រុមជំនុំគឺកម្រថាងាយស្រួលណាស់។ វាច្រើនតែត្រូវការថាមពល និងពេលវេលាច្រើនជាងអ្វីដែលយើងបានគិត។ អ្នកដឹកនាំដែលចេញដំណើរមុនពេលតែងតែបន្ទោសអ្នកដទៃហើយក៏ប្រហែលជាខកខាននូវអ្វីដែលព្រះបានត្រៀមទុកសម្រាប់គាត់។

## ការថ្វាយបង្គំដែលកែប្រែជាថ្មី៖ សង្គ្រាមខាងវិញ្ញាណ

ប្រហែលជាចំណុចសំខាន់នៃជម្លោះជុំវិញការថ្វាយបង្គំក្នុងក្រុមជំនុំ គឺជាការពិតដែលថា សាតាំងចង់បំបែកបំបាក់ក្រុមជំនុំនៅក្នុងតំបន់មួយដែលមានអំណាច និងថាមពលសម្រាប់ការជំរុញប្រសិទ្ធភាព ក្នុងគ្រប់វិស័យផ្សេងទៀតនៃព័ន្ធកិច្ច-ការថ្វាយបង្គំ។ ប្រសិនបើសាតាំងអាចបង្កើតអារម្មណ៍ នៃការពេញចិត្តជាមួយនឹងការថ្វាយបង្គំដែលគ្មានន័យ ហើយបង្កឲ្យមានជម្លោះជាមួយនឹងដំណើរការនៃការផ្លាស់ប្តូរ ទៅជាអ្វីមួយឲ្យពួកជំនុំចូលរួមយ៉ាងសកម្ម និងសហគមន៍របស់អ្នកឲ្យជួបព្រះ នោះវាប្រាកដជានឹងធ្វើឲ្យបែកបាក់។ ដូច្នេះ យើងត្រូវទទួលស្គាល់ថា ការថ្វាយបង្គំដែលកែជាថ្មី/ការផ្លាស់ប្តូរការថ្វាយបង្គំ គឺជាសមរភូមិខាងវិញ្ញាណពិតប្រាកដ ដែលយើងត្រូវធ្វើសង្គ្រាមប្រឆាំងនឹងខ្មាំងសត្រូវ។

## តើយើងឈានទៅដល់អនាគតដែលសមតាមបំណងដោយរបៀបណា?

ដូច្នេះ នៅពេលដែលយើងមានចក្ខុវិស័យច្បាស់លាស់ពីព្រះ អំពីទិសដៅនៃពេលវេលាការថ្វាយបង្គំរួមគ្នារបស់យើង តើយើងទៅទីនោះប្រកបដោយសុខភាពល្អតាមរបៀបណា? យើងលើកតម្កើងព្រះ ហើយស្រឡាញ់គ្នាទៅវិញទៅមកព្រមទាំងរក្សាភាពល្អតតខ្មោះព្រះបន្ទូល និងតន្ត្រីដោយរបៀបណា?

ជាដំបូងអ្នកត្រូវដឹងថា ការគ្រាន់តែផ្លាស់ប្តូរការថ្វាយបង្គំរួមគ្នានៅក្នុងព្រះវិហារមិនមែនជាគន្លឹះនៃការកែជាថ្មីឡើងខាងវិញ្ញាណ និងការថ្វាយបង្គំដែលរស់រវើកឡើងវិញនោះទេ។ ទីមួយ ត្រូវតែមានការផ្លាស់ប្តូរខាងវិញ្ញាណជាមុនសិន។

លោក ហ្គ្រាហាំ ខេនឌ្រីក (Graham Kendrick) បានថ្លែងយ៉ាងមានឥទ្ធិពលអំពីរឿងនេះ៖

*វាមិនអាចទៅរួច ក្នុងការទាញយកការថ្វាយបង្គំដ៏ពេញបរិបូរណ៍ ចេញពីដួងចិត្តដែលរីងស្ងួតបានទេ។ ការថ្វាយបង្គំគួរតែរីកចម្រើនទន្ទឹមនឹងការរីកលូតលាស់ខាងវិញ្ញាណ... ប៉ុន្តែ បើយើងគ្រាន់តែដាក់រចនាបថ និងវិធីសាស្ត្រថ្មីទៅលើស្ថានភាពដែលស្លាប់ នោះយើងនឹងបញ្ចប់ទៅវិញ ដោយគ្មានអ្វីប្រសើរជាងមឈូសដែលតុបតែងយ៉ាងស្រស់ស្អាតនោះទេ។ លោក ហ្គ្រាហាំ ខេនឌ្រីក (*Graham Kendrick, unknown source *)។*

*ការថ្វាយបង្គំដែលបង្រួបបង្រួមមិនអាចសម្រេចបានក្នុងក្រុមជំនុំដែលខ្វះភាពចាស់ទុំខាងវិញ្ញាណទេ។ មានការស្វែងរករបៀបវារៈផ្ទាល់ខ្លួនច្រើនពេកលើសពីការរួបរួមនៃរូបកាយ។*

ដូច ស្វីន ដុល (Swindoll) បានមានប្រសាសន៍ថា «នៅពេលដែលសេចក្តីប៉ងប្រាថ្នាដែលគិតតែពីខ្លួនឯងបានសោយរាជ្យខ្ពស់បំផុត នោះនឹងមិនមានការរួបរួមនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទទេ កុំថាឡើយក្នុងការថ្វាយបង្គំ។ ប៉ុន្តែនៅពេលការលះបង់ខ្លួនឯងត្រូវបានដាក់ជាអាទិភាព នោះការរួបរួមនឹងកើតមានឡើង»។[៣២]

ឧទាហរណ៍ដ៏មានអំណាចមួយអំពីរឿងនេះត្រូវបានគេឃើញនៅក្នុងក្រុមជំនុំដែលខ្ញុំបានធ្វើការជាមួយ កាលពីប៉ុន្មានឆ្នាំមុន។ ក្រុមជំនុំមានកម្មវិធីថ្វាយបង្គំពីរដែលមានរចនាបថខុសគ្នា។ ពួកគេបានជួបការបែកបាក់ជាច្រើននៅក្នុងក្រុមជំនុំរបស់ពួកគេ ហើយបានបញ្ជាក់យ៉ាងច្បាស់ លើសពីអ្វីទាំងអស់ គឺពួកគេចង់ត្រឡប់មកជាមួយគ្នាក្នុងការថ្វាយបង្គំវិញ—ចង់ក្លាយជារួមមកតែមួយនៅក្នុងការថ្វាយបង្គំម្តងទៀត។ មានការងារជាច្រើនដែលត្រូវបានធ្វើនៅក្នុងដំណើរការនេះ ប៉ុន្តែជម្លោះបានឈានដល់កំពូលទៅហើយ។ ការឯកភាពគ្នាមិនអាចទទួលបានទេ។ បញ្ហាគឺថាមនុស្សបាននិយាយថា ពួកគេចង់បានការរួបរួមក្នុងការថ្វាយបង្គំ ប៉ុន្តែតាមពិត ពួកគេចង់ឲ្យមនុស្សគ្រប់គ្នាមកជួបជុំគ្នាតាមរចនាបថនៃការថ្វាយបង្គំដែលពួកគេចូលចិត្ត។ ដូច្នេះ អ្នកថ្វាយបង្គំបែបប្រពៃណីចង់ឲ្យអ្នកថ្វាយបង្គំបែបសម័យ ចូលរួមច្រៀងចម្រៀងប្រពៃណី ហើយអ្នកថ្វាយបង្គំបែបសម័យ ចង់ឲ្យមនុស្សវ័យចាស់ៗមកចូលរួមថ្វាយបង្គំជាមួយពួកគេ។ មិនមានឆន្ទៈសម្រាប់ការលះបង់ឲ្យគ្នាទៅវិញទៅមកនូវចំណង់ចំណូលចិត្តផ្ទាល់ខ្លួន សម្រាប់ការរួបរួមនៃរូបកាយនោះទេ ហើយក៏មិនមានសេចក្តីស្រឡាញ់រីករាលដាលនៅក្នុងការប៉ុនប៉ងដើម្បីរួមគ្នាជាឯកភាពវិញដែរ។

៣២ លោក Chuck Swindoll.

## ជំហានទៅកាន់ការផ្លាស់ប្តូរប្រកបដោយសុខភាពល្អ

ក្នុងការធ្វើការជាមួយ និងការសង្កេតមើលក្រុមជំនុំជាច្រើនដែលឆ្លងកាត់ការផ្លាស់ប្តូរការថ្វាយបង្គំ ខ្ញុំបានកំណត់ជំហានមួយចំនួនក្នុងការធ្វើដំណើរប្រកបដោយសុខភាពល្អ៖

ការរៀបចំខាងវិញ្ញាណ។ ដូចដែលខ្ញុំបានលើកឡើងពីមុន ការកែជាថ្មីខាងវិញ្ញាណ គឺជាតម្រូវការមួយសម្រាប់ការផ្លាស់ប្តូរការថ្វាយបង្គំ។ បើមនុស្សមានចិត្តត្រជាក់ក្នុងការថ្វាយបង្គំព្រះរបស់ខ្លួនទៅហើយ នោះការផ្លាស់ប្តូរធ្វើឲ្យគ្មានប្រយោជន៍ទេ។ ចូរចំណាយពេលវេលាជួយក្រុមជំនុំរបស់អ្នក ដើម្បីស្វែងរកព្រះនៅក្នុងជីវិតរបស់ពួកគេ ហើយធ្វើឲ្យមានជីវិតរស់រវើកឡើងវិញ។ ខ្ញុំបានឃើញក្រុមជំនុំមួយចំនួនមានពេលវេលាផ្តោតអារម្មណ៍ជាច្រើនសប្តាហ៍សម្រាប់ការកែជាថ្មីជាមួយនឹងការខិតខំប្រឹងប្រែងអធិស្ឋាន ក្រុមតូចៗការជញ្ជឹងគិតប្រចាំថ្ងៃ និងច្រើនទៀត ដែលជួយមនុស្សឲ្យស្វែងរកការកែជាថ្មីផ្ទាល់ខ្លួន។

ការអធិស្ឋាន។ ជាក់ស្តែង ការអធិស្ឋានគឺជាផ្នែកមួយនៃការកែឡើងវិញខាងវិញ្ញាណ ប៉ុន្តែលើសពីនេះទៅទៀត ត្រូវធ្វើការអធិស្ឋានមុនការផ្លាស់ប្តូរ អមជាមួយការផ្លាស់ប្តូរ និងបន្តបន្ទាប់ពីការផ្លាស់ប្តូរ។ សូមចាំថា សាតាំងចង់បំបែកក្រុមជំនុំ ត្រង់កន្លែងដែលក្រុមជំនុំទទួលបានអំណាចរបស់ខ្លួន — ការថ្វាយបង្គំរួមគ្នា។ ចូលរួមជាមួយអ្នកចម្បាំងការអធិស្ឋានរបស់អ្នកមួយចំនួន ដើម្បីលើករឿងនេះឡើងជារៀងរាល់ថ្ងៃ។ សូមឧស្សាហ៍លើករឿងនេះនៅចំពោះមុខក្រុមជំនុំរបស់អ្នក នៅពេលអ្នកផ្តល់សេចក្តីត្រូវការការអធិស្ឋានសម្រាប់ក្រុមជំនុំ។

បេះដូងពេញដោយក្តីស្រឡាញ់។ យើងត្រូវមានចិត្តស្រឡាញ់មនុស្សរបស់យើង ក្នុងពេលមានការផ្លាស់ប្តូរ។ សូមផ្តល់ក្តីសង្ឃឹមដល់ពួកគេ។ ជួយពួកគេឲ្យមើលឃើញអនាគតដែលចង់បាន។ ផ្នែកមួយនៃការមានបេះដូងដែលមានក្តីស្រឡាញ់ គឺត្រូវ «រស់នៅក្នុងជីវិតជាក់ស្តែង» ជាមួយសមាជិកពួកជំនុំរបស់អ្នក—ចំណាយពេលជាមួយពួកគេក្នុងទំនាក់ទំនងជាក្រុមតូច គម្រោងបេសកកម្ម និងវិធីផ្សេងទៀតដែលអ្នកអាចស្គាល់ពួកគេ ហើយពួកគេស្គាល់អ្នក។ កាលណាមានមនុស្សកាន់តែច្រើនស្គាល់អ្នក និងទុកចិត្តអ្នកកាន់តែច្រើន ពួកគេនឹងកាន់តែទុកចិត្តអ្នក ក្នុងការផ្លាស់ប្តូរផ្នែកខ្លះនៃការថ្វាយបង្គំ។ ទំនាក់ទំនងដែលមានវិន័យគឺប្រហែលជាល្អបំផុតសម្រាប់ការស្គាល់នរណាម្នាក់ នៅកម្រិតណាមួយខាងវិញ្ញាណ។ វិធីមួយទៀតដើម្បីឲ្យមានចិត្តស្រឡាញ់គឺត្រូវពិចារណាពីភាពខុសគ្នារវាងការកម្ទេចចោល និង ការរុះរើឡើងវិញ នៅពេលនិយាយអំពីការផ្លាស់ប្តូរការ

ថ្វាយបង្គំ។ មិត្តរបស់ខ្ញុំម្នាក់ឈ្មោះ ដាវីឌ មែនន័រ (David Manner) ពន្យល់ដូចតទៅនេះ៖

> *ការកម្ទេចចោល គឺជាវិធីសាស្ត្រដ៏លឿនបំផុតក្នុងការរុះរើរចនាសម្ព័ន្ធដែលមានស្រាប់ ដើម្បីធានាថា រចនាសម្ព័ន្ធដែលសង់ក្រោយទៀតមិនមានលក្ខណៈដូចរចនាសម្ព័ន្ធដើម។*
>
> *តើនេះស្តាប់ទៅដូចជាការផ្លាស់ប្តូរនៃការថ្វាយបង្គំក្នុងក្រុមជំនុំរបស់អ្នកឬទេ?*
>
> *ក្នុងកិច្ចខិតខំប្រឹងដើម្បីផ្តួចផ្តើមគំនិតធ្វើការផ្លាស់ប្តូរការថ្វាយបង្គំ អ្នកដឹកនាំតែងតែប្រើភាពប៉ិនប្រសប់នៃបាល់បំផ្លិចបំផ្លាញ ដែលបក់បោកទៅនឹងការអនុវត្តដែលមានស្រាប់។ ផលវិបាកជាញឹកញាប់ គឺជាការបំផ្លិចបំផ្លាញទាំងស្រុង នៃមូលដ្ឋានទំនាក់ទំនងនៃសហគមន៍ដែលអាចចំណាយពេលរាប់ទសវត្សរ៍ក្នុងការកសាង។*
>
> *ការរុះរើឡើងវិញ គឺជាដំណើរការជាប្រព័ន្ធ និងដោយមានការជ្រើសរើស នៃការបំបែករចនាសម្ព័ន្ធមួយខណៈពេលដែលរក្សាដោយប្រុងប្រយ័ត្ននូវសមាសធាតុដែលមានតម្លៃ សម្រាប់ការប្រើប្រាស់ឡើងវិញ។ ការរុះរើឡើងវិញ ផ្តោតលើការផ្តល់សម្ភារៈទាំងនោះនៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់នូវជីវិតថ្មីមួយ នៅពេលដែលវាត្រូវបានគេកំណត់ថារចនាសម្ព័ន្ធ ដែលមានស្រាប់នឹងត្រូវការការផ្លាស់ប្តូរ ដើម្បីបន្តដំណើរការដោយជោគជ័យ។*
>
> *ការរុះរើឡើងវិញ គឺជាការទទួលស្គាល់ថាធាតុផ្សំជាច្រើននៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់ នៅតែមានតម្លៃ។ ការផ្លាស់ប្តូរការថ្វាយបង្គំដែលមានសុខភាពល្អ គឺត្រូវការពេលវេលាដើម្បីទទួលស្គាល់សមាសធាតុទាំងនោះ និងប្រមូលផលវាឡើងវិញ ដើម្បីទាមទារតម្លៃរបស់វាឡើងវិញ សម្រាប់សម្ភារៈសំណង់ដែលមានប្រយោជន៍នៅក្នុងរចនាសម្ព័ន្ធថ្មី។*
>
> *ការរុះរើការថ្វាយបង្គំឡើងវិញ អាចបណ្តាលឲ្យមានការរុះរើ ហើយតម្រូវឲ្យមានការប្រឌិត។ ការរុះរើឡើងវិញនៃការថ្វាយបង្គំអនុញ្ញាតឲ្យមានការជួសជុល និងលើកទឹកចិត្តឲ្យមានការបង្កើតថ្មី។ ដំណើរការទាំងពីរយល់ស្របថា ការផ្លាស់ប្តូរការថ្វាយបង្គំគឺចាំបាច់ ដោយសារក្រុមជំនុំពិចារណាអំពីវប្បធម៌ និងបរិបទរបស់ខ្លួន។ ប៉ុន្តែ ការរុះរើការថ្វាយបង្គំ យ៉ាងហោចណាស់មូលដ្ឋានគ្រឹះមិនបានបំផ្លាញចោល ដែលផ្តល់សង្ឃឹមដល់យើងអាចកសាង*

***រចនាសម្ព័ន្ធថ្មីលើនោះបាន។*** [៣៣]

ជាញឹកញាប់ ខ្ញុំឃើញឧទាហរណ៍ជាច្រើននៃការរុះរើការថ្វាយបង្គំក្នុងក្រុមជំនុំ។ នេះគឺជាឧទាហរណ៍មួយ៖ ក្រុមជំនុំមួយមានក្រុមចម្រៀងដ៏ពូកែ និងវង់ភ្លេងដែលពោរពេញដោយមនុស្សដែលមានទេពកោសល្យខ្ពស់។ គ្រូគង្វាលថ្មីម្នាក់បានកំណត់ថា ក្រុមជំនុំត្រូវផ្លាស់ទៅថ្វាយបង្គំដែលដឹកនាំដោយក្រុមតន្ត្រីថ្មី ហើយបានបណ្តេញក្រុមតន្ត្រីជាអចិន្ត្រៃយ៍ចេញ។ ឥឡូវនេះ មនុស្សជាង១០០នាក់ ដែលបានទទួលអំណោយទាន និងការត្រាស់ហៅមកពីព្រះ ឲ្យប្រើទេពកោសល្យតន្ត្រីរបស់ពួកគេក្នុងការថ្វាយបង្គំ ត្រូវបានប្រាប់ថា គេលែងត្រូវការពួកគេទៀតហើយ។ ប្រសិនបើយុទ្ធសាស្ត្រនៃការរុះរើត្រូវបានប្រើប្រាស់ ក្រុមចម្រៀងអាចត្រូវបានរៀបចំឡើងវិញជាក្រុមចម្រៀងនាំមុខការថ្វាយបង្គំ (ដែលអាចជាកត្តាជំរុញដ៏ធំ សម្រាប់ការថ្វាយបង្គំឡើងវិញ) ហើយវង់តន្ត្រីអាចត្រូវបានរៀបចំឡើងវិញ តាមរបៀបដែលពួកវាត្រូវបានប្រើ ជាការបន្ថែមទៅនឹងពេលវេលាដឹកនាំផ្នែកនៃចង្វាក់ភ្លេងក្នុងការថ្វាយបង្គំ។ ជាជាងត្រូវបានបោះចោលទាំងស្រុង អ័កហ្គែន ត្រូវបានយកប្រើប្រាស់ឡើងវិញ នៅលើបទចម្រៀងថ្វាយបង្គំទំនើបជាងមុន ដើម្បីចាក់សំឡេងបំពេញជា ឃីបត (Keyboard) ជំនួស។ ក្នុងការរុះរើឡើងវិញ មនុស្សនៅតែទទួលបានការស្រឡាញ់ និងការឲ្យតម្លៃចំពោះចំណែករបស់ពួកគេ នៅក្នុងរូបកាយ ហើយពួកគេអាចបន្តរស់នៅតាមការត្រាស់ហៅរបស់ពួកគេដើម្បីបម្រើ និងថ្វាយបង្គំដល់ព្រះ។ នៅពេលដែលអាចធ្វើទៅបាន ការរុះរើឡើងវិញនូវការថ្វាយបង្គំអាចជាវិធីដ៏ល្អបំផុត សម្រាប់ការរួបរួមក្នុងការផ្លាស់ប្តូរការថ្វាយបង្គំ។ សូមសម្លឹងមើល អ្នកណាដែលព្រះបានប្រទានឲ្យមកប្រជុំរួមគ្នា ក្នុងក្រុមជំនុំរបស់អ្នកហើយប្រើប្រាស់អំណោយទានទាំងនោះ ទោះបីជាវាមិនសមនឹងសៀវភៅគំរូ សម្រាប់ព័ន្ធកិច្ចថ្វាយបង្គំរបស់អ្នកក៏ដោយ។ ក្រុមជំនុំនីមួយៗមានការស្រឡាញ់ចូលចិត្ត និងអត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់ការថ្វាយបង្គំ ។

ចែកចាយនិមិត្ត។ អ្នកដឹកនាំត្រូវអប់រំមនុស្ស អំពីហេតុផលនៃការផ្លាស់ប្តូរ និងដំណើរការដែលកំពុងធ្វើការ។ មិនមែនធ្វើក្នុងការចាប់ផ្តើមផ្លាស់ប្តូរប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវធ្វើតាំងពីមិនទាន់ផ្លាស់ប្តូរ និងបន្តរធ្វើទៅមុខទៀតក្នុងអំឡុងពេលនៃ

---

៣៣ លោក David Manner, “Are You Leading Worship Change with a Wrecking Ball? Try Deconstruction,” Worship Evaluation, http://WorshipEvaluation.org/are-you-leading-worship-change-with-a-wrecking-ball-try-deconstruction/.ការយល់ដឹងអំពីភាពជាអ្នកដឹកនាំការថ្វាយបង្គំ

ការផ្លាស់ប្តូរ។ ជាញឹកញាប់ អ្នកដឹកនាំនិយាយអំពីតម្រូវការ និងដំណើរការនៅក្នុងកិច្ចប្រជុំ និងការសន្ទនារបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកក្រុមជំនុំជាមធ្យមប្រហែលជាមិនត្រូវបានរំលឹកពីរឿងទាំងនេះលើសពីការបង្ហាញពីដំបូងឡើយ។ វាងាយស្រួលសម្រាប់ពួកគេក្នុងការបំភ្លេចរឿងទាំងនោះ។ សរសេរអំពីរឿងនោះនៅក្នុងក្រុមហ្វេសប៊ុកឆាត ឬតេឡេក្រាមឆាត និយាយអំពីរឿងនោះនៅក្នុងកម្មវិធីថ្វាយបង្គំ ហើយរំលឹកមនុស្សអំពីរឿងនោះនៅក្នុងកិច្ចប្រជុំ និងការសន្ទនាក្រៅផ្លូវការ។ រក្សារឿងនោះទុកក្នុងគំនិតដំបូង នៃជីវិតរស់នៅរបស់មនុស្សគ្រប់រូប។ មូលហេតុ គឺសំខាន់បំផុត ហើយត្រូវនិយាយឲ្យបានញឹកញាប់។

## ធ្វើការផ្លាស់ប្តូរដោយមានតម្លាភាព

នៅពេលដែលមនុស្សដឹងពីមូលហេតុ និងយល់ពីជំហានដែលអ្នកកំពុងធ្វើពួកគេទំនងជានឹងដើរជាមួយអ្នក ហើយមិនបដិសេធទៀតឡើយ។ បន្ថែមពីលើការចែកចាយនិមិត្តអំពីមូលហេតុ អ្នកដឹកនាំត្រូវបន្តជួយមនុស្សឲ្យយល់ពីជំហានដែលពួកគេកំពុងធ្វើ ដើម្បីឈានទៅដល់លទ្ធផលដែលចង់បាន។

## ការតស៊ូ

ជាញឹកញយណាស់ ដែលអ្នកដឹកនាំត្រូវបានជំរុញឲ្យថយក្រោយ ដោយសារតែការរិះគន់ និងការរុញច្រានផ្សេងទៀត។ ក្នុងការខិតខំតស៊ូ យើងត្រូវតែឆ្ពោះទៅរកគោលដៅដែលព្រះប្រទានឲ្យដោយមិនមានការសោកស្តាយ ឬដកថយឡើយ។ នេះមិនមែនមានន័យថាធ្វើឲ្យអ្នកជិះជាន់លើមនុស្សដែលទើសផ្លូវនោះទេ។ ឧបសគ្គត្រូវតែដោះស្រាយដោយក្តីស្រឡាញ់ (សូមមើលអត្ថបទរបស់លោក ឡលេស (Lawless') ខាងលើ)។ ទោះជាយ៉ាងណាក៏ដោយយើងត្រូវតែតស៊ូក្នុងការស្វែងរកឲ្យបានសម្រេចគោលដៅរបស់យើង។

ខ្ញុំត្រឡប់ទៅកាន់កំណត់ហេតុបណ្ដាញសង្គមម្ដងទៀតដែលមិត្តរបស់ខ្ញុំ ដេវីដ មេនន័រ (David Manner) បានបង្ហាញអំពីសារៈសំខាន់នៃការនេះ៖

> *មានរឿងព្រេងមួយត្រូវបានដំណាលថា នៅពេលដែលព្រះចៅអធិរាជអាឡិចសាន់ឌឺ (*Alexander the Great*) និងកងទ័ពរបស់ទ្រង់បានមកដល់ច្រាំងនៃសមុទ្រពៃរ្យ ពួកគេបានជួបប្រទះសត្រូវដែលមានចំនួនច្រើនជាងពួកគេ។ ដោយសារវាច្បាស់ដែលថាវាសនាកំណត់មកប្រឆាំងនឹងពួកគេ ហើយអនាគតមិនប្រាកដប្រជា កងទ័ពរបស់ទ្រង់បានអង្វរ អាឡិចសាន់ឌឺឲ្យដកថយទៅកាន់ទូក និងរត់រកទីមានសុវត្ថិភាពគឺមាតុភូមិរបស់ពួកគេដើម្បី*

*កេណ្ឌប្រមូលកងទ័ព និងទទួលបានកងទ័ពបន្ថែមទៀត។*

*អាឡិចសាន់ឌឺ ប្រាកដណាស់ថាសកម្មភាពរបស់ពួកគេគឺត្រឹមត្រូវ ដែលទ្រង់បានបញ្ជាឲ្យមនុស្សជំនិតរបស់ទ្រង់ដុតទូករបស់ពួកគេចោល។*

*នៅពេលដែលមធ្យោបាយតែមួយគត់នៃការដកថយរបស់ពួកគេ ត្រូវបានឆេះនៅក្នុងអណ្ដាតភ្លើង អាឡិចសាន់ឌឺ បានងាកទៅរកកងទ័ពរបស់ទ្រង់ហើយមានបន្ទូលថា «យើងត្រឡប់ទៅផ្ទះវិញ ដោយជិះកប៉ាល់របស់ពួកពើរស៊ី ឬបើពុំនោះទេយើងនឹងស្លាប់» ។*

*ប្រសិនបើក្រុមជំនុំរបស់អ្នកបានកំណត់ថា ការផ្ដួចផ្ដើមការផ្លាស់ប្ដូរគឺជាការចាំបាច់សម្រាប់អ្នកដើម្បីរក្សាមនុស្សទាំងនោះដែលអ្នកមានរួចហើយ និងទទួលបានអ្នកដែលមិនទាន់បានចូលមកនៅឡើយ ... នោះផ្ទុយទៅវិញ បើមានការខកខានមិនបានចាប់ផ្ដើមការផ្លាស់ប្ដូរនៅពេលចាំបាច់ទេ វានឹងសម្លាប់ក្រុមជំនុំរបស់អ្នកទាំងអស់។ ការស្លាប់ជាធម្មតាកើតឡើងយឺតៗ ... ប៉ុន្តែនៅទីបំផុតវានឹងមកដល់។*

*ការជឿជាក់ និងការសហការគ្នាគឺជាកត្តាបង្រួបបង្រួមដែលជំរុញទឹកចិត្តអ្នកដឹកនាំ និងក្រុមជំនុំមិនព្រមដកថយនៅបន្តចូលទៅមុខហើយដុតទូករបស់ពួកគេសូម្បីតែនៅពេលដែលការអនុវត្តការផ្លាស់ប្ដូរចាំបាច់ជាញឹកញាប់គួរឲ្យភ័យខ្លាចក៏ដោយ ហើយលទ្ធផលចុងក្រោយគឺកម្រនឹងប្រាកដណាស់។*

*អើរនី ឡាសុន (*Earnie Larson*) ត្រូវបានគេសរសើរដោយសារតែបាននិយាយថា «គ្មានអ្វីផ្លាស់ប្ដូរប្រសិនបើគ្មានអ្វីផ្លាស់ប្ដូរ ហើយប្រសិនបើខ្ញុំបន្តធ្វើអ្វីដែលខ្ញុំតែងតែធ្វើខ្ញុំនឹងបន្តទទួលបានអ្វីដែលខ្ញុំតែងតែទទួលបាន ហើយនឹងនៅតែបន្តមានអារម្មណ៍ដូចអ្វីដែលខ្ញុំតែងតែមានអារម្មណ៍»។* 1

សរុបមកនៅពេលអ្នកស្វែងរកការណែនាំដែលអ្នកត្រូវទៅក្នុងការស្ដារឡើងវិញជាថ្មីពេលវេលានៃការថ្វាយបង្គំរួមគ្នា នៅក្នុងក្រុមជំនុំរបស់អ្នកចូលដឹកនាំក្រុមជំនុំរបស់អ្នកនៅក្នុងពេលវេលានៃការកែជាថ្មីឡើងវិញខាងវិញ្ញាណ សម្រាប់ទាំងអស់គ្នាដើម្បីមករួមគ្នាស្វែងរកព្រះភក្ត្រនៃព្រះ។ ប្រមូលអ្នកចម្បាំងអធិស្ឋានរបស់អ្នកក៏ដូចជាក្រុមជំនុំទាំងមូលដើម្បីអធិស្ឋានសម្រាប់ការខិតខំប្រឹងប្រែងនេះ។ ចូរស្រឡាញ់មនុស្សរបស់អ្នកដោយឥតលក្ខខណ្ឌដូចដែលអ្នករស់នៅជីវិតជាក់ស្ដែងជាមួយពួកគេ ហើយបម្រើជាមួយពួកគេ។ នៅពេលអ្នកពិចារណាលើការផ្លាស់ប្ដូរ

ចូរស្វែងរកវិធីប្រើប្រាស់ការរុះរើឡើងវិញជាជាងការកម្ទេចចោល។ រក្សានិមិត្តដាក់នៅមុខមនុស្សជានិច្ចកាល-មិនត្រឹមតែហេតុផលប៉ុណ្ណោះទេ ថែមទាំងរបៀបផងដែរ។ បន្ទាប់មក សូមចាំថា នៅពេលដែលអ្នកមានអារម្មណ៍ថាចង់ដើរថយក្រោយពីរជំហាន បន្ទាប់ពីបោះជំហានទៅមុខ សូមគិតអំពីស្ដេចអាឡិចសាន់ឌឺ ដែលនឹងមិនអនុញ្ញាតឲ្យកងទ័ពរបស់ទ្រង់ដកថយឡើយ។ កុំងាកមើលទៅក្រោយ ចូររុលទៅមុខ សូមថ្វាយការសរសើរដល់ព្រះ!

នៅពេលអ្នកចាប់ផ្ដើមកំណត់គោលជំហរសម្រាប់អនាគតក្នុងការថ្វាយបង្គំព្រះវិហាររបស់អ្នក តើមានរឿងអ្វីខ្លះដែលអ្នកអាចចាប់ផ្ដើមអនុវត្ត ឬយ៉ាងហោចណាស់ ធ្វើជំហានសំខាន់ៗឆ្ពោះទៅមុខ ដែលអ្នកមានអារម្មណ៍ថានឹងធ្វើឲ្យការថ្វាយបង្គំក្នុងព្រះវិហាររបស់អ្នកប្រសើរឡើង?

**តើអ្នករៀនបានអ្វីខ្លះសំខាន់ជាងគេ ពីផ្នែកនេះ ដែលនឹងជួយអ្នកឆ្លងកាត់ការផ្លាស់ប្ដូរ ក្នុងការងារផ្នែកថ្វាយបង្គំ?**

# II. ការយល់ដឹងអំពីភាពជាអ្នកដឹកនាំការថ្វាយបង្គំ

នៅក្នុងជំពូកមុននេះយើងទទួលបានគំនិតកាន់តែប្រសើរឡើង អំពីអ្វីទៅជាការថ្វាយបង្គំ ហើយបានបកស្រាយអំពីគោលគំនិតសំខាន់ៗជាច្រើន ដែលយើងត្រូវចាប់យកក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ។ ឥឡូវនេះ បន្ទាប់ពីបានស្ថាបនានៅលើមូលដ្ឋាននៃជំពូកទី ១ យើងនឹងចាប់ផ្តើមធ្វើការសិក្សាតាមរយៈការយល់ដឹងជាមូលដ្ឋានមួយចំនួន អំពីអត្ថន័យនៃការធ្វើជាអ្នកដឹកនាំការថ្វាយបង្គំ — ទំនួលខុសត្រូវក្នុងការដឹកនាំក្រុមជំនុំក្នុងការថ្វាយបង្គំដែលព្រះបានប្រទានឲ្យអ្នក។ ប្រហែលជាកន្លែងល្អបំផុតដើម្បីចាប់ផ្តើម គឺដោយការយល់ដឹងថាព្រះត្រាស់ហៅយើងឲ្យធ្វើជាអ្នកដឹកនាំការថ្វាយបង្គំ។ វាគឺជាការត្រាស់ហៅដ៏ខ្ពស់ និងជាការទទួលខុសត្រូវដ៏ធំមួយ។ សម្រាប់មនុស្សជាច្រើន ការត្រាស់ហៅច្រើនតែមានលក្ខណៈដែលហាក់ដូចជាអាថ៌កំបាំង និងមិនសូវយល់ច្បាស់។

## ការត្រាស់ហៅឲ្យដឹកនាំការថ្វាយបង្គំ

ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ យើងចាំបាច់ត្រូវស្គាល់ការត្រាស់ហៅរបស់ព្រះមកលើជីវិតរបស់យើងចំពោះព័ន្ធកិច្ចការថ្វាយបង្គំ។ ដូច្នេះសូមយើងចំណាយពេលបន្តិច ដើម្បីយល់ពីការត្រាស់ហៅខុសៗគ្នា ដែលព្រះទ្រង់មានមកលើជីវិតរបស់យើង។ មានមេរៀនជាច្រើនដែលខ្ញុំនឹងចែករំលែកជាមួយអ្នក ចេញពីសៀវភៅដ៏ល្អបំផុតមួយ ស្តីពីការយល់ដឹងអំពីការត្រាស់ហៅរបស់ព្រះ តើព្រះកំពុងត្រាស់ហៅខ្ញុំទេ?[១] ដោយលោក ចែហ្វ អ័ហ្គ (Jeff Iorg)។ ខ្ញុំនឹងផ្តល់ជូនលោកអ្នកនូវសេចក្តីសង្ខេបដូចតទៅនេះ។

---

១ លោក Jeff Iorg, Is God Calling Me? : Answering the Question Every Believer Asks (Nashville: B&H Publishing Group, ឆ្នាំ២០០៨)។

## បទពិសោធន៍នៃការត្រាស់ហៅបីប្រភេទ

មានទិដ្ឋភាពបីយ៉ាងនៃការត្រាស់ហៅ ដែលគ្រីស្ទបរិស័ទអាចទទួលបាននៅក្នុងជីវិតរបស់ពួកគេ។ គ្រីស្ទបរិស័ទទាំងអស់នឹងទទួលការត្រាស់ហៅមួយ រីឯអ្នកផ្សេងទៀតនឹងទទួលបានការត្រាស់ហៅបីប្រភេទ។

### ១.ការត្រាស់ហៅជាសកលឲ្យគ្រីស្ទបរិស័ទបម្រើព្រះ

ព្រះត្រាស់ហៅគ្រីស្ទបរិស័ទគ្រប់រូប ឲ្យរស់នៅដើម្បីថ្វាយសិរីល្អដល់ព្រះ បង្កើតសិស្ស បម្រើអ្នកដទៃ និងរីកចម្រើនកាន់តែដូចព្រះគ្រីស្ទជារៀងរាល់ថ្ងៃ។ អ្នកដើរតាមព្រះគ្រីស្ទគ្រប់រូបទទួលបានការត្រាស់ហៅនេះ។ មានបទគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរ ដែលបានថែងពីការត្រាស់ហៅនេះ។ ឧទាហរណ៍ បទគម្ពីរអេភេសូរ ៤:១-៣៖

> *ដូច្នេះខ្ញុំជាអ្នកជាប់គុកក្នុងព្រះអម្ចាស់ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរឲ្យអ្នករាល់គ្នាដើរបែបគួរនឹងការងារដែលទ្រង់បានហៅមកធ្វើចុះ ព្រមទាំងមានចិត្តសុភាព ហើយស្លូតបូតគ្រប់ជំពូកទាំងអត់ធ្មត់ ហើយទ្រាំទ្រគ្នាទៅវិញទៅមកដោយស្រឡាញ់ ហើយខំប្រឹងរក្សាសេចក្ដីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្ដីមេត្រី ទុកជាចំណងផង។*

ចែហ្វ អ័ហ្គ (Jeff Iorg) បាននិយាយអំពីភាពតានតឹងដែលកើតឡើងជារឿយៗ ក្នុងការត្រាស់ហៅនេះ៖

> *ដូច្នេះ តើការត្រាស់ហៅជាសកលរបស់ព្រះ មានទំនាក់ទំនងអ្វីខ្លះជាមួយកិច្ចការបម្រើ និងមុខរបររបស់អ្នកជឿព្រះ? ព្រះទ្រង់ត្រាស់ហៅគ្រប់អ្នកជឿមកក្នុងកិច្ចការបម្រើព្រះ។ ការត្រាស់ហៅជាសកលរបស់ព្រះ ឲ្យធ្វើការបម្រើព្រះ អាចត្រូវបានបង្ហាញតាមរយៈវិជ្ជាជីវៈដ៏ស្មោះត្រង់ណាមួយ។ ព្រះសព្វព្រះទ័យ និងបង្ហាញភាពចាំបាច់នៃគ្រូបង្រៀនគ្រីស្ទបរិស័ទ ជាងទឹក មេធាវី ជាងជួសជុល គិលានុបដ្ឋាយិកា ហើយនិងជាងឈើជាច្រើននាក់។ ទោះជាយ៉ាងណាក៏ដោយ មានការត្រាស់ហៅខុសៗគ្នា ឲ្យធ្វើការជាថ្នាក់ដឹកនាំព័ន្ធកិច្ចដែលជាញឹកញាប់ នាំឲ្យមានតួនាទីក្នុងព័ន្ធកិច្ច។* [២]

---

២ ក្នុងសៀវភៅដូចគ្នា ទំព័រ២០។

## ២. ការត្រាស់ហៅទូទៅ ឲ្យធ្វើជាអ្នកដឹកនាំព័ន្ធកិច្ច

តាមការពិពណ៌នាខាងលើ ការត្រាស់ហៅជាទូទៅឲ្យដឹកនាំព័ន្ធកិច្ច គឺជាការត្រាស់ហៅដាច់ដោយឡែក។ ព្រះត្រាស់ហៅបុរស និងស្ត្រីមួយចំនួនឲ្យមានតួនាទីជាអ្នកដឹកនាំក្នុងព័ន្ធកិច្ចណាមួយ ឬមានទំនួលខុសត្រូវដូចជា ការអធិប្បាយ ការបង្រៀន ការគ្រប់គ្រង ការធ្វើជាគ្រូគង្វាល ការផ្សាយដំណឹងល្អ ការថ្វាយបង្គំ និងកិច្ចការផ្សេងទៀត។ តួនាទីទាំងនេះអាចជាមុខការងារពេញម៉ោង ឬក្រៅម៉ោង មានប្រាក់ខែ ឬមិនមានប្រាក់ខែ។ ការត្រាស់ហៅទូទៅ និងការត្រាស់ហៅជាសកល ឲ្យធ្វើការបម្រើព្រះ មានភាពខុសគ្នានៅត្រង់ការដឹកនាំ។ មនុស្សខ្លះត្រូវបានហៅឲ្យធ្វើជាអ្នកដឹកនាំគ្រីស្ទបរិស័ទ ខណៈពេលដែលមនុស្សទាំងអស់ត្រូវបានត្រាស់ហៅឲ្យបម្រើព្រះ។ ការត្រាស់ហៅពួកសិស្សរបស់ព្រះយេស៊ូវក្នុងព្រះគម្ពីរ គឺជាឧទាហរណ៍មួយដែលយើងអាចស្វែងយល់អំពីការត្រាស់ហៅទាំងនេះ។

ព្រះត្រាស់ហៅអ្នកដឹកនាំការថ្វាយបង្គំ ក្នុងការត្រាស់ហៅជាទូទៅ ឲ្យធ្វើការដឹកនាំព័ន្ធកិច្ច។ ការត្រាស់ហៅបញ្ជាក់ពីបំណងព្រះហឫទ័យ ដែលទ្រង់មានចំពោះយើង និងអំណោយទានដែលទ្រង់បានប្រទានដល់យើង។ បើយើងគ្រាន់តែដឹងថា ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យចូលរួមក្នុងតួនាទីដឹកនាំជាក់លាក់មួយ នោះគឺមិនគ្រប់គ្រាន់ទេ ដូចនេះ យើងក៏ត្រូវតែយល់ឲ្យកាន់តែច្បាស់អំពីរបៀប និងកន្លែងដែលយើងត្រូវប្រើប្រាស់តួនាទីនោះផងដែរ។

## ៣. ការត្រាស់ហៅជាក់លាក់ ឲ្យធ្វើការបម្រើព្រះដោយការចាត់តាំង

សម្រាប់អ្នកដែលត្រូវបានត្រាស់ហៅមកកាន់ការដឹកនាំព័ន្ធកិច្ច ការត្រាស់ហៅប្រភេទនេះនឹងឈានមកដល់ការចាត់តាំងជាក់លាក់ដែលបុគ្គលនោះត្រូវទទួល។ ជាឧទាហរណ៍ ព្រះជាម្ចាស់អាចត្រាស់ហៅអ្នកឲ្យដឹកនាំការថ្វាយបង្គំនៅក្នុងការត្រាស់ហៅទូទៅរបស់អ្នក ប៉ុន្តែនៅពេលណាមួយទ្រង់នឹងត្រាស់ហៅអ្នកឲ្យមានតួនាទីបម្រើជាក់លាក់ក្នុងក្រុមជំនុំ។ នេះជាមូលហេតុដែលការពិបាកកើតមានឡើង នៅពេលដែលយើងចង់ដឹងថា យើងត្រូវបម្រើក្នុងក្រុមជំនុំ ឬអង្គការព័ន្ធកិច្ចមួយណា និងពេលណាត្រូវផ្លាស់ពីក្រុមជំនុំ និងអង្គការមួយ ទៅក្រុមជំនុំ និងអង្គការមួយទៀត ហើយតើអ្នកមានតួនាទីអ្វី ក្នុងការងារបម្រើព្រះ (ការថ្វាយបង្គំបេសកកម្ម និងការគោរពបូជា ការថ្វាយបង្គំ និងពួកចាស់ទុំ)។ល។

ព្រះមានផែនការសម្រាប់អ្នកនៅក្នុងរឿងនេះ ហើយយើងត្រូវស្វែងរកបំណងព្រះហឫទ័យទ្រង់ ដើម្បីកំណត់ថា យើងត្រូវធ្វើកិច្ចការអ្វីឲ្យជាក់លាក់។ យើងអាច

មើលឃើញឧទាហរណ៍នៃការត្រាស់ហៅ និងការដឹកនាំរបស់ព្រះ ឲ្យធ្វើកិច្ចការជាក់លាក់ណាមួយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូល ជាពិសេសនៅក្នុងកណ្ឌគម្ពីរកិច្ចការ។

ព្រះត្រាស់ហៅគ្រីស្ទបរិស័ទទាំងអស់ ក្នុងការត្រាស់ហៅជាសកលឲ្យបម្រើទ្រង់ ហើយត្រាស់ហៅគ្រីស្ទបរិស័ទមួយចំនួនឲ្យដឹកនាំព័ន្ធកិច្ច ហើយអ្នកដែលទ្រង់ត្រាស់ហៅ ឲ្យដឹកនាំព័ន្ធកិច្ចក៏ទទួលបានការចាត់តាំងជាក់លាក់មួយដែរ។

## របៀបបីយ៉ាងដែលព្រះត្រាស់ហៅ

ប្រសិនបើអ្នកនិយាយជាមួយអ្នកដឹកនាំព័ន្ធកិច្ច នោះអ្នកនឹងដឹងថា ការធ្វើតាមការត្រាស់ហៅរបស់ព្រះ ទាំងក្នុងការត្រាស់ហៅទូទៅ និងការត្រាស់ហៅជាក់លាក់ មកលើជីវិតរបស់មនុស្សម្នាក់ អាចកើតមានតាមវិធីផ្សេងៗគ្នា។ តាមរយៈការនិយាយជាមួយអ្នកដទៃ និងការស្វែងរកអត្ថបទគម្ពីរ យើងឃើញថា មានវិធីចម្បងបីយ៉ាងដែលព្រះទ្រង់ត្រាស់ហៅអ្នកដឹកនាំព័ន្ធកិច្ច។ ជាថ្មីម្តងទៀត ខ្ញុំនឹងរៀបរាប់ពីវិធីបីយ៉ាងដែលលោក ចែហ្វ អ័ហ្គ (Jeff Iorg) បង្ហាញនៅក្នុងសៀវភៅរបស់គាត់។

### ១. ការដកពិសោធន៍ភ្លាមៗជាមួយការត្រាស់ហៅ

ព្រះទ្រង់ត្រាស់ហៅអ្នកខ្លះ តាមរយៈការបទការដកពិសោធន៍ជាមួយការអស្ចារ្យ ដែលកើតឡើងភ្លាមៗ គឺដូចកាលដែលលោកសូលបានប្រែចិត្តជឿព្រះនៅតាមផ្លូវទៅក្រុងដាម៉ាស ឬកាលដែលលោកម៉ូសេបានឃើញភ្លើងឆេះគុម្ពោតព្រៃ។ ពេលខ្លះព្រះអាចប្រើវិបត្តិក្នុងជីវិតរបស់អ្នក ដើម្បីឲ្យអ្នកមានការយកចិត្តទុកដាក់ចំពោះព្រះអង្គ ហើយជួយអ្នកឲ្យរកឃើញការត្រាស់ហៅមកលើជីវិតរបស់អ្នក។ ប្រហែលជាព្រះប្រើកាលៈទេសៈផ្សេងទៀត ដើម្បីឲ្យអ្នកធ្វើតាមបំណងព្រះហឫទ័យទ្រង់។ ការត្រាស់ហៅដោយការអស្ចារ្យដូចនេះ មានអំណាចណាស់ ប៉ុន្តែមិនបានកើតឡើងចំពោះអ្នកជឿទាំងអស់ទេ។ ចូរកុំមានអារម្មណ៍ថា អ្នកមានភាពតូចទាប ឬមានតម្លៃតិចជាងគេ ប្រសិនបើការត្រាស់ហៅរបស់អ្នក មិនបានកើតឡើងដោយការដកពិសោធន៍នឹងការត្រាស់ហៅភ្លាមៗ។

ការត្រាស់ហៅរបស់ខ្ញុំឲ្យចាកចេញពីព័ន្ធកិច្ចក្រុមជំនុំក្នុងតំបន់ដែលខ្ញុំស្រឡាញ់ ហើយផ្លាស់ទៅបម្រើក្នុងការងាររបស់និកាយ គឺជាការដកពិសោធន៍នឹងការត្រាស់ហៅភ្លាមៗ ក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំបានបម្រើការជាគ្រូគង្វាលផ្នែកបេសកកម្ម និងការថ្វាយបង្គំនៅក្រុមជំនុំមួយកន្លែងអស់រយៈពេល២៣ឆ្នាំនៅពេលនោះ។ ថ្ងៃមួយ ខ្ញុំ

បាននិយាយទៅកាន់ព្រះ ក្នុងគ្រាដែលខ្ញុំនៅតែម្នាក់ឯង ក្នុងការថ្វាយបង្គំផ្ទាល់ខ្លួន ដោយទូលព្រះអង្គថា "ព្រះអង្គអើយ ទូលបង្គំស្រឡាញ់ការងារនៅទីនេះ ហើយអាចចំណាយពេលពេញមួយជីវិតរបស់ទូលបង្គំបម្រើអ្នកនៅទីនេះបានយ៉ាងងាយស្រួល ប៉ុន្តែ ប្រសិនបើមានអ្វីផ្សេងទៀតដែលទ្រង់ចង់ឲ្យទូលបង្គំធ្វើ ក្នុងជីវិតរបស់ទូលបង្គំ សូមប្រាប់ទូលបង្គំផង»។ ក្នុងរយៈពេល២៤ម៉ោង រឿងដែលមិននឹកស្មានដល់បានកើតឡើងជាបន្តបន្ទាប់។ គេមិនអាចពន្យល់ថា រឿងទាំងនោះគឺជាការចៃដន្យបានឡើយ។ បន្ទាប់ពីមានការភ្ញាក់ផ្អើលពីរបីសប្តាហ៍ជាប់គ្នា ខ្ញុំមានទំនុកចិត្ត ១០០% ថា ព្រះកំពុងត្រាស់ហៅខ្ញុំឲ្យធ្វើការជាអ្នកប្រឹក្សាយោបល់ផ្នែកថ្វាយបង្គំ សម្រាប់ក្រុមជំនុំ អិនស៊ី បាទីស (NC Baptists)។ ខ្ញុំអាចបន្ថែមថា ការបញ្ជាក់អំពីការត្រាស់ហៅយ៉ាងដូចនេះ គឺជាជំនួយដ៏អស្ចារ្យនៅប៉ុន្មានសប្តាហ៍ នៅពេលដែលខ្ញុំធ្លាក់ទឹកចិត្ត ហើយប្រហែលជាចង់បោះចោលការតស៊ូ។ ក្នុងគ្រានោះ ព្រះរំឭកខ្ញុំថា ទ្រង់ពិតជាបានត្រាស់ហៅខ្ញុំមកកន្លែងនេះ ហើយមិនបានហៅខ្ញុំឲ្យទៅឆ្ងាយទេ។ ខ្ញុំអាចបម្រើដោយការខ្នះខ្នែងជាថ្មី ដោយគ្រាន់តែចងចាំការត្រាស់ហៅដ៏ច្បាស់លាស់នេះមកលើជីវិតខ្ញុំ។

## ២. ការសម្រេចចិត្តដែលមានហេតុផល

នៅពេលអ្នកកំពុងស្វែងរកព្រះហឫទ័យរបស់ព្រះ សម្រាប់ការត្រាស់ហៅជាទូទៅ ឬជាពិសេសរបស់អ្នក ជួនកាល អ្នកត្រូវមានហេតុផលក្នុងការសម្រេចចិត្តផ្សេងៗ ខណៈពេលអ្នកពឹងផ្អែកលើព្រះអង្គ ក្នុងការអធិស្ឋាន និងការសិក្សាព្រះគម្ពីរ។ ជារឿយៗ ការត្រាស់ហៅទាំងនេះអាចកើតឡើងក្នុងរយៈពេលយូរ។

ការត្រាស់ហៅទៅកាន់ ក្រុមជំនុំដំបូងរបស់ខ្ញុំ បន្ទាប់ពីបញ្ចប់ការសិក្សាពីសាលាព្រះគម្ពីរ គឺជាការសម្រេចចិត្តដ៏សមហេតុផលមួយ។ ខ្ញុំមានចំណាប់អារម្មណ៍មកលើក្រុមជំនុំបីកន្លែង ហើយពួកគេក៏បានសម្ភាសខ្ញុំ ក្នុងអំឡុងពេលសប្តាហ៍តែមួយ។ ខ្ញុំ និងភរិយាខ្ញុំបានអធិស្ឋាន សុំឲ្យព្រះអង្គជួយយើងឲ្យយល់ច្បាស់អំពីការត្រាស់ហៅ ប្រសិនបើក្រុមជំនុំមួយ ក្នុងចំណោមក្រុមជំនុំទាំងបីនេះ គឺជាកន្លែងដែលយើងត្រូវប្រើពេលវេលានៃជីវិត ធ្វើការបម្រើព្រះនៅទីនោះ។ យើងចំណាយពេលច្រើន ក្នុងការពិភាក្សាជាមួយគ្រូគង្វាលនៃក្រុមជំនុំទាំងបី និងក្រុមជ្រើសរើស។ ខ្ញុំបានពិនិត្យមើល ថាតើគ្រូគង្វាល និងក្រុមជំនុំនោះ មានការយល់ស្របនឹងការជឿជាក់ និងការបង្រៀនរបស់ខ្ញុំអំពីការថ្វាយបង្គំយ៉ាងណាខ្លះ។ នៅពេលយើងអធិស្ឋាន ហើយពិចារណាដោយមានហេតុផល នោះយើងមានអារម្មណ៍

ថា យើងមានការជឿជាក់ ទទួលបានការបណ្ដាលចិត្ត និងមានចិត្តរំភើបរីករាយចំពោះផ្នែកទាំងអស់នៃក្រុមជំនុំមួយកន្លែង នៅទីក្រុងស្ពេគវីល រដ្ឋឃែរ៉ូឡាយណាខាងជើង។ យើងមានអារម្មណ៍លែងសង្ស័យថា វាជាកន្លែងយើងត្រូវធ្វើការជាមួយ។ ជួនកាល ព្រះបានបញ្ជាក់ការត្រាស់ហៅនោះក្នុងរយៈពេល២៣ឆ្នាំបន្ទាប់ពីយើងបានចាប់ផ្ដើមការបម្រើនៅទីនោះ។

## ៣. ការជំរុញពីអ្នកដទៃ

ពេលខ្លះ ព្រះនឹងបញ្ជូនអ្នកនាំសារណាម្នាក់ ឬច្រើននាក់ ដើម្បីនាំសេចក្ដីពិតរបស់ទ្រង់មកកាន់អ្នក។ អ្នកនោះអាចជាអ្នកប្រឹក្សាយោបល់ មិត្តភក្ដិ ឬសូម្បីតែនរណាម្នាក់ដែលអ្នកមិនស្គាល់។ ការត្រាស់ហៅរបស់លោក បាណាបាស និងសូល ឲ្យទៅធ្វើការងារបេសកកម្មនៅក្នុង បទគម្ពីរកិច្ចការ ជំពូក១៣ បានកើតឡើងយ៉ាងដូចនេះឯង។ ព្រះពិតជាអាចប្រើកូនរបស់ទ្រង់ឲ្យបញ្ជូនសារមក។

មិត្តភក្ដិរបស់ខ្ញុំ ជាអ្នកដឹកនាំការថ្វាយបង្គំឈ្មោះ ដានីយ៉ែល បាយ័រ (Daniel Byers) បានចែករំលែកជាមួយខ្ញុំ នូវរឿងដ៏គួរឲ្យកត់សម្គាល់នៃការត្រាស់ហៅប្រភេទនេះក្នុងជីវិតរបស់គាត់។ ពេលចូលរួមការបោះជំរំការកែជាថ្មីខាងវិញ្ញាណរយៈពេលបីថ្ងៃ ក្រោមប្រធានបទថា «ដំណើរទៅភូមិអេម៉ោស» មានបុរសម្នាក់ដែលដានីយ៉ែលមិនធ្លាប់ជួប បានមករកគាត់ ហើយប្រាប់គាត់ថា គាត់មានព្រះរាជសារពីព្រះ។ ដានីយ៉ែលសប្បាយចិត្តបន្តិច ហើយបានសួរគាត់ថា អំពីព្រះរាជសារដែលព្រះចង់ប្រាប់នោះ។ បុរសនោះក៏បាននិយាយថា «អ្នកនឹងក្លាយជាអ្នកបម្រើព្រះ»។ ដានីយ៉ែលបន្តទៀតថា៖

> *ខ្ញុំមិនចង់ខ្វះការគួរសម តែខ្ញុំក៏បានសើចបន្តិច នៅចំពោះមុខបុរសនោះ។ ខ្ញុំបានប្រាប់គាត់ថា «មិនអីទេ អរគុណ» ហើយខ្ញុំដើរចេញទៅ។ ឥឡូវនេះ ក្នុងការចម្រើនវ័យធំឡើង ជាកូនរបស់គ្រូគង្វាល មានពេលច្រើនដងដែលខ្ញុំដឹងថា ព្រះអម្ចាស់កំពុងត្រាស់ហៅខ្ញុំ ឲ្យធ្វើការបម្រើព្រះអង្គ ប៉ុន្តែ ខ្ញុំបានបដិសេធដោយសារតែខ្ញុំបានមើលឃើញការលំបាករបស់ឪពុកខ្ញុំ ក្នុងការងាររបស់គាត់។ ឪពុករបស់ខ្ញុំបានបម្រើ ក្នុងតួនាទីផ្សេងៗនៅក្នុងព្រះវិហារជាច្រើន ដូចជាគ្រូគង្វាល គ្រូគង្វាលយុវជន និងគ្រូគង្វាលចាស់ទុំ។ ខ្ញុំដឹងថា ការហៅចូលព័ន្ធកិច្ចអាចមានការលំបាកប៉ុណ្ណា ។*
>
> *ប្រហែលពីរឆ្នាំក្រោយមក អ្នកផ្ដល់សេវាកម្មផ្នែកបច្ចេកទេសម្នាក់ បានមកដល់ផ្ទះរបស់យើង។ ខ្ញុំមិនដែលឃើញបុរសនោះពីមុនមកទេ។ បន្ទាប់*

*ពីបានជួសជុលរួចរាល់ គាត់បានសួរខ្ញុំថា តើខ្ញុំជឿលើព្រះយេស៊ូវគ្រីស្ទឬទេ? ខ្ញុំបានប្រាប់គាត់ថា ខ្ញុំជឿ។ គាត់ក៏បានឆ្លើយតបថា «ព្រះមានសារមួយសម្រាប់អ្នក»។ ខ្ញុំភ្ញាក់ផ្អើលដោយដឹងថា គាត់ចង់និយាយអ្វី ខ្ញុំក៏សុំគាត់ប្រាប់សារនោះមកខ្ញុំ។ គាត់ប្រាប់ខ្ញុំថា ខ្ញុំនឹងក្លាយជាអ្នកបម្រើព្រះក្នុងពេលឆាប់ៗនេះ។ ខ្ញុំសើចម្តងទៀត ហើយនិយាយថា អូខេ អរគុណ។ បន្ទាប់មកបុរសនោះក៏ចាកចេញ ហើយខ្ញុំមិនដែលឃើញគាត់ទៀតទេ។*

គ្រូគង្វាលច្បងនៅក្នុងព្រះវិហារ ដែលដានីយ៉ែលបានចូលរួម បានសុំឲ្យគាត់ផ្លាស់ទៅធ្វើជាអ្នកដឹកនាំផ្នែកថ្វាយបង្គំនៅទីនោះ ដោយហេតុថាគ្រូគង្វាលផ្នែកថ្វាយបង្គំរបស់ពួកគេ បានចាកចេញពីព្រះវិហារនាពេលថ្មីៗនេះ។ ថ្វីបើមនុស្សដែលដានីយ៉ែលមិនបានស្គាល់ បានមកប្រាប់គាត់ថា គាត់ត្រូវចូលទៅក្នុងព័ន្ធកិច្ចក៏ដោយ ក៏ដានីយ៉ែលបានឆ្លើយតបថា គាត់ត្រូវការការត្រាស់ហៅយ៉ាងខ្លាំង ដែលដូចជាបទពិសោធន៍របស់ម៉ូសេ ទើបគាត់និយាយថា "បាទ" ចំពោះឱកាសនៃការបម្រើព័ន្ធកិច្ចនេះ។

ក្រោយមកនៅឆ្នាំនោះ ពេលទៅលេងឪពុកម្តាយគាត់ គ្រួសាររបស់ដានីយ៉ែលបានចូលរួមថ្វាយបង្គំនៅព្រឹកថ្ងៃអាទិត្យមួយនៅព្រះវិហារ ដែលឪពុកគាត់បានអធិប្បាយពីបទគម្ពីរទំនុកតម្កើង ១០០:១-៥។ ដានីយ៉ែលបានបញ្ចេញមតិថា៖

*នៅព្រឹកនោះ ពេលឪពុកខ្ញុំអធិប្បាយ ខ្ញុំបានដកពិសោធន៍ជាមួយការត្រាស់ហៅភ្លាមៗដូចលោកម៉ូសេ។ ព្រះបានមានបន្ទូលមកខ្ញុំ ក្នុងរបៀបដែលមិនធ្លាប់មាន។ ខ្ញុំក៏បានដឹងដោយគ្មានការសង្ស័យថា ព្រះអង្គកំពុងត្រាស់ហៅខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំជាមនុស្សតែម្នាក់គត់នៅក្នុងបន្ទប់នោះ ហើយខ្ញុំដឹងច្បាស់ថាទ្រង់កំពុងត្រាស់ហៅខ្ញុំឲ្យចូលបម្រើព័ន្ធកិច្ច។ ព្រះបានប្រើមនុស្សពីរនាក់ដែលខ្ញុំមិនស្គាល់សោះ ឲ្យនាំព្រះរាជសារមួយដើម្បីត្រាស់ហៅខ្ញុំឲ្យចូលបម្រើព្រះ។*

ដានីយ៉ែលបានចុះចូលចំពោះការត្រាស់ហៅរបស់ព្រះក្នុងជីវិតរបស់គាត់ ហើយបង្ហាញថា វាជាការសម្រេចចិត្តដ៏ល្អបំផុតមួយដែលគាត់មិនធ្លាប់មាន។ ខណៈពេលដែលការបំផុសគំនិតពីអ្នកដទៃ ច្រើនតែមកពីមនុស្សដែលអ្នកស្គាល់ ព្រះអាចប្រើមនុស្សដែលអ្នកមិនស្គាល់សោះ ដើម្បីបញ្ជូនការត្រាស់ហៅរបស់ទ្រង់មកកាន់អ្នកផងដែរ។

## ការស្គាល់ការត្រាស់ហៅរបស់ព្រះ

លោក អ័ហ្គ (Iorg) លើកឡើងអំពីវិធីមួយចំនួនដែលគ្រីស្ទបរិស័ទអាចយល់ដឹងអំពីការត្រាស់ហៅរបស់ព្រះ។ ព្រះវិញ្ញាណបរិសុទ្ធផ្តល់ឲ្យអ្នកនូវសន្តិភាពក្នុងការសម្រេចចិត្ត។ អ្នកទទួលបានការបញ្ជាក់ពីអ្នកដទៃថា ការសម្រេចចិត្តរបស់អ្នកហាក់ដូចជាត្រឹមត្រូវ។ នៅពេលអ្នកវាយតម្លៃប្រសិទ្ធភាពរបស់អ្នកក្នុងការបម្រើព្រះ អ្នកក៏បានដឹងថាព្រះទ្រង់បានបំពាក់សមត្ថភាពដល់អ្នក សម្រាប់ការត្រាស់ហៅនោះ។ ហើយអ្នកមានអំណរក្នុងការបម្រើព្រះ។ ជាញឹកញយ មនុស្សមិនហ៊ានធ្វើតាមការត្រាស់ហៅរបស់ព្រះក្នុងជីវិតរបស់ពួកគេ ដោយសារពួកគេជឿថា ពួកគេនឹងត្រូវលះបង់អ្វីដែលអាចនាំមកនូវសេចក្តីអំណរដល់ជីវិតរបស់ពួកគេ។ ពួកគេតែងតែមើលឃើញការលះបង់។ ពេលអ្នកកាត់តម្រឹមខ្លួនឯងជាមួយនឹងការត្រាស់ហៅរបស់ព្រះក្នុងជីវិតអ្នក ហើយនឹងរកឃើញអំណរដ៏អស្ចារ្យបំផុតដែលអ្នកអាចធ្វើទៅបាន។ នោះមិនមែនមានន័យថា ជីវិតនឹងមានភាពងាយស្រួល ហើយគ្មានការពិបាកនោះទេ ប៉ុន្តែ វាមានន័យថាព្រះគង់នៅជាមួយអ្នកក្នុងគ្រប់ការទាំងអស់ ហើយអ្នកនឹងរកឃើញនូវសេចក្តីអំណរ អត្ថន័យ និងគោលបំណងក្នុងជីវិតដ៏អស្ចារ្យ។

### ព្រះអាចនឹងប្រើមធ្យោបាយផ្សេងៗរួមផ្សំគ្នា ដើម្បីបង្ហាញការត្រាស់ហៅរបស់ទ្រង់។

ក្នុងមេរៀនមុន ខ្ញុំបានបង្ហាញពីវិធីបីយ៉ាង ដែលព្រះត្រាស់ហៅយើង ប៉ុន្តែ ក៏ខ្ញុំត្រូវតែចង្អុលបង្ហាញថា ពេលខ្លះ ព្រះនឹងប្រើវិធីពីរយ៉ាងក្នុងចំណោមវិធីទាំងបី ឬប្រើវិធីទាំងបីតែម្តង ដើម្បីឲ្យមនុស្សដឹងច្បាស់ថាព្រះអង្គកំពុងត្រាស់ហៅពួកគេ។

ខ្ញុំគឺជាមនុស្សរឹងរូសម្នាក់ ដែលត្រូវការព័ត៌មានពេញលេញ មុននឹងធ្វើការសម្រេចចិត្តជ្រើសរើសអាជីពរបស់ខ្ញុំ។ ការត្រាស់ហៅខ្ញុំឲ្យធ្វើជាអ្នកដឹកនាំការថ្វាយបង្គំ មានលក្ខណៈដូចនេះឯង។ ខ្ញុំបានចូលរៀននៅមហាវិទ្យាល័យដោយមានទំនុកចិត្តថា ខ្ញុំអាចបម្រើព្រះបានល្អបំផុតក្នុងនាមជាគ្រូពេទ្យ។ ខ្ញុំស្រឡាញ់វិទ្យាសាស្ត្រ និងគណិតវិទ្យាដោយចិត្តឆេះឆួល ហើយស្រឡាញ់កម្មវិធីសិក្សាត្រៀមចូលសាលាពេទ្យនៅសកលវិទ្យាល័យ (UNC-Chapel Hill)។ បន្ទាប់មក ព្រះបានប៉ះពាល់ចិត្តខ្ញុំ ដោយការដកពិសោធន៍នឹងការត្រាស់ហៅភ្លាមៗ— តាមរយៈជំងឺមហារីករបស់ម្តាយខ្ញុំ។ បញ្ហានេះបានធ្វើឲ្យជីវិតខ្ញុំរង្គោះរង្គើ។ លើសពីនេះទៀត គេបានដាក់ខ្ញុំនៅក្នុងមុខតំណែងជាអ្នកដឹកនាំនៅក្នុងសម្ព័ន្ធនិស្សិតបាទីស្ទ នៅក្នុង

ផ្នែកថ្វាយបង្គំ និងតន្ត្រី ហើយមានភារកិច្ចឲ្យដឹកនាំក្រុមចម្រៀង ជាអ្វីដែលខ្ញុំមិនដែលនឹកស្មានដល់។ គេបានបន្តស្នើឲ្យខ្ញុំទទួលតួនាទីដឹកនាំព័ន្ធកិច្ចផ្សេងទៀត។ បន្ទាប់មកមានមនុស្សជាច្រើនមកសួរខ្ញុំថា តើខ្ញុំបានគិតថា ព្រះប្រហែលជាត្រាស់ហៅខ្ញុំទៅបម្រើឬទេ—នេះជាការបំផុសគំនិតពីអ្នកដទៃ។ នៅទីបំផុតខ្ញុំចាប់ផ្ដើមយល់ស្របថា នេះប្រហែលជាអ្វីដែលព្រះកំពុងធ្វើនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំបានចាប់ផ្ដើមស្វែងរកការប្រឹក្សាយោបល់ពីគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំ រួមទាំងអ្នកបម្រើក្នុងបរិវេណសាលារបស់ខ្ញុំ គ្រូគង្វាលរបស់ខ្ញុំ មនុស្សដែលនៅមហាសន្និបាតបាទីស្ទដែលខ្ញុំបានស្គាល់ និងមិត្តភក្ដិដែលស្គាល់ខ្ញុំច្បាស់។ ខ្ញុំបានចំណាយពេលអានអំពីព្រះហឫទ័យរបស់ព្រះ អធិស្ឋាន ស្វែងរកចម្លើយពីក្នុងព្រះគម្ពីរ ហើយនិងអ្វីៗជាច្រើនទៀត។ អស់រយៈពេលជិតមួយឆ្នាំ ខ្ញុំបានឆ្លងកាត់ការសម្រេចចិត្តដែលសមហេតុផលនៅពេលខ្ញុំស្វែងរកឃើញចម្លើយ។ នៅទីបំផុត ខ្ញុំបានប្ដូរមុខជំនាញរបស់ខ្ញុំទៅតន្ត្រី ហើយបានចាប់ផ្ដើមដំណើរការទៅរកការសិក្សាដែលខ្ញុំត្រូវការ សម្រាប់ការត្រាស់ហៅថ្មីក្នុងជីវិតរបស់ខ្ញុំ។ ដំណើរការនេះនាំឲ្យខ្ញុំកាន់តែមានភាពជិតស្និទ្ធនឹងព្រះ ហើយបានផ្ដល់ឲ្យខ្ញុំនូវគោលបំណងថ្មី និងចំណង់ចំណូលចិត្តសម្រាប់ការត្រាស់ហៅរបស់ខ្ញុំ។

រឿងរបស់អ្នកនឹងមានលក្ខណៈពិសេសខុសពីអ្នកដទៃ។ ចូរយើងគ្រាន់តែទទួលស្គាល់ថា ព្រះប្រើវិធីជាច្រើនដើម្បីជួយយើងឲ្យយល់ដឹងពីការត្រាស់ហៅរបស់ទ្រង់។ ខ្ញុំបាននឹកចាំពីការសិក្សាដែលផ្លាស់ប្ដូរជីវិតដែលខ្ញុំធ្លាប់ឆ្លងកាត់មានចំណងជើងថា ការដកពិសោធន៍ជាមួយព្រះ និពន្ធដោយ ហេនរី ប្លែការប៊ី (Henry Blackaby) និង ខ្លូដ យីង (Claude King)។ ក្នុងការសិក្សានោះអ្នកនិពន្ធសរសេរថា «ព្រះមានបន្ទូលដោយព្រះវិញ្ញាណបរិសុទ្ធតាមរយៈព្រះគម្ពីរ ការអធិស្ឋាន កាលៈទេសៈផ្សេងៗ និងតាមរយៈក្រុមជំនុំ ដើម្បីបង្ហាញអង្គទ្រង់ គោលបំណង និងផ្លូវរបស់ព្រះអង្គឲ្យគេស្គាល់»។[៣] ខ្ញុំជឿថា នេះគឺស្របតាមរបៀបដែលព្រះត្រាស់ហៅ។ នៅពេលអ្នកកំពុងស្វែងរកការត្រាស់ហៅរបស់ទ្រង់ សូមចូលរួមការសិក្សាព្រះគម្ពីរ និងការអធិស្ឋានទូលសូមឲ្យព្រះបង្ហាញបំណងព្រះហឫទ័យទ្រង់។ ចូរពិភាក្សាជាមួយគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំ (ក្រុមជំនុំ) ហើយរកមើលកាលៈទេសៈដែលព្រះបានប្រើក្នុងជីវិតរបស់អ្នក ដើម្បីរៀបចំអ្នកសម្រាប់ការត្រាស់ហៅនេះ។

---

៣ លោក Henry Blackaby និង Claude King, Experiencing God: Knowing and Doing the Will of God (United States: B&H Publishing Group, ឆ្នាំ២០០៨) ទំព័រ៥៧។

**ចូរចំណាយពេលខ្លះ ដើម្បីឆ្លុះបញ្ចាំងពីជីវិតផ្ទាល់ខ្លួនរបស់អ្នក និងការត្រាស់ហៅ។ តើអ្នកមានទំនុកចិត្តថា ព្រះបានត្រាស់ហៅអ្នកឲ្យធ្វើជាអ្នកដឹកនាំការថ្វាយបង្គំឬទេ? តើអ្នកពិបាកក្នុងការកំណត់ថា តើទ្រង់កំពុងត្រាស់ហៅអ្នកឬ? តើអ្នកប្រាកដក្នុងចិត្តថា ទ្រង់កំពុងត្រាស់ហៅ ប៉ុន្តែ អ្នកបន្តមិនអើពើនឹងការត្រាស់ហៅនោះឬ?**

## ពេលវេលាចម្បង និងសំខាន់ក្នុងជីវិតរបស់ខ្ញុំមានការទាក់ទងនឹងការត្រាស់ហៅ និងចិត្តឆេះឆួល

មុនពេលយើងបន្តទៅមុខទៀត ខ្ញុំចង់ចែករំលែកបទពិសោធន៍នៃការត្រាស់ហៅនេះបន្ថែមទៀត ព្រោះវាបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំយ៉ាងច្រើន ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ អ្នកពិគ្រោះយោបល់ និងជាគ្រូបង្រៀន។ នេះមិនត្រឹមតែបង្ហាញពីការតស៊ូរបស់ខ្ញុំ ក្នុងការត្រាស់ហៅប៉ុណ្ណោះទេ ប៉ុន្តែ វានឹងជួយអ្នកឲ្យយល់អំពីទស្សនៈជាច្រើននៃសៀវភៅនេះទៅមុខទៀត។ សូមកុំរំលងវគ្គនេះ ព្រោះខ្ញុំជឿជាក់ថា ការសិក្សារបស់ខ្ញុំមានមូលដ្ឋានលើសៀវភៅដែលនៅសល់ទាំងប៉ុន្មានទៀត។

ការងារបម្រើព្រះរបស់ខ្ញុំនៅពេលក្រោយមកទៀត មានក្រុមជំនុំចំនួនបួនដែលបានទាក់ទងមកខ្ញុំ ក្នុងរយៈពេលពីរថ្ងៃ ដោយសុំឲ្យខ្ញុំពិចារណាអំពីការបម្រើនៅក្រុមជំនុំរបស់ពួកគេ ក្នុងនាមជាគ្រូគង្វាលផ្នែកថ្វាយបង្គំ។ រឿងនេះបានទាក់ទាញការចាប់អារម្មណ៍របស់ខ្ញុំ ដោយសារតែខ្ញុំមិនបានដាក់ប្រវត្តិរូបរបស់ខ្ញុំទៅកន្លែងណាមួយ ដូចជាអ្នកដែលចង់ផ្លាស់ប្តូរការងារនោះទេ។ ខ្ញុំមិនបានគិតចង់ចាកចេញពីក្រុមជំនុំដែលខ្ញុំកំពុងបម្រើនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនអាចមើលរំលងការពិតដែលថា ក្រុមជំនុំបួនបានទាក់ទងមកខ្ញុំក្នុងរយៈពេលពីរថ្ងៃជាប់គ្នា។ ក្នុងរយៈពេលមួយសប្តាហ៍ក្រុមជំនុំមួយចំនួនផ្សេងទៀតក៏បានទាក់ទងមកដែរ។ មានរឿងអ្វីមួយកើតឡើងហើយ។ ខ្ញុំមានអារម្មណ៍ថា ព្រះពិតជាកំពុងព្យាយាមទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំ។

នៅពេលខ្ញុំព្យាយាមស្វែងរកព្រះហឫទ័យរបស់ព្រះ នៅក្នុងការជ្រើសរើសក្រុមជំនុំដែលព្រះចង់ឲ្យខ្ញុំនៅបម្រើនោះ ខ្ញុំអាចបង្រួមជម្រើសមកនៅត្រឹមក្រុមជំនុំចំនួនប្រាំនៅសហរដ្ឋអាមេរិក - ក្រុមជំនុំចំនួនពីរនៅរដ្ឋ នត ឃែរ៉ូឡាញណា (North Carolina) មួយនៅរដ្ឋ សោត ឃែរ៉ូឡាញណា (South Caroli-

na) មួយទៀតនៅរដ្ឋ តិចសាស់ ហើយនិងក្រុមជំនុំដែលខ្ញុំបានបម្រើបច្ចុប្បន្ននេះ (ប្រហែលជាព្រះមិនបានហៅខ្ញុំចេញទេ?) នៅសប្តាហ៍ដដែលនោះ ខ្ញុំបានទទួលខិត្តប័ណ្ណស្តីពីសន្និបាតការថ្វាយបង្គំនៅឯក្រុមជំនុំមួយផ្សេងទៀត នៅក្នុងតំបន់ដូចគ្នានៃរដ្ឋតិចសាស់ ជាមួយនឹងក្រុមជំនុំដែលបានទាក់ទងខ្ញុំ។ ពីមុនខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវការពេលវេលានៃការដកថយ និងការបន្តឡើងវិញនៅក្នុងវិស័យនៃការថ្វាយបង្គំ។ ខ្ញុំក៏ចាប់អារម្មណ៍ក្នុងការធ្វើដំណើរទៅដោយមិនបានប្រកាសនៅក្រុមជំនុំ នៅរដ្ឋតិចសាស់ ដែលបានទាក់ទងមកខ្ញុំនោះ។ ខ្ញុំបានដឹងតិចតួចថា ពេលវេលារបស់ខ្ញុំនៅរដ្ឋតិចសាស់ នឹងមានឥទ្ធិពលបែបនេះមកលើជីវិតរបស់ខ្ញុំ ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ។

ខ្ញុំ និងមិត្តដ៏ល្អរបស់ខ្ញុំម្នាក់ឈ្មោះ ធីម ស្ទូត (Tim Stutts) ហើយខ្ញុំក៏បានទៅសន្និបាតនោះ។ (កាលនោះមក គាត់កំពុងបម្រើជាគ្រូគង្វាលយុវជនបណ្តោះអាសន្ន នៅក្រុមជំនុំដែលខ្ញុំបម្រើ)។ នៅព្រឹកថ្ងៃអាទិត្យ យើងបានចូលរួមកម្មវិធីនៅព្រះវិហារក្នុងរដ្ឋតិចសាស់ ដែលបានទាក់ទងមកខ្ញុំនោះ។ ពួកគេបានដំណើរការដោយមានមនុស្សសរុបចំនួនជាង២០០០នាក់ នៅក្នុងកម្មវិធីថ្វាយបង្គំចំនួនបីលើក ដែលកម្មវិធីពីរលើកជាកម្មវិធីថ្វាយបង្គំបែបលាយបញ្ចូលគ្នា ហើយកម្មវិធីថ្វាយបង្គំមួយលើកទៀត គឺជាការថ្វាយបង្គំបែបសហសម័យ។ យើងបានសម្រេចចិត្តចូលរួមកម្មវិធីថ្វាយបង្គំក្នុងរចនាបថទាំងពីរ។ ព្រះវិហារបានរីកចម្រើនយ៉ាងឆាប់រហ័ស ហើយខាងក្រៅមើលទៅមានសុខភាពល្អណាស់។ អ្វីដែលព្រះបានបង្ហាញខ្ញុំនៅថ្ងៃនោះបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល។ ខ្ញុំជឿថាទ្រង់កំពុងប្រើពេលនេះ ដើម្បីធ្វើអ្វីមួយក្នុងជីវិតរបស់ខ្ញុំ ប៉ុន្តែ មិនប្រាកដថាជាអ្វីនោះទេ។

កម្មវិធីថ្វាយបង្គំចម្រុះគឺជា «សមិទ្ធផល» ដ៏អស្ចារ្យដែលគ្រប់ផ្នែកនៃកម្មវិធីមានការហាត់សមយ៉ាងល្អ ហើយគ្រូគង្វាលបានផ្តល់នូវដំណើរការមួយយ៉ាងល្អ។ តែវាហាក់បីដូចជាការក្លែងបន្លំ។ យោងតាមសៀវភៅនេះ អ្វីៗគ្រប់យ៉ាងត្រូវបានធ្វើត្រឹមត្រូវ ប៉ុន្តែ ហាក់ដូចជាបាត់ធាតុផ្សំដ៏សំខាន់មួយគឺព្រះ។ ខ្ញុំមិនអាចលូកដៃចូលបានទេ។ កម្មវិធីថ្វាយបង្គំសហសម័យធ្វើបានយ៉ាងល្អណាស់។ កន្លែងនេះត្រូវបានប្រមូលផ្តុំទៅដោយមនុស្សមានសមត្ថភាព (ប្រហែល១០០០នាក់) ហើយក្រុមតន្ត្រីថ្វាយបង្គំ និងអ្នកចម្រៀងដែលបានរៀបចំយ៉ាងល្អកំពុងធ្វើការងារទាំងអស់តាមសៀវភៅដោយមានបទចម្រៀងថ្វាយបង្គំថ្មីបំផុត ដែលរួមបញ្ចូលគ្នាយ៉ាងល្អជាឈុតៗ។ ប៉ុន្តែ មានបញ្ហាចម្បងមួយ។ ខ្ញុំស្ទើរតែមានអារម្មណ៍រមួលពោះ គ្រប់ពេលខ្ញុំមើលជុំវិញ ឃើញអ្វីដែលព្រះកំពុងទតឃើញ។ មនុស្សនៅលើឆាកសម្តែង

ដូចជាការប្រគំតន្ត្រីបែបសម័យទំនើប ហើយក្រុមជំនុំ (ទស្សនិកជន) កំពុងឈរ ហើយហាក់ដូចជាមានពេលវេលាដ៏ល្អ ប៉ុន្តែ មិនចូលរួមតាមរបៀបដែលជាក់ស្តែងនោះទេ។ ស្ទើរតែគ្មាននរណាម្នាក់ច្រៀងសរសើរព្រះ។ គ្មាននរណាម្នាក់ទំនងនៅជាប់នឹងការថ្វាយបង្គំទាល់តែសោះ។ មនុស្សទាំងនោះជាអ្នកទស្សនាមួយហ្វូង។ ក្រោយមកនៅថ្ងៃដដែលនោះព្រះជាម្ចាស់បានដឹកនាំខ្ញុំទៅកាន់បទគម្ពីរ វិវរណៈ ជំពូក២ និងជំពូក៣ដែលជាដំណើររឿងនៃក្រុមជំនុំនៅក្រុងអេភេសូរ ដែលរវល់នឹងកិច្ចការរបស់ព្រះ ប៉ុន្តែ ពួកគេបានបោះបង់ចោលសេចក្តីស្រឡាញ់ដំបូងរបស់ពួកគេ និងដំណើររឿងនៃក្រុមជំនុំនៅក្រុងសាឌីស ដែលល្បីថានៅរស់ ប៉ុន្តែ បានស្លាប់ហើយ។ ព្រះបានបង្ហាញខ្ញុំថា ក្រុមជំនុំនេះពិតជារវល់នឹងការរីកចម្រើន និងរវល់នឹងការផ្តល់ឲ្យកម្មវិធីជាច្រើន—វាពិតជាមើលទៅដូចជាព្រះវិហារដែលមានសុខភាពល្អ និងរីកចម្រើន។ ប៉ុន្តែ ព្រះបានបង្ហាញខ្ញុំនៅព្រឹកនោះនូវទស្សនៈរបស់ទ្រង់ចំពោះក្រុមជំនុំដែលមិនថ្វាយបង្គំព្រះ។ ខ្ញុំចាប់ផ្តើមពិនិត្យមើលចិត្តខ្លួនឯង និងជីវិតថ្វាយបង្គំ បន្ទាប់ពីខ្ញុំបានត្រឡប់មកព្រះវិហារដែលខ្ញុំកំពុងធ្វើការបម្រើ។ តើយើងខុសគ្នាពីក្រុមជំនុំនេះទេ?

នៅយប់ថ្ងៃអាទិត្យនោះ ធីម និងខ្ញុំបានចូលរួមកម្មវិធីបើកសិក្ខាសាលាអំពីការថ្វាយបង្គំ។ សិក្ខាសាលានេះគឺជាកម្មវិធីថ្វាយបង្គំដែលមានការចូលរួមពីក្រុមចម្រៀង និងក្រុមជំនុំរបស់ពួកគេ ដែលមានអ្នកចូលរួមសិក្ខាសាលានោះ គឺជាផ្នែកនៃក្រុមជំនុំ។ ខ្ញុំមិនអាចចាប់ផ្តើមបង្ហាញអ្នកពីភាពខុសគ្នារវាងក្រុមជំនុំទាំងពីរនោះទេ។ នេះពិតជាក្រុមជំនុំដែលមានសិរីល្អរបស់ព្រះគង់នៅ។ កម្មវិធីនោះពេញដោយព្រះវិញ្ញាណ ហើយខ្ញុំជឿថា ស្ទើរតែគ្រប់គ្នាដែលចូលរួមពិតជាបានជួបជាមួយព្រះ។ ខ្ញុំបានឃើញខ្លួនខ្ញុំចាប់អារម្មណ៍ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំអស់ពីចិត្តជាខ្លាំងរហូតដល់ខ្ញុំឈប់មាន «ការវិភាគ» របស់ខ្ញុំ (ដែលស្វែងរកមើលកំហុសរបស់កម្មវិធីថ្វាយបង្គំ និងតន្ត្រី) ហើយគេក៏បាននាំខ្ញុំចូលក្នុងវត្តមានរបស់ព្រះ។ ខ្ញុំយល់ថាព្រះមានបន្ទូលមកខ្ញុំថា «នេះជាអ្វីដែលខ្ញុំចង់ឲ្យអ្នកធ្វើក្នុងការដឹកនាំការថ្វាយបង្គំ»។ សិក្ខាសាលានេះមានភាពល្អប្រសើរតាំងពីដើមដល់ចប់។ ពីមុនមកខ្ញុំមិនដែលបានចូលរួមសិក្ខាសាលានៃការថ្វាយបង្គំបែបនេះដែលមិននិយាយអំពីទម្រង់នៃការថ្វាយបង្គំ ប៉ុន្តែ និយាយអំពីចិត្តវិញ។ ព្រះទ្រង់បានចាប់ផ្តើមបណ្តាលចិត្តខ្ញុំ ឲ្យចង់នៅក្នុងវត្តមានរបស់ទ្រង់ក្នុងការថ្វាយបង្គំ និងដឹកនាំក្រុមជំនុំទៅរកការថ្វាយបង្គំពិតប្រាកដដូចនេះដែរ។

ព្រះវិហារនោះមានការថ្វាយបង្គំព្រះដោយមានសេរីភាពយ៉ាងខ្លាំង។ ពួកជំនុំ

នៅទីនោះមានអារម្មណ៍ថា ពួកគេមានសេរីភាពក្នុងការលើកដៃក្នុងកម្មវិធីថ្វាយបង្គំព្រះ បើសិនជាពួកគេចង់លើកដៃ។ ប៉ុន្តែ ខ្ញុំក៏សង្កេតឃើញថា អ្នកដែលមិនចង់ថ្វាយបង្គំដោយលើកដៃដូចនេះ ពួកគេមានអារម្មណ៍ថា គេបានស្វាគមន៍ និងបានចូលរួមទាំងស្រុង។ មនុស្សមានសេរីភាពក្នុងការថ្វាយបង្គំព្រះដោយចូលទៅកាន់អាសនា ដើម្បីអធិស្ឋាននៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធបានចាប់ផ្ដើមធ្វើការនៅក្នុងចិត្តពួកគេ។ ពួកគេមិនត្រូវពន្លត់ភ្លើងព្រះវិញ្ញាណ ហើយរង់ចាំពេលវេលា «ដែលពួកគេអាចទទួលយកបាន» នៅចុងបញ្ចប់នៃកម្មវិធីនោះទេ។ ក្រុមចម្រៀងពិតជាក្រុមដែលនាំមុខការថ្វាយបង្គំមែន។ ពួកគេស្ថិតក្នុងចំណោមក្រុមចម្រៀងដ៏ល្អបំផុតមួយដែលខ្ញុំធ្លាប់ជួប ប៉ុន្តែ ខ្ញុំមិនឃើញពួកគេធ្វើខ្លួនជាក្រុមសម្ដែងនោះទេ។ តាមរយៈការច្រៀង និងទឹកមុខរបស់ពួកគេ អ្នកអាចនិយាយបានថា ពួកគេនៅទីនោះដើម្បីថ្វាយបង្គំ ហើយដឹកនាំអ្នកដទៃទៀតថ្វាយបង្គំ។ ក្រុមជំនុំ និងក្រុមចម្រៀងមានទំនាក់ទំនងដែលស៊ីសង្វាក់យ៉ាងនេះឯង។ ពោលគឺក្រុមជំនុំហាក់បីដូចជាកំពុងដកពិសោធន៍នឹងការថ្វាយបង្គំដោយសេរីតាមរយៈការច្រៀងរបស់ក្រុមចម្រៀង។ ជាការពិតណាស់ ជាច្រើនលើកច្រើនសារនៅពេលដែលពួកជំនុំចេះបទចម្រៀងនោះ ពួកគេនឹងក្រោកឈរឡើង ហើយមនុស្សជាច្រើននឹងចាប់ផ្ដើមច្រៀងជាមួយនឹងក្រុមចម្រៀងនៅត្រង់ចំណុចបន្ទរនៃបទចម្រៀង។ ការបង្ហាញចេញនូវការថ្វាយបង្គំរបស់ពួកគេ មិនមានលក្ខណៈជាការសម្ដែងនោះទេ ប៉ុន្តែ ពួកគេមានសេរីភាព និងការបើកចំហក្នុងការឆ្លើយតបចំពោះព្រះ តាមដែលទ្រង់បានបំផុសដួងចិត្តពួកគេ។

សិក្ខាសាលានេះពោរពេញទៅដោយពេលវេលានៃការថ្វាយបង្គំ និងការបង្រៀន។ ការបង្រៀនគឺលើប្រធានបទដូចជា «ចិត្តឆេះឆួលរបស់អ្នកដឹកនាំចំពោះព្រះ» «អាទិភាពនៃការថ្វាយបង្គំ» និង «ភាពស្និទ្ធស្នាលជាមួយព្រះក្នុងការថ្វាយបង្គំ»។ ជាថ្មីម្ដងទៀត វាមិនមែនជាទម្រង់ ឬការបង្ហាញចេញទេ ប៉ុន្តែជាសណ្ឋាននៃចិត្ត។

ក្នុងអំឡុងថ្ងៃនោះដែលនៅរដ្ឋតិចសាស់ នោះព្រះបានបញ្ជាក់ក្នុងចិត្តខ្ញុំនូវអ្វីដែលទ្រង់ចង់បានពីខ្ញុំក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ ហើយឥឡូវនេះក៏ជាគ្រូបណ្ដុះបណ្ដាល អ្នកបង្កើតធនធាន និងជាអ្នកលើកទឹកចិត្តអ្នកដឹកនាំការថ្វាយបង្គំផងដែរ។ ទ្រង់បានដាក់ការនិមិត្តយ៉ាងច្បាស់ឲ្យខ្ញុំដឹងថាការថ្វាយបង្គំត្រូវមានលក្ខណៈដូចម្ដេចខ្លះ នៅក្នុងព្រះវិហារដែលខ្ញុំបម្រើ។ និយាយតាមត្រង់ទៅខ្ញុំក៏បានតយុទ្ធនឹងការសម្រេចចិត្តចាកចេញពីការបម្រើព្រះទាំងស្រុងដោយសារតែអស់

កម្លាំង និងបាក់ទឹកចិត្ត។ ព្រះបានបន្តការត្រាស់ហៅខ្ញុំទៅបម្រើ និយាយរួម ខ្ញុំដឹងថាខ្ញុំកំពុងធ្វើអ្វីដែលព្រះចង់ឲ្យខ្ញុំធ្វើ។

ខ្ញុំបានអធិស្ឋានសូមព្រះអង្គបើកបង្ហាញថា តើក្រុមជំនុំមួយណាក្នុងចំណោមក្រុមជំនុំទាំងប្រាំ ដែលខ្ញុំត្រូវជ្រើសរើសក្នុងអំឡុងពេលសម្រាកយកកម្លាំង ប៉ុន្តែជំនួសមកវិញទ្រង់បានជ្រើសរើសឲ្យខ្ញុំយល់ឃើញច្បាស់ថា ក្រុមជំនុំគួរមានលក្ខណៈដូចម្តេច និងយល់ច្បាស់អំពីសារៈសំខាន់នៃការធ្វើការជាមួយ គ្រូគង្វាលដែលមាននិមិត្តដូចខ្ញុំសម្រាប់ការថ្វាយបង្គំ។ បើគ្មានគ្រូគង្វាលដែលមាននិមិត្តដូចខ្ញុំទេ ខ្ញុំនឹងបន្តនឿយណាយយ៉ាងខ្លាំង ដោយមិនអាចធ្វើអ្វីដែលព្រះសព្វព្រះទ័យឲ្យខ្ញុំធ្វើ ប៉ុន្តែ ត្រូវបានរារាំងដោយគ្រូគង្វាលដែលមាននិមិត្តផ្សេងពីខ្ញុំ។ ក្រុមជំនុំរបស់ខ្ញុំបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលបណ្តោះអាសន្ន ដែលត្រូវស្វែងរកគ្រូគង្វាល។

ខ្ញុំក៏បានចាប់ផ្តើមធ្វើការវិភាគទៀត។ ខ្ញុំបានយក «គំរូនៃការថ្វាយបង្គំ» ដែលព្រះបានប្រទានមកខ្ញុំ ហើយចាប់ផ្តើមដាក់វាផ្ទួងផ្ទងព្រះវិហារទាំងបួនដែលនៅសល់។ ព្រះវិហារនៅរដ្ឋ សោត ឃែរ៉ូឡាញណា (South Carolina) ហាក់ដូចជាសក្តិសមបំផុត។ ប៉ុន្តែ តើព្រះចង់ឲ្យខ្ញុំទៅកន្លែងដែលសក្តិសមជាងគេបំផុត ឬតើព្រះកំពុងប្រើស្ថានភាពទាំងអស់នេះ ដើម្បីបង្ហាញខ្ញុំពីកន្លែងដែលទ្រង់ចង់ឲ្យខ្ញុំដើរតួយ៉ាងសំខាន់ក្នុងការដឹកនាំអ្នកថ្វាយបង្គំក្នុងក្រុមជំនុំ?

ដូច្នេះ តើព្រះកំពុងត្រាស់ហៅខ្ញុំទៅក្រុមជំនុំមួយណា? បន្ទាប់ពីការអធិស្ឋានជាបន្តបន្ទាប់ព្រះអង្គក៏បានបង្ហាញខ្ញុំថា ព្រះហឫទ័យទ្រង់គឺដើម្បីឲ្យខ្ញុំស្នាក់នៅព្រះវិហារដែលខ្ញុំបានបម្រើអស់រយៈពេល១៣ឆ្នាំ ហើយបន្តជំរុញក្រុមជំនុំនេះទៅមុខក្នុងការផ្លាស់ប្តូររបៀបថ្វាយបង្គំ។ ព្រះកំពុងត្រាស់ហៅខ្ញុំឲ្យនៅព្រះវិហារដែលខ្ញុំបានកំពុងបម្រើ ពោលគឺទ្រង់កំពុងត្រាស់ហៅជាថ្មី! ខ្ញុំដឹងច្បាស់ថា ខ្ញុំកំពុងនៅកន្លែងដែលព្រះចង់ឲ្យខ្ញុំនៅ—ហើយខ្ញុំស្រឡាញ់ការងាររបស់ខ្ញុំ! ខ្ញុំខានមានអារម្មណ៍ថាពេញលេញដូចនេះ តាំងពីយូរមកហើយ។

ឧបសគ្គបន្ទាប់គឺជាការបន្តក្រុមចម្រៀងឡើងវិញ។ ខ្ញុំបានមើលឃើញការផ្លាស់ប្តូរនេះ គឺជាគន្លឹះពិតប្រាកដមួយដើម្បីបំពេញនិមិត្តដែលព្រះបានប្រទានមកខ្ញុំ។ យើងមានក្រុមចម្រៀងដ៏អស្ចារ្យមួយដែលអាចគ្រប់គ្រងអ្វីដែលខ្ញុំដាក់នៅចំពោះមុខពួកគេ ប៉ុន្តែ ពួកគេជាក្រុមចម្រៀងដែលផ្តោតទៅលើការសម្តែងច្រើនជាងដែលត្រូវការរៀបចំឡើងវិញ (ការស្ដាបនាឡើងវិញ) ដើម្បីឲ្យសមនឹងចក្ខុវិស័យដែលព្រះបានប្រទានមកខ្ញុំ។ ព្រះបានត្រាស់ហៅគ្រូគង្វាលថ្មី មកក្រុមជំនុំរបស់យើង គឺលោក ជើរ៉លដ៍ បូនទ្រេជើរ (Gerald Bontrager) គឺជាអ្វីដែលខ្ញុំ និងក្រុម

ជំនុំរបស់យើងត្រូវការនៅក្នុងដំណាក់កាលបន្ទាប់នៃការកែទម្រង់ការថ្វាយបង្គំ។ ខ្ញុំនិងលោក ជើរ៉លដ៍ (Gerald) បានជួបជាមួយនឹងអ្នកលេងឧបករណ៍ភ្លេង និងអ្នកផ្សេងទៀតក្នុងក្រុមចម្រៀង ដើម្បីចែករំលែកជាមួយពួកគេ អំពីបទពិសោធន៍របស់ខ្ញុំយ៉ាងលម្អិតបំផុត។ ព្រះពិតជាបានប្រើពេលនោះ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាថ្មីដល់ក្រុមចម្រៀងនោះ។ ចាប់ពីពេលនោះមកក្រុមចម្រៀង និងខ្ញុំមានការចាប់ផ្តើមជាថ្មី ហើយព្រះបានធ្វើរឿងដ៏អស្ចារ្យជាមួយនឹងក្រុមនោះ។ ការប្តេជ្ញាចិត្តបានកើនឡើងដល់កម្រិតខ្ពស់ដែលមិនធ្លាប់មានក្នុងរដូវក្តៅឆ្នាំនោះ ហើយយើងក៏មានអំណរខ្លាំងណាស់។ ខ្ញុំអាចពង្រីកក្រុមបានហើយពួកគេកំពុងរៀន និងទន្ទេញចាំតន្ត្រីយ៉ាងឆាប់រហ័ស។ ពួកគេចាប់យកចារិតលក្ខណៈនៃក្រុមចម្រៀងដែលនាំមុខការថ្វាយបង្គំ។

តាមរយៈបទពិសោធន៍នេះ ដែលខ្ញុំទើបតែចែកចាយជាមួយអ្នក ព្រះជាម្ចាស់បានបន្តការត្រាស់ហៅខ្ញុំទៅកាន់ការដឹកនាំព័ន្ធកិច្ច ទ្រង់បានបន្តការត្រាស់ហៅខ្ញុំទៅកន្លែងថ្មី ហើយទ្រង់បានប្រទានឲ្យខ្ញុំនូវចក្ខុវិស័យថ្មី សម្រាប់ព័ន្ធកិច្ចរបស់ខ្ញុំ ហើយបានចាប់ផ្តើមកែប្រែខ្ញុំ ដើម្បីរៀបចំខ្លួនខ្ញុំសម្រាប់ការត្រាស់ហៅបន្ទាប់ដែលទ្រង់មានក្នុងជីវិតរបស់ខ្ញុំ ក្នុងរយៈពេលប្រហែលដប់ឆ្នាំទៀត។ ការស្វែងរកព្រះសម្រាប់ការត្រាស់ហៅរបស់ទ្រង់ក្នុងជីវិតរបស់អ្នក គឺរាប់បញ្ចូលការកសាងទំនាក់ទំនងរបស់អ្នកជាមួយទ្រង់ ហើយស្ម័គ្រចិត្តឲ្យព្រះអង្គកែប្រែអ្នក និងធ្វើការលះបង់បើសិនជាចាំបាច់ ហើយត្រៀមខ្លួនជាស្រេចសម្រាប់ការធ្វើដំណើរដោយមានអំណរបំផុតនៃជីវិតរបស់អ្នក ដែលយកបំណងព្រះហឫទ័យរបស់ទ្រង់ជាគោលវិញ!

ជាញឹកញយ ខ្ញុំប្រាថ្នាចង់ឲ្យព្រះគ្រាន់តែបង្ហាញឲ្យខ្ញុំឃើញចំណុចនីមួយៗនៃផែនការដែលទ្រង់មានសម្រាប់ជីវិតរបស់ខ្ញុំសម្រាប់រយៈពេល២០ឆ្នាំខាងមុខ។ ប៉ុន្តែបញ្ហានោះគឺៈ នៅពេលដែលយើងទទួលបានផែនទីបង្ហាញផ្លូវយើងហើយ យើងក៏បានប្រើវាដូចGPSទៅតាមផ្លូវដែលយើងចង់ទៅ ដោយមិនបានពឹងផ្អែកលើព្រះអង្គ។ ព្រះទ្រង់សព្វព្រះទ័យឲ្យយើងមានភាពជាប់លាប់ ក្នុងការមករកទ្រង់ជារៀងរាល់ថ្ងៃក្នុងរបត់ជីវិតបន្ទាប់ និងព័ន្ធកិច្ចរបស់យើង។ ទំនាក់ទំនងជាមួយព្រះអង្គមានសារៈសំខាន់លើសអ្វីៗទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ មានពេលជាច្រើនដងក្នុងជីវិតយើងដែលយើងចង់បានចម្លើយងាយៗ សម្រាប់ការត្រាស់ហៅរបស់យើង ដោយយើងគ្រាន់តែចង់ឲ្យព្រះអង្គសរសេរអំពីការត្រាស់ហៅនៅលើជញ្ជាំងតែម្តង។ ព្រះអាចធ្វើដូច្នេះបាន ប៉ុន្តែ ក្នុងករណីភាគច្រើន ទ្រង់ចង់ឲ្យយើង

សម្រាកនៅក្នុងទ្រង់ ហើយពឹងផ្អែកលើទ្រង់សម្រាប់អ្វីគ្រប់យ៉ាងដែលយើងធ្វើ។

## និយមន័យនៃការដឹកនាំការថ្វាយបង្គំ

នៅពេលដែលយើងទទួលស្គាល់ការត្រាស់ហៅរបស់យើង និងព្រះហស្តរបស់ព្រះនៅក្នុងជីវិតរបស់យើង នោះយើងត្រូវតែប្រដាប់កាយយើងដើម្បីបម្រើទ្រង់។ សូមឲ្យយើងស្វែងយល់ថា តើអ្នកដឹកនាំការថ្វាយបង្គំគឺជាអ្វី ហើយតើយើងមានតួនាទីអ្វីនៅក្នុងក្រុមជំនុំ។ ខ្ញុំពេញចិត្តនិយមន័យដែលលោក បប់ ខូហ្វលីន (Bob Kauflin) បានបកស្រាយអំពីអ្នកដឹកនាំការថ្វាយបង្គំយ៉ាងដូចនេះថា៖

> *អ្នកដឹកនាំការថ្វាយបង្គំដ៏ស្មោះត្រង់លើកតម្កើងភាពអស្ចារ្យរបស់ព្រះនៅក្នុងព្រះយេស៊ូវគ្រីស្ទ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដោយរួមបញ្ចូលគ្នាយ៉ាងប៉ិនប្រសប់នូវព្រះបន្ទូលរបស់ព្រះជាមួយនឹងតន្ត្រី ដោយលើកទឹកចិត្តក្រុមជំនុំ ឲ្យប្រកាសដំណឹងល្អ និងស្រឡាញ់ព្រះវត្តមានរបស់ព្រះ ហើយរស់នៅសម្រាប់សិរីល្អរបស់ព្រះ។*[៤]

**សូមចំណាយពេលបន្តិចដើម្បីពិចារណាជាលម្អិតអំពីនិយមន័យនេះ ហើយគិតអំពីរបៀបដែលអ្នកអាចធ្វើតាមនិយមន័យនេះក្នុងការថ្វាយបង្គំ។**

និយមន័យនេះបញ្ជាក់ច្បាស់ថា អ្នកដឹកនាំការថ្វាយបង្គំត្រូវតែយល់ព្រះបន្ទូលរបស់ព្រះឲ្យបានច្បាស់ ដើម្បីបញ្ចូលព្រះបន្ទូលជាមួយតន្ត្រី ដូចដែលបានពណ៌នាខាងលើ។ យើងនឹងពិនិត្យមើលបន្ថែមទៀត អំពីវិន័យរបស់អ្នកដឹកនាំការថ្វាយបង្គំក្នុងពេលបន្តិចទៀត។

លោក ប្រែនតុន ខូលីយ័រ (Brenton Collyer) បានពិពណ៌នាតួនាទីរបស់អ្នកដឹកនាំការថ្វាយបង្គំ យ៉ាងដូចនេះថា៖

> *តួនាទីរបស់អ្នកដឹកនាំការថ្វាយបង្គំ គឺត្រូវនាំពួកជំនុំឲ្យមើលឃើញ ហើយផ្តោតទៅភាពធំឧត្តមរបស់ព្រះយ៉ាងច្បាស់លាស់ ហើយឆ្លើយតបអស់ពីចិត្ត។*[៥]

---

៤ Bob Kauflin, "6 Reasons Worship Leaders Should Be Musical Pastors," ChurchLeaders.com, https://churchleaders.com/worship/worship-articles/253170-call-musical-pastors.html/2

៥ Brenton Collyer, "How to Increase Engagement in Your Worship Services," Worship Ministry Training Podcast, https://www.worshipministrytraining.com/how-to-in-

នៅពេលដែលពួកជំនុំចូលរួមកម្មវិធីថ្វាយបង្គំដែលយើងដឹកនាំ ពួកគេគួរតែបានដកពិសោធន៍ជាមួយនឹងភាពធំឧត្ដម និងព្រះចេស្ដារបស់ព្រះ។ ភាពធំឧត្ដមរបស់ព្រះអង្គគួរតែនៅចំពោះមុខពួកគេជានិច្ច។

ក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំ យើងចង់ជួយមនុស្សឲ្យចូលមកនៅចំពោះព្រះ ដើម្បីថ្វាយការថ្វាយបង្គំ និងការសរសើរដល់ទ្រង់ ធ្វើជាដង្វាយដែលគាប់ព្រះទ័យ។ ដូចខ្ញុំបាននិយាយខាងដើម យើងជាអ្នកនាំពួកជំនុំចូលទៅក្នុងដំណាក់កាលនីមួយៗនៃកម្មវិធីថ្វាយបង្គំ។ យើងត្រូវធ្វើឲ្យអស់ពីសមត្ថភាព ដើម្បីបំបាត់ការរំខានឲ្យមនុស្សអាចឆ្លើយតបនឹងព្រះក្នុងការថ្វាយបង្គំ។ សូមចាំថា ក្រុមថ្វាយបង្គំមិនត្រូវដឹកនាំកម្មវិធីថ្វាយបង្គំ ដើម្បីឲ្យមនុស្សមើលទេ (ធ្វើជាអ្នកសម្ដែង) ប៉ុន្តែយើងត្រូវជួយពួកគេក្នុងការថ្វាយបង្គំរបស់ពួកគេ ក្នុងនាមជាអ្នកនាំមុខ លើកទឹកចិត្ត និងអ្នកផ្ដល់កម្លាំងចិត្ត។

ខ្ញុំចូលចិត្តរបៀបដែលលោកគ្រូ ចន ផាយភ័រ (John Piper) និយាយអំពីការខិតខំធ្វើឲ្យបានល្អប្រសើរដោយមិនបែកអារម្មណ៍៖

> *យើងនឹងព្យាយាមច្រៀង លេងភ្លេង អធិស្ឋាន និងអធិប្បាយតាមរបៀបដែលពួកជំនុំមិនបែកអារម្មណ៍ចេញពីអត្ថន័យពិតប្រាកដនៃការថ្វាយបង្គំ ដោយសារការងារបម្រើព្រះដែលធ្វើមិនបានល្អ ឬដោយភាពល្អិតល្អន់ភាពឆើតឆាយ ឬការកែលម្អហួសហេតុនោះទេ។ ផ្ទុយទៅវិញ ភាពរៀបរយដ៏សាមញ្ញដែលមិនមានការរំខាន នឹងជួយឲ្យគេមើលឃើញសេចក្ដីពិត និងសេចក្ដីល្អរបស់ព្រះ។ យើងនឹងប្រើប្រាស់ឧបករណ៍ដែលល្អគ្រប់គ្រាន់ ដោយមិនរំខានការបង្ហាញចេញនូវសេចក្ដីយ៉ាងស្មោះត្រង់។*[៦]

ខ្ញុំត្រូវតែចង្អុលបង្ហាញនៅទីនេះថា យើងត្រូវតែទទួលស្គាល់ថាសមាជិកគ្រប់រូបនៃក្រុមរបស់យើងគឺជាធាតុផ្សំដ៏សំខាន់ ក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំរបស់យើង។ អ្នកបច្ចេកទេសកុំព្យូទ័រ ឬអ្នកបច្ចេកទេសសំឡេង សុទ្ធតែមានសារៈសំខាន់ក្នុងការដឹកនាំការថ្វាយបង្គំ ដូចអ្នកចម្រៀង ឬអ្នកលេងហ្គីតាបាសដែរ។ សូមគិតអំពីរឿងនេះ តើមួយណាជាឧបសគ្គខ្លាំងជាង ចំពោះការថ្វាយបង្គំក្នុងក្រុមជំនុំរបស់អ្នក— តើអ្នកលេងហ្គីតាបាសលេងភ្លេងខុសណោតមួយ ឬអ្នកបច្ចេកទេសកុំព្យូទ័រដែលបញ្ចាំងអត្ថបទចម្រៀងខុស? ខ្ញុំសូមណែនាំថាអត្ថបទចម្រៀងខុស

---

crease-engagement-in-your-worship-services/

៦ John Piper, "What Unites Us in Worship," DesiringGod.org, https://www.desiringgod.org/articles/what-unites-us-in-worship

នឹងរារាំងក្រុមជំនុំរបស់អ្នក ច្រើនជាងការលេងភ្លេងខុសតែមួយណោតទៅទៀត។ ក្រុមរបស់អ្នកទាំងអស់ត្រូវយល់ថា តួនាទីរបស់ពួកគេមានសារៈសំខាន់ណាស់ក្នុងការដឹកនាំក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំ ហើយទាំងអស់គ្នាគួរតែរៀបចំ និងប្រតិបត្តិការ ដោយមានបេះដូងជាអ្នកបម្រើ។

មុននឹងយើងបន្តទៅមើលវិន័យមួយចំនួនដែលអ្នកដឹកនាំការថ្វាយបង្គំត្រូវការដើម្បីធ្វើជាផ្នែកមួយនៃជីវិតរបស់ពួកគេ សូមឲ្យយើងរំឭកខ្លួនយើងអំពីការត្រាស់ហៅដ៏ខ្ពង់ខ្ពស់ឲ្យដឹកនាំការថ្វាយបង្គំ និងចារិតលក្ខណៈដែលពួកគេត្រូវមាន ដូចដែលព្រះគម្ពីរបានចង្អុលបង្ហាញសម្រាប់អ្នកដឹកនាំខាងវិញ្ញាណ៖

> *ដូច្នេះ ត្រូវឲ្យអ្នកត្រួតត្រាប្រព្រឹត្ត ដោយឥតកន្លែងចាប់ទោសបានចុះ ត្រូវជាមនុស្សមានប្រពន្ធតែ១ ជាមនុស្សដឹងខ្នាត មានចិត្តធ្ងន់ធ្ងរ កាន់គំនិតមារយាទ ជាអ្នកចៅរ៉ៅ ហើយប្រសប់នឹងការបង្រៀន។ មិនត្រូវជាអ្នកចំណូលស្រា ឬឈ្លោះប្រកែក ឬស៊ីសំណូកឡើយ ត្រូវមានចិត្តស្លូតបូត ឥតរករឿងរកហេតុ ឥតលោភចង់បានប្រាក់។ ត្រូវត្រួតត្រាផ្ទះរបស់ខ្លួន ដោយស្រួលបួល ទាំងឲ្យកូនចៅស្តាប់បង្គាប់ដោយនឹងធឹង។ បើអ្នកណាមិនចេះត្រួតត្រាផ្ទះខ្លួន ធ្វើដូចម្តេចឲ្យថែរក្សាពួកជំនុំព្រះបាន។ មនុស្សណាដែលទើបនឹងជឿថ្មី នោះធ្វើពុំបានទេ ក្រែងកើតមានចិត្តធំ ហើយធ្លាក់ទៅក្នុងទោសរបស់អារក្សវិញ។ ត្រូវឲ្យអ្នកនោះមានឈ្មោះល្អពីអ្នកដទៃផង ក្រែងគេត្មះតិះដៀល ហើយធ្លាក់ទៅក្នុងអន្ទាក់របស់អារក្ស។ ១ធីម៉ូថេ ៣:២-៧*

**តើចារិតលក្ខណៈរបស់ខ្ញុំមានភាពសមស្របនឹងការត្រាស់ហៅរបស់ខ្ញុំក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំឬទេ?**

## វិន័យខ្លះៗសម្រាប់អ្នកដឹកនាំការថ្វាយបង្គំ

វិន័យទាំងនេះគឺជាផ្នែកដ៏សំខាន់នៃការរីកចម្រើនរបស់អ្នកដឹកនាំការថ្វាយបង្គំ។ សៀវភៅនេះគ្រាន់តែបានលើកយកវិន័យមួយចំនួនមកនិយាយ ហើយយើងនឹងត្រូវបានពិភាក្សាអំពីវិន័យផ្សេងទៀត នៅពេលក្រោយនៅក្នុងសៀវភៅនេះ។ វិន័យមួយចំនួនក្នុងសៀវភៅនេះ គឺសម្រាប់បុគ្គលដែលដឹកនាំក្រុមថ្វាយបង្គំ ប៉ុន្តែ

ក្នុងចំណោមនោះមានវិន័យជាច្រើនដែលនឹងជួយក្រុមរបស់អ្នកឲ្យប្រសើរឡើងក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំផងដែរ។ ចំណុចមួយចំនួនត្រូវបានដកស្រង់ពីអត្ថបទដ៏ល្អមួយដែលលោក ដាវីឌ សែនទីស្ទេវ៉ាន (David Santistevan) បាននិពន្ធ។[៧]

## ១.ចូរយកការថ្វាយបង្គំធ្វើជាផ្នែកមួយនៃការរស់នៅប្រចាំថ្ងៃរបស់អ្នក

ដូចដែលបានរៀបរាប់នៅក្នុងជំពូកទីមួយ ការចំណាយពេលថ្វាយបង្គំផ្ទាល់ខ្លួន នៅក្នុងកន្លែងដាច់ដោយឡែកពីអ្នកដទៃ គឺចាំបាច់សម្រាប់ការរីកចម្រើនរបស់យើងនៅក្នុងព្រះគ្រីស្ទ និងការរស់នៅរបស់យើងតាមការត្រាស់ហៅរបស់យើងជាអ្នកដឹកនាំការថ្វាយបង្គំ។ តើយើងជានរណា ពេលដែលគ្មានឆាក គ្មានក្រុមតន្ត្រី គ្មានអ្នកចម្រៀង និងគ្មានភ្លើងបំភ្លឺបន្ទប់ថ្វាយបង្គំ? យើងត្រូវចំណាយពេលអានព្រះបន្ទូលទ្រង់ អធិស្ឋាន និងថ្វាយបង្គំទ្រង់។ ចូរចំណាយពេលច្រៀងថ្វាយព្រះជាលក្ខណៈឯកជន។ ចូរដាក់ផែនការអាន ឬជញ្ជឹងគិតព្រះបន្ទូលប្រចាំថ្ងៃ ដើម្បីជួយរៀបចំរចនាសម្ព័ន្ធការសិក្សារបស់អ្នក។ ចូរប្តេជ្ញាចិត្តទន្ទេញខគម្ពីរ។ តាមរយៈការដឹកនាំការថ្វាយបង្គំរបស់អ្នកនៅលើឆាក គេអាចដឹងថា ការថ្វាយបង្គំមិនមែនជាផ្នែកមួយនៃជីវិតរស់នៅរបស់អ្នកឬអត់។

**តើខ្ញុំចំណាយពេលថ្វាយបង្គំព្រះជារៀងរាល់ថ្ងៃឬទេ? តើខ្ញុំចាំបាច់ត្រូវរកនរណាម្នាក់ជួយខ្ញុំឲ្យទទួលខុសត្រូវក្នុងដំណើរនៃសេចក្តីជំនឿរបស់ខ្ញុំឬទេ?**

## ២.ចូរអភិវឌ្ឍជំនាញរបស់អ្នកឲ្យកាន់តែប្រសើរឡើង

ចូរហ្វឹកហាត់ការប្រើឧបករណ៍ភ្លេង និង/ឬប្រើសំឡេងរបស់អ្នក។ ចូរអនុវត្តនៅត្រង់ផ្នែកទន់ខ្សោយរបស់អ្នក ក្នុងការដឹកនាំការថ្វាយបង្គំ ដូចជាការនិយាយ ការផ្លាស់ប្តូរឆ្លងវគ្គ និងការផ្តល់នូវលំហូរ។ ចូលរៀនមេរៀន ឬបើមិនដូច្នេះទេ ចូរកែលម្អសមត្ថភាពច្រៀង ឬឧបករណ៍ភ្លេងរបស់អ្នកឲ្យប្រសើរឡើង។ ចូរស្វែងរកគ្រូល្អម្នាក់ ឬវគ្គសិក្សាតាមអ៊ីនធឺណិត។ ចូរហាត់ ដោយការថតសំឡេង ដើម្បីពង្រីក

៧ លោក David Santistevan, "7 Disciplines of a Good Worship Leader," Beyond Sunday Worship, https://www.davidsantistevan.com/7-disciplines-of-a-good-worship-leader/

ជំនាញរបស់អ្នក។ វិធីដ៏ល្អមួយដើម្បីកែលម្អ គឺស្តាប់សម្លេងដែលបានថតសម្លេងដោយខ្លួនឯង ហើយវាយតម្លៃផ្នែកដែលត្រូវកែលម្អ។ តើអ្នកនិយាយច្រើនពេកទេ? តើការផ្លាស់ប្តូរឆ្លងវគ្គមានន័យទេ? តើអ្នកលេងបានល្អ ហើយសមរម្យទេ? តើសំឡេងច្រៀងរបស់អ្នកមានភាពរីករាយ និងសមនឹងរចនាបថទេ?

**តើខ្ញុំត្រូវចាត់វិធានការអ្វីខ្លះ ដើម្បីកែលម្អជំនាញរបស់ខ្ញុំ ជាជំហានៗ?**

## ៣.ចូររៀនពីរចនាបថផ្សេងៗ (ស្ទីល) នៃបទចម្រៀង

ចូរស្តាប់ និងរៀនបទចម្រៀងដែលមិនមែនជារចនាបថ ឬចំណូលចិត្តផ្ទាល់ខ្លួនរបស់អ្នក។ ចូរស្គាល់បទចាស់ និងបទថ្មី។ ចូរស្តាប់ និងច្រៀងឲ្យបានញឹកញាប់នូវចម្រៀងដែលមនុស្សជំនាន់មួយផ្សេងទៀតកំពុងស្តាប់។ ទាំងអស់នេះនឹងជួយអ្នកក្នុងការដឹកនាំការថ្វាយបង្គំពហុជំនាន់ និងចម្រុះជាតិសាសន៍ ខណៈពេលដែលអ្នកចាប់ផ្តើមស្រឡាញ់ ហើយយល់ពីរចនាបថតន្ត្រីផ្សេងទៀត។

**តើរចនាបថ (ស្ទីល) នៃតន្ត្រីបែបណាដែលខ្ញុំត្រូវចេះឲ្យ<br>បានច្រើនថែមទៀត?**

ខ្ញុំមានឱកាសដ៏ល្អក្នុងការចំណាយពេលនារដូវក្តៅនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី កាលពីច្រើនឆ្នាំមុន ដើម្បីជួយ និងបណ្តុះបណ្តាលក្រុមថ្វាយបង្គំនៅក្នុងទីនោះ។ ខ្ញុំដឹងថា ខ្ញុំនឹងមានការងារមួយចំនួនជាមួយក្រុមនិស្សិត ដូច្នេះ ខ្ញុំបានរកឃើញក្រុមតន្ត្រីដែលមានឥទ្ធិពលខ្លាំងបំផុត លើការថ្វាយបង្គំរបស់និស្សិតនៅក្នុងប្រទេសនោះ ហើយបន្ទាប់មក ចាប់ផ្តើមស្តាប់តន្ត្រីនោះជាច្រើនសប្តាហ៍មុនពេលទៅបម្រើនៅទីនោះ។ វាពិតជាបានជួយខ្ញុំចាប់ផ្តើមឲ្យតម្លៃខ្ពស់ និងថ្វាយបង្គំព្រះតាមរយៈតន្ត្រីប្រភេទផ្សេងទៀត។

## ៤.ចូរធ្វើជាគំរូដ៏ប្រសើរខាងការថ្វាយបង្គំ និងខាងតន្ត្រីក្នុងការថ្វាយបង្គំ

អ្នកដឹកនាំការថ្វាយបង្គំ ចាំបាច់ត្រូវបង្ហាញចេញនូវរបៀបនៃការរស់នៅថ្វាយបង្គំព្រះ។ នៅពេលដែលយើងធ្វើជាគំរូ វានឹងលើកទឹកចិត្តក្រុមរបស់យើង និងក្រុមជំនុំរបស់យើង ឲ្យថ្វាយបង្គំពេញមួយជីវិតរបស់ពួកគេ។ សូមចំណាយពេលផ្ញើឲ្យក្រុមរបស់អ្នក នូវខគម្ពីរដែលអ្នកកំពុងសិក្សា ឬការយល់ដឹងដែលព្រះបានប្រទានដល់អ្នក ទាក់ទងនឹងការថ្វាយបង្គំផ្ទាល់ខ្លួនរបស់អ្នក។ ក្នុងការធ្វើដូច្នេះ អ្នកលើកទឹកចិត្ត និងបង្រៀនក្រុមរបស់អ្នក។ ប្រសិនបើអ្នកធ្វើជាគំរូនៃភាពល្អប្រសើរផ្នែកតន្ត្រីដោយការបន្ទាបខ្លួន នោះការនេះនឹងជំរុញទឹកចិត្តអ្នកភ្លេងក្នុងក្រុមអ្នកឲ្យឡើងមួយកំរិតទៀត។ ផ្ទុយទៅវិញ ប្រសិនបើអ្នករៀបចំមិនបានល្អវានឹង "បណ្តាលឲ្យ" អ្នកភ្លេងក្នុងក្រុមអ្នកឲ្យរៀបចំមិនបានល្អដែរ។

> តើខ្ញុំកំពុងធ្វើជាគំរូនូវរបៀបរស់នៅដែលថ្វាយបង្គំជាមួយក្រុម និងក្រុមជំនុំរបស់ខ្ញុំឬទេ? តើខ្ញុំកំពុងធ្វើជាគំរូនៃភាពល្អប្រសើរខាងតន្ត្រីឬទេ?

## ៥.ចូរឃ្វាល ហើយបង្រៀនព្រះបន្ទូលដល់ក្រុមរបស់អ្នក

ចូរចំណាយពេលថ្វាយបង្គំជាមួយក្រុមរបស់អ្នក។ បង្រៀនពួកគេតាមរបៀបដែលមានរចនាសម្ព័ន្ធ និងមិនមានរចនាសម្ព័ន្ធ (យើងនឹងសិក្សាលម្អិតនៅពេលក្រោយ)។ ចូរចែករំលែកជាមួយក្រុមរបស់អ្នកនូវការធ្វើដំណើរខាងវិញ្ញាណប្រចាំថ្ងៃរបស់អ្នក។

## ៦.ចូរចាប់យកនិមិត្តនៃគ្រូគង្វាលនាំមុខរបស់អ្នក

ដូចដែលបានរៀបរាប់ក្នុងមេរៀនមុន គ្រូគង្វាលរៀមច្បងរបស់អ្នក គឺជាអ្នកនាំថ្វាយបង្គំឈានមុខគេនៃក្រុមជំនុំ។ ចូរចំណាយពេលជាមួយគ្រូគង្វាលរបស់អ្នក ហើយធ្វើការជាមួយគ្នាក្នុងការប្រកាន់ខ្ជាប់នូវការនិមិត្ត សម្រាប់ក្រុមជំនុំដែលព្រះបានបង្កើតឲ្យមាននៅក្នុងគាត់។ ការធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រូគង្វាលរបស់អ្នក ហើយមានទំនាក់ទំនងល្អជាមួយគាត់ គឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការដឹកនាំការថ្វាយបង្គំប្រកបដោយប្រសិទ្ធភាពនៅក្នុងក្រុមជំនុំរបស់អ្នក។

**តើគ្រូគង្វាលរបស់ខ្ញុំ និងខ្ញុំមានទំនាក់ទំនងល្អទេ? តើយើងយល់គ្នាទៅវិញទៅមក អំពីក្តីសុបិន និងចំណង់ចំណូលចិត្តដែលយើងមានចំពោះព័ន្ធកិច្ចដែលយើងដឹកនាំឬទេ? តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីកែលម្អផ្នែកទាំងនេះ?**

## ៧.ចូររស់នៅក្នុងជីវិតជាក់ស្តែងជាមួយក្រុមជំនុំរបស់អ្នក

មនុស្សមិនខ្វល់ខ្វាយនឹងផលិតកម្មដ៏រលូនរបស់អ្នក និងការរៀបចំដ៏អស្ចារ្យនោះទេ។ ពួកគេចង់តភ្ជាប់ជាមួយបេះដូងដែលស្រឡាញ់ និងស្វែងរកព្រះ។ ចូរចំណាយពេលវេលាជាមួយ ក្រុមជំនុំរបស់អ្នក នៅក្រៅម៉ោងកម្មវិធី ថ្វាយបង្គំព្រះ។ ចូរស្គាល់ពួកគេ ហើយជួយពួកគេឲ្យស្គាល់អ្នក។ ពួកគេកាន់តែបើកចំហចំពោះភាពជាអ្នកដឹកនាំរបស់អ្នក នៅពេលដែលអ្នកមានទំនាក់ទំនងជាមួយពួកគេ។

**តើលោកអ្នកកំពុងតែរស់នៅក្នុងជីវិតប្រចាំថ្ងៃជាមួយនឹងក្រុមជំនុំរបស់ខ្លួន នៅក្រៅភារកិច្ច និងការទទួលខុសត្រូវរបស់លោកអ្នកក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំដែរឬទេ?**

## ៨.ចូររៀនទំនាក់ទំនងនៅមុខក្រុមជំនុំរបស់អ្នក

អ្នកដឹកនាំការថ្វាយបង្គំដ៏មានប្រសិទ្ធភាពបំផុតមួយចំនួនមិននិយាយច្រើនទេ។ ការដកស្រង់ខគម្ពីរស្ថិតក្នុងចំណោមវិធីនិយាយដែលមានប្រសិទ្ធភាពបំផុត។ ចូរស្លៀកពាក់ឲ្យសក្តិសមនឹងក្រុមជំនុំដែលអ្នកកំពុងនាំមុខ – អ្នកមិនចាំបាច់អួតសំញែងម៉ូតខោអាវរបស់អ្នកទេ។ ខ្ញុំនឹងនិយាយស៊ីជម្រៅអំពីការប្រាស្រ័យទាក់ទងគ្នាដោយការនិយាយរបស់យើង និងការទំនាក់ទំនងដោយពាក្យសម្តី និងដោយមិនប្រើពាក្យសម្តី ក្នុងមេរៀនក្រោយទៀតក្នុងសៀវភៅនេះ។

តើខ្ញុំមានប្រសិទ្ធភាពក្នុងការទំនាក់ទំនងក្នុងការថ្វាយបង្គំឬទេ? តើការស្មៀកពាក់របស់ខ្ញុំ គឺសមនឹងសំលៀកបំពាក់របស់ក្រុមជំនុំដែរឬទេ? តើខ្ញុំទាក់ទាញការចាប់អារម្មណ៍ចំពោះខ្លួនឯងឬទេ?

### ៩.ចូរខិតខំពង្រីកការយល់ដឹងរបស់អ្នកអំពីព្រះ

លោក ដាវីឌ សេនធីស្ទីវ៉ាន (David Santistevan) បានកត់សម្គាល់ថា៖ «គ្មានអ្វីបំផុសការថ្វាយបង្គំលើសពីការកោតស្ញប់ស្ញែងចំពោះព្រះនោះឡើយ។ ចូរខិតខំជារៀងរាល់ថ្ងៃ ដើម្បីឲ្យបានស្ញប់ស្ញែងកាន់តែខ្លាំងចំពោះសិរីល្អរបស់ព្រះ»។ [៨]

តើអ្នកកំពុងពង្រីកទស្សនៈដែលអ្នកមានចំពោះព្រះដោយរបៀបណា? តើអ្នកកំពុងអានសៀវភៅអ្វី? តើអ្នកកំពុងសិក្សាអត្ថបទគម្ពីរអ្វីខ្លះ?

ក្នុងចំណោមផ្នែកទាំងប្រាំបួននេះ មានផ្នែកណាដែលអ្នកត្រូវពង្រឹងខ្លាំងបំផុត? តើអ្នកនឹងកែលំអផ្នែកទាំងនោះដូចម្តេចខ្លះ?

## ចូរបង្កើតបរិយាកាសនៃក្តីស្រឡាញ់ឥតលក្ខខណ្ឌសម្រាប់ក្រុមថ្វាយបង្គំរបស់អ្នក

យើងត្រូវតែស្រឡាញ់ក្រុមថ្វាយបង្គំរបស់យើង។ នេះគឺជាទិដ្ឋភាពមួយនៃភាពជាអ្នកដឹកនាំដែលគេមិនបានលើកមកនិយាយញឹកញាប់ ហើយក៏មានសារៈសំខាន់ណាស់ដែរ។

ប៉ុន្មានឆ្នាំមុន វិធីសាស្ត្ររបស់ខ្ញុំក្នុងការងារ បេសកកម្មនៅក្នុងប្រទេស

៨ ដកស្រង់ចេញពីប្រភពដូចគ្នា។.

អាស៊ីប៉ូព៉ាបានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់។ ខណៈពេលដែលខ្ញុំបានធ្វើការបណ្តុះបណ្តាលទ្រង់ទ្រាយធំ ស្រដៀងនឹងអ្វីដែលខ្ញុំធ្វើនៅសហរដ្ឋអាមេរិក ក្នុងបណ្តាប្រទេសនានាជុំវិញពិភពលោក ការងារជាមូលដ្ឋានរបស់ខ្ញុំនៅក្នុងប្រទេសនៅអាស៊ីខាងកើតនោះ គឺជាការផ្តល់ឱវាទ និងការបង្រៀនក្រុមតូចនៃមនុស្សចម្រុះជាតិសាសន៍ ដ៏មានសក្តានុពលក្នុងភាពជាអ្នកដឹកនាំដ៏ប្រសើរ ដែលអាចជះឥទ្ធិពលយ៉ាងសំខាន់មកលើជីវិតនៃការថ្វាយបង្គំនៅប្រទេសរបស់ពួកគេ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះរបៀបដែលព្រះបានប្រើបុគ្គលទាំងនេះ ដើម្បីបណ្តុះបណ្តាល បំពាក់បំប៉ន ផ្សាយដំណឹងល្អ ហើយបង្កើតក្រុមជំនុំនៅក្នុងតំបន់របស់ពួកគេ និងកន្លែងឆ្ងាយៗ។

បន្ថែមពីលើការបណ្តុះបណ្តាល បំពាក់បំប៉ន និងផ្តល់ធនធានដល់ក្រុមចម្រុះជាតិសាសន៍របស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថា ព្រះទ្រង់បានឲ្យខ្ញុំមានទំនួលខុសត្រូវបំផុតដែលត្រូវស្រឡាញ់ និងលើកទឹកចិត្តយុវជនទាំងនេះ។ ជាការពិតណាស់ នោះគឺជាផ្នែកនៃទំនាក់ទំនងរបស់ខ្ញុំជាមួយពួកគេ កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ—ដោយរំឭកពួកគេថា ព្រះទ្រង់មានភាពគ្រប់គ្រាន់សម្រាប់អ្វីដែលពួកគេត្រូវការ និងជំរុញពួកគេ ឲ្យទៅហួសព្រំដែនដែលខ្លួនឯងបានកំណត់ ព្រមទាំងលើកទឹកចិត្តពួកគេ (អបអរពួកគេ) សម្រាប់អំពើល្អដែលពួកគេបានធ្វើ។ ហើយត្រូវស្រឡាញ់ពួកគេឲ្យដូចកូនរបស់ខ្ញុំយ៉ាងពិតប្រាកដ។ ខ្ញុំពិបាកពិពណ៌នាអំពីសេចក្តីស្រឡាញ់ដែលព្រះបានដាក់នៅក្នុងចិត្តរបស់ខ្ញុំ សម្រាប់មនុស្សទាំងនេះដែលមានវប្បធម៌ផ្សេងគ្នា ហើយនិយាយភាសាផ្សេងគ្នា ប៉ុន្តែ វាពិតជាជ្រាលជ្រៅមិនគួរឲ្យជឿ។ ទំនាក់ទំនងរបស់យើងមិនបញ្ឈប់ នៅពេលខ្ញុំចាកចេញពីប្រទេសរបស់ពួកគេទេ ប៉ុន្តែ នៅតែបន្តតាមរយៈការប្រាស្រ័យទាក់ទងប្រចាំសប្តាហ៍ ដើម្បីអធិស្ឋានឲ្យការងាររបស់ពួកគេ លើកទឹកចិត្តពួកគេ ផ្តល់ដំបូន្មានដល់ពួកគេ ឲ្យមានការតស៊ូ និងធ្វើអ្វីៗជាច្រើនទៀត។

ក្នុងការងារនោះ មានហេតុការណ៍មួយដែលបានបង្ហាញឲ្យខ្ញុំដឹង នូវអ្វីដែលខ្ញុំមិនដែលដាក់បញ្ចូលក្នុងសៀវភៅកត់ត្រាអំពីការបង្រៀនរបស់ខ្ញុំ ឬមិនបានបង្រៀន នៅក្នុងសិក្ខាសាលា សន្និបាត និងព្រឹត្តិការណ៍ជាច្រើន។ កាលនោះ ខ្ញុំ និងក្រុមរបស់ខ្ញុំ ទើបតែបានបញ្ចប់ព្រឹត្តិការណ៍រយៈពេលបីថ្ងៃ ដោយមានក្រុមថ្វាយបង្គំជាច្រើនចូលរួម។ នៅម៉ោងចុងក្រោយអ្នកចូលរួមបានចែករំលែកអំពីអ្វីៗដែលពួកគេទទួលបានពីសន្និបាតនោះ។ ខ្ញុំបានបង្រៀនមេរៀនជាច្រើន ហើយបានទទួលការឆ្លើយតបល្អក្រៃលែង។ ខ្ញុំអាចប្រាប់ថាមនុស្សកំពុងស្រូបយក និង

ពិភាក្សាពីរបៀបដើម្បីអនុវត្តតាមមេរៀនទាំងនោះ។ នៅពេលខ្ញុំបានស្តាប់ការចែកចាយអំពីមេរៀនដែលពួកគេបាន ខ្ញុំស្រមៃថា ប្រធានបទដែលខ្ញុំបានពន្យល់យ៉ាងក្បោះក្បាយដែលមានដូចជា គុណសម្បត្តិខាងវិញ្ញាណដែលសមាជិកក្រុមថ្វាយបង្គំត្រូវមាន របៀបហាត់សមក្រុមតន្ត្រីឲ្យបានល្អ របៀបផ្លាស់ប្តូរពីបទចម្រៀងមួយទៅបទចម្រៀងមួយទៀត របៀបលេងភ្លេងឲ្យកាន់តែប្រសើរនៅក្នុងសាលធំ និងប្រធានបទជាច្រើនទៀតដែលខ្ញុំមិនអាចរៀបរាប់អស់។

មានអ្នកដឹកនាំការថ្វាយបង្គំម្នាក់បានផ្តល់ឲ្យនូវការឆ្លើយតបដែលគួរឲ្យភ្ញាក់ផ្អើលថា៖ «ខ្ញុំបានទទួលឥទ្ធិពលខ្លាំងបំផុតពីគ្រូ ដែលស្រឡាញ់ក្រុមគាត់យ៉ាងខ្លាំង។ ខ្ញុំដឹងថា ខ្ញុំមិនបានបង្ហាញសេចក្តីស្រឡាញ់ និងការអាណិតអាសូរយ៉ាងដូចនេះ ចំពោះសមាជិកក្រុមរបស់ខ្ញុំនោះទេ ដែលពីមុនមកខ្ញុំមិនធ្លាប់គិតថា វាជាអ្វីមួយដែលខ្ញុំត្រូវការនោះទេ ប៉ុន្តែខ្ញុំឃើញថា វាមានសារៈសំខាន់ប៉ុណ្ណា»។

ខ្ញុំក៏បានអង្គុយ ដោយមិនដឹងថាត្រូវនិយាយដូចម្តេច។ ខ្ញុំមិនដែលបានចូលទៅកន្លែងហ្វឹកហាត់នោះ ដោយគិតថា ខ្ញុំនឹងបង្ហាញក្តីស្រឡាញ់ចំពោះសមាជិកក្រុមរបស់ខ្ញុំ ដើម្បីធ្វើជាគំរូដល់អ្នកដទៃនោះទេ។ ខ្ញុំមិនដែលនិយាយ ឬបង្រៀនអំពីភាពចាំបាច់នៃការបង្ហាញសេចក្តីស្រឡាញ់ដោយគ្មានលក្ខខណ្ឌចំពោះក្រុមរបស់ខ្ញុំឡើយ។ ខ្ញុំមិនដែលគិតសូម្បីតែបន្តិចអំពីអត្ថប្រយោជន៍នៃការស្រឡាញ់ក្រុមរបស់ខ្ញុំ ដើម្បីឲ្យពួកគេក្លាយជាអ្នកដឹកនាំការថ្វាយបង្គំកាន់តែប្រសើរ។ ខ្ញុំបានចំណាយពេលជាច្រើនសប្តាហ៍រៀបចំមេរៀនសម្រាប់ថ្ងៃនោះ ហើយបានចំណាយពេលម៉ោងរាប់មិនអស់ក្នុងការរៀបចំឯកសារ និងបទបង្ហាញជាភាសាបរទេស ដើម្បីធ្វើឲ្យបទបង្ហាញមានប្រសិទ្ធភាព តាមដែលអាចធ្វើទៅបាន។ ការរៀបចំនេះគឺពិតជាចាំបាច់សម្រាប់ការងាររបស់ខ្ញុំនៅទីនោះ។ ប៉ុន្តែ ឥឡូវនេះខ្ញុំឮថាខ្ញុំមិនបានរៀបចំខ្លួន ដោយសេចក្តីស្រឡាញ់គ្មានលក្ខខណ្ឌចំពោះក្រុមរបស់ខ្ញុំទេ គឺការរៀបចំខ្លួនដែលមិនត្រូវការជំនាញតន្ត្រី ឬការថ្វាយបង្គំឡើយ តែប្រហែលជាមានឥទ្ធិពលខ្លាំងបំផុត មកលើអ្នកដែលបានចូលរួម។

សេចក្តីស្រឡាញ់ដែលយើងជាគ្រីស្ទានបានបង្ហាញដល់អ្នកដទៃ គឺពិតជាមានអំណាចណាស់! តើអ្នកស្រឡាញ់ក្រុមថ្វាយបង្គំរបស់អ្នកខ្លាំងទេ? តើអ្នកគឺជាបុគ្គលដែលលើកទឹកចិត្តពួកគេទេ? តើពួកគេចែកចាយអំពីជីវិតរបស់ពួកគេដល់អ្នកដោយទំនុកចិត្តទេ? ភាពជាអ្នកភ្លេងពិតជាមានសារៈសំខាន់ក្នុងការនាំមុខការថ្វាយបង្គំ។ តែសេចក្តីស្រឡាញ់អាចជារឿងសំខាន់បំផុតដែលយើងអាចធ្វើបានដើម្បីអភិវឌ្ឍក្រុមរបស់យើងទៅជាបុរស និងស្ត្រីឲ្យពួកគេក្លាយជាមនុស្សដែលព្រះ

សព្វព្រះហឫទ័យ។ សូមអរព្រះគុណដល់ព្រះសម្រាប់សេចក្តីស្រឡាញ់ដែលទ្រង់បានបង្ហាញយើង។ សូមព្រះអង្គជួយយើងធ្វើជាគំរូនៃសេចក្តីស្រឡាញ់នោះក្នុងជីវិតរបស់យើង។

តើអ្នកពិតជាស្រឡាញ់សមាជិកក្រុមរបស់អ្នកមែនទេ? តើពួកគេមើលឃើញក្តីស្រឡាញ់នោះ ក្នុងរបៀបដែលអ្នកប្រាស្រ័យទាក់ទងជាមួយពួកគេទេ? តើពួកគេទទួលបានការលើកទឹកចិត្ត និងសេចក្តីស្រឡាញ់ដែលមានការលះបង់ពីអ្នកទេ?

**តើអ្នកពិតជាស្រឡាញ់សមាជិកក្រុមរបស់អ្នកមែនទេ? តើពួកគេមើលឃើញក្តីស្រឡាញ់នោះ ក្នុងរបៀបដែលអ្នកប្រាស្រ័យទាក់ទងជាមួយពួកគេទេ? តើពួកគេទទួលបានការលើកទឹកចិត្ត និងសេចក្តីស្រឡាញ់ដែលមានការលះបង់ពីអ្នកទេ?**

## ការថ្វាយបង្គំរួមគ្នា និងការបង្កើតសិស្ស

ពេលណាក្រុមជំនុំនិយាយអំពីការបង្កើតសិស្សក្នុងពេលសព្វថ្ងៃនេះជាញឹកញាប់ គេច្រើនតែនិយាយសំដៅទៅលើការបង្កើតសិស្សក្នុងក្រុមតូចក្រុមដែលមានគ្នាបីនាក់ ការផ្តល់ការបង្រៀនម្នាក់ទល់ម្នាក់ ឬប្រហែលជាថ្នាក់បង្កើតសិស្ស។ តាមពិត ការថ្វាយបង្គំគឺជាឧបករណ៍ប្រសើរបំផុតសម្រាប់ការបង្កើតសិស្សនៅក្នុងក្រុមជំនុំ។

សូមគិតអំពីចំណុចនេះចុះ។ ប្រសិនបើអ្នកមើលមនុស្សទាំងអស់ដែលចូលរួមក្នុងព្រះវិហាររបស់អ្នក និងមើលការចូលរួមរបស់ពួកគេនៅក្នុងជីវិតនៃក្រុមជំនុំ ខ្ញុំជឿថាអ្នកនឹងឃើញថា ពួកគេភាគច្រើនច្បាស់មិនចូលរួមក្នុងក្រុមតូច ក្រុមមានគ្នាបីនាក់ ការផ្តល់យោបល់ ឬថ្នាក់រៀនព្រះគម្ពីរទេ។ ភាគច្រើនពិតជាផ្តោតទៅលើការមកថ្វាយបង្គំព្រះ។ ការនេះបង្ហាញថា យើងអាចត្រឹមតែប្រើពេលនៃកម្មវិធីថ្វាយបង្គំ ដើម្បីនិយាយទៅកាន់ជីវិតរបស់សមាជិកក្រុមជំនុំទាំងនោះ ដើម្បីឲ្យពួកគេផ្លាស់ប្រែកាន់តែដូចព្រះយេស៊ូវគ្រីស្ទ។ ពិតប្រាកដណាស់ យើងបានឃើញក្នុងប្រវត្តិសាស្រ្តគ្រីស្ទបរិស័ទ ដែលក្រុមជំនុំបានចាត់ទុកកម្មវិធីថ្វាយបង្គំជាមធ្យោបាយចម្បងនៃការបង្កើតសិស្ស។ គួរឲ្យសោកស្តាយណាស់ វាហាក់បីដូចជា ក្រុមជំនុំជាច្រើនបានមើលរំលងចំណុចនេះ ហើយលែងមានគម្រោងថ្វាយបង្គំដោយបំណងចិត្តដើម្បីបង្រៀនពួកជំនុំក្នុងលក្ខណៈជាការបង្កើតសិស្សទៀត

ហើយ។ កម្មវិធីថ្វាយបង្គំ គួរតែមានអាទិភាព ដើម្បីការផ្លាស់ប្រែខាងវិញ្ញាណ។

យើងត្រូវគិតថា ខ្លួនយើងគឺជាអ្នកជំនាញសុវត្ថិភាពចំណីអាហារផ្នែកទេវសាស្ត្រ។ រាល់បទចម្រៀង រាល់ការអធិស្ឋាន រាល់ការអានព្រះគម្ពីរកំពុងតែផ្តល់ចំណីដល់ចិត្ត និងគំនិតរបស់មនុស្ស ហើយធ្វើឲ្យមានការលូតលាស់ខាងវិញ្ញាណ។ ប្រសិនបើអ្នកសួរមនុស្សគ្រប់រូបនៅក្នុងក្រុមជំនុំរបស់អ្នកឲ្យដកស្រង់រាល់ខគម្ពីរចងចាំ និងបទចម្រៀងនីមួយៗដែលពួកគេចេះ ពួកគេភាគច្រើនស្គាល់បទចម្រៀងច្រើនជាងចេះគម្ពីរឆ្ងាយណាស់។ ការនេះបានបង្ហាញពីសារៈសំខាន់នៃការដាក់បទចម្រៀងក្នុងចិត្តរបស់ពួកគេ ដែលត្រឹមត្រូវតាមទេវសាស្ត្រ និងមិនមានកំហុសឆ្គង។

ចូរសួរខ្លួនឯងនូវសំណួរនេះថា «បើសិនជារាស្ត្ររបស់ព្រះអាចទទួលការបង្រៀនអំពីព្រះ តែនៅក្នុងកម្មវិធីថ្វាយបង្គំដែលយើងរៀបចំ និងដឹកនាំ តើពួកគេនឹងចេះដឹងអ្វីខ្លះអំពីទ្រង់ ហើយតើពួកគេនឹងប្រកបទាក់ទងទ្រង់យ៉ាងដូចម្តេច?» [៩]

យើងត្រូវធ្វើឲ្យប្រាកដថា ផ្នែកនីមួយៗនៃកម្មវិធីថ្វាយបង្គំ នាំមកនូវការផ្លាស់ប្តូរដ៏ត្រឹមត្រូវសម្រាប់ពួកជំនុំរបស់យើង ឲ្យបានកាន់តែដូចព្រះគ្រីស្ទ។ ការនេះមានន័យថា ការជ្រើសរើសបទចម្រៀងសំខាន់ តែអត្ថន័យរបស់ការអធិស្ឋាន និងធាតុផ្សំដទៃទៀតនៃកម្មវិធីថ្វាយបង្គំក៏សំខាន់ណាស់ដែរ។ តើការអធិស្ឋានក្នុងកម្មវិធីថ្វាយបង្គំរបស់យើងមានភាពស៊ីជម្រៅទេ ហើយតើការអធិស្ឋាននោះ បានធ្វើជាគំរូសម្រាប់ជួយពួកជំនុំរបស់យើងឲ្យអធិស្ឋានក្នុងការថ្វាយបង្គំផ្ទាល់ខ្លួនឬទេ? តើផ្នែកនីមួយៗនៃកម្មវិធីថ្វាយបង្គំ នាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានដល់ពួកជំនុំដែរឬទេ?

អ្វីៗដែលយើងធ្វើ ក្នុងកម្មវិធីថ្វាយបង្គំ នាំមកនូវការផ្លាស់ប្តូរដល់ជីវិតរបស់ពួកជំនុំ និងការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេ ពេញមួយសប្តាហ៍។ ក្នុងនាមយើងជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ យើងចាំបាច់ត្រូវគិតអំពីវិធីដែលយើងអាចបង្រៀនពួកជំនុំរបស់យើង ក្នុងលក្ខណៈការបង្កើតសិស្ស តាមរយៈកម្មវិធីថ្វាយបង្គំ។

---

៩ លោក Zac Hicks. The Worship Pastor: A Call to Ministry for Worship Leaders and Teams (United States: Zondervan, ឆ្នាំ២០១៦) Kindle.

**អ្នកត្រូវមានតួនាទីជាអ្នកជំនាញសុវត្ថិភាពអាហារផ្នែកទេវសាស្ត្រ ដោយដឹងថា កម្មវិធីថ្វាយបង្គំអាចជាផ្លូវតែមួយ ដែលព្រះវិហារអាចបង្រៀនពួកជំនុំរបស់ខ្លួនតាមរបៀបបង្កើតសិស្ស។ តើតួនាទីនេះបានធ្វើឲ្យអ្នកដឹងច្បាស់អំពីការទទួលខុសត្រូវរបស់អ្នក ក្នុងការធ្វើផែនការ ដោយបំណងចិត្តចង់ឲ្យពួកគេចម្រើនឡើងឬទេ? តើអ្នកត្រូវកែលំអផ្នែកណាមុនគេ?**

# កសាងព័ន្ធកិច្ចថ្វាយបង្គំដែលបង្កើតសិស្ស

យើងចាំបាច់ត្រូវដឹងថា ពេលវេលានៃកម្មវិធីថ្វាយបង្គំក៏ជាពេលវេលាដែលជួយពួកសិស្សឲ្យមានការកើនឡើងផងដែរ តែទន្ទឹមនឹងនោះយើងក៏ត្រូវពិចារណាអំពីឱកាសជាច្រើន ហើយផ្សេងៗគ្នាសម្រាប់ការបង្កើតសិស្សក្នុងព័ន្ធកិច្ចនៃក្រុមថ្វាយបង្គំក្នុងពួកជំនុំរបស់យើង។

## ការផ្តល់ឱវាទ

ការឆ្លៀតពេលដើម្បីផ្តល់ឱវាទដល់អ្នកដ៏ទៃ (ជាពិសេសមនុស្សមួយចំនួនដែលប្រហែលជាមានអារម្មណ៍ថា ត្រូវបានត្រាស់ហៅទៅកាន់ព័ន្ធកិច្ចថ្វាយបង្គំ) គឺមានតម្លៃណាស់ក្នុងការបង្រៀនលើកទឹកចិត្ត និងជួយពួកគេឲ្យស្គាល់ការត្រាស់ហៅរបស់ព្រះក្នុងជីវិតរបស់ពួកគេ ។ ព្រះទ្រង់អាចបណ្តាលចិត្តអ្នកឲ្យនឹកចាំមនុស្សដែលអ្នកគួរចំណាយពេលជាមួយជាប្រចាំ ដើម្បីជួយពួកគេក្នុងការធ្វើដំណើរខាងវិញ្ញាណ។ ខ្ញុំនឹងនិយាយបន្ថែមអំពីការផ្តល់ឱវាទនេះក្នុងវគ្គបន្ទាប់។

## ការបង្កើតសិស្សក្នុងក្រុមតូច

ចូរស្វែងរកឱកាសបង្កើតក្រុមតូចមួយ ដែលមានគ្នាចាប់ពី៣ទៅ៤នាក់ ដើម្បីមានទំនាក់ទំនង បែបបង្កើតសិស្សពិតប្រាកដដោយជួយគ្នាទៅវិញទៅមកឲ្យមានទទួលខុសត្រូវខាងជំនឿ។ ក្រុមតូចនេះមិនចាំបាច់មានមនុស្សក្នុងព័ន្ធកិច្ចថ្វាយបង្គំក៏បាន ប៉ុន្តែ ក៏អាចមានដែរ។ អ្នកត្រូវការក្រុមតូចនេះ សម្រាប់ខ្លួនអ្នកក៏ដូចជាសម្រាប់អ្នកផ្សេងទៀតនៅក្នុងក្រុម។ ការបង្កើតក្រុមតូចឲ្យបានច្រើនចេញពីក្រុមតូចនេះ ក៏ជាគោលដៅមួយដែរ—ដើម្បីឲ្យអ្នកចូលរួមម្នាក់ៗនឹងបង្កើតជាក្រុមដែល

មានគ្នា៣-៤ នាក់រៀងៗខ្លួន ដើម្បីបន្តដំណើរការនៃការបង្កើតសិស្ស។

## ក្រុមបង្កើតសិស្ស

ចូរពិចារណាអំពីក្រុមផ្សេងៗដែលអ្នកដឹកនាំខ្លះអាចជាក្រុមតូច ខណៈពេលដែលខ្លះទៀតអាចមានចំនួនច្រើន។ ចូរស្វែងរកវិធីបង្រៀនក្រុមទាំងនេះ ។ មានវិធីមួយដែលអ្នកអាចបង្រៀនពួកគេ គឺតាមរយៈការចំណាយពេលអានអត្ថបទលើកទឹកចិត្តប្រចាំថ្ងៃ ឬតាមរយៈការចំណាយពេលនៅក្រោយការហាត់សម ឬមួយក្នុងការចំណាយពេលថ្វាយបង្គំព្រះ និងការសិក្សាព្រះគម្ពីរជាមួយគ្នា។ ពេលវេលាផ្សេងទៀតដែលមានសារៈសំខាន់ផងដែរ នោះគឺការផ្អាកការហាត់សមពាក់កណ្តាលទី ដែលក្នុងនោះអ្នកអាចបញ្ឈប់បទចម្រៀងដែលកំពុងច្រៀងសិន ដើម្បីនិយាយអំពីសេចក្តីពិតខាងវិញ្ញាណ ឬផ្តល់ទីបន្ទាល់ទាក់ទងនឹងអត្ថបទចម្រៀងនោះ។ ការនេះអាចជួយមនុស្សឲ្យកាន់តែមានមនោសញ្ចេតនាជាមួយបទចម្រៀងដែលពួកគេកំពុងនាំ។

## ការលើកទឹកចិត្តឲ្យមានការថ្វាយបង្គំ និងការជញ្ជឹងគិតព្រះបន្ទូលផ្ទាល់ខ្លួន

គឺដូចដែលបានរៀបរាប់ពីមុន អ្នកក៏អាចប្រើបច្ចេកវិទ្យាដូចជាការផ្ញើសារជាក្រុម អត្ថបទតាមអ៊ីនធឺណិត ឬតាមបណ្តាញសង្គម ដើម្បីចែករំលែកសេចក្តីពិតខាងវិញ្ញាណជាមួយក្រុមរបស់អ្នកពេញមួយសប្តាហ៍។ ចូរលើកទឹកចិត្ត និងជួយពួកគេឲ្យគិតអំពីរឿងរបស់ព្រះពេញមួយសប្តាហ៍ ដើម្បីបង្វែរសេចក្តីស្រឡាញ់របស់ពួកគេទៅរកព្រះ និងកែលម្អពេលវេលានៃការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេ។ ដូចគ្នានេះដែរ ការលើកទឹកចិត្តក្រុមរបស់អ្នកឲ្យថ្វាយបង្គំដោយប្រើបទចម្រៀង ដែលពួកគេនឹងដឹកនាំច្រៀងនៅថ្ងៃអាទិត្យ អាចជួយដល់ជីវិតនៃការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេមានការចម្រើនឡើងបន្ថែមទៀត ហើយនឹងជួយពួកគេដឹកនាំកម្មវិធីថ្វាយបង្គំព្រះតាមបទពិសោធន៍នៃការថ្វាយបង្គំផ្ទាល់ខ្លួនជាមួយបទចម្រៀងនោះ។

ការចំណាយពេលបង្កើតសិស្សជាទៀងទាត់ និងតាមឱកាសដែលមានក្នុងក្រុមដែលអ្នកដឹកនាំពិតជាមានសារៈសំខាន់ណាស់។

**តើអ្នកបានចូលរួមជាទៀងទាត់ក្នុងការបង្កើតសិស្សបួនប្រភេទដែលបានរៀបរាប់ខាងលើឬទេ? តើចំណុចណាខ្លះត្រូវការកែលំអ? សូមបង្កើតផែនការជាក់ស្តែងឥឡូវនេះ ដើម្បីធ្វើឲ្យការបង្កើតសិស្សក្លាយជាអាទិភាពក្នុងជីវិតរបស់អ្នក។**

# ការផ្តល់ឱវាទដល់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំ

សព្វថ្ងៃនេះ ខ្ញុំបានសង្កេតឃើញថាការដឹកនាំការថ្វាយបង្គំច្រើនតែមានទំនោរទៅរកការសង្កត់ធ្ងន់ទៅលើការផ្តល់ឱវាទដល់អ្នកដឹកនាំការថ្វាយបង្គំផ្សេងទៀត។ ជាច្រើនទសវត្សរ៍កន្លងទៅក្រុមជំនុំមួយបានហៅអ្នកដឹកនាំការថ្វាយបង្គំម្នាក់ឲ្យដឹកនាំកម្មវិធីថ្វាយបង្គំទាំងអស់នៅក្នុងក្រុមជំនុំ ហើយគ្រប់គ្រងការងារផ្នែកការថ្វាយបង្គំ និងតន្ត្រីទាំងអស់របស់ក្រុមជំនុំទាំងមូល។ គេរំពឹងថា គាត់នឹងដឹកនាំច្រៀងរាល់បទចម្រៀងទាំងអស់។ សព្វថ្ងៃនេះ មនុស្សកំពុងមើលឃើញគុណតម្លៃដ៏ឧត្តមនៃការផ្តល់ឱវាទដល់អ្នកដទៃ ដើម្បីបង្កើតឲ្យមានអ្នកដឹកនាំការថ្វាយបង្គំកាន់តែច្រើន។ ជាញឹកញយ គ្រូគង្វាលផ្នែកថ្វាយបង្គំនឹងទទួលតួនាទីជាគ្រូបង្វឹក និងជាអ្នកលើកទឹកចិត្ត ខណៈដែលអ្នកដឹកនាំការថ្វាយបង្គំកំពុងទទួលឱវាទ មានឱកាសការថ្វាយបង្គំនៅក្នុងកម្មវិធីថ្វាយបង្គំ។ គ្រូគង្វាលនៃការថ្វាយបង្គំប្រហែលជាមានតួនាទីជាអ្នកគាំទ្រ ឬជំនួយផ្នែកបច្ចេកទេស ឬមួយគ្រាន់តែចូលរួមក្រុមជំនុំក្នុងការថ្វាយបង្គំ។ គោលដៅគឺដើម្បីធ្វើឲ្យប្រាកដថា ការថ្វាយបង្គំរួមគ្នានាំមកនូវការផ្លាស់ប្រែជីវិតសម្រាប់ក្រុមជំនុំ ប៉ុន្តែរបៀបដែលការដឹកនាំកម្មវិធីថ្វាយបង្គំ អាចមានទម្រង់ផ្សេងៗគ្នាជាច្រើន។

គ្រូគង្វាលម្នាក់ដែលខ្ញុំបានបម្រើជាមួយធ្លាប់បាននិយាយថា អ្នកអាចនិយាយថា អ្នកជាអ្នកដឹកនាំដ៏ល្អប្រសិនបើអ្នកអាចដើរចេញ ហើយមនុស្សមិនដឹងទេថាអ្នកអវត្តមាន។ ការនេះបានក្លាយជារឿងពិតសម្រាប់ខ្ញុំក្នុងរយៈពេលមួយឆ្នាំមុនពេលដែលខ្ញុំនឹងចាកចេញពីប្រទេសរយៈពេលបីខែក្នុងបេសកកម្មនៅថ្ងៃឈប់សម្រាក។ ខ្ញុំបានចំណាយពេលវេលាច្រើន ក្នុងការបណ្តុះបណ្តាលក្រុមដឹកនាំកម្មវិធីថ្វាយបង្គំ ឲ្យចេះធ្វើផែនការ និងអនុវត្តកម្មវិធីថ្វាយបង្គំ។ ខ្ញុំបានផ្ទេរចំណេះដឹងទៅកាន់បុគ្គលដែលអាចឈានជើងចូលទៅក្នុងភាពជាអ្នកដឹកនាំការថ្វាយបង្គំ ដើម្បីធានាថាក្រុមជំនុំបន្តយ៉ាងរលូនពេលអវត្តមានរបស់ខ្ញុំ។

សព្វថ្ងៃនេះយើងកំពុងជួបប្រទះនូវការខ្វះខាតអ្នកដឹកនាំការថ្វាយបង្គំយ៉ាងខ្លាំងនៅសហរដ្ឋអាមេរិក។ ផ្នែកមួយនេះអាចបណ្តាលមកពីការលុបបំបាត់កម្មវិធីក្រុមចម្រៀងរបស់កុមារ និងយុវជននៅក្នុងព្រះវិហារ និងកម្មវិធីតន្ត្រីនៅក្នុងសាលារៀន។ ក្នុងនាមជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ យើងត្រូវសំគាល់មនុស្សដែលមានអំណោយទាន និងការត្រាស់ហៅឲ្យធ្វើព័ន្ធកិច្ចនៃការថ្វាយបង្គំ ហើយធ្វើអស់ពីសមត្ថភាព ដើម្បីបណ្តុះបណ្តាល បំពាក់បំប៉ន លើកទឹកចិត្ត និងផ្តល់ឱកាសឲ្យពួកគេដឹកនាំ។ យើងមិនត្រឹមតែកំពុងកែលម្អការថ្វាយបង្គំនៅក្នុងព្រះវិហារដែលយើង

បម្រើប៉ុណ្ណោះទេ ប៉ុន្តែយើងកំពុងរៀបចំអ្នកដឹកនាំថ្វាយបង្គំ ដើម្បីបញ្ជូនទៅកាន់ការងារបង្កើតក្រុមជំនុំ និងឱកាសបេសកកម្មអន្តរជាតិ ដើម្បីជួយក្រុមជំនុំដែលកំពុងជួបការលំបាកដឹកនាំកិច្ចការថ្វាយបង្គំ នៅក្រុមជំនុំដែលបានបង្កើតឡើង និងអ្វីៗជាច្រើនទៀត។

ក្នុងនាមយើងជាអ្នកដឹកនាំការថ្វាយបង្គំ យើងត្រូវតែយកការផ្តល់ឱវាទដល់អ្នកដឹកនាំការថ្វាយបង្គំជាអាទិភាពចម្បងក្នុងព័ន្ធកិច្ចបម្រើរបស់យើង។ ការផ្ទេរនូវជំនាញ និងគុណតម្លៃរបស់យើងគួរតែជាផ្នែកសំខាន់មួយដែលបង្ហាញថាយើងជានរណា។

**តើបច្ចុប្បន្ននេះអ្នកកំពុងផ្តល់ឱវាទដល់មនុស្សម្នាក់ ឬច្រើននាក់ដែលអាចដឹកនាំក្រុមរបស់អ្នក នៅពេលពួកគេដឹកនាំក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំដែរឬទេ? ពុំនោះទេ សូមអធិស្ឋានឲ្យព្រះបើកបង្ហាញនរណាម្នាក់ដល់អ្នក ដើម្បីចាប់ផ្តើមដំណើរការនេះ។**

## ការបង្កើតផ្នត់គំនិតផ្នែកបេសកកម្មក្នុងព័ន្ធកិច្ចថ្វាយបង្គំរបស់អ្នក

ខ្ញុំជឿថា យើងទាំងអស់គ្នានឹងយល់ស្របថា ពួកជំនុំរបស់យើងមិនគួរផ្តោតជាចម្បង ទៅលើផ្នែកខាងក្នុងតែប៉ុណ្ណោះទេ—ដោយគ្រាន់តែបំពេញតម្រូវការរបស់ពួកជំនុំ។ ក្រុមជំនុំដែលមិនបំពេញមហាបេសកកម្មហើយគ្រាន់តែមើលផ្នែកខាងក្នុង គឺជាក្រុមជំនុំដែលស្លាប់ ជាក្រុមជំនុំដែលវង្វេងទិសដៅរបស់ពួកគេ។

ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ យើងត្រូវស្វែងរកវិធីជំរុញចិត្តក្រុមរបស់យើង ឲ្យធ្វើបេសកកម្ម—ដោយចេញខាងក្រៅរបងព្រះវិហារ ដើម្បីប្រើប្រាស់អំណោយទានរបស់ពួកគេ ដើម្បីឈោងចាប់ពិភពលោកឲ្យថ្វាយព្រះគ្រីស្ទ។ ខាងក្រោមនេះគឺជាវិធីជាច្រើន ដើម្បីពិចារណាអំពីការចូលរួមបេសកកម្មជាមួយបុគ្គលម្នាក់ៗ និងក្រុមមកពីព័ន្ធកិច្ចថ្វាយបង្គំ៖

## កម្មវិធីបម្រើសហគមន៍

ចូរស្វែងរកវិធីបំពេញតម្រូវការរបស់មនុស្សនៅក្នុងតំបន់ដែលអ្នករស់នៅ ហើយទន្ទឹមនឹងនោះចូរកសាងទំនាក់ទំនងដែលអាចនាំទៅដល់ការចែកចាយអំពីព្រះគ្រីស្ទដល់អ្នកដទៃ។ ចូរស្វែងរកឱកាសសម្រាប់ឲ្យក្រុមរបស់អ្នកធ្វើការរួមគ្នាក្នុងការចែកចាយសេចក្ដីស្រឡាញ់របស់ព្រះ ក្នុងជម្រកជនអនាថា កន្លែងចែកអាហារ ក្នុងសាលារៀន ពន្ធនាគារ មជ្ឈមណ្ឌលស្ថានីតិសម្បទា។ល។ ចូរចំណាយពេលចែកចាយអំពីបទពិសោធន៍ទាំងនេះក្នុងកម្មវិធីក្រុមតូចប្រចាំសប្ដាហ៍ ដើម្បីអបអរសាទរជ័យជំនះ និងការផ្លាស់ប្រែជីវិតដែលព្រះប្រទាន។

ចូរដឹកនាំក្រុមចម្រៀង ក្រុមតន្ត្រី ឬក្រុមផ្សេងទៀត របស់អ្នកទៅកាន់ទីផ្សារ ដើម្បីលេងតន្ត្រី និងចែកចាយដល់មនុស្សដែលដើរកាត់។ ចូរទៅមណ្ឌលចាស់ជរា ហើយច្រៀងទំនុកសកល ឬលេងភ្លេង ដើម្បីជួយពួកគេឲ្យស្គាល់សេចក្ដីស្រឡាញ់របស់ព្រះ។ ចូរពិចារណាអំពីជម្រើសផ្សេងទៀត ដូចជាការប្រគុំតន្ត្រីក្រៅផ្ទះ សាលាតន្ត្រីទីធ្លាខាងក្រោយព្រះវិហារ កន្លែងពិធីជប់លៀង ឬមហោស្រពនៅសួនច្បារ។

## ការបង្កើតពួកជំនុំ ការឲ្យអ្នកភ្លេងទៅជួយព្រះវិហារផ្សេង

នៅក្នុងការងាររបស់ខ្ញុំ ខ្ញុំបានឮជានិច្ចអំពីក្រុមជំនុំដែលជួបការលំបាកអស់សង្ឃឹម ក្នុងការស្វែងរកអ្នកភ្លេងជួយក្នុងកម្មវិធីថ្វាយបង្គំ។ ចូរពិចារណាអំពីការឲ្យគេខ្ចីអ្នកភ្លេងរបស់អ្នកខ្លះទៅព្រះវិហារទាំងនេះ តាមមូលដ្ឋានជុំវិញ ដើម្បីធ្វើជាព្រះពរដល់ព្រះវិហារទាំងនេះ និងជួយពួកគេឲ្យមានសុខភាពល្អ។

ក្រុមដឹកនាំកម្មវិធីថ្វាយបង្គំខ្លះ កំពុងបំប៉នព្រះវិហារផ្សេងដែលកំពុងជួបការលំបាកដោយជួយពួកគេក្នុងផ្នែកជាច្រើន។ អ្នកអាចបង្កើតក្រុមថ្វាយបង្គំ ដើម្បីបម្រើព្រះវិហារនោះមួយរយៈ។ នេះជាវិធីដ៏ប្រសើរ ដើម្បីបង្កើតឲ្យមានអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ដែលអ្នកកំពុងផ្ដល់ឱកាសឲ្យពួកគេប្រើជំនាញរបស់ខ្លួន។

ការបង្កើតពួកជំនុំ គឺពិតជាសំខាន់ណាស់។ ចូរពិចារណា អំពីការបង្កើតក្រុមមួយឲ្យចេញទៅដឹកនាំកម្មវិធីថ្វាយបង្គំ នៅព្រះវិហារដែលបង្កើតថ្មី ដើម្បីជួយការងារនៅទីនោះឲ្យរីកចម្រើន។ ទោះនោះជាព្រះវិហាររបស់អ្នក ឬជាព្រះវិហារដែលជាដៃគូកំពុងបង្កើតក្ដី អ្នកអាចផ្ដល់ជំនួយច្រើនសន្ធឹកដល់ការងារថ្មីនេះ។

អ្នកអាចមានការពិបាកក្នុងការបង្វែរសមាជិកក្រុមថ្វាយបង្គំដែលមានអំណោយទានរបស់អ្នកទៅបម្រើកន្លែងផ្សេងទៀត ប៉ុន្តែ វាគឺជាផ្នែកសំខាន់មួយនៃ

ការរក្សាផ្នត់គំនិតដែលផ្ដោតលើនគរព្រះ។

## ការធ្វើដំណើរបេសកកម្ម និងការងារបម្រើរយៈពេលវែងជាង

យើងអាចពិពណ៌នាយ៉ាងសាមញ្ញថា គោលដៅនៃដំណើរបេសកកម្ម គឺដើម្បីផ្សាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ឬជួយអ្នកដទៃឲ្យផ្សាយដំណឹងល្អ។ ក្នុងនាមអ្នកជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ អ្នកអាចនាំក្រុមរបស់អ្នក ចូលរួមបេសកកម្មជាតិ និងអន្តរជាតិ តាមដែលមានឱកាស។ ចូរស្វែងរកឱកាសរយៈពេលខ្លី ដែលមានការងារជាដៃគូ ជាមួយបេសកជន ដែលពួកជំនុំរបស់អ្នកបានគាំទ្រ។ ចូរពិភាក្សាជាមួយសមាគមន៍ និងនិកាយរបស់ព្រះវិហាររបស់អ្នក ដើម្បីស្វែងរកឱកាស តាមរយៈអង្គការទាំងនោះ។ ចូរស្វែងរកមធ្យោបាយដែលក្រុមថ្វាយបង្គំរបស់អ្នកអាចធ្វើការជាដៃគូជាមួយពួកគេ ក្នុងការងាររបស់ពួកគេ តាមរយៈកម្មវិធីឈោងចាប់ការហ្វឹកហ្វឺន។ល។ ចូរលើកទឹកចិត្តសមាជិកក្រុមរបស់អ្នកឲ្យគិតអំពីការបម្រើក្នុងបេសកកម្មអស់រយៈពេល៣ខែទៅ២ឆ្នាំ។ អង្គការបេសកកម្មដែលអ្នកបានជួយ អាចផ្ដល់ឱកាសឲ្យពួកគេបម្រើ។ ទន្ទឹមនឹងនោះ ចូរលើកទឹកចិត្តពួកជំនុំរបស់អ្នកឲ្យគិតអំពីការបម្រើក្នុងការងារបេសកកម្មរយៈពេលវែង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំដែលខ្ញុំបានបម្រើក្រុមជំនុំក្នុងតំបន់ យើងបានចូលរួមជាញឹកញាប់ នៅក្នុងបេសកកម្មសហគមន៍តាមរយៈកម្មវិធីជប់លៀងការប្រគំតន្ត្រីខាងក្រៅ ការចាប់ដៃគូជាមួយព្រះវិហារផ្សេងទៀត ដើម្បីឈោងចាប់តំបន់ដែលកំពុងជួបការលំបាក ការទៅមណ្ឌលចាស់ជរាដើម្បីច្រៀង និងចែករំលែក និងមានអ្វីៗជាច្រើនទៀត។ យើងបានធ្វើដំណើរជាច្រើនដង ដើម្បីជួយបេសកជនរបស់យើងនៅតំបន់ផ្សេងទៀតនៃប្រទេសរបស់យើងតាមវិធីជាច្រើន កម្មវិធីខ្លះមានតន្ត្រី ហើយខ្លះទៀតមិនមានតន្ត្រី។ ខ្ញុំបានយកក្រុមថ្វាយបង្គំរៀងរាល់ពីរឆ្នាំម្ដង ទៅកាន់ទ្វីបអាស៊ី ដើម្បីដឹកនាំសន្និបាតថ្វាយបង្គំ ព្រឹត្តិការណ៍ឈោងចាប់ កម្មវិធីថ្វាយបង្គំ និងអ្វីៗផ្សេងទៀតដែលបេសកជន និងអ្នកដឹកនាំក្រុមជំនុំនៅក្នុងប្រទេសបានស្នើសុំ។ ព្រះវិហាររបស់ខ្ញុំបានផ្ដល់ឲ្យខ្ញុំនូវបេសកកម្មក្នុងពេលវិស្សមកាល ដើម្បីបម្រើនៅក្នុងប្រទេសមួយនៅរដូវក្ដៅ ដើម្បីជួយក្រុមថ្វាយបង្គំ ដែលរស់នៅក្នុងទីក្រុងនោះ។

ការទាំងអស់នេះបានបង្កើតជាផ្នត់គំនិតបេសកកម្មមួយ នៅក្នុងព័ន្ធកិច្ចថ្វាយបង្គំរបស់យើង។ យើងក៏បានដឹងថា ព្រះអង្គត្រាស់ហៅយើងឲ្យធ្វើលើសពីការដឹកនាំការថ្វាយបង្គំរៀងរាល់ថ្ងៃអាទិត្យនៅព្រះវិហារក្នុងតំបន់ ពោលគឺឲ្យយើងបម្រើ

ព្រះអង្គនៅក្រៅព្រះវិហារផងដែរ។ ខ្ញុំជឿថា ការចូលរួមរបស់យើងនៅខាងក្រៅរបងព្រះវិហារ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់យើង ក្នុងការដឹកនាំការថ្វាយបង្គំពីមួយសប្តាហ៍ទៅមួយសប្តាហ៍។ វាក៏បានធ្វើឲ្យទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងកាន់តែជិតស្និទ្ធផងដែរ។

**តើវិធីជាក់លាក់អ្វីខ្លះ ដែលអ្នកអាចនាំក្រុមរបស់អ្នកធ្វើបេសកកម្មក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស? តើព្រះវិហាររបស់អ្នកអាចមានឱកាសចូលរួម ក្នុងការជួយពួកជំនុំដទៃ ឬបង្កើតពួកជំនុំ? តើអ្នកអាចស្វែងរកឱកាសធ្វើបេសកកម្មរយៈពេលខ្លី ក្នុងពេលវិស្សមកាលឬទេ?**

## អភិវឌ្ឍន៍ឲ្យមានកំរិតខ្ពស់នៃភាពល្អប្រសើរក្នុងក្រុមថ្វាយបង្គំរបស់អ្នក

នៅក្នុងការយល់ដឹងអំពីការដឹកនាំការថ្វាយបង្គំក្នុងផ្នែកទីមួយនៃជំពូកនេះ យើងបានព្យាយាមស្វែងយល់ពីអ្វីទៅជាអ្នកដឹកនាំការថ្វាយបង្គំ ហើយនិងវិន័យមួយចំនួនដែលអ្នកដឹកនាំថ្វាយបង្គំគួរអនុវត្ត។ យើងក៏បានឃើញផងដែរថា អ្នកដឹកនាំការថ្វាយបង្គំត្រូវតែមានតួនាទីជាអ្នកជំនាញសុវត្ថិភាពអាហារផ្នែកទេវសាស្ត្រ ដើម្បីបម្រើយ៉ាងប្រុងប្រយ័ត្ននូវកម្មវិធីថ្វាយបង្គំដែលនឹងធ្វើឲ្យអ្នកចូលរួមកាន់តែដូចរូបអង្គនៃព្រះគ្រីស្ទ។ ផ្នែកដ៏ធំមួយទៀតនៃការធ្វើជាអ្នកដឹកនាំការថ្វាយបង្គំ គឺការផ្តល់ការណែនាំ និងបង្រៀនក្រុមរបស់អ្នកប្រកបដោយប្រសិទ្ធភាព ដូចដែលបានពិភាក្សានៅក្នុងមេរៀនមុននេះ។ យើងក៏គួរអំពាវនាវដល់ក្រុមយើងឲ្យមានភាពល្អប្រសើរក្នុងព័ន្ធកិច្ចរបស់ពួកគេ មិនត្រឹមតែដោយសារព្រះគម្ពីរទាមទារប៉ុណ្ណោះទេ ប៉ុន្តែ ក៏ដោយសារតែវាជួយយ៉ាងខ្លាំង ដល់សមត្ថភាពរបស់យើង ក្នុងការដឹកនាំការថ្វាយបង្គំដែលបំផ្លាស់បំប្រែយ៉ាងមានប្រសិទ្ធភាព។

នៅពេលយើងពិចារណារឿងនេះជាដំបូង ខ្ញុំបាននាំអ្នកទៅកាន់ការដកស្រង់ចេញពីសៀវភៅរបស់លោក រ៉ូរី ណូលែន (Rory Noland) មានចំណងជើងថា បេះដូងនៃអ្នកសិល្បៈដែលក្នុងនោះគាត់និយាយអាកប្បកិរិយា និងប្រតិកម្មដែល

មនុស្សមានផ្សេងៗគ្នា នៅក្នុងព័ន្ធកិច្ចថ្វាយបង្គំ គឺអ្នកដែលគ្រាន់តែចាត់ទុកខ្លួនឯងជាអ្នកស្ម័គ្រចិត្ត ឬអ្នកដែលព្រះត្រាស់ហៅឲ្យបម្រើព្រះ និងក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំ។ ចូរអានអំពីភាពខុសគ្នា (dichotomy) នីមួយៗ ហើយមើលពីរបៀបដែលទស្សនៈផ្សេងគ្នា អាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងខ្លាំង នៅក្នុងសមត្ថភាពក្រុមរបស់អ្នកក្នុងការដឹកនាំការថ្វាយបង្គំប្រកបដោយប្រសិទ្ធភាព។ អ្នកក៏ឃើញកម្រិតកាន់តែស៊ីជម្រៅនៃការតាំងចិត្ត សេចក្តីអំណរ និងគោលបំណងនៅក្នុងអ្នកដែលស្គាល់ការត្រាស់ហៅរបស់ព្រះ។

## អ្នកស្ម័គ្រចិត្ត ឬមនុស្សដែលព្រះបានត្រាស់ហៅ?

១. អ្នកស្ម័គ្រចិត្តមើលឃើញការចូលរួមរបស់ពួកគេនៅក្នុងក្រុមជំនុំជាការបម្រើសហគមន៍ ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅយល់ឃើញថាការចូលរួមនោះគឺការងារបម្រើព្រះ។
២. អ្នកស្ម័គ្រចិត្តភ្ញាក់ផ្អើលអំពីអ្វីដែលពួកគេនឹងត្រូវលះបង់ ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅបានតាំងចិត្តបម្រើព្រះ។
៣. អ្នកស្ម័គ្រចិត្តដកខ្លួនចេញពីការដោះស្រាយជម្លោះក្នុងទំនាក់ទំនង ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅស្វែងរកដំណោះស្រាយជម្លោះក្នុងទំនាក់ទំនង ដើម្បីការរួបរួមក្នុងក្រុមជំនុំ។
៤. អ្នកស្ម័គ្រចិត្តមើលទៅការហាត់សម ជាការប្តេជ្ញាចិត្តមួយទៀត ដែលពួកគេមានកាតព្វកិច្ចត្រូវបំពេញ ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅទន្ទឹងរង់ចាំឱកាសមួយទៀតដែលព្រះទ្រង់ប្រើ។
៥. អ្នកស្ម័គ្រចិត្តធ្វើការបន្តិចបន្តួចក្រៅពីការហាត់ ឬការរៀបចំខ្លួន ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅ មកហាត់សម និងថ្វាយបង្គំតាមដែលអាចធ្វើទៅបាន ទាន់ពេលវេលា និងត្រៀមខ្លួនបម្រើទ្រង់។
៦. អ្នកស្ម័គ្រចិត្តមិនចំហចិត្ត ទទួលការរិះគន់ក្នុងន័យស្ថាបនាឡើយ តែពួកគេការពារខ្លួនពីការរិះគន់ ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅ មានការដឹងគុណចំពោះមតិកែលម្អ ពីព្រោះពួកគេចង់ក្លាយជាមនុស្សល្អបំផុតតាមដែលពួកគេអាចធ្វើបានសម្រាប់ព្រះ។
៧. អ្នកស្ម័គ្រចិត្តមានអារម្មណ៍ថា ត្រូវបានគំរាមកំហែងដោយទេពកោសល្យរបស់អ្នកដទៃ ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅ សរសើរទ្រង់សម្រាប់ការចែកចាយអំណោយទាន និងទេពកោសល្យតាមការជ្រើស

រើសរបស់ទ្រង់។

៨. អ្នកស្ម័គ្រចិត្តចង់ឈប់ធ្វើការ នៅពេលឃើញសញ្ញាដំបូងនៃភាពមិនអំណោយផល ឬការធ្លាក់ទឹកចិត្ត ប៉ុន្តែ មនុស្សដែលប្រកាន់គោលជំហរ និងមានការស៊ូទ្រាំ។

៩. អ្នកស្ម័គ្រចិត្តស្វែងរកប្រភពនៃការស្កប់ចិត្តនៅក្នុងទេពកោសល្យ និងសមត្ថភាពរបស់ពួកគេ ប៉ុន្តែមនុស្សដែលព្រះបានត្រាស់ហៅដឹងថា ខ្លួនមានការស្កប់ចិត្តបំផុត នៅក្នុងការងារបម្រើព្រះ ដើម្បីបំពេញបំណងព្រះទ័យទ្រង់ ។

១០. អ្នកស្ម័គ្រចិត្តច្រើនតែមិនអាចស៊ូទ្រាំ នឹងស្ថានភាពដែលរុញច្រានពួកគេចេញពីភាពសុខស្រួល ប៉ុន្តែ មនុស្សដែលព្រះបានត្រាស់ហៅ ឆ្លើយតបនឹងការហៅរបស់ព្រះអង្គដោយការពឹងផ្អែកលើទ្រង់ដោយបន្ទាបខ្លួន។[១០]

**បន្ទាប់ពីបានអានការបកស្រាយទាំងដប់ចំណុចនេះហើយ តើអ្នកនឹងនិយាយថា អ្នកមានអារម្មណ៍ថា អ្នកជាមនុស្សដែលព្រះបានត្រាស់ហៅ ឬជាអ្នកស្ម័គ្រចិត្ត? តើការប្រព្រឹត្តរបស់អ្នកដូចមួយណាជាង? តើអ្នកឃើញសមាជិកក្រុមអ្នក មានអាកប្បកិរិយាអ្វីខ្លះដែលបង្ហាញការស្ម័គ្រចិត្ត ឬការត្រាស់ហៅ?**

ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យចំណាយពេលខ្លះ ដើម្បីឲ្យក្រុមថ្វាយបង្គំរបស់អ្នកចំណាយពេលគិតអំពីចំណុចខាងលើនេះ ហើយជួយពួកគេឲ្យរកឃើញថា តើពួកគេមានអារម្មណ៍ដូចជាអ្នកស្ម័គ្រចិត្ត ឬជាមនុស្សដែលព្រះបានត្រាស់ហៅ។ អ្នកនឹងរកឃើញថា ពួកគេខ្លះគិតថាខ្លួនត្រូវបានព្រះត្រាស់ហៅ ប៉ុន្តែ ពួកគេបានបង្ហាញពីអាកប្បកិរិយាជាអ្នកស្ម័គ្រចិត្តយ៉ាងច្បាស់។ ការមានការពិភាក្សាដោយបើកចំហអំពីបញ្ហានេះ អាចជួយបង្រៀនក្រុមរបស់អ្នកអំពីផ្នែកនេះ។

## ការបណ្ដុះវប្បធម៌ដែលនាំឲ្យមានការហាត់សមកាន់តែប្រសើរ

មេរៀនបន្ទាប់នេះគឺជាឧបករណ៍ដ៏ល្អសម្រាប់ការដឹកនាំក្រុមរបស់អ្នកឲ្យបានល្អបំផុតដែលពួកគេអាចធ្វើបាន។ លោក ចន នីកូល (Jon Nichol) ជាម្ចាស់

១០ លោក Rory Noland, The Heart of the Artist: A Character-Building Guide for You and Your Ministry Team (United States, Zondervan, ឆ្នាំ២០០៩), Kindle.

វេបសាយ WorshipTeamCoach.com បានធ្វើការសិក្សាដ៏ល្អមួយដែលបង្កើតមូលដ្ឋានគ្រឹះតាមព្រះគម្ពីរ សម្រាប់ការដឹកនាំការថ្វាយបង្គំដោយឧត្ដមភាព ហើយស្ថាបនាលើគ្រឹះនោះ តាមការអនុវត្តជាក់ស្តែង ក្នុងការងារផ្នែកថ្វាយបង្គំ។ ដោយមានការអនុញ្ញាតពីលោក ចន ខ្ញុំបានបញ្ចូលមេរៀនគាត់ក្នុងសៀវភៅនេះ។ អ្នកអាចនឹងកែសម្រួលគោលការណ៍ទាំងនេះ ឲ្យត្រូវនឹងស្ថានភាពរបស់អ្នក។ មានអ្វីច្រើននៅទីនេះដែលត្រូវខិតខំបន្ត ប៉ុន្តែ ការព្យាយាមដោះស្រាយអ្វីទាំងអស់ក្នុងពេលតែមួយអាចនឹងលើសលប់សម្រាប់ស្ថានភាពជាច្រើន។

## ហេតុអ្វីយើងត្រូវមានការរៀបចំ

គោលបំណងចម្បងរបស់យើង គឺដើម្បីថ្វាយបង្គំព្រះ និងជួយអ្នកឯទៀតឲ្យថ្វាយបង្គំព្រះអង្គ។ យើងធ្វើការនេះបានតាមវិធីបួនយ៉ាង៖

១. **យើងធ្វើការបម្រើព្រះតាមរយៈការថ្វាយបង្គំ** (ចោទិយកថា ១០:៨)។
២. **យើងនាំគេចូលព្រះវត្តមានរបស់ព្រះ** (១ពេត្រុស ២:៩; ចោទិយកថា ១០:៨-៩; កូឡូស ១:២៧)។
៣. **យើងបង្កើតកន្លែងសម្រាប់ឲ្យមនុស្សជួបជាមួយព្រះ៖**
   a. យើងធ្វើឲ្យបរិយាកាសកាន់តែប្រសើរឡើងខាងទស្សនីយភាព និងតន្ត្រី។
   b. យើងលុបបំបាត់ការធ្វើឲ្យបែកអារម្មណ៍។
៤. **យើងធ្វើជាគំរូខាងការថ្វាយបង្គំ និងបង្រៀនអ្នកដទៃឲ្យថ្វាយបង្គំ។**

ហេតុអ្វីយើងទាមទារឲ្យមានការរៀបចំ?

## ទស្សនវិជ្ជានៃការរៀបចំ

- ការរៀបចំគឺជាការតម្រូវស្របតាមការកំណត់របស់ព្រះគម្ពីរ អំពីជំនាញខាងតន្ត្រីក្នុងការថ្វាយបង្គំ។ បទគម្ពីរទំនុកតម្កើង ៣៣:៣ ពួកលេវីដឹកនាំផ្នែកតន្ត្រី «លេងភ្លេងយ៉ាងស្ទាត់ជំនាញ» ... ១របាក្សត្រ ១៥:២២ «លោកត្រួតលើចំរៀង គឺលោកដែលបង្ហាត់ការនោះ ពីព្រោះលោកជាអ្នកប៉ិនប្រសប់»។
- ការរៀបចំគឺជាសកម្មភាពនៃការថ្វាយបង្គំ។ យើងត្រូវការពេលវេលា ទេពកោសល្យ និងកម្លាំងក្នុងការរៀបចំ ដើម្បីបម្រើព្រះ និងប្រជារាស្ត្ររបស់ទ្រង់។ រ៉ូម ១២:១ «យញ្ញបូជារស់ និងបរិសុទ្ធ ... នេះជាការថ្វាយបង្គំដែលគាប់ព្រះហឫទ័យដល់ព្រះ»។ កូឡុស ៣:២៣-២៤ «ចូរធ្វើទាំងអស់ ... ទុកដូចជា

បម្រើដល់ព្រះអម្ចាស់មិនបម្រើដល់មនុស្សទេ»។

- ការរៀបចំអនុញ្ញាតឲ្យមានសេរីភាពក្នុងការថ្វាយបង្គំ។ ការថ្វាយបង្គំរបស់យើងអាចបង្ហាញចេញដួងចិត្តយើងដោយមិនមានការទើសទាល់ ប្រសិនបើយើងមានការរៀបចំបានល្អ ទាំងការរៀបចំជាលក្ខណៈបុគ្គល និងជាក្រុម។
- ការរៀបចំជួយយើងផ្តល់ឲ្យនូវភាពល្អប្រសើរ និងរៀបរយ។ ភីលីព ៤:៨ «សេចក្តីណាដែលគួរស្រឡាញ់ សេចក្តីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្តីសរសើរណា នោះចូរពិចារណាពីសេចក្តីទាំងនោះចុះ»។
- ការរៀបចំទាមទារការចំណាយពេល និងកម្លាំងផ្ទាល់ខ្លួន និងជាក្រុម។ ការអនុវត្តគឺជារឿងផ្ទាល់ខ្លួន ហើយការហាត់សមគឺត្រូវធ្វើរួមគ្នា។
- ការអនុវត្តគឺរឿងផ្ទាល់ខ្លួន។ អ្នកភ្លេង និងអ្នកបច្ចេកទេសម្នាក់ៗ ត្រូវរៀនផ្នែករបស់គាត់មុនពេលសម។ វាគឺជាការចំណាយពេល និងកម្លាំងសម្រាប់កម្មវិធីថ្វាយបង្គំ និងការហាត់សម។
- ការហាត់សមគឺត្រូវធ្វើរួមគ្នា។ ការហាត់សមគឺការធ្វើការជាក្រុម។ វាត្រូវការពេលវេលារបស់យើងរួមគ្នា ដើម្បីរៀបចំបទចម្រៀង ហាត់សមនូវលំហូរនៃកម្មវិធីថ្វាយបង្គំ និងរីកចម្រើនជាមួយគ្នាជាក្រុម។ ប្រសិនបើខ្ញុំមកចូលរួមដោយមិនបានត្រៀមខ្លួន (ឬមិនបានចូលរួមទាល់តែសោះ) ខ្ញុំនឹងធ្វើឲ្យប៉ះពាល់ដល់ក្រុមទាំងមូលព្រមទាំងកម្មវិធីថ្វាយបង្គំ។

**ហេតុអ្វីបានជាការរៀបចំឲ្យបានល្អប្រសើរ មានសារៈសំខាន់ចំពោះការដឹកនាំការថ្វាយបង្គំ? តើការបង្រៀនឲ្យមានការអនុវត្តផ្ទាល់ខ្លួនផ្នែកតន្ត្រី មុនពេលអ្នកចូលរួមការហាត់សមមានលក្ខណៈចម្លែកសម្រាប់អ្នកឬទេ? ចុះក្រុមរបស់អ្នកវិញ?**

## ហេតុផលជាក់ស្តែងហេតុអ្វីការហាត់សមមានសារៈសំខាន់

ទំនុកចិត្ត និងសេរីភាពក្នុងការថ្វាយបង្គំ

- ការរៀបចំ = ទំនុកចិត្ត
- ទំនុកចិត្ត = សេរីភាពកាន់តែច្រើនក្នុងការថ្វាយបង្គំ
- សេរីភាពកាន់តែច្រើនក្នុងការថ្វាយបង្គំ = ការដឹកនាំ និងការចូលរួមបានកាន់

តែប្រសើរជាមួយក្រុមជំនុំទាំងមូល

ទាំងអស់នោះគឺស្មើនឹងបទពិសោធន៍កាន់តែប្រសើរសម្រាប់មនុស្សគ្រប់គ្នា។ សូមគិតអំពីរឿងនេះ។ កាលណាយើងត្រៀមខ្លួនកាន់តែច្រើនដើម្បីស្គាល់តន្ត្រី ការផ្លាស់ប្ដូរ ។ល។ នោះយើងកាន់តែមានទំនុកចិត្តកាន់តែខ្លាំងក្នុងការដឹកនាំការថ្វាយបង្គំ។ ការបង្កើនទំនុកចិត្តអនុញ្ញាតឲ្យយើងមានសេរីភាពកាន់តែច្រើន ដោយសារយើងមិនសូវប្រឹងមើលណោតតន្ត្រី។ ការមានសេរីភាពកាន់តែច្រើនអនុញ្ញាតឲ្យយើងប្រាស្រ័យទាក់ទង ហើយចូលរួមក្នុងក្រុមជំនុំយ៉ាងពិតប្រាកដនៅកម្រិតខ្ពស់ ដោយសារយើងមិនចាំបាច់ផ្ដោតទៅលើការកត់ចំណាំ ចង្វាក់ ការរៀបចំ។ល។ ពីព្រោះយើងបានស្គាល់តន្ត្រីយ៉ាងច្បាស់ហើយ។

**សូមគិតអំពីពេលវេលាដែលក្រុមរបស់អ្នករៀបចំខ្លួនមិនបានល្អ សម្រាប់ការដឹកនាំការថ្វាយបង្គំ និងពេលវេលាដែលពួកគេបានរៀបចំខ្លួនយ៉ាងល្អ។ តើនោះមានអារម្មណ៍ខុសគ្នាយ៉ាងណាក្នុងជីវិតរបស់ក្រុមថ្វាយបង្គំ? តើអ្នកគិតថា ក្រុមជំនុំមានបទពិសោធន៍ខុសគ្នាបែបណា?**

## របៀបដឹកនាំសមាជិកក្រុមរបស់អ្នកឲ្យមានទម្លាប់អនុវត្តបានកាន់តែល្អ

តើអ្នក និងក្រុមរបស់អ្នកបានរៀបចំខ្លួនសម្រាប់ការលេងតន្ត្រី ក្នុងការអនុវត្តផ្ទាល់បានល្អប៉ុណ្ណា មុនពេលមកសម? ចូរវាយតម្លៃខ្លួនអ្នកនៅលើមាត្រដ្ឋាននេះ៖

**ការអនុវត្តមុនការហ្វឹកហាត់**

តើអ្នកវាយតម្លៃខ្លួនអ្នកយ៉ាងដូចម្ដេច ផ្អែកទៅលើការអនុវត្តផ្ទាល់ខ្លួន?

**១ ស្ទើរតែគ្មាន** — **១០ ធ្វើបានល្អ**

តើអ្នកវាយតម្លៃក្រុមរបស់អ្នកយ៉ាងដូចម្ដេច ចំពោះការអនុវត្តការហាត់សម?

**១ ស្ទើរតែគ្មាន** — **១០ ធ្វើបានល្អ**

**ខាងក្រោមនេះគឺជាវិធីដឹកនាំក្រុមរបស់អ្នក ដើម្បីឲ្យមានទម្លាប់អនុវត្តឲ្យកាន់តែល្អ៖**

**ចូរធ្វើជាគំរូ:** ដើម្បីដឹកនាំសមាជិកក្រុមរបស់អ្នកឲ្យរៀបចំខ្លួនបានល្អសម្រាប់ការសម ជាបឋម អ្នកចាំបាច់ត្រូវធ្វើជាគំរូ ដើម្បីឲ្យពួកគេយល់អត្ថន័យនៃការរៀបចំខ្លួន។ អ្នកគួរតែជាមនុស្សដែលមានការត្រៀមខ្លួនខ្លាំងបំផុត ក្នុងចំណោមពួកគេ។ អ្នកត្រូវមកដោយស្គាល់បទចម្រៀងរបស់អ្នកឲ្យបានហ្មត់ចត់ និងដឹងថាអ្នកចង់ធ្វើអ្វីខ្លះ នៅក្នុងការហាត់សម។ អ្នកត្រូវយកសមាជិកក្រុមសំខាន់ៗផ្សេងទៀត ធ្វើជាគំរូនៃការរៀបចំដ៏ល្អផងដែរ។ ប្រសិនបើមានពេលខ្លះដែលអ្នករៀបចំមិនបានល្អ កុំធ្វើការដោះសារ តែចូរទទួលខុសត្រូវចំពោះការខ្វះខាតរបស់អ្នក។ ភាពស្មោះត្រង់ជួយអ្នកឲ្យទៅបានឆ្ងាយ។

**តើអ្នកមកសមជាទៀតទាត់ ដោយមានការរៀបចំខ្លួនទុកជាមុនដែរឬទេ?**

**ចូរសរសើរពួកគេ:** នៅពេលអ្នកផ្សេងទៀតមក ដោយរៀបចំខ្លួនបានល្អសម្រាប់ការហាត់សម ចូរសរសើរពួកគេ ហើយប្រាប់ពួកគេថា អ្នកពេញចិត្តចំពោះការត្រៀមខ្លួននោះ។ ចូរជួយពួកគេឲ្យមើលឃើញថា ការត្រៀមខ្លួនរបស់ពួកគេ ធ្វើឲ្យពេលវេលានៃការសមមានភាពរលូនជាងមុន។ ការលើកទឹកចិត្តរបស់អ្នកនឹងជួយពង្រឹងការត្រៀមខ្លួនឲ្យបានល្អប្រសើរ។

**តើសមាជិកក្រុមណាតែងតែរៀបចំខ្លួនបានល្អ? តើនរណាជាអ្នកទាញក្រុមថយក្រោយដោយសារការត្រៀមខ្លួនមិនបានល្អ?**

**ចូរស្រមៃមើលរូបភាព:** អ្នកត្រូវជួយក្រុមរបស់អ្នកឲ្យមើលឃើញថាការរៀបចំដ៏អស្ចារ្យមានលក្ខណៈដូចម្ដេចដែរ ហើយហេតុអ្វីបានជាវាសំខាន់។ ក្រោយមកបន្ទាប់ពីក្រុមរបស់អ្នកដឹកនាំបានល្អដោយសារការរៀបចំយ៉ាងហ្មត់ចត់ ចូរចង្អុលបង្ហាញថា ក្រុមទាំងមូល និងពួកជំនុំបានដកពិសោធនឹងកម្មវិធីថ្វាយបង្គំកាន់តែល្អ

ប៉ុណ្ណា។

អ្នកអាចជួយក្រុមរបស់អ្នក ឲ្យស្រមៃឃើញរូបភាព ដោយជួយពួកគេរក្សាគោលដៅនេះ នៅចំពោះមុខពួកគេជានិច្ច ហើយប្រើសេចក្តីថ្លែងការណ៍ខ្លីៗមួយចំនួនដូចជា៖

- ការអនុវត្តសម្រាប់ធ្វើផ្ទាល់ខ្លួន ហើយការហាត់សមសម្រាប់ធ្វើរួមគ្នា
- យើងមិនអាចដឹកនាំបានល្អ នូវអ្វីដែលយើងមិនចេះច្បាស់នោះទេ
- ប្រសិនបើអ្នកត្រូវបានត្រាស់ហៅមកបម្រើក្នុងក្រុមថ្វាយបង្គំ នោះអ្នកក៏ត្រូវបានត្រាស់ហៅឲ្យមានភាពស្ទាត់ជំនាញផងដែរ។ (ហើយជំនាញទាមទារឲ្យមានការត្រៀមខ្លួន។)
- យើងជាសង្ឃដែលមានតួនាទីរៀបចំកន្លែងសម្រាប់រាស្ត្ររបស់ព្រះជួបជាមួយព្រះអង្គ។

**តើមានវិធីណាខ្លះដែលខ្ញុំអាចចាប់ផ្តើមជួយក្រុមរបស់ខ្ញុំឲ្យមើលឃើញថា ការរៀបចំដ៏ប្រសើរមើលទៅមានលក្ខណៈដូចម្តេច ហើយតើលទ្ធផលអាចនឹងទៅជាយ៉ាងណា? តើភាពជោគជ័យអ្វីខ្លះនៅពេលថ្មីៗនេះ ដែលយើងអាចមើលទៅកាន់វា ដើម្បីលើកទឹកចិត្តដល់ការរៀបចំដ៏ប្រសើរ? តើសេចក្តីថ្លែងការណ៍ខ្លីៗអ្វីខ្លះ ដែលអាចជួយបង្កើតវប្បធម៌នៃការត្រៀមខ្លួនយ៉ាងល្អសម្រាប់ការហាត់សម?**

**ចូរបញ្ជាក់ឲ្យច្បាស់លាស់:** ត្រូវមានភាពជាក់លាក់ អំពីការរៀបចំសម្រាប់ការហាត់សមដែលត្រូវមានលក្ខណៈបែបណា។ ចូរឲ្យឧទាហរណ៍។ ជៀសវាងការកំណត់រយៈពេល។ មនុស្សមួយចំនួនអាចឈានដល់កម្រិតខ្ពស់នៃការត្រៀមខ្លួនក្នុងរយៈពេលតិចជាងអ្នកដទៃ។ ការកំណត់ពេលវេលាមិនមានភាពចាំបាច់ត្រង់ចំណុចនេះទេ។ ចូរជួយក្រុមរបស់អ្នករៀនពីរបៀបអនុវត្ត ដើម្បីឲ្យពួកគេប្រើប្រាស់ពេលវេលាផ្ទាល់ខ្លួនបានល្អបំផុត។ ការរៀបចំគោលការណ៍ដែលបង្ហាញថាអ្នករំពឹងចង់បានអ្វី អាចមានប្រយោជន៍ខ្លាំងណាស់ដោយបង្ហាញបំណងប្រាថ្នាទាំងនេះដល់ក្រុមរបស់អ្នក។ ចូរបង្ហាញពួកគេផងដែរថា អ្នកក៏រំពឹងចង់បានអ្វីខ្លះ ពីការអនុវត្តផ្ទាល់ខ្លួន ការសម ការឆែកសំឡេង/កំដៅសាច់ដុំ និងការរីកចម្រើន។ (ខ្ញុំនឹងនិយាយលម្អិតអំពីរឿងនេះនៅពេលក្រោយ)។

**តើក្រុមរបស់អ្នកដឹងថា អ្នករំពឹងចង់បានអ្វីខ្លះពីពួកគេ ក្នុងការរៀបចំខ្លួនសម្រាប់ការហាត់សម? តើអ្នកនឹងបង្ហាញឲ្យពួកគេដឹងអំពីការរំពឹងចង់បាននេះយ៉ាងដូចម្ដេចខ្លះ? ចូរជួយសមាជិកក្រុមរបស់អ្នកឲ្យយល់ និងគាំទ្រគោលការណ៍ដែលអ្នកបានរៀបចំ។**

**ចូររំពឹងទុកជាមុនៈ** នៅពេលដែលអ្នកបានបង្ហាញការរំពឹងទុកបានច្បាស់លាស់ហើយ ចូររំពឹងថាសមាជិកក្រុមរបស់អ្នកនឹងធ្វើតាម។ ចូរសង្ឃឹមថាក្រុមរបស់អ្នកនឹងធ្វើតាមបានល្អបំផុត។ អ្នកត្រូវមានការសន្ទនាដែលសំខាន់ៗ និងដឹកនាំដោយក្ដីស្រឡាញ់ នៅពេលអ្នកប្រឈមមុខនឹងមនុស្សដែលមិនបានត្រៀមខ្លួនហើយទាញក្រុមឲ្យថយក្រោយ។ អ្នកត្រូវលើកទឹកចិត្តអ្នកដែលរៀបចំខ្លួនបានល្អ។ អ្នកត្រូវដឹងថា មនុស្សមួយចំនួនត្រូវការចំណាយពេលច្រើន ហើយមិនមែនជាអ្វីដែលអាចនឹងកើតឡើងភ្លាមៗសម្រាប់សមាជិកគ្រប់គ្នានោះទេ។ ចូរអបអរជំហានតូចៗ ដែលក្រុមរបស់អ្នកបានឈានទៅមុខ នៅក្នុងដំណើរការនេះ។

**ប្រសិនបើក្រុមរបស់អ្នកដឹងថា អ្នកបានរំពឹងចង់បានអ្វីពីពួកគេ តើអ្នកឲ្យពួកគេទទួលខុសត្រូវទេ? តើអ្នកត្រូវមានការសន្ទនាដែលពិបាក ប៉ុន្តែ ពេញដោយក្ដីស្រឡាញ់ដូចម្ដេចខ្លះជាមួយអ្នកដែលរៀបចំខ្លួនមិនបានល្អ?**

## ការរំពឹងទុកសម្រាប់ការរៀបចំខ្លួន

នេះគឺជាពាក្យដែលយើងប្រើនៅពេលយើងនិយាយអំពីការរៀបចំខ្លួនៈ

**ការអនុវត្ត** គឺជាការរៀបចំផ្ទាល់ខ្លួនដែលអ្នកមាននៅក្នុងការសិក្សាអំពីផ្នែក និងតួនាទីរបស់អ្នក នៅក្នុងកម្មវិធីការថ្វាយបង្គំ។

**ការហាត់សម** គឺជាពេលសមរួមគ្នា ដែលមានការតភ្ជាប់វគ្គនីមួយៗនៃបទចម្រៀងចូលគ្នា និងតភ្ជាប់បទចម្រៀងនីមួយៗ ដើម្បីឲ្យការថ្វាយបង្គំមានភាពរលូន។

**ការត្រួតពិនិត្យសម្លេង** គឺជាពេលដែលយើងត្រូវធ្វើឲ្យប្រាកដថា ផ្នែកទាំងអស់នៃប្រព័ន្ធសម្លេងដំណើរការល្អ ក៏ដូចជាប្រព័ន្ធសម្លេងសម្រាប់ក្រុមថ្វាយបង្គំ និងប្រព័ន្ធ

**ការសមភ្លេងមួយចប់កម្មវិធី** គឺលើសពីការកំដៅសាច់ដុំ។ វាជាពេលដែលយើងរៀបចំខ្លួនខាងផ្លូវតន្ត្រី និងផ្លូវអារម្មណ៍ ដើម្បីដឹកនាំកម្មវិធីថ្វាយបង្គំតាមរយៈតន្ត្រី។ តរិយាបថ និងអាកប្បកិរិយារបស់យើងក្នុងអំឡុងពេលសមភ្លេងមួយចប់កម្មវិធីគួរតែដូចតរិយាបថ និងអាកប្បកិរិយារបស់យើងក្នុងពេលនៃកម្មវិធីថ្វាយបង្គំ។

**ពេលវេលាចាប់ផ្តើម** គឺមានន័យថា «ត្រៀមជាស្រេចដើម្បីលេងភ្លេង»។ ចូរមកដល់ព្រះវិហារមុនម៉ោង ដើម្បីត្រៀមខ្លួនលេងនៅម៉ោងចាប់ផ្តើមដែលបានកំណត់។

**ការរីកចម្រើនផ្ទាល់ខ្លួន** គឺជាការបន្តការប្តេជ្ញាចិត្តផ្ទាល់ខ្លួន ដើម្បីចម្រើនឡើងក្នុងនាមជាអ្នកភ្លេង ឬអ្នកបច្ចេកទេស។ ការនេះកើតឡើងតាមរយៈការអនុវត្តមេរៀន វគ្គបណ្តុះបណ្តាល និងវិធីផ្សេងទៀតដែលអ្នកបានលះបង់កម្លាំង និងពេលវេលា ដើម្បីឲ្យជំនាញរបស់អ្នកកាន់តែស៊ីជម្រៅ។

## ការរំពឹងទុកសម្រាប់ការអនុវត្តផ្ទាល់ខ្លួន

អ្នកត្រូវស្នើក្រុមរបស់អ្នក ឲ្យចាប់ផ្តើមរៀនបទចម្រៀងរបស់ពួកគេនៅដើមសប្តាហ៍ ដើម្បីទុកពេលរៀបចំខ្លួនគ្រប់គ្រាន់សម្រាប់ការហាត់សម។ ពួកគេគួរតែចំណាយពេលពិនិត្យមើលបទចម្រៀងឡើងវិញក្នុងរយៈពេល២៤ម៉ោង បន្ទាប់ពីការសមហើយពិនិត្យមើលឡើងវិញទៀតក្នុងរយៈពេល២៤ម៉ោងមុនកម្មវិធីថ្វាយបង្គំ។ ការនេះនឹងជួយឲ្យពួកគេចូលមកសម និងកម្មវិធីថ្វាយបង្គំ ដោយបទចម្រៀងដែលពួកគេទើបតែបានពិនិត្យឡើងវិញថ្មីៗ។

**តើការរៀបចំខ្លួនមានលក្ខណៈដូចម្តេច?** (ចូរប្រើតារាងនេះ ដើម្បីឲ្យមានការយល់កាន់តែប្រសើរក្នុងការរៀបចំក្នុងកំរិតផ្សេងគ្នា៖

<table>
<tr><th>១</th><th>២</th><th>៣</th><th>៤</th><th>៥</th></tr>
<tr><td colspan="2">ដឹងខ្លួនថា<br>មិនមានសមត្ថភាព</td><td colspan="2">ដឹងខ្លួនថា<br>មានសមត្ថភាព</td><td>មានសមត្ថភាព<br>ដោយមិនដឹងខ្លួន</td></tr>
<tr><td colspan="2">កំពុងរៀន</td><td colspan="2">កំពុងចេះ</td><td>ស្ទាត់ជំនាញ</td></tr>
</table>

**ការរៀបចំខ្លួនសម្រាប់ការហាត់សមៈ** ចូរត្រៀមបទចម្រៀងល្អបំផុតឲ្យដល់កម្រិតទីពមុននឹងចូលរួមការហាត់សម។ ប្រសិនបើអ្នកនៅរៀនមូលដ្ឋានគ្រឹះនៃបទចម្រៀងអំឡុងពេលសមនៅឡើយ នោះអ្នកមិនអាចជួយអ្វីច្រើនដល់ក្រុមទាំងមូលនោះទេ។ ការរៀបចំខ្លួនសម្រាប់ការហាត់សមគួរតែរាប់បញ្ចូលការយល់អំពីទម្រង់នៃបទចម្រៀង និងការអានកំណត់ចំណាំសម្រាប់ការហាត់សម ព្រមទាំងការស្ដាប់បទចម្រៀងច្រើនដង (តាមដែលចាំបាច់)។

**ការរៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំៈ** ចូររៀបចំបទចម្រៀងដល់កម្រិតទី៤ ឬ៥ នៅថ្ងៃកម្មវិធីថ្វាយបង្គំរួមគ្នា។ កាលណាអ្នកមានសេរីភាពកាន់តែច្រើនក្នុងការលេងភ្លេង និងច្រៀងចម្រៀងរបស់អ្នក ដោយមិនគិតពីបច្ចេកទេស នោះអ្នកនឹងមានសេរីភាពកាន់តែច្រើនក្នុងការថ្វាយបង្គំ និងការដឹកនាំអ្នកដទៃថ្វាយបង្គំព្រះ។

**ចូរគិតអំពីប្រភេទទាំងបីនៃការរៀបចំខ្លួន និងរបៀបដែលការរៀបចំខ្លួនមានឥទ្ធិពលមកលើសមត្ថភាពរបស់អ្នក ក្នុងការដឹកនាំការថ្វាយបង្គំ។ តើគោលការណ៍នៃការរៀបចំទាំងនេះ ហាក់ដូចជាមានការតម្រូវដែលសមហេតុផលដែរឬទេ?**

## ការរំពឹងទុកសម្រាប់ការហាត់សម

១. ការហាត់សមគឺជាកាតព្វកិច្ច។ ដោយសារតែការចូលរួមការហាត់សមមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីត្រៀមខ្លួនដឹកនាំកម្មវិធីថ្វាយបង្គំឲ្យបានល្អ ក្រុមជំនុំជាច្រើននឹងសម្រេចចិត្តនិយាយថា ប្រសិនបើអ្នកលេងភ្លេងមិនអាចចូលរួមការហាត់សមបានទេ នោះគាត់នឹងមិនអាចដឹកនាំការថ្វាយបង្គំនៅសប្ដាហ៍នោះទេ។ ទោះយ៉ាងណាក៏ដោយ ប្រហែលជាមានករណីដែលគេពិតជាត្រូវការអ្នកលេងភ្លេងយ៉ាងខ្លាំងនៅក្នុងក្រុមក្នុងសប្ដាហ៍នោះ ហើយគេត្រូវបំពេញតម្រូវការផ្សេងទៀត ដូចជាការជួបជាមួយអ្នកដឹកនាំការថ្វាយបង្គំនៅពេលផ្សេងទៀត ដើម្បីមើលឲ្យគ្រប់ជ្រុងជ្រោយ ហើយដើម្បីឲ្យអ្នកលេងភ្លេងបានត្រៀមខ្លួនឲ្យរួចរាល់។ សមាជិកក្រុមពិតជាចាំបាច់ត្រូវមើលឃើញថាការសមគឺជាផ្នែកចាំបាច់នៃការរៀបចំខ្លួន។

២. ចូរត្រៀមខ្លួនជាស្រេចសម្រាប់ពេលចាប់ផ្តើម។ សមាជិកក្រុមត្រូវត្រៀមខ្លួនជាស្រេចសម្រាប់ការហាត់សមតាមពេលវេលាកំណត់ថានឹងចាប់ផ្តើមសមនៅពេលណា។ ការនេះតម្រូវឲ្យចូលមកមុនម៉ោងចាប់ផ្តើមដើម្បីដំឡើងឧបករណ៍ត្រៀមក្រដាសចំរៀង។ល។

៣. ត្រូវជូនដំណឹងដល់អ្នកដឹកនាំការថ្វាយបង្គំជាមុន អំពីការប្តេជ្ញាចិត្តចំពោះពេលវេលាត្រួតលើគ្នា។ សមាជិកក្រុមគួរតែពិភាក្សាជាមួយអ្នកដឹកនាំការថ្វាយបង្គំមុនពេលហាត់សម ប្រសិនបើចាំបាច់ត្រូវមកដល់យឺត ឬចាកចេញមុនម៉ោងដោយសារហេតុផលណាមួយ។

ការរំពឹងទុកទាំងនេះហាក់ដូចជាមានភាពតឹងរ៉ឹង ប៉ុន្តែ នៅពេលដែលក្រុមរបស់អ្នកយល់ពីហេតុផលទាំងនេះ ថាហេតុអ្វីបានជាយើងត្រូវការស្តង់ដារទាំងនេះដើម្បីជួយយើងឲ្យរៀបចំខ្លួនឲ្យបានច្រើនបំផុតហើយមានសេរីភាពបំផុតក្នុងការដឹកនាំការថ្វាយបង្គំឲ្យបានល្អប្រសើរ។.

## ការប្តេជ្ញាចំពោះការរៀបចំ

នេះគឺជាឧទាហរណ៍មួយនៃគោលការណ៍សម្រាប់ការរៀបចំ។ អ្នកនឹងត្រូវធ្វើការជាមួយក្រុមរបស់អ្នក ដើម្បីបង្កើតគោលការណ៍មួយសម្រាប់ក្រុមជំនុំរបស់អ្នក។

ក្នុងនាមជាផ្នែកមួយនៃក្រុមថ្វាយបង្គំអ្នកនឹងធ្វើការប្តេជ្ញាចិត្តដូចខាងក្រោម៖

### កាលវិភាគប្រចាំសប្តាហ៍របស់អ្នក

- ចូរប្តេជ្ញានឹងស្តាប់ និងរៀនបទចម្រៀងយ៉ាងហោចណាស់២៤ម៉ោង មុនពេលការសម។ ចូលរួម និងរួមចំណែកពេញលេញក្នុងការហាត់សម និងត្រួតពិនិត្យសំឡេង ហើយសមភ្លេងមួយចប់កម្មវិធី។
- ចូរមកដល់មុនម៉ោង ល្មមនឹងអាចលេងភ្លេងទាន់ម៉ោងដែលបានកំណត់។
- ចូរបោះពុម្ពក្រដាសភ្លេងមុនពេល តំឡើងរាដាក់ឧបករណ៍ថេប្លេត (Tablet) ឬមកដល់មុនម៉ោង ដើម្បីទទួលបានក្រដាសភ្លេង(តាមជាក់ស្តែង)។
- ចូរគូសចំណាំពីលើតារាងរបស់អ្នកត្រង់ចំណុចដែលត្រូវផ្លាស់ប្តូរកន្លែងពិបាកៗ តំបន់ដែលមានបញ្ហា។ល។
- បន្ទាប់ពីសមហើយ សូមតាំងចិត្តហាត់បទចម្រៀងទាំងអស់ក្នុងរយៈពេល ២៤ម៉ោង មុនកម្មវិធីការថ្វាយបង្គំ។

- ចូរមកដល់ដោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីបញ្ចប់ការរៀបចំណាមួយ មុនពេលការពិនិត្យសំឡេងថ្វាយបង្គំ និងការសមភ្លេងមួយចប់កម្មវិធី។

### ប្រចាំខែ

ចូរកំណត់ពេលវេលាជាទៀងរាល់ខែសម្រាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន (កំណត់គោលដៅ)។ នេះគឺជាការណែនាំមួយចំនួនៈ

- ចូរអានអត្ថបទស្តីពីឧបករណ៍ភ្លេងរបស់អ្នក។
- ចូរមើលវីដេអូបណ្តុះបណ្តាល។
- ចូរជួបជាមួយអ្នកលេងភ្លេង/អ្នកចម្រៀងដែលមានបទពិសោធន៍ច្រើនជាង ដើម្បីទទួលឱវាទ។
- ចូរចំណាយពេលវេលាទៅរៀន ឬចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗ ដើម្បីរៀនជំនាញជាក់លាក់ណាមួយ។

### ប្រចាំឆ្នាំ

- ចូរប្តេជ្ញាចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលដើម្បីអភិវឌ្ឍន៍ជំនាញយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។

## ការទទួលខុសត្រូវ

ការប្តេជ្ញាចិត្តចំពោះការងារផ្នែកថ្វាយបង្គំនេះមានន័យថាជាការតាំងចិត្តចំពោះការរំពឹងទុកសម្រាប់ការរៀបចំខ្លួន។ការរំពឹងទុកទាំងនេះ គឺមានសម្រាប់សមាជិកក្រុម និងអ្នកដឹកនាំដូចគ្នា។ ក្នុងនាមជាក្រុមយើងជួយគ្នាទៅវិញទៅមកឲ្យទទួលខុសត្រូវចំពោះស្តង់ដារទាំងនេះ។ ប៉ុន្តែ យើងធ្វើដូច្នេះដោយព្រះគុណ និងដើម្បីប្រយោជន៍អ្នកដទៃ ខណៈពេលដែលយើងមិនត្រូវខ្មាសអៀន ចំពោះការសន្ទនាសំខាន់ៗ ដែលយើងត្រូវនិយាយការពិតនោះឡើយ។

ឯកសារបែបនេះជួយឲ្យយើងធ្វើដំណើរឆ្ពោះទៅរកស្តង់ដារទូទៅមួយ និងលើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យធ្វើការឆ្ពោះទៅរកស្តង់ដារនេះដែរ។

**ចូរចាប់ផ្ដើមរៀបចំផែនការឥឡូវនេះ ដើម្បីកំណត់ថា អ្នកណានឹងជួយអ្នកបង្កើតឯកសារប្រភេទនេះសម្រាប់ការងារផ្នែកថ្វាយបង្គំនៅឯព្រះវិហាររបស់អ្នក។ តើនឹងរួមបញ្ចូលអ្វីខ្លះ? តើអ្នកនឹងចែកចាយអំពីស្តង់ដានេះទៅកាន់ក្រុមរបស់អ្នកដូចម្តេចខ្លះ? តើអ្នកនឹងឲ្យពួកគេត្រូវទទួលខុសត្រូវយ៉ាងណា?**

សូមចាំថានៅពេលអ្នកចាប់ផ្ដើមអនុវត្តតាមស្តង់ដារនេះ អ្នកចាំបាច់ត្រូវប្រាប់ក្រុមរបស់អ្នកអំពីមូលហេតុដែលយើងត្រូវធ្វើតាមស្តង់ដារនេះ។ បើគ្មានការរៀបចំបានល្អទេ យើងនឹងមិនងាយទទួលបានសេរីភាពដែលយើងត្រូវការ ដើម្បីជួយក្រុមជំនុំក្នុងដំណើរនៃការថ្វាយបង្គំឡើយ។ យើងត្រូវដកការរំខានដែលអាចរារាំងពេលវេលានៃការថ្វាយបង្គំ។ ការមិនត្រៀមខ្លួនគឺជាការរំខានដ៏អាក្រក់បំផុត។ ពេលណាយើងជួយគ្នាទៅវិញទៅមកឲ្យមានការទទួលខុសត្រូវចំពោះស្តង់ដារខ្ពស់ នៅពេលយើងរស់នៅតាមការត្រាស់ហៅរបស់យើង ព្រះទ្រង់អាចប្រើប្រាស់យើងកាន់តែប្រសើរឡើង ដើម្បីដឹកនាំរាស្ត្រទ្រង់ក្នុងការថ្វាយបង្គំ។

# III. ការរៀបចំផែនការនៃការថ្វាយបង្គំ

ដោយបានបង្កើតមូលដ្ឋានគ្រឹះនៃការថ្វាយបង្គំ និងភាពជាអ្នកដឹកនាំការថ្វាយបង្គំ ឥឡូវនេះយើងត្រៀមខ្លួនរួចជាស្រេចដើម្បីកសាងគំនិតទាំងនោះ។ នៅក្នុងជំពូកនេះ យើងនឹងពិចារណាអំពីរបៀបរៀបចំផែនការកម្មវិធីថ្វាយបង្គំរួមគ្នាជាមួយរាស្ត្ររបស់ព្រះក្នុងការថ្វាយបង្គំដែលបំផ្លាស់បំប្រែ។ ដំណើរការរៀបចំផែនការមានសារៈសំខាន់ណាស់ ចំពោះជីវិតថ្វាយបង្គំក្នុងក្រុមជំនុំ។ នៅពេលយើងរៀបចំផែនការនៃការថ្វាយបង្គំ យើងស្វែងរកផែនការរបស់ព្រះ ហើយយើងប្រើប្រាស់ឧបករណ៍ដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីសម្រេចបាននូវដំណើរនៃការថ្វាយបង្គំក្នុងក្រុមជំនុំ។

## ទម្រង់នៃការថ្វាយបង្គំ

មានសារៈសំខាន់ណាស់សម្រាប់អ្នករៀបចំផែនការថ្វាយបង្គំ ដែលត្រូវមានចំណេះដឹងខ្លះអំពីទម្រង់ទាំងនេះ ដើម្បីផ្តល់វិធីសាស្ត្រ និងធនធានបន្ថែមសម្រាប់រៀបចំផែនការការថ្វាយបង្គំសម្រាប់ក្រុមជំនុំក្នុងតំបន់។

## ការថ្វាយបង្គំមានបួនទម្រង់៖

តាមលំដាប់ពិធីថ្វាយបង្គំ

កម្មវិធីថ្វាយបង្គំបែបពិធីបុណ្យសាសនា ត្រូវបានរៀបចំស្របតាមកាលវិភាគឆ្នាំនៃក្រុមជំនុំ ហើយជាធម្មតាធ្វើតាមទម្រង់ប្រចាំសប្តាហ៍ដែលអាចព្យាករណ៍បាន ឬពិធីបុណ្យសាសនា (មានន័យថា ការងាររបស់ប្រជាជាតិ)។ កម្មវិធីមានរចនាសម្ព័ន្ធជារបៀបច្បាស់លាស់។ ជាទូទៅ មានអ្នកចូលរួមជាច្រើនក្នុងក្រុមជំនុំដោយ

ការច្រៀង ការអានសេចក្ដីអធិស្ឋានព្រះអម្ចាស់ គោលលទ្ធិជំនឿ ពិធីលៀងព្រះអម្ចាស់ និងសកម្មភាពជាច្រើនទៀត។ កម្មវិធីបែបនេះត្រូវបានរៀបចំនៅជុំវិញអត្ថបទព្រះគម្ពីរដែលកំណត់ដោយសៀវភៅ ដែលជាសៀវភៅដែលរាយបញ្ជីបណ្ដុំនៃការអានព្រះគម្ពីរ ដែលត្រូវបានចាត់តាំងសម្រាប់ថ្ងៃអាទិត្យជាក់លាក់នៃឆ្នាំរបស់ក្រុមជំនុំ។ វារួមបញ្ចូលការអានគម្ពីរសញ្ញាចាស់ ទំនុកតម្កើង ការអានគម្ពីរសញ្ញាថ្មី និងការអានដំណឹងល្អ សម្រាប់សប្ដាហ៍នីមួយៗ។

សំខាន់សម្រាប់កម្មវិធីថ្វាយបង្គំបែបប្រកបពិធីបុណ្យសាសនា គឺជាប្រតិទិននៃគ្រីស្ទបរិស័ទដែលជារង្វង់នៃរដូវកាល និងថ្ងៃបរិសុទ្ធដែលរំលឹកពីព្រះជន្ម ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ។ សៀវភៅត្រូវបានរៀបចំឡើងសម្រាប់ប្រើប្រាស់ពេញមួយឆ្នាំ និងថ្ងៃបរិសុទ្ធក្នុងប្រតិទិននៃគ្រីស្ទបរិស័ទ។ ការអានមកជាបីជុំដែលគ្របដណ្ដប់រយៈពេលបីឆ្នាំ។ ក្នុងវគ្គនៃមេរៀនទាំងអស់សក្ខីភាពទាំងមូលនៃព្រះគម្ពីរ នឹងបង្ហាញដល់ក្រុមជំនុំ។ មានលើកមកជាចេតនាដ៏ល្អប្រសើរ និងផែនការនៃការបង្កើតសិស្សដោយប្រើប្រាស់ប្រតិទិនឆ្នាំនៃក្រុមជំនុំ និងមេរៀនក្នុងការថ្វាយបង្គំ។ វាជួយមនុស្សឲ្យចូលរួមក្នុងព្រះរាជសារនៃដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ហើយបង្ហាញពួកគេទៅកាន់ការយល់នៃព្រះបន្ទូលរបស់ព្រះ ។ ក្រុមជំនុំមិនចំណាយពេលច្រើនក្នុងការអានព្រះបន្ទូលដ៏មានអានុភាពនៃព្រះនៅក្នុងកម្មវិធីថ្វាយបង្គំរបស់ពួកគេ។ ត្រូវបានធ្វើប្រាំមួយសប្ដាហ៍មុនបុណ្យព្រះអង្គមានព្រះជន្មរស់មកដល់ យើងជ្រើសរើសបទគម្ពីរ រហូតទាល់តែក្រុមជំនុំបានឮតែផ្នែកណាមួយនៃព្រះបន្ទូលរបស់ព្រះជារៀងរាល់ឆ្នាំ។ ជាញឹកញាប់ក្រុមជំនុំរបស់យើងផ្ដោតលើថ្ងៃបុណ្យ ជាជាងប្រារព្ធថ្ងៃបរិសុទ្ធក្នុងប្រតិទិននៃគ្រីស្ទបរិស័ទ។ បញ្ហាទាំងនេះត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងប្រពៃណីកម្មវិធីថ្វាយបង្គំបែបពិធីបុណ្យ។

ខ្ញុំសូមបង្ហាញពីរបៀបដែលមានទំនាក់ទំនងជាមួយនឹងឆ្នាំគ្រីស្ទបរិស័ទ ក្នុងការថ្វាយបង្គំ អាចជាអត្ថប្រយោជន៍ដល់ក្រុមជំនុំរបស់អ្នក៖

ខ្ញុំបានធំឡើងដោយគិតថា ថ្ងៃសំខាន់ៗចំនួនបួនក្នុងឆ្នាំនៃក្រុមជំនុំគឺ បុណ្យណូអែល បុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ទិវាគុណម្ដាយ និងទិវាគុណឪពុក។ ទាំងនោះពិតជាថ្ងៃដែលហាក់ដូចជាទទួលបាននូវភាពរំភើប និងពិសេសបំផុតនៅក្នុងឫសគល់ប្រពៃណីបាទីស្ទរបស់ខ្ញុំ។ តាំងពីកុមារភាពមក ខ្ញុំបានប៉ះពាល់ និងសិក្សាពីទំនៀមទំលាប់នៃការថ្វាយបង្គំផ្សេងៗជាច្រើន ហើយបានរកឃើញថា ជារឿយៗ យើងខ្វះបទពិសោធន៍ដ៏អស្ចារ្យដែលយើងអាចមានក្នុងការ

ថ្វាយបង្គំ ដោយសារយើងបានលុបបំបាត់ចោលនូវប្រតិទិនប្រពៃណីរបស់ក្រុមជំនុំជាច្រើន។

តាមរយៈការនេះ ខ្ញុំចង់និយាយថា ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីឃ្លាតឆ្ងាយចេញពីប្រពៃណីមួយចំនួនរបស់គ្រីស្ទបរិស័ទ យើងបែរជាបានប្រតិកម្មហួសហេតុ និងដកចេញនូវប្រពៃណីដ៏មានតម្លៃមួយចំនួនដែលអាចបម្រើយើងបានយ៉ាងល្អនាពេលបច្ចុប្បន្ននេះ។

សូមក្រឡេកមើលរយៈពេលមួយឆ្នាំក្នុងប្រតិទិនគ្រីស្ទបរិស័ទ—រដូវកាលនៃការជញ្ជឹងគិត។ ៤០ថ្ងៃមុនថ្ងៃបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ជាការចាប់ផ្តើមក្នុងរដូវកាលនៃការតមអាហារ និងការប្រែចិត្ត។ រយៈពេល៤០ថ្ងៃនៃការតមអាហារ និងការប្រែចិត្ត (Lenten) គឺមានរៀបចំយ៉ាងលំអិតអធិស្ឋាន និងការរៀបចំដើម្បីប្រារព្ធពិធីបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ (Easter)។ ចាប់តាំងពីថ្ងៃអាទិត្យនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវ ប្រាំមួយអាទិត្យដែលកើតឡើងក្នុងអំឡុងពេលការជញ្ជឹងគិត មិនត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃ៤០ថ្ងៃនៃការជញ្ជឹងគិតទេ ហើយត្រូវបានគេហៅថាថ្ងៃអាទិត្យនៅក្នុងការជញ្ជឹងគិត។ ៤០ថ្ងៃនៃការជញ្ជឹងគិត ត្រូវបានភ្ជាប់ជាមួយនឹងព្រឹត្តិការណ៍ព្រះគម្ពីរជាច្រើន ប៉ុន្តែ ជាពិសេសជាមួយនឹងរយៈពេលសែសិបថ្ងៃ ដែលព្រះយេស៊ូវបានចំណាយពេលនៅក្នុងទីរហោស្ថាន រៀបចំសម្រាប់ព័ន្ធកិច្ចបម្រើរបស់ទ្រង់ដោយប្រឈមមុខនឹងការល្បួងដែលអាចនាំទ្រង់ឲ្យបោះបង់ចោលបេសកកម្ម និងការត្រាស់ហៅរបស់ទ្រង់។

រដូវនៃការតមអាហារ និងការប្រែចិត្ត បញ្ចប់ជាមួយនឹងសប្តាហ៍បរិសុទ្ធដោយចាប់ផ្តើមថ្ងៃអាទិត្យមុនបុណ្យព្រះយេស៊ូវរស់ពីសុគតឡើងវិញ និងរហូតដល់ថ្ងៃអាទិត្យបុណ្យព្រះយេស៊ូវរស់ពីសុគតឡើងវិញ។ ថ្ងៃអាទិត្យមុនបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ គឺជាថ្ងៃអាទិត្យបុណ្យស្លឹកចាក (Palm Sunday) ឬ ថ្ងៃអាទិត្យបរិសុទ្ធ (Passion Sunday) ហើយជាទូទៅប្រារព្ធការចូលក្រុងយេរូសាឡិមជ័យជំនះរបស់ព្រះយេស៊ូវ។ ថ្ងៃព្រហស្បតិ៍បរិសុទ្ធគឺ (Maundy Thursday ឬ Holy Thursday) ហើយជាចងចាំនៃថ្ងៃពិធីជប់លៀងព្រះអម្ចាស់ចុងក្រោយ។ ថ្ងៃសុក្រដ៏ល្អ គឺជាថ្ងៃដែលយើងរំឭកដល់ការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង។ ទីបំផុត ថ្ងៃអាទិត្យ បុណ្យព្រះយេស៊ូវរស់ពីសុគត គឺជាថ្ងៃដ៏អស្ចារ្យសម្រាប់ការប្រារព្ធពិធីបុណ្យមានព្រះជន្មរស់ឡើងវិញ។

រដូវកាលនៃការតមអាហារ និងការប្រែចិត្តគេអាចសម្គាល់ដោយការអធិស្ឋានការតមអាហារ និងការចែកទានដល់អ្នកដទៃ។ គ្រីស្ទបរិស័ទសព្វថ្ងៃនេះ នៅតែប្រើ

រដូវកាលនៃការអធិស្ឋានតមសម្រាប់ការជញ្ជឹងគិត ពិនិត្យខ្លួនឯង និងការប្រែចិត្ត។

ព្រះវិហារខ្លះនៅតែអនុវត្តការអធិស្ឋានតមបានកំណត់យ៉ាងជាក់លាក់ ជាពិសេសការលះបង់សាច់ បង្អែម និងអាហារប្រភេទផ្សេងៗទៀត។ ជារឿយៗ ខ្ញុំលះបង់អ្វីមួយក្នុងអំឡុងពេលអធិស្ឋានតម។ ឧទាហរណ៍ ខ្ញុំបានបោះបង់ចោលភេសជ្ជៈ និងទឹកតែរស់ជាតិផ្អែម (ជាកន្លែងដែលនៅភាគខាងត្បូងសហរដ្ឋអាមេរិកចូលចិត្ត) ដោយផឹកតែទឹកប៉ុណ្ណោះ (ខ្ញុំពិបាកចិត្តដោយសារគ្មានទឹកតែផ្អែមរបស់ខ្ញុំ!) ខ្ញុំបានរកឃើញថា រាល់ពេលដែលខ្ញុំឃ្លានទឹកតែផ្អែម ឬភេសជ្ជៈ ខ្ញុំគិតអំពីមូលហេតុដែលខ្ញុំបោះបង់ភេសជ្ជៈនេះ ហើយផ្តោតលើការរងទុក្ខ និងការសុគតរបស់ព្រះយេស៊ូវ។ វាពិតជាមិនគួរឲ្យជឿទេដែលវាជួយខ្ញុំឲ្យផ្តោតអារម្មណ៍ និងរៀបចំសម្រាប់បុណ្យព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ។ របៀបថ្វាយបង្គំផ្សេងទៀតមិនផ្តោតលើការអធិស្ឋានតមច្រើនទេ ប៉ុន្តែផ្តោតលើសកម្មភាពសប្បុរសធម៌ជាពិសេសការជួយអ្នកដែលត្រូវការអាហារ និងសំលៀកបំពាក់ ឬគ្រាន់តែផ្តល់ប្រាក់ជាអំពើសប្បុរសធម៌។ ពួកជំនុំគ្រីស្ទបរិស័ទភាគច្រើនដែលបានធ្វើកម្មវិធីអធិស្ឋានតម ផ្តោតសំខាន់លើវាជាពេលវេលានៃការអធិស្ឋាន ជាពិសេសការសោយទិវង្គត ការប្រែចិត្តចំពោះការបរាជ័យ និងអំពើបាបជាវិធីសាស្ត្រមួយដើម្បីឲ្យយើងផ្តោតលើតម្រូវការព្រះគុណរបស់ព្រះ។ នេះគឺជាការរៀបចំខ្លួនដើម្បីអបអរការប្រោសលោះដ៏អស្ចារ្យរបស់ព្រះនៅបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ និងការរស់ឡើងវិញដែលយើងកំពុងរស់នៅ ហើយនឹងមានក្តីសង្ឃឹមក្នុងនាមជាគ្រីស្ទបរិស័ទ។

តាមគំនិតរបស់ខ្ញុំ លុះត្រាណាតែយើងពិតជាមានបទពិសោធន៍អំពីរដូវនៃការតមអាហារ និងការប្រែចិត្តជាមុនសិន ពុំនោះទេបុណ្យព្រះអង្គមានព្រះជន្មរស់ពីសុគតឡើងវិញ នឹងមិនបានចាត់ទុកថាជាការប្រារព្ធពិធីដ៏ធំនោះទេ។ ទោះយ៉ាងណាក៏ដោយគំនិតនេះអាចហាក់ដូចជាចម្លែកសម្រាប់មនុស្សជាច្រើនដែលមិនធ្លាប់បានបង្ហាញពីប្រតិទិនប្រចាំឆ្នាំនៃគ្រីស្ទបរិស័ទ "ពិតប្រាកដ" ដើម្បីបង្ហាញបន្ថែមទៀតអំពីរបៀបដែលយើងអាចទាញយកប្រយោជន៍ពីប្រពៃណីនេះសម្រាប់ជាប្រយោជន៍ដល់ក្រុមជំនុំរបស់យើង នេះជាវិធីមួយចំនួនដែលអ្នកអាចជួយក្រុមជំនុំរបស់អ្នកក្នុងការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេ និងពេលវេលានៃការថ្វាយបង្គំក្នុងក្រុមជំនុំក្នុងរដូវកាលនៃការតមអាហារ និងការប្រែចិត្ត៖

- រៀបចំការជញ្ជឹងគិតរយៈពេល៤០ថ្ងៃ (ឬ ៤៦ថ្ងៃ) ក្នុងរដូវកាលនៃការតម

អាហារ និងការប្រែចិត្ត ឬសូម្បីតែសប្ដាហ៍បរិសុទ្ធ (៨ថ្ងៃ) សម្រាប់ក្រុមជំនុំទាំងមូលដើម្បីចូលរួមចំណែក។

- លើកទឹកចិត្តក្រុមជំនុំរបស់អ្នក ឲ្យធ្វើគម្រោងការអានព្រះគម្ពីរប្រចាំថ្ងៃសម្រាប់ក្នុងរដូវកាលនៃការតមអាហារ និងការប្រែចិត្ត។
- រៀបចំផែនការកម្មវិធីថ្វាយបង្គំនៅថ្ងៃចាប់ផ្ដើមមុនពិធីបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញឈានមកដល់ (Ash Wednesday) ។
- អ្នកអាចចាត់តាំងសមាជិកផ្សេងៗឲ្យសរសេរចុះនូវការជញ្ជឹងគិតផ្ទាល់ខ្លួនក្នុងរដូវកាលនៃការតមអាហារ និងការប្រែចិត្តនៅក្នុងព្រឹត្តិបត្រប្រចាំសប្ដាហ៍ ឬព្រឹត្តិបត្រផ្ទាល់ខ្លួនដើម្បីឲ្យពួកគេមានចិត្តចូលរួមសម្រាប់ព្រះវិហាររបស់អ្នក។
- រៀបចំផែនការថ្វាយបង្គំរាល់ថ្ងៃអាទិត្យទាំងអស់ ដើម្បីផ្ដោតលើការរៀបចំចិត្តគំនិតរបស់អ្នកសម្រាប់មុនពេលពិធីបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញឈានមកដល់។ ប្រហែលជាជ្រើសរើសបទចម្រៀងដែលនឹងត្រូវភ្ជាប់តាមពេលវេលានោះជាមួយគ្នាជារៀងរាល់សប្ដាហ៍។
- រៀបចំផែនការកម្មវិធីថ្វាយបង្គំពិសេសប្រចាំសប្ដាហ៍៖ ថ្ងៃព្រហស្បតិ៍នៃសប្ដាហ៍ដ៏បរិសុទ្ធ ហើយនឹងថ្ងៃសុក្រដ៏ល្អ (Palm Sunday, Maundy Thursday, និង Good Friday)។
- បន្ថែមការតុបតែងលម្អផ្សេងៗដោយសង្កត់ធ្ងន់លើការរៀបចំចិត្តគំនិតរបស់ពួកគេសម្រាប់ថ្ងៃបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ (Lenten) ក្នុងក្រុមជំនុំទាំងមូល។ បង្កើតសេចក្ដីប្រកាសសម្រាប់ក្រុមជំនុំរបស់អ្នក ហើយនិងទំនុកច្រៀងជាមួយ និងការរៀបចំចិត្តគំនិតស្អាតស្អំសម្រាប់ថ្ងៃបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ។
- ចែកដែកគោល ឬឈើឆ្កាងតូចៗដល់មនុស្សម្នាក់ៗដើម្បីទុកជាមួយពួកគេពេញមួយរដូវជាការរំឭកដល់រដូវកាលនោះ។
- លើកទឹកចិត្តដល់ក្រុមគ្រួសារឲ្យប្រារព្ធពិធីតមអាហារ និងការប្រែចិត្តនៅតាមផ្ទះ។ មានប្រភពជាច្រើនក្នុងអ៊ីនធឺណេតដើម្បីផ្ដល់គំនិតដល់អ្នក។

មានធនធានដ៏ល្អសម្រាប់ប្រើប្រាស់ដើម្បីធ្វើឲ្យថ្ងៃពិសេសទាំងនេះមានជីវិតរស់រវើកសម្រាប់អ្នកថ្វាយបង្គំ។ គំនិតពីមុនមានគោលបំណងជួយអ្នកអានឲ្យឃើញពីតម្លៃក្នុងទម្រង់ពិធីបុណ្យសាសនា និងប្រពៃណីដែលអមជាមួយវា។

## តាមប្រធានបទ៖

កម្មវិធីថ្វាយបង្គំតាមប្រធានបទត្រូវបានបង្កើតឡើងដោយគំនិតដែលថា គ្រប់ធាតុផ្សំទាំងអស់គួរតែគាំទ្រប្រធានបទសម្រាប់ថ្ងៃនោះ។ ជាធម្មតា ប្រធានបទនៃសេចក្តីអធិប្បាយ ធ្វើឲ្យមានការប្តេជ្ញាចិត្តតាម។ បន្ទាប់មកការអានបទគម្ពីរ ហើយចម្រៀងទាំងអស់នឹងទាក់ទង ទៅនឹងប្រធានបទនោះ។ ព្រះវិហារខ្លះអាចអនុវត្តបន្ថែមទៀតដោយមាន វីដេអូខ្លីៗ ក្រាហ្វិក និងអ្វីជាច្រើនទៀតទាក់ទងនឹងប្រធានបទនៃថ្ងៃនោះ។ ក្នុងនាមជាអ្នករៀបចំផែនការថ្វាយបង្គំតាមប្រធានបទ អ្នកនឹងទទួលបានប្រធានបទនៃសេចក្តីអធិប្បាយពីគ្រូគង្វាលរបស់អ្នក។ បន្ទាប់មកអ្នកនឹងជ្រើសរើសចម្រៀងពីបញ្ជីចម្រៀងក្នុងក្រុមជំនុំរបស់អ្នក ហើយប្រហែលជាបទចម្រៀងដែលពួកគេមិនចេះយកមកប្រើប្រាស់ក្នុងការថ្វាយបង្គំ។ ធាតុផ្សេងទៀតនៃការថ្វាយបង្គំទាំងអស់នឹងត្រូវបានជ្រើសរើសជាមួយនឹងប្រធានបទនៅក្នុងចិត្ត។

អត្ថប្រយោជន៍ធំមួយនៃទម្រង់ថ្វាយបង្គំប្រភេទនេះគឺថា នៅពេលអ្នកចូលរួមក្រុមជំនុំចាកចេញពីកម្មវិធីថ្វាយបង្គំទៅពួកគេគួរតែស្គាល់ច្បាស់ជាមួយប្រធានបទនៃថ្ងៃនោះ។ «គំនិតសំខាន់» សម្រាប់ថ្ងៃនោះ គួរតែត្រូវបានប្រាស្រ័យទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាព។

វាក៏មានចំណុចខ្សោយចំពោះទម្រង់នេះផងដែរ ដែលការស្វែងរកបទចម្រៀងគាំទ្រសម្រាប់ប្រធានបទមួយចំនួនដូចជា «ព្រះគុណ» ឬ «ឋានសួគ៌» ប្រហែលជាសាមញ្ញ ប៉ុន្តែប្រធានបទជាច្រើនស្ទើរតែមិនអាចស្វែងរកបទចម្រៀងដែលទាក់ទងនឹងប្រធានបទនោះទេ។ ម្យ៉ាងទៀត ការបង្រួញកម្មវិធីទាំងមូលទៅប្រធានបទតែមួយអាចបណ្តាលឲ្យអ្នកខកខានការថ្វាយបង្គំដ៏ទូលំទូលាយ ដែលយើងត្រូវបង្ហាញក្នុងការជួយមនុស្សឲ្យពិសោធន៍សិរីល្អនៃព្រះ ភាពទាបថោកនៃអំពើបាប និងព្រះគុណដែលទ្រង់ប្រទានមក។ យើងអាចនឹងលុបបំបាត់ការបញ្ចេញមតិផ្ទាល់ខ្លួនដែលពួកជំនុំត្រូវការនៅថ្ងៃអាទិត្យនោះ ពីព្រោះការជ្រើសរើសត្រូវបានកំណត់រួចហើយ។

ទាំងកម្មវិធីថ្វាយបង្គំតាមបែបពិធីបុណ្យ និងតាមប្រធានបទ សុទ្ធតែត្រូវបានបង្កើតឡើងដោយធាតុផ្សំដាច់ដោយឡែក ជាញឹកញាប់មិនមានលំហូរតក្កភាពទេ។ បទចម្រៀងមួយអាចត្រូវបានអមដោយការអធិស្ឋាន ចម្រៀងមួយទៀត សេចក្តីប្រកាសព័ត៌មាន សេចក្តីអធិប្បាយសម្រាប់កុមារ បទចម្រៀងមួយផ្សេងទៀត ចម្រៀងឧបករណ៍ភ្លេង ចម្រៀងបទបង្ហាញក្រុមចម្រៀង វីដេអូ ការអធិប្បាយបទចម្រៀងផ្សេងទៀត និងម៉ោងប្រកាសដំណឹងផ្សេងៗ។ នេះមិនមែនជារឿងចម្លែក

ដែលថា នៅក្នុងព្រះវិហារជាច្រើន មានទម្រង់ថ្វាយបង្គំតាមប្រធានបទ។ នេះគឺជាទម្រង់ទូទៅក្នុងបែបបទថ្វាយបង្គំប្រពៃណីផងដែរ។

ទម្រង់ទីបីមានបំណងដើម្បីលុបបំបាត់ធាតុផ្សំនៃការថ្វាយបង្គំដែលមិនជាប់គ្នា ហើយបង្កើតលំហូរកាន់តែច្រើន និងអារម្មណ៍អំពីដំណើរនៃការថ្វាយបង្គំ។

## លំហូរនៃការសរសើរតម្កើងដោយសេរី

នៅក្នុងកម្មវិធីថ្វាយបង្គំដែលមានទម្រង់នៃការសរសើរដោយសេរី តន្ត្រី និងការអធិប្បាយ អាចឯករាជ្យពីគ្នាទាំងស្រុង (មិនមានទំនាក់ទំនងតាមប្រធានបទ)។ នៅក្នុងទម្រង់នេះ អាចមានផ្នែកបន្តបន្ទាប់គ្នាច្រើននៃការច្រៀង—ឧទាហរណ៍ ផ្នែកនៃការច្រៀងដែលមិនមានការរំខានអាចមានរយៈពេល ១០-៥០នាទី។ ពេលវេលានៃការច្រៀងប្រកបដោយស្លេរភាព ទាមទារឲ្យមានផែនការ ជំនាញ និងការយល់ដឹងបន្ថែមទៀត ដើម្បីអនុវត្តវាឲ្យមានប្រសិទ្ធភាព ប៉ុន្តែពួកគេអាចមានអត្ថន័យយ៉ាងជ្រាលជ្រៅក្នុងការថ្វាយបង្គំ។

រចនាបថសហសម័យនៃការថ្វាយបង្គំសព្វថ្ងៃនេះ ធ្វើតាមទម្រង់នេះ។ នៅក្នុងកម្មវិធីជាច្រើន ធាតុផ្សំសំខាន់នៃកម្មវិធីថ្វាយបង្គំគឺជាផ្នែកនៃការច្រៀង អមដោយការអធិប្បាយ។ ប្រហែលជាមានការស្វាគមន៍ខ្លីៗ និងការប្រកាសដំណឹង ប៉ុន្តែជាញឹកញាប់គឺតិចតួចណាស់។ ប្រហែលជាលក្ខណៈសំខាន់បំផុតនៃទម្រង់នេះ គឺការសង្កត់ធ្ងន់លើលំហូរតតដាច់នៅក្នុងកម្មវិធី។

ខ្ញុំរកឃើញតម្លៃដ៏អស្ចារ្យនៅក្នុងទម្រង់នៃការថ្វាយបង្គំទាំងបី។ ខ្ញុំជឿថាការលាយបញ្ចូលគ្នានូវទម្រង់ទាំងបីនេះមានតម្លៃដ៏ល្អសម្រាប់ក្រុមជំនុំសព្វថ្ងៃនេះ។ នោះនាំទៅរកទម្រង់ទីបួននៃការថ្វាយបង្គំ។

## ការច្របាច់បញ្ចូលគ្នា

អ្នករៀបចំផែនការថ្វាយបង្គំដែលធ្វើតាមទម្រង់នៃការច្របាច់បញ្ចូលគ្នា នឹងទាញចេញពីបែបបទប្រពៃណីណាមួយ ឬទាំងអស់ក្នុងការបង្កើតជាកម្មវិធីថ្វាយបង្គំ។ ឧទាហរណ៍ យើងអាចបង្កើតកម្មវិធីថ្វាយបង្គំមួយ ចំពេលនៃបុណ្យថ្ងៃទី៥០ ដែលផ្តោតលើការយាងមកនៃព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃអាទិត្យមួយនោះ។ យើងអាចជ្រើសរើសចម្រៀងក្រុមជំនុំតែមួយ ឬបទបង្ហាញដែលសមនឹងប្រធានបទសម្រាប់សេចក្តីអធិប្បាយមួយសប្តាហ៍។ យើងអាចស្វែងរកគោលជំនឿសំខាន់មួយពីទំនៀមទំលាប់នៃពិធីបុណ្យបរិសុទ្ធនោះដែលមានឥទ្ធិពលនៅពេលអានជាមួយគ្នាជាក្រុមជំនុំ អំឡុងពេលប្រជុំគ្នាថ្វាយបង្គំ។ យើងបង្កើតលំហូរជំនួស

អារម្មណ៍មិនចុះសម្រុងក្នុងការថ្វាយបង្គំដោយការខ្វីពីទម្រង់លំហូរនៃការសរសើរតម្កើងដោយសេរី។ យើងអាចស្វែងរកគុណតម្លៃពិសេស និងផ្តល់នូវបទពិសោធន៍ថ្មីៗក្នុងការថ្វាយបង្គំដោយស្វែងរកបំណែកដ៏អស្ចារ្យៗនៅក្នុងទម្រង់នីមួយៗ។

**សូមមើលផែនការថ្វាយបង្គំនៅឯព្រះវិហាររបស់អ្នក។ តើវាមើលទៅដូចគ្នាពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ដោយគ្រាន់តែមានចំណងជើងបទចម្រៀង និងសេចក្តីអធិប្បាយខុសគ្នាទេ? តើតាមវិធីណាខ្លះដែលការផ្លាស់ប្តូរទៅជាបែបបទនៃការថ្វាយបង្គំដែលច្របាច់បញ្ចូលគ្នាមួយអាចផ្តល់ដង្ហើមជីវិតថ្មីទៅក្នុងកម្មវិធីថ្វាយបង្គំដែលអាចនឹងជាប់គាំងពីការធ្វើរឿងដដែលៗម្តងហើយម្តងទៀត?**

## បទចម្រៀងថ្វាយបង្គំ

បទចម្រៀងជាផ្នែកសំខាន់ក្នុងការជួយយើងបង្ហាញពីការថ្វាយបង្គំរបស់យើងចំពោះព្រះ។ ពួកគេជួយយើងបង្ហាញពីការថ្វាយបង្គំរបស់យើងចំពោះព្រះ។ ដរាបណាយើងចេះច្រៀងចម្រៀង យើងអាចថ្វាយបង្គំដោយមិនមានការរារាំងក្នុងការរៀនបទភ្លេង និងចង្វាក់ថ្មីៗ។ នៅពេលដែលយើងដាក់បទចម្រៀងថ្មីនៅក្នុងពេលវេលានៃការថ្វាយបង្គំរួមគ្នា យើងអាចរំខានដល់លំហូរនៃការថ្វាយបង្គំរបស់យើង។ នៅពេលដែលបទចម្រៀងថ្មីត្រូវបានណែនាំជាលើកដំបូង មនុស្សគ្រប់គ្នាត្រូវបានផ្តោតលើភារកិច្ចសិក្សាបទភ្លេងថ្មីនោះ ហើយពួកគេមិនបានផ្ចង់ចិត្តទៅកាន់ព្រះអម្ចាស់ឡើយ។ ជាមួយនឹងគំនិតនេះ ខ្ញុំជឿថា បទចម្រៀងថ្មីៗអាចសម្លាប់ការថ្វាយបង្គំរបស់យើង ប៉ុន្តែវាក៏អាចលើកកម្ពស់ការថ្វាយបង្គំរបស់យើងយ៉ាងខ្លាំងផងដែរ។ សូមពិនិត្យមើលរឿងនេះឲ្យកាន់តែស៊ីជម្រៅ។

### ហេតុអ្វីត្រូវរៀនបទចម្រៀងថ្មី?

បទគម្ពីរប្រាប់យើងឲ្យ «ច្រៀងបទថ្មីថ្វាយព្រះអម្ចាស់»។ នេះគឺជាឧទាហរណ៍ខ្លះៗ៖

- ចូរច្រៀងទំនុកថ្មីថ្វាយទ្រង់ ហើយលេងភ្លេងឲ្យពីរោះ ដោយប៉ិនប្រសប់។ ទំនុកតម្កើង ៣៣:៣
- ទ្រង់បានបណ្តាលឲ្យមានទំនុកថ្មីនៅក្នុងមាត់ខ្ញុំ។ ទំនុកតម្កើង ៤០:៣

- ចូរច្រៀងបទថ្មីថ្វាយព្រះយេហូវ៉ា។ ទំនុកតម្កើង ៩៦:១
- ឱព្រះអង្គអើយ ទូលបង្គំនឹងច្រៀងបទថ្មីថ្វាយទ្រង់។ ទំនុកតម្កើង ១៤៤:៩
- ចូរសរសើរដល់ព្រះយេហូវ៉ា ចូរច្រៀងបទ១ថ្មីថ្វាយព្រះយេហូវ៉ា។ ទំនុកតម្កើង ១៤៩:១

ការច្រៀងបទចម្រៀងថ្មី មិនមែនគ្រាន់តែដើម្បីភាពថ្មីថ្មោងនោះទេ។ បទចម្រៀងថ្មីៗមានប្រយោជន៍ ព្រោះវាធ្វើឲ្យយើងមិនដាច់ចង្វាក់ នាំឲ្យយើងមានអារម្មណ៍ស្រស់ស្រាយ និងភាពរីករាយ ជំរុញយើងឲ្យគិតអំពីអ្វីដែលយើងកំពុងច្រៀង ពង្រីកវាក្យសព្ទថ្វាយបង្គំរបស់យើង និងជួយយើងចាប់យកអ្វីដែលព្រះកំពុងមានបន្ទូលទៅកាន់រូបកាយពួកជំនុំនៅពេលវេលានោះ។ ជាទូទៅ បទចម្រៀងសម័យថ្មី នឹងភ្ជាប់ទៅវប្បធម៌សព្វថ្ងៃ ជាភាសាដែលពួកគេយល់បានប្រសើរជាងបទចម្រៀងជាច្រើនទសវត្សរ៍ ឬច្រើនសតវត្សរ៍កន្លងទៅហើយ។

បទចម្រៀងថ្មីមានសារៈសំខាន់ចំពោះការថ្វាយបង្គំរបស់ក្រុមជំនុំ។ ដូច្នេះយើងងាកមករកកន្លែងល្អបំផុតដើម្បីស្វែងរកបទចម្រៀងថ្មីៗ និងរបៀបកំណត់ថាតើបទចម្រៀងដែលមានសក្តានុពលទាំងនេះ ជាបទចម្រៀងល្អបំផុតសម្រាប់ក្រុមជំនុំរបស់អ្នកឬអត់។

**តើព្រះវិហាររបស់អ្នកបញ្ចូលបទចម្រៀងថ្មី ទៅក្នុងបញ្ជីនៃបទចម្រៀងដែលប្រើប្រាស់ក្នុងការថ្វាយបង្គំឬទេ?**

## ការស្វែងរកបទចម្រៀង

នៅពេលអ្នកចាប់ផ្តើមស្វែងរកបទចម្រៀងថ្មីៗល្អបំផុត ដើម្បីណែនាំដល់ក្រុមជំនុំរបស់អ្នក សូមចាំថា អត្តសញ្ញាណនៃការថ្វាយបង្គំនៃក្រុមជំនុំរបស់អ្នកមិនដូចក្រុមជំនុំផ្សេងទៀត ឬបទចម្រៀងដែលអ្នកមើលតាមអ៊ីនធឺណិតនោះទេ។ ត្រូវដឹងថា ក្រុមជំនុំរបស់អ្នកមានសារៈសំខាន់យ៉ាងពិសេសក្នុងការជ្រើសរើសបទចម្រៀងឲ្យបានត្រឹមត្រូវ។ ជំហានដំបូងក្នុងការស្វែងរកបទចម្រៀងដ៏ត្រឹមត្រូវសម្រាប់ការថ្វាយបង្គំគឺការស្វែងរកទៅតាមលទ្ធភាព។ អ្នកនាំចម្រៀងពិភាក្សាជាមួយអ្នកភ្លេងជាពិសេសគឺពិភាក្សាជាមួយចាស់ទុំក្នុងព្រះវិហាររបស់អ្នកអំពីបទចម្រៀងដែលត្រូវតាមគោលលទ្ធិនៃជំនឿគ្រីស្ទានពីព្រោះមិនមែនដើម្បីស្វែងរកបទចម្រៀង

ពីរោះៗនោះទេ នៅប្រទេសកម្ពុជាមានក្រុមជំនុំច្រើនតែមិនមែនទាំងអស់សុទ្ធតែឈរលើគោលលទ្ធិត្រឹមត្រូវនោះទេ។ ហើយអាចសួរទៅកាន់ព្រះវិហារដែលស្គាល់ច្បាស់តើពួកគេច្រៀងបទអ្វី? តើអ្នកបានឮអ្វីខ្លះនៅក្នុងការជួបជុំ ឬសន្និបាតនានា? តើបទចម្រៀងអ្វីខ្លះដែលអ្នកស្ដាប់តាមអ៊ីនធឺណិត? បន្ទាប់មក យើងនឹងពិនិត្យមើលតម្រងដើម្បីកំណត់ថាបទចម្រៀងដែលអ្នករកឃើញ វាត្រឹមត្រូវសម្រាប់ក្រុមជំនុំរបស់អ្នក។

## ការវាយតម្លៃបទចម្រៀង

សូមចងចាំផ្នែកស្ដីពីការបង្កើតសិស្ស ក្នុងកម្មវិធីថ្វាយបង្គំរួមគ្នា ដែលថាមនុស្សចងចាំបទចម្រៀងច្រើនជាងខគម្ពីរទៅទៀត។ ចម្រៀងដែលយើងប្រើបង្រៀនទេវវិជ្ជា ដូច្នេះយើងត្រូវគិតពិចារណាឲ្យបានច្បាស់លាស់សិន មុនពេលយើងណែនាំបទចម្រៀងនោះដល់ក្រុមជំនុំរបស់យើង។ ការវាយតម្លៃបទចម្រៀងគឺលើសពីការជ្រើសរើសយកបទចម្រៀងមួយ ដោយសារយើងចូលចិត្តសំឡេង ឬដោយសារតែវាពេញនិយម។ ដោយសារអ្នកផ្សេងប្រើបទចម្រៀងនេះ មិនមានន័យថាអាចទទួលយកបានសម្រាប់ក្រុមជំនុំរបស់អ្នកទេ។ ខ្ញុំបានកែសម្រួលឧបករណ៍វាយតម្លៃដ៏ល្អដោយលោក ស្កត់ គ្រីស្ទិនសិន (Scott Christensen) ដើម្បីជួយយើងក្នុងដំណើរការនេះ។ [១]

### ការវាយតម្លៃទំនុកច្រៀងនៃបទចម្រៀងនីមួយៗ

លក្ខណៈវិនិច្ឆ័យត្រឹមត្រូវ៖ ទំនុកច្រៀងគួរតែស្របទៅនឹងព្រះគម្ពីរ ឬដកស្រង់ចេញតាមខ្លឹមសារនៃព្រះគម្ពីរធ្វើជាទំនុកច្រៀងទាំងអស់ (យ៉ូហាន ១៧:១៧)

**តើទំនុកច្រៀងស្របតាមបទគម្ពីរ និងត្រឹមត្រូវតាមគោលលទ្ធិឬទេ?** តើអត្ថបទចម្រៀងមានលក្ខណៈពិសេស និងត្រឹមត្រូវដែលឆ្លុះបញ្ចាំង ឬគំនិតក្នុងគម្ពីរឬទេ? តើពួកគេមានបទគម្ពីរ និង/ឬគំនិតដែលបានបំផុសគំនិតតាមបទគម្ពីរទេ? តើទំនុកច្រៀងឆ្លុះបញ្ចាំងពីទេវសាស្ត្រត្រឹមត្រូវ និងការប្រតិបត្តិរបស់គ្រីស្ទានឬទេ? ចំណាំ៖ វាអាចមានមួយជួរនៅក្នុងបទចម្រៀង ដែលអាចដកសិទ្ធិបទចម្រៀងពីការប្រើប្រាស់ទាំងស្រុង។

**តើទំនុកច្រៀងមានន័យខាងវិញ្ញាណ និងផ្ដោតចំពោះព្រះឬទេ?** តើអត្ថបទចម្រៀងជំរុញឲ្យមានការឆ្លុះបញ្ចាំងក្នុងវិញ្ញាណផ្ទាល់ខ្លួន និងការជញ្ជឹងគិតអំពី

១ Adapted from Pastor Scott Christensen's document, How to Evaluate Songs for Congregational Worship. Summit Lake Community Church, Mancos, Colorado.

សេចក្ដីពិតទេ? តើបទទាំងនោះជំរុញឲ្យមានការសរសើរ ការអរព្រះគុណ ការរួមគំនិត និងអំណរដែលត្រូវបានដឹកនាំដោយព្រះឬទេ? តើបទចម្រៀងនេះធ្វើឲ្យមនុស្សម្នាក់រីករាយចំពោះព្រះរាជលក្ខណៈ និងការដែលព្រះធ្វើ ឬលើខ្លួនយើង និង/ឬតម្លៃអ្វីៗខាងលោកិយឬទេ? ការថ្វាយបង្គំត្រូវតែលើកតម្កើងសិរីរុងរឿងរបស់ព្រះ។

**តើទំនុកច្រៀងច្បាស់លាស់ ហើយអាចយល់បានឬទេ?** តើអត្ថបទចម្រៀងប្រាស្រ័យទាក់ទងព្រះរាជសារយ៉ាងច្បាស់លាស់ ក្នុងរបៀបដែលអាចយល់បានឬទេ? តើព្រះរាជសារត្រូវបានបិទបាំងដោយភាសាហួសសម័យ ឬភាសាដែលពេញនិយមខ្លាំងពេក ដែលនឹងហួសសម័យក្នុងពេលឆាប់ៗនេះ? តើមានគុណភាពជាប់រហូតចំពោះពាក្យដែលបានជ្រើសរើសប្រើប្រាស់ឬទេ?

**បន្ថែមពីលើនេះ តើពាក្យមានលក្ខណៈជាគ្រីស្ទានជាក់លាក់ឬទេ?** អត្ថបទចម្រៀងខ្លះមានភាពស្រពិចស្រពិល ដែលអាចច្រៀងអំពីព្រះនៃសាសនាណាមួយផងដែរ។

លើសពីនេះទៅទៀត ប្រសិនបើអ្នកមិនមែនជាគ្រូគង្វាលច្បងទេ ខ្ញុំនឹងស្នើឲ្យគ្រូគង្វាលរៀមច្បងយល់ព្រមលើបទចម្រៀងថ្មីណាមួយ ដើម្បីប្រាកដថាគាត់បញ្ជាក់ឲ្យប្រើប្រាស់បទចម្រៀងនោះ។

## ការវាយតម្លៃតន្ត្រីនៃបទចម្រៀងនីមួយៗ

លក្ខណៈវិនិច្ឆ័យជាប្រធានបទចំហ៖ ទំនុកភ្លេង — ដែលចំណង់ចំណូលចិត្តផ្ទាល់ខ្លួនត្រូវតែបាននាំមុខដោយគោលការណ៍តាមព្រះគម្ពីរ (ភីលីព ៤:៨)៖

**តើវាល្អទាំងស្រុងទេ?** តើរចនាបថតន្ត្រីឆ្លុះបញ្ចាំងគុណតម្លៃនៃពិភពលោក ឬអ្វីដែលអាចត្រូវបានសម្គាល់ដោយឡែកជាមួយនឹងស្តង់ដារប្រវត្តិសាស្ត្រនៃការពិតរបស់សិល្បៈ សេចក្ដីថ្លៃថ្នូរ និងភាពស្រស់ស្អាតដែរឬទេ?

**តើវាល្អប្រសើរ និងមានការច្នៃប្រឌិតឬទេ?** តើតន្ត្រីបំពេញតាមស្តង់ដារឧត្ដមភាពឬទេ? តើវាមានទម្រង់បទភ្លេងដែលមានទំនុកភ្លេង និងមានចង្វាក់ល្អដែរឬទេ? តើវាជាលក្ខណៈដើមហើយជាសិល្បៈ ជាជាងរូបមន្ត ឬជាការពិតដែរឬទេ? យើងថ្វាយសិរីល្អដល់ព្រះដ៏ខ្ពស់បំផុត ដោយថ្វាយដល់ទ្រង់នូវអ្វីដែលល្អបំផុតរបស់យើង។ ទោះជាយ៉ាងណា គោលដៅរបស់យើងមិនមែនជាភាពល្អឥតខ្ចោះទេ ប៉ុន្តែគឺជាការលើកតម្កើងព្រះកិត្តិនាមរបស់ព្រះ។ ម្យ៉ាងទៀត ការថ្វាយបង្គំមិនមែនគ្រាន់តែអនុលោមតាមស្តង់ដារខាងក្រៅមួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែចេញពី

ចិត្ត (ម៉ាកុស ៧:៦-៧)។

**តើវាគួរឲ្យចងចាំហើយអាចច្រៀងបានទេ?** បទចម្រៀងនេះមានបទចម្រៀងគួរឲ្យចងចាំឬទេ? តើតន្ត្រីជួយឲ្យគេចងចាំទំនុកច្រៀងដែលបង្កប់នូវការពិតក្នុងចិត្ត និងគំនិតដែរឬទេ?

**តើបទចម្រៀងនេះផ្តល់ឲ្យមនុស្សធម្មតារៀនចេះច្រៀងឬទេ?** តើវាមានសាច់ភ្លេង និងចង្វាក់ដែលសមហេតុផល ដែលស្រួលច្រៀងតាមក្រុមជំនុំ ឬអាចសម្រួលបានឬទេ? តើកម្រិតសំឡេងនៅក្នុងដែនកំណត់ដែលអាចទទួលយកបានសម្រាប់មនុស្សភាគច្រើនច្រៀងបានដែរឬទេ? (ខ្ញុំនឹងពិភាក្សាលម្អិតបន្តិចនៅពេលក្រោយ)។ ការច្រៀងជាក្រុមមិនត្រូវការជំនាញវិជ្ជាជីវៈទេ។

**តើវាអាចស្រុះស្រួលគ្នាទេ? តើតន្ត្រីសមគ្នានឹងអត្ថបទទេ?** តើទាំងពីរចូលរួមគ្នាបានល្អដូចជាការបង្ហាញសារ ឬអត្ថន័យនៃបទចម្រៀងសមស្របឬទេ? តើតន្ត្រីមានការលើកទឹកចិត្តក្នុងការថ្វាយបង្គំព្រះ ឬគ្រាន់តែជាការកំសាន្តសប្បាយតែប៉ុណ្ណោះ? តើតន្ត្រីរារាំង ឬលើកកម្ពស់សារនៃអត្ថបទចម្រៀងដែលផ្តល់ឲ្យនូវប្រភេទជាក់លាក់នៃការសង្កត់ធ្ងន់ (ឧ. អារម្មណ៍ — រីករាយ ឱឡារិក អស្ចារ្យ?)។ ល។

## ការវាយតម្លៃរូបរាងនៃបទចម្រៀងរបស់អ្នក (ក្នុងបញ្ជីបទចម្រៀងរបស់អ្នក)

បន្ថែមពីលើការមានបទចម្រៀងដែលមានទំនុកច្រៀងដ៏អស្ចារ្យ និងតន្ត្រីសមរម្យ យើងត្រូវប្រើប្រាស់បទចម្រៀងចម្រុះគ្នាសម្បូរបែបក្នុងការថ្វាយបង្គំ។ សូមក្រឡេកមើលបទចម្រៀងក្នុងបញ្ជីចម្រៀងរបស់អ្នក ហើយពិចារណាចំណុចទាំងនេះ៖

តើទំនុកច្រៀងនៃបទចម្រៀងប៉ះពាល់ដល់ចិត្ត និងគំនិតឬទេ (ឧទាហរណ៍ បទចម្រៀងដែលបំផុសឲ្យមានការស្រឡាញ់ត្រឹមត្រូវនៃដួងចិត្តក៏ដូចជាការឆ្លុះបញ្ចាំងឲ្យមានការត្រិះរិះពិចារណាទៅកាន់ព្រះ)? តើមានតុល្យភាពរវាងបទចម្រៀងដែលមានទម្ងន់ និងការបំផុសគំនិត (ឧទាហរណ៍ បទចម្រៀងដែលផ្តោតលើការពិតដ៏ជ្រាលជ្រៅ) ក៏ដូចជាបទចម្រៀងដែលសាមញ្ញ (ប៉ុន្តែមិនមែនជារឿងតូចតាច), សមាធិ, ច្រំដែល (ឧទាហរណ៍ ចំណាំ ទំនុកដំកើង ១៣៦) និងឆ្លើយតបតាមធម្មជាតិឬទេ?

តើទំនុកចម្រៀងត្រូវបានសម្គាល់ដោយភាពចម្រុះគ្នាឬទេ? តើបទចម្រៀងឆ្លុះបញ្ចាំងពីតុល្យភាពក្នុងការសង្កត់ធ្ងន់ទេ (អេភេសូរ ៥:១៩ និងកូល៉ុស ៣:១៦ —

ទំនុកតម្កើង ទំនុកបរិសុទ្ធ និងចម្រៀងខាងវិញ្ញាណ)? តើបទទាំងនោះឆ្លុះបញ្ចាំងបទចម្រៀងដែលនិយាយអំពីព្រះដោយផ្ទាល់ (សព្វនាមបុរិសៈបុរសទីមួយ និងទីពីរ) ក៏ដូចជាបទចម្រៀងដែលនិយាយអំពីព្រះ (សព្វនាមបុរសទីបី) ដែរឬទេ? តើពួកគេផ្ដោតលើព្រះរាជលក្ខណៈរបស់ព្រះក៏ដូចជាសកម្មភាពរបស់ទ្រង់ដែរឬទេ? តើពួកគេឆ្លុះបញ្ចាំងពីគោលលទ្ធិ និងទេវសាស្ត្រ (អ្វីដែលយើងជឿ) ក៏ដូចជាបទពិសោធន៍ និងការអនុវត្ត (អ្វីដែលយើងធ្វើ)? តើពួកគេសង្កត់ធ្ងន់លើការថ្វាយបង្គំរួម (ជាក្រុមជំនុំ) ក៏ដូចជា ផ្ទាល់ខ្លួនដែរឬទេ? តើពួកគេឆ្លុះបញ្ចាំងពីការឆ្លើយតបយ៉ាងទូលំទូលាយនៃការថ្វាយបង្គំ (ឧទាហរណ៍ ការសញ្ជឹងគិត ការដឹងគុណសេចក្ដីអំណរ ការសរសើរ សន្តិភាព ការប្រារព្ធពិធី ការឆ្លុះបញ្ចាំង ការលើកតម្កើង។ល។)? តើភាពខុសគ្នានៃបទចម្រៀងភាគច្រើនឧទ្ទិសថ្វាយព្រះជាប្រធានបទ (ជាជាងខ្លួនយើង) ឬទេ? ព្រះជាគោលដៅនៃការថ្វាយបង្គំរបស់យើង។

តើបទចម្រៀងមានតុល្យភាពទេ? តើតន្ត្រីឆ្លុះបញ្ចាំងពីតុល្យភាព និងរចនាបថផ្សេងៗគ្នា (អេភេសូរ ៥:១៩ និង កូល៉ុស ៣:១៦) ហើយឧបករណ៍ (ទំនុកដំកើង ១៥០) ដែលទាក់ទងទៅជួរដ៏ធំទូលាយនៃរសជាតិ និងសោភ័ណភាព (ឧទាហរណ៍ បទចាស់ និងបទថ្មីៗ) ខណៈពេលដែលរក្សាបាននូវសុខមាលភាពល្អ និងគុណតម្លៃដ៏អស្ចារ្យឬទេ? តើមានតុល្យភាពរវាងទំនុកតម្កើងជាប្រវត្តិសាស្ត្រ និងចម្រៀង ក៏ដូចជាវគ្គបន្ទរសហសម័យ និងរចនាបថតន្ត្រីដែរឬទេ? តើមានការកោតសរសើរ និងការប្រើប្រាស់នូវភាពសម្បូរបែបនៃការបង្ហាញសោភ័ណភាព និងសមត្ថភាពច្នៃប្រឌិតដែលព្រះបានប្រទានដល់យើងដែរឬទេ? ចំណង់ចំណូលចិត្តផ្ទាល់ខ្លួនមិនគួរត្រូវបានលើកឡើងគ្របដណ្ដប់លើស្ថានភាពនៃគោលការណ៍ព្រះគម្ពីរទេ ធ្វើដូច្នោះវានឹងលើកកម្ពស់ក្រឹត្យវិន័យនិយម។ ព្រះគម្ពីរគ្មានកន្លែងណាបញ្ជាបែបបទតន្ត្រីជាក់លាក់ទេ (ម៉ាកុស ៧:៨-៩, ១៣)។ អ្នកជឿគួរគោរព និងបន្ទាបខ្លួនទៅនឹងរសនិយម និងចំណង់ចំណូលចិត្តរបស់អ្នកដទៃ ហើយមិនស្វែងរកត្រឹមតែប្រយោជន៍របស់ខ្លួនទេ (ភីលីព ២:៣-៤)។

### ការជ្រើសរើសបទចម្រៀង

- លើកតម្កើងព្រះ យកព្រះគ្រីស្ទជាគោល និងពោរពេញដោយបទគម្ពីរ។
- មានអត្ថបទអំពីព្រះ មិនមែនគ្រាន់តែអំពីយើងប៉ុណ្ណោះឡើយ។
- អនុញ្ញាតឲ្យយើងច្រៀងថ្វាយទៅកាន់ព្រះ។ (ខ្សែបញ្ឈរ)
- អនុញ្ញាតឲ្យយើងលើកទឹកចិត្តដល់គ្នាទៅវិញទៅមក។ (ខ្សែផ្ដេក)

- *គ្រួសារក្រុមជំនុំរបស់អ្នកនឹងភ្ជាប់ទំនាក់ទំនង។*

## ការវាយតម្លៃតុងភ្លេង

តុងដែលសមរម្យដើម្បីច្រៀងរួមគ្នាជាលក្ខណៈក្រុមជំនុំក្នុងការជួបជុំគ្នា។ ការនាំយកបទចម្រៀងស្ថិតក្នុងតុងដែលខ្ពស់ពេកមានកម្រិតសម្លេងខ្ពស់ពេក សម្រាប់អ្នកមានសម្លេងធម្មតាគឺជា «កំហុសឆ្គង» ដ៏ធំបំផុតមួយរបស់អ្នកដឹកនាំចម្រៀងថ្វាយបង្គំ ហើយជាការបង្កើតឲ្យអ្នកទស្សនាក្នុងក្រុមជំនុំ ជាជាងអ្នកចូលរួមថ្វាយបង្គំ។ នេះជាបញ្ហាមួយភាគធំដែលមានឃើញក្នុងក្រុមជំនុំដែលគ្រាន់តែប្រើចម្រៀងថ្វាយបង្គំសម័យទំនើប។

ខ្ញុំបានចូលរួមព្រះវិហារមួយដែលមានក្រុមភ្លេង និងក្រុមអ្នកច្រៀងល្អអស្ចារ្យមិនគួរឲ្យជឿ។ មានគេប្រាប់ខ្ញុំថា ភ្លេងថ្វាយបង្គំនៅព្រះវិហារនោះវិសេសណាស់។ ហ្នឹងហើយមានការលេងភ្លេងយ៉ាងពីរោះល្អតតខ្មោះ ប៉ុន្តែខ្ញុំកត់សម្គាល់ឃើញថាស្ទើរតែគ្មាននរណាម្នាក់ច្រៀងតាមនៅក្នុងក្រុមជំនុំនោះទេ។ មូលហេតុចម្បងមួយគឺថា បទចម្រៀងត្រូវបានច្រៀងដោយតុងដែលខ្ពស់ពេកសម្រាប់មនុស្សភាគច្រើន។

អ្នកដឹកនាំការថ្វាយបង្គំជាច្រើនមានអារម្មណ៍ថា ការល្អបំផុតក្នុងការច្រៀងចម្រៀងគឺតាមតុងដើម (តុងហ្សីន) គឺដើម្បីស្តាប់ទៅដូចសម្លេងដើម គឺល្អបំផុត។ ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ ការត្រាស់ហៅរបស់យើងគឺមិនមែនឲ្យមានសំឡេងដូចការថតសំឡេងដើមឡើយ ផ្ទុយទៅវិញ គឺដើម្បីជួយពួកជំនុំរបស់យើងឲ្យបញ្ចេញសំឡេងថ្វាយបង្គំ និងការសរសើរព្រះ។ ពេលខ្លះនោះមានន័យថា ត្រូវលះបង់គំនិតរបស់យើង ដើម្បីសម្រួលឲ្យមានគោលគំនិតរបស់យើងក្នុងបរិយាកាសល្អប្រសើរសម្រាប់ការថ្វាយបង្គំ។

ការយល់ដឹងសំខាន់ៗ

ទំនួលខុសត្រូវរបស់យើងគឺដើម្បីជួយឲ្យក្រុមជំនុំអាចច្រៀងសរសើរតម្កើងព្រះទាំងអស់គ្នា មិនមែនដើម្បីបង្ហាញ ឬបង្អួតសំឡេងលើឆាកដ៏អស្ចារ្យរបស់យើងឡើយ ហើយជាមួយការយកបទចម្រៀងតាមកម្រិតតារារបស់យើងទេ។

ដើម្បីឲ្យមនុស្សម្នាច្រៀងបទថ្វាយបង្គំដែរ ចម្រៀងត្រូវដាក់ក្នុងតុងដែលមនុស្សជាធម្មតាអាចច្រៀងតាមបាន។ បើបទចម្រៀងមានតុងខ្ពស់ពេក មនុស្សជាច្រើនឈប់ច្រៀងព្រោះឈឺកពេលច្រៀងដល់សំឡេងខ្ពស់។ អ្នកច្រៀងត្រូវបញ្ចុះមកតុងទាបៗនូវផ្នែកខ្លះនៅកន្លែងដែលសាច់ភ្លេងត្រូវច្រៀងសម្លេងខ្ពស់ខ្លាំង។ បញ្ហាគឺថា អ្នកចម្រៀងជាធម្មតាមានកម្រិតសំឡេងទាប ហើយអ្នកដឹកនាំថ្វាយបង្គំជា

ច្រើនមានសំឡេងខ្ពស់ ហើយចង់ដាក់បទចម្រៀងជាតុងដែលពួកគេស្តាប់ទៅល្អបំផុត។

ការថ្វាយបង្គំមិនមែនជាការធ្វើឲ្យក្រុមជំនុំ មានការរំភើបជាមួយនឹងជំនាញសំឡេងដ៏អស្ចារ្យរបស់យើងនោះទេ។ ក៏ប៉ុន្តែក្នុងនាមជាអ្នកដឹកនាំថ្វាយបង្គំ គឺភារកិច្ចរបស់យើងធ្វើឲ្យអ្នកដទៃចូលរួមថ្វាយបង្គំទាំងអស់គ្នា។

ដូច្នេះ តើអ្វីទៅជា «ទំនុកភ្លេងដែលអាចច្រៀងបាន?» តើអាចកំណត់តុងភ្លេងដែលក្រុមជំនុំអាចច្រៀងបានដូចម្ដេច? (អុកតាវ ឬតុងសម្លេង)

បទភ្លេងគួរតែអាចទទួលបានដោយអ្នកច្រៀង «ធម្មតា»។ តាមការសិក្សាអំពីសម្លេងរបស់មនុស្ស និងជួរសម្លេងក៏ដូចជាការសង្កេតដោយអ្នកដឹកនាំជាច្រើន កម្រិតសម្លេងកណ្ដាល គឺជួរសម្លេងពី ដូ (ណោតកណ្ដាលC៤) ដល់ ដូ (ណោតខ្ពស់C៥) ជាមួយអុកតាវ ។ ត្រូវពិនិត្យមើលជួរសម្លេងនៃបទភ្លេងត្រូវស្ថិតនៅក្នុងចន្លោះជួរសម្លេងនេះ ហើយភាគច្រើននៃក្រុមជំនុំរបស់អ្នកនឹងអាចច្រៀងបានយ៉ាងល្អ។

ទោះយ៉ាងណាក៏ដោយ បទចម្រៀងជាច្រើនមិនអាចមាននៅក្នុងអុកតាវនោះទេ។ នៅក្នុងករណីទាំងនោះ ជ្រើសរើសតុងសម្រាប់បទចម្រៀងដែលមានជួរសម្លេងមិនទាបជាងណោត A និងមិនខ្ពស់ជាងណោត D ឬណោតEbម្ដងម្កាល។ ណោតEbនេះគួរតែកើតឡើងក្នុងឱកាសដ៏កម្រ និងមិនមាននិរន្តរភាពទេ។ មនុស្សជាមធ្យមនឹងពិបាកជាមួយចម្រៀងណោត E និងខ្ពស់ជាងនេះ។ (នេះគឺជាគោលគំនិតដ៏សំខាន់មួយដែលខ្ញុំឲ្យអ្នកចូលរួមនៅក្នុងសិក្ខាសាលានៃការថ្វាយបង្គំរបស់ខ្ញុំលើកដៃស្ដាំ ហើយសន្យាថា ពួកគេនឹងលែងដឹកនាំក្រុមជំនុំឲ្យច្រៀងតុងភ្លេងដែលមិនសមរម្យទៀត!) ប្រសិនបើផ្នែកខ្លះនៃបទចម្រៀងស្ថិតនៅចុងជួរសម្លេងខ្ពស់វគ្គច្រៀងនោះយូរ អំឡុងពេលនេះវានឹងធ្វើឲ្យអ្នកច្រៀងឆាប់អស់ខ្យល់។ ដូច្នេះបទចម្រៀងទាំងនោះត្រូវការតុងទាបតែប៉ុន្តែណោតទាបបំផុតនៅក្នុងជួរដែលអាចទទួលយកបាន ។ កុំគិតស្មានថា «តុងដើម» របស់បទចម្រៀងគឺជាតុងដ៏ល្អសម្រាប់ក្រុមជំនុំនោះឡើយ។

ម៉្យាងទៀត ប្រសិនបើបទណាមួយមានកម្រិតសម្លេងទាបជ្រុល ហើយអាចទទួលយកបានក្នុងតុងជាច្រើន ទោះបីជាបទដើមណាត្រូវបានគេច្រៀងតាមតុងខ្ពស់ជាងនេះ ខ្ញុំនឹងកែបទចម្រៀងនោះទៅជាតុងដែលអាចតាមកម្ពស់ខ្ពស់បំផុតណាមួយដែលក្រុមជំនុំអាចច្រៀងបានដោយនៅតែរក្សាសាច់ភ្លេងដើមពីរោះដដែល។

ទំនុកភ្លេងងាយចងចាំ/ឆាប់រៀនចេះ។ តើតន្ត្រីជួយឲ្យគេចងចាំទំនុកច្រៀង ដោយដាក់សេចក្តីពិតទៅក្នុងចិត្ត និងគំនិតឬទេ? ខ្ញុំបានចូលក្នុងការបម្រើព័ន្ធកិច្ចថ្វាយបង្គំ ដែលបទចម្រៀងថ្មីត្រូវបានណែនាំ ហើយយើងបានច្រៀងបទនោះយ៉ាងហោចណាស់ប្រាំពីរនាទី។ ក្រោយពីច្រៀងចប់ ខ្ញុំមិនអាចច្រៀងតាមលំនាំបទភ្លេងនោះវិញបានទេ។ វាពិតជាមិនអាចចងចាំបាន។ បទចម្រៀងដែលយើងប្រើគួរតែជាបទចម្រៀងដែលនឹងដក់ជាប់ក្នុងគំនិត និងដួងចិត្តនៃក្រុមជំនុំរយៈពេលច្រើនថ្ងៃ និងច្រើនឆ្នាំទៅមុខទៀត។

ភាពចុះសម្រុងគ្នាយ៉ាងល្អជាមួយទំនុកច្រៀង និងអត្ថបទចម្រៀង។ តើចម្រៀងច្រៀងចូលគ្នាបានល្អដើម្បីបង្ហាញសារ ឬអត្ថន័យនៃបទចម្រៀងសមស្របឬទេ? តើចម្រៀងមានគាំទ្រអត្ថន័យនៃទំនុកច្រៀងសម្រាប់ការថ្វាយបង្គំព្រះជាជាងតន្ត្រីគ្រាន់តែនាំការសប្បាយដែរឬទេ? តើទំនុកភ្លេងធ្វើឲ្យបាត់ ឬរំលងខ្លឹមសារនៃទំនុកច្រៀងដែរឬទេ?

ការត្រាស់ហៅនៃអ្នកដឹកនាំថ្វាយបង្គំគឺដើម្បីជួយមនុស្សឲ្យច្រៀងដោយអស់ពីសមត្ថភាពខ្លួនពួកគេ ទោះបីជាតម្រូវឲ្យលះបង់នូវប្រការមួយចំនួន ដែលយើងជាអ្នកភ្លេងចង់បានក៏ដោយ។ ការត្រាស់ហៅជាអ្នកដឹកនាំថ្វាយបង្គំ អាចទាមទារនូវការលះបង់តន្ត្រីភាព សម្រាប់ជាប្រយោជន៍ដល់ក្រុមជំនុំទាំងមូល។

បន្ទាប់ពីធ្វើការតាមវិធីទាំងអស់នៃការវាយតម្លៃបទចម្រៀងដែលប្រើក្នុងការថ្វាយបង្គំហើយ តើអ្នកត្រូវធ្វើផ្នែកអ្វីខ្លះទៀត?

## ចម្រៀងសម័យទំនើបសម្រាប់ការថ្វាយបង្គំអន្តរជំនាន់

នៅពេលដែលយើងខិតខំដឹកនាំការថ្វាយបង្គំរួមគ្នាជាមួយមនុស្សពហុជំនាន់ខ្ញុំបានចោទជាសំណួរនេះ៖ តើយើងជ្រើសរើសដោយរបៀបណានូវបទចម្រៀងថ្វាយបង្គំសម័យទំនើបពីប្រភពផ្សេងៗនៃបទចម្រៀងទាំងឡាយណាដែលល្អប្រសើរ ដែលអាចទាក់ទាញមនុស្សបានល្អបំផុត ជាមួយនឹងចំណូលចិត្តបទចម្រៀងសហសម័យ និងអ្នកដែលចូលចិត្តបទចម្រៀងប្រពៃណីច្រើនជាង? ការទទួលបានសិទ្ធិនេះអាចធ្វើឲ្យមានការបោះជំហានយ៉ាងល្អ ក្នុងការទាញមនុស្សគ្រប់ជំនាន់នៅក្នុងពេលវេលាដ៏មានប្រយោជន៍នៃការថ្វាយបង្គំរួមគ្នា។

គុណសម្បត្តិដូចគ្នាមួយចំនួន ដែលជួយក្រុមជំនុំទាំងអស់ឲ្យច្រៀងបានល្អ គឺចាំបាច់ដើម្បីចូលរួមជាមួយពួកជំនុំចាស់ៗពីដើម —ការជ្រើសរើសតុងច្រៀង និងបទចម្រៀងស្រដៀងគ្នា ហើយងាយស្រួលច្រៀង។ ដូចដែលបានរៀបរាប់ពីមុន

បទចម្រៀងត្រូវតែស្ថិតនៅក្នុងតុងដែលអាចច្រៀងបាន សម្រាប់មនុស្សចាស់ដែលពេញចិត្តច្រៀងតាម។ ការចេះបទចម្រៀងដែលអាចច្រៀងបានគឺជាកត្តាដ៏ធំមួយដែលខ្ញុំនឹងនិយាយបន្ថែមនៅពេលក្រោយនៅក្នុងសៀវភៅនេះ។ របៀបដែលយើងណែនាំបទចម្រៀង របៀបដែលយើងចង់ច្រៀងឡើងវិញ និងចំនួនបទចម្រៀងនៅក្នុងបញ្ជីចម្រៀងរបស់យើង សុទ្ធតែជាផ្នែកសំខាន់នៃការពិចារណា សម្រាប់ការចូលរួមរបស់មនុស្សជំនាន់មុន។ ការផ្ទៀងផ្ទាត់បញ្ជីបទចម្រៀងសម្រាប់ការច្រៀងរាល់សប្តាហ៍នីមួយៗមិនគួរមានច្រើនពេកទេ ដើម្បីអាចឲ្យមានការដាក់បញ្ចូលនៅបទចម្រៀងថ្មីក្នុងការថ្វាយបង្គំបាន (យើងនឹងនិយាយគ្នាបន្ថែមនៅពេលក្រោយ)។

ចម្រៀងដែលពិបាកច្រៀងដោយសារមានចង្វាក់ច្រើនចូលគ្នា និងសាច់ភ្លេងឡើងចុះពិបាកៗ។ល។ គួរតែចៀសវាងវគ្គច្រៀងខ្លះនៃបទចម្រៀងមានអឿនគ្រហឹមតាមបែបមនុស្សចាស់ ហើយក៏មិនគួរច្រៀងវគ្គស្ពានចម្លងសារចុះឡើងដដែលៗច្រើនតាមចិត្តរបស់យុវជនដែល ពីព្រោះវាអាចមនុស្សដែលមានវ័យចាស់ៗមានអារម្មណ៍ធុញថប់ ហើយយើងត្រូវចាំថាមនុស្សនៅក្នុងក្រុមជំនុំនីមួយៗមានវ័យខុសៗគ្នា។

ការប្រើប្រាស់ ការរៀបចំបទចម្រៀងសម័យទំនើប ឬបទចម្រៀងបែបប្រពៃណីមិនមែនបញ្ហាទេ តែអ្នកដឹកនាំត្រូវការមានប្រាជ្ញាមកពីព្រះដើម្បីធ្វើការនោះ តើពេលណាត្រូវប្រើបទចម្រៀងថ្មី ហើយពេលណាត្រូវប្រើបទចម្រៀងបែបប្រពៃណីដែលរក្សានូវចង្វាក់ និងបទភ្លេងដើម។ ពីព្រោះចំណុចសំខាន់នៃការនេះគឺមនុស្សគ្រប់ជំនាន់មកចូលរួមថ្វាយបង្គំជាមួយគ្នារាប់ថាជាប្រយោជន៍រួមថ្វាយសិរីរុងរឿងទៅព្រះអម្ចាស់។

ក្នុងនាមជាអ្នករៀបចំផែនការនៃការថ្វាយបង្គំ អ្នកតែងតែគិតដល់មនុស្សដែលអ្នកដឹកនាំក្នុងការថ្វាយបង្គំ។ អ្នកត្រូវមានទឹកចិត្តជាគ្រូគង្វាលដើម្បីរួបរួមរូបកាយព្រះគ្រីស្ទជាជាងការបំបែកបំបាក់ក្នុងការសម្រួលតន្ត្រី។ សូមកុំគិតតែលើមនុស្សតែមួយជំនាន់តែប៉ុណ្ណោះ ពីព្រោះតែយើងត្រូវប្រើប្រាស់បទចម្រៀងទាំងបទទំនុកតម្កើង និងបទនិពន្ធថ្មីដែលមានគោលលទ្ធិត្រឹមត្រូវឲ្យពួកជំនុំអាចច្រៀងរួមគ្នាបានព្រមទាំងរក្សាទំរង់បទភ្លេងដើមរបស់អ្នកនិពន្ធក្នុងការច្រៀងសរសើរតម្កើងព្រះអម្ចាស់រួមគ្នាតែមួយ។

# បទចម្រៀងថ្មី៖ លើកស្ទួយការថ្វាយបង្គំ ឬក៏សម្លាប់ការថ្វាយបង្គំ

មុននេះ ខ្ញុំបានចង្អុលបង្ហាញថា វាចាំបាច់សម្រាប់យើងក្នុងការច្រៀងចម្រៀងថ្មីពេលថ្វាយបង្គំ — បទថ្មីៗអាចជួយជំរុញចិត្តក្នុងពេលថ្វាយបង្គំរបស់យើងកាន់តែខ្លាំង។ យ៉ាងណាក៏ដោយ បទចម្រៀងថ្មីក៏អាចជាការរំខានដល់ការថ្វាយបង្គំដែរ។

មានរឿងមួយជ្រុល នៅក្នុងកម្មវិធីថ្វាយបង្គំបែបសហសម័យជាច្រើនដងអ្នកដឹកនាំថ្វាយបង្គំនាំយកបទចម្រៀងថ្មីៗជាច្រើនបទ នៅក្នុងកម្មវិធីតែមួយ។ ហេតុនេះបានធ្វើឲ្យក្រុមជំនុំលែងចូលរួមការថ្វាយបង្គំហើយជំនួសវិញរៀនបទចម្រៀងថ្មី ឬបង្វែរទាំងស្រុងទៅជាអ្នកទស្សនាការថ្វាយបង្គំ ហើយចាត់ទុកបទចម្រៀងនេះជាផ្នែក «ចម្រៀងពិសេស» នៃកម្មវិធីថ្វាយបង្គំ។ នៅក្នុងព្រះវិហារដែលមានអ្នកដឹកនាំ/អ្នករៀបចំផែនការនៃការថ្វាយបង្គំច្រើនជាងម្នាក់ នាំឲ្យបញ្ហានេះកាន់តែអាក្រក់ទៅៗជាមួយនឹងការសម្របសម្រួលមិនគ្រប់គ្រាន់ សម្រាប់បទចម្រៀងដែលប្រើក្នុងការថ្វាយបង្គំ។

មានរឿងជ្រុលនិយមមួយទៀត នៅក្នុងកម្មវិធីថ្វាយបង្គំតាមបែបប្រពៃណីមួយចំនួន ក៏នៅតែមានការស្ទាក់ស្ទើរក្នុងការប្រើប្រាស់បទចម្រៀងថ្វាយបង្គំសហសម័យណាមួយ។ ពួកគេមិនអើពើនឹងបញ្ញត្តិនៃព្រះគម្ពីរ អំពីព្រះពរនៃការផ្សារភ្ជាប់ជាមួយនឹងអ្វីដែលព្រះកំពុងធ្វើការនៅក្នុងតន្ត្រីថ្វាយបង្គំ និងលទ្ធភាពក្នុងការអនុវត្តគោលគំនិតព្រះគម្ពីរមានការភ្ជាប់ទំនាក់ទំនងកាន់តែល្អជាមួយនឹងវប្បធម៌សព្វថ្ងៃ។

ដូច្នេះ តើយើងថ្លឹងថ្លែងយ៉ាងដូចម្ដេចកំណត់សម្គាល់ពីបញ្ហារវាងអ្នកទស្សនានិងការបញ្ចេញអារម្មណ៍ព្រមទាំងហេតុផលដ៏អស្ចារ្យទាំងអស់ដើម្បីអាចបញ្ចូលបទចម្រៀងថ្មីក្នុងការថ្វាយបង្គំរបស់យើង?

**គន្លឹះគឺជារបៀបដែលយើងបង្ហាញបទចម្រៀងនានា និងភាពញឹកញាប់នៃការណែនាំបទចម្រៀងថ្មី។**

# តើយើងគួរច្រៀងចម្រៀងថ្មីប៉ុន្មានបទ?

ទី១៖ សូមកុំណែនាំបទចម្រៀងថ្មីលើសពីមួយបទក្នុងកម្មវិធីថ្វាយបង្គំម្ដង។ បើមិនដូច្នោះទេ អ្នកប្រថុយនឹងការរំខានដល់លំហូរ និងសន្ទុះនៃការថ្វាយបង្គំ។ ក្នុងការក្រឡេកមើលក្រុមជំនុំ និងបទពិសោធន៍ជាច្រើន វាអាចកំណត់បានថា ការ

ច្រៀងចម្រៀងថ្មីច្រើនជាងមួយបទ នៅក្នុងកម្មវិធីថ្វាយបង្គំគឺជាការរំខានដល់ការថ្វាយបង្គំ។ នេះគឺជាចំណុចទីពីរ ដែលខ្ញុំបានសុំឲ្យអ្នកចូលរួមការបណ្ដុះបណ្ដាលអ្នកដឹកនាំថ្វាយបង្គំ លើកដៃស្ដាំរបស់ពួកគេសម្រាប់ការសច្ចាប្រណិធាន ហើយនិយាយថាពួកគេនឹងមិនដែលឲ្យក្រុមជំនុំច្រៀងបទថ្មីលើសពីមួយបទក្នុងកម្មវិធីថ្វាយបង្គំម្ដងនោះឡើយ។ ក្នុងករណីដែលមិនអាចចងចាំជាលើកទីមួយ យើងគួរតែរំឭកការនេះម្ដងទៀត៖

**មិនត្រូវណែនាំបទចម្រៀងថ្មីលើសពីមួយបទក្នុងកម្មវិធីថ្វាយបង្គំម្ដង។**

ទី២៖ ការដាក់បទចម្រៀងថ្មីដែលអ្នកគួរប្រើក្នុងខែណាមួយគឺអាស្រ័យលើក្រុមជំនុំរបស់អ្នក។ ក្រុមជំនុំនីមួយៗមានភាពខុសប្លែកគ្នា ទាក់ទងនឹងចំនួនបទចម្រៀងថ្មីដែលពួកគេអាចច្រៀងតាមពេលវេលាដែលផ្ដល់ឲ្យ ដូច្នេះសូមប្រយ័ត្នតាមដាន និងមើលសញ្ញានៃ «ច្រៀងបទថ្មីច្រើនហួសហេតុពេក» ដោយសារបទថ្មី (ឧ. ការថយចុះយ៉ាងខ្លាំងក្នុងកម្រិតនៃការចូលរួម)។ សម្រាប់ព្រះវិហារខ្លះ មួយបទក្នុងមួយខែ ប្រហែលជាគ្រប់គ្រាន់ហើយ។ សម្រាប់អ្នកផ្សេង ពីរបទក្នុងមួយខែ គឺសមហេតុផល។

**តើអ្នកត្រូវការកែសម្រួលចំនួន និងភាពញឹកញាប់នៃការប្រើបទចម្រៀងថ្មីឬទេ?**

# ការណែនាំបទចម្រៀងថ្មី

### ១.ចាប់ផ្ដើមកម្មវិធីថ្វាយបង្គំដោយបទចម្រៀងថ្មី

បទចម្រៀងថ្មីនឹងមិនរារាំងដំណើរការនៃការថ្វាយបង្គំទេ ប្រសិនបើលើកយកបទនោះមកច្រៀងនៅដើមកម្មវិធី។ បន្ទាប់បទចម្រៀងថ្មីអ្នកក៏អាចច្រៀងបន្តតាមក្រោយដោយបទដែលធ្លាប់ចេះ ហើយបន្តដំណើរការថ្វាយបង្គំរបស់អ្នក។ វាក៏ល្អបំផុតផងដែរ ក្នុងការច្រៀងសារឡើងវិញនូវវគ្គ និង/ឬបន្ទរ ជាច្រើនដង។ វិធីនេះ

ធ្វើឲ្យបទចម្រៀងដក់ជាប់ក្នុងចិត្ត និងគំនិតបានកាន់តែឆាប់ជួយឲ្យក្រុមជំនុំចងចាំ។

**២.ប្រសិនបើអ្នកចង់ប្រើបទចម្រៀងនៅពេលក្រោយក្នុងកម្មវិធីថ្វាយបង្គំ សូមធ្វើការណែនាំនៃបទនោះមុនជិតដល់ពេលកម្មវិធីថ្វាយបង្គំចាប់ផ្តើម**

ប្រាប់ក្រុមជំនុំថា នេះជាបទចម្រៀងថ្មី អ្នកនឹងច្រៀងវាម្តងទៀតនៅពេលក្រោយនៅក្នុងកម្មវិធីថ្វាយបង្គំហើយអ្នកចង់ឲ្យអ្នកគ្រប់គ្នាស្គាល់បទនោះមុនពេលការថ្វាយបង្គំចាប់ផ្តើម។ បន្ទាប់មកចូលច្រៀងតាមវគ្គ និងបន្ទរ (អ្នកអាចធ្វើដូច្នេះដោយលេងតែហ្គីតា ឬព្យាណូ)។ ក្នុងន័យនេះអ្នកផ្តើមការថ្វាយបង្គំដោយប្រើពេលវេលាហ្វឹកហាត់ — ណែនាំបទចម្រៀងថ្មីដែលអាចប្រើក្នុងការថ្វាយបង្គំនៅពេលក្រោយ ។

**៣.បទថ្មីត្រូវច្រៀងច្រើនសប្តាហ៍ជាប់គ្នា**

ជារឿយៗ គំនិតនេះត្រូវបានអ្នកដឹកនាំថ្វាយបង្គំមើលរំលង ហើយដែលនេះគឺជាប្រការដ៏មានសារៈសំខាន់។ មួយភាគបី ឬច្រើននៃក្រុមជំនុំរបស់អ្នកអវត្តមាននៅថ្ងៃអាទិត្យជាក់លាក់ណាមួយ។ កាលៈទេសៈផ្សេងទៀត កាត់បន្ថយចំនួនអ្នកចូលរួមសរុបនៅថ្ងៃអាទិត្យណាមួយតែម្តង។ សូមប្រើច្បាប់ ៣-១-១ ឬ ២-១-១។ ចូរច្រៀងបទថ្មីម្តងទៀតសម្រាប់ថ្ងៃអាទិត្យពីរឬបីសប្តាហ៍ជាប់ៗគ្នា ហើយបន្ទាប់មក សម្រាកច្រៀងវាមួយថ្ងៃអាទិត្យសិន។ រួចបន្ថែមវាត្រឡប់ទៅកាន់ការថ្វាយបង្គំនៅថ្ងៃអាទិត្យបន្ទាប់ ហើយមើលថាតើក្រុមជំនុំបានរៀនចេះយ៉ាងដូចម្តេច។ ជាមួយនឹងពាក្យដដែលនេះ អ្នកកំពុងតែជួយក្រុមជំនុំឲ្យអាចទទួលយកបទចម្រៀងថ្មីក្នុងការថ្វាយបង្គំ។ គួរឲ្យស្តាយប្រសិនបើអ្នកច្រៀងបទចម្រៀងថ្មីតែមួយសប្តាហ៍ ហើយរំលងមួយខែ ឬយូរជាងនោះ បទចម្រៀងថ្មីនៅអាចហាក់ដូចជានៅតែថ្មីម្តងទៀត។ ជាការចាំបាច់ដែលអ្នកត្រូវប្រើប្រាស់វិធីសាស្ត្ររំឭកឡើងវិញដដែលៗក្នុងការរៀនបទចម្រៀងថ្មី!

**៤.ណែនាំបទចម្រៀងថ្មីៗក្នុងការប្រជុំក្រុមតូចៗ មុនពេលអ្នកប្រើវាក្នុងក្រុមជំនុំរបស់អ្នក**

ពេលណាមានអ្នកស្គាល់បទចម្រៀងកាន់តែច្រើន ក្រុមជំនុំអាចចាប់បានបទថ្មីកាន់តែលឿន។ ចូរបង្រៀនបទចម្រៀងថ្មីនោះនៅក្នុងការថ្វាយបង្គំនៃក្រុមយុវជនការសិក្សាព្រះគម្ពីរជាក្រុមតូចៗ ក្រុមចម្រៀង ក្រុមបុរស ឬក្រុមតូចៗផ្សេងទៀតដែលជួយដល់ជីវិតរបស់ក្រុមជំនុំរបស់អ្នក។ កាលណាមានមនុស្សកាន់តែច្រើនស្គាល់បទចម្រៀងមុនពេលអ្នកណែនាំវានៅក្នុងការថ្វាយបង្គំនោះធ្វើឲ្យគេមានអំណរជាមុនក្នុងការថ្វាយបង្គំ។

**៥.ធ្វើការណែនាំបទចម្រៀងថ្មីមានលក្ខណៈជា «ជាការសម្ដែងតន្ត្រី/បង្ហាញតន្ត្រីពិសេស»**

អ្នកសម្ដែងទោល ឬក្រុមចម្រៀងអាចច្រៀងបទចម្រៀងនៅថ្ងៃអាទិត្យ មុនពេលប្រើវាជាមួយក្រុមជំនុំធំ ការសម្រួលតន្ត្រីដ៏ល្អអាចជួយមនុស្សឲ្យចងចាំទំនុកភ្លេង។

**៦.ចាក់ស្ដាប់បទចម្រៀងថ្មី ខណៈដែលមនុស្សគ្រប់គ្នាកំពុងមកថ្វាយបង្គំ**

អ្នកអាចជ្រើសរើសបទចម្រៀងថ្មីចំនួន១០បទ ដើម្បីណែនាំនៅប៉ុន្មានខែខាងមុខនេះ ហើយឲ្យពួកគេលេងនៅពេលដែលមនុស្សប្រមូលផ្ដុំគ្នាសម្រាប់ការថ្វាយបង្គំ។ បន្តិចម្ដងៗ មនុស្សកាន់តែស្គាល់បទចម្រៀងនោះ មុនពេលដែលបទចម្រៀងត្រូវបានណែនាំជាផ្លូវការក្នុងការថ្វាយបង្គំ។

## ធ្វើបញ្ជីបទចម្រៀងសម្រាប់ការរៀបចំផែនការថ្វាយបង្គំ

ចម្រៀងគឺជាផ្នែកមួយដ៏សំខាន់នៃការថ្វាយបង្គំក្នុងក្រុមជំនុំរបស់អ្នក។ ក្រុមជំនុំថ្វាយសម្លេងការថ្វាយបង្គំតាមរយៈបទចម្រៀង និងការសរសើររបស់ពួកគេ។ ចម្រៀងមានសារៈសំខាន់ក្នុងការបង្កើតសិស្ស។ មនុស្សថ្វាយបង្គំបានល្អបំផុត ជាមួយនឹងបទចម្រៀងដែលពួកគេចេះច្រៀង។

មនុស្សខ្លះមានផែនការសម្រាប់ការថ្វាយបង្គំ ដោយជ្រើសរើសបទចម្រៀងចេញពីខួរក្បាលរបស់ពួកគេ។ ប្រហែលជាការលើកទឹកចិត្តមកពីបទចម្រៀងមួយដែលអ្នកបានឮក្នុងសប្ដាហ៍នេះ ឬគ្រាន់តែជាបទចម្រៀងពីអតីតកាលដែលពួកគេបានចងចាំ។ ការនេះមើលរំលងចម្រៀងជាច្រើន ដែលអាចជាជម្រើសល្អសម្រាប់ក្រុមជំនុំរបស់អ្នកក្នុងសប្ដាហ៍នេះ។

អ្នករៀបចំផែនការថ្វាយបង្គំខ្លះ មានបញ្ជីដែលរួមបញ្ចូលរាល់បទចម្រៀងដែលក្រុមជំនុំរបស់ពួកគេធ្លាប់ច្រៀង។ វាប្រហែលជាមានច្រើនជាង២០០បទនៅក្នុងបញ្ជីនោះ។ ខណៈពេលដែលវាអាចមានដំណើរការល្អជាមួយក្រុមជំនុំដែលមានភាពចាស់ទុំ បានឈរជើងរឹងមាំហើយ តែវាក្លាយជាបញ្ហាដ៏ធំ ប្រសិនបើក្រុមជំនុំរបស់អ្នកកំពុងមានការរីកចម្រើន ជាមួយនឹងមនុស្សដែលមិនបានរីកចម្រើនខាងឯព្រលឹងវិញ្ញាណនៅក្នុងក្រុមជំនុំដែលច្រៀងចម្រៀងទាំងនេះទេ ឬប្រសិនបើក្រុមជំនុំរបស់អ្នកចង់ដាក់ខ្លួនដើម្បីឈោងចាប់ និងបង្កើតសិស្សនៅក្នុងសហគមន៍របស់អ្នក។ ការមានបញ្ជីចម្រៀងក្រាស់ពេកមានន័យថា មនុស្សថ្មីកម្រស្គាល់បទចម្រៀងដែលអ្នកច្រៀង ដែលជាឧបសគ្គរារាំងពួកគេមិនឲ្យចូលរួមក្នុងការថ្វាយបង្គំបានពេញលេញ។

**ប្រសិនបើអ្នកមានបញ្ជីចម្រៀងដែលអ្នកប្រើក្នុងការធ្វើផែនការថ្វាយបង្គំ តើមានបទចម្រៀងប៉ុន្មានបទក្នុងបញ្ជី? តើអ្នកធ្លាប់ដកបទចម្រៀងចេញពីបញ្ជី ឬក៏វាកាន់តែកើនច្រើនឡើងៗរាល់ឆ្នាំ? តើអ្នកកំណត់ដោយរបៀបណាថាបទចម្រៀងប៉ុន្មានបទគួរមានក្នុងបញ្ជីរបស់អ្នក?**

## ហេតុអ្វីបានជាយើងត្រូវកាត់បន្ថយបទចម្រៀងក្នុងបញ្ជីរបស់យើង?

ការដែលមានបទចម្រៀងច្រើនពេកនៅក្នុងបញ្ជីរបស់អ្នកនាំឲ្យមានបទចម្រៀងដែលអាចច្រៀងឡើងវិញកាន់តែតិច ហើយក្នុងករណីជាច្រើន មនុស្សមួយចំនួនក្នុងក្រុមជំនុំរបស់អ្នកនឹងមិនស្គាល់បទចម្រៀងដែលអ្នកកំពុងប្រើក្នុងការថ្វាយបង្គំនោះទេ។ បទចម្រៀងដែលមិនសូវមានគេចេះនាំឲ្យមានភាពអសកម្ម ធ្វើឲ្យខ្វះការចូលរួមក្នុងការថ្វាយបង្គំ ហើយនាំឲ្យអ្នកចូលរួមច្រៀងក្លាយជាអ្នកទស្សនាវិញ។

**ទំហំនៃបញ្ជីចម្រៀងគោលរបស់អ្នកអាចប៉ះពាល់ខ្លាំងដល់ការថ្វាយបង្គំក្នុងព្រះវិហាររបស់អ្នក**

ចូរយើងគិតពីទំហំនៃបញ្ជីចម្រៀងរបស់អ្នក។ ប្រសិនបើបញ្ជីរបស់អ្នកមានបទចម្រៀងលើសពី ២០០ បទ ហើយព្រះវិហាររបស់អ្នកពេលថ្វាយបង្គំម្តងៗជាធម្មតាច្រៀងចម្រៀងតែបួនបទក្នុងមួយសប្តាហ៍ នោះអ្នកនឹងមិនអាចច្រៀងបទចម្រៀងដែលបានផ្តល់ឲ្យច្រើនជាងម្តងក្នុងមួយឆ្នាំទេ ប្រសិនបើអ្នកច្រៀងចម្រៀងទាំងអស់! នោះសមស្របសម្រាប់ព្រះវិហាររបស់អ្នកត្រូវបានបង្កើតឡើងដោយមនុស្សដែលជាចំនួននៃក្រុមជំនុំជាក់លាក់របស់អ្នកអស់ជាច្រើនទសវត្សរ៍ ឬប្រសិនបើអ្នកកំពុងប្រើតែបទចម្រៀងប្រពៃណីចាស់ៗសម្រាប់ក្រុមអ្នកចូលរួមក្នុងព្រះវិហារចាស់។

ប៉ុន្តែចុះយ៉ាងណាវិញ ប្រសិនបើក្រុមជំនុំរបស់អ្នកកំពុងរីកចម្រើន ហើយទទួលស្វាគមន៍អ្នកជឿថ្មីជាប្រចាំនោះ? ប្រហែលជាអ្នកមានចំនួនអ្នកចូលរួមច្រើន

ជារៀងរាល់សប្តាហ៍។ តើមនុស្សទាំងនេះដែលមិនបានធំឡើងនៅក្នុងព្រះវិហារនឹងស្គាល់តន្ត្រីរបស់អ្នកទេ? ប្រហែលជាមិនទំនងទេ។

**ប្រសិនបើព្រះវិហាររបស់អ្នកកំពុងរីកចម្រើន និងឈោងចាប់មនុស្សបានច្រើន អ្នកត្រូវតែដាក់កម្រិតសមរម្យនៃបទចម្រៀងដែលយកមកច្រៀងជាទៀងទាត់ដើម្បីឲ្យពួកគេស្គាល់ ហេតុនេះហើយទើបមានការចូលរួមក្នុងការថ្វាយបង្គំ។**

យើងក៏ត្រូវពិចារណាផងដែរថា អ្នកចូលរួមព្រះវិហារជាមធ្យមមិនថ្វាយបង្គំនៅព្រះវិហាររបស់អ្នករាល់សប្តាហ៍។ ទោះបីជាពួកគេចូលរួមរៀងរាល់សប្តាហ៍ផ្សេងទៀតជាមធ្យមក៏ដោយ វាប៉ះពាល់យ៉ាងខ្លាំងដល់ចំនួនដងដែលពួកគេជួបបទចម្រៀងជាក់លាក់មួយនៅក្នុងបញ្ជីបទចម្រៀងគោលរបស់អ្នក។ (ប្រសិនបើអ្នកច្រៀងចម្រៀងបួនដងក្នុងមួយឆ្នាំ ហើយពួកគេចូលរួមត្រឹមតែពាក់កណ្តាលនៃពេលវេលា ពួកគេអាចនឹងច្រៀងវាពីរដងដែរ)។

ចម្រៀងច្រើនពេកនៅក្នុងបញ្ជីចម្រៀងរបស់អ្នកនឹងធ្វើឲ្យក្រុមជំនុំពិបាកក្នុងការថ្វាយបង្គំ។

ដូច្នេះ ប្រសិនបើអ្នកចង់ជួយក្រុមជំនុំរបស់អ្នកឲ្យច្រៀងបាន ដោយជួយពួកគេក្នុងការច្រៀងចម្រៀងដែលពួកគេធ្លាប់ស្គាល់ នោះអ្នកត្រូវតែកំណត់ទំហំនៃបញ្ជីចម្រៀងកុំឲ្យច្រើនពេក។

## ជ្រើសរើសបទចម្រៀងចម្រុះដែលអ្នកនឹងប្រើក្នុងបញ្ជីចម្រៀងរបស់អ្នក

ដើម្បីធានាបាននូវភាពចម្រុះសម្រាប់ក្រុមជំនុំរបស់ខ្ញុំ ខ្ញុំបែងចែកប្រភេទបទចម្រៀងនៅក្នុងបញ្ជីរបស់ខ្ញុំតាមវិធីមួយក្នុងចំណោមវិធីទាំងបួន ដូចបានរៀបរាប់ខាងក្រោម។ អ្នកអាចរកឃើញថាការចាត់ថ្នាក់ផ្សេងៗគ្នាមានដំណើរការប្រសើរជាងសម្រាប់ការកំណត់របស់អ្នក។

**សូមចាំថា បញ្ជីចម្រៀងដែលធំក្រាស់ពេក ឬតូចស្តើងពេកអាចជះឥទ្ធិពលអវិជ្ជមានដល់ការសម្តែងក្នុងការថ្វាយបង្គំក្នុងព្រះវិហាររបស់អ្នករៀងរាល់សប្តាហ៍។**

## ប្រភេទបញ្ជីចម្រៀងចំនួនបីគឺ (បុរាណ/សម័យ/ចម្រុះ) ដែលគួរតែជាផ្នែកមួយនៃបញ្ជីចម្រៀងគោលរបស់អ្នក

### ១. ទំនុកតម្កើង/បទចម្រៀងប្រពៃណី

វាជាបទចម្រៀងដ៏អស្ចារ្យដែលបានឆ្លងកាត់ការសាកល្បងពេលវេលាដ៏យូរ ហើយជាការចាំបាច់ណាស់ដើម្បីជួយយើងឲ្យតភ្ជាប់ជាមួយនឹងកេរ្តិ៍ដំណែលរបស់យើង ហើយវាជាទំនុកភាសាក្នុងចិត្តរបស់អ្នកថ្វាយបង្គំច្រើនជំនាន់ក្នុងក្រុមជំនុំរបស់យើង។

### ២. បទចម្រៀងថ្វាយបង្គំបែបបុរាណ

ទាំងនេះគឺជាបទចម្រៀងថ្វាយបង្គំដែលមិនចេះរីងស្ងួតនៅជាមួយយើង។ បទចម្រៀងថ្មីៗជាច្រើនមានការពេញនិយមពីពីរបីខែ ទៅពីរបីឆ្នាំ – បន្ទាប់មក បទទាំងនោះសាបរលាបអស់ទៅវិញ ហើយកម្រនឹងយកមកប្រើម្តងទៀត។ បទចម្រៀងបែបបុរាណបានរក្សាជាប់ការនិយមចូលចិត្តទោះបីជានិពន្ធយូរលង់មកហើយក៏ដោយ ហើយនៅពេលដែលបាននាំយកមកក្នុងកម្មវិធីថ្វាយបង្គំម្តងទៀត អាចត្រូវបានទទួលយកជាការបង្ហាញនូវការថ្វាយបង្គំដ៏អស្ចារ្យសម្រាប់ក្រុមជំនុំ។ សូមគិតអំពីបទចម្រៀងដូចជា «ទ្រង់ធំណាស់ណា!» និង «មានឈើឆ្កាងដ៏គួរស្បើម» ជាដើម បទចម្រៀងទាំងនេះមានអាយុប្រហែលជាមិនតិចជាង១០០ឆ្នាំទេ។ សម្រាប់មនុស្សនៅក្នុងក្រុមជំនុំរបស់អ្នក ដែលបានចូលរួមព្រះវិហារអស់ជាច្រើនឆ្នាំ បទចម្រៀងបែបបុរាណទាំងនេះ ប្រហែលជាសាំនៅសប្តាហ៍ដំបូងដែលអ្នកប្រើវា។

### ៣. បទចម្រៀងថ្វាយបង្គំសម័យថ្មី

ទាំងនេះជាបទចម្រៀងដែលនិពន្ធក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះ។ បទចម្រៀងទាំងនេះអាចរួមបញ្ចូលរចនាបថចម្រៀងផ្សេងគ្នាជាច្រើន ប៉ុន្តែចម្រៀងទាំងអស់គឺជាការសម្តែងអារម្មណ៍កាន់តែខ្លាំងចេញពីសេចក្តីជំនឿក្នុងសម័យរបស់យើងនេះ ជាជាងការដែលព្រះទ្រង់ធ្វើការផ្លាស់ប្តូរនៅក្នុងជីវិតមនុស្សសម្រាប់បច្ចុប្បន្ននេះ។

### ៤. បទចម្រៀងថ្មី

ទាំងនេះគឺជាបទចម្រៀងដែលថ្មីសម្រាប់ក្រុមជំនុំរបស់អ្នក។ បទទាំងនោះអាចមកពីប្រភេទណាមួយក្នុងចំណោមបីប្រភេទខាងលើ ប៉ុន្តែជាទូទៅចម្រៀងទាំងនេះនឹងត្រូវច្រៀងឡើងវិញជាច្រើនដងនៅពេលដំបូង ដើម្បីស្គាល់ និងក្លាយជាធាតុផ្សំប្រកបនៃការថ្វាយបង្គំក្នុងក្រុមជំនុំរបស់អ្នក។

**សម្គាល់៖** អ្នកប្រហែលចង់បន្ថែមប្រភេទផ្សេងទៀត ឬផ្លាស់ប្តូរប្រភេទទាំងនេះក៏បាន។ ការយល់ដឹងអំពីគោលគំនិតរួម គឺចាំបាច់ ប៉ុន្តែ អ្នកប្រាកដជាមានសេរីភាពក្នុងការដាក់បទចម្រៀង ទៅក្នុងវិធីដែលបម្រើក្រុមជំនុំរបស់អ្នកបានល្អបំផុត។

**សូមចាំថា បញ្ជីចម្រៀងដែលធំក្រាស់ពេក ឬតូចស្តើងពេកអាចជះឥទ្ធិពលអវិជ្ជមានដល់ការសម្តែងក្នុងការថ្វាយបង្គំក្នុងព្រះវិហាររបស់អ្នករៀងរាល់សប្តាហ៍។**

## ប្រភេទបញ្ជីចម្រៀងចំនួនបីគឺ (បុរាណ/សម័យ/ចម្រុះ) ដែលគួរតែជាផ្នែកមួយនៃបញ្ជីចម្រៀងគោលរបស់អ្នក

ការបង្កើតបញ្ជីចំនួនបី នឹងជួយអ្នកក្នុងការរៀបចំផែនការរបស់អ្នក។ បញ្ជីមួយនឹងជាបញ្ជីដែលអ្នកគួរតែពិនិត្យគម្រោងនោះ។ បញ្ជីមួយនឹងជាបញ្ជីដែលអ្នករក្សាទុកបទចម្រៀងថ្មីៗ ដែលអ្នកនឹងណែនាំជាប្រព័ន្ធដល់ក្រុមជំនុំ ហើយចុងក្រោយមានបញ្ជីដើម្បីរក្សាបទចម្រៀងដែលចូលនិវត្តន៍ ដែលអាចនឹងត្រឡប់មកបញ្ជីចម្បងរបស់អ្នកវិញនាពេលអនាគត។ខាងក្រោមនេះគឺជាការពិពណ៌នានៃបញ្ជីទាំងបី៖

**១. បទចម្រៀងបច្ចុប្បន្ន**

នេះជាបញ្ជីដែលអ្នកប្រើដើម្បីរៀបចំការថ្វាយបង្គំ។ បញ្ជីនេះត្រូវបានរៀបចំយ៉ាងយកចិត្តទុកដាក់ជាមួយនឹងចំនួន ហើយនិងប្រភេទបទចម្រៀងដែលត្រឹមត្រូវដូចដែលយើងបានពិភាក្សាឲ្យត្រូវជាមួយពួកជំនុំរបស់អ្នក។

**២. បទចម្រៀងស្ថិតក្រោមការពិចារណា**

នេះជាបញ្ជីចម្រៀងរបស់អ្នកដែលបានបំពេញតម្រូវការទាំងអស់សម្រាប់បទចម្រៀងថ្មីដែលអ្នកនឹងណែនាំដល់ក្រុមជំនុំរបស់អ្នក។ បទទាំងនេះត្រូវបានសម្រិតសម្រាំងយ៉ាងយកចិត្តទុកដាក់ផ្នែកតន្ត្រី និងអត្ថបទ ដូចដែលបានពិភាក្សាកន្លងមក។ បទចម្រៀងនៅក្នុងបញ្ជីនេះទំនងជានឹងបញ្ចប់នៅក្នុងបញ្ជីបទចម្រៀងនាពេលអនាគត។

**៣. បទចម្រៀងចូលនិវត្តន៍**

នៅពេលអ្នកលុបបទចម្រៀងចេញពីបញ្ជីបទចម្រៀងបច្ចុប្បន្ន អ្នកអាចដាក់វា

នៅក្នុងបញ្ជីចម្រៀងដែលត្រូវចូលនិវត្តន៍ ដរាបណាអ្នកមានអារម្មណ៍ថាវាមិនធានាថានឹងប្រើវាម្តងទៀតនាពេលអនាគត។ បញ្ជីនេះអាចរីកធំឡើងនាពេលអនាគត។

**កុំបន្តប្រើបទចម្រៀងល្អធម្មតាៗ ខណៈពេលដែលអ្នកអាចផ្តោតលើបទចម្រៀងអស្ចារ្យៗសម្រាប់ក្រុមជំនុំរបស់អ្នក។**

## ការរៀបចំទម្រង់បញ្ជីចម្រៀងមេរបស់អ្នក

ខ្ញុំបញ្ចូលព័ត៌មានទាំងអស់នៅក្នុងបញ្ជីដែលអាចត្រូវបានតម្រៀបសម្រាប់ជាជំនួយក្នុងការរៀបចំផែនការថ្វាយបង្គំ។ ខ្ញុំលើកទឹកចិត្តថាសូមបញ្ចូលព័ត៌មានលម្អិតដាក់លាក់លើបទចម្រៀងនីមួយៗ ដើម្បីជួយខ្ញុំរៀបចំផែនការថ្វាយបង្គំ។ នេះជាការផ្តល់យោបល់មួយចំនួន—អ្នកអាចចូលចិត្តវិធីសាស្ត្រដែលមានការតម្រៀបចុះក្រោម។ ព័ត៌មានដែលសម្គាល់ដោយសញ្ញាផ្កាយគឺសំខាន់បំផុត។

**១.*ចំណងជើងបទចម្រៀង**

**២.*គន្លឹះទី១** — នេះគួរតែជាចម្រៀងដែលងាយស្រួលក្នុងក្រុមជំនុំ ហើយរួមបញ្ចូលតុងចុងក្រោយ ប្រសិនបើការរៀបចំផ្លាស់ប្តូរតុង។ សមត្ថភាពក្នុងការតម្រៀបតាមតុងមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរៀបចំផែនការបទចម្រៀងថ្វាយបង្គំដែលគ្មានភាពរអាក់រអួល និងមានលំហូរបានល្អ ដូចដែលអ្នកនឹងឃើញនៅក្នុងមេរៀននៅពេលក្រោយ។

**៣.*គន្លឹះទី២** (ប្រសិនបើអាចប្រើបាន) — នេះគួរតែជាតុងដែលងាយស្រួលក្នុងក្រុមជំនុំ ហើយរួមបញ្ចូលតុងចុងក្រោយ ប្រសិនបើការរៀបចំផ្លាស់ប្តូរតុង។

**៤.ប្រភព** — អ្នកប្រហែលជាចង់កំណត់ចំណាំកន្លែងដែលជាប្រភពដើមនៃការរៀបចំបទចម្រៀង ដូចជា: (សៀវភៅទំនុកសកល, ទំនុកខ្មែរ និងតាមតំណភ្ជាប់គេហទំព័រផ្សេងៗ។ល។)។

**៥.*ប្រភេទ** — ជ្រើសរើសប្រភេទបទចម្រៀងដែលសមរម្យពីជម្រើសមកពីបញ្ជីទាំងបី។

**៦.កំណត់ល្បឿន #** — តើអ្វីជាការកំណត់ចង្វាក់ភ្លេងសម្រាប់ចម្រៀងនោះ?

**៧.ល្បឿន** — ជ្រើសរើសលឿន មធ្យម ឬយឺតពីជម្រើសមកពីបញ្ជីទាំងបី។

**៨.លេខចង្វាក់ភ្លេង** — ជ្រើសរើសលេខចង្វាក់ឲ្យត្រឹមត្រូវជម្រើសមកពីបញ្ជីទាំងបី។

ដើម្បីបង្កើតបញ្ជីនេះ ជាដំបូង កំណត់ថាតើបទចម្រៀងប៉ុន្មានបទគួរមាននៅក្នុងបញ្ជីរបស់អ្នក ដើម្បីឲ្យមានពាក្យដដែលៗ ដើម្បីជួយមនុស្សរបស់អ្នកឲ្យស្គាល់តន្ត្រី។ បន្ទាប់មកកំណត់ចំនួនបទចម្រៀងមួយប្រភេទ។ ឧទាហរណ៍ ខ្ញុំប្រហែលជាសម្រេចចិត្តថាមានបទចម្រៀងចំនួន៣០បទនៅក្នុងបញ្ជីបទចម្រៀងបច្ចុប្បន្នរបស់ខ្ញុំ។ ក្នុងចំណោម៣០បទនោះ មានចំនួន១២បទជាបទថ្វាយបង្គំសម័យទំនើប៨បទជាបទថ្វាយបង្គំជំនាន់ដើម៧បទជាបទប្រពៃណី និង៣បទទៀតជាបទថ្មី (មួយខែមានពាក្យដដែលៗដូចបានរៀបរាប់ខាងដើម)។ សូមចងចាំថាមិនគួរមានបទចម្រៀងថ្មីណាមួយនៅក្នុងបីប្រភេទដំបូងឡើយ។ អ្នកអាចដាក់បទចម្រៀងល្បីផ្សេងទៀតនៅក្នុងបញ្ជីចម្រៀងដែលចូលនិវត្តន៍ដើម្បីប្រើពេលអ្នកកែសម្រួលបញ្ជីរបស់អ្នករាល់បីខែ។ អ្នកនឹងដាក់បទចម្រៀងដែលអ្នកនឹងណែនាំនៅពេលអនាគតដែលអ្នកបានឆ្លងកាត់តម្រងចម្រៀងរួចហើយនៅក្នុងបញ្ជីដែលស្ថិតក្រោមការពិចារណា។

## ការប្រើប្រាស់បញ្ជីក្នុងការរៀបចំផែនការថ្វាយបង្គំ

នៅពេលអ្នករៀបចំផែនការថ្វាយបង្គំ អ្នកនឹងប្រើតែបញ្ជីបទចម្រៀងបច្ចុប្បន្នប៉ុណ្ណោះ។ ក្នុងរយៈពេលបីខែអ្នកនឹងប្រើប្រាស់បទចម្រៀងដដែលៗ ដើម្បីជួយក្រុមជំនុំរបស់អ្នក និងមនុស្សថ្មីឲ្យពិតជាចូលរួមក្នុងការថ្វាយបង្គំជាមួយនឹងបទចម្រៀងដែលពួកគេចេះ។

បន្ទាប់ពីរយៈពេលបីខែ អ្នកត្រូវតែប្តូរបទចម្រៀងថ្មីទាំងបីបទនោះ ទៅប្រភេទសមស្របជាមួយពួកគេ (មួយក្នុងចំណោមបីប្រភេទផ្សេងទៀត) ហើយបន្ថែមបទចម្រៀងថ្មីចំនួនបីបទទៀតពីបញ្ជីដែលស្ថិតក្រោមការពិចារណា។ អ្នកត្រូវលុបបទចម្រៀងយ៉ាងហោចណាស់បីបទចេញពីបញ្ជីគោល ដូច្នេះចំនួនសរុបរបស់អ្នកនៅក្នុងបញ្ជីនោះនឹងមិនកើនឡើងទេ។ ផ្លាស់ទៅបញ្ជីចម្រៀងដែលចូលនិវត្តន៍។ ចូរកុំមានអារម្មណ៍ខ្លាចក្រែង ក្នុងការផ្លាស់ប្តូរពីរបីទៀតរវាងបញ្ជីចូលនិវត្តន៍របស់អ្នក និងបញ្ជីចម្រៀងបច្ចុប្បន្ន។

គំនិតនេះគឺដើម្បីរក្សាទំហំបញ្ជីរបស់អ្នកឲ្យអាចគ្រប់គ្រងបាន និងផ្តល់នូវភាពចម្រុះ និងទំនុកច្រៀងដដែលៗសម្រាប់ក្រុមជំនុំរបស់អ្នក។

## គំនិតបិទបញ្ចប់លើបញ្ជីបទចម្រៀង

ខ្ញុំលើកទឹកចិត្តអ្នកដែលមានបទចម្រៀងច្រើនក្នុងបញ្ជីរបស់អ្នក ពិចារណាអំពីហេតុផលក្នុងការសរសេរនេះ ហើយកំណត់ថា តើអ្នកចង់ទទួលបានបញ្ជីរបស់

អ្នកក្នុងស្ថានភាពប្រសើរជាងមុន ដើម្បីជួយក្រុមជំនុំរបស់អ្នកឲ្យពិតជាថ្វាយបង្គំជាមួយនឹងបទចម្រៀងដែលពួកគេចេះច្បាស់ឬអត់។

ប្រសិនបើក្រុមជំនុំរបស់អ្នកជាក្រុមដែលមានវ័យចំណាស់ ដែលបង្កើតឡើងដោយមនុស្សដែលបានចូលរួមក្នុងព្រះវិហារពេញមួយជីវិតរបស់ពួកគេ ហើយអ្នកមានមនុស្សតិចតួចបំផុត ដែលទើបតែបានចូលរួមមិនយូរប៉ុន្មាន នោះប្រហែលជាបញ្ជីដ៏ធំបំផុតដំណើរការល្អសម្រាប់អ្នក។

ប្រសិនបើអ្នកចង់ភ្ជាប់ទំនាក់ទំនងជាមួយអ្នកផ្សេងក្រៅពីការពិពណ៌នានោះ ខ្ញុំជឿថាបញ្ជីរបស់អ្នកត្រូវតែកាត់បន្ថយយ៉ាងខ្លាំងតាមដែលអាចធ្វើទៅបាន។

**ការបង្កើតបញ្ជីបទចម្រៀងអាចតម្រូវឲ្យយើងចំណាយពេលយូរ ប៉ុន្តែវាផ្តល់នូវផលប្រយោជន៍ជាច្រើនក្នុងការរៀបចំផែនការថ្វាយបង្គំ និងជួយដល់ក្រុមជំនុំរបស់លោកអ្នកឲ្យចូលរួមក្នុងការថ្វាយបង្គំដែលផ្លាស់ប្តូរជីវិតពួកគាត់។ សូមផ្តល់អាទិភាពក្នុងការញែកពេលវេលាឲ្យបានរៀងយូរ ដើម្បីបង្កើតបញ្ជីបទចម្រៀងរបស់លោកអ្នក ប្រសិនបើលោកអ្នកមិនទាន់មាននៅឡើយ ឬក៏ដើម្បីផ្លាស់ប្តូរបញ្ជីបទចម្រៀងដែលលោកអ្នកមានស្រាប់ហើយ។.**

## ដំណើរការឆ្លងក្នុងការថ្វាយបង្គំ

ផ្នែកខាងក្រោមផ្តល់ជូននូវជំនួយជាក់ស្តែង ក្នុងការរចនាកម្មវិធីថ្វាយបង្គំជាមួយនឹងធាតុផ្សំដ៏រឹងមាំ នៃការសរសើរតម្កើងដោយសេរី ប៉ុន្តែក៏មានការបញ្ចូលគ្នានៃទម្រង់ថ្វាយបង្គំផ្សេងទៀត។ ការចាប់អារម្មណ៍ជាពិសេស គឺសមត្ថភាពក្នុងការនាំយកធាតុអំពីទិសដៅ និងប្រធានបទទៅក្នុងគំរូនៃការសរសើរដោយសេរីក្នុងកម្រិតជាក់លាក់ និងដែនកំណត់នៃពេលវេលាការថ្វាយបង្គំក្នុងព្រះវិហាររបស់អ្នក។ ការពិចារណាលើតន្ត្រី មានសារៈសំខាន់ក្នុងការតភ្ជាប់បទចម្រៀងជាមួយគ្នានៅក្នុងរយៈពេលនៃការច្រៀង។ តំណភ្ជាប់អត្ថបទ និងប្រធានបទមានសារៈសំខាន់ក្នុងការផ្តល់ទិសដៅ និងលំហូរទៅកាន់កម្មវិធីថ្វាយបង្គំ និងពង្រឹងរាជសាររបស់គ្រូគង្វាល។ មុននឹងយើងពិចារណាអំពីគោលគំនិតទាំងមូលនៃការរៀបចំផែនការបទពិសោធន៍នៃការថ្វាយបង្គំនោះ គឺជាការល្អបំផុតដែលត្រូវយល់ពីរបៀបដែលបទចម្រៀងមានទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាពក្នុងការផ្តល់នូវលំហូរនៃការថ្វាយបង្គំយ៉ាងរលូន។

## ការតភ្ជាប់បទចម្រៀងថ្វាយបង្គំ៖ ការពិចារណាអំពីតន្ត្រី

ជាដំបូង យើងពិចារណាវិធីតភ្ជាប់បទចម្រៀងតាមភ្លេង ដើម្បីឲ្យវាហូរចូលគ្នាយ៉ាងរលូនពីមួយទៅមួយ។ ការនេះប៉ះប៉ូវការអនុវត្តដែលឆ្គាំឆ្គង និងភាពច្របូកច្របល់ដែលជាធម្មតាកើតឡើងក្នុងការបញ្ចប់បទចម្រៀង ហើយបន្ទាប់មក មានការបំពេញដ៏ឆ្គាំឆ្គងមួយពេលអ្នកទទួលបានបទចម្រៀងបន្ទាប់ដែលបានត្រៀមរួច។ នៅក្នុងការតភ្ជាប់តន្ត្រី បទចម្រៀងទីពីរហូរចេញពីទីមួយ បង្កើតអារម្មណ៍នៃការធ្វើដំណើរ និងការតភ្ជាប់គ្នា។ មានវិធីសាស្ត្រចម្បងចំនួនបីដែលយើងនឹងប្រើដើម្បីភ្ជាប់បទចម្រៀងជាមួយគ្នានៅក្នុងការថ្វាយបង្គំ:

### លំនាំដើមត្រួតគ្នា




នៅក្នុងវិធីអាំងត្រួត្រួតគ្នា នៅពេលដែលណោតចុងក្រោយនៃបទចម្រៀងទីមួយត្រូវបានច្រៀង ការណែនាំទៅកាន់បទចម្រៀងទីពីរចាប់ផ្តើមនៅជាមួយគ្នា។ អារម្មណ៍របស់បទចម្រៀងថ្មី ហើយប្រហែលជាការផ្លាស់ប្តូរនៃល្បឿនគ្រប់គ្រងយ៉ាងជាក់លាក់នៅចំណុចនោះ ដែលទាក់ទាញក្រុមជំនុំចូលទៅក្នុងបទចម្រៀងទីពីរ។ វិធីសាស្ត្រនេះទាមទារអាគ័រចុងក្រោយនៃបទចម្រៀងទីមួយ និងអាគ័រដំបូងនៃបទចម្រៀងទីពីរដូចគ្នាដែលជាធម្មតា វិធីសាស្ត្រនេះដំណើរការបានល្អសម្រាប់បទចម្រៀងពីរដែលមានគុងភ្លេងដូចគ្នា។

### ទុកចន្លោះខ្លី



នៅក្នុងវិធីសាស្ត្រទុកចន្លោះខ្លីបទចម្រៀងទីមួយបញ្ចប់ ហើយបទចម្រៀងទីពីរចាប់ផ្តើម បន្ទាប់ពីទុករយៈពេលមួយភ្លែតវាគ្រប់គ្រាន់ដើម្បីគ្រប់ដង្ហើម "ដកដង្ហើម" ។ វិធីសាស្ត្រនេះល្អបំផុតក្នុងការភ្ជាប់បទចម្រៀងមួយទៅមួយខ្លាតចង្វាក់ ឬពាក់កណ្តាលដាច់ពីគ្នា និងបទចម្រៀងដែលបទចម្រៀងទីពីរគឺជាការឆ្លើយតបដោយឯកឯងទៅនឹងបទទីមួយ។

## គ្មានគម្លាត




វិធីសាស្ត្រគ្មានគម្លាត ចូលរួមជាមួយនឹងបទចម្រៀងពីរបទ ដោយមួយបទចាប់ផ្តើមត្រង់ពេលបញ្ចប់នៃបទមុន។ ស្គរចង្វាក់នៅតែបន្តតឈប់។ សេរីភាពកើតឡើងក្នុងការកំណត់រយៈពេល (ឬវត្តមាន) នៃផ្នែកបញ្ចប់ និងផ្នែកចាប់ផ្តើម (outros និង intros) ដើម្បីបង្កើតចំនួននៃការភ្ជាប់ឧបករណ៍រវាងផ្នែកច្រៀងនៃបទចម្រៀងទាំងពីរ។ វិធីសាស្ត្រនេះដំណើរការសម្រាប់បទចម្រៀងក្នុងខ្ទង់ដូចគ្នា ឬដាច់ពីគ្នាគម្លាតបួន ឬគុងប្រាំ។

## ទំនាក់ទំនងគុង

**បទចម្រៀងនៅក្នុងគុងដូចគ្នា និងមានចង្វាក់ដូចគ្នាអាចនឹងដំណើរការល្អជាមួយគ្នា។**

ប្រសិនបើ ល្បឿន (Tempos) ដូចគ្នាចាប់ផ្តើមច្រៀងបទទីពីរនៅលើណោតចុងក្រោយនៃបទចម្រៀងមុន។ (ចាប់ផ្តើមត្រួតគ្នា) (INTRO OVERLAP)

ឧបមាថា ល្បឿន (Tempos) នៃបទចម្រៀងមិនដូចគ្នា។ ក្នុងករណីនោះ

អ្នកអាចបន្ថែមស្លាកបន្ទរបន្ថែម ។ល។ ដល់ចុងបញ្ចប់នៃបទចម្រៀងទីមួយ នៅចង្វាក់នៃបទចម្រៀងទីពីរ ប្រសិនបើសមរម្យ បន្ទាប់មកផ្លាស់ទីទៅបទចម្រៀងទីពីរ ដោយចាប់ផ្ដើមច្រៀងបទទីពីរ នៅលើណោតចុងក្រោយនៃបទចម្រៀងមុន។ (ចាប់ផ្ដើមត្រួតគ្នា) (INTRO OVERLAP)

ផ្លាស់ប្តូរយ៉ាងរលូនទៅក្នុងបទចម្រៀងបន្ទាប់ដោយគ្រាន់តែផ្អាកមួយរយៈខ្លីប៉ុណ្ណោះ។ នេះអាចដំណើរការបានល្អដែលចង្វាក់គឺខុសគ្នាខ្លាំងដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់លើអាគ័រដែលមាននិរន្តរភាព ដើម្បីឲ្យអ្នកវាយស្គររាប់ពីចង្វាក់ថ្មី។ នេះក៏ដំណើរការបានយ៉ាងល្អជាមួយនឹងវិធីសាស្ត្រការឆ្លើយតបឯកឯងតាមការគ្រោងទុក ដែលបានពិពណ៌នានៅពេលក្រោយនៅក្នុងផ្នែកនេះ។ (ចន្លោះពេលខ្លី) (SHORT GAP)

ផ្លាស់ប្តូរភ្លាម ដោយចាប់ផ្តើមបទចម្រៀងបន្ទាប់ភ្លាមៗបន្ទាប់ពីបញ្ចប់បទទីមួយ។ នេះតម្រូវឲ្យអ្នកចូលទៅបទចម្រៀងបន្ទាប់ឲ្យបានលឿន។ ប្រសិនបើវាហាក់ដូចជាប្រញាប់ពេក សូមពិចារណាប្រើគំនិតតភ្ជាប់ខាងក្រោម។ (មិនសម្រាក) (NO BREAK)

ដាក់ចង្វាក់បន្ថែមមួយ ឬពីរនៃ «ការបំពេញបន្ថែម» រវាងបទចម្រៀងទាំងពីរ នៅពេលអ្នកភ្ជាប់ដោយផ្ទាល់ក្នុងការច្រៀងបទចម្រៀងទីពីរ។ (មិនសម្រាក) (NO BREAK)

ប្រើការច្នៃប្រឌិតរបស់អ្នកដើម្បីបង្កើតលំហូរយ៉ាងរលូនថាតើមានចង្វាក់ប៉ុន្មានដើម្បីបញ្ចប់បទចម្រៀងទីមួយ និងមានចង្វាក់ប៉ុន្មានដើម្បីច្រៀងបទទីពីរ។ អ្នកអាចរៀបចំការប្រគុំតន្ត្រីនៃពេលវេលាគ្រប់គ្រាន់សម្រាប់អត្ថបទគម្ពីរសំខាន់ៗ កំណត់អារម្មណ៍ថ្មី ឬផ្លាស់ទៅយ៉ាងលឿនក្នុងបទចម្រៀងបន្ទាប់ អាស្រ័យលើអ្វីដែលអ្នកចង់សម្រេច។

**ចម្រៀងនៅក្នុងពាក់កណ្ដាលតុង ឬមួយតុងដាច់ពីគ្នា ដំណើរការជាមួយគ្នាយ៉ាងល្អ។**

ចំណាំ៖ ជាទូទៅវាជាការល្អបំផុតក្នុងការផ្លាស់ទី គឺឡើងលើក្នុងតុង មិនមែនចុះក្រោមតុងទេ។

វាជាការល្អបំផុតក្នុងការបញ្ចប់បទចម្រៀងមួយបទ ហើយចាប់ផ្តើមការណែនាំខាងក្រោមភ្លាមៗនៅក្នុងតុងខ្ពស់ជាងនេះ។ (ចន្លោះពេលខ្លី) (SHORT GAP)

ពេលខ្លះ ការប្រើអាគ័រទីប្រាំដែលមានតុងទីប្រាំពីរ (Dominant 7th or V7) ក្នុងបទចម្រៀងទីពីរ មានប្រសិទ្ធភាពក្នុងការនាំអ្នកទៅកាន់តុងថ្មី។ ឧទាហរណ៍ពី Bb ទៅ C: Bb > F/G (IV/V ក្នុង តុង ថ្មី) > G7 (V7 in new key) > C (គ្មានចន្លោះ) (NO GAP)

កែប្រែនៅក្នុងបទចម្រៀងទីមួយ ដើម្បីច្រៀងមួយវគ្គ ច្រៀងបន្ទរ ឬស្ពានរំកិលឡើងកន្លះតុង ឬមួយតុង (ទៅតុងដូចគ្នាទៅនឹងបទចម្រៀងទីពីរ) បន្ទាប់មក ប្រើវិធីសាស្ត្រមួយសម្រាប់ការភ្ជាប់បទចម្រៀងនៅក្នុងតុងដូចគ្នា។ ចាប់ផ្តើមត្រួតគ្នា (INTRO OVERLAP)

**ការផ្លាស់ប្តូរឡើងបួនតុង ឬឡើងប្រាំតុង ក៏ដំណើរការល្អផងដែរ។**

ចំណាំ៖ ការផ្លាស់ប្តូរនេះ រំកិលឡើងលើបួនតុង ឬប្រាំតុង គឺប្រហែលជាសំឡេងល្អបំផុតសម្រាប់ត្រចៀក ក្រៅពីការផ្លាស់ប្តូរទៅកាន់បទចម្រៀងនៅក្នុងតុងដូចគ្នា។ ឧទាហរណ៍ ប្រសិនបើអ្នកស្ថិតនៅក្នុងតុងដូ (C) ហើយអ្នកនឹងទៅបទចម្រៀងមួយទៀតនៅក្នុងតុងហ្វា (F) (IV) ឬ សុល (G) (V) នោះវានឹងស្តាប់ទៅត្រឹមត្រូវនៅនឹងត្រចៀកពេលអ្នកផ្លាស់ទៅបទចម្រៀងថ្មី ដោយសារអាគ័រសំខាន់ ហ្វា(F) (ឬសុល G) គឺជាផ្នែកនៃបទចម្រៀងនៅក្នុងដូ (C) ។ វាផ្តល់នូវការផ្លាស់ប្តូរដ៏ល្អទៅកាន់បទចម្រៀងនៅក្នុងតុងផ្សេងទៀត។

ចាប់ផ្តើមការណែនាំបទចម្រៀងទីពីរដោយបន្ទាប់ពីបញ្ចប់បទចម្រៀងមុន ប្រសិនបើល្បឿន (tempo) ដូចគ្នា។ មិនសម្រាក (NO BREAK)

ចាប់ផ្តើមការណែនាំបទចម្រៀងទីពីរបន្ទាប់ពីការផ្អាកមួយរយៈ ប្រសិនបើចង្វាក់នៃបទចម្រៀងមួយខុសពីបទចម្រៀងផ្សេងទៀត។ ចន្លោះពេលខ្លី (SHORT GAP)

ផ្លាស់ប្តូរដោយច្រៀងបទបន្ទាប់ក្រោយពីបទដំបូង ឬបន្ទាប់ពីការផ្អាកមួយរយៈ។ ចំណាំ៖ បទចម្រៀងទីពីរគឺនៅក្នុងតុងថ្មី។ អ្នកត្រូវតែមានទំនុកចិត្តលើណោតដំបូងនៃបទចម្រៀងទីពីរ ដោយមិនចាំបាច់ត្រូវការឧបករណ៍ជំនួយ។ នេះគឺជាគំនិតតភ្ជាប់មួយផ្សេងទៀតសម្រាប់ការឆ្លើយតបឯកឯងតាមការគ្រោងទុក។ ចន្លោះពេលខ្លី (SHORT GAP)

សូមកត់ចំណាំថា បទចម្រៀងថ្វាយបង្គំសហសម័យជាច្រើនបានបញ្ចប់នៅ

លើអាគ័រ៤។ នៅពេលដែលបទចម្រៀងបញ្ចប់នៅលើអាគ័រ៤ អ្នកអាចចូលទៅត្រង់សំឡេងនៃបទចម្រៀងទីពីរ ដែលជាបទឡើង៤តុងខាងលើក្នុងករណីជាច្រើនដោយមិនចាំបាច់មានការណែនាំណាមួយដើម្បីបង្កើតតុងថ្មី។ (ចន្លោះពេលខ្លី) (SHORT GAP)

## ការឆ្លើយតបទៅតាមគម្រោងនៃការថ្វាយបង្គំ

ខ្ញុំប្រើពាក្យនេះដើម្បីពិពណ៌នាអំពីការតភ្ជាប់ ដែលបានគ្រោងទុករវាងបទចម្រៀងពីរ ដែលទោះបីជាអ្នកបញ្ចប់បទចម្រៀងទីមួយ តែហាក់ដូចជាអ្នកបានគិតភ្លាមៗ អំពីបទចម្រៀងទីពីរដែលនឹងជាការឆ្លើយតបដ៏ល្អ ចំពោះបទចម្រៀងទីមួយ។ បន្ទាប់មក អ្នកដឹកនាំដោយផ្ទាល់ក្នុងការច្រៀងវា។ បទចម្រៀងទីពីរនឹងចាប់ផ្តើមដោយឯកឯងដោយឧបករណ៍តិចតួចបំផុត - ប្រហែលជាគ្រាន់តែជាព្យាណូប៉ុណ្ណោះ។ បន្ទាប់មក បទចម្រៀងអាចបង្កើតបានតាមកម្រិតនៃចង្វាក់តន្ត្រីបាន។ តាមគម្រោងនៃការថ្វាយបង្គំបានរៀបចំទុកគឺដំណើរការល្អបំផុតរវាងបទចម្រៀងនៅក្នុងតុងដូចគ្នា ប៉ុន្តែ វាក៏ដំណើរការបានល្អនៅក្នុងណោត ដូចឧទាហរណ៍ខាងលើ ដែលបទចម្រៀងដែលបញ្ចប់នៅលើអាគ័រ៤ទៅបទចម្រៀងនៅក្នុងតុងមួយខ្ពស់ជាងបួនតុង។ ផ្នែកសំខាន់ក្នុងករណីនេះគឺថា អ្នកដឹកនាំការថ្វាយបង្គំត្រូវតែដឹងថាតើត្រូវចាប់ផ្តើមណោតអ្វី ហើយទទួលបានតុងថ្មីនៅក្នុងខួរក្បាលរបស់ពួកគេភ្លាមៗចាប់តាំងពីមិនមានការណែនាំដើម ដើម្បីលេងភ្លេងក្នុងតុងនោះ។ ការធ្វើនេះអាចមានឥទ្ធិពលខ្លាំងក្នុងការថ្វាយបង្គំ។ (ចន្លោះពេលខ្លី) (SHORT GAP)

## ផ្លាស់ប្តូរទៅតុងពិបាកជាងមុន

ពេលខ្លះ អ្នកប្រហែលជាត្រូវប្រើបទចម្រៀងពីរជាប់គ្នាដែលមិនមានការផ្លាស់ប្តូរតុងសាមញ្ញ។ ជាញឹកញយ វាល្អបំផុតក្នុងស្ថានភាពទាំងនេះ ដើម្បីឲ្យមានការសម្រាកខ្លីៗរវាងបទចម្រៀង សម្រាប់ការអធិស្ឋាន ការអានព្រះគម្ពីរ ឬធាតុផ្សំនៃថ្វាយបង្គំផ្សេងទៀត។ វាជាការសមរម្យសម្រាប់អ្នកភ្លេងម្នាក់ ឬច្រើននាក់ ក្នុងការចាប់ផ្តើមលេងភ្លេងដោយស្ងាត់ស្ងៀមនៅក្នុងតុងថ្មី បន្ទាប់ពីផ្អាកមួយរយៈដើម្បី «ដកដង្ហើម» នៃតុងទីមួយ។

# តារាងទំនាក់ទំនងគុងសំខាន់ៗសម្រាប់ការផ្លាស់ប្តូរសាមញ្ញ

ប្រើតារាងនេះដើម្បីកំណត់គុងទាំងប្រាំយ៉ាងរហ័ស ដែលបទនេះនៅក្នុងគុង (G) ដើម្បីបង្កើតការផ្លាស់ប្តូរគ្មានថ្នេររវាងបំណែកពីរ។ សូមចងចាំថា បទចម្រៀងមួយអាចចូលគ្នាទៅបទមួយទៀតនៅ

| KEY | UP 1/2 STEP | UP WHOLE STEP | UP FOURTH | UP FIFTH |
|---|---|---|---|---|
| A | Bb/A# | B | D | E |
| Bb/A# | B | C | Eb/D# | F |
| B | C | Db/C# | E | F#/Gb |
| C | Db/C# | D | F | G |
| Db/C# | D | Eb/D# | F#/Gb | Ab/G# |
| D | Eb/D# | E | G | A |
| Eb/D# | E | F | Ab/G# | Bb/A# |
| E | F | F#/Gb | A | B |
| F | F#/Gb | G | Bb/A# | C |
| F#/Gb | G | Ab/G# | B | Dd/C# |
| G | Ab/G# | A | C | D |
| Ab/G# | A | Bb/A# | Db/C# | Eb/D# |

ក្នុងគុងដូចគ្នាឡើងកន្លះគុង ឬឡើងមួយគុង ឬឡើងបួនគុង ឬប្រាំគុង។ សូមចងចាំទំនាក់ទំនងសំខាន់ៗរវាងបទចម្រៀងក្នុងការថ្វាយបង្គំ។ ត្រូវតែដឹងជានិច្ចថា អ្នកនៅទីណា និងកន្លែងដែលអ្នកទៅ ដូច្នេះអ្នកនឹងដឹងថាណោតអ្វីនៅខាងមុខ ហើយមិនចាំបាច់រង់ចាំអ្នកឧបករណ៍ភ្លេងដើម្បីដឹកនាំអ្នកក្នុងការបង្កើតបទចម្រៀងនោះទេ។

**ជាធម្មតា តើបទចម្រៀងបន្តបន្ទាប់គ្នា នៅក្នុងឈុតថ្វាយបង្គំរបស់អ្នក មិនជាប់គ្នា ខ្វះភាពរលូនពីមួយទៅមួយទេ? តើអ្នកអាចចាត់វិធានការអ្វីខ្លះ ដើម្បីជម្នះបញ្ហានេះ?**

## ការភ្ជាប់បទចម្រៀងថ្វាយបង្គំ៖ ការពិចារណាលើអត្ថបទ

បន្ថែមពីលើទំនាក់ទំនងតុងសំខាន់ៗ អ្នកអាចបង្កើតទំនាក់ទំនងរវាងបទចម្រៀងតាមរយៈអត្ថបទ។ ខ្ញុំបានខ្ចីគំនិតទាំងនេះពី ដុនចាបមែន (Don Chapman) នៃ WorshipIdeas.com ។ នៅពេលដែលអ្នកអាចប្រើប្រាស់ការភ្ជាប់អត្ថបទ និងការតភ្ជាប់តន្ត្រីអ្នកបង្កើតការផ្លាស់ប្តូរដ៏មានឥទ្ធិពល។ សូមពិចារណាវិធីបន្ថែម ដើម្បីភ្ជាប់បទចម្រៀង៖

### តំណភ្ជាប់អត្ថបទ

សូមមើលអត្ថបទចម្រៀង ហើយមើលថាតើពាក្យគន្លឹះ ឬឃ្លាណាមួយណែនាំបទចម្រៀងផ្សេងទៀត។ ពិចារណាវគ្គទាំងអស់នៃបទចម្រៀង ក៏ដូចជាលទ្ធភាពនៃការចាប់ផ្តើមជាមួយនឹងបន្ទរ ស្ពាន ឬឃ្លានៃបទចម្រៀង។ ការប្តូរវគ្គនៃបទចម្រៀងអាចត្រូវបានធ្វើឡើងដើម្បីជួយភ្ជាប់អត្ថបទ ដរាបណាវានៅតែសមហេតុផលនៅក្នុងលំដាប់នោះ។ ឧទាហរណ៍មួយនឹងត្រូវបានបញ្ចប់ ព្រះយើងធំមហិមា “How Great Is Our God” ហើយភ្លាមៗចូលទៅក្នុងការច្រៀងបន្ទរនៃ យើងច្រៀងថា ទ្រង់ធំណាស់ណា “How Great Thou Art.” ។

### តំណភ្ជាប់ប្រធានបទ

ចម្រៀងអាចភ្ជាប់គ្នាបានដោយផ្អែកលើប្រធានបទរបស់ពួកគេ។ ឧទាហរណ៍ការជ្រើសរើសបទចម្រៀងពីរ ឬច្រើនលើប្រធានបទនៃព្រះគុណ នឹងផ្តល់នូវតំណភ្ជាប់ប្រភេទនេះ។ លើសពីនេះទៀត វាជាការល្អបំផុតប្រសិនបើអ្នកព្យាយាមភ្ជាប់បទចម្រៀងជាមួយនឹងទំនាក់ទំនងសំខាន់ៗ សម្រាប់ការផ្លាស់ប្តូរកាន់តែរលូន។

## តំណភ្ជាប់ការឆ្លើយតប

ពេលអ្នកច្រៀងចម្រៀងចប់សូមគិតថា៖ «តើខ្ញុំចង់ទៅកន្លែងណាទៀត? តើខ្ញុំចង់ឆ្លើយតបយ៉ាងណា?» ជ្រើសរើសបទចម្រៀងដែលឆ្លើយសំណួរនោះ។

# ធាតុមិនមែនជាតន្ត្រីនៃការថ្វាយបង្គំ

ក្នុងនាមជាអ្នករៀបចំការថ្វាយបង្គំ យើងត្រូវពិចារណាលើសពីបទចម្រៀងដ៏អស្ចារ្យក្នុងគម្រោងការថ្វាយបង្គំរបស់យើង។ សូមគិតអំពីការប្រើប្រាស់ការអធិស្ឋាន ការអានព្រះគម្ពីរ ការបង្រៀន ទីបន្ទាល់ ពិធីលៀងព្រះអម្ចាស់ ពិធីបុណ្យជ្រមុជទឹក វីដេអូ ការសូត្រគោលជំនឿពួកសាវ័ក/ការអានផ្សេងទៀត រឿងខ្លី និងសិល្បៈច្នៃប្រឌិតផ្សេងទៀត។ នេះមិនត្រឹមតែនឹងរួមបញ្ចូលអំណោយទាននៃសមាជិកក្រុមជំនុំរបស់អ្នកកាន់តែច្រើនប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងទាក់ទាញដួងចិត្តមនុស្សក្នុងក្រុមជំនុំរបស់អ្នក តាមរបៀបដែលតន្ត្រីតែមួយមុខគត់មិនអាចធ្វើបាន។ សូមបើកគំនិត និងការស្រមើស្រមៃរបស់អ្នក ចំពោះវិធីនានាដើម្បីរួមបញ្ចូលក្រុមជំនុំរបស់អ្នក ក្នុងការថ្វាយបង្គំដោយចេះសាកល្បងច្នៃប្រឌិតនូវអ្វីថ្មីៗមិនមែនធ្វើដូចគ្នាដដែលៗរាល់សប្តាហ៍។ យើងនឹងនិយាយបន្ថែមទៀតអំពីរឿងនេះពេលយើងឈានដល់ការរៀបចំកម្មវិធីថ្វាយបង្គំ។

# តួនាទីនៃបទបង្ហាញ/តន្ត្រីតំណាង

ខណៈពេលដែលតួនាទីចម្បងនៃក្រុមចម្រៀងក្នុងក្រុមជំនុំ និងក្រុមភ្លេងផ្សេងទៀតគឺដើម្បីដឹកនាំ និងធ្វើឲ្យក្រុមជំនុំចូលរួមក្នុងការច្រៀងសរសើររបស់ពួកគេ ក្រុមចម្រៀងក៏មានកន្លែងសម្រាប់បំពេញមុខងារនៃការបង្ហាញ ឬ «ធ្វើជាតំណាង» បន្ថែមទៀត នៅក្នុងពេលវេលានៃការថ្វាយបង្គំរួមគ្នារបស់យើងដែរ។ ព្រះវិហារជាច្រើនបានលុបចេញទាំងស្រុងនូវ «ចម្រៀងពិសេស» ដោយព្រោះវាអាចមើលទៅហាក់ដូចជាការសម្តែងច្រើនជាងនេះ ដែលជាធាតុផ្សំបង្កើតឲ្យមានអ្នកទស្សនាក្នុងកម្មវិធីថ្វាយបង្គំ។ ខណៈពេលដែលវាអាចជាការពិតនៅក្នុងករណីជាច្រើន ខ្ញុំជឿថា នៅតែមានកន្លែងសំខាន់សម្រាប់តន្ត្រីដែលអាចឲ្យពួកជំនុំចូលរួមច្រៀងបាននៅក្នុងកម្មវិធីថ្វាយបង្គំ។

ការពិពណ៌នាដ៏ល្អបំផុតនៃតួនាទីនៃតន្ត្រីបង្ហាញនៅក្នុងព្រះវិហារដែលខ្ញុំបានឃើញ ចេញពីសៀវភៅរបស់ ខន់ស្តេន ឆឺរី (Constance Cherry) ដែលមានចំណងជើងថា «ស្ថាបត្យករតន្ត្រី (The Music Architect: គោលការណ៍

សម្រាប់ធ្វើឲ្យអ្នកថ្វាយបង្គំជក់ចិត្តនៅក្នុងបទចម្រៀង (Blueprints for Engaging Worshipers in Song:)»៖

> *ការបង្ហាញតន្ត្រី គឺជាតន្ត្រីដែលត្រូវបានរៀបចំជាមុនដោយអ្នកភ្លេងម្នាក់ ឬច្រើននាក់ ដើម្បីបង្ហាញក្នុងនាមអ្នកថ្វាយបង្គំផ្សេងទៀត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះ។ តន្ត្រីភាគច្រើនក្នុងការថ្វាយបង្គំគួរតែត្រូវបានបកប្រែជារួម។ ការអនុវត្តនេះគឺល្អ និងត្រឹមត្រូវ។ ទោះយ៉ាងណាក៏ដោយ មានកន្លែងសម្រាប់តន្ត្រីដែលត្រូវបានបង្ហាញជាងតំណាង។ នៅក្នុងក្រុមជំនុំជាច្រើន តន្ត្រីបង្ហាញ ជួនកាលគេហៅថា «តន្ត្រីពិសេស» ត្រូវបានលុបចោល ដើម្បីជាការបំពេញចិត្តចំពោះបទចម្រៀងក្រុមជំនុំទាំងស្រុង។ ប៉ុន្តែ តន្ត្រីបង្ហាញមានតួនាទីក្នុងការថ្វាយបង្គំរួមគ្នាដរាបណាការសង្កត់ធ្ងន់នៅតែមានច្រើនលើការច្រៀងក្នុងក្រុមជំនុំ។ ប្រហែលជាពាក្យល្អជាងគឺ «តន្ត្រីតំណាង»—បទចម្រៀង ឬឧបករណ៍ភ្លេងដែលត្រូវបានរៀបចំដោយសមាជិកមានលក្ខណសម្បត្តិគ្រប់គ្រាន់រួមគ្នា ហើយបន្ទាប់មក ផ្តល់ជូនក្នុងនាមសហគមន៍ ដែលតំណាងឲ្យសំឡេងទាំងមូល។ វាត្រូវបានគេយល់ថា តន្ត្រីបែបនេះបម្រើមុខងារដូចគ្នានៅក្នុងការថ្វាយបង្គំជាបទចម្រៀងផ្សេងទៀតដែលច្រៀងដោយក្រុម (ការប្រកាស ការអធិស្ឋាន ការដាស់តឿន។ល។) ប៉ុន្តែ ត្រូវបានបញ្ចេញដោយសមាជិកដែលបានរៀបចំ។ ក្នុងពេលជាមួយគ្នានេះដែរ វាត្រូវបានគេយល់ផងដែរថាគឺដើម្បីពង្រឹងដល់អ្នកថ្វាយបង្គំរួមគ្នា ដោយបំផុសគំនិតពួកគេក្នុងការថ្វាយការសរសើរ និងការអធិស្ឋានរបស់ពួកគេផ្ទាល់។ តើអ្នកធ្លាប់ឮនរណាម្នាក់និយាយយ៉ាងស្ងាត់ជំនាញ ហើយគិតថា ខ្ញុំចង់អាចធ្វើបែបនេះបានដែរ? បទពិសោធនោះគឺស្របតាមតន្ត្រីបង្ហាញ។ តន្ត្រីបង្ហាញមិនគួរត្រូវបានគេមើលឃើញថា ជាតន្ត្រីសម្តែង — ជាអ្វីដែលបង្ហាញជាចម្បងសម្រាប់ធ្វើឲ្យអ្នកដទៃរីករាយ — ទោះបីជាវាពិតជាអាចត្រូវបានរីករាយមែនក៏ដោយ។ ផ្ទុយទៅវិញ វាត្រូវតែត្រូវបានចាត់ទុកជាតន្ត្រីតំណាង ដែលថ្លែងចេញមកដើម្បីឲ្យគោលបំណង និងបំផុសការថ្វាយបង្គំព្រះរបស់ពួកគេ។*

ឆឺរី (Cherry) ដកស្រង់ស្រាប់យោងពី ជេមស៍ វ៉ាយថ៍ (James White) នៅក្នុងសេចក្តីសង្ខេបរបស់គាត់ អំពីតួនាទីរបស់ក្រុមចម្រៀង (ឬក្រុមផ្សេងទៀត) ក្នុងការថ្វាយបង្គំថាមានមុខងារបីយ៉ាង៖

១.ច្រៀងជូនក្រុមជំនុំ ដោយការរួមចំណែកក្នុងព័ន្ធកិច្ចនៃព្រះបន្ទូល

២.ច្រៀងសម្រាប់ក្រុមជំនុំក្នុងការថ្វាយនូវភាពល្អប្រពៃ និង
៣.ច្រៀងជាមួយក្រុមជំនុំក្នុងបទចម្រៀងក្រុមជំនុំនាំមុខ[២]

ខ្ញុំជឿថា បទបង្ហាញតន្ត្រីអាចនៅតែមានកន្លែងសំខាន់ក្នុងការថ្វាយបង្គំរួមគ្នា ប្រសិនបើប្រើដោយបេះដូង និងការយល់ដឹងត្រឹមត្រូវ។ នៅក្នុងគំរូរបស់ខ្ញុំអំពីការត្រាស់ហៅរបស់ព្រះមកលើជីវិតរបស់ខ្ញុំ ដោយពណ៌នាអំពីព្រះវិហារពីរនៅរដ្ឋតិចសាស់ អ្នកអាចមើលឃើញពីរបៀបដែលបទចម្រៀងបង្ហាញរបស់ក្រុមចម្រៀងអាចជាពេលវេលាដ៏ជ្រាលជ្រៅនៃការថ្វាយបង្គំសម្រាប់ក្រុមជំនុំ។.

**ប្រសិនបើក្រុមជំនុំរបស់អ្នកមានក្រុមចម្រៀង តើអ្នកត្រូវជួយពួកគេឲ្យយល់មុខងាររបស់ពួកគេ ហើយជួយពួកគេឲ្យក្លាយជាអ្នកបំផុសនៃការថ្វាយបង្គំដែរឬទេ?**

## ក្រុមរៀបចំផែនការថ្វាយបង្គំ

ការរៀបចំផែនការថ្វាយបង្គំមានវិមាត្រធំជាង នៅពេលអ្នកឲ្យអ្នកដទៃចូលទៅក្នុងដំណើរការរៀបចំផែនការ។ ក្រុមរៀបចំផែនការថ្វាយបង្គំ ឬក្រុមសិល្បៈថ្វាយបង្គំប្រកបដោយការច្នៃប្រឌិតគឺមានតម្លៃដ៏ធំធេង។

ការបង្កើតក្រុមរៀបចំផែនការថ្វាយបង្គំនឹងសម្រេចបាននូវកិច្ចការមួយចំនួនៈ

១. វានឹងផ្តល់នូវវេទិកាដ៏ល្អមួយសម្រាប់ការរៀបចំផែនការកម្មវិធីថ្វាយបង្គំដែលស្រូបទាញមនុស្សដែលមានកម្លាំង និងទេពកោសល្យផ្សេងៗ។
២. វានឹងជួយដល់អ្នកដឹកនាំការថ្វាយបង្គំបច្ចុប្បន្ន ដែលពីមុនបានដឹកនាំតែការថ្វាយបង្គំតាមបែបប្រពៃណីក្នុងការរៀបចំផែនការ និងដឹកនាំទម្រង់ថ្មីនៃការថ្វាយបង្គំ។
៣. វានឹងទាញយកអត្ថប្រយោជន៍ពីឃ្លាំងដ៏អស្ចារ្យនៃទេពកោសល្យច្នៃប្រឌិតនៅក្នុងសិល្បៈថ្វាយបង្គំដែលប្រហែលជាមិនត្រូវបានប្រើប្រាស់នាពេលបច្ចុប្បន្ននេះ។
៤. វានឹងផ្តល់នូវបទពិសោធន៍នៃការថ្វាយបង្គំពហុរសជាតិសម្រាប់ក្រុមជំនុំរបស់អ្នក។

---

២ James White, Introduction to Christian Worship, 3rd ed. (Nashville: Abingdon, 2000), 114.

៥. វានឹងបញ្ជូនការត្រឡប់ទៅក្រុមទាំងមូលជាជាងមនុស្សតែម្នាក់។

## ទស្សនៈទាន

ខ្ញុំនឹងបង្ហាញឧទាហរណ៍មួយដែលខ្ញុំបានប្រើនៅក្នុងព្រះវិហារដែលផ្តល់លទ្ធផលដ៏អស្ចារ្យ។ កែសម្រួលគំនិតទាំងនេះដើម្បីបំពេញតម្រូវការនៃក្រុមជំនុំរបស់អ្នក និងមនុស្សដែលអ្នកកំណត់ថា នឹងត្រូវក្លាយជាសមាជិកក្រុម។

ក្រុមអ្នកដឹកនាំការថ្វាយបង្គំនឹងជួបជារៀងរាល់សប្តាហ៍ ដើម្បីរៀបចំផែនការពេលវេលាថ្វាយបង្គំរួមគ្នា។ សមាជិកតំណាងឲ្យវិស័យសិល្បៈជាច្រើនដូចជាការសម្តែងរឿង ក្រាហ្វិក វីដេអូ ថតរូប រាំ និងសិល្បៈ។ វាក៏នឹងមានអ្នកបន្ថែមដែលមានសមត្ថភាពច្នៃប្រឌិត និងអ្នកភ្លេងពីរបីនាក់។ តាមឧត្តមគតិ គ្រូគង្វាលច្បងក៏នឹងជួបជាមួយក្រុមផងដែរ (ប្រសិនបើមិនមានដោយផ្ទាល់ទេ គាត់នឹងត្រូវផ្ញើព័ត៌មានលម្អិត)។ គាត់អាចចែករំលែកគំនិតរបស់គាត់ទាក់ទងនឹងសេចក្តីអធិប្បាយនាពេលខាងមុខ ឬទិសដៅពិសេសដែលគាត់ចង់ឃើញបញ្ចូលទៅក្នុងការថ្វាយបង្គំ។

ក្រុមការងារនឹងយកព័ត៌មាននេះ ហើយចាប់ផ្តើមបង្កើតគំនិតដើម្បីជះឥទ្ធិពលដល់ក្រុមជំនុំក្នុងការថ្វាយបង្គំដោយបញ្ចូលអារម្មណ៍។ ឧទាហរណ៍ បុគ្គលដែលមានភាពខ្លាំងក្នុងក្រុមអាចយល់ឃើញពីវិធីដ៏មានឥទ្ធិពលមួយ ក្នុងការបញ្ជូនសារតាមរយៈការសម្តែងរឿង។ អ្នកផ្សេងទៀតប្រហែលជាគិតអំពីវិធីមួយ ដើម្បីធ្វើឲ្យក្រុមជំនុំចូលរួម តាមរយៈរូបភាពនៅលើអេក្រង់ ឬកំណាព្យ ឬផ្លាស់ប្តូរកន្លែងថ្វាយបង្គំ ឧទាហរណ៍ ប្រសិនបើក្រុមកំណត់ថា នៅក្នុងកម្មវិធីមួយ៤សប្តាហ៍ចាប់ពីពេលនេះតទៅ យើងនឹងមានការសម្តែងរឿង ប្រើប្រាស់ក្រាហ្វិកដ៏មានអានុភាពនៅលើគម្របព្រឹត្តិបត្រ ហើយប្រើវីដេអូពីប្រភពផ្សេងទៀត នោះអ្នកដឹកនាំរឿងនឹងសរសេរដោយដៃ និងរៀបចំសាច់រឿងសម្រាប់កម្មវិធីថ្វាយបង្គំ។ អ្នកកាន់ក្រាហ្វិកនឹងរៀបចំការងាររបស់ពួកគេ។ មនុស្សម្នាក់ទៀតក៏នឹងទទួលខុសត្រូវចំពោះការធានាឲ្យបាននូវវីដេអូដើម្បីអាចប្រើប្រាស់បានផងដែរ។

អ្នកដឹកនាំ/គ្រូគង្វាលនឹងរៀបចំធាតុទាំងអស់នេះ ទៅក្នុងកម្មវិធីថ្វាយបង្គំសម្រាប់ថ្ងៃមួយនោះ។ ក្រុមរៀបចំផែនការថ្វាយបង្គំ (WPT) មួយចំនួនរៀបចំគម្រោងរាល់ព័ត៌មានលម្អិតនៃកម្មវិធី រួមទាំងតន្ត្រីផងដែរ។ អ្នកខ្លះទៀតទុកព័ត៌មានលម្អិតខ្លះដល់អ្នកដឹកនាំការថ្វាយបង្គំ។

ការប្រើវិធីបែបនេះនឹងទាក់ទាញមនុស្សដែលមានសមត្ថភាពច្នៃប្រឌិតមិនត្រឹម

តែអ្នកភ្លេងដើម្បីប្រើអំណោយរបស់ពួកគេសម្រាប់សិរីល្អរបស់ព្រះ និងក្រុមជំនុំ។

ស្វែងយល់ពីអ្នកណាដែលព្រះបានដាក់នៅក្នុងក្រុមជំនុំរបស់អ្នកដែលអ្នកអាចចូលរួមក្នុងវិធីនេះ ហើយជួយពួកគេបំពេញការត្រាស់ហៅក្នុងជីវិតរបស់ពួកគេដើម្បីប្រើប្រាស់អំណោយរបស់ពួកគេដើម្បីស្អាងក្រុមជំនុំឡើង។

**តើមានមនុស្សនៅក្នុងព្រះវិហាររបស់អ្នកដែលមានអំណោយទានប្រកបដោយការច្នៃប្រឌិតដែលអាចជួយឲ្យពេលវេលាការថ្វាយបង្គំរបស់អ្នកកាន់តែមានន័យ និងមានឥទ្ធិពលដែរឬទេ?**

## ការរក្សាតុល្យភាពខាងវិញ្ញាណ និងសេចក្ដីពិត

យើងទាំងអស់គ្នាសុទ្ធតែស្គាល់ការឆ្លើយតបរបស់ព្រះយេស៊ូវទៅកាន់ស្ត្រីនៅឯអណ្ដូងទឹក៖ តែនឹងមានពេលវេលាមក ក៏នៅតឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្ដីពិត ពីព្រោះព្រះវរបិតាទ្រង់រកពួកអ្នកយ៉ាងនោះ ឲ្យបានថ្វាយបង្គំទ្រង់ ២៤ ឯព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ និងសេចក្ដីពិតដែរ។ យ៉ូហាន ៤:២៣-២៤

តើយើងគួរមើលទៅលើពាក្យផ្ទុយគ្នានៃវិញ្ញាណ និងសេចក្ដីពិតយ៉ាងដូចម្ដេច? សូមពិចារណាវិធីទាំងនេះក្នុងការមើលវិញ្ញាណ និងសេចក្ដីពិត៖ ចិត្តធៀបនឹងគំនិត; អារម្មណ៍ធៀបនឹងបញ្ញា; គ្មានពាក្យសម្ដី ធៀបនឹងពាក្យសម្ដី; មិនអាចទាយទុកជាមុនបាន ធៀបនឹងអាចព្យាករណ៍បាន; និមិត្តរូប និងការច្នៃប្រឌិតធៀបនឹងរបៀបរៀបរយ និងតម្រង់ទិស។

ក្រុមជំនុំខ្លះទំនោរទៅខាងវិញ្ញាណ។ ការថ្វាយបង្គំជាទូទៅ ធ្វើឡើងដោយឯកឯង ហើយដឹកនាំដោយព្រះវិញ្ញាណ។ កម្មវិធីមានទំនោរទៅខាងរាងកាយ និងអារម្មណ៍។ មួយចំនួនខ្លះទៀតនៃក្រុមជំនុំទំនោរទៅខាងសេចក្ដីពិត។ នៅទីនេះការថ្វាយបង្គំកាន់តែមានរបៀបរៀបរយ និងរចនាសម្ព័ន្ធ។ ទំនៀមទម្លាប់នីមួយៗមានតម្លៃអស្ចារ្យផ្សេងគ្នា។

ប៉ុន្តែ ព្រះយេស៊ូវបានមានព្រះបន្ទូលថា អ្នកថ្វាយបង្គំដ៏ពិតត្រូវតែថ្វាយបង្គំដោយវិញ្ញាណ និងសេចក្ដីពិត មិនមែនមានតែមួយ ឬមួយផ្សេងទៀតនោះឡើយ។

ទំនៀមទម្លាប់ទាំងពីរនេះ បាត់សញ្ញានៃការថ្វាយបង្គំដូចដែលព្រះទ្រង់សព្វព្រះហឫទ័យឲ្យការថ្វាយបង្គំកើតឡើង។ ប្រសិនបើកម្មវិធីថ្វាយបង្គំរបស់យើងជាប់ក្នុងសេចក្តីពិតយើងត្រូវលាយបញ្ចូលវិញ្ញាណបន្ថែមទៀតទៅក្នុងពេលវេលាថ្វាយបង្គំរបស់យើង។

ខ្ញុំបានចូលរួមព័ន្ធកិច្ចនៅព្រះវិហារដែលទំនោរទៅខាងវិញ្ញាណ។ មានភាពឯកឯងច្រើន និងរចនាសម្ព័ន្ធតិចតួច។ នៅក្នុងព្រះវិហារទាំងនេះប្រហែលជាមិនមានការថ្វាយបង្គំដែលបានគ្រោងទុកទេ។ ការថ្វាយបង្គំហូរពីធាតុមួយទៅធាតុមួយទៀត នៅពេលអ្នកដឹកនាំដឹងពីចលនានៃព្រះវិញ្ញាណ។ មនុស្សនៅក្នុងទំនៀមទម្លាប់នេះជារឿយៗនឹងមើលរចនាសម្ព័ន្ធនៃក្រុមជំនុំ «សេចក្តីពិត» ហើយមានអារម្មណ៍ថាពួកគេបានបិទសមត្ថភាពនៃព្រះវិញ្ញាណបរិសុទ្ធដើម្បីធ្វើការនៅក្នុងកម្មវិធីថ្វាយបង្គំ។ ព្រះវិហារដែលមានរចនាសម្ព័ន្ធជាច្រើនតែមានអារម្មណ៍ថាក្រុមជំនុំ «វិញ្ញាណ» មិនបានផ្តល់ឲ្យបានល្អសម្រាប់ក្រុមជំនុំរបស់ពួកគេដោយមិនបានរៀបចំផែនការដោយប្រុងប្រយ័ត្ននូវបទពិសោធន៍នៃការថ្វាយបង្គំដើម្បីបំពេញតម្រូវការការបង្កើតសិស្ស និងការថ្វាយបង្គំរបស់ពួកគេ។

## ក្រុមទាំងពីរគឺសុទ្ធតែខ្វះខាតជាញឹកញាប់

សព្វថ្ងៃនេះនៅក្នុងផ្នែកជាច្រើននៃពិភពលោក ព្រះវិហារតែងតែកំណត់ពេលកម្មវិធីថ្វាយបង្គំរបស់ពួកគេដល់នាទីសម្រាប់ធាតុនីមួយៗនៃការថ្វាយបង្គំ។ បទចម្រៀងនេះត្រូវបានបែងចែក៥នាទី ៣០វិនាទី; ការអធិស្ឋាននេះត្រូវបានកំណត់ត្រឹមពីរនាទី។ វីដេអូនឹងដំណើរការ២:១៥។ល។ ប៉ុន្តែ តើមានអ្វីកើតឡើងនៅពេលដែលព្រះបង្ហាញនៅក្នុងវិធីដែលមិននឹកស្មានដល់? ប្រសិនបើកម្មវិធីថ្វាយបង្គំរបស់យើងត្រូវបានរៀបចំជាលើកទីពីរ តើយើងធ្វើដូចម្តេច ប្រសិនបើភ្លាមៗនោះអាសនៈកំពុងពេញដោយមនុស្សបង្ហូរដួងចិត្តរបស់ពួកគេ ចំពោះព្រះនៅពាក់កណ្តាលនៃបទចម្រៀងមួយ?

ចម្លើយគឺត្រូវរៀបចំផែនការឲ្យបានហ្មត់ចត់ និងត្រៀមខ្លួនរួចជាស្រេចដើម្បីបត់បែន។ នៅពេលយើងអធិស្ឋាន ហើយពឹងលើព្រះក្នុងដំណើរការរៀបចំផែនការនោះទ្រង់ពិតជាអាចដឹកនាំផែនការតាមដែលទ្រង់សព្វព្រះទ័យ។ បន្ទាប់មកនៅពេលយើងដឹកនាំក្នុងការថ្វាយបង្គំយើងត្រូវតែដឹងជានិច្ចនូវអ្វីដែលកំពុងកើតឡើងក្នុងចំណោមមនុស្ស។ តើផែនការរបស់យើងអាចជាឧបសគ្គចំពោះអ្វីដែលព្រះនឹងធ្វើចលនាទៅតាមរបៀបរបស់ទ្រង់ឬទេ? បើដូច្នេះតើខ្ញុំត្រូវធ្វើការផ្លាស់ប្តូរអ្វី?

ខ្ញុំបាននៅក្នុងកម្មវិធីថ្វាយបង្គំមួយកាលពីប៉ុន្មានឆ្នាំមុន ដែលបទចម្រៀងមួយត្រូវបានគ្រោងទុកដូចជា ការណែនាំវគ្គ បន្ទរ វគ្គ បន្ទរ ស្ពានចម្លង បន្ទរ បន្ទរ និងបញ្ចប់។ នៅលើការបន្ទរពីរចុងក្រោយមនុស្សបានមកអាសនាដោយឯកឯង ហើយស្រែកទៅកាន់ព្រះជាម្ចាស់។ ចាប់តាំងពីបទចម្រៀងកំពុងដំណើរការជាមួយនឹងបទគាំទ្រអ្នកដឹកនាំថ្វាយបង្គំបានអនុញ្ញាតឲ្យតន្ត្រីបញ្ចប់តាមការគ្រោងទុក ហើយពួកគេបានផ្លាស់ប្តូរដោយផ្ទាល់ទៅក្នុងពេលវេលានៃការប្រកាសទោះបីជាមនុស្សនៅតែនៅក្នុងអាសនាក៏ដោយ។ នេះគឺជាការមិនគួរឲ្យជឿ និងបង្ហាញពីភាពជាអ្នកដឹកនាំខ្សោយ និងខ្វះការធ្វើតាមការបំផុសគំនិតរបស់ព្រះវិញ្ញាណ។

យើងត្រូវការរចនាសម្ព័ន្ធ និងផែនការក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែយើងក៏ត្រូវការភាពបត់បែនក្នុងការផ្លាស់ប្តូរដែរនៅពេលយើងដឹងពីតម្រូវការ។ វាអាចមានន័យថាពង្រីកបទចម្រៀងបន្ថែមបទចម្រៀងមួយទៀតផ្លាស់ទីទៅពេលស្ងប់ស្ងាត់ពេលវេលានៃការអធិស្ឋាន ឬអ្វីផ្សេងទៀត។ នៅពេលពិសេសនោះសូមកុំឲ្យសកម្មភាពទំនួលខុសត្រូវ និងខ្សែសង្វាក់នៃផែនការថ្វាយបង្គំរបស់អ្នករារាំងអ្វីដែលកំពុងកើតឡើងនៅក្នុងចិត្តរបស់មនុស្ស។

ប្រហែលភាពបត់បែន និងភាពឯកឯងអាចជាការលំបាកសម្រាប់ក្រុមរបស់អ្នក។ នេះជាអ្វីដែលអ្នកត្រូវសាកល្បងជាប្រចាំក្នុងការហាត់សម។ ចេញពីផែនការដោយគ្មាននរណាម្នាក់ដឹង ហើយមើលថាតើមនុស្សមានប្រតិកម្មយ៉ាងណា។ និយាយអំពីរបៀបដែលអ្នកគ្រប់គ្នាអាចទទួលបានភាពងាយស្រួលជាមួយនឹងភាពឯកឯង។ ពេលដែលអ្នក «ហាត់សម» កាន់តែច្រើនឡើងៗពេលវេលានៃភាពឯកឯង ទោះទាំងក្រុមតន្ត្រីអ្នកចម្រៀង និងអ្នកបច្ចេកទេសរបស់អ្នកកាន់តែមានភាពងាយស្រួលនៅពេលដែលវាកើតឡើងនៅក្នុងការថ្វាយបង្គំ។

នៅពេលដែលខ្ញុំកំពុងដឹកនាំការថ្វាយបង្គំ នៅព្រះវិហារដែលមនុស្សគ្រប់គ្នាត្រូវការសរសេរតន្ត្រីសម្រាប់អ្វីៗដែលយើងបានធ្វើ (ផ្ទុយពីសមត្ថភាពក្នុងការលេងដោយត្រចៀកយ៉ាងងាយស្រួល) ជាញឹកញាប់ ខ្ញុំនឹងមានបទចម្រៀងបន្ថែមជាច្រើនដែលល្បីត្រៀមចេញជារៀងរាល់សប្តាហ៍ ប្រសិនបើយើង ត្រូវការដើម្បីផ្លាស់ប្តូរទៅបទចម្រៀងផ្សេងទៀត។ អ្នកដែលដំណើរការស្លាយទំនុកច្រៀងក៏បានរៀបចំបទចម្រៀងទាំងនោះដែរបើចាំបាច់។ វាបានផ្តល់ជម្រើសបន្ថែមជាច្រើនសម្រាប់ភាពឯកឯង ប្រសិនបើយើងមានអារម្មណ៍ថា ត្រូវការបទចម្រៀងមួយផ្សេងទៀតនៅពេលណាមួយ។ ប្រសិនបើអ្នកកំពុងប្រើការថតសម្លេងចម្រៀងទុកត្រៀមចាក់សម្លេងនោះជំនួសអ្នកត្រូវប្រាកដថា អ្នកដែលទទួលខុសត្រូវលើផ្នែកនោះគួរតែដឹង

ពីរបៀបដំណើរការឡើងវិញហើយត្រូវបញ្ចប់បទចម្រៀងឲ្យបានឆាប់ ដើម្បីចៀសវាងកុំឲ្យបន្តទៅបទចម្រៀងដែលមិនមាននៅក្នុងគម្រោងដើម។

ត្រូវដឹងដែរថា នៅក្នុងពេលវេលានៃភាពឯកឯងទាំងនេះ អ្នកប្រហែលជាមិនចាំបាច់ផ្លាស់ប្តូរទៅបទចម្រៀងថ្មី ឬបន្តទៅជាបទផ្សេងទៀតទេ។ ដូចដែលខ្ញុំបានលើកឡើងពីមុន វាអាចមានន័យថា យើងគួរតែផ្លាស់ទីទៅពេលវេលាស្ងប់ស្ងាត់ ពេលវេលានៃការអធិស្ឋាន ឬអ្វីផ្សេងទៀតវិញក៏បាន។

ទូលសុំព្រះធ្វើការនេះសម្រាប់អ្នក និងក្រុមរបស់អ្នកឲ្យមានភាពបត់បែនចំពោះការធ្វើការរបស់ទ្រង់ នៅក្នុងកម្មវិធីថ្វាយបង្គំរបស់អ្នក។ បន្ទាប់មក សូមបើកភ្នែកខាងវិញ្ញាណរបស់អ្នកគ្រប់ពេល ចំពោះអ្វីដែលកំពុងកើតឡើងក្នុងការថ្វាយបង្គំ។ កុំផ្តោតខ្លាំងលើផែនការដែលអ្នកកំពុងអនុវត្តក្នុងការថ្វាយបង្គំ ដែលធ្វើឲ្យអ្នកមិនអាចមើលឃើញនូវអ្វីដែលព្រះកំពុងធ្វើការ។

## យើងមិនគួរធ្វើឲ្យផលិតកម្មសំខាន់ជាងវត្តមានរបស់ព្រះនោះទេ

នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា ស្វែងរកព្រះហឫទ័យព្រះអម្ចាស់ (Desiring God) លោក ចន ផាបភ័រ (John Piper) សរសេរថា៖

> *ការថ្វាយបង្គំត្រូវតែមានសារៈសំខាន់ និងពិតប្រាកដនៅក្នុងចិត្ត ហើយការថ្វាយបង្គំត្រូវតែពឹងផ្អែកលើការយល់ឃើញពិតអំពីព្រះ។ ត្រូវតែមានវិញ្ញាណ ហើយត្រូវតែមានសេចក្តីពិត។ ... មានសេចក្តីពិតដែលគ្មានវិញ្ញាណ បង្កើតឲ្យមានការគោរពប្រតិបត្តិដែលស្លាប់ ហើយព្រះវិហារមានពេញ (ឬ ពេញពាក់កណ្តាល) នៃអ្នកសរសើរសិប្បនិម្មិត។ ... ម្យ៉ាងវិញទៀតមានអារម្មណ៍ថាមិនមានព្រះវិញ្ញាណបរិសុទ្ធ ហើយបង្កើតភាពច្របូកច្របល់ទទេ ហើយបណ្តុះមនុស្សរាក់កំផែល ដែលបដិសេធការប្រៀនប្រដៅនៃគំនិតដ៏ម៉ត់ចត់។ ប៉ុន្តែ ការថ្វាយបង្គំពិតកើតចេញពីមនុស្សដែលមានអារម្មណ៍ជ្រាលជ្រៅ ហើយស្រឡាញ់គោលលទ្ធិដ៏ជ្រាលជ្រៅ និងត្រឹមត្រូវ។ សេចក្តីស្រឡាញ់ដ៏ខ្លាំងចំពោះព្រះដែលចាក់ឫសក្នុងសេចក្តីពិត គឺជាឆ្អឹង និងខួរឆ្អឹងនៃការថ្វាយបង្គំតាមព្រះគម្ពីរ។*

ណាដែលអ្នកមានសុទ្ធតែសេចក្ដីពិត ហើយគ្មានវិញ្ញាណ នោះមនុស្សមានទំនោរប្រែក្លាយជារឹងស្ងួត

ទីណាដែលអ្នកមានសុទ្ធតែវិញ្ញាណ ហើយគ្មានសេចក្ដីពិត នោះមនុស្សមានទំនោរប៉ោងឡើង

ទីណាដែលអ្នកមានទាំងសេចក្ដីពិត និងវិញ្ញាណ នោះមនុស្សមានទំនោររីកលូតលាស់ឡើង។[៣]

តើការអនុវត្តជាក់ស្ដែងនៃការថ្វាយបង្គំរបស់អ្នកមានសភាពដូចម្ដេច?

**តើការអនុវត្តជាក់ស្ដែងនៃការថ្វាយបង្គំរបស់អ្នកមានសភាពដូចម្ដេច?**

## ការរៀបចំផែនការកម្មវិធីថ្វាយបង្គំ

វាត្រូវចំណាយពេលយូរបន្តិចដើម្បីទៅដល់ផ្នែកនៃសៀវភៅនេះ។ មុននឹងយើងអាចត្រូវបានគេទុកចិត្តឲ្យធ្វើផែនការនៃព័ន្ធកិច្ចនោះ យើងត្រូវយល់អំពីទិដ្ឋភាពគ្រឹះនៃការថ្វាយបង្គំដែលបានពិភាក្សាក្នុងជំពូកទីមួយ និងទីពីរ។ លើសពីនេះ គោលគំនិតដែលបង្ហាញក្នុងជំពូកនេះ គឺជាបណ្ដុំនៃការសាងសង់ក្នុងការរចនាបថកម្មវិធីថ្វាយបង្គំដែលនឹងធ្វើឲ្យក្រុមជំនុំរបស់អ្នកចូលរួមក្នុងការថ្វាយបង្គំ។

ខណៈដែលព្រះគម្ពីរមិនបានចែងច្បាស់ថាការថ្វាយបង្គំគួរមានលក្ខណៈយ៉ាងណានោះ មានការណែនាំសម្រាប់ដំណើរស្វែងរករបស់យើង។ លោក ស្ទីវិន ប្រូកស៍ (Steven Brooks) ចងក្រង «ភាពចាំបាច់» សម្រាប់ការថ្វាយបង្គំរួមគ្នានៃគម្ពីរសញ្ញាថ្មី៖

១. ការអានព្រះបន្ទូល (១ធីម៉ូថេ ៤:១៣-១៥)
២. ការអធិប្បាយ (កិច្ចការ ២:៤២; ១ធីម៉ូថេ ៤:១៣; ២ធីម៉ូថេ ៣:១៥-១៧; ៤:២)
៣. ការអធិស្ឋាន (១ធីម៉ូថេ ២:១; ១កូរិនថូស ១៤:១៦; ហេព្រើរ ៤:១៦; កិច្ចការ ១:១៤; ២:១; ៤:២៤, ៣២)
៤. ការច្រៀង (អេភេសូរ ៥:១៩; កូឡុស ៣:១៦; វិវរណៈ ៥:៩-១៣;

៣ I heard this in a sermon years ago, source unknown.

១៥:៣, ៤)
៥. ការរក្សាពិធីជ្រមុជទឹកទៀងទាត់ (ម៉ាថាយ ២៨:១៩, ២០; កិច្ចការ ២:៤១; ៨:១២, ៣៦-៣៨; ៩:១៨) និងពិធីលៀងព្រះអម្ចាស់ (កិច្ចការ ២:៤២; ១កូរិនថូស ១១:២៤-៣០)
៦. ការថ្វាយជាទៀងទាត់សម្រាប់កិច្ចការងារនៃព្រះបន្ទូល (១កូរិនថូស ១៦:២; ២កូរិនថូស ៩:៧)

ក្នុងនាមជាអ្នករៀបចំផែនការថ្វាយបង្គំ យើងត្រូវតែស្មោះត្រង់ក្នុងការរួមបញ្ចូលអ្វីៗទាំងអស់នេះនៅក្នុងពេលវេលានៃការថ្វាយបង្គំរួមរបស់យើង។

**ក្នុងនាមជាអ្នកដឹកនាំ/អ្នករៀបចំការថ្វាយបង្គំ យើងត្រូវកំណត់អត្តសញ្ញាណ និងលុបបំបាត់ការរំខានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីយើងអាចបង្កើតបរិយាកាសដែលជួយមនុស្សឲ្យភ្ជាប់ទំនាក់ទំនងជាមួយព្រះ។**

នៅពេលយើងចាប់ផ្តើមដំណើរការរៀបចំផែនការថ្វាយបង្គំយើងត្រូវអធិស្ឋានសុំព្រះឲ្យដឹកនាំយើងក្នុងការរៀបចំផែនការដើម្បីជួយយើងជ្រើសរើសបទចម្រៀងល្អបំផុតសម្រាប់ថ្ងៃនោះដើម្បីទាក់ទាញទៅផ្នែកផ្សេងទៀតនៃការថ្វាយបង្គំ ដើម្បីប្រើប្រាស់ក្នុងកម្មវិធីថ្វាយបង្គំ និងដើម្បីបង្កើតបរិយាកាសជួយមនុស្សឲ្យទទួលបទពិសោធន៍ពីព្រះក្នុងការថ្វាយបង្គំ។

ដោយអនុលោមច្របាច់បញ្ចូលគ្នា យើងចង់ពិចារណាទាញការថ្វាយបង្គំតាមបែបពិធីបុណ្យ និងតាមប្រធានបទដ៏ល្អបំផុត ខណៈពេលដែលរក្សាការសរសើរតម្កើងដោយសេរីចំពោះកម្មវិធីថ្វាយបង្គំ ដោយលុបបំបាត់គ្រាដែលឆ្គាំឆ្គង និងច្របូកច្របល់ (លុះត្រាតែព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំយើងឲ្យចូលទៅក្នុងបទពិសោធន៍ដែលមិនមានរបៀបរៀបរយបន្ថែមទៀត)។

មើលកម្មវិធីថ្វាយបង្គំជាបទពិសោធន៍តាំងពីដើមដល់ចប់ ប្រើតន្ត្រី សិល្បៈ ទីបន្ទាល់ ព្រះគម្ពីរ ការអធិស្ឋាន ពេលវេលានៃការធ្វើព័ន្ធកិច្ច និងអ្វីៗជាច្រើនទៀតដើម្បីជួយក្រុមជំនុំទទួលបទពិសោធន៍ពីព្រះក្នុងការថ្វាយបង្គំ។

## ជំហានទៅកាន់ការរៀបចំផែនការថ្វាយបង្គំ

នៅក្នុងផ្នែកដែលនៅសល់នៃជំពូកនេះ និងជំពូកបន្ទាប់ ខ្ញុំចង់បង្ហាញការណែនាំជាក់ស្តែងមួយ ដើម្បីជួយអ្នកផ្លាស់ទីកម្មវិធីថ្វាយបង្គំពីគំនិតទៅជាការអនុវត្ត ដោយមើលទៅយ៉ាងជិតស្និទ្ធលើផ្នែកជាច្រើន។ ផ្នែកនេះនឹងនិយាយអំពីការរៀបចំផែនការនៃកម្មវិធីថ្វាយបង្គំ ហើយជំពូកបន្ទាប់នឹងពិនិត្យមើលរបៀបអនុវត្តផែនការក្នុងការរៀបចំសម្រាប់ការថ្វាយបង្គំ។

ដោយសារក្រុមជំនុំភាគច្រើនមានមនុស្សពហុជំនាន់ ឬកំពុងឈានទៅរកភាពដូច្នេះ ខ្ញុំនឹងទទួលយកវិធីសាស្រ្តរបស់អ្នកដឹកនាំនៃក្រុមជំនុំបែបនេះជាមួយនឹងក្រុមចម្រៀង ក្រុមអ្នកភ្លេង (ដែលមើលទៅខុសគ្នាខ្លាំងពីព្រះវិហារមួយទៅព្រះវិហារទៀត) និងក្រុមអ្នកច្រៀង។ ជាការពិតណាស់ អ្នកអាចធ្វើការសម្របខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់អ្នក។

ក្នុងនាមជាអ្នកដឹកនាំការថ្វាយបង្គំ ការរៀបចំផែនការ ការហាត់សម និងការអនុវត្តការថ្វាយបង្គំ គឺជាកិច្ចការចម្បង។ ការរៀបចំទាំងអស់សម្រាប់ការថ្វាយបង្គំកើតឡើងចេញពីផែនការថ្វាយបង្គំដែលអ្នកបានបង្កើត។ នេះគឺជាជំហានមួយចំនួនដើម្បីបង្កើតផែនការកម្មវិធីថ្វាយបង្គំ៖

### ជួបជាមួយគ្រូគង្វាលរបស់អ្នក

នៅក្នុងការរៀបចំផែនការថ្វាយបង្គំ វាអាចមានអត្ថន័យច្រើនជាងសម្រាប់ផ្នែកខ្លះនៃការថ្វាយបង្គំ ដែលមិនមែនជាការអធិប្បាយ តែដើម្បីគាំទ្រសេចក្តីអធិប្បាយ។ យើងបាននិយាយអំពីរឿងនេះទាក់ទងនឹងទម្រង់នៃការថ្វាយបង្គំតាមប្រធានបទ។ វាអាចមានអត្ថន័យខ្លាំងណាស់ ប្រសិនបើធៀបនៃកម្មវិធីថ្វាយបង្គំមួយ ឬពីរភ្ជាប់ជាមួយនឹងការអធិប្បាយ ជាពិសេសប្រសិនបើអ្នកមានបទបង្ហាញណាមួយ។ លើសពីនេះ ប្រសិនបើអ្នកប្រើប្រាស់ក្រុមដឹកនាំការថ្វាយបង្គំ ហើយត្រូវរៀបចម្រៀង វីដេអូ ការអានផ្សេងៗជាដើម ច្រើនសប្តាហ៍អាចនឹងត្រូវបានទាមទារសម្រាប់ការរៀបចំ។ ដោយហេតុផលនេះ ការចាប់ផ្តើមដោយព័ត៌មានសេចក្តីអធិប្បាយជាច្រើនសប្តាហ៍ជាមុន នឹងជួយសម្រួលដល់ដំណើរការរៀបចំផែនការយ៉ាងសំខាន់ ដោយព្រោះធាតុមួយចំនួននៃការថ្វាយបង្គំត្រូវចំណាយពេលច្រើនក្នុងការរៀបចំ (ដូចជា តន្ត្រីបង្ហាញ ដូចជាការជ្រើសរើសក្រុមចម្រៀង វីដេអូដែលបង្កើតក្នុងស្រុក ការសម្តែងរឿង។ល។ គ្រូគង្វាលគួរតែឃើញអត្ថប្រយោជន៍ដ៏អស្ចារ្យនៃការផ្តល់ព័ត៌មាននោះនៅសប្តាហ៍ខាងមុខ នៅពេលដែលពេលវេលានៃ

ការថ្វាយបង្គំរួមគ្នាកាន់តែមានភាពទាក់ទាញ និងមានអត្ថន័យ។ គ្រូគង្វាល សូមផ្តល់ព័ត៌មានអធិប្បាយដល់អ្នកដឹកនាំការថ្វាយបង្គំរបស់អ្នក យ៉ាងហោចណាស់ពីរខែខាងមុខ ប្រសិនបើអាចធ្វើបាន។ បីខែ ឬច្រើនជាងនេះគឺជាគោលដៅ ហាលេលូយ៉ា!

ខ្ញុំដឹងថាវាគ្រាន់តែជាសុបិនសម្រាប់អ្នកដឹកនាំការថ្វាយបង្គំជាច្រើន។ មនុស្សជាច្រើនដែលខ្ញុំនិយាយជាមួយ មិនទាន់ទទួលបានការជូនដំណឹងជាមុនអំពីព័ត៌មានសេចក្តីអធិប្បាយ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យនិយាយជាមួយគ្រូគង្វាលរបស់អ្នកអំពីអត្ថប្រយោជន៍មួយចំនួននៃការអាចពង្រឹងសារ ហើយមើលថាតើគាត់នឹងមានបំណងបើកចំហក្នុងការជូនដំណឹងទុកជាមុនដែរឬទេ។ បើមិនដូច្នេះទេ កុំបារម្ភអ្នកនៅតែអាចបង្កើតកម្មវិធីថ្វាយបង្គំដ៏មានអានុភាពដោយមិនមានទំនាក់ទំនងតាមប្រធានបទ។

## ជ្រើសរើសចម្រៀងក្រុមចម្រៀង និងតន្ត្រីបទបង្ហាញផ្សេងទៀត

ការរៀបចំក្រុមចម្រៀង ក្រុមតន្ត្រី ឬអ្នកលេងភ្លេងគឺល្អបំផុត ដោយមានការជូនដំណឹងទុកជាមុន។ ខ្ញុំចូលចិត្តការចាប់ផ្តើមបទចម្រៀងក្រុមចម្រៀងថ្មីយ៉ាងហោចណាស់ ៦-៨ សប្តាហ៍មុនថ្ងៃអាទិត្យដែលបានកំណត់គោលដៅ។ រំពឹងគិតនៅលើព័ត៌មាននៃសេចក្តីអធិប្បាយ ដែលគ្រូគង្វាលរបស់អ្នកបានផ្តល់ និងស្វែងរកដោយអធិស្ឋានសម្រាប់តន្ត្រីបង្ហាញដែលនឹងគាំទ្រដល់ទិសដៅនៃសេចក្តីអធិប្បាយនោះ។ ជាការពិតណាស់ ពេលខ្លះអ្នកនឹងមិនធ្វើការតភ្ជាប់នោះ ឬអ្នកនឹងចូលចិត្តទៅទិសដៅផ្សេង។ ទោះយ៉ាងណាក៏ដោយ អ្នកត្រូវរៀបចំផែនការពី៦ទៅ៨សប្តាហ៍ខាងមុខ សម្រាប់ការរៀបចំដ៏សមស្រប ដែលនឹងផ្តល់លទ្ធផលល្អប្រសើរ។ (បន្ថែមទៀតនៅពេលយើងពិភាក្សាអំពីក្រុមចម្រៀង)។

## ឧបករណ៍រៀបចំផែនការថ្វាយបង្គំ

ស្វែងរកវិធីប្រើប្រាស់ឧបករណ៍អនឡាញ ដើម្បីចែករំលែកផែនការ និងធនធាននៃការថ្វាយបង្គំរបស់អ្នកជាមួយក្រុមរបស់អ្នក។ អ្នកអាចផ្ញើឯកសារ និងគម្រោងទៅពួកគេមុនពេលវេលា ដើម្បីជួយពួកគេក្នុងការរៀបចំ។

ជារឿយៗ ខ្ញុំចាប់ផ្តើមជាមួយឯកសារ ឬសៀវភៅបញ្ជីហើយបញ្ចូលព័ត៌មានពីសេចក្តីអធិប្បាយ កំណត់ចំណាំធាតុច្នៃប្រឌិតដែលអាចធ្វើបាន គំនិតតន្ត្រីធ្វើបទបង្ហាញដែលអាចកើតមាន និងច្រើនទៀត។ បន្ទាប់មក វាផ្តល់ផ្ទាំងឯកសារមួយដែលខ្ញុំអាចរៀបចំកម្មវិធីថ្វាយបង្គំបាន។

## ពិចារណាបទចម្រៀងក្នុងក្រុមជំនុំដែលសមរម្យពីបញ្ជីចម្រៀងរបស់អ្នក.

បន្ថែមពីលើទំនាក់ទំនងតុងសំខាន់ៗ អ្នកអាចបង្កើតទំនាក់ទំនងរវាងបទចម្រៀងតាមរយៈអត្ថបទ។ ខ្ញុំបានខ្ចីគំនិតទាំងនេះពី ដុនចាបមែន (Don Chapman) នៃ WorshipIdeas.com ។ នៅពេលដែលអ្នកអាចប្រើប្រាស់ការភ្ជាប់អត្ថបទ និងការតភ្ជាប់តន្ត្រីអ្នកបង្កើតការផ្លាស់ប្តូរដ៏មានឥទ្ធិពល។ សូមពិចារណាវិធីបន្ថែម ដើម្បីភ្ជាប់បទចម្រៀង៖

- ចំណាយពេលខ្លះដើម្បីសរសើរព្រះគុណនៃលក្ខណៈរបស់ព្រះ។
- មានបទចម្រៀងដែលផ្តោតលើការអធិស្ឋាន ការសារភាព ការអបអរសាទរ និងច្រើនទៀត។
- ជ្រើសរើសបទចម្រៀងដែលជួយក្រុមជំនុំរបស់អ្នកបញ្ចេញសំឡេងថ្វាយបង្គំរបស់ពួកគេ។

## ស្វែងរកធាតុច្នៃប្រឌិតនៃការថ្វាយបង្គំ

តើមានវិធីអ្វីខ្លះដែលអ្នកអាចធ្វើឲ្យកម្មវិធីថ្វាយបង្គំនេះកាន់តែមានជីវិតរស់រវើកសម្រាប់ក្រុមជំនុំ? ពិចារណាអំពីគំនិតច្នៃប្រឌិតនៅក្នុងព្រះវិហាររបស់អ្នក ដើម្បីបង្កើត និងផ្តល់ធាតុទាំងនេះសម្រាប់ការថ្វាយបង្គំ ដូចដែលបានពិភាក្សាជាមួយក្រុមរៀបចំការថ្វាយបង្គំ។ សូមចងចាំថា មានធាតុទាំងនេះជាច្រើននឹងត្រូវការពេលវេលារៀបចំជាច្រើនសប្តាហ៍។

## ត្រូវដឹងអំពីការរួមបញ្ចូលពិសេសណាមួយនៅក្នុងកម្មវិធីថ្វាយបង្គំ

នៅថ្ងៃអាទិត្យដែលបានកំណត់ អ្នកអាចមានពិធីលៀងព្រះអម្ចាស់ ពិធីបុណ្យជ្រមុជទឹក ឬពិធីពិសេសផ្សេងៗទៀត។ ទាំងអស់នេះអាចត្រូវការផ្នែកសំខាន់នៃកម្មវិធី។ ធាតុទាំងនេះគួរតែជាចំណុចសំខាន់ក្នុងការថ្វាយបង្គំរបស់អ្នក ជាជាងការដាក់ចុងដៃចុងជើងនៃកម្មវិធីថ្វាយបង្គំ។ ចាត់ទុកពិធីទាំងនោះសំខាន់តាមដែលគួរគប្បី។

## រៀបចំលំដាប់លំដោយនៃព្រឹត្តិការណ៍

ឥឡូវនេះ អ្នកបានប្រមូលធាតុថ្វាយបង្គំផ្សេងៗ នោះអ្នកនឹងចាប់ផ្តើមកម្មវិធីយ៉ាងពេញលេញ។ លំដាប់លំដោយដែលផ្នែកនីមួយៗ (ចម្រៀង ការអធិស្ឋាន ការអានព្រះគម្ពីរ ធាតុច្នៃប្រឌិត។ ចងចាំទំនាក់ទំនងសំខាន់ៗនៃបទចម្រៀងដែលអ្នកបានជ្រើសរើស ដើម្បីធានាបាននូវការផ្លាស់ប្តូរដោយរលូន។ កម្មវិធីថ្វាយបង្គំ

គួរជារឿងសមហេតុសមផលជាក់លាក់ មិនមែនជាការជ្រើសរើសរបស់របរដែលធូររលុងនោះទេ។

ខណៈពេលដែលមិនចាំបាច់ដូច្នោះរហូតនោះទេ ការអនុវត្តធម្មតាគឺត្រូវចាប់ផ្តើមជាមួយនឹងបទចម្រៀងថ្វាយបង្គំតាមក្រុមជំនុំដែលមានលក្ខណៈការសរសើរចង្វាក់លឿនៗ ដែលធ្វើការឆ្ពោះទៅរកតន្ត្រីថ្វាយបង្គំដ៏ស្ងប់ស្ងាត់ជាង និងស្និទ្ធស្នាលជាងមុននៅពេលខាងក្រោយក្នុងកម្មវិធីថ្វាយបង្គំ។ នេះធ្វើតាមគំរូនៃគម្ពីរសញ្ញាចាស់នៃការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ និងធ្វើឲ្យយល់បានតាមវិធីមួយផ្សេងទៀត។ នៅពេលដែលមនុស្សទើបតែមកដល់ដើម្បីថ្វាយបង្គំ ពួកគេច្រើនតែមិនត្រៀមខ្លួនដើម្បីចូលរួមយ៉ាងស្និទ្ធស្នាលក្នុងការថ្វាយបង្គំនៅខាងដើមដំបូងឡើយ ប៉ុន្តែត្រូវការពេលវេលាខ្លះដើម្បីផ្តោតគំនិត និងដួងចិត្តរបស់ពួកគេទៅរកព្រះ។ បទចម្រៀងដែលជួយប្រមូលផ្តុំមនុស្ស និងក្តីស្រឡាញ់របស់ពួកគេ គឺជាការចាប់ផ្តើមដ៏ល្អ។

យើងមិនចង់ឲ្យមានការទាយដឹងមុនបែបនេះទេ ដែលយើងប្រើលំដាប់លំដោយកម្មវិធីដូចគ្នាជារៀងរាល់សប្តាហ៍រួមជាមួយនឹងការរីកចម្រើននៃបទចម្រៀងដូចគ្នានោះទេ។ យើងចង់ដាស់ការស្រមើស្រមៃរបស់មនុស្សជានិច្ច ពេលយើងប្រកាសអំពីភាពអស្ចារ្យនៃព្រះរបស់យើងក្នុងការថ្វាយបង្គំ។ ព្យាយាមកុំឲ្យធ្លាក់លង់ទៅក្នុងការរៀបចំផែនការថ្វាយបង្គំ។ មានភាពច្នៃប្រឌិត។ ផ្លាស់ប្តូរអ្វីៗដែលចាំបាច់។

ការប្រកាសណែនាំភ្ញៀវរំខានដល់លំហូរនៃការថ្វាយបង្គំ។ ប្រកាសផ្សាយទៅកាន់វីដេអូ និងការទំនាក់ទំនងតាមឌីជីថល រួមទាំងបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម សន្លឹកព័ត៌មានដែលបានបោះពុម្ព។ល។ ផ្សាយតែសេចក្តីប្រកាសដំណឹងសំខាន់ៗ និងចាំបាច់បំផុតនៅដើម ឬចុងបញ្ចប់នៃកម្មវិធីថ្វាយបង្គំធ្វើដូច្នេះលំហូរនៃការថ្វាយបង្គំនឹងមិនត្រូវបានប៉ះពាល់ធ្ងន់ធ្ងរទេ។

## បង្កើតការផ្លាស់ប្តូរតន្ត្រី

កសាងស្ពានចម្លងនៃតន្ត្រីរវាងបទចម្រៀង (សូមមើលផ្នែក តំណភ្ជាប់បទចម្រៀងថ្វាយបង្គំ)។ វាជាការល្អបំផុតក្នុងការរក្សាលំហូរជាបន្តបន្ទាប់រវាងបទចម្រៀងជាឈុតមួយ។ ប្រសិនបើអ្នកបញ្ឈប់បទចម្រៀងភ្លាមៗ ការវិវត្តនឹងឈប់ ហើយត្រូវចាប់ផ្តើមម្តងទៀត។ មានពេលខ្លះដែលការផ្អាក ឬរង់ចាំគឺសមរម្យ ទោះយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរទាំងនេះគួរតែកម្រណាស់។ ដូចគ្នានេះផងដែរ រៀប

ចំផែនការផ្លាស់ប្តូររវាងធាតុនីមួយៗនៃកម្មវិធី។ ឧទាហរណ៍ កំណត់របៀបដែលអ្នកនឹងផ្លាស់ទីពីបទចម្រៀងបើកមួយ ទៅពេលអធិស្ឋាន និងទៅបទចម្រៀងមួយទៀត។

## ត្រួតពិនិត្យមាតិកា និងលំហូរ

ឥឡូវនេះ អ្នកមានកម្មវិធីថ្វាយបង្គំជិតចុងក្រោយបំផុតហើយ។ សូមចំណាយពេលខ្លះដើម្បីគិតតាមរយៈលំហូរនៃការថ្វាយបង្គំទាំងមូល ហើយពិចារណាថាតើធាតុនីមួយៗដែលអ្នកបានរួមបញ្ចូលនោះសមស្របកម្រិតណា។ សម្រាកហើយមើលលំហូរដោយក្រសែភ្នែកជាថ្មីនៅពេលក្រោយ។ សួរខ្លួនអ្នកថា «តើខ្ញុំនឹងផ្លាស់ទីពីធាតុមួយនោះ ទៅធាតុមួយបន្ទាប់ទៀតដោយរបៀបណា?» «តើខ្ញុំគួរដាក់ធាតុនោះមុន ឬក្រោយទៅក្នុងកម្មវិធី?» «តើមានបទចម្រៀងថ្មីៗច្រើនពេកទេ (មិនគួរលើសពីមួយទេ)?» «តើមានវគ្គអត្ថបទព្រះគម្ពីរច្រើនប្រភេទ និងធាតុផ្សេងទៀតដែលក្រុមជំនុំទាំងមូលពិបាកនឹងទាក់ទងជាមួយឬទេ? ប្រភេទនៃសំណួរទាំងនេះនឹងជួយអ្នកជួសជុលភាពទន់ខ្សោយដែលអាចកើតមាន។ អ្នកក៏នឹងយល់ថា វាមានប្រយោជន៍ក្នុងការដំណើរការឆ្លងកាត់ការផ្លាស់ប្តូរតន្ត្រីណាមួយ ដើម្បីពិនិត្យមើលថាតើវានឹងដំណើរការឬអត់ - ធ្វើការកែតម្រូវឲ្យបានឆាប់ជាមុន ជាជាងទុកបណ្តោយដល់យឺតពេល។

## វាយតម្លៃការចូលរួម

ជំហានចុងក្រោយគឺត្រូវវាយតម្លៃផែនការកម្មវិធីរបស់អ្នក តាមកម្រិតនៃការចូលរួមដែលនឹងត្រូវបានទាមទារពីអ្នកថ្វាយបង្គំ។ សូមចងចាំថា ការថ្វាយបង្គំមិនមែនជាកីឡាសម្រាប់អ្នកទស្សនាទេ ប៉ុន្តែជាព្រឹត្តិការណ៍ចូលរួមមួយ ដែលមនុស្សម្នាក់ៗចូលរួមចំណែកយ៉ាងពេញលេញ តាមដែលអាចធ្វើទៅបាន។ ចំណាយពេលខ្លះធ្វើការតាមផែនការ ដើម្បីកំណត់វិធីទាំងអស់ដែលមនុស្សនឹងចូលរួម។ យកធាតុផ្សំនៃការថ្វាយបង្គំនីមួយៗ ហើយសួរខ្លួនឯងអំពីរបៀបដែលអ្នកអាចប្រើវា ដើម្បីជួយសម្រួលដល់ការចូលរួមក្នុងក្រុមជំនុំ។ វានឹងរួមបញ្ចូលការរៀបចំបន្ថែមទៀតដើម្បីឲ្យអ្នកដទៃអាន ចែករំលែក ឬធ្វើសកម្មភាព ប៉ុន្តែនេះជាការចាំបាច់សម្រាប់ការថ្វាយបង្គំ ដើម្បីជាព្រឹត្តិការណ៍ដែលមានការចូលរួមយ៉ាងពិតប្រាកដ។

## ពេញមួយដំណើរការទាំងមូល សូមសហការជាមួយគ្រូគង្វាល

លើសពីរយៈពេលពីរសប្តាហ៍ទៀត ខ្ញុំចង់មានសេចក្តីព្រាងនៃកម្មវិធីថ្វាយបង្គំនេះរួចរាល់ ដើម្បីចែករំលែកជាមួយគ្រូគង្វាល។ យកល្អបំផុត អ្នកត្រូវប្រាស្រ័យទាក់ទងគ្នាជាបណ្តើរៗនៅពេលដែលរៀបចំកម្មវិធីមកជាមួយគ្នា។ នៅពេលនេះ សូមចែករំលែកនូវអ្វីដែលអ្នកបានរៀបចំឡើង ដើម្បីជាផែនការចុងក្រោយ ដើម្បីទទួលបានភ្លើងខៀវ ឬធ្វើការកែប្រែ មុនពេលបោះពុម្ពទៅក្រុមដែលនៅសល់របស់អ្នក។

## បង្ហើយផែនការកម្មវិធីឲ្យបានពីរសប្តាហ៍មុន

សម្រាប់មនុស្សមួយចំនួន ការអនុវត្តរបស់អ្នកប្រហែលជាត្រូវបង្ហើយផែនការកម្មវិធីថ្វាយបង្គំត្រឹមតែពីរបីថ្ងៃមុនថ្ងៃអាទិត្យ (ឬខ្លះទៀតថែមទាំងដល់យប់ថ្ងៃសៅរ៍!) យ៉ាងណាក៏ដោយ យើងត្រូវការពេលវេលាបន្ថែមទៀត ដើម្បីរៀបចំរួចរាល់ហើយធនធានដែលត្រៀមរួចជាស្រេចសម្រាប់ក្រុមរបស់អ្នក ដើម្បីមានពេលគ្រប់គ្រាន់សម្រាប់ហាត់មុនពេលហាត់សម។

ដូចដែលខ្ញុំបានលើកឡើង វាជាការល្អបំផុតក្នុងការធ្វើឲ្យផែនការរបស់អ្នកបានបង្កើតរយៈពេលពីរបីសប្តាហ៍មុន ដើម្បីឲ្យការរៀបចំទាំងអស់អាចដំណើរការបាន។ ធាតុច្នៃប្រឌិតជាច្រើន (ប្រសិនបើផលិតថ្មីដោយផ្ទាល់) និងតន្រ្តីបទបង្ហាញចាំបាច់ត្រូវរៀបចំផែនការយ៉ាងហោចណាស់ ៦-៨ សប្តាហ៍មុន ដើម្បីទទួលបានលទ្ធផលល្អបំផុត។ ក្នុងរយៈពេលពីរសប្តាហ៍ទៀត អ្នកនឹងបានបន្ថែមតន្រ្តីក្រុមជំនុំ និងធាតុផ្សេងទៀត ហើយបង្កើតលំហូរដ៏ល្អបំផុតសម្រាប់លំដាប់លំដោយនៃការថ្វាយបង្គំ។ នៅពេលដែលវាត្រូវបានបញ្ចប់ អ្នកអាចធ្វើជាការប្រាស្រ័យទាក់ទងទៅកាន់មនុស្សដែលកំណត់ពេលសម្រាប់កម្មវិធីនោះដោយអនុញ្ញាតឲ្យពួកគេដឹងថា ធនធានរបស់ពួកគេរួចរាល់ហើយ ដូច្នេះពួកគេអាចចាប់ផ្តើមរៀបចំបាន។

តឡូវនេះ អ្នកមានផែនការនៅនឹងកន្លែងហើយធនធានត្រូវបានរៀបចំ។ នៅក្នុងជំពូកបន្ទាប់ យើងនឹងពិនិត្យមើលរបៀបអនុវត្តផែនការនេះដោយរៀបចំក្រុមចម្រៀងរបស់អ្នក ក្រុមសំឡេង ក្រុមតន្រ្តី ក្រុមបច្ចេកវិទ្យា ក្រុមជំនុំ និងខ្លួនអ្នកផ្ទាល់។

# IV. ការរៀបចំខ្លួនសម្រាប់ការថ្វាយបង្គំ

ខ្ញុំមានឱកាសដ៏អស្ចារ្យក្នុងការបម្រើជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំបណ្ដោះអាសន្ន នៅព្រះវិហារដ៏អស្ចារ្យពីរបីឆ្នាំចុងក្រោយនេះ។ នៅពេលដែលខ្ញុំបានដឹកចូលជ្រៅទៅក្នុងការដឹកនាំ និងការគ្រប់គ្រងនៃព័ន្ធកិច្ចទាំងនោះ ខ្ញុំបានរកឃើញថា អ្វីដែលខ្ញុំកំពុងធ្វើ គឺស្មើនឹងភារកិច្ចរបស់អ្នកដឹកនាំការថ្វាយបង្គំដែលធ្វើការងារពីរក្នុងពេលតែមួយ ឬធ្វើការក្រៅម៉ោង។ ខ្ញុំមានការងារពេញម៉ោង ដែលមានការតម្រូវជាច្រើន រួមជាមួយនឹងការទទួលខុសត្រូវដ៏ធំក្នុងការដឹកនាំព័ន្ធកិច្ចថ្វាយបង្គំទាំងនេះ។ ខ្ញុំសូមនិយាយថា ខ្ញុំមានការគោរពយ៉ាងខ្លាំងចំពោះអ្នកដែលកំពុងបម្រើក្នុងការងារពីរក្នុងពេលតែមួយ ដែលត្រូវរុករកទំនួលខុសត្រូវក្នុងជីវិតទាំងអស់នោះ ជាមួយនឹងពេលវេលាមានកំណត់។

ជាលទ្ធផលក្នុងឱកាសនៃព័ន្ធកិច្ចទាំងនេះ ខ្ញុំបានពិនិត្យយ៉ាងដិតដល់នូវកិច្ចការដែលអ្នកដឹកនាំថ្វាយបង្គំត្រូវធ្វើរៀងរាល់សប្ដាហ៍ ដើម្បីរៀបចំផែនការ ការហាត់សម និងការអនុវត្តនូវការថ្វាយបង្គំប្រកបដោយឧត្ដមភាព។ នៅក្នុងជំពូកនេះ ខ្ញុំនឹងបង្ហាញការណែនាំជាក់ស្ដែងដែលអាចជួយអ្នកផ្លាស់ប្ដូរកម្មវិធីថ្វាយបង្គំពីគំនិតទៅជាការអនុវត្ត ដោយមើលយ៉ាងដិតស្និទ្ធលើផ្នែកជាច្រើន។

ដូច្នេះ ព្រះវិហារជាច្រើនសព្វថ្ងៃនេះ មានសមាជិកស្ថិតក្នុងជំនាន់ចម្រុះគ្នា ឬកំពុងស្វែងរកការបង្រួបបង្រួមក្នុងវិធីសាស្ត្ររបស់ពួកគេ ដូច្នេះ ខ្ញុំនឹងពិនិត្យមើលយ៉ាងដិតដល់នូវការរៀបចំការថ្វាយបង្គំដែលចាំបាច់សម្រាប់ព្រះវិហារដែលមានក្រុមចម្រៀង ក្រុមតន្ត្រី (ដែលមើលទៅខុសគ្នាខ្លាំងពីព្រះវិហារមួយទៅព្រះវិហារមួយ) និងក្រុមច្រៀង។ ជាការពិតណាស់ អ្នកអាចធ្វើការសម្របខ្លួនទៅតាមស្ថានភាពជាក់លាក់របស់អ្នក។ ព្រះវិហារនីមួយៗមានលក្ខណៈពិសេសរៀងៗខ្លួន ហើយខ្ញុំគិតថាអ្នកអាចសម្របខ្លួនតាមការកំណត់របស់អ្នកពីគោលការណ៍ដែលខ្ញុំនឹង

រៀបរាប់នៅក្នុងជំពូកនេះ។ ប្រសិនបើក្រុមជំនុំរបស់អ្នកមិនមានក្រុមចម្រៀងទេ អ្នកអាចរំលងទៅផ្នែកបន្ទាប់ដែលស្ដីពីការរៀបចំក្រុមតន្ត្រី និងក្រុមច្រៀង។

## ការរៀបចំក្រុមចម្រៀង

ក្រុមចម្រៀងអាចជាផ្នែកវិជ្ជមាននៃការផ្លាស់ប្ដូរក្នុងការថ្វាយបង្គំនៅក្នុងព្រះវិហារ។ សូម្បីតែនៅក្នុងរចនាបទការថ្វាយបង្គំសហសម័យក៏ដោយ ក៏ក្រុមចម្រៀងអាចជាកត្តាជំរុញដ៏ល្អសម្រាប់ការងើបឡើងវិញកម្មវិធីថ្វាយបង្គំ។ ជួនកាល ដូចដែលបានរៀបរាប់ពីមុន ក្រុមចម្រៀងដែលធ្វើការតាមប្រពៃណី ត្រូវរៀបចំឡើងវិញ ទៅជាក្រុមចម្រៀងនាំមុខកម្មវិធីថ្វាយបង្គំ។

គោលគំនិតនៅក្នុងផ្នែកនេះអាចលើសពីអ្វីដែលក្រុមចម្រៀងរបស់អ្នកមានក្នុងពេលបច្ចុប្បន្ន ប៉ុន្តែ វាអាចផ្ដល់នូវគំនិតមួយចំនួន សម្រាប់បង្កើតចក្ខុវិស័យនាពេលអនាគត។ ផ្នែកនេះគឺផ្អែកលើក្រុមចម្រៀងដែលខ្ញុំបានធ្វើការជាមួយនៅសហរដ្ឋអាមេរិក និងអាស៊ី។ ផ្នែកនេះជាការសន្មតថា អ្នកមានក្រុមចម្រៀងដែលច្រៀងជាទៀងទាត់ ក្នុងកម្មវិធីថ្វាយបង្គំ ហើយហាត់សមរាល់សប្ដាហ៍ក្នុងទំនួលខុសត្រូវជាអ្នកដឹកនាំរបស់ពួកគេ។

នៅក្នុងផ្នែកខាងក្រោម ខ្ញុំសន្មតថា ក្រៅពីដឹកនាំពួកជំនុំច្រៀងក្នុងកម្មវិធីថ្វាយបង្គំ ក្រុមចម្រៀងរបស់អ្នកក៏ច្រៀងបទចម្រៀងពិសេសជាក្រុមជាច្រើនសប្ដាហ៍ផងដែរ។ បទចម្រៀងពិសេសគឺជាបទចម្រៀង ដែលក្រុមចម្រៀងច្រៀងតែឯងដោយក្រុមជំនុំមិនច្រៀងជាមួយទេ—មនុស្សជាច្រើនហៅតន្ត្រីនេះថាបទចម្រៀងពិសេស។ (សូមមើលជំពូកមុន សម្រាប់ការស្វែងយល់បន្ថែមអំពីក្រុមចម្រៀងក្នុងកម្មវិធីថ្វាយបង្គំ)។

## ការកំណត់កាលវិភាគបទចម្រៀង

ដើម្បីឲ្យក្រុមចម្រៀងច្រៀងដោយមានទំនុកចិត្ត គេត្រូវស្គាល់បទចម្រៀងឲ្យបានច្បាស់។ ការចំណាយពេលពីរបីនាទីលើបទចម្រៀងជាច្រើនសប្ដាហ៍ជាប់ៗគ្នានឹងផ្ដល់លទ្ធផលល្អប្រសើរជាងការព្យាយាមរៀនមួយបទនៅក្នុងការហាត់សមម្ដងឬពីរដង។ គេអាចទន្ទេញបទចម្រៀងជាច្រើនឲ្យចាំមាត់ ប្រសិនបើមានពេលជាច្រើនសប្ដាហ៍សម្រាប់ការរៀបចំ (ដែលជាគោលដៅសក្ដិសមដើម្បីសាកល្បង)។ ជាការពិតណាស់ បទចម្រៀងដែលបានបង្ហាញកាលពីមុនអាចនាំយកមក ក្នុងការត្រៀមខ្លួន ដោយចំណាយពេលតិចជាងនេះ។ ជាធម្មតា បើសិនជាអាច ខ្ញុំលើក

ទឹកចិត្តឲ្យទន្ទេញបទចម្រៀងដែលបានច្រៀងជាលើកទីពីរហើយ ។ ការច្រៀងបទចម្រៀងដែលបានចាំស្ទាត់ មានឥទ្ធិពលខ្លាំងជាង ចំពោះការថ្វាយបង្គំ។

ចូរពិគ្រោះអំពីផែនការរៀបចំប្រធានបទអធិប្បាយព្រះបន្ទូល ក្នុងចន្លោះពីប្រាំបីទៅដប់ពីរសប្ដាហ៍បន្ទាប់ ប្រសិនបើអ្នកមាន។ សូមពិចារណាផងដែរ នូវចំណុចដែលត្រូវសង្កត់ធ្ងន់ជាពិសេស ឬចំណុចផ្សេងទៀតដែលត្រូវដាក់បញ្ចូល។ បន្ទាប់មក ចូរជ្រើសរើសបទចម្រៀងសម្រាប់ឲ្យក្រុមចម្រៀងច្រៀង ដែលសមរម្យសម្រាប់ច្រៀងពិសេសរាល់ថ្ងៃអាទិត្យ (ឧបមាថា ក្រុមចម្រៀងនោះត្រូវច្រៀងប្រចាំសប្ដាហ៍)។ ប្រសិនបើអ្នកមិនដឹងអំពីប្រធានបទនៃការអធិប្បាយព្រះបន្ទូលទេ អ្នកនៅតែអាចរៀបចំផែនការទុកជាមុន សម្រាប់ជាច្រើនសប្ដាហ៍បន្ទាប់ ដើម្បីរៀបចំបទចម្រៀងឲ្យបានល្អ។

ចូរប្រើបទចម្រៀងដែលធ្លាប់ស្គាល់រួចហើយ ឲ្យបានសមរម្យ ហើយណែនាំគេច្រៀងបទចម្រៀងថ្មីៗ។ ការផ្ដល់ឲ្យក្រុមចម្រៀងរបស់អ្នកនូវបទចម្រៀងថ្មីៗជាប្រចាំ គឺមានប្រយោជន៍ណាស់។ ពួកគេអាចមានអារម្មណ៍ធុញទ្រាន់ ប្រសិនបើអ្នកឲ្យពួកគេច្រៀងតែបទចាស់ដដែលៗ។ ចូរព្យាយាមពង្រីកបទពិសោធន៍របស់ពួកគេ ដោយរចនាបថថ្មី និងបញ្ហាប្រឈមថ្មី។ ការនេះនឹងជួយឲ្យការហាត់សមមានភាពស្រស់ស្រាយ និងគួរឲ្យរំភើបសម្រាប់ពួកគេ។ វាក៏ជាការប្រសើរផងដែរ ដែលយើងរួមបញ្ចូលបទចម្រៀងដែលបានប្រើកាលពីមុន ដែលក្រុមជំនុំប្រហែលជាធ្លាប់ស្គាល់ ហើយអ្នកអាចឈានទៅដល់កម្រិតថ្មីមួយនៃតន្ត្រី និងការទន្ទេញចងចាំ។

ចូរបង្កើតកាលវិភាគសម្រាប់កំណត់បទចម្រៀងដែលបានជ្រើសរើសសម្រាប់កម្មវិធីថ្វាយបង្គំនៅសប្ដាហ៍នីមួយៗ ដែលក្រុមចម្រៀងនឹងច្រៀងសម្រាប់រយៈពេលប្រាំបីសប្ដាហ៍បន្ទាប់ ឬយូរជាងនេះ។ ខ្ញុំចូលចិត្តប្រើតារាងសម្រាប់ការធ្វើកាលវិភាគ ដើម្បីជួយក្នុងការរៀបចំផែនការរបស់ខ្ញុំ។

## ការថតសំឡេងសម្រាប់អនុវត្ត

ការថតសំឡេងសម្រាប់អនុវត្ត អាចមានការពិបាកផ្នែកបច្ចេកទេសសម្រាប់អ្នកខ្លះ ប៉ុន្តែ ប្រហែលជាមាននរណាម្នាក់ ក្នុងពួកជំនុំអ្នកអាចថតសំឡេងនោះបាន។ អ្នកបោះពុម្ពផ្សាយជាច្រើនកំពុងផ្ដល់ឲ្យនូវសំឡេងថតសម្រាប់អ្នក។ ក្រុមចម្រៀងរបស់អ្នកនឹងឡើងថ្នាក់កាន់តែខ្ពស់មួយកម្រិតទៀត បើសិនជាអ្នកផ្ដល់ឲ្យពួកគេ នូវសំឡេងដែលបានថត សម្រាប់ប្រើនៅក្រៅម៉ោងហាត់សម ដែលផ្ដោតជាពិសេសទៅលើផ្នែកដែលពួកគេត្រូវច្រៀង។ ពេលវេលាដែលយើងមានជាមួយ

គ្នាប្រចាំសប្តាហ៍ មានតម្លៃ និងមានកំណត់។ ការដែលសមាជិកក្រុមចម្រៀងរបស់អ្នកស្តាប់សំឡេងថតទាំងនោះ ខណៈពេលដែលពួកគេបើកបរ ធ្វើការ និងលេងកីឡា អាចជួយពួកគេចេះបទចម្រៀងនោះកាន់តែច្បាស់។ តាមរយៈវិធីសាស្ត្រនេះ អ្នកអាចធ្វើកិច្ចការផ្នែកតន្ត្រីជាច្រើនទៀត ក្នុងការហាត់សម និងជំរុញពួកគេឲ្យធ្វើលើសអ្វីដែលមានស្រាប់។ សំឡេងថតទាំងនោះក៏មានប្រយោជន៍យ៉ាងខ្លាំងដល់ការទន្ទេញបទចម្រៀង។ ខ្ញុំបានចែករំលែកសំឡេងថតជាមួយអ្នកភ្លេង ប៉ុន្មានសប្តាហ៍មុនពេលយើងចាប់ផ្តើមប្រគំបទចម្រៀងនោះ។

ខ្ញុំមានសមាជិកក្រុមជាច្រើនអរគុណខ្ញុំ សម្រាប់សំឡេងថតទាំងនោះ។ ពួកគេស្តាប់សំឡេងថតទាំងនោះ ខណៈពេលដែលពួកគេកំពុងធ្វើសកម្មភាពផ្សេងៗប្រចាំថ្ងៃ។ ពួកគេប្រាប់ខ្ញុំថា ពួកគេបានថ្វាយបង្គំព្រះដោយចិត្តឆេះឆួលប៉ុណ្ណា ខណៈពេលដែលពួកគេស្តាប់សំឡេងថតទាំងនោះ។ ក្នុងការចែករំលែកសំឡេងថតទាំងនេះ អ្នកមិនគ្រាន់តែបានជួយពួកគេរៀនបទចម្រៀងនោះប៉ុណ្ណោះទេ តែអ្នកក៏ជួយពួកគេតភ្ជាប់ចិត្តជាមួយបទភ្លេង និងបទចម្រៀងក្នុងការថ្វាយបង្គំផ្ទាល់ខ្លួន បានជាពួកគេអាចច្រៀងបានល្អ ក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំ ដោយសារការចំណាយពេលត្រៀមខ្លួនបានល្អ។

## ផែនការហាត់សម

នៅពេលដែលអ្នកបានរៀបកាលវិភាគ សម្រាប់បទចម្រៀង និងថតសម្លេងច្រៀងរួចហើយ អ្នកចាំបាច់ត្រូវគិតគូរពីការរៀបចំផែនការសម។ ដូចដែលខ្ញុំបាននិយាយមុននេះ ក្រុមចម្រៀងរបស់អ្នកនឹងរៀនបានបន្ថែមទៀត ពីការសមបទចម្រៀងរយៈពេលប្រាំមួយសប្តាហ៍ដោយប្រើរយៈពេល១០នាទី ក្នុងពេលសមម្តងៗ បន្ទាប់មកត្រូវសម៦០នាទីក្នុងពេលសមមួយលើក។

នេះគឺជាគោលការណ៍ណែនាំមួយចំនួនសម្រាប់ការធ្វើផែនការរបស់អ្នក៖

- **សូមមើលកាលវិភាគបទចម្រៀងរបស់អ្នក ហើយបន្ទាប់មករៀបផែនការចាប់ផ្តើមហាត់ច្រៀងបទចម្រៀងមួយរយៈពេលបួន ឬច្រើនសប្តាហ៍ មុនសប្តាហ៍ដែលអ្នកនឹងច្រៀងបទនោះ។** ការនេះប្រហែលជាខុសពីការយល់ដឹងរបស់អ្នកក្នុងពេលបច្ចុប្បន្ន ប៉ុន្តែ បទចម្រៀងសម្រាប់ថ្ងៃអាទិត្យបន្ទាប់ គួរតែជាបទដែលអ្នកបានសិក្សាទាំងស្រុង និងត្រៀមជាស្រេច មុនពេលដែលអ្នកសមចុងក្រោយនោះ។ កំរិតនៃការលំបាករបស់បទចម្រៀងនឹងកំណត់ថាតើត្រូវការពេលប៉ុន្មានសប្តាហ៍ និងត្រូវលះបង់ពេលច្រើនប៉ុណ្ណា សម្រាប់តន្ត្រីក្នុងមួយសប្តាហ៍។ បទចម្រៀងមួយចំនួន នឹងត្រូវការពេលច្រើនជាងប្រាំមួយ

សប្តាហ៍ ដើម្បីឲ្យបានល្អតតខ្ទេះ។ ការនេះប្រហែលជាការផ្លាស់ប្តូរវប្បធម៌នៃការធ្វើការដ៏សំខាន់មួយសម្រាប់ក្រុមរបស់អ្នក។

- **នៅពេលដែលអ្នកកំពុងសមបទចម្រៀងជាច្រើនសប្តាហ៍ទុកជាមុន ការនេះធ្វើឲ្យគេមានអារម្មណ៍ថា ការហាត់សមមានសារៈសំខាន់ប៉ុណ្ណា។** ជារឿយៗខ្ញុំឮគេនិយាយអំពីសមាជិកក្រុមចម្រៀងដែលនឹងមិនមកសមនៅសប្តាហ៍មុនពេលថ្ងៃអាទិត្យដែលពួកគេនឹងអវត្តមាន ដោយសារពួកគេមានអារម្មណ៍ថាការហាត់សមនោះមិនចាំបាច់។ ពេលវេលាសមតិចតួចយ៉ាងខ្លាំង គួរតែត្រូវបានប្រើសម្រាប់បទចម្រៀង ដែលបានគ្រោងទុកសម្រាប់ការថ្វាយបង្គំនាពេលខាងមុខ។ ការនេះបង្ការមិនឲ្យមានអ្នកគេចម៉ោងហាត់សម ដោយលើកហេតុផលថា ពួកគេនឹងអវត្តមាននៅថ្ងៃអាទិត្យ។ ព្រោះការនេះអាចផ្តល់ភាពងាយស្រួលដល់ពួកគេក្នុងការហាត់សម ទោះពួកគេនឹងអវត្តមាននៅថ្ងៃអាទិត្យក៏ដោយ។ ប្រសិនបើពួកគេចូលរួមការសមជាទៀងទាត់ នោះពួកគេនឹងបានចំណាយពេលជាមួយបទចម្រៀងទាំងអស់ក្នុងអំឡុងពេលសមជាច្រើនដង។
- **បទចម្រៀងដែលក្រុមចម្រៀងបានច្រៀងពីមុន នឹងមិនត្រូវការពេលវេលាសមច្រើនទេ។ សូមហាត់បទចម្រៀងទាំងនោះឲ្យចាំស្ទាត់។** អ្នកអាចខិតខំដើម្បីឈានដល់កំរិតដែលល្អប្រសើរ និង/ឬ ទន្ទេញចាំបទចម្រៀងដែលធ្លាប់ស្គាល់។ ការនេះនឹងជួយឲ្យបទចម្រៀងមានឥទ្ធិពលកាន់តែខ្លាំង។
- ចូរចាប់ផ្តើមការហាត់សមជាមួយដោយចំណាយពេលថ្វាយបង្គំ ដោយប្រើបទចម្រៀងសម្រាប់នាំក្រុមជំនុំច្រៀងក្នុងកម្មវិធីថ្វាយបង្គំនៅសប្តាហ៍នេះ ពុំនោះទេ ប្រសិនបើបទចម្រៀងថ្មីៗនឹងមកដល់ក្នុងពេលឆាប់ៗនេះ ចូរចាប់ផ្តើមច្រៀបបទទាំងនោះក្នុងការហាត់សមឲ្យបានមួយឬពីរសប្តាហ៍មុន។ ការធ្វើដូចនេះអនុញ្ញាតឲ្យក្រុមចម្រៀងរបស់អ្នកត្រៀមខ្លួនបានប្រសើរជាងមុន សម្រាប់ការដឹកនាំក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំ។ ភារកិច្ចជាបឋមរបស់ក្រុមចម្រៀង គឺមិនមែនធ្វើជាក្រុមសម្តែងទេ ប៉ុន្តែជាក្រុមដែលដឹកនាំការថ្វាយបង្គំ គឺជាកងទ័ពនៃការសរសើរដំកើងព្រះ។
- នៅពេលដែលអ្នកចំណាយពេលផ្ទាល់ខ្លួនច្រៀងបទចម្រៀងសម្រាប់នាំក្រុមជំនុំច្រៀងហើយ ចូរឲ្យក្រុមចម្រៀងច្រៀងបទទាំងនោះធ្វើការហាត់សមសម្រាប់កម្មវិធីថ្វាយបង្គំសប្តាហ៍នេះ។ ប្រសិនបើការសមបានដំណើរការដូចការព្យាករ អ្នកមិនចាំបាច់ត្រូវចំណាយពេលច្រើនលើបទចម្រៀងនេះទេ។

ភាគច្រើន អ្នកគួរកែតម្រូវតែពីរបីចំណុចប៉ុណ្ណោះ។

- បន្ទាប់មក ចូររៀនបទចម្រៀងថ្មី ឬមួយបទដែលទាមទារឲ្យមានការប្រឹងប្រែងខ្លះ ខណៈដែលក្រុមចម្រៀងរបស់អ្នកកំពុងផ្ដោតអារម្មណ៍បានល្អ។
- ចូរកុំមានអារម្មណ៍ថា អ្នកត្រូវហាត់បទចម្រៀងទាំងមូលជារៀងរាល់សប្ដាហ៍។ អ្នកអាចផ្ដោតតែមួយផ្នែក ឬពីរផ្នែកនៃបទចម្រៀងនោះក្នុងសប្ដាហ៍នេះក៏បាន។ បន្ទាប់មក នៅសប្ដាហ៍ក្រោយអ្នកអាចបន្ថែមមួយផ្នែកទៀត ហើយពិនិត្យមើលការងារកាលពីសប្ដាហ៍មុន។ ជារឿយៗ យើងខ្ជះខ្ជាយពេលវេលាដោយគ្រាន់តែច្រៀងចម្រៀងពីដើមដល់ចប់ជារៀងរាល់សប្ដាហ៍ ដោយមិនផ្ដោតទៅលើផ្នែកផ្សេងៗនៃបទចម្រៀងនោះទេ។
- ត្រូវជួយក្រុមចម្រៀងឲ្យចេះកំណត់ចំណាំ ដូចជាត្រង់ផ្នែកដែលច្រំដែលជាជំនួយដល់ការរៀនច្រៀង។ ជាពិសេស ការច្រៀងឲ្យចាំមាត់ក៏មានប្រយោជន៍ដែរ។ ឧទាហរណ៍ ចូរចង្អុលបង្ហាញថា វគ្គបន្ទរទីពីរមានលក្ខណៈដូចវគ្គបន្ទរទីមួយលើកលែងតែខ្ទាតចង្វាក់ភ្លេងពីរចុងក្រោយ។ ការនេះតម្រូវឲ្យយើងជាអ្នកដឹកនាំ ស្គាល់បទចម្រៀងឲ្យបានច្បាស់ ហើយក៏ជួយពួកគេឲ្យឆាប់ចេះបទនោះដែរ។

## ការច្រៀងចេញពីការចងចាំ

ខ្ញុំបានធ្វើការជាមួយក្រុមចម្រៀងជាច្រើន ដែលមិនជឿថាខ្លួនអាចទន្ទេញចាំបទចម្រៀង ឬមើលឃើញតម្លៃពិតប្រាកដណាមួយនៅក្នុងបទនោះ។ ការចាប់ផ្ដើមដោយបទចម្រៀងដែលពួកគេចេះច្បាស់ស្រាប់ គឺមិនធ្វើឲ្យស្មុគស្មាញជាចំណុចចាប់ផ្ដើមដ៏ល្អ។ ចូរយកម្ដងមួយវគ្គៗ ដូចជាវគ្គបន្ទរ ហើយឲ្យក្រុមចម្រៀងច្រៀងវាជាលើកដំបូងជាមួយនឹងភ្លេង បន្ទាប់មកច្រៀងបទនោះតាមការចងចាំ។ ចូរបន្តទៅផ្នែកផ្សេងទៀតដែលដូចគ្នាបេះបិទ (វគ្គបន្ទរមួយទៀត) ឬស្រដៀងគ្នាខ្លាំង (ប្រហែលហាម៉ូនីនៃវគ្គបន្ទរនេះមានខ្ទាតចង្វាក់ភ្លេងខុសគ្នាតែបន្តិចបន្តួច) ហើយជួយពួកគេឲ្យឃើញភាពខុសគ្នានោះ ហើយបន្ទាប់មកច្រៀងផ្នែកនោះតាមការចងចាំ។ អ្នកអាចបន្ថែមផ្នែកផ្សេងនៅសប្ដាហ៍ក្រោយ ដោយពិនិត្យមើលការងារកាលពីសប្ដាហ៍មុន ហើយដាក់ផ្នែកទាំងពីរបញ្ចូលគ្នា។ មិនយូរប៉ុន្មាន អ្នកនឹងចាំបទចម្រៀងទាំងមូល។ ដំណើរការនេះនឹងកាន់តែលឿន ប្រសិនបើពួកគេមានសម្លេងចម្រៀងដែលបានថត សម្រាប់ស្ដាប់ជាជំនួយ។ នៅពេលដែលពួកគេច្រៀងតាមការចងចាំក្នុងកម្មវិធីថ្វាយបង្គំ ពួកគេនឹងបានដកពិសោធន៍នឹងសេរីភាពក្នុងការដឹក

នាំ ក៏ដូចជាដកពិសោធនឹងការប៉ះពាល់ចិត្តដោយអត្ថន័យនៃបទចម្រៀង ដែលពួកគេដឹកនាំច្រៀងនោះដោយមិនមានការរំខានពីក្រដាសចម្រៀង។

នៅពេលដែលក្រុមចម្រៀងរបស់អ្នកចាប់ផ្តើមដកពិសោធន៍នឹងការច្រៀងតាមការចងចាំ អ្នកនឹងឃើញថា វាកាន់តែងាយស្រួល ហើយពួកគេកាន់តែបើកចំហចំពោះការច្រៀងតាមការចងចាំ។ ដូចដែលបានរៀបរាប់ខាងលើ ជាលើកដំបូងដែលអ្នកច្រៀងចម្រៀងក្នុងការថ្វាយបង្គំ អ្នកប្រហែលជាចង់ធ្វើវាជាមួយនឹងតន្ត្រី។ លើកក្រោយ អ្នកអាចចំណាយពេលសមបន្ថែមទៀត ដើម្បីទន្ទេញឲ្យចាំ និងចេះច្រៀងស្ទាត់។ ការច្រៀងតាមការចងចាំ នឹងនាំមកនូវអត្ថប្រយោជន៍ច្រើនណាស់!

## ក្រដាសចម្រៀងសម្រាប់ហាត់សម

ចូរបោះពុម្ពក្រដាសចម្រៀងតែម្ខាង ឬទាំងសង្ខាងដែលក្រុមចម្រៀងអាចរើសយកនៅពេលពួកគេចូលសម។ ការនេះនឹងជួយឲ្យការសមកាន់តែរលូន និងផ្តល់ព័ត៌មានបន្ថែម។ ចូររាប់បញ្ចូលធាតុផ្សំជាច្រើននៅលើទំព័រនោះ៖

- **លំដាប់លំដោយនៃការសម**
  ខ្ញុំរាយបញ្ជីចម្រៀងសម្រាប់នាំក្រុមជំនុំច្រៀង និងបទចម្រៀងរបស់ក្រុមចម្រៀង ដែលយើងត្រូវសមតាមលំដាប់លំដោយដែលយើងនឹងត្រូវសម។ តាមវិធីនេះពួកគេអាចទទួលបានតន្ត្រីរបស់ពួកគេតាមលំដាប់លំដោយនៅពេលពួកគេមកដល់។ វាជួយសន្សំសំចៃពេលវេលាយ៉ាងច្រើនណាស់ ដោយគេមិនពិបាកស្វែងរកបទចម្រៀងក្នុង "សៀវភៅគម្របពណ៌ស្វាយ" នៅពាក់កណ្តាលពេលនៃការសម - អ្នកដឹងពីអ្វីដែលខ្ញុំចង់មានន័យហើយ។ វាក៏អនុញ្ញាតឲ្យក្រុមរបស់អ្នកដឹងថា អ្នកបានរៀបចំផែនការដើម្បីប្រើប្រាស់ពេលវេលារបស់ពួកគេបានល្អ។ ខ្ញុំក៏បញ្ចូលកាលបរិច្ឆេទ នៅក្បែរចំណងជើងបទចម្រៀង ដើម្បីឲ្យពួកគេអាចតាមដានកាលបរិច្ឆេទដែលបទចម្រៀងនឹងត្រូវច្រៀងក្នុងកម្មវិធីថ្វាយបង្គំ។

- **ទំនុកច្រៀងរបស់ចម្រៀងសម្រាប់ក្រុមជំនុំច្រៀង**
  បទចម្រៀងដែលយើងនឹងច្រៀងក្នុងការថ្វាយបង្គំត្រូវបានបោះពុម្ពនៅលើសន្លឹកនេះ ដើម្បីនាំក្រុមជំនុំច្រៀងជាមួយយើង។ សូមបញ្ចូលព័ត៌មានរក្សាសិទ្ធិនៅកន្លែងដែលអាចអនុវត្តបាន។ ការនេះអាចមានប្រយោជន៍យ៉ាងខ្លាំងដល់

ការជញ្ជឹងគិតព្រះបន្ទូលប្រចាំថ្ងៃ នៅពេលដែលសមាជិកក្រុមចម្រៀង យកក្រដាសចម្រៀងទាំងនោះទៅផ្ទះ ហើយជញ្ជឹងគិតអំពីអត្ថបទរបស់ចម្រៀងទាំងនោះ ក្នុងការចំណាយពេលថ្វាយបង្គំផ្ទាល់ខ្លួន។

- **ការប្រកាសដំណឹងអំពីការសម**

  ការប្រកាសនេះត្រូវរាប់បញ្ចូលកម្មវិធីពិសេសការសមបន្ថែម ការផ្លាស់ប្តូរពេលវេលាសមជាដើម។ ចូរផ្សព្វផ្សាយគេហទំព័ររៀបចំការថ្វាយបង្គំរបស់អ្នក និងគេហទំព័ររបស់ព័ន្ធកិច្ចថ្វាយបង្គំប្រសិនបើអាច។ ខ្ញុំនឹងចែករំលែកបន្ថែមអំពីរឿងទាំងនេះនៅពេលក្រោយ។

## ការបង្កើតសិស្ស

ការបង្កើតសិស្សគឺជាផ្នែកមួយដ៏សំខាន់ ប្រហែលជាផ្នែកដ៏សំខាន់បំផុតនៃការរៀបចំក្រុមចម្រៀង។

ទំនួលខុសត្រូវដ៏សំខាន់មួយរបស់អ្នកដឹកនាំការថ្វាយបង្គំ គឺការបង្កើតសិស្ស។ នៅក្នុងការសមបទចម្រៀងដែលក្រុមច្រៀងត្រូវច្រៀង ចូរធ្វើឲ្យទំនុកច្រៀងមានភាពរស់រវើកឡើង។ អ្នកត្រូវជួយពួកគេឲ្យយល់អំពីមូលដ្ឋានគ្រឹះនៃព្រះគម្ពីរ។ ហើយត្រូវជួយពួកគេភ្ជាប់ទីបន្ទាល់របស់ពួកគេជាមួយនឹងទីបន្ទាល់នៃបទចម្រៀង។ អ្នកត្រូវជួយពួកគេឲ្យយល់ពីអ្វីដែលពួកគេកំពុងច្រៀង។ វានឹងធ្វើឲ្យមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង នៅក្នុងការឡើងច្រៀងនៅថ្ងៃអាទិត្យ នៅពេលដែលបទចម្រៀងមានការទាក់ទងនឹងជីវិតរបស់ពួកគេ ទាំងខាងផ្លូវចិត្ត ខាងវិញ្ញាណ និងបញ្ញា។ ជារឿយៗ យើងមានអារម្មណ៍ថា មានសម្ពាធខ្លាំងចំពោះពេលវេលា ដែលយើងមិនចំណាយសម្រាប់រឿងនេះ។ នេះគឺជាផ្នែកសំខាន់នៃពេលវេលាសមដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ក្រុមចម្រៀង និងក្រុមជំនុំ។ នៅពេលដែលពួកគេមានការប៉ះពាល់ចិត្តដោយអត្ថបទចម្រៀង ការច្រៀងរបស់ពួកគេនឹងកាន់តែស៊ីជម្រៅ ហើយជីវិតរបស់ពួកគេនឹងត្រូវបានផ្លាស់ប្តូរដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធដែលធ្វើការតាមរយៈពួកគេ។ យើងអាចធ្វើការនេះ តាមរយៈពេលវេលាដែលអាចបង្រៀនយើងបានជាច្រើន ក្នុងអំឡុងពេលសម មិនមែនគ្រាន់តែនៅពេលវេលា «ដែលបានកំណត់» ដើម្បីផ្អាកការច្រៀងសិន ដើម្បីជញ្ជឹងគិតព្រះបន្ទូលប៉ុណ្ណោះទេ។ ខ្ញុំចូលចិត្តឈប់នៅចំកណ្តាលបទចម្រៀងពេលកំពុងសម ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលយើងទើបតែច្រៀង ហើយជួយអ្នកច្រៀងផ្សាភ្ជាប់ទៅនឹងអត្ថន័យឲ្យកាន់តែស៊ីជម្រៅ។ បន្ទាប់ពីពេលបង្កើតសិស្សចប់ហើយ ទើបយើងបន្តច្រៀងទៀត។

នៅក្នុងការសមនាពេលថ្មីៗនេះ ក្រុមចម្រៀងដែលខ្ញុំកំពុងដឹកនាំកំពុងសមបទ មានចំណងជើងថា ខ្ញុំថ្លែងពីព្រះនាមព្រះយេស៊ូវ (I Speak Jesus) ជាបទដែលមានប្រជាប្រិយភាពនៅអាមេរិកនិពន្ធដោយ លោក ឆារីធី ហ្គេយ៉ល (Charity Gayle)។ បទចម្រៀងដ៏មានអំណាចនេះមានការផ្សាភ្ជាប់នឹងជីវិតយើងយ៉ាងខ្លាំង។ ខ្ញុំមានអារម្មណ៍ប៉ះពាល់ចិត្តណាស់ នៅក្នុងការច្រៀងដ៏ឆេះឆួលនៅត្រង់វគ្គតភ្ជាប់ ដែលច្រៀងថា «ព្រះយេស៊ូវ បានឈ្នះលើខ្មាំងសត្រូវក្នុងភាពងងឹត ព្រះយេស៊ូវថែរក្សាគ្រួសារខ្ញុំ ខ្ញុំនិយាយចេញព្រះនាមដ៏បរិសុទ្ធគឺ ព្រះយេស៊ូវ» ខ្ញុំបានយកឈ្នះដោយអារម្មណ៍ ។ ព្រះយេស៊ូវគឺជាចម្លើយចំពោះអ្វីៗទាំងអស់ដែលមានគ្រោះថ្នាក់ដល់ពិភពលោកយើង។ ទ្រង់រង់ចាំជួយយើងក្នុងគ្រាងងឹត។ ទ្រង់ត្រៀមជាស្រេចដើម្បីគ្រួសាររបស់យើងតាមរយៈអ្វីដែលយើងជួបប្រទះ។ ខ្ញុំបានផ្អាកការសមមួយភ្លែត ដើម្បីនិយាយអំពីរឿងនេះ ហើយបន្ទាប់មកបានសុំពួកគេឲ្យគិតអំពីរបៀបដែលព្រះយេស៊ូវបានត្រៀមជាស្រេចដើម្បីជួយពួកគេ ក្នុងគ្រាងងឹតពោលគឺនិយាយអំពីរបៀបដែលទ្រង់បានបំបែកបន្ទាយមាំមួនក្នុងជីវិតពួកគេ។ ខ្ញុំក៏បានឲ្យពួកគេអធិស្ឋានអរគុណព្រះអង្គដែលបានជួយពួកគេក្នុងគ្រាទាំងនេះ ។ ខ្ញុំបានសុំឲ្យពួកគេចែករំលែកយ៉ាងខ្លីជាមួយអ្នកជិតខាងរបស់ពួកគេអំពីរឿងនេះ។ បន្ទាប់មក យើងច្រៀងស្ពានចម្លងម្តងទៀតដោយមានមនោសញ្ចេតនា និងទឹកចិត្តឆេះឆួលច្រើន។ គ្រាន់តែភ្ជាប់អ្វីដែលយើងកំពុងច្រៀងទៅនឹងជីវិតរបស់យើង ធ្វើឲ្យមានភាពខុសគ្នាយ៉ាងខ្លាំងចំពោះសារដែលយើងប្រកាស។

## ការទំនាក់ទំនង

សូមចាំថាការទំនាក់ទំនងពិតជាមានសារៈសំខាន់ណាស់។

ប្រសិនបើអ្នកចង់ពង្រឹងក្រុមចម្រៀងរបស់អ្នក ហើយចង់ឲ្យពួកគេអ្នកមានប្រសិទ្ធភាពក្នុងការងារ ការប្រាស្រ័យទាក់ទងគ្នាគឺជាកត្តាដ៏ចាំបាច់។ ខ្ញុំចូលចិត្តទំនាក់ទំនងជាមួយសមាជិកក្រុមចម្រៀងរបស់ខ្ញុំតាមអ៊ីមែលយ៉ាងហោចណាស់ ១-២ដងក្នុងមួយសប្តាហ៍។

១. ជាធម្មតា ខ្ញុំផ្ញើអ៊ីមែលនៅថ្ងៃច័ន្ទ ឬថ្ងៃអង្គារដោយអរគុណពួកគេ សម្រាប់ការដឹកនាំរបស់ពួកគេនៅថ្ងៃអាទិត្យ ផ្តល់មតិយោបល់សមរម្យអំពីកម្មវិធី និងលើកទឹកចិត្តពួកគេ ក្នុងការបម្រើព្រះ តាមការត្រាស់ហៅពួកគេឲ្យធ្វើជាអ្នកដឹកនាំថ្វាយបង្គំ។ ខ្ញុំអាចផ្តល់យោបល់អំពីឥទ្ធិពលរបស់បទចម្រៀងដែលគេទន្ទេញចាំមាត់ កាលពីថ្ងៃអាទិត្យកន្លងទៅ ហើយ

សរសេរអំពីមតិដែលខ្ញុំបានឮពីក្រុមជំនុំ។ ខ្ញុំលើកទឹកចិត្តពួកគេ ហើយតែងតែបន្តបង្ហាញបេសកកម្មរបស់ពួកគេឲ្យច្បាស់លាស់នៅចំពោះមុខពួកគេ។ ម្យ៉ាងទៀត ខ្ញុំអាចនឹងបង្ហាញខ្លះៗអំពីថ្ងៃអាទិត្យខាងមុខ និងការហាត់សមពាក់កណ្ដាលសប្ដាហ៍របស់យើង។ ខ្ញុំចង់ឲ្យក្រុមចម្រៀងដឹងថាខ្ញុំស្រឡាញ់ និងឲ្យតម្លៃពួកគេប៉ុណ្ណា។

២. ជាធម្មតា ខ្ញុំផ្ញើអ៊ីមែលមួយផ្សេងទៀតនៅថ្ងៃព្រហស្បតិ៍ ឬថ្ងៃសុក្រដោយព័ត៌មានបន្ថែមអំពីថ្ងៃអាទិត្យ ហើយសុំឲ្យពួកគេអធិស្ឋានឲ្យគ្នាទៅវិញទៅមក និងអធិស្ឋានសម្រាប់កម្មវិធីថ្វាយបង្គំថ្ងៃអាទិត្យ។ ជារឿយៗ ខ្ញុំចង្អុលប្រាប់ពួកគេអំពីការរៀបចំតាមអ៊ីនធឺណិតសម្រាប់សេចក្ដីអធិប្បាយ និងចម្រៀងក្នុងក្រុមជំនុំ។

## អ្នកអវត្តមាន

ខ្ញុំបានទាក់ទងរៀងរាល់សប្ដាហ៍ទៅកាន់អ្នកដែលខកខានមិនបានមកសមចម្រៀងសម្រាប់ក្រុមចម្រៀង។ ខ្ញុំប្រាប់ពួកគេថា ពួកគេបានខកខាន និងប្រាប់ពួកគេនូវអ្វីដែលពួកគេត្រូវដឹង អំពីកម្មវិធីថ្វាយបង្គំនៅថ្ងៃអាទិត្យ ដើម្បីត្រៀមខ្លួនឲ្យកាន់តែល្អហើយដើម្បីឲ្យបានដឹងថា តើអវត្តមានរបស់ពួកគេបណ្ដាលមកពីបញ្ហាអ្វីដែលខ្ញុំអាចអធិស្ឋានឲ្យដែរឬទេ (ដូចជាជំងឺ ឬវិបត្តិគ្រួសារ) ។ ក្រុមចម្រៀងគឺជាក្រុម និងគ្រួសារមួយ នៅពេលមានម្នាក់អវត្តមាននោះក្រុមទាំងមូលទទួលផលប៉ះពាល់។ ខ្ញុំចង់ឲ្យសមាជិកយើងដឹងថាពួកគេមានសារៈសំខាន់ប៉ុណ្ណា ហើយរកមើលថា តើមានតម្រូវការជាក់លាក់អ្វីក្នុងជីវិតរបស់ពួកគេ ដែលរារាំងការចូលរួមរបស់ពួកគេ។

## គេហទំព័រសម្រាប់អ្នកដឹកនាំថ្វាយបង្គំ

ការបង្កើតគេហទំព័រសម្រាប់អ្នកដឹកនាំការថ្វាយបង្គំ គឺជាការវិនិយោគដ៏ល្អមួយនៅក្នុងភាពជោគជ័យរបស់ពួកគេ។ គេហទំព័រសព្វថ្ងៃនេះគឺសាមញ្ញណាស់ក្នុងការផលិត និងមានការចំណាយតិចតួចទាក់ទងនឹងពួកគេ។ ខ្ញុំចូលចិត្តប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជួយដល់អ្នកដឹកនាំថ្វាយបង្គំរបស់យើងនៅក្នុងអ្វីដែលពួកគេធ្វើ។ ខ្ញុំមានគេហទំព័រដែលការពារដោយពាក្យសម្ងាត់សម្រាប់តែអ្នកដឹកនាំការថ្វាយបង្គំនៅព្រះវិហាររបស់យើង ដែលខ្ញុំបង្ហោះព័ត៌មានពាក់ព័ន្ធចម្រៀងវីដេអូ យូ

ធូប (YouTube) នាពេលខាងមុខ បទចម្រៀងសម្រាប់ហាត់សម តាមកាលវិភាគចម្រៀងសម្រាប់ក្រុមចម្រៀង នាពេលខាងមុខ ព្រមទាំងអត្ថបទដែលគួរឲ្យចាប់អារម្មណ៍ និងច្រើនទៀត។ ខ្ញុំទាក់ទងជាមួយក្រុមចម្រៀងរបស់ខ្ញុំតាមរយៈគេហទំព័រនេះ អ៊ីមែល គេហទំព័ររៀបចំការថ្វាយបង្គំព្រះវិហារ (បន្ថែមលើនេះបន្តិចទៀត) និងអត្ថបទជាក្រុម។

# ការរៀបចំក្រុមភ្លេង និងក្រុមច្រៀង

ខ្ញុំដឹងថា សម្រាប់អ្នកទាំងអស់គ្នា «ក្រុមភ្លេង» អាចមានអ្នកលេងព្យាណូតែម្នាក់ និងមិនមានអ្នកលេងភ្លេងផ្សេងទៀតទេ។ សម្រាប់អ្នកផ្សេងទៀត អ្នកអាចមានអ្នកកាន់ឧបករណ៍ភ្លេងផ្សេងទៀត។ អ្នកខ្លះថែមទាំងអាចមានវង់ភ្លេងមហោស្រពទៀតផង។ ព្រះវិហារនីមួយៗមានលក្ខណៈពិសេសរៀងៗខ្លួន។ គោលគំនិតដែលខ្ញុំនឹងពិភាក្សានៅទីនេះ អាចត្រូវបានសម្របខ្លួន និងអនុវត្តទៅតាមការពិតជាក់ស្ដែងរបស់អ្នក។

«ក្រុមច្រៀង» របស់អ្នកអាចជាអ្នក និងមនុស្សម្នាក់ទៀត ឬមនុស្សមួយចំនួនដែលជួយដឹកនាំក្នុងពេលវេលានៃកម្មវិធីថ្វាយបង្គំនៃក្រុមជំនុំរបស់អ្នក។

ខាងក្រោមនេះជាជំហានក្នុងការរៀបចំក្រុមភ្លេង និងក្រុមច្រៀងរបស់អ្នកៈ

## ចាត់តាំងអ្នកភ្លេងទៅកាន់កម្មវិធី

ព្រះវិហាររបស់អ្នកអាចមានអ្នកកាន់ឧបករណ៍ភ្លេងដដែលជារៀងរាល់សប្ដាហ៍ ឬព្រះប្រទានពរអ្នកឲ្យមានអ្នកភ្លេងជាច្រើននាក់ដែលលេងវិលជុំប្ដូរវេនបាន។ គំនិតទាំងនេះនឹងជួយអ្នកដោះស្រាយបញ្ហាដ៏ស្មុកស្មាញនៃការចាត់តាំងអ្នកភ្លេង។

ពេលណាខ្ញុំបានកំណត់កាលបរិច្ឆេទ និងពេលវេលានៃកម្មវិធីថ្វាយបង្គំហើយ ហើយបន្ថែមព័ត៌មានលម្អិតសម្រាប់កម្មវិធីថ្វាយបង្គំ ហើយខ្ញុំអាចចាត់តាំងអ្នកភ្លេងសម្រាប់កម្មវិធីថ្វាយបង្គំ។ ខ្ញុំផ្ញើសារទៅពួកគេ ដោយសួរថា តើពួកគេអាចប្ដេជ្ញាចិត្តទៅចូលរួមបម្រើព្រះនៅថ្ងៃនោះឬទេ។ ខ្ញុំទទួលបានការឆ្លើយតបរបស់ពួកគេ បានជាខ្ញុំដឹងថា នរណាខ្លះនឹងអវត្តមាន និងត្រូវការអ្នកជំនួសបើសិនជាមាន។

ខ្ញុំបានរៀបកាលវិភាគសម្រាប់ការចាត់តាំងសមាជិកក្រុមឲ្យបានមុនប៉ុន្មានសប្ដាហ៍ ដើម្បីឲ្យខ្ញុំមានពេលច្រើនសម្រាប់ការកែសម្រួលកាលវិភាគក្នុងករណីមានអ្នកអវត្តមាន។ ប្រសិនបើ អ្នកភ្លេងខ្លះពូកែជាងអ្នកភ្លេងផ្សេងទៀត នោះការដឹងថាអ្នកណាត្រូវលេងភ្លេងនៅថ្ងៃអាទិត្យណាអាចជួយអ្នកក្នុងការជ្រើស

រើសបទចម្រៀង ដោយដឹងអំពីកំរិតនៃការលំបាកក្នុងការច្រៀងបទចម្រៀងណាខ្លះ និងដឹងអំពីសមត្ថភាពរបស់អ្នកភ្លេង។ អ្នកអាចរៀបកាលវិភាគសម្រាប់ការចាត់តាំងសមាជិកក្រុមទោះអ្នកមិនទាន់បានរៀបកាលវិភាគសម្រាប់កម្មវិធីថ្វាយបង្គំក៏ដោយ។ បន្ទាប់មកអ្នកអាចផ្ញើសារទៅពួកគេ នៅពេលដែលអ្នកបានត្រៀមអ្វីៗរួចរាល់ហើយ។ អ្នកចាំបាច់ត្រូវបង្កើតប្រព័ន្ធដែលផ្តល់ភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយអ្នកភ្លេងរបស់អ្នក ហើយអាចដឹងថាពួកគេអាចប្តេជ្ញាចិត្តចំពោះកិច្ចការដែលបានចាត់តាំងឬអត់។

## បង្ហើយផែនការ សម្រាប់កម្មវិធីថ្វាយបង្គំ

ដូចដែលខ្ញុំបាននិយាយពីមុន ការបញ្ចប់ផែនការសម្រាប់កម្មវិធីថ្វាយបង្គំប្រហែលពីរសប្តាហ៍ជាមុន គឺល្អបំផុត។ អ្នកអាចប្រើកម្មវិធី Word or Excel ដើម្បីបង្ហាញផែនការសម្រាប់កម្មវិធីថ្វាយបង្គំក៏បាន។ អ្នកអាចរាប់បញ្ចូលព័ត៌មានដែលចាំបាច់ទាំងអស់អំពីលំដាប់លំដោយនៃកម្មវិធី ទុកឲ្យអ្នកភ្លេងមើល (ខ្ញុំនឹងនិយាយអំពីរឿងនេះបន្តិចទៀត) ហើយរក្សាទុកជាឯកសារ PDF សម្រាប់ការចែកចាយបែបឌីជីថល។ បើសិនជាអាច ចូរបង្កើតសឺមីរបស់កម្មវិធីថ្វាយបង្គំ ដែលអ្នកអាចដាក់ឯកសារដែលត្រូវបោះពុម្ព និងឯកសារចម្រៀង សម្រាប់បទចម្រៀងនីមួយៗ និងលំដាប់លំដោយនៃកម្មវិធី និងឯកសារជំនួយដទៃទៀត រួចចែករំលែកសឺមីនោះជាមួយក្រុមរបស់អ្នកចុះ។

## បញ្ចូលផែនការបទចម្រៀង និងកំណត់ចំណាំផ្សេងទៀតសម្រាប់បទចម្រៀងនីមួយៗ

អ្នកត្រូវរៀបចំផែនការ សម្រាប់បទចម្រៀងឲ្យបានច្បាស់លាស់—តើអ្នកនឹងធ្វើផែនការសម្រាប់បទចម្រៀងដែលមានវគ្គ បន្ទរ វគ្គ បន្ទរ វគ្គតភ្ជាប់ បន្ទរ បន្ទរឃ្លាចុងក្រោយ (VCVCBCCT) ឬផែនការផ្សេងទៀតសម្រាប់បទចម្រៀងនេះ? តើអ្នកនឹងធ្វើផែនការនោះតាមតារាងដែលមានស្រាប់ ឬអ្នកនឹងកែប្រែអ្វីដែលមាននៅលើទំព័រនោះ? ត្រង់ចំណុចនេះ អ្នកត្រូវបញ្ជាក់ច្បាស់ថា អ្នកមានបំណងឲ្យគេច្រៀងបទចម្រៀងនោះដូចម្តេច ក្នុងកម្មវិធីថ្វាយបង្គំ។ ខ្ញុំច្រើនតែពន្យល់អំពីការផ្លាស់ប្តូរក្នុងការៀបចំក្នុងកំណត់សំគាល់ផងដែរ។ (ដូចដែលខ្ញុំបានរៀបរាប់រួចហើយ សូមអនុញ្ញាតឲ្យផែនការនេះផ្លាស់ប្តូរ នៅក្នុងកម្មវិធីថ្វាយបង្គំជាក់ស្តែងតាមការដឹកនាំព្រះវិញ្ញាណបរិសុទ្ធ — កុំតឹងរ៉ឹងខ្លាំងពេកដែលអ្នកមិនអាចផ្លាស់ប្តូរ

ផែនការ នៅពេលដែលព្រះកំពុងធ្វើការក្នុងកម្មវិធីថ្វាយបង្គំ)។ បន្ទាប់មក ចូររៀបរាប់អំពីភ្លេងដំបូងនៃបទចម្រៀង ហើយអ្នកណានឹងលេងភ្លេងនោះ។ ប្រសិនបើអ្នកមានចម្រៀងពីរបទ ឬច្រើនបទ ដែលក្រុមចម្រៀងត្រូវច្រៀងនៅក្នុងកម្មវិធី សូមគូសបញ្ជាក់ពីរបៀបដែលក្រុមតន្ត្រីនឹងឆ្លងពីបទមួយទៅបទមួយទៀត។ ព័ត៌មានទាំងអស់នេះគួរតែត្រូវបានបញ្ចូលទៅក្នុងផ្នែកកំណត់ចំណាំ។

## ជូនដំណឹងដល់អ្នកភ្លេងថាតន្ត្រីរួចរាល់

នៅពេលដែលអ្នកបានបំពេញផែនការសម្រាប់កម្មវិធីថ្វាយបង្គំរួចហើយ អ្នកអាចជូនដំណឹងដល់អ្នកភ្លេងដែលអ្នកបានរៀបចំក្នុងកាលវិភាគថា យើងបានរៀបចំតន្ត្រីសម្រាប់ពួកគេរួចរាល់ហើយ។ អ្នកគួរតែផ្ញើផែនការកម្មវិធីថ្វាយបង្គំ និងតំណភ្ជាប់ (Link) ទៅពួកគេដើម្បីឲ្យពួកគេអាចទាញយកប្រើនៅក្នុងឧបករណ៍ ឬបោះពុម្ព ស្តាប់សំឡេងគំរូមើលកំណត់ចំណាំទាំងអស់ ហើយចាប់ផ្តើមរៀបចំសម្រាប់ការហាត់សម។ ដូចដែលបានពិភាក្សាពីមុននៅក្នុងផ្នែក «ការបង្កើតវប្បធម៌សម្រាប់ការសមកាន់តែប្រសើរ» ពួកគេត្រូវបានគេរំពឹងថា នឹងស្គាល់ភ្លេងទាំងនោះ មុនពេលមកហាត់សម។ ពួកគេមានអ្វីៗដែលពួកគេត្រូវការ ដើម្បីត្រៀមខ្លួនឲ្យបានល្អ ប្រសិនបើអ្នកបានធ្វើការរៀបចំដូចបានរៀបរាប់នៅទីនេះ។ ដោយសារពួកគេទទួលបានតន្ត្រីតាំងពីជាងមួយសប្តាហ៍មុន ទើបពួកគេគួរតែមានពេលដើម្បីធ្វើហាត់សមវា។

នៅពេលដែលការរៀបចំទាំងអស់នោះរួចរាល់ យើងដល់ពេលទៅដំណាក់កាលបន្ទាប់៖

## ការហាត់សម!

ចូរប្រមូលផ្តុំក្រុមជាមួយគ្នា ហើយហាត់សមបទចម្រៀងនីមួយៗ។ ការនេះគួរតែជ្រើសរើសធ្វើនៅថ្ងៃផ្សេងពីថ្ងៃនៃកម្មវិធីថ្វាយបង្គំ។ ចូរស្វែងយល់បទចម្រៀងនីមួយៗជាលម្អិត។ តើយើងនឹងចាប់ផ្តើមប្រគំបទចម្រៀងនោះដោយរបៀបណា? តើអ្វីបទចម្រៀងនោះមាន ចង្វាក់យឺត ឬលឿនយ៉ាងណា? តើយើងច្រៀងផ្នែកនីមួយៗនៃបទចម្រៀងដូចម្តេចខ្លះ? ចូរគ្រាន់តែដឹងថាវាជាការល្អបំផុតដែលយើងមិនច្រៀងល្បះនីមួយៗ និងបន្ទរ ។ល។ តាមរបៀបដដែលនោះទេ។ តើយើងនឹងច្រៀងវគ្គនីមួយៗ តាមរបៀបខុសពីគ្នាដូចម្តេចខ្លះ? តើយើងអាចគូរបង្ហាញអត្ថន័យនៃបទចម្រៀងយ៉ាងដូចម្តេច ដើម្បីឲ្យក្រុមជំនុំយល់? តើយើងនឹងភ្ជាប់ពីបទចម្រៀងមួយទៅមួយទៀត ក្នុងលំដាប់លំដោយនៃកម្មវិធីថ្វាយបង្គំយ៉ាងដូចម្តេចខ្លះ? តើ

យើងបញ្ចប់បទចម្រៀងដោយរបៀបណា? ខ្ញុំនឹងទុកពេលយ៉ាងហោចណាស់មួយម៉ោងសម្រាប់ការសមនេះ។ អ្នកអាចកំណត់រយៈពេលសមវែង ឬខ្លីជាងនេះ អាស្រ័យទៅលើស្ថានភាពជាក់ស្តែង និងផ្អែកទៅលើសមត្ថភាពរបស់អ្នកភ្លេង និងការលំបាកក្នុងការច្រៀងបទណាមួយ និងការរៀបចំរបស់អ្នក។ ត្រូវតែបន្តស្វែងរកពេលវេលាដែលអាចបង្រៀនជាលក្ខណៈបង្កើតសិស្ស ដូចដែលខ្ញុំបានពិពណ៌នានៅក្នុងផ្នែករៀបចំក្រុមចម្រៀង (ប្រសិនបើអ្នករំលងផ្នែកនោះ សូមត្រឡប់ទៅអានផ្នែកស្តីពីភាពជាសិស្សជាមួយក្រុមចម្រៀង) រួមទាំងវិធីដើម្បីជួយក្រុមតន្ត្រី និងអ្នកចម្រៀងឲ្យមានការប៉ះពាល់ចិត្ត ដោយអត្ថន័យនៃបទចម្រៀងដែលពួកគេកំពុងប្រគំនោះ។

អ្នកច្រៀងរបស់អ្នកនឹងទទួលបានអត្ថប្រយោជន៍ពីការហាត់សមនូវផ្នែករបស់ពួកគេដាច់ដោយឡែកពីក្រុមនៅពេលនេះ បន្ទាប់មកផ្នែករបស់ពួកគេរួមគ្នាប្រហែលនៅក្នុងការសមភ្លេងមួយចប់កម្មវិធី។

## ការសមភ្លេងមួយចប់កម្មវិធី

ចូរជួបជាមួយក្រុមភ្លេង ក្រុមច្រៀង និងក្រុមបច្ចេកទេស នៅថ្ងៃនៃកម្មវិធីថ្វាយបង្គំ ដើម្បីសមបទចម្រៀងទាំងអស់ឲ្យចប់សព្វគ្រប់—គឺប្រៀបដូចជាកំពុងដឹកនាំក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំដោយធ្វើការកែសម្រួលដែលចាំបាច់នៅនាទីចុងក្រោយ។ សូមប្រាកដថា ក្រុមទាំងមូលយល់ដឹងអំពីការឲ្យសញ្ញាចាប់ផ្តើមនីមួយៗក្នុងកម្មវិធីថ្វាយបង្គំ (ឧទាហរណ៍ អ្នកវាយស្គរឲ្យសញ្ញាដោយការរាប់ពីមួយដល់បួនភ្លាមៗបន្ទាប់ពីពាក្យ «អាម៉ែន» ដើម្បីឲ្យក្រុមជំនុំអាចចាប់ផ្តើមច្រៀងទាំងអស់គ្នា)។

ឥឡូវនេះ ការរៀបចំរបស់អ្នករួចរាល់ហើយ។ អ្នកបានស្វែងរកការណែនាំពីព្រះក្នុងការធ្វើផែនការ។ អ្នកបានផ្តល់អត្ថប្រយោជន៍គ្រប់យ៉ាងដល់អ្នកភ្លេងរបស់អ្នក ដើម្បីលេងភ្លេងឲ្យបានល្អប្រសើរ ហើយឥឡូវនេះអ្នកបានដាក់វានៅក្នុងព្រះហស្តរបស់ព្រះនៅពេលដែលអ្នកដឹកនាំក្នុងពេលវេលានៃកម្មវិធីថ្វាយបង្គំនេះ។

**តើការរៀបចំសម្រាប់ក្រុមច្រៀង និងក្រុមភ្លេងមានផ្នែកណាខ្លះដែលត្រូវកែលម្អ?**

# ការរៀបចំប្រព័ន្ធផ្សព្វផ្សាយ

នៅក្នុងព្រះវិហារជាច្រើនដែលប្រើអេក្រង់វីដេអូ អ្វីដែលនៅលើអេក្រង់គឺជាទំនួលខុសត្រូវរបស់អ្នកដឹកនាំថ្វាយបង្គំ និងគ្រូគង្វាល (គ្រូគង្វាលយកចិត្តទុកដាក់ជាចម្បងលើស្លាយសេចក្ដីអធិប្បាយ)។ ក្នុងករណីជាច្រើន អ្នកស្ម័គ្រចិត្តអាចជួយបង្កើតស្លាយជាច្រើន។

សូមគិតអំពីអេក្រង់ ថាជាផ្ទាំងទស្សនីភាពដែលអ្នកបង្កើតរូបភាពប្រើក្នុងកម្មវិធីថ្វាយបង្គំ ដើម្បីឲ្យពេលវេលានៃកម្មវិធីថ្វាយបង្គំកាន់តែល្អប្រសើរ។ ការបញ្ចាំងរូបភាពគឺជាមធ្យោបាយទំនាក់ទំនងដ៏មានអានុភាព ហើយគួរតែត្រូវបានរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន ដើម្បីជួយអ្នកថ្វាយបង្គំឲ្យជាប់ចិត្តនឹងបទពិសោធន៍នៃការថ្វាយបង្គំទាំងមូល។ ស្លាយដែលមិនសូវល្អអាចបញ្ចេញសារដែលអ្នកមិនចង់បាន។

## ការប្រើប្រាស់វីដេអូ

នៅពេលដែលអ្នកគិត អំពីអ្វីដែលនឹងបង្ហាញនៅលើអេក្រង់ ខាងក្រោមនេះជារបៀបប្រើប្រាស់វីដេអូ៧យ៉ាង នៅក្នុងព្រះវិហារតែមិនបានបញ្ជាក់អំពីលំដាប់លំដោយទេ៖

### ការប្រកាសដំណឹងផ្សេងៗ

ការប្រកាសដំណឹងផ្សេងៗដោយផ្ទាល់មាត់អាចធ្វើឲ្យខូចកម្មវិធីថ្វាយបង្គំ ជាពិសេសប្រសិនបើគេប្រកាសនៅពាក់កណ្ដាលកម្មវិធី។ អ្នកអាចប្ដូរពេលប្រកាសដំណឹងភាគច្រើននៅលើស្លាយ/វីដេអូ នៅដើមដំបូងនៃកម្មវិធី ឬពេលពួកជំនុំចូលក្នុងទីបរិសុទ្ធ។ អ្នកក៏អាចប្រើក្រដាសកម្មវិធី ព្រឹត្តិបត្រ និងបណ្ដាញសង្គម ដើម្បីប្រកាសផងដែរ។ ហើយក៏មានការប្រកាសដំណឹងមួយចំនួន ដែលចាំបាច់ត្រូវធ្វើដោយផ្ទាល់មាត់តាមពេលវេលាសមស្របនៅដើម និងចុងនៃកម្មវិធីថ្វាយបង្គំ។

### វីដេអូបេសកកម្ម

ការប្រើប្រាស់វីដេអូគឺមធ្យោបាយដ៏ប្រសើរ ដើម្បីនិយាយសង្កត់ធ្ងន់អំពីបុព្វហេតុនៃបេសកកម្ម និងអង្គការដែលក្រុមជំនុំរបស់អ្នកកំពុងឧបត្ថម្ភ។ អង្គការបេសកកម្មភាគច្រើនអាចផ្ដល់ឲ្យនូវវីដេអូមានគុណភាពខ្ពស់សម្រាប់អ្នកប្រើប្រាស់។ អ្នកអាចស្វែងរកវេបសាយរបស់អង្គការបេសកកម្មដែលព្រះវិហារអ្នកឧបត្ថម្ភ ដើម្បីស្វែងរកវីដេអូដែលពួកគេអាចផ្ដល់ឲ្យ។ ការរាប់បញ្ចូលវីដេអូសង្ខេប

អំពីដំណើរបេសកកម្មរបស់ពួកជំនុំ ចាំបាច់ត្រូវមានការថតវីដេអូ និងការកែសម្រួលវីដេអូ ប៉ុន្តែ អ្នកនឹងទទួលព្រះពរជាច្រើន នៅពេលដែលអ្នកអាចចែកចាយរឿង អំពីរបៀបដែលព្រះទ្រង់ធ្វើការតាមរយៈក្រុមបេសកកម្មរបស់ព្រះវិហារអ្នកតាមរបៀបនេះ។

## វីដេអូខ្លីៗ

ប្រហែលជាមានវីដេអូខ្លីជាច្រើនដែលអ្នកអាចប្រើដែលមានប្រយោជន៍ដល់ការអធិប្បាយព្រះបន្ទូលនៅពេលព្រឹក និងការណែនាំអំពីបទចម្រៀង ឬការសង្កត់ធ្ងន់អំពីពិធីបុណ្យធំៗរបស់ព្រះវិហារ។ អ្នកនឹងឃើញថា មានវីដេអូខ្លីជាច្រើនដែលនាំឲ្យមានការថ្វាយបង្គំដ៏ប្រសើរ ឬជញ្ជឹងគិតខគម្ពីរ។ អ្នកក៏អាចប្រើវីដេអូខ្លីជាធាតុផ្សំនៃការតភ្ជាប់ពីចំណុចមួយទៅចំណុចមួយទៀតក្នុងលំហូរនៃការថ្វាយបង្គំ។ បើអ្នកមានសមាជិកពួកជំនុំដែលមានអំណោយទានផលិតវីដេអូ ពួកជំនុំរបស់អ្នកអាចបង្កើតវីដេអូខ្លីៗដោយខ្លួនឯងបាន។

## វីដេអូទីបន្ទាល់

វីដេអូនៃទីបន្ទាល់ផ្ទាល់ខ្លួន អាចជួយក្រុមជំនុំអបអរអ្វីដែលព្រះកំពុងធ្វើការក្នុងជីវិតរបស់សមាជិកក្រុមជំនុំ។ ពេលខ្លះ ការប្រគល់មីក្រូហ្វូនដល់មនុស្សម្នាក់ឲ្យចែកចាយទីបន្ទាល់ នៅព្រឹកថ្ងៃអាទិត្យអាចនាំមកនូវលទ្ធផលដែលនឹកស្មានមិនដល់ ប៉ុន្តែ ការថតទីបន្ទាល់ និងការកែសម្រួលដោយប្រុងប្រយ័ត្នមួយចំនួន អាចបង្កើតជាវីដេអូទីបន្ទាល់ខ្លីដ៏មានអានុភាពដែលអាចបង្ហាញនៅក្នុងការថ្វាយបង្គំ។ វីដេអូទាំងនេះអាចមានឥទ្ធិពលជាពិសេស នៅមុនពេលពិធីបុណ្យជ្រមុជទឹកជាដើម។

ខ្ញុំបានឃើញព្រះវិហារនានាប្រើប្រាស់វីដេអូទីបន្ទាល់ មុនពិធីបុណ្យជ្រមុជទឹកតាមរបៀបដ៏មានអនុភាព។ អ្នកចែកចាយទីបន្ទាល់បានឲ្យគេថតវីដេអូគាត់ចែកចាយទីបន្ទាល់អំពីជីវិតផ្លាស់ប្រែក្នុងព្រះគ្រីស្ទ។ វីដេអូត្រូវបានកែសម្រួលតាមដែលចាំបាច់ ដើម្បីបង្កើតទីបន្ទាល់ដ៏មានអនុភាព។ ឧទាហរណ៍ នៅពេលដែលម្ចាស់ទីបន្ទាល់ដើរចូលទៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក គេចាក់បញ្ចាំងខ្សែវីដេអូបង្ហាញពីទីបន្ទាល់របស់ពួកគេ ហើយបន្ទាប់មកអ្នកនោះក៏បានទទួលបុណ្យជ្រមុជទឹក។ នេះជាវិធីដ៏មានឥទ្ធិពលមួយ ដើម្បីចែកចាយសារអំពីការផ្លាស់ប្រែ និងការកើតជាថ្មី។

## ការបញ្ចាំងទំនុកច្រៀងរបស់បទចម្រៀងសម្រាប់ក្រុមជំនុំច្រៀង

ព្រះវិហារអាចចាប់ផ្តើមចូលទៅក្នុងពិភពចាក់បញ្ចាំងវីដេអូពីចំណុចនេះទៅ។ កំណត់ចំណាំទាក់ទងនឹងកម្មវិធីថ្វាយបង្គំរបស់ពួកជំនុំដែលមានជំនាន់ផ្សេងគ្នា៖ សូមប្រយ័ត្ន កុំធ្វើខុសដូចព្រះវិហារជាច្រើន ហើយបង្ហាញតែបទចម្រៀង "សហសម័យ" នៅលើអេក្រង់ រួចច្រៀងចម្រៀងចាស់ៗដោយប្រើសៀវភៅចម្រៀង។ ការធ្វើដូចនេះ អាចនាំឲ្យមានការបែងចែកក្រុមនៅក្នុងក្រុមជំនុំរបស់អ្នកដោយអចេតនា ដោយធ្វើឲ្យមានគំលាតកាន់តែធំរវាងទំនុកចាស់ៗ និងបទចម្រៀងថ្មីៗ។ គ្រប់បទដែលត្រូវច្រៀងក្នុងកម្មវិធីថ្វាយបង្គំ ត្រូវចាក់បញ្ចាំងនៅលើអេក្រង់ ឬបើបទចម្រៀងណាមួយមិនមានអត្ថបទសម្រាប់បញ្ចាំងទេ ចូរកុំបញ្ចាំងទាំងអស់តែម្តងល្អជាង។ អ្នកនៅតែអាចប្រកាសដំណឹងបោះពុម្ព ឬបង្ហាញលេខបទចម្រៀងនៅក្នុងសៀវភៅចម្រៀង ដើម្បីឲ្យពួកជំនុំអាចជ្រើសរើសប្រើសៀវភៅ ឬចម្រៀងនៅលើអេក្រង់។ តាមបទពិសោធន៍របស់ខ្ញុំ មានមនុស្សតិចណាស់ដែលប្រើសៀវភៅចម្រៀង បន្ទាប់ពីប្រើវាបានពីរបីខែ ទោះបីជាពួកគេគិតពីដំបូងថា នោះជាចំណូលចិត្តរបស់ពួកគេក៏ដោយ។

## ការប្រើរូបភាពលើអេក្រង់សម្រាប់ជំនួយដល់សេចក្តីអធិប្បាយ

គ្រូគង្វាលជាច្រើនដែលបានប្រើការបង្ហាញលើអេក្រង់គ្រាន់តែបានគិតដល់ការបង្កើតបទបង្ហាញអក្សរ (PowerPoint) ដែលមានពាក្យលេចឡើងម្តងមួយចំណុចៗនៅលើអេក្រង់ ។ ការអនុវត្តដូចនេះអាចមានប្រយោជន៍សម្រាប់អ្នកខ្លះក្នុងការតាមដានការចែកចាយ តែផ្ទុយទៅវិញ ចូរគិតអំពីវិធីប្រើប្រាស់រូបភាពដែលជួយអ្នកស្តាប់ស្រមៃឃើញទិដ្ឋភាពពិត ដែលជួយឲ្យពួកគេយល់កាន់តែច្បាស់។ គឺដូចដែលមានពាក្យស្លោកមួយពោលថា «រូបភាពមួយមានតម្លៃស្មើពាក្យមួយពាន់ម៉ាត់»។ វីដេអូខ្លីៗ និងកំណាត់វីដេអូ ក៏អាចមានប្រយោជន៍ណាស់ដែរ។ បើអ្នកប្រើកំណាត់វីដេអូ អ្នកត្រូវតែយល់អំពីបញ្ហាកម្មសិទ្ធិបញ្ញា និងមានការអនុញ្ញាតត្រឹមត្រូវ។

## រូបភាពលើអេក្រង់

នៅពេលផ្សេងគ្នាក្នុងដំណើរនៃបទពិសោធន៍ក្នុងការថ្វាយបង្គំ សូមប្រើរូបភាពដើម្បីជួយណែនាំអ្នកថ្វាយបង្គំ។ ប្រសិនបើព្រះវិហារអ្នកមានមនុស្សដែលមានជំនាញសិល្បៈពួកគេអាចបង្កើតរូបភាពដែលអាចត្រូវបានប្រើនៅក្នុងការបញ្ចាំងរូបភាព និងការបង្ហាញដទៃទៀតរបស់កម្មវិធីថ្វាយបង្គំ ដូចជាក្រដាសកម្មវិធី ការដាក់

តាំង និងគេហទំព័រជាដើម។

## ការពង្រីករូបភាព

បើកន្លែងថ្វាយបង្គំរបស់អ្នកមានទំហំធំខ្លាំង អ្នកអាចប្រើប្រព័ន្ធវីដេអូ ជាជំនួយដល់ការទំនាក់ទំនង ដោយពង្រីករូបភាពរបស់គ្រូគង្វាលកំពុងអធិប្បាយ ឬអ្នកដទៃទៀតដែលកំពុងដឹកនាំកម្មវិធី។

ខ្ញុំបាននិយាយអំពីមធ្យោបាយជាបឋមដែលក្រុមជំនុំអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនៅលើអេក្រង់។ មានវិធីផ្សេងទៀត ដែលព្រះវិហារអាចលើកកម្ពស់ការថ្វាយបង្គំ តាមរយៈការបញ្ចាំងរូបភាព ប៉ុន្តែ វិធីទាំងនេះប្រហែលជាមានសាមញ្ញបំផុត។ សូមចំណាយពេលស្រមៃអំពីពេលនីមួយៗ ក្នុងកម្មវិធីថ្វាយបង្គំរបស់អ្នក ហើយរៀបចំផែនការដោយប្រុងប្រយ័ត្ន សម្រាប់អ្វីដែលនឹងមាននៅលើអេក្រង់។

ការរៀបចំផែនការដោយប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វីដេអូឲ្យបានល្អ គឺមានសារៈសំខាន់ខ្លាំងណាស់។ ការបញ្ចាំងចម្រុះគ្នាដោយគ្មានផែនការល្អិតល្អន់ អាចធ្វើឲ្យបែកអារម្មណ៍ជាជាងជួយឲ្យផ្ដោតអារម្មណ៍ អាចប៉ះពាល់ដល់កម្មវិធីថ្វាយបង្គំ។

អ្នករៀបផែនការសម្រាប់កម្មវិធីថ្វាយបង្គំ អាចប្រើកម្មវិធីក្នុងកុំព្យូទ័រជាច្រើន (កម្មវិធីដំឡើងក្នុងកុំព្យូទ័រ និងវេបសាយ) ដើម្បីប្រមូលផ្តុំ និងបញ្ចាំងរូបភាព ឬវីដេអូក្នុងកម្មវិធីថ្វាយបង្គំ។ ព្រះវិហារជាច្រើនប្រើកម្មវិធី PowerPoint ព្រោះពួកគេមានកម្មវិធីនេះ ហើយក៏ចេះប្រើវាស្រាប់ផង។ គួរឲ្យស្តាយ ដែលកម្មវិធី PowerPoint មិនអាចធ្វើអ្វីបានច្រើនទេ ហើយត្រូវបានគេរចនាមក មិនមែនដើម្បីបំពេញតម្រូវការនៃកម្មវិធីថ្វាយបង្គំដែរ។ សព្វថ្ងៃនេះ មានកម្មវិធីជាច្រើនដែលគេបានរចនាមកជាពិសេស សម្រាប់កម្មវិធីថ្វាយបង្គំ និងសម្រាប់ឲ្យអ្នកស្វែងយល់អំពីលទ្ធភាពដែលអាចប្រើពួកវាបានក្នុងកម្មវិធីថ្វាយបង្គំ។

ខាងក្រោមនេះ គឺជាគំនិតមួយចំនួនអំពីដំណើរការនៃការងារប្រចាំសប្តាហ៍ ខណៈពេលដែលអ្នករៀបចំវីដេអូសម្រាប់ការថ្វាយបង្គំ។

# លំហូរការងារប្រចាំសប្តាហ៍

អ្នកគួរទទួលព័ត៌មានថ្មីៗអំពីវីដេអូពិសេសៗ ឬធនធានដ៏ប៉ិនប្រសព្វផ្សេងទៀត និងប្រព័ន្ធផ្សព្វផ្សាយជាជំនួយតាមដែលត្រូវការ។ ប៉ុន្មានសប្តាហ៍មុននេះនៅពេលដែលគ្រូគង្វាលជូនដំណឹងអំពីការអធិប្បាយព្រះបន្ទូលដែលបានកំណត់ទុកសម្រាប់ថ្ងៃអាទិត្យ អ្នករៀបចំផែនការសម្រាប់កម្មវិធីថ្វាយបង្គំបានចាប់ផ្តើមស្វែងរកវីដេអូដែលសមស្របនឹងប្រធានបទនៃការអធិប្បាយព្រះបន្ទូលនោះ ប្រសិនបើ

ចាំបាច់។ វីដេអូនោះអាចត្រូវបានផលិតដោយអ្នកជំនាញនៅក្រៅព្រះវិហារ ឬព្រះវិហារបង្កើតវាដោយខ្លួនឯង។ អ្នកគួរតែបញ្ចូលព័ត៌មាននៃផ្នែកទាំងអស់នេះ ទៅក្នុងកម្មវិធីសម្រាប់ធ្វើផែនការតាមអនឡាញរបស់អ្នក ឬសៀវភៅបញ្ជីរបស់អ្នក ឬរក្សាទុកជាឯកសារ (Word) ដើម្បីរក្សាទុកព័ត៌មានសម្រាប់កម្មវិធីថ្វាយបង្គំនោះ។

សូមមើលលំហូរនៃកម្មវិធីថ្វាយបង្គំដែលអ្នកបានបង្កើត។ សូមពិនិត្យមើលគ្រប់ផ្នែកនៃកម្មវិធីថ្វាយបង្គំ ហើយកំណត់យកការបញ្ចាំងអ្វីមួយ ដែលអាចជួយដល់ផ្នែកណាមួយនៃកម្មវិធីថ្វាយបង្គំ។ សូមពិនិត្យឡើងវិញនូវគំនិតនៅក្នុងបញ្ជីដែលខ្ញុំទើបតែបានពិភាក្សា ដើម្បីជំរុញការគិតរបស់អ្នក។

កំណត់ផ្ទៃខាងក្រោយដែលអ្នកនឹងប្រើសម្រាប់បញ្ចាំងអត្ថបទចម្រៀង។ អ្នកគួរតែកំណត់ថា តើអ្នកនឹងប្រើផ្ទៃខាងក្រោយដែលគ្មានចលនា (រូបភាព ឬពណ៌តែមួយ/ពណ៌ដែលប្រែពីចុងម្ខាងទៅចុងម្ខាង) ឬផ្ទៃខាងក្រោយមានចលនា (វីដេអូ)។ តើផ្ទៃខាងក្រោយនឹងជួយឆ្លុះបញ្ចាំងអត្ថន័យរបស់ពាក្យទេ ឬវាគ្រាន់តែជាផ្ទាំងក្រណាត់ទទេដែលមានអក្សរពីលើ? ព្រះវិហារខ្លះប្រើផ្ទៃខាងក្រោយរបស់វីដេអូដែលមានលក្ខណៈស្មុគស្មាញ ខណៈពេលដែលអ្នកផ្សេងទៀតចូលចិត្តប្រើអក្សរពណ៌ស នៅលើផ្ទៃខាងក្រោយពណ៌ខ្មៅ។ យើងមានជម្រើសច្រើនណាស់។ ចូរកំណត់យកអ្វីដែលល្អបំផុតសម្រាប់ស្ថានភាពផ្ទាល់របស់អ្នក។

ខ្ញុំបានដឹកនាំក្រុមថ្វាយបង្គំមួយ ទៅធ្វើបេសកកម្មនៅប្រទេសម៉ាឡេស៊ីជាច្រើនឆ្នាំកន្លងទៅ។ យើងកំពុងនាំមុខក្នុងការថ្វាយបង្គំនៅព្រះវិហារមួយ ហើយខ្ញុំបានប្រើកុំព្យូទ័ររបស់ខ្ញុំ ក្នុងការបញ្ចាំងវីដេអូនៅលើអេក្រង់។ ខ្ញុំបានប្រើវីដេអូមានចលនា បញ្ចាំងពីក្រោយអត្ថបទចម្រៀង តាមទម្លាប់របស់ព្រះវិហារជាច្រើននៅសហរដ្ឋអាមេរិកនៅសម័យនោះ។ ក្រោយមក និស្សិតមហាវិទ្យាល័យដែលខ្ញុំកំពុងធ្វើការជាមួយ បានបញ្ចេញយោបល់អំពីការរំខានដែលវីដេអូនោះមានចំពោះនាង។ ខ្ញុំមិនដែលគិតអំពីលទ្ធផល ដែលវីដេអូនៅផ្ទៃខាងក្រោយអាចរំខានដល់ការថ្វាយបង្គំទេ។ នាងមានការព្រួយបារម្ភមួយដ៏ត្រឹមត្រូវ។ ព្រះវិហារជាច្រើនបានផ្លាស់ប្ដូរពីការបញ្ចាំងវីដេអូដ៏ស្មុគស្មាញទៅជារូបភាពសាមញ្ញបំផុតក៏ដោយសារការព្រួយបារម្ភនេះដែរ។ សូមពិចារណាអំពីស្ថានភាពរបស់អ្នក និងអ្វីដែលទំនាក់ទំនងល្អ និងអ្វីដែលរំខាន នៅពេលអ្នកកំណត់ពីរបៀបជ្រើសរើសផ្ទៃខាងក្រោយសម្រាប់បញ្ចាំងអត្ថបទចម្រៀង។

ផ្នែកខ្លះនៃកម្មវិធីអាច ឬមិនអាចត្រូវបានធ្វើឲ្យប្រសើរឡើង ដោយសាររូប

ភាពនៅលើអេក្រង់នោះទេ។ ព្រះវិហារខ្លះចូលចិត្តមានការបញ្ចាំងពីដើមដល់ចប់កម្មវិធីថ្វាយបង្គំ។ ព្រះវិហារខ្លះទៀតមិនមានការបញ្ចាំងក្នុងផ្នែកខ្លះនៃកម្មវិធីថ្វាយបង្គំ។ ខ្ញុំសូមលើកទឹកចិត្តអ្នក សូមកុំបញ្ចាំងរូបឡូហ្គោរបស់ព្រះវិហារ ក្នុងពេលដែលមិនមានបញ្ចាំងអ្វីសោះ ដូចដែលព្រះវិហារជាច្រើនកំពុងធ្វើនោះឡើយ។ កម្មវិធីថ្វាយបង្គំមិនមែនជាពេលសម្រាប់ផ្សព្វផ្សាយផ្លាកយីហោរបស់អ្នកនោះទេ តែផ្ទុយទៅវិញវាជាពេលលើកដំកើងព្រះយេស៊ូវ។

ចូរបង្កើតបទបង្ហាញរបស់អ្នក។ នៅពេលអ្នកចាប់ផ្ដើមចងក្រងវីដេអូ ឬរូបភាពសម្រាប់បញ្ចាំង ក្នុងកម្មវិធីថ្វាយបង្គំ សូមបើកកម្មវិធីក្នុងកុំព្យូទ័រសម្រាប់បញ្ចាំង និងលំហូរនៃកម្មវិធីថ្វាយបង្គំសម្រាប់កម្មវិធីថ្វាយបង្គំ។ សូមបង្កើតបញ្ជីថ្មីមួយនៅក្នុងកម្មវិធីធ្វើបទបង្ហាញសម្រាប់កម្មវិធីថ្វាយបង្គំ សម្រាប់យោងទៅតាមលំហូរនៃកម្មវិធីថ្វាយបង្គំ ហើយចាប់ផ្ដើមដាក់បញ្ចូល ឬបង្កើតធាតុផ្សំទាំងអស់សម្រាប់កម្មវិធីតាំងពីដើមដល់ចប់។ ឧទាហរណ៍ ព្រះវិហារអ្នកអាចបញ្ចាំងស្លាយផ្សាយដំណឹងផ្សេងៗ នៅពេលដែលពួកជំនុំកំពុងចូលកៅអីជួបជុំគ្នាមុនពេលកម្មវិធីចាប់ផ្ដើម។ ស្លាយរូបភាពមិនមានចលនាអាចជួយបង្កើតបរិយាកាសសម្រាប់ការអធិស្ឋាន ពិធីលៀងព្រះអម្ចាស់។ល។ អ្នកអាចបង្ហាញអត្ថបទព្រះគម្ពីរនៅលើអេក្រង់ ខណៈពេលដែលពួកគេអានដោយផ្ទាល់ខ្លួន ឬអានជាមួយគ្នា។

នៅពេលអ្នកបង្កើតបទចម្រៀងនីមួយៗ សូមប្រាកដថា អត្ថបទចម្រៀង និងលំដាប់លំដោយបទចម្រៀងត្រូវគ្នានឹងអ្វីដែលអ្នកចង់ធ្វើនៅក្នុងការថ្វាយបង្គំ។ ការនេះនឹងជួយបង្ការមិនឲ្យអត្ថបទចម្រៀងចេញខុសនៅលើអេក្រង់ក្នុងកម្មវិធីថ្វាយបង្គំ។ ប្រសិនបើអ្នកកំពុងច្រៀងដោយប្រើសៀវភៅទំនុកតម្កើង និងការបញ្ចាំងនៅអេក្រង់ សូមប្រាកដថា ពាក្យនៅលើអេក្រង់ត្រូវគ្នានឹងពាក្យនៅក្នុងសៀវភៅទំនុកតម្កើង។

អ្នកអាចបញ្ចូលក្រាហ្វិកជាជំនួយដល់ការអធិប្បាយ។ គ្រូគង្វាលជាច្រើនបានបង្កើតសម្ភារៈជាជំនួយដល់ការបង្រៀនផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រសិនបើវាត្រូវបានធ្វើរួចនៅក្នុងកម្មវិធី PowerPoint ឬ Keynote អ្នកអាចដំណើរការវានៅក្នុងកម្មវិធីដើមរបស់ពួកវា ឬបញ្ចូលស្លាយទៅក្នុងកម្មវិធីបញ្ចាំងរបស់កម្មវិធីថ្វាយបង្គំដើម្បីឲ្យមានបទពិសោធន៍ឲ្យកាន់តែរលូន និងអាចគ្រប់គ្រងបាន។ អ្នកនាំចេញស្លាយនីមួយៗជាឯកសាររូបភាព (PNG ឬ JPEG) ហើយបន្ទាប់មកបញ្ចូលវាទៅក្នុងកម្មវិធីបញ្ចាំងរូបភាពរបស់អ្នក។ ត្រូវប្រាកដថាអ្នកទាញចេញឯកសារដែលមានគុណភាពបង្ហាញខ្ពស់ដែលត្រូវគ្នា ឬលើសពីគុណភាពបង្ហាញរបស់អ្នក។

នៅពេលដែលអ្នកបានប្រមូលផ្ដុំរូបភាព ឬវីដេអូទាំងអស់ និងត្រៀមជាស្រេចសម្រាប់ចាក់បញ្ចាំង អ្នកគួរតែបង្កើតក្រដាសបច្ចេកទេស ដើម្បីជួយណែនាំអ្នកស្ម័គ្រចិត្តដែលបញ្ចាស្លាយក្នុងកម្មវិធីថ្វាយបង្គំ។ ខ្ញុំបង្កើតកំណត់ចំណាំផ្នែកបច្ចេកទេសសម្រាប់អ្នកបច្ចេកទេស ដោយបង្ហាញព័ត៌មានដែលពួកគេត្រូវការ។

ជាងនេះទៅទៀត កុំភ្លេចផ្ដល់ការបណ្ដុះបណ្ដាលដ៏ល្អសម្រាប់អ្នកបច្ចេកទេសរបស់អ្នក។ សូមជួយពួកគេឲ្យទទួលបានជោគជ័យក្នុងការងាររបស់ពួកគេតាមរយៈការផ្ដល់ឲ្យពួកគេនូវការបណ្ដុះបណ្ដាលដើម្បីបំពេញតម្រូវការរបស់ពួកគេ។

**ក្នុងការត្រៀមការចាក់បញ្ចាំង តើមានផ្នែកណាខ្លះ**
**ដែលអ្នកត្រូវកែលម្អ?**

## ការរៀបចំក្រុមជំនុំសម្រាប់កម្មវិធីថ្វាយបង្គំ

ប្រសិនបើក្រុមជំនុំបានប្រជុំគ្នា ដោយការត្រៀមខ្លួនសម្រាប់ការថ្វាយបង្គំរួមរៀងរាល់សប្ដាហ៍ ការចំណាយពេលរបស់យើងជាមួយគ្នា នឹងកាន់តែមានអត្ថន័យថែមទៀត។ ក្នុងនាមជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ខ្ញុំដឹងថាមនុស្សច្រៀងបានល្អបំផុត នៅពេលដែលពួកគេច្រៀងចម្រៀងដែលពួកគេចេះ។ ហើយខ្ញុំក៏ដឹងដែរថា ការថ្វាយបង្គំផ្ទាល់ខ្លួនត្រូវកើតមានមុនការថ្វាយបង្គំរួម បានសេចក្ដីថាពេលវេលាឯកជននៃការថ្វាយបង្គំប្រចាំថ្ងៃមានសារៈសំខាន់ខ្លាំងណាស់ចំពោះការថ្វាយបង្គំរួម។ ដើម្បីជួយក្រុមជំនុំរៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំ ខ្ញុំចង់លើកទឹកចិត្តឲ្យមានការថ្វាយបង្គំផ្ទាល់ខ្លួនក្នុងអំឡុងសប្ដាហ៍នោះ ហើយផ្ដល់ឲ្យពួកគេនូវឧបករណ៍ ដើម្បីរៀបចំខ្លួនសម្រាប់ការច្រៀងជាលក្ខណៈក្រុមជំនុំ ដើម្បីជួយពួកគេឲ្យស្គាល់បទចម្រៀងក្នុងក្រុមជំនុំ និងព្រះរាជសារ។ ព្រះវិហារជាច្រើនបោះពុម្ពផ្សាយឯកសារ (តាមអ៊ីនធឺណិត និង/ឬច្បាប់ចម្លងរឹង) ដើម្បីជួយក្រុមជំនុំរបស់ពួកគេរៀបចំខ្លួន (ដោយផ្ទាល់ខ្លួន ឬជាលក្ខណៈគ្រួសារ) សម្រាប់កម្មវិធីថ្វាយបង្គំប្រចាំសប្ដាហ៍។ ខាងក្រោមនេះគឺជាគំនិតមួយចំនួន ដែលអាចជំរុញឲ្យអ្នកគិត អំពីរបៀបជួយក្រុមជំនុំរបស់អ្នកបានល្អបំផុត៖

# មាតិកា

តើព័ត៌មានអ្វីខ្លះដែលអ្នកចង់ផ្តល់ឲ្យពួកជំនុំរបស់អ្នក ដើម្បីជួយពួកគេរៀបចំខ្លួន? នេះគឺជាឱកាសរបស់អ្នកដើម្បីជួយសមាជិកក្រុមជំនុំរបស់អ្នករៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំរៀងរាល់សប្តាហ៍។ មានធាតុផ្សំជាច្រើនអាចមានប្រយោជន៍ក្នុងផ្នែកចែករំលែកព័ត៌មានរបស់អ្នក។ សូមប្រយ័ត្នកុំធ្វើឲ្យវាស្មុគស្មាញពេក ដើម្បីកុំឲ្យពួកគេមានអារម្មណ៍ថា វានឹងចំណាយពេលច្រើនពេកដើម្បីចូលរួម។ ការថ្វាយបង្គំគឺជាធាតុសំខាន់នៃដំណើរការបង្កើតសិស្ស។ សូមរាប់បញ្ចូលធាតុផ្សំទាំងនេះនៅក្នុងផ្នែកចែករំលែកព័ត៌មានរបស់អ្នក៖

## ការរៀបចំសម្រាប់ការអធិប្បាយព្រះបន្ទូល

សូមផ្តល់ឲ្យពួកជំនុំនូវអត្ថបទព្រះគម្ពីរ និងព័ត៌មានមួយចំនួន (ប្រហែលជាសង្ខេបខ្លីៗ) ដើម្បីជួយពួកគេរៀបចំខ្លួនទទួលការអធិប្បាយព្រះបន្ទូល។ សូមសួរសំណួរដែលនឹងជួយពួកគេចាប់អារម្មណ៍នឹងចំណុចសំខាន់ៗក្នុងការអធិប្បាយព្រះបន្ទូល។

## ចំណុចអធិស្ឋាន

សូមផ្តល់ឲ្យចំណុចអធិស្ឋានជាក់លាក់ ដែលនឹងជួយពួកជំនុំរៀបចំចិត្តសម្រាប់កម្មវិធីថ្វាយបង្គំ ហើយអធិស្ឋានអំពីផែនការទាំងនោះ និងកម្មវិធីថ្វាយបង្គំផងដែរ។ នេះមិនមែនជាបញ្ជីអធិស្ឋានរបស់ក្រុមជំនុំរបស់អ្នកសម្រាប់អ្នកដែលឈឺ ឬកាន់ទុក្ខ។ល។ តែជាបញ្ជីសេចក្តីអធិស្ឋាន សម្រាប់ជួយពួកជំនុំអ្នកអធិស្ឋានជាក់លាក់ អំពីកម្មវិធីថ្វាយបង្គំ និងអ្នកដឹកនាំ។ សេចក្តីអធិស្ឋានទាំងនេះផ្តោតទៅលើនគរព្រះច្រើនជាង។ ខ្ញុំសូមផ្តល់ជាគំនិតខ្លះៗដូចជា៖ ចូរអធិស្ឋានឲ្យអ្នកដែលនឹងដឹកនាំនៅក្នុងការថ្វាយបង្គំ សូមអធិស្ឋានសុំព្រះវិញ្ញាណបរិសុទ្ធធ្វើចលនានៅក្នុងការថ្វាយបង្គំរបស់យើង ដឹកនាំយើងឲ្យលើកតម្កើងព្រះយេស៊ូវគ្រីស្ទ និងអធិស្ឋានសូមព្រះទ្រង់ជំរុញយើងឲ្យចែកចាយសេចក្តីស្រឡាញ់របស់ទ្រង់ជាមួយសហគមន៍របស់យើង។ល។

## បទចម្រៀងថ្វាយបង្គំ

អ្នកអាចបញ្ចូលតំណភ្ជាប់អ៊ីនធឺណិតទៅកាន់បទចម្រៀងក្នុងបណ្តាញសង្គម បទចម្រៀងដែលបង្ហាញអត្ថបទ ដើម្បីក្រុមជំនុំរបស់អ្នកអាចថ្វាយបង្គំបទចម្រៀងនោះពេញមួយសប្តាហ៍។ សូមស្វែងរកបទចម្រៀង ដែលពួកគេប្រហែលជាមិន

សូរមានអ្នកចេះ។ អ្នកអាចបញ្ចូលអត្ថបទព្រះបន្ទូលសម្រាប់ការប្រកបជាមួយព្រះ ដែលទាក់ទងទៅនឹងអត្ថបទនៃបទចម្រៀងផងដែរ បើសិនជាអាច។

### ការតាមដានពីសប្តាហ៍មុន

អ្នកអាចរាប់បញ្ចូលសំណួរ និងអត្ថបទពន្យល់បន្ថែមសម្រាប់ឲ្យពួកជំនុំពិចារណាបន្ទាប់ពីការថ្វាយបង្គំកាលពីសប្តាហ៍មុន ដើម្បីបន្តការចូលរួមរបស់ពួកគេជាមួយនឹងព្រះបន្ទូលរបស់ព្រះសម្រាប់ថ្ងៃនោះ។

### ការថ្វាយបង្គំជាលក្ខណៈគ្រួសារ

ស្វែងរកវិធីជួយក្រុមគ្រួសាររបស់អ្នក ឲ្យថ្វាយបង្គំជាមួយគ្នានៅផ្ទះ។ ចូរបង្កើតការជួបប្រជុំគ្នាក្នុងការថ្វាយបង្គំជាលក្ខណៈគ្រួសារ ដែលនាំមនុស្សគ្រប់ជំនាន់មកជុំគ្នារៀនព្រះបន្ទូលព្រះ។ អ្នកអាចបង្កើតមេរៀន ជាពិសេសសម្រាប់ពេលវេលាថ្វាយបង្គំជាក្រុមគ្រួសារ ទាក់ទងនឹងការសង្កត់ធ្ងន់ប្រចាំសប្តាហ៍។

## ប្រព័ន្ធចែកផ្សាយព័ត៌មាន

អ្នកអាចរៀបចំនូវអ្វីដែលត្រូវចែកផ្សាយតាមវិធីជាច្រើន។ អ្នកអាចប្រើវិធីមួយ ឬច្រើនក្នុងចំណោមវិធីខាងក្រោមនេះជាប្រយោជន៍ដល់ក្រុមជំនុំរបស់អ្នក។ ការប្រើមធ្យោបាយច្រើនធ្វើឲ្យការងារមានប្រសិទ្ធភាពបំផុត។

### មាតិការអនឡាញ

អ្នកអាចរៀបចំឲ្យមានគេហទំព័រដែលមានព័ត៌មានប្រចាំសប្តាហ៍ ដែលគេអាចចូលមើលយ៉ាងងាយស្រួល និងមានតំណបណ្តាញទៅកាន់វេទិកាអនឡាញផ្សេងៗ។ វាអាចនៅលើគេហទំព័រដែលមានស្រាប់របស់ព្រះវិហាររបស់អ្នក ឬជាគេហទំព័រពិសេសដែលបង្កើតឡើងសម្រាប់គោលបំណងនេះ។

### បណ្តាញសង្គម

អ្នកអាចប្រើមធ្យោបាយបណ្តាញសង្គម ដើម្បីភ្ជាប់ខ្លឹមសារជាមួយពួកជំនុំរបស់អ្នក ក្នុងអំឡុងពេលសប្តាហ៍នីមួយៗ។

### អ៊ីម៉ែល

អ្នកក៏អាចគិតចង់ប្រើអ៊ីមែលប្រចាំសប្តាហ៍ និង/ឬប្រចាំថ្ងៃដែលមានខ្លឹមសារសម្រាប់មួយសប្តាហ៍នោះ។

### ការផ្ញើសារជាក្រុម

អ្នកអាចផ្ញើសារជាក្រុមដោយមានតំណភ្ជាប់ទៅកាន់ធនធាន ដូចជាវីដេអូអនឡាញ ឬគេហទំព័រថ្វាយបង្គំ ដើម្បីជួយពួកជំនុំក្នុងការរៀបចំខ្លួន។

### ការបោះពុម្ពជាក្រដាស

ក្នុងកម្មវិធីថ្វាយបង្គំ អ្នកអាចចែកចាយក្រដាសមេរៀនដែលមានខ្លឹមសារនៃកម្មវិធីថ្វាយបង្គំក្នុងសប្តាហ៍បន្ទាប់។ (ជាការពិតណាស់ វិធីមួយនេះមិនមានប្រយោជន៍សម្រាប់អ្នកដែលអវត្តមានក្នុងសប្តាហ៍នេះ ប៉ុន្តែ មានប្រយោជន៍សម្រាប់អ្នកដែលមិនមានអ៊ីនធឺណិតប្រើ) ។

ការឆ្លៀតពេលផលិតមេរៀនជាជំនួយការរៀបចំខ្លួនដូចនេះ អាចមានអត្ថប្រយោជន៍យ៉ាងខ្លាំង ដល់ការបង្កើតសិស្សដែលថ្វាយបង្គំព្រះ។

## ការអនុវត្តល្អបំផុត

កាលខ្ញុំមានតួនាទីជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំបណ្ដោះអាសន្ន ខ្ញុំបានធ្វើកិច្ចការមួយចំនួនដើម្បីជួយក្រុមជំនុំរបស់យើងនៅក្នុងផ្នែកនេះ៖

- ខ្ញុំបានបង្កើតគេហទំព័រថ្វាយបង្គំសម្រាប់ក្រុមជំនុំដែលផ្ដល់ព័ត៌មានអំពីសេចក្ដីអធិប្បាយជារៀងរាល់សប្ដាហ៍ ហើយបានផ្ដល់ឲ្យវីដេអូដែលមានទំនុកច្រៀងរបស់បទចម្រៀងសម្រាប់ក្រុមជំនុំច្រៀង។ គេហទំព័រនេះក៏មានតំណភ្ជាប់ទៅកាន់គេហទំព័រការថ្វាយបង្គំជាច្រើន សម្រាប់ការប្រើប្រាស់ក្នុងក្រុមជំនុំរបស់យើង។

- នៅលើបណ្ដាញសង្គម និងក្នុងការផ្ញើសារជាក្រុម ខ្ញុំបានបង្ហោះតំណភ្ជាប់ទៅកាន់គេហទំព័រ ជាជំនួយការរៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំ និងមានការលើកទឹកចិត្តឲ្យរៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំ។

- ខ្ញុំបានបញ្ចូលអត្ថបទចម្រៀងពីលើវីដេអូនៅលើបណ្ដាញសង្គម ឬក្នុងការផ្ញើសារជាក្រុម។

- ខ្ញុំបានបញ្ចូលពាក្យជំរុញចិត្តឲ្យអធិស្ឋានអំពីកម្មវិធីថ្វាយបង្គំនៅលើទំព័របណ្ដាញសង្គម ឬក្នុងការផ្ញើសារជាក្រុម។

- អ៊ីមែលប្រចាំសប្ដាហ៍ត្រូវបានផ្ញើទៅសមាជិកព្រះវិហារដែលមានដំណឹងផ្សេងៗរួមទាំងបញ្ជីចម្រៀងប្រចាំសប្ដាហ៍។ ហើយក៏មានការលើកទឹកចិត្តឲ្យក្រុមជំនុំចូលទៅកាន់គេហទំព័រសម្រាប់ការរៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំ (URL ត្រូវបានបញ្ចូល) ដើម្បីរៀបចំខ្លួនឲ្យកាន់តែល្អសម្រាប់កម្មវិធីថ្វាយបង្គំ។

- ក្នុងការជូនដំណឹង និងការប្រកាសនៅលើអេក្រង់មានការបង្ហាញគេហទំព័រសម្រាប់ការរៀបចំខ្លួនសម្រាប់កម្មវិធីថ្វាយបង្គំ។

យើងដឹងថាក្រុមជំនុំនីមួយៗមានលក្ខណៈពិសេសរៀងខ្លួន ហើយរបៀបដែលអ្នកអាចរៀបចំក្រុមជំនុំរបស់អ្នកបានល្អបំផុត គួរតែស្របតាមតម្រូវការក្នុងក្រុមជំនុំរបស់អ្នក។

ការដែលគ្រូគង្វាលរបស់អ្នកលើកឡើងអំពីធនធានទាំងនេះទៀងទាត់ នឹងជួយឲ្យក្រុមជំនុំមានចំណាប់អារម្មណ៍ច្រើនចំពោះធនធានទាំងនេះ។ នៅព្រះវិហារមួយដែលខ្ញុំបានបម្រើគ្រូគង្វាលបានរៀបរាប់ថាគាត់ និងប្រពន្ធកូនរបស់គាត់បានចំណាយពេលជាញឹកញាប់ក្នុងមួយសប្ដាហ៍ ដើម្បីច្រៀងចម្រៀងដែលនឹងត្រូវប្រើក្នុងការថ្វាយបង្គំនៅថ្ងៃអាទិត្យខាងមុខនេះ។ ការចែកចាយទីបន្ទាល់អំពីរបៀបដែលការអនុវត្តដូចនេះបានជួយដល់ការថ្វាយបង្គំផ្ទាល់ខ្លួននិងពេលវេលាថ្វាយបង្គំជាគ្រួសារ គឺជាវិធីល្អបំផុត ដើម្បីលើកទឹកចិត្តឲ្យក្រុមជំនុំរបស់គាត់ឲ្យអនុវត្តដូចនេះដែរ។

**តើអ្នកត្រូវអនុវត្តជាជំហានៗដូចម្ដេចខ្លះ ដើម្បីជួយពួកជំនុំរបស់អ្នករៀបចំខ្លួនសម្រាប់ការថ្វាយបង្គំរួម?**

## ការរៀបចំផ្ទាល់ខ្លួនសម្រាប់ការថ្វាយបង្គំ

មកដល់ពេលនេះ អ្នកបានរៀបចំអ្នកភ្លេង ក្រុមជំនុំ និងក្រុមប្រព័ន្ធបញ្ចាំងរូបភាពសម្រាប់កម្មវិធីថ្វាយបង្គំហើយ ប៉ុន្តែ អ្នកត្រូវតែគិតដល់ផ្នែកដ៏សំខាន់មួយគឺខ្លួនឯង។ ការនេះមានសារៈសំខាន់ណាស់។ ក្នុងនាមអ្នកជាអ្នកដឹកនាំការថ្វាយបង្គំ

តើអ្នករៀបចំខ្លួនសម្រាប់ការថ្វាយបង្គំរួមដោយរបៀបណា? របៀបដែលអ្នកឆ្លើយសំណួរនេះ អាចមានឥទ្ធិពលខ្លាំងលើការដឹកនាំរបស់អ្នក។ នេះជាវិធីមួយចំនួនដែលខ្ញុំរៀបចំសម្រាប់ការដឹកនាំកម្មវិធីថ្វាយបង្គំ។

## រៀបចំខាងវិញ្ញាណ

ចូរចំណាយពេលជាមួយព្រះពេញមួយសប្តាហ៍។ ចូរឲ្យការថ្វាយបង្គំក្លាយជាផ្នែកធម្មតាមួយនៃជីវិតរបស់អ្នកពេញមួយថ្ងៃ។

- វិធីដ៏ប្រសើរមួយ ដើម្បីរៀបចំខ្លួនជាពិសេសសម្រាប់កម្មវិធីថ្វាយបង្គំប្រចាំសប្តាហ៍ គឺត្រូវចំណាយពេលក្នុងការថ្វាយបង្គំផ្ទាល់ខ្លួន ដោយប្រើបទចម្រៀងដែលអ្នកនឹងដឹកនាំគេច្រៀង។ សូមជញ្ជឹងគិតអំពីពាក្យនៃបទចម្រៀង។ សូមអនុញ្ញាតឲ្យពាក្យពេចន៍ទាំងនោះប៉ះពាល់ជីវិតរបស់អ្នក។ អ្នកអាចអានបទគម្ពីរដែលពាក់ព័ន្ធនឹងបទចម្រៀងទាំងនោះ។ ចូរច្រៀងបទចម្រៀងទាំងនោះថ្វាយព្រះ ដូចដែលអ្នកថ្វាយបង្គំ និងសរសើរតម្កើងព្រះដោយផ្ទាល់ខ្លួន។ កាលណាអ្នកថ្វាយបង្គំដោយប្រើបទចម្រៀងកាន់តែច្រើនក្នុងអំឡុងសប្តាហ៍នោះ ការដឹកនាំរបស់អ្នកនឹងកាន់តែប្រសើរឡើងដោយសាររបៀបដែលអ្នកដើរជាមួយព្រះ។

- សូមចំណាយពេលជាមួយព្រះបន្ទូល និងការអធិស្ឋាន។ ចូរស្វែងរកព្រះហឫទ័យនៃព្រះសម្រាប់ជីវិត និងព័ន្ធកិច្ចរបស់អ្នក។

- បើសិនជាអាច សូមចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ នៅក្នុងកន្លែងកម្មវិធីថ្វាយបង្គំនៃព្រះវិហាររបស់អ្នក ហើយអធិស្ឋានឲ្យអ្នកដែលនឹងចូលរួមក្នុងកម្មវិធីនេះ។ សូមអធិស្ឋានដោយដើរទៅមកនៅទីនោះ។ នៅពេលអ្នកដើរអធិស្ឋានក្នុងកន្លែងកម្មវិធីថ្វាយបង្គំ សូមអធិស្ឋានសម្រាប់មនុស្សតាមឈ្មោះជាក់លាក់អំពីតម្រូវការដែលអ្នកដឹង។ ក្នុងពេលថ្វាយបង្គំផ្ទាល់ខ្លួនសូមលេងព្យាណូ ឬហ្គីតា ខណៈពេលដែលអ្នកច្រៀងបទចម្រៀង ដែលអ្នកនឹងដឹកនាំច្រៀង នៅថ្ងៃអាទិត្យ។

គេមិនអាចមើលស្រាលតម្លៃខាងវិញ្ញាណនៃការរៀបចំផ្ទាល់ខ្លួនឡើយ។ សម្រាប់ខ្ញុំពេលវេលាប្រកបជាមួយព្រះក្នុងការថ្វាយបង្គំតាមរយៈបទចម្រៀងទាំងនេះ មានប្រយោជន៍ជាខ្លាំងចំពោះភាពជាអ្នកដឹកនាំរបស់ខ្ញុំក្នុងការថ្វាយបង្គំរួមគ្នា។

ការអធិស្ឋានដ៏ជាក់លាក់សូមព្រះអង្គធ្វើការក្នុងកម្មវិធីថ្វាយបង្គំ ហើយអធិស្ឋានឲ្យគេចំឈ្មោះ គឺជាធាតុផ្សំដ៏មានអំណាច ក្នុងការរៀបចំខ្លួន។ លើសពីនេះទៅទៀត ពេលខ្លះ ខ្ញុំបានអញ្ជើញអ្នកផ្សេងទៀត ឲ្យចូលរួមជាមួយខ្ញុំនៅក្នុងការដើរអធិស្ឋានក្នុងទីបរិសុទ្ធ នៅព្រឹកថ្ងៃអាទិត្យមុនពេលកម្មវិធីថ្វាយបង្គំចាប់ផ្ដើម។ ការបង្រួបបង្រួមដួងចិត្តយ៉ាងដូចនេះ គឺជាការអនុវត្តដែលមានតម្លៃណាស់។

# រៀបចំខ្លួនអ្នកសម្រាប់ការដឹកនាំ

## ការឆ្លងបទចម្រៀង និងការនាំចូលបទចម្រៀង

បន្ថែមពីលើការរៀបចំខាងវិញ្ញាណ ខ្ញុំឆ្លៀតពេលគិតអំពីការឆ្លងពីចំណុចមួយទៅចំណុចមួយទៀតក្នុងកម្មវិធីថ្វាយបង្គំ។ ខ្ញុំផ្ដោតជាពិសេសលើរបៀបដែលខ្ញុំនឹងនាំគេចូលចម្រៀងនីមួយៗដែលក្រុមជំនុំនឹងច្រៀង។ ប្រសិនបើបទចម្រៀងនោះ គឺជាផ្នែកមួយក្រុមបទចម្រៀង (ពីរ ឬច្រើនបទជាប់ៗគ្នា) ខ្ញុំក៏គិតអំពីឃ្លាភ្ជាប់សេចក្តីពីបទមួយទៅបទមួយទៀតដែលចាំបាច់ ក្នុងអំឡុងពេលការប្រគំតន្ត្រី/ការផ្លាស់ប្តូរដែលឆ្លងបទចម្រៀងជាមួយគ្នាយ៉ាងរលូន។ ការកាត់បន្ថយការបរិយាយបទចម្រៀងឲ្យខ្លីៗ គឺជាជម្រើសល្អបំផុតស្ទើរគ្រប់ពេល ហើយជាញឹកញាប់ការអនុញ្ញាតឲ្យបទចម្រៀងបកស្រាយអត្ថន័យដោយខ្លួនឯង ក៏ជាជម្រើសល្អបំផុតផងដែរ(អាចនិយាយម៉្យាងទៀតថា យើងមិននិយាយអ្វីនៅដើមដំបូងនៃបទចម្រៀង)។ អ្នកក៏អាចទទួលខុសត្រូវចំពោះការតភ្ជាប់រវាងធាតុផ្សំផ្សេងទៀតនៃកម្មវិធីថ្វាយបង្គំផងដែរ ដូច្នេះ សូមរៀបចំផែនការសម្រាប់ចំណុចនេះផងដែរ។ ជំពូកបន្ទាប់នឹងចូលជ្រៅទៅក្នុងការឆ្លងបទចម្រៀងដោយពាក្យសំដី។

## ការប្រើប្រាស់បទគម្ពីរ

ខ្ញុំយល់ឃើញថា ការដកស្រង់បទគម្ពីរ គឺជាវិធីដែលមានឥទ្ធិពលបំផុត ដើម្បីនាំគេចូលបទចម្រៀង។ សូមស្វែងរកខគម្ពីរដែលសមស្របនឹងអត្ថបទចម្រៀងរបស់អ្នក។ សូមប្តេជ្ញាចិត្តចងចាំខគម្ពីរសម្រាប់ការសរសើរតម្កើង។ មានពេលខ្លះព្រះទ្រង់អាចធ្វើឲ្យអ្នកនឹកឃើញខគម្ពីរមួយ នៅពេលអ្នកកំពុងដឹកនាំកម្មវិធីថ្វាយបង្គំ។

## ការកត់ត្រាទុកពាក្យពេចន៍ដែលអ្នកនឹងប្រើក្នុងការឆ្លងចម្រៀង

នៅពេលដែលអ្នកគិតឃើញរបៀបដែលអ្នកនឹងនាំគេចូលបទចម្រៀងណាមួយ សូមសរសេរវាទុក។ មានពេលញឹកញាប់ពេកហើយដែលអ្នកដឹកនាំកម្មវិធី

ថ្វាយបង្គំនិយាយដោយមិនបានព្រាងទុក ហើយនិយាយច្រើនពេកដោយមិនមានអ្វីជាដុំកំភួន។ ការសរសេរគំនិតនោះទុកជួយអ្នករៀបចំគំនិតរបស់អ្នក និងសង្ខេបវាឲ្យខ្លី។ អ្នកមិនចាំបាច់អានអ្វីដែលអ្នកសរសេរទេ ប៉ុន្តែ ពេលអ្នកនិយាយអ្នកនឹងនិយាយដោយការរៀបចំបានល្អ និងច្បាស់លាស់ទៅកាន់ពួកជំនុំ។

## ការចងក្រងធនធាន

ព្រះវិហារខ្លះប្រើស្រ្កីនដែលអ្នកនៅលើឆាកអាចមើល ពេលកំពុងដឹកនាំកម្មវិធីថ្វាយបង្គំ។ អ្នកអាចមើលឃើញអត្ថបទចម្រៀងដែលកំពុងនាំគេច្រៀង និងមើលស្លាយបន្ទាប់។ ខ្ញុំក៏បានត្រៀមក្រដាសចម្រៀងដែលសម្រាប់បទចម្រៀងនីមួយៗ ដែលមួយទំព័រមានបទចម្រៀងមួយបទ ទុកសម្រាប់ប្រើតាមដែលចាំបាច់។ លើសពីនេះទៀត ខ្ញុំនឹងរៀបចំកំណត់ចំណាំដែលខ្ញុំត្រូវការសម្រាប់នាំគេចូលបទចម្រៀង។ ខ្ញុំក៏មានក្រដាសកម្មវិធីថ្វាយបង្គំទាំងមូលដែលមើលលំដាប់លំដោយនៃកម្មវិធី។ ខ្ញុំអាចបោះពុម្ពវាចេញនៅលើក្រដាស ឬផ្ទុកវានៅលើឧបករណ៍ថេប្លេតប្រសិនបើមាន។

**នៅពេលអ្នករៀបចំខ្លួនបានល្អអ្នកនឹងឃើញថា អ្នកមានសេរីភាពកាន់តែច្រើនក្នុងការថ្វាយបង្គំរបស់អ្នក ហើយមានសមត្ថភាពកាន់តែច្រើនក្នុងការថ្វាយបង្គំ ខណៈពេលដែលកំពុងដឹកនាំកម្មវិធីថ្វាយបង្គំ។**

**តើអ្នកកំពុងត្រៀមខ្លួនយ៉ាងគ្រប់គ្រាន់ ដើម្បីដឹកនាំកម្មវិធីថ្វាយបង្គំ រៀងរាល់សប្តាហ៍ឬទេ? តើអ្នកត្រូវត្រៀមខ្លួនខ្លាំងបំផុតនៅត្រង់ផ្នែកណាខ្លះ?**

## គំនិតចុងក្រោយ

មកដល់ពេលនេះអ្នកបានរៀបចំផែនការ និងរៀបចំខ្លួនបានល្អហើយ ឥឡូវនេះ អ្នកដល់ពេលដែលត្រូវដឹកនាំឲ្យបានល្អ។ ប្រសិនបើ អ្នកបានធ្វើការរៀបចំខ្លួនជាលក្ខណៈផ្ទាល់ខ្លួនខាងវិញ្ញាណ និងខាងតន្ត្រីក៏ដូចជាការរៀបចំផ្សេងទៀតដែលខ្ញុំបានរៀបរាប់រួចហើយ សូមថ្វាយពេលវេលារបស់អ្នកដាច់ដល់ព្រះ ហើយដឹកនាំក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំ។ ចូរបន្តនាំពួកជំនុំផ្តោតទៅលើព្រះ ហើយមិនមែនទៅ

លើអ្នកដឹកនាំកម្មវិធីថ្វាយបង្គំឡើយ។ ចូររៀបចំបរិយាកាសដោយបំបាត់ការរំខាន ដែលរារាំងការថ្វាយបង្គំរបស់ពួកជំនុំ។ កាលណាអ្នក និងក្រុមរបស់អ្នកមានការ រៀបចំបានល្អជាងមុន អ្នកនឹងកាន់តែអាចថ្វាយបង្គំពិតប្រាកដ ខណៈពេលដែល អ្នកកំពុងដឹកនាំ។ ចូរអបអរសាទរជីវិតដែលបានផ្លាស់ប្ដូរតាមរយៈការចំណាយ ពេលថ្វាយបង្គំ!

សូមថ្វាយសិរីរុងរឿងដល់ព្រះ!

# V. ការដឹកនាំការថ្វាយបង្គំ

ក្នុងជំពូកកន្លងមក យើងបានរៀនបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការថ្វាយបង្គំ រៀបចំផែនការ និងការអនុវត្តនូវការថ្វាយបង្គំរួម។ មានផ្នែកផ្សេងទៀត នៅក្នុងការដឹកនាំការថ្វាយបង្គំដែលគេបានសួរខ្ញុំជាប្រចាំ គឺផ្នែកដែលមានការនិយាយនៅចន្លោះបទចម្រៀង និងធាតុផ្សំផ្សេងទៀតនៃការថ្វាយបង្គំ ហើយនិងការជួយក្រុមចម្រៀងធ្វើការនៅលើវេទិកា។ ខ្ញុំនឹងផ្ដល់ការណែនាំមួយចំនួននៅក្នុងផ្នែកទាំងនោះនៅក្នុងជំពូកនេះ។ ដូចគ្នានេះផងដែរ ខ្ញុំនឹងពិភាក្សាអំពីវិធីដឹកនាំការថ្វាយបង្គំដោយជោគជ័យ នៅពេលដែលគេស្នើអ្នកឲ្យដឹកនាំក្រុមមនុស្សពីព្រះវិហារផ្សេងៗមកជួបជុំគ្នាសម្រាប់សន្និសីទ ការជួបជុំទ្រង់ទ្រាយធំការថ្វាយបង្គំ ឬកិច្ចប្រជុំផ្សេងទៀត។ ប៉ុន្តែ ជាដំបូងខ្ញុំនឹងចែករំលែកអត្ថបទមួយដែលត្រូវបានបោះពុម្ពជាប្រាំបីភាសា និងមានមនុស្សជិត២លាននាក់អានក្នុង២០០ប្រទេស។ ប្រជាប្រិយភាពរបស់វា គឺដោយសារតែវាបានលើកយកបញ្ហាជាសកលមួយមកនិយាយ គឺបញ្ហាដែលមនុស្សជាច្រើនមិនច្រៀងក្នុងកម្មវិធីថ្វាយបង្គំនៅក្នុងព្រះវិហារជាច្រើន។ ខ្ញុំបានលើកយកបញ្ហានេះមកនិយាយនៅក្នុងជ្រុងជាច្រើននៅក្នុងសៀវភៅនេះរួចហើយ។ សៀវភៅនេះបកស្រាយអំពីហេតុផលប្រាំបួនយ៉ាងដែលមនុស្សមិនច្រៀងក្នុងការថ្វាយបង្គំ (Nine Reasons People Aren't Singing in Worship[1]) នឹងពិនិត្យឡើងវិញនូវចំណុចភាគច្រើន ក៏ដូចជាការលើកឡើងនូវចំណុចបន្ថែមមួយចំនួនផងដែរ។ មានហេតុផលជាច្រើនដែលយើងមិនបានលើកមក

១ លោក Kenny Lamm, "9 Reasons People Aren't Singing in Worship," Renewing Worship, https://www.renewingworshipnc.org/nine-reasons-people-arent-singing-in-worship. ខ្ញុំបានដកស្រង់គំនិតមួយចំនួនក្នុងដើមកថាខណ្ឌនេះពីអត្ថបទរបស់លោក David Murrow, Why men have stopped singing in church. https://www.patheos.com/blogs/churchformen/2013/05/why-men-have-stopped-singing-in-church/.

និយាយនៅទីនេះ ដូចជាហេតុផលដែលទាក់ទងនឹងដួងចិត្តរបស់អ្នកថ្វាយបង្គំជាដើម។ ខ្ញុំដឹងថា មនុស្សដែលគ្មានទំនាក់ទំនងជាមួយព្រះគ្រីស្ទគ្មានហេតុផលដែលត្រូវច្រៀងក្នុងកម្មវិធីថ្វាយបង្គំឡើយ។ ផ្ទុយទៅវិញ ខ្ញុំបានរៀបរាប់អំពីហេតុផលទាំងនោះដោយផ្តោតទៅលើអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ—គឺអ្វីដែលយើងកំពុងធ្វើដែលប្រហែលជារារាំងដល់ការច្រៀងក្នុងក្រុមជំនុំ។ ទាំងនេះគឺជារឿងដែលយើងអាចទប់ស្កាត់បាននៅពេលដែលយើងទទួលស្គាល់បញ្ហា។

## ហេតុផលប្រាំបួនយ៉ាងដែលពួកជំនុំមិនច្រៀងក្នុងការថ្វាយបង្គំ និងអ្វីដែលយើងត្រូវធ្វើ

អ្នកដឹកនាំកម្មវិធីថ្វាយបង្គំនៅទូទាំងពិភពលោក កំពុងកែប្រែកម្មវិធីថ្វាយបង្គំក្នុងព្រះវិហាររបស់ពួកគេយ៉ាងសោកសៅ (ជាញឹកញាប់ គឺដោយអចេតនា) ទៅជាព្រឹត្តិការណ៍សម្រាប់អ្នកទស្សនា និងលែងមានពួកជំនុំច្រៀងទៀត។ មុននឹងពិភាក្សាអំពីស្ថានភាពបច្ចុប្បន្នរបស់យើង សូមក្រឡេកមើលប្រវត្តិសាស្ត្រឡើងវិញ។ មុនចលនាកំណែទម្រង់ កម្មវិធីថ្វាយបង្គំត្រូវបានធ្វើឡើង ភាគច្រើនសម្រាប់ពួកជំនុំស្តាប់ និងទស្សនា។ តន្ត្រីករអាជីពគឺជាអ្នកលេងភ្លេង ហើយគេច្រៀងជាភាសាដែលពួកជំនុំមិនចេះ (គឺភាសាឡាតាំង)។ ចលនាកំណែទម្រង់នាំកម្មវិធីថ្វាយបង្គំត្រឡប់មកពួកជំនុំវិញ ដោយរាប់បញ្ចូលការច្រៀងរបស់ពួកជំនុំដែលប្រើបទភ្លេងសាមញ្ញ និងអាចច្រៀងបានជាមួយនឹងទំនុកច្រៀងតាមបទគម្ពីរដ៏រឹងមាំជាភាសាដែលពួកជំនុំចេះនិយាយ។ កម្មវិធីថ្វាយបង្គំមានការចូលរួមពីពួកជំនុំឡើងវិញ។

ការវិវត្តន៍នៃសៀវភៅទំនុកសកលដែលបានបោះពុម្ពផ្សាយ បាននាំមកនូវការផ្ទុះឡើងវិញនៃការច្រៀងរបស់ក្រុមជំនុំ ហើយក្រុមជំនុំស្រឡាញ់ពេញចិត្តការច្រៀងកាន់តែកើនឡើង។

ជាមួយនឹងការមកដល់នៃបច្ចេកវិទ្យាវីដេអូថ្មីៗព្រះវិហារបានចាប់ផ្តើមបញ្ចាំងអត្ថបទចម្រៀងរបស់ពួកគេនៅលើអេក្រង់ ហើយចំនួននៃបទចម្រៀងដែលត្រូវបានបោះចោលក្នុងព្រះវិហារបានកើនឡើងជាលំដាប់។ ដំបូងឡើយ ភាពជឿនលឿននៃបច្ចេកវិទ្យានេះនាំឲ្យមានការច្រៀងក្នុងក្រុមជំនុំឲ្យកាន់តែខ្លាំងក្លា ប៉ុន្តែ មិនយូរប៉ុន្មានការផ្លាស់ប្តូរនៃការដឹកនាំក្នុងកម្មវិធីថ្វាយបង្គំបានចាប់ផ្តើមនាំពួកជំនុំត្រឡប់ទៅជារកកម្មវិធីថ្វាយបង្គំដ៏អសកម្ម (ពួកជំនុំក្លាយជាអ្នកទស្សនា) មុនសម័យកំណែទម្រង់វិញ។

អ្វីដែលបានកើតឡើងនោះអាចត្រូវបានសង្ខេបថា ជាការធ្វើឲ្យតន្ត្រីរបស់ក្រុមជំនុំមានលក្ខណៈជាវិជ្ជាជីវៈឡើងវិញ និងការបាត់បង់គោលដៅសំខាន់នៃការថ្វាយបង្គំដែលនាំឲ្យមនុស្សអាចច្រៀងសរសើរព្រះ។ និយាយឲ្យសាមញ្ញ យើងកំពុងបង្កាត់វប្បធម៌អ្នកទស្សនានៅក្នុងព្រះវិហាររបស់យើងដោយផ្លាស់ប្ដូរបរិយាកាសនៃការថ្វាយបង្គំដែលមានការចូលរួមពីពួកជំនុំ ទៅជាព្រឹត្តិការណ៍ទស្សនាការប្រគំតន្ត្រីទៅវិញ។ ការថ្វាយបង្គំកំពុងផ្លាស់ប្ដូរទៅភាពរញ៉េរញ៉ៃដូចមុនសម័យកំណែទម្រង់។

## ខ្ញុំសង្កេតឃើញហេតុផលប្រាំបួនយ៉ាង ដែលមនុស្សលែងច្រៀងទៀត៖

១. **ពួកគេមិនចេះបទចម្រៀងទាំងនោះ:** ដោយសារការចេញបទចម្រៀងថ្មីៗរៀងរាល់សប្ដាហ៍ និងការកើនឡើងនៃបទចម្រៀងដែលបាននិពន្ធក្នុងស្រុក អ្នកដឹកនាំថ្វាយបង្គំកំពុងផ្ដល់ឲ្យជាប់ជានិច្ចនូវរបបអាហាររឹងនៃបទចម្រៀងថ្វាយបង្គំទាន់សម័យបំផុត និងដ៏អស្ចារ្យបំផុត ។ ជាការពិតណាស់ យើងគួរតែច្រៀងចម្រៀងថ្មីៗ ប៉ុន្តែ អត្រាខ្ពស់ពេកនៃការបញ្ចូលបទចម្រៀងថ្មីៗក្នុងការថ្វាយបង្គំអាចសម្លាប់អត្រានៃការចូលរួមហើយបង្វែរក្រុមជំនុំទៅជាអ្នកទស្សនា។ ខ្ញុំឃើញរឿងនេះកើតឡើងគ្រប់ពេល។ ខ្ញុំតស៊ូមតិមិនឲ្យធ្វើការច្រៀងបទចម្រៀងថ្មីលើសពីមួយបទក្នុងកម្មវិធីថ្វាយបង្គំមួយលើក ហើយបន្ទាប់មកឲ្យគេច្រៀងបទថ្មីនោះម្ដងហើយម្ដងទៀតជាច្រើនសប្ដាហ៍រហូតដល់ក្រុមជំនុំចេះស្ទាត់។ ពួកជំនុំថ្វាយបង្គំព្រះបានល្អបំផុតតាមរយៈបទចម្រៀងដែលពួកគេចេះ ដូច្នេះ យើងត្រូវបង្រៀន និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការបង្ហាញចេញការថ្វាយបង្គំតាមបទចម្រៀងថ្មី។

២. **យើងកំពុងច្រៀងចម្រៀងដែលពួកជំនុំពិបាកច្រៀង:** មានបទចម្រៀងថ្វាយបង្គំថ្មីៗអស្ចារ្យជាច្រើននាពេលបច្ចុប្បន្ននេះ ប៉ុន្តែ នៅក្នុងចំណោមបទចម្រៀងថ្មីដ៏ច្រើនទាំងនោះ គឺមិនសមរម្យសម្រាប់ឲ្យពួកជំនុំច្រៀងជាមួយគ្នាទេ ដោយសារបញ្ហាចង្វាក់បទចម្រៀង (ពិបាកពេកសម្រាប់អ្នកច្រៀងកំរិតមធ្យម) ឬមានណោតទាប ឬខ្ពស់ពេក (ចូរគិតដល់អ្នកច្រៀងកំរិតមធ្យមកុំគិតដល់កំពូលតារាចម្រៀងនៅលើឆាក) ។ បទចម្រៀងខ្លះប្រហែលជាមិនមានទំនុកច្រៀងដែលសមនឹងឲ្យពួកជំនុំច្រៀងព្រមគ្នា

នោះទេ។

៣. **យើងកំពុងច្រៀងនៅក្នុងខ្ទង់ខ្ពស់ពេក សម្រាប់អ្នកចម្រៀងជាមធ្យម:** ពួកជំនុំដែលយើងកំពុងដឹកនាំក្នុងកម្មវិធីថ្វាយបង្គំជាទូទៅសំឡេងរបស់ពួកគេមានកំណត់ ហើយមិនមានកម្រិតខ្ពស់នោះទេ។ នៅពេលដែលយើងដាក់បទចម្រៀងក្នុងខ្ទង់ខ្ពស់ពេកនោះក្រុមជំនុំនឹងឈប់ច្រៀងមានការហត់នឿយ ហើយទីបំផុតក៏ឈប់ ហើយក្លាយជាអ្នកទស្សនាតែម្តង។ សូមចាំថាទំនួលខុសត្រូវរបស់យើង គឺត្រូវធ្វើឲ្យក្រុមជំនុំអាចច្រៀងសរសើរតម្កើងព្រះមិនមែនដើម្បីបង្អួតសមត្ថភាពសំឡេងដ៏អស្ចារ្យរបស់យើងនៅលើវេទិកាដោយនាំគេច្រៀងក្នុងកំរិតដ៏ខ្ពស់របស់យើង។ កម្រិតសំឡេងជាមូលដ្ឋាននៃអ្នកចម្រៀងជាមធ្យម គឺសម្របសម្រួលដោយប្រើអុកតាវ (octave ការឡើងផសម្លេង) និងការប្រើណោតឡា (A) ដល់រ៉េ (D) (ជាមួយ Eb ម្តងម្កាល)។

៤. **ក្រុមជំនុំមិនអាចឮមនុស្សជុំវិញពួកគេច្រៀង:** បើភ្លេងយើងឮខ្លាំងពេកធ្វើឲ្យពួកជំនុំមិនអាចស្តាប់ឮអ្នកដទៃច្រៀងនោះមានន័យថាវាឮពេកហើយ។ ផ្ទុយទៅវិញ បើភ្លេងស្ងាត់ពេកជាទូទៅក្រុមជំនុំនឹងមិនអាចច្រៀងឲ្យបានខ្លាំងបានទេ។ ចូរស្វែងរកតុល្យភាពដែលត្រឹមត្រូវ ខ្លាំងប៉ុន្តែកុំខ្លាំងពេក។ ខ្ញុំបានឃើញព្រះវិហារខ្លះចែកឧបករណ៍ញាត់ត្រចៀក ពីព្រោះកម្រិតសំឡេងខ្ពស់ពេក។ ការនោះពិតជាប្រែក្លាយកម្មវិធីថ្វាយបង្គំទៅជាមានលក្ខណៈជាព្រឹត្តិការណ៍សម្រាប់អ្នកទស្សនាច្រើនជាង ដោយសារតែអ្នកមិនអាចឮផ្នែក "រួមគ្នា" នៃការថ្វាយបង្គំ ពោលគឺមិនឮមនុស្សជុំវិញអ្នកច្រៀង។

៥. **យើងបានបង្កើតកម្មវិធីថ្វាយបង្គំធ្វើជាព្រឹត្តិការណ៍សម្រាប់អ្នកទស្សនាដោយបង្កើតបរិយាកាសនៃការសម្តែង:** ខ្ញុំសូមគាំទ្រយ៉ាងមុតមាំឲ្យមានការរៀបចំបរិយាកាសដ៏ប្រសើរសម្រាប់ការថ្វាយបង្គំរួម ដោយរាប់បញ្ចូលទាំងការរៀបចំភ្លើងបំភ្លឺ ការបញ្ចាំងរូបភាព ការរាប់បញ្ចូលសិល្បៈ។ល។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលបរិយាកាសរបស់យើងឈានដល់កម្រិតមួយដែលទាក់ទាញចំណាប់អារម្មណ៍ហួសហេតុមកលើអ្នកដែលនៅលើឆាក ឬបច្ចេកទេសឡូយឆាយ និងបង្វែរអារម្មណ៍ចេញពីការថ្វាយបង្គំព្រះនោះមានន័យថា យើងបានធ្វើលើសពេកហើយ។ យើងគួរធ្វើឲ្យបានល្អប្រសើរ។ តែមិនត្រូវមានលក្ខណៈជាការសម្តែងបែប

អាជីពកំរិតខ្ពស់នោះទេ។

៦. **ក្រុមជំនុំមានអារម្មណ៍ថា គេមិនរំពឹងឲ្យពួកគេច្រៀង :** ក្នុងនាមជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ជារឿយៗ យើងផ្តោតខ្លាំងពេកទៅលើការធ្វើកម្មវិធីថ្វាយបង្គំឲ្យមានវិជ្ជាជីវៈទំនើប បានជាយើងបាត់បង់ភាពពិតប្រាកដក្នុងការអញ្ជើញក្រុមជំនុំឲ្យចូលរួមក្នុងដំណើរនៃការថ្វាយបង្គំ។ យើងត្រូវតែសម្រួលបទពិសោធន៍ដោយការច្រៀងចម្រៀងដែលគេចេះច្រៀង ណែនាំបទចម្រៀងថ្មីៗឲ្យបានត្រឹមត្រូវ និងច្រៀងចម្រៀងដែលក្រុមជំនុំអាចច្រៀងបាន។ មានថ្ងៃមួយមិត្តម្នាក់របស់ខ្ញុំសួរខ្ញុំថា តើគេបានរំពឹងឲ្យគាត់ច្រៀងក្នុងពេលថ្វាយបង្គំនូវបទចម្រៀងណាមួយកាលពីចុងសប្តាហ៍មុនមែនទេ។ ខ្ញុំបានសុំឲ្យគាត់ពន្យល់ថាតើគាត់ចង់មានន័យថាម៉េច។ គាត់បានតបថាភាគច្រើនបទចម្រៀងត្រូវបានដឹកនាំច្រៀងដោយបុរសម្នាក់ដែលជាគ្រូគង្វាលផ្នែកថ្វាយបង្គំ ប៉ុន្តែ សម្រាប់បទចម្រៀងពិសេសមួយនោះ មាននារីម្នាក់ក្នុងក្រុមបានដឹកនាំនៅដើមដំបូង។ អត្ថបទចម្រៀងមាននៅលើអេក្រង់ស្រាប់ ប៉ុន្តែ អ្នកច្រៀងផ្សេងទៀតមិនបានច្រៀងជាមួយគាត់ទេ ហើយពួកគេទាំងអស់គ្នាកំពុងទស្សនាស្ត្រីដែលកំពុងដឹកនាំច្រៀងបទចម្រៀងនោះ។ ខ្ញុំក៏បានឲ្យយោបល់ថា ពួកគេប្រហែលជាមានបំណងចង់ឲ្យក្រុមជំនុំច្រៀង ប៉ុន្តែ តាមរយៈភាពអសកម្មរបស់ពួកគេ ពួកគេកំពុងតែប្រាប់ដល់មនុស្សគ្រប់គ្នាឲ្យគ្រាន់តែឈរស្តាប់គាត់ច្រៀងប៉ុណ្ណោះ។ អ្នកច្រៀងផ្សេងទៀតមិនបានច្រៀងជាមួយគាត់ទេ។ ពួកគេទាំងអស់គ្នាសម្លឹងមើលអ្នកច្រៀង។ ខ្ញុំតែងតែណែនាំក្រុមអ្នកចម្រៀងនៅពេលនោះឲ្យបន្តច្រៀង និងនាំក្រុមជំនុំចូលរួមច្រៀង (មើលទៅក្រុមជំនុំជាជាងមើលទៅអ្នកច្រៀង) ដោយមិនដាក់ក្បាលមីក្រូនៅមុខពួកគេឡើយ។ គេឮតែស្ត្រីនោះច្រៀងម្នាក់ឯង ប៉ុន្តែ ពេលដែលពួកជំនុំឃើញគ្រប់គ្នាកំពុងច្រៀង ហើយពួកគេសន្និដ្ឋានថា ពួកគេត្រូវបានរំពឹងឲ្យច្រៀងជាមួយផងដែរ។ ក្នុងនាមជាក្រុមថ្វាយបង្គំ យើងត្រូវប្រាកដថា យើងមិនបានបញ្ជូនសារដែលមានន័យផ្ទុយនឹងអ្វីដែលយើងចង់បាននោះទេ ។

៧. **យើងខ្វះបទចម្រៀង ដែលពួកជំនុំអាចច្រៀងជាមួយគ្នាបាន:** ដោយសារមានបទចម្រៀងថ្មីៗជាច្រើន ជារឿយៗយើងធ្វើឲ្យមានការលំបាកដល់ការរៀបចំផែនការសម្រាប់កម្មវិធីថ្វាយបង្គំដោយទាញយកបទ

ចម្រៀងពីប្រភពជាច្រើនដោយមិនបានពង្រឹងការច្រៀងបទចម្រៀងដែលមានសម្រាប់ និងមិនបានជួយក្រុមជំនុំប្រើបទចម្រៀងទាំងនោះក្នុងការបង្ហាញចេញការថ្វាយបង្គំរបស់ពួកគេជាធម្មតា។ នៅសម័យបុរាណគេទុកដាក់សៀវភៅចម្រៀងយ៉ាងប្រុងប្រយ័ត្នណាស់។ សព្វថ្ងៃនេះ យើងត្រូវបង្កើតបញ្ជីបទចម្រៀង សម្រាប់ប្រើក្នុងការរៀបចំផែនការសម្រាប់កម្មវិធីថ្វាយបង្គំរបស់យើង។ ម្យ៉ាងទៀត ដោយសារសព្វថ្ងៃមានបទចម្រៀងច្រើនណាស់ ហើយក៏គ្មានការបញ្ជាក់អំពីប្រភពដើមនៃនិកាយដែលបាននិពន្ធបទចម្រៀងទាំងនោះ ដូចបទទំនុកសកលកាលពីដើម ហេតុនេះហើយ ពួកជំនុំនីមួយៗអាចមានបទចម្រៀងច្រើនប្រភេទ ច្រើនបែបដែលពួកគេច្រៀងជាទៀងទាត់។ នៅពេលបទចម្រៀងដែលគ្រប់គ្នាចេះច្រៀងមានចំនួនកាន់តែតិច ហើយអ្នកជឿណាម្នាក់រើទៅកន្លែងផ្សេង ហើយចូលរួមជាមួយព្រះវិហារផ្សេងទៀត ពួកគេអាចនឹងមិនស្គាល់បទចម្រៀងដែលប្រើនៅព្រះវិហារថ្មីទេ ហើយពួកគេនឹងអសកម្មយ៉ាងខ្លាំងក្នុងការថ្វាយបង្គំរបស់ពួកគេ។ ដើម្បីប៉ះប៉ូវដល់ចំណុចនេះ ព្រះវិហារគួរតែខិតខំឲ្យមានរបបអាហារនៃបទចម្រៀងដែលមួយផ្នែកធំ គឺជាបទចម្រៀងដែលគេច្រៀងជាទូទៅនៅក្នុងព្រះវិហារនានាទូទាំងប្រទេសរបស់ពួកគេ។ ការផ្តល់របបអាហារនៃបទចម្រៀងដែលមានការសម្រិតសម្រាំងត្រឹមត្រូវ ចេញពីបញ្ជីបទចម្រៀងទាំងនេះ នឹងជួយធានាថាព្រះវិហារមានបទចម្រៀងដែលអាចច្រៀងរួមគ្នាកាន់តែច្រើន។

៨. **អ្នកដឹកនាំការថ្វាយបង្គំធ្វើការបន្ថែមល្បោយពីលើបទចម្រៀងច្រើនពេក:** សូមបន្តលេងបទភ្លេងឲ្យច្បាស់ និងស្រួលស្តាប់។ មនុស្សក្នុងពួកជំនុំមានសមត្ថភាពក្នុងផ្នែកតន្ត្រីក្នុងកំរិតផ្សេងគ្នា។ នៅពេលដែលយើងងាកចេញពីទំនុកភ្លេងដោយការបន្ថែមល្បោយ នៅពេលដែលភ្លេងកំពុងលេង ពួកជំនុំព្យាយាមច្រៀងតាមការដឹកនាំរបស់យើង ហើយក៏មានភាពនឿយណាយហើយឈប់ច្រៀងតែម្តង។ ការបន្ថែមល្បោយខ្លះល្អ ហើយអាចលើកកំពស់ការថ្វាយបង្គំ (ជាពិសេសនៅត្រង់កន្លែងដែលមានតែភ្លេងក្នុងបទចម្រៀង) ប៉ុន្តែ កុំអនុញ្ញាតឲ្យវានាំពួកជំនុំរបស់អ្នកឲ្យវង្វេងឡើយ។ មានពេលមួយ ខ្ញុំប្រាប់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំថាការបន្ថែមល្បោយប្រហែលជាល្អនៅពេលដែលក្រុមជំនុំកំពុងច្រៀងបទចម្រៀងដែលពួកគេស្គាល់ច្បាស់។ ក្រោយមក ខ្ញុំបានទៅប្រទេសធំមួយ

នៅតំបន់អាស៊ីប៉ូព៉ាហើយបានដកពិសោធន៍ជាមួយការថ្វាយបង្គំរួមជាមួយមនុស្សពីរបីរយនាក់។ ពួកគេកំពុងច្រៀងបទ "ព្រះយើងធំអស្ចារ្យ"។ អ្នកដឹកនាំការថ្វាយបង្គំបានចាប់ផ្ដើមបន្ថែមល្បោយពីលើវគ្គបន្ទរ ហើយភ្លាមៗនោះក្រុមជំនុំក៏បានលែងច្រៀងខ្លាំងដូចមុនទៀត។ពួកជំនុំកំពុងព្យាយាមច្រៀងតាមណោតដែលគាត់បន្ថែមធ្វើជាល្បោយនោះ ប៉ុន្តែ មិនអាចច្រៀងតាមបាន។ បទចម្រៀងទើបតែបាត់បង់ចាមពល។ ពេលនេះខ្ញុំលើកទឹកចិត្តថា ពួកជំនុំគួរតែអាចឮទំនុកភ្លេងច្បាស់ៗ ដើម្បីឲ្យពួកគេអាចបន្តច្រៀង ដោយមិនមានការភាន់ច្រឡំ។

៩. **អ្នកដឹកនាំកម្មវិធីថ្វាយបង្គំមិនមានការតភ្ជាប់ជាមួយក្រុមជំនុំទេ** ជាញឹកញយយើងលង់នៅក្នុងពិភពនៃផលិតកម្មតន្ត្រីដ៏អស្ចារ្យរបស់យើង ហើយភ្លេចគោលបំណងរបស់យើង ដែលត្រូវជួយក្រុមជំនុំឲ្យបន្លឺសម្លេងច្រៀងក្នុងកម្មវិធីថ្វាយបង្គំ។ ចូរប្រាប់ពួកគេថា អ្នករំពឹងថាពួកគេនឹងច្រៀងជាមួយអ្នក។ សូមដកស្រង់ខគម្ពីរដើម្បីលើកកំពស់ការបង្ហាញចេញនូវការថ្វាយបង្គំរបស់ពួកគេ។ សូមប្រុងប្រយ័ត្នចំពោះរបៀបដែលក្រុមជំនុំកំពុងដើរតាមការដឹកនាំរបស់អ្នក ហើយសូមផ្លាស់ប្ដូរទិសដៅតាមដែលចាំបាច់។ ការតភ្ជាប់ជាមួយពួកជំនុំក្នុងកម្មវិធីថ្វាយបង្គំ មានទិដ្ឋភាពពីរយ៉ាងដែលចាំបាច់។

**ទិដ្ឋភាពទីមួយ មានការជាប់ទាក់ទងនឹងពេលវេលារបស់យើងនៅលើឆាក។** ក្នុងស្ថានភាពដែលមានពន្លឺភ្លើងភ្លឺច្បាស់នៅលើឆាក ហើយកន្លែងពួកជំនុំអង្គុយមានពន្លឺភ្លើងតិចជាង ឬបិទភ្លើង អ្នកប្រហែលមិនអាចមើលឃើញពួកជំនុំដែលអ្នកកំពុងដឹកនាំនោះទេ។ ការប្រើកាសញ្ជាត់ត្រចៀកក្នុងពេលដឹកនាំច្រៀងធ្វើឲ្យអ្នកឮតែភ្លេង សម្លេងខ្លួនឯងច្រៀង តែមិនឮសម្លេងពួកជំនុំច្រៀងទេ។ យកល្អអ្នកគួរតែកែសម្រួលផ្នែកនេះ ដោយសាពន្លឺភ្លើង ដើម្បីឲ្យអ្នកអាចមើលឃើញមនុស្សដែលអ្នកកំពុងដឹកនាំច្បាស់ ឬដោយដកកាសញ្ជាត់ត្រចៀកចេញ ឬក៏បន្ថែមសម្លេងពួកជំនុំច្រៀង (តាមរយៈក្បាលមេក្រូចាប់សម្លេងពួកជំនុំច្រៀង) នៅក្នុងកាសញ្ជាត់ត្រចៀក ដើម្បីឲ្យអ្នកអាចឮពួកជំនុំច្រៀង។

**ទិដ្ឋភាពទីពីរ ទាក់ទងនឹងជីវិតនៅក្រៅឆាក។** ដូចដែលខ្ញុំបានលើកមកនិយាយរួចហើយ អ្នកនឹងមានការតភ្ជាប់ជាមួយពួកជំនុំកាន់តែស៊ីជម្រៅថែមទៀតនៅពេលដែលអ្នកមានការប្រកបជាមួយពួកគេក្នុងការថ្វាយបង្គំ និងការបម្រើព្រះជាមួយគ្នាព្រមទាំងនៅក្នុងការបង្កើតសិស្ស ការចូលរួមក្នុងគម្រោងបេសកកម្ម ។

ល។ ការមានចិត្តដែលចង់ធ្វើជាកំពូលតារាចម្រៀងនៅលើឆាកព្រះវិហារ នឹងនាំឲ្យអ្នកបង្កើតផ្នត់គំនិតទស្សនិកជននៅក្នុងពួកជំនុំ។

**ពេលណាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំមានចក្ខុវិស័យដែលជួយពួកជំនុំឲ្យអាចធ្វើជាអ្នកចូលរួមក្នុងដំណើរនៃការថ្វាយបង្គំរួម ខ្ញុំជឿថាយើងអាចជួយពួកគេវិលត្រឡប់ទៅរកការថ្វាយបង្គំត្រឹមត្រូវឡើងវិញ។**

**ក្នុងចំណោមចំណុចទាំង៩នេះ មានចំណុចមួយណាដែលត្រូវការកែលំអក្នុងពួកជំនុំរបស់អ្នក? តើអ្នកត្រូវកែលំអបញ្ហាទាំងនេះ ជាជំហានៗដូចម្ដេចខ្លះ?**

## ការនិយាយនៅចន្លោះបទចម្រៀង និង ធាតុផ្សំផ្សេងទៀតនៃការថ្វាយបង្គំ

មានពេលខ្លះអ្នកដឹកនាំកម្មវិធីថ្វាយបង្គំអាចជួយក្រុមជំនុំក្នុងដំណើរនៃការថ្វាយបង្គំ គឺតាមរយៈការនិយាយ។ អ្នកពិតជាចាំបាច់ត្រូវគិត និងរៀបផែនការទុកជាមុនសម្រាប់ពាក្យសម្ដី ដែលអ្នកនឹងប្រើក្នុងការឆ្លងពីបទចម្រៀងមួយទៅបទចម្រៀងមួយទៀត។ អ្នកដឹកនាំថ្វាយបង្គំខ្លះនិយាយដោយគ្មានការត្រៀងទុក ហើយជារឿយៗលទ្ធផល គឺរដិបរដុបគ្មានប្រសិទ្ធភាពដែលអាចរារាំងដល់ការថ្វាយបង្គំ។ នេះជាបញ្ហាដែលបានកើតឡើងញឹកញាប់ពេកហើយ។ ដូច្នេះ វាចាំបាច់ណាស់ដែលអ្នកត្រូវចំណាយពេល និងសរសេរនូវអ្វីដែលអ្នកនឹងនិយាយនៅចំណុចភ្ជាប់បទចម្រៀងមួយទៅមួយទៀត។ បន្ទាប់មក ទន្ទេញឲ្យចាំចំណុចសំខាន់ៗ ហើយហាត់សមនូវអ្វីដែលអ្នកនឹងនិយាយក្នុងកម្មវិធីរួម។ សូមនិយាយបែបសន្ទនា។ ការសរសេរផ្នែកដែលត្រូវនិយាយនឹងជួយអ្នករៀបចំគំនិតរបស់អ្នក ដើម្បីធ្វើឲ្យអ្វីដែលអ្នកនិយាយ មានតម្លៃចំពោះពេលវេលានៃកម្មវិធីថ្វាយបង្គំ។

ខ្ញុំចង់លើកទឹកចិត្តអ្នកឲ្យពិនិត្យមើលកម្មវិធីថ្វាយបង្គំពីសប្ដាហ៍មុនៗឡើងវិញ ហើយគិតអំពីពាក្យសម្ដីដែលអ្នកប្រើក្នុងការឆ្លងពីបទចម្រៀងមួយទៅមួយទៀត។

តើវាជាពាក្យសម្ដីរាក់កំផែល និងប្រើច្រំដែលទេ ឬក៏មានភាពច្បាស់លាស់ ហើយបានគិតទុកមុនបានល្អបានវាមានតម្លៃចំពោះការដកពិសោធន៍របស់ក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំ? ជាញឹកញយណាស់ យើងនិយាយឲ្យរួចតែពីមាត់ ដើម្បីបន្ថែមល្បោយ ដែលមិនអាចជួយអ្វីបានក្រៅពីរារាំងដល់ការថ្វាយបង្គំ។

អ្នកមិនគួរមើលឃើញខ្លួនឯងថា ជាអ្នកដឹកនាំបទចម្រៀងដែលផ្ដោតទៅលើការច្រៀង ដើម្បីឲ្យតែអស់បទចម្រៀងនៅក្នុងបញ្ជីបទចម្រៀងនោះទេ ។ ផ្ទុយទៅវិញ សូមមើលខ្លួនអ្នកថាជាអ្នកដឹកនាំដែលមានចិត្តធ្វើជាគ្រូគង្វាល និងដឹកពួកជំនុំក្នុងដំណើរនៃការថ្វាយបង្គំរយៈពេល២០នាទី ឬលើសនេះទៀត។ អ្នកកំពុងឃ្វាលមនុស្សតាមរបៀបឆ្លើយឆ្លងតាមរយៈបទចម្រៀង បទគម្ពីរ និងការអធិស្ឋាន។

**គោលដៅរបស់យើងគឺដើម្បីលើកតម្កើងព្រះ និងជួយអ្នកឯទៀតថ្វាយបង្គំព្រះអម្ចាស់**

យើងមិនគួរប្រឹងប្រែងធ្វើជាមនុស្សឡូយឆាយឡើយ។ យើងត្រូវការបង្ហាញភាពជាមនុស្សពិតៗ។ សូមគិតថា ការជួបជុំថ្វាយបង្គំព្រះមានលក្ខណៈជាគ្រួសារច្រើនជាងការប្រគុំតន្ត្រី ឬកន្លែងសម្ដែងខ្នាតធំឡើយ។

មុនពេលអ្នកឡើងវេទិកា សូមអធិស្ឋានឲ្យមនុស្សដែលអ្នកហៀបនឹងដឹកនាំ។ ការនេះនឹងជួយអ្នកឲ្យផ្ដោតអារម្មណ៍បានត្រឹមត្រូវ។ ព្រះអង្គអើយ! យើងខ្ញុំមកទីនេះដើម្បីបម្រើ។ សូមប្រទានយើងខ្ញុំនូវចិត្តដែលស្រឡាញ់មនុស្សដែលយើងខ្ញុំហៀបនឹងដឹកនាំ។ សូមជួយយើងខ្ញុំឲ្យគិតអំពីភាពប្រេះបែក និងការលំបាកដែលពួកជំនុំកំពុងឆ្លងកាត់។ សូមជួយយើងខ្ញុំបើកចំហចិត្តឆាប់ឆ្លើយតបចំពោះព្រះវិញ្ញាណទ្រង់។ សូមព្រះអង្គចាក់បំពេញក្រុមជំនុំនេះដោយព្រះវិញ្ញាណព្រះអង្គក្នុងពេលឥឡូវនេះ។

## ប្រភេទនៃការនិយាយដែលអ្នកអាចប្រើះ

ចំណាំះ គំរូទាំងនេះអាចមានការផ្លាស់ប្ដូរ ទៅជាបទចម្រៀងដែលក្រុមជំនុំកម្ពុជាស្គាល់ច្បាស់ថា ពេញនិយម ឬនៅតែពេញនិយម (ប្រហែលជានៅតែអាចទទួលបានអត្ថន័យ)។

## ដកស្រង់បទគម្ពីរ

ការប្រើព្រះបន្ទូលរបស់ព្រះ ក្នុងកម្មវិធីថ្វាយបង្គំគឺមានអំណាចណាស់។ ចូរស្វែងរកវិធីដើម្បីបញ្ចូលបទគម្ពីរក្នុងកម្មវិធីថ្វាយបង្គំរបស់អ្នក។ សូមកត់សំគាល់ខគម្ពីរនៃការសរសើរតម្កើងក្នុងព្រះគម្ពីរដែលអ្នកត្រូវទន្ទេញឲ្យចាំ និងប្រើក្នុងកម្មវិធីថ្វាយបង្គំ។ អត្ថបទព្រះគម្ពីរអាចបំផុសគំនិត ណែនាំ ដាស់តឿន បណ្ដាលចិត្តឲ្យទទួលស្គាល់កំហុស ។ល។

ឧទាហរណ៍៖ ទំនុកតម្កើង ៣០:៤ ចែងថា «ឱពួកអ្នកបរិសុទ្ធរបស់ទ្រង់អើយ ចូរច្រៀងសរសើរដល់ព្រះយេហូវ៉ាចុះ។ ចូរអរព្រះគុណ ដោយនឹកចាំពីសេចក្តីបរិសុទ្ធនៃទ្រង់។ សូមចូលរួមច្រៀងសរសើរ និងអរព្រះគុណដល់ព្រះនៃយើងនៅព្រឹកនេះ»។

## ប្រើផ្នែកណាមួយនៃទំនុកច្រៀងរបស់បទចម្រៀង។

ប្រហែលជាមានផ្នែកដែលមានការប៉ះពាល់ចិត្តខ្លាំងក្នុងទំនុកច្រៀងរបស់បទចម្រៀង ដែលយើងអាចប្រើ ដើម្បីជួយពួកជំនុំផ្ដោតចិត្តក្នុងកម្មវិធីថ្វាយបង្គំ។

ឧទាហរណ៍៖ ក្នុងបទចម្រៀង «សេចក្តីមេត្តាករុណារបស់ទ្រង់គឺច្រើនជាង» "His Mercy Is More" យើងអាចប្រើល្បះដែលច្រៀងថា "តើអ្នកគិតយ៉ាងណាចំពោះការពិតដែលថា ព្រះដ៏បរិសុទ្ធអាចស្រឡាញ់មនុស្សមានបាបដូចជាអ្នក ហើយនិងខ្ញុំ? ទោះបីយើងមានចំណុចខ្វះខាតទាំងអស់ក៏ដោយ ព្រះស្រឡាញ់យើង? ពេលអ្នកច្រៀងបទនេះ ពិតជាស្រែកចេញពីដំណឹងល្អ ពីព្រោះពេលដែលអំពើបាបរបស់យើងមានច្រើនសេចក្តីមេត្តាករុណារបស់ទ្រង់មានច្រើនជាង!"

## ដឹកនាំនៅក្នុងពេលធ្វើការបម្រើព្រះ

សូមយើងឲ្យពួកជំនុំអរគុណព្រះសម្រាប់ព្រះពររបស់ពួកគេ ឬសារភាពអំពើបាបរបស់ពួកគេ — ផ្អែកលើអ្វីដែលទើបតែបានច្រៀង។

ឧទាហរណ៍៖ ប្រសិនបើអ្នកកំពុងច្រៀងបទ «សរសើរព្រះនាមទ្រង់» "Blessed Be Your Name," អ្នកអាចនិយាយអំពីបន្ទាត់ដែលថា «គ្រប់ទាំងព្រះពរដែលទ្រង់បានប្រទាន នោះខ្ញុំនឹងថ្វាយដល់ ទ្រង់វិញដោយការសរសើរ» ហើយលើកទឹកចិត្តពួកជំនុំឲ្យគិតអំពីព្រះពរមួយចំនួនក្នុងពេលមួយសប្ដាហ៍នេះ ដែលពួកគេអាចថ្វាយជាការសរសើរដល់ទ្រង់វិញ។ "យើងគ្រាន់តែច្រៀងថា គ្រប់ព្រះពរដែលទ្រង់បានប្រទាន នោះយើងខ្ញុំនឹងថ្វាយដល់

ទ្រង់វិញដោយការសរសើរ។ តើអ្នកបានឆ្លៀតពេលដើម្បីធ្វើកិច្ចការនោះក្នុងសប្ដាហ៍នេះ — ដើម្បីសរសើរតម្កើងព្រះជាម្ចាស់ចំពោះអ្វីៗទាំងអស់ដែលទ្រង់បានធ្វើសម្រាប់អ្នក និងព្រះពរដែលទ្រង់បានបង្ហូរមកដល់អ្នកឬទេ? សូមចំណាយពេលបន្តិចដើម្បីថ្វាយការសរសើរដល់ទ្រង់ក្នុងពេលឥឡូវនេះនៅកន្លែងដែលអ្នកកំពុងនៅនេះ»។ នៅពេលដែលភ្លេងកំពុងលេងសូមទុកពេលឲ្យក្រុមជំនុំមួយភ្លែត ដើម្បីឲ្យពួកគេសរសើរដល់ព្រះ។ បន្ទាប់មក តន្ត្រីបានចូលដល់បទចម្រៀងមួយទៀត ដូចជាបទ «ព្រះនាម ទ្រង់» “Your Name” ដែលផ្ដល់ឲ្យក្រុមជំនុំនូវវិធីមួយផ្សេងទៀត ដើម្បីបញ្ចេញសំឡេងសរសើររបស់ពួកគេ (ហើយបទចម្រៀងនេះបំពេញការផ្លាស់ប្ដូរអត្ថបទទាក់ទងនឹងព្រះនាមរបស់ព្រះ)។

## អធិស្ឋាន

សូមផ្ដល់ឲ្យនូវការអធិស្ឋានដែលភ្ជាប់ជាមួយអ្វីដែលទើបតែបានច្រៀង ឬប្រហែលជាភ្ជាប់ទៅអត្ថន័យរបស់បទចម្រៀងបន្ទាប់។

ឧទាហរណ៍៖ អ្នកអាចភ្ជាប់បទ "ទ្រង់រៀបចំផ្លូវ" “Way Maker” ជាមួយ «ក្ដីសប្បុរសនៃព្រះ» “Goodness of God.” ដោយការអធិស្ឋានយ៉ាងដូចនេះថា «ព្រះវរបិតា ទ្រង់គឺជាអ្នករៀបចំផ្លូវសម្រាប់យើងខ្ញុំ ទ្រង់ធ្វើការអស្ចារ្យសម្រាប់យើងខ្ញុំ ទ្រង់រក្សាការសន្យាចំពោះយើងខ្ញុំ និងអ្វីៗគ្រប់យ៉ាងសម្រាប់យើងខ្ញុំ។ យើងខ្ញុំចូលមកចំពោះទ្រង់នៅថ្ងៃនេះ ដោយសុំឲ្យទ្រង់ធ្វើចលនានៅកណ្ដាលចំណោមយើងខ្ញុំ ហើយផ្លាស់ប្រែជីវិតយើងខ្ញុំជាថ្មីឡើងវិញ។ សូមប៉ះពាល់បំណែកដែលបែកបាក់របស់យើងខ្ញុំ ហើយនាំមកនូវក្ដីសង្ឃឹម និងកម្លាំងសាជាថ្មី។ សេចក្ដីមេត្តាករុណារបស់ទ្រង់មិនដែលធ្វើឲ្យយើងខ្ញុំខកចិត្តឡើយ។ ទ្រង់តែងតែបីទ្រយើងខ្ញុំនៅក្នុងព្រះហស្តរបស់ទ្រង់។ សូមអរព្រះគុណចំពោះសេចក្ដីស្មោះត្រង់របស់ទ្រង់...»។

## ចែកចាយអំពីសាវតារខ្លះៗនៃបទចម្រៀង។

ពេលខ្លះ ប្រវត្តិរបស់បទចម្រៀងអាចធ្វើឲ្យប៉ះពាល់គំនិត និងដួងចិត្តរបស់មនុស្សតាមរបៀបមួយដ៏អស្ចារ្យ នៅពេលដែលពួកគេភ្ជាប់ជាមួយនឹងអ្វីដែលពួកគេកំពុងច្រៀង។

ឧទាហរណ៍៖ ចំពោះបទ «ជ័យជំនះក្នុងព្រះយេស៊ូវ» (Victory in Jesus) សូមនិយាយអំពីប្រវត្តិខ្លះៗរបស់បទនេះ យ៉ាងដូចនេះថា «នៅក្នុងឆ្នាំ ១៩៣៩

ជំងឺដាច់សរសៃឈាមខួរក្បាលបានធ្វើឲ្យលោក យូជីន ប៊ិតលេត (Eugene Bartlett) ពិការមួយចំហៀងខ្លួន ហើយមិនអាចបន្តអាជីពតន្ត្រីដំណឹងល្អដ៏ពេញនិយមរបស់គាត់បានទេ។ គាត់បានក្លាយជាអ្នកជំងឺដែលមិនអាចក្រោកចេញពីគ្រែក្នុងរយៈពេល២ឆ្នាំចុងក្រោយនៃជីវិតគាត់។ នៅក្នុងកាលៈទេសៈដ៏អាក្រក់បែបនេះ គាត់បានសរសេរបទចម្រៀងចុងក្រោយ និងជាទីស្រឡាញ់បំផុតរបស់គាត់ដែលមានចំណងជើងថា «ជ័យជំនះក្នុងព្រះយេស៊ូវ» (Victory in Jesus) ជាបទចម្រៀងដែលផ្ដល់ឲ្យក្ដីសង្ឃឹម ដែលមានមនុស្សរាប់លាននាក់យកមកច្រៀងក្នុងកម្មវិធីថ្វាយបង្គំ ហើយបណ្ដាអ្នកចម្រៀងដំណឹងល្អល្បីល្បាញបំផុតបានច្រៀងបទនេះផងដែរ។ ខណៈពេលដែលយើងច្រៀងបទនេះនៅថ្ងៃនេះ សូមគិតថា មិនថាអ្នកកំពុងឆ្លងកាត់រឿងអ្វីក៏ដោយក្នុងនាមអ្នកជាកូនរបស់ព្រះ អ្នកនៅតែអាចប្រកាសពីជ័យជម្នះ!»។

## គោលគំនិតសំខាន់

យើងអាចមានឱកាសទាញយកអត្ថន័យពីប្រធានបទនៃការអធិប្បាយព្រះបន្ទូល ឬប្រធានបទផ្សេងទៀតនៅថ្ងៃថ្វាយបង្គំនោះមកភ្ជាប់បទចម្រៀងជាមួយនឹងខ្លឹមសារហើយប៉ះពាល់ចិត្ត និងគំនិតរបស់ពួកជំនុំ។

ឧទាហរណ៍៖ ក្នុងការប្រើប្រាស់ប្រធានបទ «ការឈោងចាប់ពិភពលោកថ្វាយព្រះគ្រីស្ទ» អ្នកអាចប្រើបទចម្រៀង «សេចក្ដីស្រឡាញ់នៃព្រះនោះខ្លាំង» ដោយពោលថា «យើងមានមហាព្រះរាជបញ្ញាឲ្យយកដំណឹងល្អទៅកាន់គ្រប់ជ្រុងជ្រោយនៃពិភពលោករបស់យើង។ យើងត្រូវប្រកាសដំណឹងល្អដល់អ្នកដែលនឿយព្រួយ ហើយចែកចាយដំណឹងល្អដល់អ្នកស្រេកឃ្លាន ឲ្យចូលមករកសេចក្ដីមេត្ដាករុណានៅឈើឆ្កាង ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ទើបទ្រង់បានប្រទានព្រះរាជបុត្រាតែមួយរបស់ទ្រង់ឲ្យស្វែងរកយើងដើម្បីជួយសង្គ្រោះយើង ហើយអ្នកណាដែលជឿលើទ្រង់ នឹងមានជីវិតរស់នៅអស់កល្បជានិច្ច»។

## ការបង្រៀនថ្វាយបង្គំ

អ្នកអាចឆ្លៀតឱកាសពោលពាក្យខ្លីៗក្នុងកម្មវិធី ដើម្បីជួយពួកជំនុំឲ្យយល់ថាអ្វីទៅជាការថ្វាយបង្គំយល់អំពីការផ្ដោតទៅលើការថ្វាយបង្គំ រៀបអង្គុយឬឈរត្រឹមត្រូវក្នុងការថ្វាយបង្គំ។ល។ ការប្រើខគម្ពីរក៏មានអំណាចខ្លាំងណាស់ដែរក្នុងការពោលពាក្យខ្លីៗដូចនេះ។

ឧទាហរណ៍៖ អ្នកអាចនិយាយថា «បទគម្ពីរទំនុកតម្កើង ១៣៤:២ បានចែងថា «ចូរប្រណម្យដៃទៅឯទីបរិសុទ្ធ ហើយសូមឲ្យព្រះយេហូវ៉ាបានព្រះពរចុះ»។ ក្នុងព្រះគម្ពីរទាំងមូល យើងឃើញថាការថ្វាយបង្គំមានលក្ខណៈសកម្មខាងរាងកាយ ហើយជាញឹកញាប់ក៏រាប់បញ្ចូលការលើកដៃសរសើរដំកើងព្រះ។ ពេលយើងច្រៀងបទនេះសូមលើកដៃឡើងក្នុងទីបរិសុទ្ធ ហើយថ្វាយព្រះពរដល់ព្រះអម្ចាស់សម្រាប់ការអ្វីដែលទ្រង់បានធ្វើក្នុងជីវិតយើង»។

## ចូរបង្រៀនអំពីលក្ខណសម្បត្តិរបស់ព្រះ

ក្រុមជំនុំត្រូវយល់ និងថ្វាយបង្គំចំពោះលក្ខណសម្បត្តិផ្សេងៗរបស់ព្រះ។ ប្រសិនបើបទចម្រៀងដែលអ្នកកំពុងប្រើនិយាយអំពីលក្ខណសម្បត្តិណាមួយរបស់ព្រះ សូមចំណាយពេលបន្តិច ដើម្បីជួយក្រុមជំនុំយល់អំពីលក្ខណសម្បត្តិនោះ។ នេះគឺជាផ្នែកមួយទៀតដែលអ្នកគួរប្រើបទគម្ពីរ ដើម្បីបំភ្លឺសេចក្ដីពិត។

ឧទាហរណ៍៖ ក្នុងការនិយាយអំពីលក្ខណសម្បត្តិនៃភាពស្មោះត្រង់របស់ព្រះ ចូរច្រៀងបទ «ការអស្ចារ្យ» ហើយនិយាយយ៉ាងដូចនេះថា «ព្រះគម្ពីរប្រាប់យើងថា សេចក្ដីស្រឡាញ់ដ៏ស្មោះត្រង់របស់ព្រះអម្ចាស់មិនចេះចប់ឡើយ! សេចក្ដីមេត្តាករុណារបស់ទ្រង់មិនចេះចប់ឡើយ។ ភាពស្មោះត្រង់របស់ទ្រង់ដ៏អស្ចារ្យ។ សេចក្ដីមេត្តាករុណារបស់ទ្រង់ចាប់ផ្ដើមជាថ្មីរាល់ព្រឹក»។ ព្រះរបស់យើងគឺស្មោះត្រង់។ អាម៉ែន? ទ្រង់អាចឲ្យយើងពឹងផ្អែកលើទ្រង់បានដោយសុវត្ថិភាព។ យើងអាចជឿជាក់លើទ្រង់ទាំងស្រុង។ ភាពស្មោះត្រង់គឺជាផ្នែកមួយនៃលក្ខណៈជាព្រះរបស់ទ្រង់។ មិនថាអ្នករាល់គ្នាជួបរឿងអ្វីនៅថ្ងៃនេះទេ ចូរដឹងថា ព្រះរបស់យើងទ្រង់ស្មោះត្រង់។ ទ្រង់នឹងមិនធ្វើឲ្យអ្នកខកចិត្ត ឬបែរខ្នងដាក់អ្នកឡើយ។ ចូរទុកចិត្តទ្រង់ក្នុងគ្រប់ការទាំងអស់»។ សូមតភ្ជាប់ដោយផ្ទាល់ទៅវគ្គទីពីរនៃបទចម្រៀង «ទ្រង់ស្មោះត្រង់ឆ្លងកាត់ព្យុះទីមួយៗ ... »

**ការស្វាគមន៍/ការដាស់តឿន/ការទូន្មាន។** សូមមើលផ្នែកស្ដីពីការបើកកម្មវិធី/ការស្វាគមន៍ខាងក្រោមនេះសម្រាប់ការស្វែងយល់លម្អិត។

# ចំណុចសំខាន់ប្រាំយ៉ាងដែលគួរនិយាយ៖

១. **ការបើកកម្មវិធី /ការស្វាគមន៍**

យើងចាំបាច់ត្រូវប្រញាប់បង្កើតភាពស្និទ្ធស្នាលជាមួយនឹងក្រុមជំនុំឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ទើបពួកគេជឿជាក់លើការដឹកនាំរបស់អ្នក។ នាទី

ដំបូងនៃកម្មវិធីថ្វាយបង្គំអាចកំណត់បរិយាកាសសម្រាប់ពេលវេលាការដឹកនាំរបស់អ្នកក្នុងកម្មវិធីថ្វាយបង្គំទាំងមូលតាមរយៈឥរិយាបថរបស់អ្នក និងរបៀបដែលអ្នកស្វាគមន៍ក្រុមជំនុំ។ អ្នកត្រូវមានលក្ខណៈជាខ្លួនឯងពិតប្រាកដ។ អ្នកមិនមែនជាពិធីកររបស់កម្មវិធីលេងហ្គេមនោះទេ។ ត្រូវមានចិត្តសុភាព។ សូមនិយាយទៅកាន់ក្រុមជំនុំ ដូចដែលអ្នកចង់និយាយទៅកាន់ក្រុមមិត្តភក្តិ ដើម្បីអញ្ជើញពួកគេចូលទៅក្នុងកម្មវិធីថ្វាយបង្គំ។

> ឧទាហរណ៍៖ «អរុណសួស្តី ខ្ញុំមានអំណរណាស់ ដែលយើងអាចជួបជុំគ្នាជាថ្មីម្តងទៀត។ សូមយើងរៀបចំចិត្ត ដើម្បីថ្វាយបង្គំព្រះអម្ចាស់។ សូមបង្វែរការសទ្ធារបស់យើងទៅកាន់ព្រះអម្ចាស់ ខណៈពេលដែលយើងចាប់ផ្តើមច្រៀង និងអធិស្ឋាននៅព្រឹកនេះ (តន្ត្រីចាប់ផ្តើម)។ សូមក្រោកឈរឡើង...»

ខ្ញុំពិតជាចង់លើកទឹកចិត្តអ្នកឲ្យប្រើប្រាស់បទគម្ពីរក្នុងការលើកទឹកចិត្តពួកជំនុំឲ្យចូលរួមក្នុងការថ្វាយបង្គំ — ដើម្បីជួយពួកគេផ្តោតចិត្តទៅលើព្រះ។ មានខគម្ពីរសរសើរតម្កើងជាច្រើននៅក្នុងព្រះគម្ពីរដែលមានប្រសិទ្ធភាពយ៉ាងខ្លាំង។

> ឧទាហរណ៍៖ «អរុណសួស្តីអស់លោកបងប្អូន។ សូមស្វាគមន៍មកកាន់កម្មវិធីថ្វាយបង្គំរបស់យើងនៅថ្ងៃនេះ! ខណៈពេលយើងចាប់ផ្តើមថ្វាយបង្គំព្រះអម្ចាស់ សូមឲ្យយើងមើលបទគម្ពីរទំនុកតម្កើង ៥១:១៥ «ឱព្រះអម្ចាស់អើយ សូមបើកបបូរមាត់ទូលបង្គំ នោះមាត់ទូលបង្គំនឹងបានប្រកាសប្រាប់ពីសេចក្តីសរសើររបស់ទ្រង់»។ យើងមកជួបជុំគ្នានៅពេលព្រឹកនេះ ដើម្បីបន្លឺសម្លេងសរសើរដំកើងព្រះអម្ចាស់នៃយើងដោយចិត្តដែលបើកចំហ និងក្លាហានឡើង។ សូមក្រោកឈរឡើង ហើយបន្លឺសម្លេងសរសើរតម្កើងព្រះអង្គ។ ចូរប្រកាសពីភាពសក្តិសមរបស់ព្រះអង្គនៅពេលឥឡូវនេះ!»

ក្នុងអំឡុងពេលនៃការស្វាគមន៍នេះ យើងចង់ជួយពួកគេឲ្យយល់អំពីមូលហេតុដែលយើងកំពុងធ្វើសកម្មភាពទាំងនោះនៅក្នុងកម្មវិធីថ្វាយបង្គំ (ប្រហែលជាតាមរយៈការលើកទឹកចិត្តតាមបទគម្ពីរ) និងអ្វីដែលយើងរំពឹងឲ្យពួកគេធ្វើ (ការក្រោកឈរ ការច្រៀង ការសរសើរតម្កើងព្រះដោយបបូរមាត់របស់អ្នក) ។ល។

ប្រសិនបើមានការសង្កត់ធ្ងន់ជាក់លាក់ ឬប្រភេទនៃខ្លឹមសារនៃការថ្វាយបង្គំនៅថ្ងៃនោះអ្នកអាចលើកយកវាមកនិយាយនៅក្នុងការបើកកម្មវិធីផងដែរ។

២. **មុនពេលបទចម្រៀងចាប់ផ្តើម**

ខណៈពេលដែលគេចាប់ផ្តើមលេងភ្លេងដើមដំបូងនៃបទចម្រៀង អ្នកអាចអនុវត្តតាមលំនាំណាមួយ នៅក្នុងផ្នែកណែនាំអំពីការនិយាយ ក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំ។ បើសិនជាភ្លេងដើមដំបូងនៃបទចម្រៀងមានការអង្រួនចិត្តខ្លាំង អ្នកអាចផ្តើមដោយភ្លេងស្រទន់ជាង មុននឹងចូលទៅក្នុងភ្លេងដើមដំបូងនៃបទចម្រៀងដែលអង្រួនចិត្តខ្លាំងជាង នៅពេលបញ្ចប់ការនិយាយរបស់អ្នក។

៣. **នៅពាក់កណ្តាលបទចម្រៀង**

នៅក្នុងកំណាត់ភ្លេង មុនពេលត្រឡប់ទៅរកខគម្ពីរ ឬក្នុងវគ្គភ្លេងសុទ្ធ នៅក្នុងបទចម្រៀងណាមួយ អ្នកអាចជួយពួកជំនុំរៀបចំខ្លួនសម្រាប់ល្បះបន្ទាប់ ដោយដកស្រង់បទគម្ពីរដែលទាក់ទងនឹងបទចម្រៀង ពុំនោះទេអ្នកអាចលើកទឹកចិត្តពួកគេឲ្យថ្វាយបង្គំ និងការសរសើរតម្កើង។ អ្នកអាចគ្រាន់តែប្រើពាក្យមួយឃ្លាដែលនឹងជួយក្រុមជំនុំឲ្យមានការចូលរួម និងមានការផ្តោតចិត្តកាន់តែច្រើន ក្នុងការថ្វាយបង្គំព្រះ។

៤. **ចុងបញ្ចប់នៃបទចម្រៀង**

ខណៈពេលដែលបទចម្រៀងឈានដល់សេចក្តីបញ្ចប់ ហើយភ្លេងនៅចុងបទចម្រៀងកំពុងលេង អ្នកអាចដកស្រង់បទគម្ពីរ ឬដកស្រង់ពាក្យមួយឃ្លាពីបទចម្រៀងដែលអ្នកទើបតែបានដឹកនាំច្រៀង ដែលអាចជួយក្រុមជំនុំផ្តោតអារម្មណ៍ ឬក៏អធិស្ឋានខ្លីៗដើម្បីបញ្ចប់បទចម្រៀងនោះ។ កុំទាន់បញ្ចប់នៅត្រឹមនោះអ្នកអាចត្រឡប់ទៅច្រៀងផ្នែកណាមួយនៃបទចម្រៀងនោះភ្លាមៗតាមរបៀបស្រគត់ស្រគំ និងសាមញ្ញជាង (សូមមើលផ្នែកស្តីពីការឆ្លើយតបឯកឯងតាមការគ្រោងទុក)។

៥. **នៅចន្លោះរវាងបទចម្រៀង**

ក្នុងករណីភាគច្រើន អ្នកប្រហែលជាចង់តភ្ជាប់បទចម្រៀង ដើម្បីដំណើរការយ៉ាងរលូនដូចដែលបានពិភាក្សាពីមុននៅក្នុងសៀវភៅនេះ។ ទោះយ៉ាងណាក៏ដោយ អ្នកអាចឲ្យគេលេងភ្លេងសុទ្ធដែលទាក់ទងនឹងបទចម្រៀង ដើម្បីឲ្យអ្នកអាច

និយាយក្នុងអំឡុងពេលនេះ។ នៅពេលនោះ អ្នកអាចដកស្រង់បទគម្ពីរទាញយកឃ្លាពីបទចម្រៀងមុន ដើម្បីជួយក្រុមជំនុំផ្តោតអារម្មណ៍ ឬផ្តល់ជាការអធិស្ឋាន។

## គំនិតបន្ថែម

បន្ទាប់ពីអ្នករៀបចំផែនការសម្រាប់លំដាប់លំដោយនៃកម្មវិធីថ្វាយបង្គំ អ្នកចាំបាច់ត្រូវធ្វើការតាមផែនការនោះ ដើម្បីទទួលបានលទ្ធផលល្អ។ តើធាតុនីមួយៗនឹងភ្ជាប់គ្នាយ៉ាងដូចម្តេច? តើមានអ្វីពាក្យសម្តីអ្វីខ្លះដែលមានប្រយោជន៍ ប្រសិនបើអ្នកមានអ្វីត្រូវនិយាយ? នៅពេលដែលអ្នកសម្រេចចិត្តថា អ្នកគួរនិយាយ នៅត្រង់ចំណុចណាខ្លះនៃកម្មវិធីថ្វាយបង្គំ ចូរកត់ត្រាទុកហើយទន្ទេញចំណុចគន្លឹះ ហើយហាត់សមប្រើពាក្យនោះតាមពេលវេលាដែលអ្នកនឹងមាន។ អ្នកក៏គួរតែហាត់សមជាមួយនឹងក្រុមតន្ត្រី ដើម្បីឲ្យពួកគេត្រៀមខ្លួនផងដែរ។

ប្រសិនបើអ្នកខ្លាចការនិយាយនៅលើឆាក សូមមុជចូលទៅក្នុងបទគម្ពីរដែលអ្នកអាចដកស្រង់នៅក្នុងកម្មវិធីថ្វាយបង្គំ។ សូមប្តេជ្ញាចិត្តទន្ទេញខគម្ពីរចងចាំឲ្យបានច្រើន។ ព្រះទ្រង់នឹងធ្វើឲ្យខគម្ពីរទាំងនោះផុសឡើងក្នុងគំនិតអ្នក ពេលអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ។ នៅពេលអ្នកបន្តសរសេរពាក្យដែលត្រូវនិយាយ និងហាត់សមការនិយាយព្រះអង្គនឹងប្រទានឲ្យអ្នកមានទំនុកចិត្តបន្ថែមទៀត ក្នុងការដឹកនាំរាស្ត្ររបស់ទ្រង់ក្នុងការថ្វាយបង្គំ។ សូមប្តេជ្ញាចិត្តអធិស្ឋានអំពីរឿងនេះយ៉ាងខ្ជាប់ខ្ជួន។

ទោះជាយ៉ាងណាក៏ដោយ អ្នកត្រូវដឹងច្បាស់ថា ការនិយាយច្រើនពេកនឹងធ្វើឲ្យបាត់ភាពរលូននៃដំណើរការរបស់កម្មវិធីថ្វាយបង្គំ។ ការឆ្លងពីចំណុចមួយទៅមួយទៀត ក្នុងកម្មវិធីថ្វាយបង្គំដោយប្រើពាក្យសម្តីខ្លះមានប្រយោជន៍ ប៉ុន្តែ តាមធម្មតាការនិយាយកាន់តែតិចកាន់តែល្អ។ ការប្រើអត្ថបទគម្ពីរខ្លីៗគឺល្អបំផុត។

**តើអ្នកចាំបាច់ត្រូវរៀបចំផែនការ សម្រាប់ការឆ្លងពីចំណុចមួយទៅចំណុចមួយ ក្នុងកម្មវិធីថ្វាយបង្គំ ដោយប្រើពាក្យសម្តីយ៉ាងប្រុងប្រយ័ត្នឬទេ?**

# វត្តមាននៅលើវេទិកា

ជាញឹកញាប់ ខ្ញុំឃើញក្រុមថ្វាយបង្គំដែលហាក់ដូចជារឹងស្លូក នៅពេលពួកគេដឹកនាំការថ្វាយបង្គំ។ ទឹកមុខ និងកាយវិការរបស់ពួកគេមិនទាក់ទាញ ហើយក៏មិនធ្វើជាគំរូតាមអត្ថន័យនៃការធ្វើជាអ្នកថ្វាយបង្គំដែរ។ ជាច្រើនដងពេកហើយ ដែលក្រុមអ្នកដឹកនាំថ្វាយបង្គំចំណាយពេលទាំងអស់របស់ពួកគេផ្តោតទៅលើរឿងតន្ត្រី ដោយមើលរំលងផ្នែកសំខាន់នៃភាពជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ។

ដោយមានការអនុញ្ញាត ខ្ញុំបានកែសម្រួលផ្នែកនេះភាគច្រើនចេញពីផតខាស (Podcasts) ធ្វើឡើងដោយ អាឡិកស៍ អិនហ្វាយដ៏ជៀន (Alex Enfiedjian 1)។ សូមពិនិត្យមើលគេហទំព័ររបស់ Alex: WorshipMinistryTraining.com សម្រាប់ធនធានដ៏អស្ចារ្យជាច្រើន។

ព្រះយេស៊ូវបានមានបន្ទូលថា ក្រឹត្យវិន័យធំបំផុតគឺត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្ត ព្រលឹង គំនិត និងកម្លាំង — នោះគឺពេញមួយរូបកាយរបស់អ្នក។ ហើយនៅក្នុង រ៉ូម ១២:២ ចែងថា យើងគួរតែថ្វាយរូបកាយរបស់យើងជាយញ្ញបូជារស់ដែលជាការថ្វាយបង្គំខាងវិញ្ញាណរបស់យើង។ ដូច្នេះតើយើងអាចប្រើរូបកាយរបស់យើងដើម្បីថ្វាយបង្គំព្រះ និងដឹកនាំអ្នកដទៃក្នុងកម្មវិធីថ្វាយបង្គំដោយរបៀបណា? តើអ្នកដឹងទេថា ពាក្យសម្តីរបស់អ្នករួមចំណែកត្រឹមតែ៧% នៃការទំនាក់ទំនងរបស់អ្នកប៉ុណ្ណោះ? អ្វីដែលនៅសល់ គឺភាសាកាយវិការ ការលើកដាក់សំឡេង ទឹកមុខ និងឥរិយាបថ។ ប្រសិនបើពាក្យសម្តីរបស់អ្នកមិនបានអមដោយភាសាកាយវិការត្រឹមត្រូវទេ ការប្រាស្រ័យទាក់ទងរបស់យើងគឺខ្សោយហើយ។ នោះហើយជាមូលហេតុដែលកាយវិការ មានសារៈសំខាន់ចំពោះអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ (គឺនរណាក៏ដោយដែលកំពុងដឹកនាំនៅលើឆាក គឺអ្នកភ្លេង និងអ្នកច្រៀងជាដើម)។ យើងត្រូវតែយកចិត្តទុកដាក់ចំពោះវត្តមានរបស់យើងនៅលើឆាក។ យើងត្រូវតែប្រើរូបកាយរបស់យើងតាមរបៀបដែលជួយពួកជំនុំភ្ជាប់ទំនាក់ទំនងជាមួយព្រះយេស៊ូវ។

**របៀបដែលយើងបង្ហាញខ្លួនយើងនៅលើឆាកអាចជួយ ឬធ្វើជាឧបសគ្គដល់ពួកជំនុំក្នុងកម្មវិធីថ្វាយបង្គំ**

ក្នុងនាមជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ យើងមិនគួរធ្វើឲ្យរូបកាយរបស់យើង និងរបៀបដែលយើងកំពុងឈរ ឬទឹកមុខរបស់យើងធ្វើជាឧបសគ្គដល់ការទំនាក់

ទំនងរវាងពួកជំនុំនឹងព្រះអម្ចាស់ឡើយ។ ត្រង់ចំណុចនេះ ខ្ញុំសូមបង្ហាញគន្លឹះសាមញ្ញចំនួនប្រាំបីដែលខ្ញុំសង្ឃឹមថានឹងធ្វើឲ្យវគ្គមានរបស់អ្នកនៅលើឆាកកាន់តែប្រសើរឡើង។ ក្នុងនោះ មានគន្លឹះប្រាំពីរចំណុចដែលត្រូវធ្វើ និងមួយចំណុចដែលមិនត្រូវធ្វើ។

១. **ត្រូវដឹងខ្លួន។** ត្រូវដឹងពីអ្វីដែលកំពុងកើតឡើងលើរាងកាយរបស់អ្នក។ ចូរដឹងអំពីឥរិយាបថ ដៃ ទឹកមុខ និងកាយវិការដែលឆ្លង។ តើកាយវិការរបស់អ្នកឆ្លុះបញ្ចាំងអំពីក្តីអំណរក្នុងព្រះអម្ចាស់ទេ? វិធីដ៏មានន័យមួយដែលយើងអាចកែលម្អ គឺការញញឹមពេលយើងដឹកនាំ — វាអាចមានឥទ្ធិពលយ៉ាងខ្លាំងមកលើក្រុមជំនុំ។ លើសពីនេះ វាគឺជាជំនួយដ៏ល្អប្រសិនបើអ្នកច្រៀង ទោះបីជាអ្នកមិនមែនជាអ្នកចម្រៀងក៏ដោយ ហើយទោះបីជាអ្នកច្រៀងដោយមិនបើកមេក្រូហ្វូននៅពេលនោះក៏ដោយ។ ពេលអ្នកច្រៀង ពួកជំនុំនឹងឃើញអ្នកផ្ចង់អារម្មណ៍ក្នុងកម្មវិធីថ្វាយបង្គំ ហើយការនេះនឹងបណ្តាលចិត្តពួកគេឲ្យផ្ចង់ចិត្តផងដែរ។

២. **ត្រូវមានទំនុកចិត្ត។** បើពួកជំនុំឃើញអ្នកអ្នកភ័យញ័រនៅលើឆាកនោះពួកគេអាចភ័យជាមួយអ្នកដែរ ហើយការនេះគឺជារនាំងធំមួយ។ មធ្យោបាយដ៏ល្អបំផុត ដើម្បីឲ្យអ្នកមានទំនុកចិត្ត គឺត្រូវរៀបចំខ្លួនឲ្យបានល្អ។ អ្នកត្រូវស្គាល់ភ្លេងឲ្យបានហ្មត់ចត់ ហើយកុំចេះតែច្រៀងៗ ដោយមិនស្គាល់ភ្លេងច្បាស់ឡើយ។ សូមទន្ទេញបទចម្រៀងឲ្យចាំ បើសិនជាអាច។ ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងសៀវភៅនេះ ប្រសិនបើអ្នកនឹងនិយាយក្នុងពេលកំពុងដឹកនាំ ចូរត្រៀមខ្លួន និងហាត់សមនូវអ្វីដែលអ្នកនឹងនិយាយ។

៣. **ត្រូវសម្តែងចេញលក្ខណៈជាខ្លួនឯង។** ជាទូទៅ គេអាចដឹងបានថាអ្នកមានលក្ខណៈជាខ្លួនឯងឬអត់។ ពួកគេអាចដឹងថា អ្នកគ្រាន់តែសម្តែងគឺមិនមែនកំពុងតែច្រៀង និងថ្វាយបង្គំ ដោយអស់ពីចិត្តឬអត់ ឬអ្នកគ្រាន់តែចាក់បណ្តោយតាមគេតាមឯងក្នុងកម្មវិធីថ្វាយបង្គំ។ យើងត្រូវតែបង្ហាញធាតុពិតរបស់យើង។ សូមបន្លឺសម្លេងឡើងដោយអំណរ ឬយំ ឬបញ្ចេញកាយវិការ។ ការបង្ហាញចេញនេះមានលក្ខណៈខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ សូមប្រើរូបកាយរបស់អ្នក ប៉ុន្តែ ប្រើវាតាមរបៀបដែលតំណាងឲ្យខ្លួនអ្នក ហើយមើលទៅដូចជាខ្លួនអ្នកផ្ទាល់។

៤. **ចូរធ្វើជាគំរូ។** ក្រុមជំនុំឆ្លុះបញ្ចាំងពីអ្នកដឹកនាំរបស់ពួកគេ។ បើយើងធុញទ្រាន់ ឬមិនបានធ្វើអស់ពីចិត្តនៅលើឆាក ក្រុមជំនុំប្រហែលជាធុញទ្រាន់ និងមិនចូលរួមអស់ពីចិត្តដែរ។ ហេតុអ្វីបានជាយើងគួររំពឹងឲ្យពួកគេស្រែកឡើងហើយលើកដៃថ្វាយបង្គំព្រះអម្ចាស់ដោយចិត្តឆេះឆួលបាន បើយើងមិនឆេះឆួលទេនោះ? ពួកគេគ្រាន់តែឆ្លុះបញ្ចាំងពីអ្វីដែលពួកគេឃើញយើងធ្វើប៉ុណ្ណោះ។ យើងជួយក្រុមជំនុំឲ្យចូលរួមដោយអស់ពីចិត្តពេលយើងបង្ហាញគំរូឲ្យពួកគេធ្វើតាម។ សូមយើងបង្ហាញពួកគេពីរបៀបធ្វើជាគំរូ។ យើងត្រូវជំរុញពួកគេដោយភាសាកាយវិការរបស់យើង។

៥. **ចូរស្ដាប់បង្គាប់ព្រះគម្ពីរ។** យើងមានព្រះរាជបញ្ជាឲ្យ «ច្រៀងថ្វាយព្រះអម្ចាស់» ប៉ុន្តែ ជាញឹកញាប់ យើងមិនធ្វើលើសពីនេះទេ។ ចុះចំណែកឯព្រះរាជបញ្ជាឲ្យលើកដៃ ទះដៃ រាំ និងស្រែកឡើងដោយអំណរ ហើយស្រែកឲ្យឮៗ? ខណៈពេលដែលអ្នកធ្វើតាមបទគម្ពីរ នៅក្នុងសកម្មភាពរបស់អ្នក អ្នកនឹងបង្រៀនក្រុមជំនុំឲ្យធ្វើតាមបទគម្ពីរផងដែរ ហើយដឹកនាំពួកគេដោយធ្វើជាគំរូ។

៦. **ត្រូវភ្ជាប់ទំនាក់ទំនង។** សូមបើកភ្នែករបស់អ្នក ចូលរួមជាមួយក្រុមជំនុំ មើលទៅពួកគេក្នុងកន្លែងកម្មវិធីថ្វាយបង្គំ ញញឹម ហើយផ្ដោតចិត្តទៅលើកម្មវិធីនៅទីនោះ។ សូមឲ្យចិត្តអ្នកនៅជាប់នឹងពេលនៃកម្មវិធីថ្វាយបង្គំ — សូមរីករាយនឹងការថ្វាយបង្គំព្រះបិតាដ៏ល្អរបស់យើង។ ការមើលឃើញពួកគេថ្វាយបង្គំអាចជួយអ្នកឲ្យថ្វាយបង្គំផងដែរ។

៧. **ត្រូវចេះគ្រប់គ្រងខ្លួនឯង។** សូមប្រើភាសាកាយវិការរបស់អ្នក ដើម្បីដឹកនាំក្រុមជំនុំ។ សូមប្រើភាសាកាយវិការរបស់អ្នកដើម្បីជួយក្រុមជំនុំឲ្យដឹងថាពេលណាត្រូវចាប់ផ្ដើមច្រៀង។ សូមបង្វែរការយកចិត្តទុកដាក់របស់អ្នកទៅរកអ្នកណាដែលនិយាយអានបទគម្ពីរ។ល។ ដើម្បីជួយមនុស្សក្នុងកន្លែងថ្វាយបង្គំឲ្យផ្ដោតលើអ្វីដែលសំខាន់។ ចូរប្រយ័ត្នកុំទាញចំណាប់អារម្មណ៍មកលើខ្លួនឯង។

៨. **កុំធ្វើឲ្យគេបែកអារម្មណ៍** ការដឹកនាំថ្វាយបង្គំ គឺជាសិល្បៈនៃការលុបបំបាត់ការបែកអារម្មណ៍។ កុំស្លៀកសម្លៀកបំពាក់មិនសមរម្យដែលធ្វើឲ្យគេបែកអារម្មណ៍។ ត្រូវប្រាកដថា ចលនារបស់អ្នកសមស្របនឹងបរិបទរបស់អ្នក។

**ប្រើភាសាកាយវិការរបស់អ្នកជាឧបករណ៍ដើម្បីដឹកនាំពួកជំនុំ កុំធ្វើឲ្យពួកគេបែកអារម្មណ៍ឡើយ**

**សូមចងចាំថា ព្រះទ្រង់បានត្រាស់ហៅអ្នក ឲ្យប្រើរូបកាយរបស់អ្នកជាឧបករណ៍សម្រាប់ថ្វាយបង្គំព្រះ និងជាឧបករណ៍សម្រាប់ដឹកនាំក្រុមជំនុំរបស់អ្នកក្នុងការថ្វាយបង្គំ។**

**សូមមើលវីដេអូនៃក្រុមថ្វាយបង្គំរបស់អ្នកដឹកនាំកម្មវិធីថ្មីៗកន្លងមកនេះ។ តើក្រុមរបស់អ្នកត្រូវការអ្វី ដើម្បីធ្វើការទំនាក់ទំនងកាន់តែល្អក្នុងការប្រើវត្តមានរបស់ពួកគេនៅលើវេទិកា? តើអ្នកត្រូវការការកែលម្អផ្ទាល់ខ្លួនដូចម្តេចខ្លះ?**

## ការដកឧបសគ្គដែលរារាំងការតភ្ជាប់ជាមួយក្រុមជំនុំ

ថ្មីៗនេះ ខ្ញុំបានចូលរួមកម្មវិធីថ្វាយបង្គំដែលក្នុងនោះឧបសគ្គខាងរូបកាយ គឺជាការរារាំងដល់ការដឹកនាំ។ នៅក្នុងកម្មវិធីនោះ អ្នកច្រៀងទោលដ៏ឆ្នើមម្នាក់បានច្រៀងចម្រៀងប៉ះពាល់ចិត្តដែលមានសក្តានុពលយ៉ាងខ្លាំង ក្នុងការចែកចាយទីបន្ទាល់ដ៏មានឥទ្ធិពល។ អ្នកចម្រៀងទោលនោះបានឈរនៅកន្លែងសម្រាប់ក្រុមចម្រៀងឈរច្រៀង នៅពីក្រោយកន្លែងអ្នកភ្លេង នៅពីក្រោយព្យាណូធំ នៅពីក្រោយគ្រឿងសង្ហារឹមនៃវេទិកា (កៅអី តុអាសនាមានទំហំធំខ្លាំង។ល។) ហើយនាងក៏បានច្រៀងដោយមើលក្រដាសចម្រៀង។ ការច្រៀងនោះមានការតភ្ជាប់នៃដួងចិត្តតិចតួចណាស់ជាមួយនឹងក្រុមជំនុំ។ ការផ្លាស់ប្តូរយ៉ាងខ្លាំងអាចកើតឡើង

ប្រសិនបើអ្នកលេងភ្លេងចេះ និងចាំបទចម្រៀងនោះច្បាស់ ហើយឈរនៅលើឆាក នៅក្បែរតុអាសនាដោយគ្មានរនាំងរវាងនាង និងក្រុមជំនុំហើយច្រៀងបទចម្រៀងនោះ ដោយមានការតភ្ជាប់ដ៏មានថាមពលជាមួយក្រុមជំនុំ។ នាងអាចច្រៀងបទចម្រៀងនោះដោយមានឥទ្ធិពលខ្លាំងជាងនេះនៅក្នុងកម្មវិធីថ្វាយបង្គំនៅថ្ងៃនោះ។ អ្នកដឹកនាំថ្វាយបង្គំគួរតែខិតខំដករនាំងនៃរូបកាយដែលរារាំងតួនាទីរបស់ពួកគេ។

ស្រដៀងគ្នានេះដែរ ក្រុមចម្រៀងត្រូវព្យាយាមដករនាំងចេញ។ ឧបសគ្គដ៏ធំបំផុតមួយដែលក្រុមចម្រៀងមាន គឺក្រដាសចម្រៀង។ ពេលក្រុមចម្រៀងទន្ទេញចាំបទចម្រៀង ហើយចាប់ផ្តើមថ្វាយបង្គំព្រះអម្ចាស់ ពេលពួកគេច្រៀងនោះក្រុមជំនុំនឹងមានចិត្តឆេះឆួលចង់ថ្វាយបង្គំជាមួយពួកគេផងដែរ។ពួកគេចាប់ផ្តើមនាំក្រុមជំនុំចូលទៅក្នុងការថ្វាយបង្គំជាជាងធ្វើឲ្យពួកគេគិតថា ពួកគេគួរតែអង្គុយស្តាប់ការសម្តែងដ៏អស្ចារ្យដោយក្រុមចម្រៀង។

មុននេះបន្តិច ខ្ញុំបានរៀបរាប់ពីសារៈសំខាន់នៃក្រុមចម្រៀងដែលទន្ទេញចាំបទចម្រៀង។ នៅក្នុងសៀវភៅដែលលោក ដេវ វីលៀមសិន (Dave Williamson) បាននិពន្ធមានចំណងជើងថា អ្នកចម្រៀងរបស់ព្រះ គាត់បានដាស់តឿនពីអត្ថប្រយោជន៍នៃក្រុមចម្រៀងដែលទន្ទេញចាំបទចម្រៀង៖

- ក្រុមចម្រៀងច្រៀងបានល្អជាង ហើយមានសេរីភាពជាង។
- របាំង (ក្រដាសចម្រៀង) ដែលបានដកចេញធ្វើឲ្យក្រុមជំនុំមានអារម្មណ៍ជិតស្និទ្ធនឹងក្រុមចម្រៀងក្នុងនាមជាអ្នកដឹកនាំពួកគេថ្វាយបង្គំ។
- ដៃរបស់ក្រុមចម្រៀងទំនេរមិនមានកាន់អ្វីអាចលើកឡើងក្នុងឥរិយាបថថ្វាយបង្គំតាមព្រះគម្ពីរ។
- ក្រុមចម្រៀងបានងើបមុខឡើង ពួកជំនុំអាចឃើញមុខរបស់ពួកគេទាំងអស់គ្នាច្បាស់។
- ក្រុមចម្រៀងដឹងពីវត្តមានរបស់គ្នាទៅវិញទៅមក ហើយអាចរួបរួមចិត្តគំនិតក៏ដូចជាសំឡេងនៅក្នុងសកម្មភាពនៃការដឹកនាំថ្វាយបង្គំ។
- ក្រុមចម្រៀងមានអារម្មណ៍ជិតស្និទ្ធនឹងក្រុមជំនុំ ហើយអាចដឹកនាំពួកគេក្នុងការថ្វាយបង្គំកាន់តែមានប្រសិទ្ធភាព។
- ដែលសំខាន់បំផុតនោះ គឺក្រុមចម្រៀងមានសេរីភាពក្នុងការផ្តោតអារម្មណ៍ទាំងមូលទៅលើសកម្មភាពនៃការថ្វាយបង្គំព្រះដែលជាជំហានដំបូង និងចាំបាច់បំផុត ក្នុងដំណើរការនៃការដឹកនាំអ្នកដទៃថ្វាយបង្គំទ្រង់។ [២]

---

២ លោក Dave Williamson, God’s Singers: A Guidebook for the Worship Leading Choir in

មតិដូចគ្នាដែលខ្ញុំបានលើកឡើងខាងលើអំពីក្រុមចម្រៀង និងអ្នកចម្រៀងទោលក៏អាចអនុវត្តចំពោះក្រុមច្រៀងផងដែរ។ សូមយើងស្វែងរកវិធីដករនាំងរវាងអ្នកចម្រៀង និងក្រុមជំនុំចេញ។

សូមវាយតម្លៃអ្នកចម្រៀងដែលដឹកនាំពួកជំនុំក្នុងការថ្វាយបង្គំ។ តើពួកគេកំពុងបង្កើតបរិយាកាសសម្រាប់អ្នកទស្សនានៅក្នុងព្រះវិហាររបស់អ្នក ឬពួកគេកំពុងជួយពួកជំនុំឲ្យពិតជាថ្វាយបង្គំព្រះប្រាកដមែន? តើមានឧបសគ្គដែលអាចមើលឃើញអ្វីខ្លះ ដែលរារាំងការដឹកនាំរបស់ពួកគេ? តើអ្នកអាចកែលម្អអ្នកចម្រៀងរបស់អ្នកដោយរបៀបណា?

## ការរៀបផែនការកម្មវិធីថ្វាយបង្គំសម្រាប់មនុស្សមកពីព្រះវិហារផ្សេងគ្នា និងមានរចនាបថថ្វាយបង្គំផ្សេងៗគ្នា

ជារឿយៗ ខ្ញុំដឹកនាំការថ្វាយបង្គំនៅក្នុងព្រឹត្តិការណ៍ ដែលមានអ្នកចូលរួមមកពីព្រះវិហារជាច្រើន។ ព្រះវិហារទាំងនេះជាតំណាងឲ្យរចនាបថនៃកម្មវិធីថ្វាយបង្គំផ្សេងគ្នា និងមានបទចម្រៀងថ្វាយបង្គំខុសគ្នា។ អ្នកខ្លះច្រៀងបទទំនុកសកលហើយប្រើតែចម្រៀងថ្វាយបង្គំសម័យទំនើបពីរបីបទ ឬមិនប្រើទាល់តែសោះ។ អ្នកខ្លះច្រៀងតែបទចម្រៀងសម័យបច្ចុប្បន្នភាគច្រើន។ ព្រះវិហារខ្លះថ្វាយបង្គំដោយប្រើតែឧបករណ៍អ័ក ឬព្យាណូ ឯខ្លះទៀតប្រើវង់ភ្លេងថ្វាយបង្គំ។ ខ្លះទៀតប្រើក្រុមចម្រៀង ហើយខ្លះទៀតប្រើក្រុមច្រៀង។ ព្រះវិហារខ្លះទៀតស្ថិតនៅចន្លោះប្រភេទទាំងអស់នេះ។

ការរៀបចំផែនការសម្រាប់កម្មវិធីថ្វាយបង្គំក្នុងព្រឹត្តិការណ៍ទាំងនេះអាចជួបបញ្ហាប្រឈមច្រើន។ ដើម្បីឲ្យមនុស្សចូលរួមក្នុងការថ្វាយបង្គំ យើងត្រូវប្រើបទចម្រៀងដែលពួកគេស្គាល់ ប៉ុន្តែ ប្រសិនបើអ្នកមានបញ្ជីបទចម្រៀងនីមួយៗដែលពួកគេម្នាក់ៗចេះច្រៀងអ្នកអាចឃើញថា មានបទចម្រៀងមិនច្រើនទេ ដែលពួកគេតែងតែចេះច្រៀងទាំងអស់គ្នា។ លើសពីនេះ ខ្ញុំយល់ថាយើងចាំបាច់ត្រូវប្រើប្រាស់បទចម្រៀងជាច្រើន ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមនុស្សម្នាក់ៗតាមប្រភេទបទ

the 21st Century (United States: In: Ciite Media, ឆ្នាំ២០១០) ទំព័រ១២៤។

ចម្រៀងដែលពួកគេចូលចិត្ត។ ដូច្នេះ តើយើងត្រូវបង្កើតបរិយាកាសថ្វាយបង្គំយ៉ាងដូចម្ដេច ដែលពួកជំនុំរបស់យើងអាចចូលរួម និងថ្វាយបង្គំបាន?

១. **ខ្ញុំអធិស្ឋានសុំការណែនាំពីព្រះក្នុងការជ្រើសរើសតន្ត្រី និងធ្វើផែនការរៀបចំពេលវេលាថ្វាយបង្គំ។**

២. **ខ្ញុំជ្រើសរើសចម្រៀងជាច្រើនប្រភេទ** (ឆ្នាំនៃការនិពន្ធ រចនាបថ ។ល។) ដើម្បីបញ្ចូលក្នុងពេលវេលានៃការថ្វាយបង្គំ។

៣. **ខ្ញុំទាញយកបទចម្រៀងពីក្នុងចំណោមបទចម្រៀងដែលគេស្គាល់ច្រើនបំផុតនៃសម័យកាល** និងរចនាបថទាំងនោះ។ បើអាចធ្វើបាន សូមពិភាក្សាជាមួយថ្នាក់ដឹកនាំដែលមកពីក្រុមជំនុំនានា ដែលចូលរួមកម្មវិធីថ្វាយបង្គំ។ ពេលខ្ញុំមើលបញ្ជីបទចម្រៀងរបស់CCLI ខ្ញុំអាចជ្រើសរើសបទចម្រៀង ដែលពួកជំនុំស្គាល់ច្រើនជាង។

៤. **ខ្ញុំត្រូវប្រាកដថា យើងច្រៀងបទចម្រៀងទាំងអស់ដោយប្រើគុង ដែលអ្នកចូលរួមភាគច្រើន អាចច្រៀងបាន។** ខ្ញុំបានសរសេរយ៉ាងទូលំទូលាយលើប្រធានបទនេះ ប៉ុន្តែ ចំណុចសំខាន់គឺថាបទភ្លេងគួរតែស្ថិតនៅចន្លោះគុងដូ (C) និងដូ (C) ដោយបទចម្រៀងដែលនៅចន្លោះគុងច្រើន គឺពីឡា (A) ដល់រ៉េ (D) និងជួនកាលមានគុង Eb ។ ការច្រៀងនៅខាងក្រៅចន្លោះគុងនេះនាំឲ្យគេខ្វះការចូលរួម។

៥. **បើសិនជាអាច ខ្ញុំព្យាយាមបញ្ចូលជម្រើសផ្សេងៗឲ្យបានច្រើននៅក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំ។** សូមប្រើប្រាស់ក្រុមចម្រៀង ក្រុមច្រៀងផ្នែកចង្វាក់/វង់ភ្លេង ផ្នែកផ្លុំស្នែង។ល។

៦. **ខ្ញុំបានត្រៀមធនធានជាជំនួយដល់កម្មវិធីថ្វាយបង្គំដែលមានបទចម្រៀងទាំងអស់ដែលយើងនឹងច្រៀង។** សម្រាប់បទចម្រៀងនីមួយៗ ខ្ញុំបានដាក់បញ្ចូលវីដេអូដែលមានទំនុកច្រៀង ដើម្បីឲ្យពួកជំនុំរៀនច្រៀងបទចម្រៀងទាំងនោះមុនពេលពួកគេចូលរួមកម្មវិធីថ្វាយបង្គំ។ បើសិនជាអាចខ្ញុំផ្ញើវាទៅអ្នកចូលរួមម្នាក់ៗមុនថ្ងៃកម្មវិធីថ្វាយបង្គំ ហើយសុំឲ្យពួកគេចាប់ផ្ដើមរៀនបទចម្រៀងដែលពួកគេមិនស្គាល់នៅក្នុងពេលវេលានៃ

ការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីឲ្យពួកគេមានពេលវេលាដ៏មានន័យបន្ថែមទៀតក្នុងកម្មវិធីការថ្វាយបង្គំរួមគ្នានៅពេលយើងជួបជុំគ្នាសម្រាប់ព្រឹត្តិការណ៍នោះ។ នេះជាជំនួយដ៏ធំមួយសម្រាប់ព្រឹត្តិការណ៍ក្នុងអតីតកាល ហើយបាននាំមកនូវការសរសើរយ៉ាងច្រើនពីអ្នកចូលរួម។

៧. **ខ្ញុំអធិស្ឋានសូមព្រះនាំក្រុមជំនុំ ចូលរួមក្នុងកម្មវិធីថ្វាយបង្គំនោះដោយទុកចោលនូវចំណង់ចំណូលចិត្តផ្ទាល់ខ្លួន** និងភាពលំអៀងទាក់ទងនឹងបទចម្រៀងដែលយើងកំពុងប្រើ ហើយគ្រាន់តែលើកតម្កើងព្រះយេស៊ូវវិញ។

កាលពីប៉ុន្មានឆ្នាំមុន គេបានអញ្ជើញខ្ញុំឲ្យដឹកនាំផ្នែកតន្ត្រីក្នុងកម្មវិធីថ្វាយបង្គំសម្រាប់សន្និបាតដ៏ធំមួយ។ កាលពីមុន កិច្ចប្រជុំតែងតែត្រូវបានដឹកនាំតាមរបៀបប្រពៃណី ដោយប្រើទំនុកសកល និងឧបករណ៍អ័ក ឬព្យាណូ។ អ្នករៀបចំព្រឹត្តិការណ៍ចង់ឲ្យខ្ញុំដឹកនាំក្រុមតន្ត្រី និងក្រុមច្រៀង ជំនួសវិញ ដោយបញ្ចូលរចនាបថថ្វាយបង្គំទំនើប។ ខ្ញុំបានសារភាពថា ខ្ញុំពិតជាបារម្ភអំពីរបៀបដែលក្រុមជំនុំនឹងចូលរួម។ ខ្ញុំបានរៀបចំផែនការគ្រប់ពេលវេលានៃកម្មវិធីថ្វាយបង្គំ ហើយរៀបចំគេហទំព័រដែលមានវីដេអូបទចម្រៀងដែលមានបង្ហាញទំនុកច្រៀងនៅពីលើ និងការណែនាំមួយចំនួន។ អ្នកចូលរួមទាំងអស់ត្រូវបានជំរុញឲ្យត្រៀមខ្លួនទុកជាមុន។ ខ្ញុំមានការភ្ញាក់ផ្អើលនៅពេលដែលក្រុមជំនុំនោះ គឺជាក្រុមជំនុំមួយដែលមានការចូលរួមច្រើនបំផុតដែលខ្ញុំធ្លាប់ដឹកនាំ។ សំឡេងច្រៀងរាប់រយនាក់បានបន្លឺឡើងយ៉ាងខ្លាំងក្លាដោយចិត្តឆេះឆួល។ ខ្ញុំជឿថា ជោគជ័យដ៏អស្ចារ្យនេះ គឺដោយសារការធ្វើតាមការណែនាំដែលខ្ញុំបានរៀបរាប់ខាងលើ។ សូមអធិស្ឋាន រៀបចំខ្លួនអ្នក និងជួយអ្នកចូលរួមត្រៀមខ្លួន សម្រាប់កម្មវិធីថ្វាយបង្គំ។

ប្រហែលឧទាហរណ៍មួយ ក្នុងចំណោមគំរូដ៏អស្ចារ្យបំផុតនៃការជួយពួកជំនុំឲ្យមានការត្រៀមខ្លួនជាមុន គឺក្នុងអំឡុងពេលប៉ុន្មានឆ្នាំនៃការជួបជុំរបស់ចលនា Promise Keepers’ rallies នៅសហរដ្ឋអាមេរិកដែលមានអ្នកចូលរួមពេញកីឡាដ្ឋានបាល់ទាល់ជាច្រើននៅទូទាំងប្រទេសដែលពួកគេសុទ្ធតែជាបុរសដែលថ្វាយបង្គំព្រះ។ បន្ទាប់ពីពួកគេចុះឈ្មោះចូលរួមព្រឹត្តិការណ៍នោះ ពួកគេនឹងទទួលបានការសែតម៉ាញ៉េសម្រាប់ចាក់ស្តាប់ចម្រៀងទាំងអស់ដែលគេនឹងប្រើក្នុងកម្មវិធីថ្វាយបង្គំក្នុងព្រឹត្តិការណ៍នោះ។ បុរសទាំងនោះក៏បានស្តាប់បទចម្រៀងទាំង

នោះម្តងហើយម្តងទៀតជាច្រើនសប្តាហ៍មុនពេលទៅចូលរួមការជួបជុំនោះ។ ពេលដែលថ្ងៃនោះបានមកដល់ ការច្រៀងបានបន្លឺឡើងដោយសម្លេងកងរំពង ខណៈដែលបុរសទាំងនោះបង្ហាញចេញនូវការថ្វាយបង្គំព្រះដោយចិត្តឆេះឆួល។ ការនោះមិនអាចកើតឡើងបានទេ បើគ្មានការត្រៀមខ្លួនទុកជាមុន។

ប្រាកដណាស់ មានពេលជាច្រើនដងដែលការជួយក្រុមជំនុំត្រៀមខ្លួនជាមុនដោយការចែករំលែកធនធានយ៉ាងដូចនេះ គឺជាអ្វីដែលគេមិនអាចធ្វើបាន។ ក្នុងករណីទាំងនោះ អ្នកអាចខិតខំសម្រេចគ្រប់ចំណុចខាងលើ លើកលែងតែចំណុចមួយនោះ។ ការដឹកនាំការជួបជុំគ្នាដែលមានការឆេះឆួលដូចនេះ ពិតជាមានអំណរខ្លាំងណាស់។

**តើអ្នកអាចគិតអំពីឧទាហរណ៍នៃព្រឹត្តិការណ៍ប្រភេទនេះដែលអ្នកអាចនឹងមានឱកាសដឹកនាំបានទេ? វាអាចជាការប្រជុំនៃព្រះវិហារតាមតំបន់ សន្និបាតបុរស ឬស្ត្រី ឬការប្រជុំអំពីបេសកកម្ម។ តើអ្នកនឹងខិតខំឆ្ពោះទៅរកឱកាសបែបនេះក្នុងការធ្វើផែនការ និងការអនុវត្តផែនការយ៉ាងដូចម្តេចខ្លះ?**

# VI. ការវាយតម្លៃកម្មវិធី ថ្វាយបង្គំ

ការវាយតម្លៃជាប្រចាំ មកលើអ្វីដែលអ្នកចង់កែលម្អ គឺជាផ្នែកដ៏សំខាន់នៃការរីកចម្រើន។ ការដឹកនាំកម្មវិធីថ្វាយបង្គំក៏មានលក្ខណៈដូចនេះផងដែរ។ នៅពេលអ្នកធ្វើការផ្លាស់ប្តូរ និងព្យាយាមកែលម្អខ្លួនឯង ក្នុងនាមជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ និងព័ន្ធកិច្ចថ្វាយបង្គំក្នុងព្រះវិហាររបស់អ្នក អ្នកត្រូវតែវាយតម្លៃការរីកចម្រើនរបស់អ្នកឲ្យបានទៀងទាត់។

ដើម្បីវាយតម្លៃការដឹកនាំ និងព័ន្ធកិច្ចរបស់អ្នក អ្នកត្រូវតែមានគោលដៅ ឬស្តង់ដារមួយចំនួនដែលអ្នកកំពុងព្យាយាមឈោងឲ្យដល់។

ក្រុមថ្វាយបង្គំរបស់អ្នក អាចចាប់ផ្តើមធ្វើការវាយតម្លៃ ដោយពិភាក្សាអំពីចក្ខុវិស័យ ដែលព្រះទ្រង់មានសម្រាប់ព័ន្ធកិច្ចរបស់អ្នក។ សូមមើលឧទាហរណ៍ខាងក្រោម៖

- ក្រុមជំនុំជាទីកន្លែងដែលមនុស្សមានចិត្តឆេះឆួលចង់មកជួបជាមួយព្រះរៀងរាល់សប្តាហ៍។
- ក្រុមថ្វាយបង្គំដែលប្តេជ្ញាទាំងស្រុងចំពោះកិច្ចការដែលព្រះបានត្រាស់ហៅពួកគេ ហើយការកែលម្អ និងរីកចម្រើនក្នុងទំនាក់ទំនងរបស់ពួកគេជាមួយព្រះ និងក្នុងសិល្បៈចម្រៀង។
- មនុស្សគ្រប់ជំនាន់ថ្វាយបង្គំរួមគ្នាពិតប្រាកដ និងថ្វាយការសរសើរជាដង្វាយ។

ទាំងនេះគឺជាគោលដៅដែលសក្តិសមបំផុត។

## តើអ្នកមានអារម្មណ៍ថា ព្រះបណ្ដាលចិត្តក្រុមរបស់អ្នកឲ្យធ្វើអ្វី?

ក្រៅពីការធ្វើការជាមួយក្រុមថ្វាយបង្គំរបស់អ្នក ដើម្បីកំណត់គោលដៅមួយចំនួនសម្រាប់ព័ន្ធកិច្ច ខ្ញុំសូមលើកទឹកចិត្តអ្នកមើលសៀវភៅនេះឡើងវិញ ហើយកំណត់គោលដៅច្បាស់លាស់មួយចំនួនសម្រាប់ការរស់នៅ និងព័ន្ធកិច្ចរបស់អ្នក។ អ្នកអាចកំណត់គោលដៅរបស់ព័ន្ធកិច្ចតាមលំនាំខាងលើ។ ប្រហែលជា គោលដៅរបស់បុគ្គលម្នាក់ៗ គួរតែដើម្បីឱ្យអ្នកកាន់តែងាយស្រួលនិយាយ និងឆ្លងពីចំណុចមួយទៅចំណុចមួយទៀតនៃកម្មវិធីថ្វាយបង្គំ ឬដើម្បីឱ្យកាន់តែប្រសើរឡើង ក្នុងការធ្វើឱ្យមានតុល្យភាពខាងវិញ្ញាណ និងសេចក្ដីពិតក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំ។

អ្វីក៏ដោយដែលអ្នកយល់ថា ព្រះកំពុងដឹកនាំអ្នកឱ្យខិតខំប្រឹងប្រែងធ្វើ អ្នកគួរតែកំណត់ជំហានច្បាស់លាស់មួយចំនួន ដើម្បីសម្រេចបាននូវគោលដៅទាំងនោះ។ កំណត់ជំហានសកម្មភាព និងពេលវេលាកំណត់ ដើម្បីឱ្យអ្នកបន្តអនុវត្តតាម។ ឧទាហរណ៍ អ្នកប្រហែលជាមានអារម្មណ៍ថា អ្នកត្រូវតែមានខគម្ពីរសរសើរតម្កើង ដែលអ្នកអាចបញ្ចូលទៅក្នុងកម្មវិធីថ្វាយបង្គំបានយ៉ាងងាយស្រួល។ អ្នកបានកំណត់សកម្មភាពជាជំហាន នៃការទន្ទេញមួយខគម្ពីរ១ខក្នុងមួយសប្ដាហ៍ ខណៈពេលដែលពិនិត្យមើលសប្ដាហ៍មុនៗឡើងវិញ ក្នុងរយៈពេលប្រាំមួយខែដំបូង។ ក្នុងរយៈពេលប្រាំមួយខែ អ្នកមាន២៦ខគម្ពីរ ដែលបានប្ដេជ្ញាចិត្តទន្ទេញឲ្យចាំ។ ប្រហែលជាអ្នកអាចកំណត់គោលដៅមួយ ដើម្បីការដឹកនាំរបស់អ្នកកាន់តែល្អ ក្នុងការថ្វាយបង្គំព្រះ ក្នុងការបន្ថែមសកម្មភាព នៅចន្លោះចំណុចណាមួយ ក្នុងកម្មវិធីថ្វាយបង្គំ តាមការគ្រោងទុក។ សកម្មភាពជាជំហានៗ អាចជាការចំណាយពេលពីរបីម៉ោង ជារៀងរាល់សប្ដាហ៍ ដើម្បីបង្កើត និងហាត់សមរបៀបឆ្លងពីចំណុចមួយទៅចំណុចមួយ ក្នុងកម្មវិធីថ្វាយបង្គំ សម្រាប់រយៈពេលមួយខែ បន្ទាប់មក អ្នកចាប់ផ្ដើមបន្ថែមសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពបន្ថែម នៅចន្លោះចំណុចណាមួយនៃកម្មវិធីថ្វាយបង្គំ។ ជំហានទាំងនេះអាចជួយក្រុមថ្វាយបង្គំរបស់អ្នក សម្របខ្លួនទៅនឹងសកម្មភាពបន្ថែមទាំងនេះ។

យើងគួរកំណត់គោលដៅ ដោយមានដំណើរការយ៉ាងជាប់លាប់ដូចនេះ ដើម្បីធ្វើឲ្យមានការរីកចម្រើន ដោយខិតខំសម្រេចគោលដៅទាំងនោះ និងវាយតម្លៃការរីកចម្រើនរបស់អ្នក។ នៅពេលណាអ្នកមានអារម្មណ៍ថា អ្នកបានទៅដល់គោល

ដៅ ចូរស្វែងរកការណែនាំពីព្រះសម្រាប់ជំហានបន្ទាប់ក្នុងការកែលម្អឲ្យប្រសើរឡើង។ ចូរគូសចំណាំកន្លែងណាមួយក្នុងសៀវភៅនេះ ដែលអ្នកមានអារម្មណ៍ថាព្រះកំពុងមានបន្ទូលទៅកាន់អ្នក អំពីផ្នែកដែលត្រូវការលើកយកមកដោះស្រាយ។ សូមពិនិត្យមើលសម្ភារៈជាបន្តបន្ទាប់ ហើយវាយតម្លៃពីរបៀបដែលអ្នក និងក្រុមជំនុំរបស់អ្នកកំពុងធ្វើនៅក្នុងចំណុចទាំងនេះ។ សូមបន្តរំឭកមេរៀនក្នុងសៀវភៅនេះ និងវាយតម្លៃមកលើដំណើរការដែលអ្នក និងពួកជំនុំរបស់អ្នកក្នុងផ្នែកទាំងនេះ។ ការប្រើបញ្ជីសម្រាប់វាយតម្លៃ គឺជាវិធីសាស្ត្រដ៏ប្រសើរ ដើម្បីចង្អុលបង្ហាញចំណុចខ្វះខាត និងការព្រួយបារម្ភ។

ការវាយតម្លៃខាងក្រោមរាប់បញ្ចូលអ្វីដែលខ្ញុំបានពិភាក្សានៅក្នុងសៀវភៅនេះ ដើម្បីជួយឲ្យអ្នកមើលឃើញកាន់តែច្បាស់ នូវអត្ថប្រយោជន៍ដែលមេរៀនក្នុងសៀវភៅនេះ មានចំពោះកម្មវិធីថ្វាយបង្គំរបស់អ្នករៀងរាល់សប្ដាហ៍។

# បញ្ជីវាយតម្លៃការថ្វាយបង្គំ

តើអ្នកធ្វើការវាយតម្លៃដោយស្មោះត្រង់ មកលើកម្មវិធីថ្វាយបង្គំរបស់អ្នកនៅពេលណា? ខ្ញុំមិននិយាយសំដៅទៅលើការអង្គុយជុំគ្នានៅព្រឹកថ្ងៃច័ន្ទ ហើយសួរថា "តើកម្មវិធីថ្វាយបង្គំកាលពីថ្ងៃអាទិត្យមុន មានដំណើរការដូចម្ដេច?" ការធ្វើការវាយតម្លៃម្ដងម្កាក់យ៉ាងដូចនេះអាចមានប្រយោជន៍ តែការវាយតម្លៃដែលស៊ីជម្រៅជាងនេះនឹងជួយយើងឱ្យលះបង់កាន់តែខ្លាំងថ្វាយព្រះក្នុងកម្មវិធីថ្វាយបង្គំ។

ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យថតវីដេអូកម្មវិធីថ្វាយបង្គំរបស់អ្នក ហើយបន្ទាប់មកអង្គុយជាមួយអ្នកដឹកនាំសំខាន់ៗរបស់អ្នក ក្រុមថ្វាយបង្គំទាំងមូល ក្រុមចម្រៀង ឬអ្នកផ្សេងទៀត ហើយផ្ដល់ការវាយតម្លៃដោយស្មោះត្រង់សម្រាប់កម្មវិធីនេះ។ វីដេអូនេះនឹងមានប្រយោជន៍យ៉ាងខ្លាំង ចំពោះការវាយតម្លៃក្នុងផ្នែកខ្លះ ខណៈពេលដែលផ្នែកផ្សេងទៀតនឹងត្រូវបានវាយតម្លៃល្អបំផុតតែនៅក្នុងកម្មវិធីផ្សាយបន្តផ្ទាល់ប៉ុណ្ណោះ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យមើលសំណួរខាងក្រោមនេះឡើងវិញដោយផ្ទាល់រៀងរាល់ថ្ងៃច័ន្ទ នៅពេលអ្នកវាយតម្លៃកម្មវិធីថ្វាយបង្គំនៅថ្ងៃអាទិត្យមុន។ អ្នកប្រហែលជាយល់ថា ការមើលសំណួរខាងក្រោមនេះឡើងវិញមានប្រយោជន៍ចំពោះការរៀបផែនការសម្រាប់កម្មវិធីថ្វាយបង្គំ ក្នុងរយៈពេលពីរបីសប្ដាហ៍ខាងមុខផងដែរ!

ខ្ញុំបានប្រមូលផ្ដុំសំណួរមួយចំនួនខាងក្រោម ដើម្បីជួយអ្នកក្នុងការវាយតម្លៃ៖

## ទស្សនីយភាព

- តើទឹកមុខរបស់ក្រុមច្រៀង/ក្រុមអ្នកភ្លេង/ក្រុមចម្រៀង មានភាពសមរម្យសម្រាប់កម្មវិធីថ្វាយបង្គំឬទេ?
- តើវត្តមានរបស់ក្រុមនេះនៅលើវេទិកាមានភាពសមរម្យសម្រាប់កម្មវិធីថ្វាយបង្គំទេ?
- តើសមាជិកម្នាក់ៗបានចូលរួមតាមរបៀបដែលធ្វើឲ្យក្រុមជំនុំមានចិត្តចង់ចូលរួមឬទេ?
- តើក្រុមថ្វាយបង្គំជាគំរូដ៏ល្អបំផុតនៃអ្នកថ្វាយបង្គំដែលចូលរួមយ៉ាងសកម្មឬទេ?
- តើកាយវិការរបស់នរណាម្នាក់ធ្វើឲ្យគេបែកអារម្មណ៍ ឬហាក់ដូចជាទាញចំណាប់អារម្មណ៍មកលើខ្លួនគាត់ឬទេ?
- តើការស្លៀកពាក់របស់ក្រុមមានភាពថ្លៃថ្នូរ និងសមរម្យទេ? តើវាឆ្លុះបញ្ចាំងពីក្រុមជំនុំរបស់អ្នកទេ?
- តើឆាកត្រូវបានរៀបចំឡើងតាមរបៀបដែលគេអាចមើលឃើញច្បាស់ទេ?
- តើសោភ័ណភាពនៃឆាកមានអំណោយផលដល់ការថ្វាយបង្គំទេ?
- តើភ្លើងសម្រាប់បញ្ចាំងបន្ថែម និងភ្លើងបំភ្លឺផ្សេងទៀត អំណោយផលដល់ការថ្វាយបង្គំដោយមិនធ្វើឲ្យគេមានអារម្មណ៍ថា ពួកគេកំពុងនៅក្នុងរោងមហោស្រពឬទេ?
- តើពាក្យ ឬរូបភាពនៅលើអេក្រង់អាចឲ្យគេមើលឃើញច្បាស់ពីកន្លែងអង្គុយទាំងអស់ទេ?
- តើបរិយាកាសនៃការថ្វាយបង្គំទាំងមូល អំណោយផលដល់ការថ្វាយបង្គំដែលមានការចូលរួមយ៉ាងសកម្ម ឬវាហាក់ដូចជាកន្លែងមនុស្សកំពុងទស្សនាការសម្តែង?

## ផ្នែកតន្ត្រី

- តើសមាជិកក្រុមទាំងអស់ហាក់ដូចជាស្គាល់បទចម្រៀងនេះច្បាស់ដែរឬទេ?
- តើបទចម្រៀងត្រូវបានលេងក្នុងល្បឿនចង្វាក់ត្រឹមត្រូវឬទេ?
- តើអ្នកច្រៀងបានច្រៀងត្រូវតាមខ្នងឬទេ?
- តើឧបករណ៍ភ្លេងត្រូវបានលេងត្រូវគុងឬទេ?

- តើតម្រុយរបស់អ្នកដឹកនាំការថ្វាយបង្គំជាការគួរឲ្យកត់សម្គាល់ និងងាយស្រួលក្នុងការធ្វើតាមឬទេ?
- តើការចុះសម្រុងគ្នាមានភាពត្រឹមត្រូវ និងសមរម្យទេ?
- តើគេប្រគំបទចម្រៀងនៅក្នុងតុងដែលសមស្របសម្រាប់ក្រុមជំនុំច្រៀងជាមួយឬទេ?
- តើមាននរណាម្នាក់កំពុងធ្វើឲ្យគេបែកអារម្មណ៍ដោយការលេងភ្លេងឬច្រៀងដែលលេចធ្លោពេក ឬមិនបានត្រៀមខ្លួន និងធ្វើបទបង្ហាញមិនបានល្អឬទេ?

## ផ្នែកបច្ចេកទេស

- តើការ mixភ្លេងមានលក្ខណៈដូចម្ដេចដែរ?
- តើកម្រិតសម្លេងសមរម្យឬទេ?
- តើក្រុមជំនុំអាចឮមនុស្សនៅជុំវិញពួកគេច្រៀងបានល្អដែរឬទេ? (ឧ. កម្រិតសម្លេងតន្ត្រីនៅលើឆាកមិនបានឮលប់ពីលើការច្រៀងរបស់ក្រុមជំនុំខ្លាំងពេក)?
- តើគេអាចឮអ្នកចម្រៀងបញ្ចេញសម្លេងច្រៀងច្បាស់ឬអត់?
- តើភ្លេងរបស់បទចម្រៀងតែងតែឮជាងសម្លេងផ្សេងទៀតឬទេ?
- តើសម្លេងរបស់ឧបករណ៍ភ្លេងត្រូវបានលាយបញ្ចូលគ្នាយ៉ាងល្អឬទេ?
- បើក្រុមថ្វាយបង្គំមិនប្រើកាសក្នុងត្រចៀក តើពួកគេអាចស្ដាប់សម្លេងហើយដឹកនាំបានល្អឬទេ?
- តើរូបភាពដែលបានបញ្ចាំងបានលើកកម្ពស់ ឬរារាំងដល់ការថ្វាយបង្គំឬទេ?
- តើស្លាយអត្ថបទចម្រៀងបានផ្លាស់ប្ដូរពីវគ្គមួយទៅវគ្គមួយទៀតឲ្យបានមុនពេលដែលក្រុមជំនុំមានទំនុកចិត្តច្រៀងនៅឃ្លាបន្ទាប់ឬទេ?

## ការនាំពួកជំនុំចូលរួម

- តើអ្នកមានអារម្មណ៍ថាក្រុមជំនុំមានចិត្តដែលនៅជាប់ជាមួយនឹងព្រះក្នុងការថ្វាយបង្គំឬទេ?
- តើពួកជំនុំបានចូលរួមកម្មវិធីថ្វាយបង្គំយ៉ាងសកម្ម ដោយការបណ្ដាលចិត្តតាមរយៈមធ្យោបាយផ្សេង ក្រៅពីការច្រៀង (ដូចជាការអធិស្ឋានជាក្រុមតូចៗ ការអានបទគម្ពីរឮៗ ការចែករំលែកជាមួយអ្នកដទៃ ពីរបៀបដែលព្រះកំពុងធ្វើការ ការអធិស្ឋាននៅអាសនា ការនាំយកតង្វាយនៅខាងមុខ ការប៉ះពាល់ចិត្ត

ក្នុងពិធីលៀងព្រះអម្ចាស់។ល។)?
- តើកាយវិការចលនា និងឥរិយាបថបែបណា ដែលក្រុមជំនុំត្រូវបានអញ្ជើញឱ្យចូលរួម (ដូចជា ការលើកដៃ ទះដៃ ងើបក្បាល ឱនក្បាល យោលខ្លួន អង្គុយចុះ ឬចាកចេញមានរបៀប លុតជង្គង់ ឈរ ក្រាប បើកចំហដៃ លើកដៃឡើងលើ ដាក់បាតដៃផ្ងារ។ល។)?
- តើពួកជំនុំក្នុងជំនាន់នីមួយៗហាក់ដូចជាបានចូលរួមក្នុងការថ្វាយបង្គំឬទេ?
- តើអ្នកមានចេតនារៀបចំការថ្វាយបង្គំ ដើម្បីឲ្យមានការបង្រួបបង្រួមឬទេ?
- តើអ្នកមានការរៀបចំជាជំហាន ដើម្បីជួយក្រុមជំនុំត្រៀមខ្លួនសម្រាប់ការថ្វាយបង្គំរួមគ្នាដោយផ្តល់បទចម្រៀងក្នុងអំឡុងសប្តាហ៍ ដើម្បីណែនាំពួកគេក្នុងការរៀបចំដែរឬទេ?
- តើក្រុមជំនុំតែងតែដឹងថា គេបានរំពឹងពួកគេឲ្យច្រៀងបទចម្រៀងដែលក្រុមជំនុំត្រូវច្រៀងឬទេ (ឧទាហរណ៍ តើក្រុមជំនុំចូលរួមច្រៀងជាមួយក្រុមថ្វាយបង្គំយ៉ាងសកម្មទេ នៅពេលដែលអ្នកច្រៀងតែម្នាក់កំពុងច្រៀងតាមមីក្រូហ្វូន)?
- តើក្រុមថ្វាយបង្គំតែងតែដឹងថាក្រុមជំនុំកំពុងមានការចូលរួមដូចម្តេចខ្លះ ទាំងការមើលឃើញ និងសម្លេងឬទេ? (ឧទាហរណ៍ តើពន្លឺ និងសម្លេងបានជួយពួកគេឲ្យមើលឃើញ និងស្តាប់ឮពួកជំនុំជាជាងមានអារម្មណ៍ដាច់ចេញពីពួកគេ?

## លំដាប់លំដោយនៃការថ្វាយបង្គំ

- តើការបើកកម្មវិធី/ស្វាគមន៍ត្រូវបានគិតទុកជាមុនយ៉ាងល្អិតល្អន់ និងបានបង្ហាញចេញមក ដើម្បីជួយពួកជំនុំមានអារម្មណ៍កក់ក្តៅ និងអញ្ជើញពួកគេឱ្យថ្វាយបង្គំឬទេ?
- តើការថ្វាយបង្គំមានលំដាប់លំដោយពីដើមដល់ចប់យ៉ាងណាខ្លះ?
- តើការឆ្លងពីចំណុចមួយទៅចំណុចមួយទៀតក្នុងកម្មវិធីថ្វាយបង្គំធ្វើបានល្អទេ?
- តើការឆ្លងពីចំណុចមួយទៅចំណុចមួយទៀតមានលក្ខណៈផ្សេងៗពីគ្នាដែរឬទេ (ឧទាហរណ៍ ការដកស្រង់បទគម្ពីរ ការប្រើសម្រង់អត្ថបទចម្រៀង ការដឹកនាំក្នុងពេលបម្រើ ការអធិស្ឋាន ការបង្រៀនអំពីការថ្វាយបង្គំ ការចែកចាយអំពីប្រវត្តិរបស់បទចម្រៀង ការបង្រៀនអំពីលក្ខណសម្បត្តិរបស់ព្រះ ឬការភ្ជាប់ជាមួយប្រធានបទ)?

- តើការឆ្លងពីចំណុចមួយទៅចំណុចមួយទៀតដោយប្រើពាក្យសម្ដីមានភាពគ្រប់គ្រាន់ និងមានន័យទេ?
- តើការឆ្លងពីចំណុចមួយទៅចំណុចមួយទៀតដោយប្រើភ្លេងបានប្រតិបត្តិបានល្អ និងមានប្រយោជន៍ចំពោះលំដាប់លំដោយនៃកម្មវិធីថ្វាយបង្គំដែរទេ?
- តើការឆ្លងពីចំណុចមួយទៅចំណុចមួយទៀត ដោយប្រើអត្ថបទ ឬ ការតភ្ជាប់នឹងប្រធានបទរបស់កម្មវិធីថ្វាយបង្គំ នៅចន្លោះបទចម្រៀង បានតភ្ជាប់ដួងចិត្ត និងគំនិតឱ្យកាន់តែប្រសើរឡើងទេ?
- តើមានការរំខានដល់ដំណើរការដ៏រលូន និងទិសដៅក្នុងកម្មវិធីថ្វាយបង្គំឬទេ?
- តើការប្រកាសព័ត៌មានត្រូវបានបន្ថយឱ្យតិចបំផុត ហើយត្រូវបានរាប់បញ្ចូលតែនៅដើមដំបូង ឬចុងបញ្ចប់នៃការថ្វាយបង្គំឬទេ?

## ការបន្ថែមសកម្មភាពនៅចន្លោះវគ្គ

- តើមានពេលសម្រាប់ការបន្ថែមសកម្មភាពនៅចន្លោះវគ្គតាមការគ្រោងទុកឬទេ? បើដូច្នេះ តើអ្នកបានអនុវត្តបានល្អយ៉ាងណា? តើការបន្ថែមសកម្មភាពនោះ មានប្រសិទ្ធភាពយ៉ាងណា ក្នុងការនាំពួកជំនុំចូលរួមយ៉ាងសកម្ម?
- នៅក្នុងកម្មវិធីថ្វាយបង្គំ តើមានពេលដែលអ្នកមាន «សកម្មភាពបន្ថែម» នៅចន្លោះវគ្គ ដើម្បីដើរតាមការដឹកនាំនៃព្រះវិញ្ញាណដែរឬទេ? តើតន្ត្រីករ និងក្រុមបច្ចេកទេសសម្របខ្លួនតាមអ្នកបានល្អប៉ុណ្ណា? តើវាមានប្រសិទ្ធភាពយ៉ាងណាចំពោះក្រុមជំនុំ? តើអ្នកត្រូវហាត់សមរបៀបបន្ថែមសកម្មភាពសម្រាប់ពេលអនាគតជាមួយក្រុមរបស់អ្នកដែរឬទេ?

## ប្រសិទ្ធភាព និងការបង្កើតសិស្ស

- តើអ្នកគិតថា ក្រុមរបស់អ្នកមានប្រសិទ្ធភាពយ៉ាងណា ក្នុងការដឹកនាំក្រុមជំ តើអ្នកគិតថា ក្រុមរបស់អ្នកមានប្រសិទ្ធភាពយ៉ាងណា ក្នុងការដឹកនាំក្រុមជំនុំ ចូលទៅក្នុងព្រះវត្តមានរបស់ព្រះ?
- ឧបមាថា កម្មវិធីថ្វាយបង្គំនេះ គឺជាមធ្យោបាយតែមួយគត់ ដែលពួកជំនុំអាចទទួលបានការបង្រៀន ក្នុងលក្ខណៈជាការបង្កើតសិស្សក្នុងសប្ដាហ៍នេះ។ តើអ្នកបានរៀបចំផែនការ និងអនុវត្តនូវការអធិស្ឋាន ការអានបទគម្ពីរ ចម្រៀង និងការឆ្លងពីចំណុចមួយទៅចំណុចមួយទៀត ក្នុងកម្មវិធីថ្វាយបង្គំដូចម្ដេចខ្លះ ដើម្បីបង្រៀនពួកជំនុំ ក្នុងលក្ខណៈជាការបង្កើតសិស្ស?

- តើកម្មវិធីនោះរួមបញ្ចូលធាតុទាំងបីរបស់អក្សរ G នៃរឿងដំណឹងល្អ៖ សិរីល្អនៃព្រះ (Glory of God), ទម្ងន់របស់បាប (Gravity of sin) និងភាពអស្ចារ្យនៃព្រះគុណ (Greatness of Grace) ដែរឬទេ?

## បទចម្រៀង

- តើអ្នកកំពុងប្រើបញ្ជីបទចម្រៀងក្នុងការធ្វើផែនការសម្រាប់កម្មវិធីថ្វាយបង្គំឬទេ?
- តើបទចម្រៀងទាំងអស់ដែលអ្នកបានប្រើបានឆ្លងកាត់ការសម្រិតសម្រាំងស្របតាមព្រះគម្ពីរ និងតន្ត្រីដែលបានពិភាក្សានៅក្នុងសៀវភៅនេះទេ?
- តើបទចម្រៀងដែលគេប្រើក្នុងការថ្វាយបង្គំដែលបង្ហាញពីភាពសម្បូរបែប (បទទំនុកសកល ទំនុកខ្មែរបរិសុទ្ធ បទទំនុកសកលចាស់ បទចម្រៀងថ្វាយបង្គំសម័យទំនើប។ល។) ឬទេ?
- តើអ្នកមានការកំណត់សម្រាប់ការបន្ថែមបទចម្រៀងថ្មីក្នុងកម្មវិធីថ្វាយបង្គំមិនឲ្យលើសពីមួយបទឬទេ?
- តើអ្នកនាំគេច្រៀងបទចម្រៀងថ្មីតាមរបៀបដែលបានរៀបរាប់ក្នុងសៀវភៅនេះឬទេ?
- តើគេរៀនច្រៀងបទចម្រៀងថ្មីឲ្យស្ទាត់ដោយការច្រៀងឡើងវិញចំនួនបីសប្ដាហ៍ជាប់គ្នាឬទេ?
- តើអ្នកមានអារម្មណ៍ថា បទចម្រៀងណាមួយដែលអ្នកបានច្រៀងក្នុងសប្ដាហ៍នេះមានរយៈពេលវែងពេក ឬច្រំដែលពេកសម្រាប់ក្រុមជំនុំឬទេ (ក្រុមជំនុំហាក់ដូចជាមិនសូវមានការចូលរួមនៅពេលដែលបទចម្រៀងបន្តទៅមុខទៀត)?

## បទបង្ហាញ

- តើបទចម្រៀងត្រូវបានច្រៀង តាមរបៀបដូចគ្នាក្នុងល្បឿន បន្ទរ និងស្ពានចម្លងនីមួយៗ ឬច្រៀងតាមរបៀបចម្រុះគ្នានៅក្នុងបទចម្រៀងទាំងមូលដែលបង្កើតឲ្យមានលក្ខណៈនៃបទចម្រៀង និងអារម្មណ៍ចម្រុះគ្នាឬទេ?
- ប្រសិនបើគេច្រៀងបទចម្រៀងដែលពួកជំនុំមិនចាំបាច់ត្រូវបន្លឺសម្លេងច្រៀងជាមួយ តើក្រុមចម្រៀងបានច្រៀងក្នុងលក្ខណៈជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំឬជាក្រុមសម្ដែង?

## ក្រុមចម្រៀង

- ប្រសិនបើគេប្រើក្រុមចម្រៀង តើគេយល់ឃើញថា ក្រុមចម្រៀងនោះកំពុងដឹកនាំគេថ្វាយបង្គំដែរឬទេ?
- តើគេមើលឃើញសមាជិកម្នាក់ៗមានការចូលរួមយ៉ាងសកម្មក្នុងបទចម្រៀងសម្រាប់ពួកជំនុំច្រៀងជាមួយ និងបទដែលពួកជំនុំមិនចាំបាច់ត្រូវច្រៀងជាមួយឬទេ?
- តើសមាជិកម្នាក់ៗមានការសម្ដែងចេញដោយអំណរឬទេ?
- តើអ្នកមានអារម្មណ៍ថា ក្រុមចម្រៀងជាកត្តាជំរុញពួកជំនុំឲ្យចូលរួមការថ្វាយបង្គំឬទេ?

## ធាតុផ្សំដែលប៉ិនប្រសប់

- តើធាតុផ្សំប្រកបដោយភាពប៉ិនប្រសប់របស់កម្មវិធីថ្វាយបង្គំមានប្រសិទ្ធភាពប៉ុណ្ណា ដូចជាការសម្ដែងរឿង ការបញ្ចាំងរូបភាព ការអាន រូបគំនូរ ការសម្ដែងដោយប្រើកាយវិការ និងវីដេអូ?
- តើធាតុផ្សំទាំងនោះមានការរៀបចំ និងបង្ហាញបានល្អដែរឬទេ?
- តើពួកគេបានជួយនាំចិត្ត និងគំនិតរបស់អ្នកថ្វាយបង្គំឲ្យចូលរួមដែរឬទេ?
- តើការប្រើធាតុផ្សំដែលប៉ិនប្រសប់ទាំងនេះចង្អុលមនុស្សទៅរកព្រះជាជាងទាក់ទាញការចាប់អារម្មណ៍ចំពោះអ្នកដឹកនាំកម្មវិធីនោះឬទេ?

## ការអធិស្ឋាន

- តើពេលអធិស្ឋានជាគំរូដ៏សំខាន់ និងមានប្រសិទ្ធភាពក្នុងការជួយបង្កើតសិស្សក្នុងក្រុមជំនុំរបស់អ្នកឬទេ?
- តើការបន្ថែមការអធិស្ឋានលើផែនការក្នុងកម្មវិធីថ្វាយបង្គំមានភាពគ្រប់គ្រាន់ ឬប្រើឃ្លាច្រំដែលច្រើនពេក?
- តើពួកជំនុំត្រូវបានលើកទឹកចិត្តឲ្យមានឥរិយាបថអធិស្ឋាន ដូចជាលុតជង្គង់ លើកដៃឡើង ឬងើបភ្នែកមើលទៅលើឬទេ?
- តើពួកជំនុំត្រូវបានលើកទឹកចិត្តឲ្យមានការចូលរួមកាន់តែច្រើននៅក្នុងពេលអធិស្ឋានដោយការអធិស្ឋានឮៗ អធិស្ឋានជាមួយអ្នកដទៃ ឬអធិស្ឋានដោយស្ងៀមស្ងាត់ តាមការណែនាំឬទេ?

## ក្ដីបារម្ភ

- តើអ្នកបានលើកទឹកចិត្តក្រុមរបស់អ្នកឲ្យមានការអធិស្ឋាន និងការថ្វាយបង្គំផ្ទាល់ខ្លួនដែរឬទេ?
- តើអ្នក និងក្រុមរបស់អ្នកបានចំណាយពេលអធិស្ឋានសម្រាប់ការថ្វាយបង្គំ និងអ្នកចូលរួម ហើយនិងថ្នាក់ដឹកនាំពេញមួយសប្ដាហ៍ឬទេ?
- តើចំណុចជាក់លាក់អ្វីខ្លះដែលរារាំងដល់ការដឹកនាំប្រកបដោយប្រសិទ្ធភាព?
- តើបញ្ហាបច្ចេកទេសថ្មីៗ ដែលចាំបាច់ត្រូវលើកយកមកដោះស្រាយដែរឬទេបើសិនជាមាន?
- តើមានបញ្ហាតន្ត្រីអ្វីខ្លះ ដែលចាំបាច់ត្រូវដោះស្រាយ (បើសិនជាមាន ដូចជាការច្រៀងខុសតុង ការច្រៀង ឬលេងភ្លេងខុសរបៀប ឧបករណ៍ភ្លេងឮខ្លាំងពេក?)។ល។
- តើមានបញ្ហាទំនាក់ទំនង ឬការលំបាកក្នុងចំណោមសមាជិកក្រុមដែលត្រូវដោះស្រាយឬទេ?
- តើមានបញ្ហាខាងវិញ្ញាណដែលត្រូវដោះស្រាយនៅក្នុងសមាជិកក្រុមរបស់អ្នកទេ?
- តើមានបញ្ហានៃការប្ដេជ្ញាចិត្តដែលត្រូវដោះស្រាយដែរឬទេ?
- តើគ្រូគង្វាលរបស់អ្នកបានចូលរួមយ៉ាងសកម្មពេញមួយកម្មវិធីថ្វាយបង្គំដែរឬទេ?

## គំនិតបន្ថែម

សំណួរខាងលើនេះគ្រាន់តែជាការផ្ដល់យោបល់សម្រាប់ការពិភាក្សា នៅពេលអ្នកធ្វើការវាយតម្លៃ។ សូមធ្វើផែនការនៅពេលឥឡូវនេះ សម្រាប់ការវាយតម្លៃកម្មវិធីថ្វាយបង្គំនាពេលខាងមុខ។ តើមានសំណួរអ្វីផ្សេងទៀតដែលអ្នកគិតថា មានសារៈសំខាន់ចំពោះការវាយតម្លៃនេះ?

> **សូមចាំថា:**
> **របៀបដែលពួកជំនុំធ្វើកម្មវិធីថ្វាយបង្គំមានការលូតលាស់ផ្អែកទៅលើការយល់ដឹងជាមូលដ្ឋាន អំពីអត្ថន័យនៃការថ្វាយបង្គំ និងតួនាទីរបស់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំ។ ពេលណាមូលដ្ឋានគ្រឹះនោះមិនមានភាពត្រឹមត្រូវ របៀបដែលពួកជំនុំធ្វើកម្មវិធីថ្វាយបង្គំក៏មិនមានភាពត្រឹមត្រូវមានប្រយោជន៍ខាងវិញ្ញាណដែរ។**

សៀវភៅនេះនឹងជួយអ្នកសង់គ្រឹះឲ្យបានរឹងមាំ ហើយទន្ទឹមនឹងនោះអ្នកអាចដឹងថាគ្រឹះទាំងនោះមានអត្ថប្រយោជន៍យ៉ាងខ្លាំងក្នុងការងារព្រះវិហារ។

## ការប្រើសារអេឡិចត្រូនិក ឬ (Email)

ខាងក្រោមនេះជាសារអេឡិចត្រូនិក ដែលខ្ញុំបានទទួល (ខ្ញុំសូមមិនបញ្ចេញឈ្មោះអ្នកផ្ញើសារនេះ):

*អស់រយៈពេល៤សប្តាហ៍ហើយដែលខ្ញុំ និងភរិយារបស់ខ្ញុំបានចូលរួមជាមួយព្រះវិហារមួយកន្លែងដែលធ្វើកម្មវិធីថ្វាយបង្គំ តាមរបៀបដែលថ្មីសម្រាប់យើង។ យើងកំពុងអធិស្ឋាន និងស្វែងរកព្រះវិហារដែលយើងអាចលះបង់ពេលវេលា និងកម្លាំងរបស់យើងក្នុងការបម្រើព្រះជាមួយពួកគេ។ បន្ទាប់ពីយើងបានចូលរួមបាន៤សប្តាហ៍ ខ្ញុំគិតចង់ស្វែងរកព្រះវិហារមួយកន្លែងទៀត។ អ្វីដែលខ្ញុំបានដកពិសោធន៍នៅទីនោះមានដូចតទៅ៖*

- *ម៉ាស៊ីនបញ្ចេញផ្សែងនៅលើឆាក*
- *ការបញ្ចាំងភ្លើងដែលបញ្ជាដោយកម្មវិធីកុំព្យូទ័រធ្វើឲ្យអ្នកចូលរួមស្រវាំងភ្នែកនៅពេលដែលពួកគេបញ្ចាំងភ្លើងដែលភ្លឺខ្លាំងទៅលើពិដាន បន្ទាប់ពីពួកគេបញ្ចាំងភ្លើងដ៏ស្រទន់នៅលើកម្រាលតដ្ឋ។*
- *ពួកគេច្រៀងចម្រៀងដែលយើងមិនអាចច្រៀងតាមបានដោយបទចម្រៀងភាគច្រើន យើងមិនដែលបានឮពីមុនមក។ យើងមិនអាចចាំទំនុកភ្លេងរបស់បទចម្រៀងទាំងនោះ។ មានអ្នកចូលរួមមិនច្រើនទេ ដែលហាក់ដូចជាចេះច្រៀងបទទាំងនោះ។ ជាការពិតណាស់ យើងមើលជុំវិញខ្លួនយើងក្នុងអំឡុងពេលគេនាំយើងច្រៀងបទចម្រៀងមួយនោះ យើងមិនឃើញមានអ្នកចូលរួមណាម្នាក់ច្រៀងបទចម្រៀងនោះទេ។*
- *បទចម្រៀងខ្លះមានគុងខ្ពស់ពេកបានជាខ្ញុំមិនអាចច្រៀងបាន។ បើសិនជាអ្នក*

*ដឹកនាំកម្មវិធី បានគិតដល់លទ្ធភាពដែលសមាជិកភាគច្រើនអាចច្រៀងបាន នោះមិនដឹងជាល្អយ៉ាងណាទេ។*

- *នៅថ្ងៃអាទិត្យមួយនោះ យើងបានទៅដល់ព្រះវិហារនៅពេលដែលគេចាប់ផ្តើមលេងភ្លេងហើយ ហើយយើងត្រូវឈរនៅកៅអីខាងក្រោយមួយសន្ទុះ ដើម្បីឲ្យភ្នែករបស់យើងអាចសម្របនឹងភាពងងឹតក្នុងកន្លែងថ្វាយបង្គំ មុនពេលយើងស្វែងរកកៅអីអង្គុយ។ យើងស្ទើរតែមិនអាចមើលឃើញមនុស្សនៅក្នុងព្រះវិហារនោះ។*
- *នៅថ្ងៃនេះ ខ្ញុំស្ទើរតែចង់ដើរចេញក្នុងអំឡុងពេលគេច្រៀងបទចម្រៀងទី២ ព្រោះបទចម្រៀងនោះកំពុងតែធ្វើឲ្យខ្ញុំឈឺត្រចៀក។ ក្នុងអំឡុងពេលយើងបើកឡានត្រឡប់មកផ្ទះវិញ ភរិយាខ្ញុំប្រាប់ខ្ញុំថា បទចម្រៀងដែលឮខ្លាំងពេកកំពុងតែធ្វើឲ្យមានថប់បារម្ភដ៏ធ្ងន់ធ្ងរ។ អ្នកចូលរួមអាចយកជ័រសម្រាប់ញ៉ុកត្រចៀកនៅកន្លែងទទួលភ្ញៀវបាន គឺជាសញ្ញាបង្ហាញច្បាស់ថា ព្រះវិហារនោះអាចមានបញ្ហាហើយ។*
- *នៅថ្ងៃអាទិត្យនេះ ពួកគេប្រាកដជាមិនបានពិនិត្យមើលប្រព័ន្ធសំឡេងមុនកម្មវិធីថ្វាយបង្គំ ព្រោះពួកគេបានសារេសំឡេង ខណៈពេលដែលគេកំពុងច្រៀង។ ទាល់តែគេច្រៀងដល់ល្បះទី២ទើបគេអាចសារេសំឡេងច្រៀងជិតត្រូវសំឡេងភ្លេង។ ខ្ញុំមិនអាចឮសំឡេងអ្នកច្រៀងរងទាល់តែសោះ ហើយខ្ញុំក៏មិនឮសម្លេងអ្នកច្រៀងនាំមុខច្បាស់ដែរ ព្រោះសម្លេងឧបករណ៍ភ្លេងលាន់ឮខ្លាំងពេក។*

*យើងស្គាល់មនុស្សជាច្រើនដែលមានវ័យដូចយើង ដែលមានអារម្មណ៍ដូចកូនៗរបស់ពួកគេដែរ។ ខ្ញុំស្គាល់យុវជនមួយចំនួនក្នុងវ័យ២០ឆ្នាំប្លាយដែលទៅចូលរួមកម្មវិធីថ្វាយបង្គំនៅព្រះវិហារនេះ គ្រាន់តែដើម្បីស្តាប់ការអធិប្បាយដែលប៉ះពាល់ចិត្តខ្លាំង តែពួកគេមានអារម្មណ៍មិនស្រួល នៅពេលគេប្រគំបទចម្រៀងនៅទីនោះ។*

*ហេតុអ្វីក្នុងការច្រៀងបទចម្រៀងសរសើរតម្កើង និងថ្វាយបង្គំស្ទើរទាំងអស់គេបានឡើងតុងអុកតាវ ហើយដំឡើងសម្លេងលាន់ឮខ្លាំងទ្វេដងក្នុងពាក់កណ្តាលបទចម្រៀង បន្ទាប់មក កំរិតសម្លេងបានធ្លាក់ចុះមកវិញ នៅផ្នែកចុងក្រោយនៃបទចម្រៀង?*

*ហេតុអ្វីបានជាមានអ្នកដឹកនាំកម្មវិធីថ្វាយបង្គំច្រើនណាស់ពាក់មួក ខណៈពេលដែលក្នុងចំណោមពួកជំនុំ គ្មាននរណាម្នាក់ពាក់មួក?*

*យើងមានមិត្តភក្តិម្នាក់ ដែលបានចូលរួមកម្មវិធីថ្វាយបង្គំ នៅថ្ងៃអាទិត្យមួយនោះ។ គាត់គឺជាអ្នកបច្ចេកទេសប្រព័ន្ធសម្លេង នៅតាមបណ្តាមហោស្រពតន្ត្រីធំៗ។ អ្វីដែលគាត់ទទួលបាននៅថ្ងៃនោះ ក្រៅពីការសារសេរសំឡេងមិនបានល្អ បើសិនជាពួកជំនុំបានច្រៀងទាំងអស់គ្នា (ថ្ងៃនោះមានមនុស្សតិចណាស់ដែលបានច្រៀង) យើងមិនអាចឮពួកគេច្រៀងបានឡើយ។ នេះជាផ្នែកដ៏សំខាន់នៃការថ្វាយបង្គំរួមដែលក្នុងនោះ យើងត្រូវច្រៀងជាមួយពួកបរិសុទ្ធនៅជុំវិញយើង ដោយទទួលព្រះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធ ដោយការប៉ះពាល់ចិត្ត ស្រក់ទឹកភ្នែក និងការឈឺចិត្ត។*

*ដូចនេះ យើងក៏បានព្យាយាមស្វែងរកដំណោះស្រាយដោយបន្តទៅចូលរួមជាមួយពួកជំនុំនេះទៀត តែធ្វើដំណើរទៅដល់ព្រះវិហារ តែនៅពេលដែលការអធិប្បាយព្រះបន្ទូលចាប់ផ្តើម ព្រោះ "បទពិសោធន៍ដែលពួកគេទទួលបានក្នុងកម្មវិធីថ្វាយបង្គំជាដំបូង" មិនបាននាំយើងចូលទៅជិតបល្ល័ង្ករបស់ព្រះអង្គទាល់តែសោះ ឬអាចសាកទៅព្រះវិហារមួយទៀត ហើយស្តាប់ការចាក់ផ្សាយសម្លេងអធិប្បាយរបស់ព្រះវិហារនេះ នៅពេលក្រោយក្នុងសប្តាហ៍នោះ។*

*រឿងដែលគួរឲ្យចាប់អារម្មណ៍នោះ មានការបញ្ចេញមតិជាប្រចាំអំពីការផុសផុលថ្មីៗនេះ នៅសកលវិទ្យាល័យអាសប៊ឺរី (Asbury) ដែលបាននិយាយថា នៅទីនោះមិនមានម៉ាស៊ីនបញ្ចេញផ្សែងនៅលើឆាក មិនមានភ្លើងពណ៌ មិនមានសម្លេងធុងបាសលាន់ឮខ្លាំង មិនមានសម្លេងវាយឆាបខ្លាំងៗ ហើយក៏គ្មានអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ដែលពាក់មួកហាមបញ្ច្រាស និងពាក់ខោខៅប៊យ មានប្រហោងធំៗឡើយ។ គឺគ្រាន់តែមានកម្មវិធីថ្វាយបង្គំដ៏សាមញ្ញ ... ហើយព្រះវិញ្ញាណបរិសុទ្ធក៏បានធ្វើការយ៉ាងសកម្ម។ ពួកគេមិនមែនកំពុងតែមានការកន្ត្រាក់អារម្មណ៍ដោយសារតន្ត្រីនោះទេ តែកំពុងដកពិសោធន៍នឹងព្រះវត្តមានរបស់ព្រះ។*

## មេរៀនដែលទទួលបាន

ខ្ញុំជឿថា កម្មវិធីថ្វាយបង្គំគួរតែមានភាពល្អប្រសើរគ្រប់មធ្យោបាយ។ យើងគួរតែប្រើបច្ចេកវិទ្យាជាជំនួយដល់ការងារបម្រើព្រះតាមដែលចាំបាច់។ ការចាក់ភ្លេងជំនួយ ការប្រើកាសក្នុងត្រចៀក ពន្លឺភ្លើង និងឧបករណ៍សម្លេង និងវីដេអូដ៏អស្ចារ្យអាចជួយយើងក្នុងការដឹកនាំពួកជំនុំរបស់យើង ក្នុងការថ្វាយបង្គំដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ ទោះជាយ៉ាងណាក៏ដោយ យើងក៏អាចប្រើឧបករណ៍ទាំងនេះក្នុងផ្លូវខុស តាមរបៀបដែលធ្វើឲ្យពួកជំនុំបែកអារម្មណ៍ក្នុងកម្មវិធីថ្វាយបង្គំ។

ក្នុងនាមយើងជាអ្នកដឹកនាំ និងអ្នករៀបផែនការសម្រាប់កម្មវិធីថ្វាយបង្គំ យើងចាំបាច់ត្រូវដឹង និងលប់បំបាត់ការបែកអារម្មណ៍ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីបង្កើតបរិយាកាសដែលជួយពួកគេឲ្យតភ្ជាប់ជាមួយព្រះ។ ជាងនេះទៅទៀត ក្នុងនាមយើងជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ យើងត្រូវតែមើលឃើញខ្លួនឯងជាអ្នកជំរុញ ឬអ្នកនាំផ្លូវដែលជួយពួកជំនុំឲ្យចូលរួមក្នុងការថ្វាយបង្គំ និងការសរសើរដំកើង។ យើងមិនត្រូវមើលឃើញខ្លួនឯងជាអ្នកសម្តែង ហើយពួកជំនុំជាអ្នកទស្សនានោះទេ។ ជាការពិតណាស់ យើងចាំបាច់ត្រូវជួយពួកជំនុំឲ្យដកពិសោធន៍ជាមួយព្រះដោយមិនទាក់ទាញចំណាប់អារម្មណ៍សម្រាប់ខ្លួនឯង។

សូមយើងស្វែងយល់ជាលម្អិត តាមរយៈការឆ្លើយតបរបស់ខ្ញុំចំពោះសារអេឡិចត្រូនិកនោះ។

## ពន្លឺភ្លើង និងផ្សែងនៅលើឆាក

សំណង់អាគារព្រះវិហារចាស់ៗ គឺជាស្ថាបត្យកម្មគួរឲ្យស្ញប់ស្ញែង ដែលបណ្តាលចិត្តយើង ហើយក៏អាចបង្កើតបរិយាកាសដ៏ល្អប្រសើរ សម្រាប់ការថ្វាយបង្គំព្រះជាយ៉ាងណានោះពន្លឺភ្លើង និងការប្រើផ្សែងនៅលើឆាក ក៏អាចជួយបង្កើតកន្លែងចូលព្រះវត្តមានព្រះ ពេលណាយើងប្រើប្រាស់ដោយប្រុងប្រយ័ត្ន និងមិនហួសហេតុ ជាពិសេសនៅកន្លែងថ្វាយបង្គំដែលសាមញ្ញ។ យើងចាំបាច់ត្រូវកំណត់ថា មានអ្វីខ្លះដែលមានប្រយោជន៍ ដល់ការបង្កើតបរិយាកាស ដែលអំណោយផលដល់ការថ្វាយបង្គំ និងបរិយាកាសដែលបណ្តាលឲ្យបែកអារម្មណ៍ (ដូចជាការប្រើពន្លឺភ្លើងជំនួយបានល្អ ឬថែមទាំងពន្លឺភ្លើងដែលរំខានភ្នែកពួកជំនុំ)។ ក្នុងនាមយើងជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ យើងចាំបាច់ត្រូវមានប្រាជ្ញា ក្នុងការប្រើអំណោយទាំងអស់នេះ តាមរបៀបដែលមានប្រយោជន៍ដល់កម្មវិធីថ្វាយបង្គំជាជាងធ្វើឲ្យបែកអារម្មណ៍។

ខ្ញុំចូលចិត្តរបៀបដែលលោក ដារីឌ មែនន័រ (David Manner) បានមានប្រសាសន៍អំពីបញ្ហានេះ ក្នុងបណ្តាញសង្គមដូចតទៅ៖

> **យើងត្រូវតែមានការប្រុងប្រយ័ត្នមិនត្រូវបណ្តោយឲ្យភាពប៉ិនប្រសប់ក្នុងកម្មវិធីថ្វាយបង្គំ ធ្វើឲ្យយើងផ្តោតទៅលើភាពប៉ិនប្រសប់ខ្លាំងជាងព្រះអាទិករនោះឡើយ។**

# បទចម្រៀង

ដូចដែលបានលើកមកនិយាយក្នុងមេរៀនមុនក្នុងការស្ទង់មតិ និងការធ្វើការជាមួយពួកជំនុំយ៉ាងទូលំទូលាយ ខ្ញុំបានរកឃើញវិធីដ៏សំខាន់បំផុតពីរយ៉ាង ដែលអ្នកដឹកនាំកម្មវិធីថ្វាយបង្គំបានធ្វើឲ្យពួកជំនុំរបស់ពួកគេ ប្រែក្លាយជាទស្សនិកជនតាមរយៈការច្រៀងចម្រៀងដែលពួកគេមិនចេះច្រៀង និងច្រៀងក្នុងតុងដែលអ្នកចម្រៀងកំរិតមធ្យមមិនអាចច្រៀងបាន។ ដើម្បីឲ្យពួកជំនុំមានការចូលរួមយ៉ាងសកម្ម ក្នុងកម្មវិធីថ្វាយបង្គំ ពួកគេត្រូវតែច្រៀងបទចម្រៀងដែលពួកគេចេះច្រៀង។ បទចម្រៀងថ្មីៗ មានសារៈសំខាន់ចំពោះការថ្វាយបង្គំ និងត្រូវសមស្របនឹងព្រះគម្ពីរ ប៉ុន្តែ អ្នកដឹកនាំកម្មវិធីថ្វាយបង្គំត្រូវតែមានប្រាជ្ញាក្នុងការនាំពួកជំនុំច្រៀងបទថ្មីៗ និងជួយពួកគេឲ្យចេះចាំតាមរយៈការច្រៀងឡើងវិញនៅពេលក្រោយៗទៀត។ ម្យ៉ាងទៀត បើយើងចង់ឲ្យពួកជំនុំផ្លាស់ប្ដូរពីទស្សនិកជនទៅជាអ្នកចូលរួមយ៉ាងសកម្មក្នុងកម្មវិធីថ្វាយបង្គំដែលជាគំរូល្អ យើងត្រូវតែច្រៀងបទចម្រៀងក្នុងតុងដែលអ្នកច្រៀងកំរិតមធ្យមអាចច្រៀងបាន។

ដូចដែលខ្ញុំបានចង្អុលបង្ហាញកន្លងមក ព្រះទ្រង់ត្រាស់ហៅអ្នកដឹកនាំកម្មវិធីថ្វាយបង្គំឲ្យជួយពួកជំនុំឲ្យអស់ពីចិត្ត កម្លាំង និងវិញ្ញាណ ទោះជាត្រូវលះបង់អ្វីៗដែលយើងបានជ្រើសរើសក្នុងនាមជាតន្ត្រីករ។ កម្មវិធីថ្វាយបង្គំ មិនមែនជាការធ្វើឲ្យពួកជំនុំស្ញប់ស្ញែងចំពោះជំនាញច្រៀងរបស់យើងឡើយ តែផ្ទុយទៅវិញ កិច្ចការរបស់យើងជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ គឺត្រូវជួយអ្នកដទៃឲ្យអាចថ្វាយបង្គំព្រះ។

សព្វថ្ងៃនេះ បទចម្រៀងជាច្រើន មានការហក់លោតសម្លេងអុកតាវដែលធ្វើឲ្យគេមានអារម្មណ៍ថា បទចម្រៀងនោះមានការប្រកាស និងអំណាចគឺដូចដែលបានពិពណ៌នាក្នុងសារអេឡិចត្រូនិកខាងលើ។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលមានរឿងនេះកើតឡើង អ្នកច្រៀងកំរិតសម្លេងមធ្យមច្រើនតែមិនអាចតាមទាន់អ្នកច្រៀងនៅលើឆាក។ ជាលទ្ធផល អ្នកចម្រៀងកំរិតមធ្យម ក៏បានបោះបង់ចោលពាក់កណ្ដាលផ្លូវ ហើយក៏ក្លាយជាអ្នកទស្សនាវិញ។ បើបទចម្រៀងមានកំរិតតុងដែលលើសសមត្ថភាពរបស់អ្នកច្រៀងកំរិតមធ្យម យើងគួរតែសម្រួលបទចម្រៀង ឬកុំប្រើវាក្នុងកម្មវិធីថ្វាយបង្គំឡើយ។ មានបទចម្រៀងល្អៗជាច្រើនដែលអាចជំនួសបទចម្រៀងនោះបាន។

សារអេឡិចត្រូនិកខាងលើក៏បាននិយាយអំពីទំនុកភ្លេងដែលគេមិនអាចចងចាំបាន។ អ្នកដឹកនាំកម្មវិធីថ្វាយបង្គំ គួរតែជ្រើសរើសបទចម្រៀងល្អៗ ដែលមានទំនុកភ្លេង ដែលដាក់ជាប់ក្នុងចិត្តរបស់ពួកជំនុំ បន្ទាប់ពីកម្មវិធីថ្វាយបង្គំចប់។ គួរ

ឲ្យស្ដាយណាស់ ដែលយើងច្រើនតែជំរុញពួកជំនុំឲ្យច្រៀងបទចម្រៀងដែលគេមិនអាចចាំបាន បន្ទាប់ពីគេច្រៀងចម្រៀងនោះចប់បានពីរបីនាទី។ យើងគួរតែព្យាយាមផ្ដល់ឲ្យនូវរបបអាហារដែលជាទំនុកច្រៀង និងទំនុកភ្លេងល្អបំផុតសម្រាប់ពួកជំនុំរបស់យើង។

ក្នុងនាមយើងជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ យើងមិនមែនជាសិល្បករតន្ត្រីគ្រីស្ទាននោះបានជាយើងត្រូវតែធ្វើតាមលទ្ធភាពរបស់យើង ដើម្បីជួយបងប្អូនរួមជំនឿរបស់យើង ច្រៀងបទចម្រៀងអស់ពីចិត្ត។

## កំរិតសម្លេង និងពន្លឺក្នុងកន្លែងថ្វាយបង្គំ

ខ្ញុំឮគេត្អូញត្អែរជាញឹកញាប់ថា៖ «ភ្លេងឮខ្លាំងពេកក្នុងកម្មវិធីថ្វាយបង្គំធ្វើឲ្យខ្ញុំឈឺត្រចៀក»។ មានពេលជាច្រើនដង ដែលយើងចង់ដំឡើងសម្លេងច្រៀង និងភ្លេងឲ្យលេចធ្លោខ្លាំង។ ពេលខ្លះ យើងចង់ឲ្យសម្លេងច្រៀងលាន់ឮពេញកន្លែងថ្វាយបង្គំ។ មានកំរិតសម្លេងដែលមិនខ្លាំងពេក មិនខ្សោយពេក ដែលយើងអាចប្រើដើម្បីបង្ហាញចេញនូវការថ្វាយបង្គំ។ ទោះជាយ៉ាងណាក៏ដោយ ពេលណាក្រុមភ្លេងនិងអ្នកចម្រៀងបញ្ចេញសម្លេងឮខ្លាំងពេក គឺមានន័យថាយើងបង្កើតបរិយាកាសសម្រាប់ទស្សនិកជន ជាជាងបរិយាកាសចូលរួម។ ភ្លេងដែលឮខ្លាំងពេក ក៏ប្រាសចាកគោលការណ៍ក្នុងព្រះគម្ពីរដែលកំណត់មកថា ការថ្វាយបង្គំគួរតែមានលក្ខណៈខ្សែបន្ទាត់ឈរ (ពួកជំនុំឆ្ពោះទៅរកព្រះ) និងខ្សែបន្ទាត់ផ្ដេក(ពួកជំនុំរួមគ្នា) គឺដូចមានសេចក្ដីចែងថា «ហើយនិយាយគ្នាទៅវិញទៅមកដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ នឹងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតាជាដរាបក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ» (អេភេសូរ ៥:១៩-២០)។

*បទគម្ពីរនេះ បានលើកឡើងអំពីចំណុចសំខាន់មួយ ដែលយើងបានលើកមកនិយាយ ក្នុងជំពូកទី១ថា កម្មវិធីថ្វាយបង្គំ មានធាតុផ្សំខ្សែបន្ទាត់ឈរ និងខ្សែបន្ទាត់ផ្ដេក។ ការថ្វាយបង្គំរបស់យើងមិនគ្រាន់តែសំដៅទៅរកព្រះ ខណៈពេលដែលយើងថ្វាយព្រះអង្គដោយការសរសើរដំកើង និងថ្វាយបង្គំប៉ុណ្ណោះទេ ដោយថ្វាយការអរព្រះគុណសម្រាប់ការទាំងអស់ដែលព្រះអង្គបានធ្វើ តែក៏តម្រូវឲ្យយើង «និយាយទៅកាន់គ្នាទៅវិញទៅមក» ក្នុងការប្រកាសអំពីភាពសក្ដិសមរបស់ព្រះអង្គដោយធ្វើបន្ទាល់ អំពីសេចក្ដីល្អរបស់ព្រះអង្គ និងចែកចាយអំពីលក្ខណសម្បត្តិផ្សេងទៀតរបស់ព្រះអង្គ។*

ក្នុងព្រះវិហារដែលមានលក្ខណៈដូចព្រះវិហារក្នុងសារអេឡិចត្រូនិកខាងលើ គេបានបើកភ្លើងខ្សោយយ៉ាងខ្លាំង បានជាអ្នកស្ទើរតែមើលមិនឃើញមនុស្សក្នុងកន្លែងថ្វាយបង្គំ ហើយសម្លេងភ្លេងក៏ឮខ្លាំងពេក បានជាអ្នកមិនអាចឮខ្លួនឯងច្រៀង កុំថាឡើយ ស្តាប់ឮសម្លេងមនុស្សនៅក្បែរអ្នកច្រៀង។ ការនេះធ្វើឲ្យគេមានអារម្មណ៍ថា «ទស្សនិកជន» បានមកព្រះវិហារ ដើម្បីទស្សនាការសម្តែង។ ដូចនេះពួកគេក្រោកឈរតែមិនបានចូលរួម គឺដូចដែលសារអេឡិចត្រូនិកខាងលើបានបង្ហាញការសង្កេតមើល។ នៅពេលដែលអ្នកមិនអាចស្តាប់ឮមនុស្សនៅក្បែរអ្នកច្រៀង អ្នកក៏មិនមានការធ្វើដំណើរជាមួយគ្នាក្នុងការថ្វាយបង្គំរួមដែរ។

## របៀបស្លៀកពាក់របស់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំ

នេះជាផ្នែកដែលខ្ញុំនឹងចង់លើកមកនិយាយទាល់តែសោះ។ នៅពេលដែលយុវជនវ័យ២០ឆ្នាំមានការងឿងឆ្ងល់ ហើយសួរខ្ញុំអំពីមូលហេតុដែលអ្នកដឹកនាំកម្មវិធីថ្វាយបង្គំពាក់មួកកីឡាករបេសប៊លនៅលើឆាក ខ្ញុំក៏បានសន្មតថា វាមិនមែនជាបញ្ហាសម្រាប់តែមនុស្សអាយុជាង៤០ឆ្នាំនោះទេ ប៉ុន្តែ ការស្លៀកពាក់របស់អ្នកដឹកនាំកម្មវិធីថ្វាយបង្គំអាចធ្វើឲ្យមនុស្សជាច្រើនបែកអារម្មណ៍ក្នុងកម្មវិធីថ្វាយបង្គំ។ យើងមិនគួរធ្វើខ្លួនជាមនុស្សដែលពិសេស ឬខ្ពស់ជាងគេដែលស្លៀកពាក់ខុសពីអ្នកផ្សេងក្នុងពួកជំនុំរបស់យើងឡើយ។ យើងមិនគួរទាក់ទាញចំណាប់អារម្មណ៍សម្រាប់ខ្លួនយើង។ អ្នកទំនងជាបានឃើញការបង្ហោះសារកំប្លែងអំពីការពាក់មួក ការស្លៀកខោខៅប៊យរីបរាង ឬខោរហែក និងការតុបតែងខ្លួនប្លែកៗជាច្រើនទៀត។ នេះជាការសង្កេតមើលធម្មតាមួយក្នុងចំណោមព្រះវិហារជាច្រើន។ ខ្ញុំគ្រាន់តែសួរគេថា “តើមានហេតុផលអ្វីដែលក្រុមថ្វាយបង្គំ ត្រូវស្លៀកពាក់ខុសពីអ្នកផ្សេងក្នុងពួកជំនុំ?” តើមានអ្វីជំរុញចិត្តយើងឲ្យធ្វើដូចនេះ? ខ្លួនខ្ញុំផ្ទាល់មិនយល់ឃើញថាវាធ្វើឲ្យបែកអារម្មណ៍ខ្លាំងពេកនោះទេ ប៉ុន្តែ តាមមតិយោបល់ដែលខ្ញុំទទួលបានពីមនុស្សជាច្រើនក្នុងវ័យផ្សេងគ្នា ខ្ញុំយល់ថាវាជាបញ្ហាបានជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំគួរតែលើកយកមកពិចារណា។

## សេចក្តីសន្និដ្ឋាន

ឥឡូវនេះ ខ្ញុំសូមសួរថា តើមនុស្សក្នុងពេលសព្វថ្ងៃកំពុងស្វែងរកការដកពិសោធន៍នឹងកម្មវិធីថ្វាយបង្គំពិតប្រាកដមានលក្ខណៈស្របតាមព្រះគម្ពីរ ដែលមិនមានការទាក់ទាញដោយបច្ចេកវិទ្យាកំរិតខ្ពស់ ដែលមានពន្លឺភ្លើងទំនើប ផ្សេងនៅលើឆាក សម្លេងធុងបាសឮៗ អ្នកដឹកនាំកម្មវិធីស្លៀកពាក់ឡូយឆាយ? ។ ល។

ខ្ញុំគិតថា អ្នកសរសេរសារអេឡិចត្រូនិកខាងលើនិយាយបានល្អ នៅពេលដែលគាត់ថា :

រឿងដែលគួរឲ្យចាប់អារម្មណ៍នោះមាន*ការបញ្ចេញមតិជាប្រចាំអំពីការផុសផុលថ្មីៗនេះ នៅសកលវិទ្យាល័យអាសប៊ឺរី (Asbury) ដែលបាននិយាយថា នៅទីនោះ មិនមានម៉ាស៊ីនបញ្ចេញផ្សែងនៅលើឆាក មិនមានភ្លើងពណ៌ មិនមានសម្លេងធុងបាសលាន់ឮខ្លាំង មិនមានសម្លេងវាយឆាបខ្លាំងៗ ហើយក៏គ្មានអ្នកដឹកនាំកម្មវិធីថ្វាយបង្គំដែលពាក់មួកហាមបញ្ច្រាស និងពាក់ខោខោវប៊យ មានប្រហោងធំៗឡើយ។ គឺគ្រាន់តែមានកម្មវិធីថ្វាយបង្គំដ៏សាមញ្ញ ... ហើយព្រះវិញ្ញាណបរិសុទ្ធក៏បានធ្វើការយ៉ាងសកម្ម។ ពួកគេមិនមែនកំពុងតែមានការកន្ត្រាក់អារម្មណ៍ដោយសារតន្ត្រីនោះទេ តែកំពុងដកពិសោធន៍នឹងព្រះវត្ត មានរបស់ព្រះ។.*

តើអ្នកផ្តោតទៅលើផែនការខ្លាំងពេក បានជាអ្នកមិនបើកចំហចិត្តឲ្យព្រះវិញ្ញាណធ្វើការ ក្នុងការដឹកនាំកម្មវិធីថ្វាយបង្គំរបស់អ្នកឬ? តើយើងផ្តោតទៅលើការសម្តែងខ្លាំងពេក បានជាពួកជំនុំរបស់យើង មិនមានការចូលរួមក្នុងកម្មវិធីថ្វាយបង្គំ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែឬ?

ខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យទូលសូមព្រះឆែកមើលចិត្តអ្នក ជាជាងមានអារម្មណ៍ថា គេរិះគន់អ្នក ឬអ្នកចង់ការពារខ្លួនឯង។ តើការងារផ្នែកថ្វាយបង្គំដែលអ្នកដឹកនាំពិតជានាំពួកជំនុំចូលរួមយ៉ាងសកម្មតាមព្រះគម្ពីរដែលនាំឲ្យជីវិតផ្លាស់ប្រែឬទេ?

អ្នកប្រហែលជាគួរតែងាកទៅរក “ទំនៀមទំលាប់ចាស់” ក្នុងកម្មវិធីថ្វាយបង្គំនៅថ្ងៃអាទិត្យណាមួយ ដោយបោះបង់ចោលម៉ាស៊ីនផ្សែង ការបញ្ចេញពន្លឺភ្លើងពណ៌ទំនើប និងអ្វីៗដែលស្រដៀងនេះ ហើយអ្នកនឹងបានឃើញថា អ្នកអាចផ្តោតទៅលើការដឹកនាំពួកជំនុំចូលទៅជួបព្រះ នៃចក្រវាលនេះដែរឬទេ។

# អវសានកថា

សៀវភៅនេះបានផ្ដល់នូវខ្លឹមសារជាច្រើនសន្ធឹក។ ខ្ញុំសូមអធិស្ឋានសូមឲ្យអ្នកប្រើមេរៀនទាំងអស់នេះ ដើម្បីស្វែងរកការដឹកនាំពីព្រះហើយទូលសូមព្រះអង្គបង្ហាញរបៀបដែលព្រះអង្គសព្វព្រះទ័យឲ្យអ្នកចម្រើនឡើង ក្នុងនាមជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ និងរបៀបដែលទ្រង់សព្វព្រះទ័យនឹងបង្កើត ហើយកែលម្អកម្មវិធីថ្វាយបង្គំនៅព្រះវិហារ ដែលទ្រង់បានប្រគល់ឲ្យអ្នកដឹកនាំ។ ការដឹកនាំកម្មវិធីថ្វាយបង្គំគឺជាឯកសិទ្ធិ និងសេចក្តីអំណរដ៏អស្ចារ្យ ប៉ុន្តែ ក៏ជាទំនួលខុសត្រូវដ៏អស្ចារ្យផងដែរ ដូចដែលបានរៀបរាប់នៅលើទំព័រសៀវភៅនេះ។ សម្រាប់អ្នកព្រះទ្រង់បានត្រាស់ហៅឲ្យធ្វើកិច្ចការបម្រើនេះ ព្រះអង្គនឹងប្រទានដល់យើងនូវអ្វីទាំងអស់ដែលយើងត្រូវការ ដើម្បីបំពេញការត្រាស់ហៅរបស់យើង នៅពេលយើងស្វែងរកទ្រង់ ហើយខិតខំដើម្បីទទួលបានការបណ្តុះបណ្តាល និងចំណេះដឹងដែលយើងត្រូវការដើម្បីបម្រើទ្រង់កាន់តែប្រសើរឡើង។ ខ្ញុំសូមអបអរសាទរអ្នកដែលបានចំណាយពេលអានសៀវភៅនេះ។

ខ្ញុំសង្ឃឹមថា អ្នកនឹងរំឭកមេរៀននេះជាទៀងទាត់ហើយសួរថា "តើខ្ញុំអាចកែលម្អផ្នែកទាំងនេះដោយរបៀបណា?" ការរៀនសូត្រ និងការកែលម្អ គឺជាដំណើរការពេញមួយជីវិត។ រាល់ពេលដែលខ្ញុំបង្រៀនមេរៀនទាំងនេះ ខ្ញុំតែងតែទទួលការបណ្តាលចិត្តឲ្យមើលខ្លួនឯង នៅមានចំណុចខ្វះខាតច្រើនប៉ុណ្ណា ឬបានប្រើផ្លូវកាត់ច្រើនប៉ុណ្ណា។ ខ្ញុំចាំបាច់ត្រូវរំឭកមេរៀនទាំងនេះជាប្រចាំ ហើយត្រូវប្រាកដថាខ្ញុំបានបម្រើក្រុមជំនុំរបស់ខ្ញុំបានល្អដោយបង្រៀនពួកគាត់តាមរបៀបបង្កើតសិស្សជួយពួកគាត់ឲ្យចូលរួមក្នុងការថ្វាយបង្គំ ហើយបន្ទាប់មក មើលឃើញការផ្លាស់ប្រែរបស់ពួកគេ។

ជាធម្មតា ខ្ញុំតែងតែបញ្ចប់វគ្គបណ្តុះបណ្តាល ដែលខ្ញុំបង្រៀនដោយផ្ទាល់

ដោយលើកឧទាហរណ៍មួយ ដែលខ្ញុំនឹងចែករំលែកនៅទីនេះ៖

ក្នុងការងារបេសកកម្មរបស់ខ្ញុំជាច្រើនឆ្នាំកន្លងមកនេះ មានពេលជាច្រើនដង ដែលខ្ញុំបានបម្រើព្រះក្នុងប្រទេសបិទទ្វារមិនឲ្យដំណឹងល្អចូលដែលមាន «ស្ដេច» គ្រប់គ្រងប្រទេស។ រឿងដែលខ្ញុំរៀបនឹងចែកចាយនេះ គឺជារឿងប្រឌិតឡើងហើយ ខ្ញុំនឹងដាក់ឈ្មោះឲ្យប្រទេសនោះថា កាម៉ារៀ ( Kamaria) ជាឈ្មោះប្រឌិតជំនួស ឲ្យឈ្មោះពិតរបស់ប្រទេស។

## រឿងនេះក្នុងទម្រង់ទីមួយ

ក្រុមបេសកកម្មរបស់យើងបានទៅប្រទេស កាម៉ារៀ ( Kamaria) ដើម្បី លើកទឹកចិត្ត និងបំពាក់បំប៉នក្រុមជំនុំ។ យើងបាននៅទីនោះអស់ជាច្រើនថ្ងៃដើម្បី ដឹកនាំសន្និបាត និងកម្មវិធីថ្វាយបង្គំ។ ស្ដេចរបស់ប្រទេស កាម៉ារៀ ( Kamaria) តែងតែស្វែងរកមធ្យោបាយដើម្បីកែលម្អទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក។ ទ្រង់ បានឮថា មានភ្ញៀវដែលមកពីសហរដ្ឋអាមេរិកនៅក្នុងប្រទេសរបស់ទ្រង់ ហើយ ទ្រង់បានឲ្យគេមករកខ្ញុំ ហើយអញ្ជើញខ្ញុំមកទទួលទានអាហារពេលល្ងាច ដែល មានតែខ្ញុំ និងស្ដេចប៉ុណ្ណោះ។ ខ្ញុំស្ទើរតែមិនអាចជឿថា ខ្ញុំបានទទួលការអញ្ជើញ បែបនេះឡើយ! គឺអាហារពេលល្ងាចជាមួយស្ដេច! ខ្ញុំបានដឹងថា ទ្រង់បានរស់ នៅក្នុងវាំងដែលមានទំហំលើសពីទំហំ និងភាពអស្ចារ្យនៃរាជវាំង បាក់ឃីងហាំ (Buckingham) នៅប្រទេសអង់គ្លេសទៅទៀត។ គេបានប្រាប់ខ្ញុំថាទីនោះជា កន្លែងដ៏អស្ចារ្យមួយដែលត្រូវទៅមើល។ ខ្ញុំបានសុំគ្រួសារម្ចាស់ផ្ទះដែលខ្ញុំស្នាក់នៅ ឲ្យខ្ញុំខ្ចីរថយន្តរបស់ពួកគេធ្វើដំណើរទៅរាជវាំងនោះ ដើម្បីញ៉ាំអាហារពេលល្ងាច។ ពួកគេបានយល់ព្រមដោយចិត្តសប្បុរស។

ខ្ញុំក៏បានបើកឡានទៅព្រះបរមរាជវាំង ហើយបុគ្គលិកសន្តិសុខបានអនុញ្ញាត ឲ្យខ្ញុំចូលរួចខ្ញុំបើកឡានកាត់តាមទៅច្រកចូលនៃសំណង់អគារដ៏ធំស្កឹមស្កៃ។ អ្នក បម្រើក្នុងរាជវាំងបានស្វាគមន៍ខ្ញុំ ហើយយករថយន្តដែលខ្ញុំបានបើកមកទៅចត នៅក្នុងយានដ្ឋាន។ គាត់បាននាំខ្ញុំទៅច្រកចូលខាងមុខ ដែលមានមេការម្នាក់ ចាំទទួលខ្ញុំបន្ត។ គាត់គឺជាបុរសវ័យកណ្ដាលដែលមានចិត្តល្អម្នាក់ដែលបាននាំខ្ញុំ ចូលក្នុងយកអាវធំរបស់ខ្ញុំទុក ហើយបន្ទាប់មកឲ្យខ្ញុំអង្គុយនៅក្នុងសាល ដើម្បីរង់ ចាំពេលវេលាញ៉ាំអាហារ។ គាត់អង្គុយជាមួយខ្ញុំ ហើយចាប់ផ្ដើមនិយាយជាមួយ ខ្ញុំអំពីស្ដេច។ ព្រះរាជាគឺជាបុគ្គលអស្ចារ្យ មានព្រះទ័យអាណិតអាសូរចំពោះប្រជា រាស្ត្ររបស់ទ្រង់។ ទ្រង់មានសេចក្ដីយុត្តិធម៌ និងទៀងត្រង់ក្នុងការទំនាក់ទំនងជា

មួយមនុស្ស ហើយខ្ញុំមានឱកាសដ៏អស្ចារ្យដែលបានចំណាយពេលជាមួយទ្រង់។ មេការរូបនោះបានព្យាយាមធ្វើឲ្យខ្ញុំសម្រួលអារម្មណ៍ ដើម្បីកុំឲ្យខ្ញុំមានភាពតានតឹងក្នុងពេលវេលានៃការប្រកបអាហាររបស់យើងនោះឡើយ។ ខ្ញុំបានយល់ដឹងបន្ថែមទៀតអំពីរបៀបដ៏ប្រសើរដែលស្តេចស្រឡាញ់ប្រជាជនរបស់ទ្រង់ ហើយខិតខំធ្វើឲ្យប្រទេស កាម៉ារៀ (Kamaria) ក្លាយជាប្រទេសល្អបំផុតនៅលើផែនដី។ ដល់ពេលដែលគាត់នាំខ្ញុំចូលទៅក្នុងបន្ទប់ពិសារភោជនាហារក្នុងរាជវាំង ខ្ញុំបានត្រៀមខ្លួនជាស្រេចដើម្បីចូលគាល់ព្រះរាជា។ ខ្ញុំបានដឹងពីផ្នែកនៃការពិភាក្សាដែលស្តេចនឹងចាប់អារម្មណ៍ប្រសិនបើខ្ញុំមានឱកាសល្អ។ ខ្ញុំបានដឹងពីរបៀបសរសើរទ្រង់ ចំពោះកិច្ចការដ៏អស្ចារ្យទាំងអស់ដែលទ្រង់បានធ្វើសម្រាប់ប្រជាជន កាម៉ារៀ (Kamaria)។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំដូចជាធ្លាប់ស្គាល់ទ្រង់បន្តិចហើយមុនពេលចូលបន្ទប់នោះ។

អាហារពេលល្ងាចរបស់យើងបានប្រព្រឹត្តទៅយ៉ាងល្អប្រសើរ។ យើងបានញ៉ាំអាហារលំដាប់ថ្នាក់ពិភពលោក ហើយការសន្ទនាក៏មានដំណើរទៅមុខយ៉ាងរលូន។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានចំណងមិត្តភាពជាមួយនឹងស្តេច នៅពេលដែលអាហារពេលល្ងាចជិតដល់ទីបញ្ចប់។ ក្រោយពីទទួលទានអាហាររួចព្រះរាជាបានលាខ្ញុំយ៉ាងកក់ក្តៅ ហើយមេការក៏បានជូនដំណើរខ្ញុំ។ គាត់បានប្រគល់អាវក្រៅមកខ្ញុំវិញ ហើយយើងក៏មានការជជែកគ្នាបន្ថែមទៀត។ បន្ទាប់មក គាត់ក៏ចង្អុលបង្ហាញទៅរកឡានដែលខ្ញុំបានបើកបរមកដោយគាត់រង់ចាំខ្ញុំនៅខាងមុខកាំជណ្តើរ។ ខ្ញុំបានបើកឡានទៅផ្ទះដោយចិត្តរីករាយ ដោយនឹកឃើញពេលវេលាដែលខ្ញុំបានចំណាយជាមួយស្តេច។ វាពិតជារាត្រីដ៏ល្អក្រៃលែងដែលខ្ញុំនឹងនៅតែចងចាំជារៀងរហូត។

## រឿងនេះក្នុងទម្រង់ទីពីរ

ខ្ញុំបានទៅប្រទេស កាម៉ារៀ (Kamaria) ជាមួយក្រុមបេសកកម្មរបស់ខ្ញុំ នៅពេលខ្ញុំបានទទួលការអញ្ជើញឲ្យ ទទួលទានអាហារពេលល្ងាចជាមួយស្តេច។ ខ្ញុំបានខ្ចីឡានរបស់ម្ចាស់ផ្ទះខ្ញុំ បានឆ្លងកាត់សន្តិសុខវាំង និងបើកឡានទៅកន្លែងទទួលភ្ញៀវ ហើយបន្ទាប់មក ក៏បានឡើងជណ្តើរទៅទ្វារខាងមុខ។ មេការម្នាក់ប្រចាំរាជវាំងបានស្វាគមន៍ខ្ញុំនៅមាត់ទ្វារ យកអាវក្រៅរបស់ខ្ញុំទៅទុក ហើយនាំខ្ញុំចូលទៅក្នុងបន្ទប់ធំ ដើម្បីរង់ចាំអាហារពេលល្ងាច។ មេការនោះអង្គុយជាមួយខ្ញុំ ហើយចាប់ផ្តើមសន្ទនាជាមួយខ្ញុំ។ ដោយសារខ្ញុំចូលចិត្តអាហារអន្តរជាតិ ពួក

យើងបាននិយាយអំពីអាហារនៅប្រទេស កាម៉ារៀ (Kamaria) ហើយខ្ញុំបានដឹងពីចំណូលចិត្ត និងទឹកន្លែងរបស់គាត់ នៅក្នុងទីក្រុងដែលគាត់ចូលចិត្តជាពិសេស។ យើងបាននិយាយគ្នាអំពីគ្រឿងទេសពិសេសដែលពួកគេប្រើនៅប្រទេស កាម៉ារៀ (Kamaria)។ ខ្ញុំបាននិយាយជាមួយគាត់ អំពីអាហារដែលខ្ញុំចូលចិត្តនៅសហរដ្ឋអាមេរិក ព្រមទាំងអាហារដែលខ្ញុំចូលចិត្តក្នុងប្រទេសមួយចំនួនទៀត។ យើងបានអស់សំណើចពេលយើងនិយាយអំពីអាហារមួយចំនួនដែលយើងបានជួបប្រទះនៅបរទេស ហើយបានសារភាពថា យើងបានញ៉ាំរបស់ដែលគួរខ្ពើមផងដែរ។ គាត់បានរៀបរាប់ថា កូនប្រុសគាត់ដែលជាសិស្សវិទ្យាល័យមានចំណាប់អារម្មណ៍ចង់ទៅរៀននៅមហាវិទ្យាល័យ នៅសហរដ្ឋអាមេរិក គាត់បានសួរខ្ញុំអំពីមហាវិទ្យាល័យជាក់លាក់មួយចំនួន ហើយខ្ញុំក៏បានប្រាប់គាត់អំពីមហាវិទ្យាល័យដែលខ្ញុំបានដឹង។ យើងបាននិយាយអំពីមុខវិជ្ជាដែលមានសក្ដានុពល ហើយនិយាយអំពីការរស់នៅក្នុងតំបន់ផ្សេងៗគ្នានៃសហរដ្ឋអាមេរិក។ មេការនោះក៏បានសួរខ្ញុំនូវសំណួរអំពីគ្រួសាររបស់ខ្ញុំ ហើយគាត់ក៏បានរៀបរាប់ប្រាប់ខ្ញុំអំពីប្រពន្ធ និងកូនបីនាក់ទៀតរបស់គាត់។ ខ្ញុំបានយល់ដឹងខ្លះៗអំពីរបៀបអ្នកបម្រើធ្វើការក្នុងរាជវាំង។ យើងនិយាយគ្នាពីរបីម៉ោង បន្ទាប់មកខ្ញុំបានយកអាវរបស់ខ្ញុំ ហើយគាត់បានជូនដំណើរខ្ញុំ ទៅដល់ឡានរបស់ខ្ញុំកំពុងចតនៅខាងមុខនៃកាំជណ្ដើរ។ ខ្ញុំបានចូលឡានរបស់ខ្ញុំ ហើយចាប់ផ្ដើមបើកឡានត្រឡប់ទៅផ្ទះវិញ។ ប្រហែលពាក់កណ្ដាលផ្លូវមកផ្ទះ ខ្ញុំបានដឹងខ្លួនថា "ខ្ញុំមិនទាន់បានជួបជាមួយស្ដេចនៅឡើយទេ!" ខ្ញុំបានចូលទៅវាំងដើម្បីចូលគាល់ស្ដេច ហើយទទួលលៀងអាហារពេលល្ងាចជាមួយទ្រង់ ប៉ុន្តែ ខ្ញុំមិនដែលឃើញទ្រង់ទេ!

ការធ្វើជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ គឺដូចជាការធ្វើជាមេការម្នាក់ដែរ។ យើងនាំមនុស្សចូលទៅក្នុងវត្តមានរបស់ព្រះ ដោយរៀបចំផែនការ ហាត់សម និងដឹកនាំនៅក្នុងពេលនៃការថ្វាយបង្គំដែលត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ន និងលាងសម្អាតដោយការអធិស្ឋាន។ គួរឲ្យស្ដាយការសិក្សាបង្ហាញថា មនុស្សមួយចំនួនធំដែលមកថ្វាយបង្គំរួមគ្នាបានបង្ហាញថាពួកគេមិនមានអារម្មណ៍ថា ពួកគេបានជួបព្រះក្នុងការថ្វាយបង្គំឡើយ។ ជាញឹកញយណាស់ យើងអាចមានលក្ខណៈដូចជាមេការក្នុងរាជវាំងក្នុងរឿងទីពីរ។ យើងនាំពួកជំនុំចូលរួមនៅក្នុងការសន្ទនាការកម្សាន្តអារម្មណ៍ និងពេលវេលាដែលមិនអាចបំភ្លេចបាន ប៉ុន្តែ យើងមិនដែលនាំពួកគេត្រៀមខ្លួនឲ្យបានត្រឹមត្រូវ ហើយនាំពួកគេចូលទៅក្នុងព្រះវត្តមានរបស់ព្រះដ៏ជាព្រះមហាក្សត្រនោះទេ។ មានពេលច្រើនដងពេកហើយ ដែលគេផ្ដោតការថ្វាយ

បង្គំ ទៅលើបទចម្រៀងដ៏ពីរោះៗ និងការបង្ហាញដ៏អស្ចារ្យៗជាជាងការជួបជាមួយព្រះ។ ឱព្រះអម្ចាស់អើយ សូមអត់ទោសឲ្យយើងខ្ញុំដែលបានធ្វើកម្មវិធីថ្វាយបង្គំដែលផ្តោតទៅលើខ្លួនឯងជាជាងផ្តោតទៅលើព្រះនៃយើងខ្ញុំ។

ទំនួលខុសត្រូវរបស់យើងជាមេការ គឺធំធេងណាស់។ តើយើងនឹងព្យាយាមធ្វើដូចជាមេការក្នុងរឿងទីមួយដែលជួយមនុស្សរៀបចំខ្លួនជួបជាមួយព្រះ ហើយផ្តល់ជំនួយតាមដែលត្រូវការក្នុងការបង្ហាញសេចក្តីស្រឡាញ់ ការថ្វាយបង្គំ និងការសរសើរដល់ព្រះអាទិកររបស់ពួកគេឬទេ?

ខ្ញុំសង្ឃឹមថាសៀវភៅនេះបានជួយអ្នកឲ្យគិត និងអនុវត្តដូចដែលមេការនាំខ្ញុំចូលគាល់ស្តេច។

ក្នុងនាមអ្នកជាអ្នកដឹកនាំថ្វាយបង្គំអ្នកគួរតែ៖

- អធិស្ឋាន ក្នុងការជ្រើសរើសបទចម្រៀងត្រឹមត្រូវ និងធាតុផ្សំផ្សេងទៀតនៃការថ្វាយបង្គំ
- រៀបចំផែនការសម្រាប់ការឆ្លងពីចំណុចមួយទៅចំណុចមួយទៀត និងលំដាប់លំដោយក្នុងកម្មវិធីថ្វាយបង្គំ ខណៈពេលដែលអ្នកបង្កើតកម្មវិធីថ្វាយបង្គំ
- ផ្តល់ធនធានដល់ក្រុមរបស់អ្នក
- ហាត់សមជាមួយក្រុមរបស់អ្នក
- នាំក្រុមជំនុំរបស់អ្នករៀបចំខ្លួន
- រៀបចំខ្លួនឯង
- ដឹកនាំ
- វាយតម្លៃ និងធ្វើឲ្យប្រសើរឡើង

ខ្ញុំសង្ឃឹមថាសៀវភៅនេះបានជួយ ហើយនឹងនៅតែបន្តធ្វើជាជំនួយដល់ព័ន្ធកិច្ចរបស់អ្នក។ ខ្ញុំពិតជាមានអំណរណាស់ដែលបានធ្វើដំណើរជាមួយអ្នកក្នុងសៀវភៅគ្រប់ទំព័រ!

ខ្ញុំអធិស្ឋានសូមឲ្យអ្នកក្រោកឡើង ដើម្បីឆ្លើយតបចំពោះការត្រាស់ហៅដែលព្រះបានដាក់ក្នុងជីវិតរបស់អ្នក ហើយដឹកនាំពួកជំនុំរាល់សប្តាហ៍ ឲ្យចូលទៅក្នុងព្រះវត្តមាននៃការបំផ្លាស់បំប្រែរបស់ព្រះ។ សូមថ្វាយសិរីរុងរឿងដល់ព្រះអង្គ!

**ឥឡូវនេះ សូមចំណាយពេលបន្តិច ដើម្បីអធិស្ឋានសូមព្រះអង្គដឹកនាំអ្នកក្នុងការធ្វើដំណើរក្នុងភាពជាអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ។ សូមអធិស្ឋាន សូមព្រះអង្គបង្ហាញឲ្យអ្នកដឹងថា ព្រះអង្គសព្វព្រះទ័យឲ្យអ្នកមានការកែលម្អឲ្យប្រសើរឡើង ហើយជួយអ្នកប្រឹងប្រែងអស់ពីចិត្តដោយអំណាចព្រះចេស្តាទ្រង់ដើម្បីធ្វើការកែលម្អទាំងនោះ។**

# ការថ្លែងអំណរគុណ

ខ្ញុំមានចិត្តឆេះឆួលយ៉ាងខ្លាំងក្នុងការហ្វឹកហ្វឺនអ្នកដឹកនាំការថ្វាយបង្គំនៅពេញពិភពលោក ដើម្បីឲ្យពួកគាត់អាចដឹកនាំក្រុមជំនុំរបស់ខ្លួនឲ្យកាន់តែល្អប្រសើរជាងមុន ក្នុងការថ្វាយបង្គំដែលផ្លាស់ប្ដូរជីវិត។ ខ្ញុំមានសេចក្ដីរំភើបចំពោះលទ្ធភាពដែលសៀវភៅនេះនឹងផ្ដល់ជូន ដល់មនុស្សជាច្រើននាក់ទៀត ជាមួយនឹងកម្មវិធីសិក្សាដែលបានអភិវឌ្ឍជាង២០ឆ្នាំមកនេះ។ មានមនុស្សជាច្រើននាក់ ដែលព្រះអង្គបានប្រកបប្រើប្រាស់ ដើម្បីលើកទឹកចិត្តខ្ញុំ ជាពិសេសក្នុងការជួយតម្រង់ទិសទាក់ទងទៅនឹងការរៀបចំសៀវភៅនេះឡើង។

ជាដំបូង កាលពីជាង២០ឆ្នាំមុន ខ្ញុំបានទទួលទូរស័ព្ទពីលោក Mark Abernathy ដែលជាអ្នកធ្វើការនៅអង្គការ North Carolina Baptists on Missions ដោយសូមឲ្យខ្ញុំនាំក្រុមថ្វាយបង្គំនៅក្រុមជំនុំរបស់ខ្ញុំទៅដឹកនាំការប្រជុំធំមួយនៃបេសកជន និងគ្រួសាររបស់ពួកគេក្នុងការថ្វាយបង្គំសម្រាប់សន្និសីទរយៈពេលមួយសប្ដាហ៍ នៅប្រទេសម៉ាឡេស៊ី។ បន្ទាប់មកលោក Rodney Duncan ដែលជាបេសកជននៅប្រទេសម៉ាឡេស៊ីបានសូមឲ្យខ្ញុំបង្រៀនក្នុងសន្និសីទថ្វាយបង្គំនៅប្រទេសម៉ាឡេស៊ី និងសិង្ហបុរីក្នុងសប្ដាហ៍។ នោះពិតជាកិច្ចការដែលហួសពីភាពស្រណុកសុខស្រួលរបស់ខ្ញុំមែន ហើយជាអ្វីដែលខ្ញុំមិនដែលធ្លាប់បានធ្វើពីមុនមកទេ។ ចម្លើយ «ព្រម» មួយនេះដែលខ្ញុំបានផ្ដល់ដល់គាត់បានផ្លាស់ប្ដូរព័ន្ធកិច្ចរបស់ខ្ញុំជារៀងរហូត។ ខ្ញុំនៅតែបន្តនាំក្រុមការងារទៅកាន់តំបន់នៃពិភពលោកនោះជាទៀងទាត់ ដោយដឹកនាំសន្និសីទថ្វាយបង្គំ និងកម្មវិធីផ្សេងៗទៀត ព្រមទាំងកែសម្រួល និងរៀបចំកម្មវិធីសិក្សាដែលយើងប្រើប្រាស់ឲ្យស្របតាមបរិបទជាបន្តបន្ទាប់ដែរ។

ព្រះអង្គក៏បានប្រកបប្រើប្រាស់គ្រូគង្វាលពីរនាក់ទៀតនៅក្រុមជំនុំដែលខ្ញុំបាន

បម្រើការជាគ្រូគង្វាលបេសកកម្ម និងការថ្វាយបង្គំ គឺក្រុមជំនុំ Front Street Baptist Church ក្នុងក្រុង Statesville រដ្ឋ North Carolina ដើម្បីលើកទឹកចិត្ត និងអភិវឌ្ឍរូបខ្ញុំក្នុងអំឡុងពេលប៉ុន្មានឆ្នាំដែលខ្ញុំបានបម្រើការជាមួយពួកគាត់។ ខ្ញុំបានរៀនសូត្រយ៉ាងច្រើនពីបុរសទាំងពីរនាក់នេះ។ លោក Gerald Bontrager បានជួយខ្ញុំយ៉ាងខ្លាំងឲ្យលូតលាស់ជាអ្នកដឹកនាំ និងបានលើកទឹកចិត្តដល់ការចូលរួមក្នុងកិច្ចការបេសកកម្មរបស់ខ្ញុំ។ លោក Tim Stutts មិនត្រឹមតែជាអ្នកលើកទឹកចិត្ត និងជាមិត្តដ៏ល្អម្នាក់ក្នុងអំឡុងពេលប៉ុន្មានឆ្នាំដែលយើងបានបម្រើការជាមួយគ្នាប៉ុណ្ណោះទេ ប៉ុន្តែលោកក៏នៅតែបន្តជាមិត្តជិតស្និទ្ធរហូតមកដល់សព្វថ្ងៃនេះ ដែលខ្ញុំតែងតែមានការប្រាស្រ័យទាក់ទងគ្នាយ៉ាងច្រើន។

សមាជិកជាច្រើនក្នុងក្រុមថ្វាយបង្គំនៃក្រុមជំនុំ Front Street Baptist Church ក៏បានសូមឈប់សម្រាកពីការងារជាច្រើនសប្តាហ៍ ដើម្បីជួយខ្ញុំក្នុងកិច្ចការបេសកកម្មអន្តរជាតិក្នុងអំឡុងពេលខ្ញុំនៅទីនោះ។ ខ្ញុំពិតជាអរគុណយ៉ាងខ្លាំងចំពោះការលះបង់ដែលពួកគេបានធ្វើឡើង និងជីវិតមនុស្សជាច្រើនដែលពួកគេបានជះឥទ្ធិពលលើ។ ក្រុមជំនុំក៏បានអនុញ្ញាតឲ្យខ្ញុំមានពេលសម្រាកពីបេសកកម្ម ដែលបានកែប្រែជីវិតរបស់ខ្ញុំបន្ថែមទៀត ខណៈពេលដែលខ្ញុំបានបម្រើការពីរបីខែនៅប្រទេសម៉ាឡេស៊ី។ លើសពីនេះទៅទៀតក៏នៅមានមនុស្សជាច្រើនមកពីក្រុមជំនុំផ្សេងៗទៀតប៉ុន្មានឆ្នាំថ្មីៗនេះ គឺពួកគាត់ក៏បានជួយជ្រោមជ្រែងខ្ញុំក្នុងដំណើរទៅក្រៅប្រទេសទាំងនេះ ហើយពួកគេមានកន្លែងពិសេសមួយនៅក្នុងចិត្តរបស់ខ្ញុំចំពោះការបម្រើ ប្រកបដោយការលះបង់របស់ពួកគេ។

លោក Brian Upshaw បានអញ្ជើញខ្ញុំឲ្យចូលរួមជាបុគ្គលិកនៃក្រុម Baptist State Convention of North Carolina (BSCNC) កាលពី១៣ឆ្នាំមុន។ លោកបានមានប្រសាសន៍ថា ការធ្វើការនៅលើវេទិការបស់ BSCNC នឹងផ្តល់ឲ្យខ្ញុំនូវឱកាសកាន់តែល្អៗទៀត ក្នុងការបង្កើតការផ្លាស់ប្តូរជីវិតរបស់អ្នកដឹកនាំការថ្វាយបង្គំរាប់ពាន់នាក់។ ការធ្វើការឲ្យក្រុម North Carolina Baptists ពិតជាបានបំពេញចិត្ត និងបង្កើតភាពរំភើបយ៉ាងខ្លាំងនៅក្នុងកិច្ចការរបស់អង្គការនៅរដ្ឋ North Carolina និងនៅទូទាំងពិភពលោក។ លោក Brian ដែលជាមិត្ត និងជាអ្នកដឹកនាំដ៏ល្អម្នាក់ គឺគាត់នៅតែបន្តគាំទ្រខ្ញុំតាមច្រើនរបៀប ហើយបានជួយខ្ញុំយ៉ាងខ្លាំងក្នុងការអភិវឌ្ឍខ្លួនជាអ្នកដឹកនាំ។

មានបេសកជនម្នាក់ទៀតដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍរូបខ្ញុំជាអ្នកហ្វឹកហ្វឺនអ្នកដឹកនាំការថ្វាយបង្គំគឺលោក Michael Webber (ឈ្មោះ

ត្រូវបានផ្លាស់ប្តូរដើម្បីហេតុផលសុវត្ថិភាព)។ កាលពីច្រើនឆ្នាំមុន លោកបានអញ្ជើញខ្ញុំឲ្យទៅកាន់ប្រទេសដែលលោកបម្រើបេសកកម្ម តាមការស្នើសូមរបស់ក្រុមជំនុំតាមផ្ទះ ដើម្បីហ្វឹកហ្វឺនអ្នកដឹកនាំការថ្វាយបង្គំវ័យក្មេងមួយចំនួនតូច ដែលគេបានជ្រើសរើស ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្តបន្ទាប់គ្នា។ នោះប្រហែលជាព័ន្ធកិច្ចដែលបំពេញចិត្តខ្ញុំបំផុតដែលខ្ញុំធ្លាប់បានធ្វើ—គឺការបង្កើនពហុគុណខ្លួនឯង នៅក្នុងប្រទេសដែលបិទជិត និងការចាក់បញ្ចូលជីវិតទៅក្នុងគ្រីស្ទបរិស័ទវ័យក្មេងនៅទីនោះ។ ខ្ញុំបានដាក់យុវជន និងយុវតីដ៏ជាទីស្រឡាញ់ទាំងនោះនៅក្នុងចិត្តរបស់ខ្ញុំ ហើយខ្ញុំពិតជាអរគុណចំពោះពួកគេយ៉ាងខ្លាំង (ខ្ញុំចង់ដាក់ឈ្មោះពួកគេនៅទីនេះណាស់ដែរ ប៉ុន្តែដោយសារហេតុផលសុវត្ថិភាព ខ្ញុំមិនអាចធ្វើបានទេ)។ បន្ទាប់មកលោក Michael បានអញ្ជើញខ្ញុំឲ្យចូលរួមក្នុងកិច្ចការដែលកំពុងកើតឡើងនៅប្រទេសកម្ពុជា ដែលបានបើកឱកាសថ្មីៗជាច្រើន។

ឱកាសមួយក្នុងចំណោមនោះ គឺការផ្តល់សៀវភៅស្តីពីការថ្វាយបង្គំសម្រាប់ក្រុមជំនុំនៅប្រទេសកម្ពុជា។ បេសកជនដែលបម្រើជាមួយនឹងអង្គការសកម្មភាពកម្ពុជាម្នាក់បានលើកទឹកចិត្តខ្ញុំឲ្យបង្កើតធនធានឯករាជ្យមួយ (សៀវភៅ) ដើម្បីជួយក្រុមជំនុំនៅទីនោះ ដោយសារតែគ្មានសៀវភៅស្តីពីការថ្វាយបង្គំដែលមានការបោះពុម្ពជាភាសាខ្មែរនៅឡើយ។ ខ្ញុំមានសេចក្តីរំភើបដែលអាចបន្តកិច្ចការដែលបានចាប់ផ្តើមនៅទីនោះក្រោយពីបានធ្វើសន្និសីទពីរបីសប្តាហ៍ បន្ទាប់ពីបានចេញផ្សាយសៀវភៅនេះ។ ខ្ញុំពិតជាអរគុណយ៉ាងខ្លាំងចំពោះអ្នកបកប្រែផ្ទាល់មាត់របស់ខ្ញុំនៅប្រទេសកម្ពុជា ដែលបានបកប្រែប្រកបដោយសេចក្តីស្រឡាញ់នូវសេចក្តីព្រាងសៀវភៅនេះជាភាសាខ្មែរ ដើម្បីរៀបចំសម្រាប់ការបោះពុម្ពផ្សាយ។ នៅពេលដែលខ្ញុំបានរៀបចំសេចក្តីព្រាងនោះរួចរាល់ ខ្ញុំក៏បានបន្តរៀបចំសៀវភៅនេះសម្រាប់ការបោះពុម្ពផ្សាយជាភាសាអង់គ្លេសដែរ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងពិសេសជាទីបំផុតចំពោះលោកស្រី Doris Henderson ដែលជាស្ត្រីម្នាក់បានបង្ហាញគំរូក្នុងការបម្រើព្រះអង្គដោយអស់ពីកម្លាំងកាយចិត្ត ទោះបីជាគាត់បានចូលនិវត្តន៍ក៏ដោយ។ គាត់បានចំណាយពេលរាប់ម៉ោងប្រកបដោយសេចក្តីស្រឡាញ់ក្នុងការកែសម្រួលសេចក្តីព្រាងសៀវភៅនេះ ដើម្បីជួយឲ្យវាមានប្រសិទ្ធភាព និងមានឥទ្ធិពលកាន់តែខ្លាំងក្នុងការទំនាក់ទំនង។

បន្ថែមពីលើនេះលោក David Manner ដែលជាមិត្តភក្តិរបស់ខ្ញុំ ដែលគាត់ក៏ជាអ្នកណែនាំ និងជាអ្នកលើកទឹកចិត្តយ៉ាងអស្ចារ្យម្នាក់តាមរយៈដំណើរការ

នៃការសរសេរសៀវភៅនេះ។ លោក David គឺជាមិត្តដ៏ល្អ និងជាអ្នកនិពន្ធដែលបានជំរុញទឹកចិត្តខ្ញុំជាច្រើនឆ្នាំមកហើយ ដោយលោកមានប្រាជ្ញាជាច្រើន ហើយលោកក៏បានសរសេរក្នុងផ្នែកនៃការថ្វាយបង្គំដែរ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងពិសេសផងដែរដល់ក្រុមការងារទីផ្សារ និងទំនាក់ទំនង (Marketing and Communications Group) នៅក្រុម Baptist State Convention of North Carolina ដែលតែងតែបង្ហាញគំរូនៃឧត្តមភាព ក្នុងគ្រប់កិច្ចការដែលពួកគេធ្វើ ហើយបានជួយខ្ញុំ និងដៃគូរបស់ខ្ញុំឲ្យសម្រេចការត្រាស់ហៅរបស់យើងដោយឧត្តមភាព។ ពួកគេបានយកគម្រោងនេះទៅអនុវត្តយ៉ាងសកម្ម ដើម្បីជួយខ្ញុំអាចប្រើប្រាស់វាបាន ក្នុងការបម្រើដល់ក្រុមជំនុំនានានៅទូទាំងពិភពលោក។ ខ្ញុំពិតជាជំពាក់គុណយ៉ាងពិសេសចំពោះអ្នករចនាសៀវភៅដើមដ៏ល្អរបស់ខ្ញុំ គឺនាង Carlee Hoopes ដែលបានធ្វើការជាមួយខ្ញុំប្រកបដោយការអត់ធ្មត់ ដើម្បីសម្រេចបាននូវសមិទ្ធផលដែលអ្នកកំពុងកាន់នៅក្នុងដៃរបស់អ្នកនៅពេលនេះ។

ក្រុមពិសេសមួយទៀតនៅក្នុងជីវិតរបស់ខ្ញុំ គឺរួមមានដៃគូការងាររបស់ខ្ញុំមកពីសមាគម Baptist ប្រចាំរដ្ឋផ្សេងៗទៀត។ យើងជាក្រុមមិត្តភក្តិដ៏ជិតស្និទ្ធ ដែលធ្វើការជាមួយគ្នា ដើម្បីជួយក្រុមជំនុំរបស់យើងឲ្យកែលម្អពេលវេលាថ្វាយបង្គំរបស់ពួកគេ ព្រមទាំងគាំទ្រ និងលើកទឹកចិត្តគ្នាទៅវិញទៅមក។ ក្រុមនេះគឺដូចជាគ្រួសារមួយសម្រាប់ខ្ញុំ។

នៅពេលនិយាយអំពីការសម្រេចភារកិច្ចដែលព្រះអង្គបានត្រាស់ហៅឲ្យធ្វើខ្ញុំ គឺខ្ញុំត្រូវតែទទួលស្គាល់ថា ខ្ញុំមានពរយ៉ាងខ្លាំងដែលមានជំនួយការផ្នែកព័ន្ធកិច្ចដ៏ល្អម្នាក់ គឺលោក Ethan Nunn ដែលធ្វើឲ្យជីវិត និងការងាររបស់ខ្ញុំមានភាពងាយស្រួលជាងមុនយ៉ាងខ្លាំង។

ខ្ញុំសូមអរគុណបំផុតចំពោះភរិយារបស់ខ្ញុំ គឺលោកស្រី Sandy ដែលជាមិត្តដ៏ល្អបំផុត និងជាដៃគូជីវិតរបស់ខ្ញុំ។ ការគាំទ្រ និងសេចក្ដីស្រឡាញ់របស់នាងបានធ្វើឲ្យខ្ញុំបន្តដំណើរទៅមុខទៀត។ នាងត្រូវអត់ធ្មត់យ៉ាងខ្លាំងចំពោះការធ្វើដំណើរ និងការងាររបស់ខ្ញុំ ប៉ុន្តែប្រពន្ធខ្ញុំតែងតែធ្វើឲ្យផ្ទះរបស់យើងក្លាយជាកន្លែងដ៏ពិសេសបំផុតសម្រាប់ត្រឡប់មកវិញ។ ខ្ញុំអរព្រះគុណព្រះអង្គដែលបានឲ្យនាងធ្វើជាប្រពន្ធខ្ញុំ! ព្រះអង្គក៏បានប្រទានពរដល់ខ្ញុំនូវកូនពីរនាក់ (លោក Kevin និងនាង Katie) កូនប្រសាស្រីដ៏ល្អម្នាក់ (នាង Zion) និងកូនប្រសាប្រុសដ៏ល្អម្នាក់ (លោក Jonathan) ហើយឥឡូវនេះខ្ញុំក៏មានចៅស្រីដ៏គួរឲ្យស្រឡាញ់ពីរនាក់

ទៀត (នាង Raelyn និងនាង Zoe)។

លើសពីនេះទៅទៀត ខ្ញុំសូមអរព្រះគុណព្រះអង្គដែលទ្រង់ស្រឡាញ់មនុស្សមានបាបដូចជាខ្ញុំ ហើយទ្រង់តែងតែអត់ធ្មត់ចំពោះកំហុសឆ្គង និងការខុសឆ្គងទាំងអស់របស់ខ្ញុំ។ ទ្រង់ស្រឡាញ់ខ្ញុំដោយគ្មានលក្ខខណ្ឌ ហើយដឹកនាំខ្ញុំទៅកាន់ឱកាសដ៏រំភើបៗដែលនាំមកនូវអំណរយ៉ាងខ្លាំង ខណៈពេលដែលខ្ញុំរកឃើញចំណុចកណ្តាលនៃព្រះហឫទ័យរបស់ទ្រង់សម្រាប់ជីវិតខ្ញុំ។

ខ្ញុំសូមអធិស្ឋានសូមឲ្យព្រះអង្គប្រើប្រាស់សៀវភៅនេះ ដើម្បីជួយអ្នកដឹកនាំការថ្វាយបង្គំជាច្រើនឲ្យបង្កើតនូវការផ្លាស់ប្តូរនៅក្នុងជីវិតនៃក្រុមជំនុំរបស់ពួកគេ ដោយផ្តល់នូវពេលវេលានៃការថ្វាយបង្គំដែលផ្លាស់ប្តូរជីវិតមែន។

# កំណត់ឈោង

## សេចក្តីផ្តើម


១. លោក John Piper, "Missions Exists Because Worship Doesn't," Desiring God, https://www.desiringgod.org/messages/missions-exists-because-worship-doesnt-a-bethlehem-legacy-inherited-and-bequeathed.

២. លោក Chuck Swindoll, The Church Awakening: An Urgent Call for Renewal (United States: FaithWords, ឆ្នាំ២០១០), Kindle.

៣. លោក Constance M. Cherry, The Worship Architect: A Blueprint for Designing Culturally Relevant and Biblically Faithful Services (Grand Rapids: Baker, ឆ្នាំ២០១០), ទំព័រ២៧០។

៤. លោក Constance M. Cherry, The Worship Architect: A Blueprint for Designing Culturally Relevant and Biblically Faithful Services (Grand Rapids: Baker, ឆ្នាំ២០១០), ទំព័រ២៧០, ដូចដែលបានលើកឡើងដោយលោក James Magaw, "The Power We Invoke," Alive Now (May-June ឆ្នាំ១៩៨៨): 60, quoting Annie Dillard, Teaching a Stone to Talk: Expeditions and Encounters (New York: Harper Collins, ឆ្នាំ១៩៨២), ទំព័រ៤០-៤១។

៥. លោក James Magaw, "The Power We Invoke," Alive Now (May-June ឆ្នាំ១៩៨៨) ទំព័រ៦០-៦១។


## ការយល់ដឹងអំពីការថ្វាយបង្គំ


៦. "Worship," Merriam-Webster Online Dictionary, https://www.merriam-webster.com/dictionary/worship.

៧. លោក Tim Keller, Counterfeit Gods: The Empty Promises of Money, Sex, and Power, and the Only Hope That Matters (Viking, ឆ្នាំ២០០៩), xviii.

៨. លោក Harold Best, Music Through the Eyes of Faith (HarperOne, ឆ្នាំ១៩៩៣), ទំព័រ១៤៣។

៩. "Worship," Merriam-Webster Online Dictionary.

១០. លោក Michael Morrison, “What is Worship? A Survey of the Bible,” Grace Communion Seminary, https://learn.gcs.edu/mod/page/view.php? id=4256.

១១. “Proskuneo,” Bible Study Tools, https://www.biblestudytools.com/lexicons/greek/kjv/proskuneo.html.

១២. “Shachah,” Bible Tools, https://www.bibletools.org/index.cfm/fuseaction/lexicon.show/ID/h7812/page/2.

១៣. លោក John Piper, “What Is Worship,” Desiring God, https://www.desiringgod.org/interviews/what-is-worship.

១៤. ១៤. លោក Warren Wiersbe, Real Worship: It Will Tranform Your Life (United States, Baker Publishing Group, ឆ្នាំ២០០០), ទំព័រ ២៦។

១៥. លោក Robert Schaper, In His Presence: Appreciating Your Worship Tradition (Nashville: T. Nelson Publishers), ទំព័រ១៥-១៦។

១៦. លោក Stephen Brooks, Worship Quest: An Exploration of Worship Leadership (United States: Wipf and Stock Publishers, ឆ្នាំ ២០១៥), Kindle.

១៧. លោក Michael Morrison.

១៨. លោក Bob Kauflin, “Defining Worship, Pt.3,” Worship Matters, https://worshipmatters.com/2005/11/08/defining-worship-part-3.

១៩. លោក Bryan Chapell, Christ-Centered Worship: Letting the Gospel Shape Our Practice (United States: Baker Academic, ឆ្នាំ ២០១៧), ទំព័រ១១៤-១១៥។

២០. លោក Michael Morrison.

២១. លោក Richard Foster, Celebration of Discipline: The Path to Spiritual Growth (New York: HarperCollins, ឆ្នាំ១៩៩៨) ទំព័រ១៧៣។

២២. លោក Steven Brooks.

២៣. ជាចម្បង ការយល់ដឹងអំពីបរិបទទាំងបួននេះគឺដកចេញពីការនិពន្ធរបស់លោក Syd Hielema និងលោក Paul Clark, Jr., និងលោក Steven Brooks. លោកអ្នកនឹងឃើញព័ត៌មានបន្ថែមអំពីធនធានយ៉ាងនេះនៅក្នុងការនិពន្ធ។

២៤. ២៤. លោក Syd Hielema, “The Festival-Envy Syndrome: Four Contexts of Worship”, Reformed Worship 71 (ឆ្នាំ២០០៤). Worship Ministries of the Reformed Church. ប្រើប្រាស់ដោយមានការ

អនុញ្ញាត។
២៥. លោក Jim Altizer, The Making of a Worship Leader (United States: Sound & Light Publishing, ឆ្នាំ២០១៣), ទំព័រ៥២។
២៦. លោក Paul B. Clark, Jr. Tune My Heart to Sing Thy Grace: Worship Renewal Through Congregational Singing (United States: Cross Books Publishing, ឆ្នាំ២០១០), ទំព័រ៤៨-៤៩។
២៧. លោក Syd Hielema.
២៨. លោក Rory Noland, Worship on Earth As It Is in Heaven: Exploring Worship as a Spiritual Discipline. (United States: Zondervan, ឆ្នាំ២០១១), Kindle.
២៩. លោក Kierkegaard, Søren, trans. Douglas V. Steere. Purity of Heart Is to Will One Thing (New York: HarperCollins, ឆ្នាំ ២០០៨), ទំព័រ១៨០-១៨៩។
៣០. លោក Brian Crosby, "Participation in Worship", TableTalk Magazine, https://tabletalkmagazine.com/article/2022/01/participation-in-worship.
៣១. លោក Steve Hamrick, Associate Pastor of Worship & Media, FBC Greenville, MS, សាស្ត្រាចារ្យក្រៅម៉ោងនៅ William Carey University.
៣២. លោក Ed Stetzer និង Thom Rainer, Transformational Church: Creating a New Scorecard for Congregations (United States: B&H Publishing Group, ឆ្នាំ២០១០), ទំព័រ១៦១។
៣៣. លោក Chuck Swindoll, The Church Awakening: An Urgent Call for Renewal (United States: FaithWords, ឆ្នាំ២០១០), Kindle.
៣៤. ក្នុងសៀវភៅដូចគ្នា។
៣៥. ក្នុងសៀវភៅដូចគ្នា។
៣៦. ដកស្រង់ចេញពី First Baptist Church, Durham, NC. ប្រើប្រាស់ដោយមានការអនុញ្ញាត។
៣៧. លោក Chuck Swindoll.
៣៨. ក្នុងសៀវភៅដូចគ្នា។
៣៩. លោក C. S. Lewis, "Answers to Questions on Christianity," in God in the Dock: Essays on Theology and Ethics (Grand Rapids: Eerdmans, ឆ្នាំ១៩៧០], ទំព័រ៥១-៥២។
៤០. លោក Tullian Tchividjian, Unfashionable: Making a Difference in the World by Being

៤១. Different (United States: Crown Publishing Group, ឆ្នាំ២០១២), Kindle. លោក Jim Bradford, ក្នុងសំបុត្រដែលគាត់បានសរសេរជូនទៅកាន់ក្រុមជំនុំគាត់នៅ Central Assembly of God in Springfield, Missouri. លោកបណ្ឌិត Bradford បានអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់សំបុត្រនេះនៅក្នុងសៀវភៅរបស់ខ្ញុំ។

៤២. លោក Henry Blackaby, Richard Blackaby. Flickering Lamps: Christ and His Church. (United States: Blackaby Ministries International), ឆ្នាំ២០១៥។

៤៣. លោក Chuck Lawless, "10 Leadership Mistakes in Transitioning a Church," Chuck Lawless: Evangelism, Leadership, Missiology, Church Health, https://chucklawless.com/2015/10/10-leadership-mistakes-in-transitioning-a-church.

៤៤. លោក Graham Kendrick, មិនស្គាល់ប្រភព។

៤៥. លោក Chuck Swindoll.

៤៦. លោក David Manner, "Are You Leading Worship Change with a Wrecking Ball? Try Deconstruction," Worship Evaluation, http://WorshipEvaluation.org/are-you-leading-worship-change-with-a-wrecking-ball-try-deconstruction/.ការយល់ដឹងអំពីភាពជាអ្នកដឹកនាំការថ្វាយបង្គំ

៤៧. លោក David Manner, "Is Change Necessary? Then Burn Your Boats," Worship Evaluation, http://WorshipEvaluation.org/is-change-necessary-then-burn-your-boats/.

៤៨. លោក Jeff Iorg, Is God Calling Me? : Answering the Question Every Believer Asks (Nashville: B&H Publishing Group, ឆ្នាំ ២០០៨)។

៤៩. ក្នុងសៀវភៅដូចគ្នា ទំព័រ២០។

៥០. លោក Henry Blackaby និង Claude King, Experiencing God: Knowing and Doing the Will of God (United States: B&H Publishing Group, ឆ្នាំ២០០៨) ទំព័រ៥៧។

៥១. លោក Bob Kauflin, "6 Reasons Worship Leaders Should Be Musical Pastors," ChurchLeaders.com, https://churchleaders.com/worship/worship-articles/253170-call-musical-pastors.html/2.

៥២. លោក Brenton Collyer, "How to Increase Engagement in Your Worship Services," Worship Ministry Training Podcast, https://

www.worshipministrytraining.com/how-to-increase-engagement-in-your-worship-services/.

៥៣. លោក John Piper, "What Unites Us in Worship," DesiringGod.org, https://www.desiringgod.org/articles/what-unites-us-in-worship.

៥៤. David Santistevan, "7 Disciplines of a Good Worship Leader," Beyond Sunday Worship, https://www.davidsantistevan.com/7-disciplines-of-a-good-worship-leader/.

៥៥. ដកស្រង់ចេញពីប្រភពដូចគ្នា។

៥៦. លោក A.W. Tozer, The Knowledge of the Holy: The Attributes of God, Their Meaning in the Christian Life (United Kingdom: Clarke, ឆ្នាំ១៩៦៥), Kindle.

៥៧. លោក Zac Hicks. The Worship Pastor: A Call to Ministry for Worship Leaders and Teams (United States: Zondervan, ឆ្នាំ ២០១៦) Kindle.

៥៨. ក្នុងសៀវភៅដូចគ្នា។

៥៩. លោក Rory Noland, The Heart of the Artist: A Character-Building Guide for You and Your Ministry Team (United States, Zondervan, ឆ្នាំ២០០៩), Kindle.

៦០. លោក Jon Nichols ព្យាយាមជួយអ្នកដឹកនាំការថ្វាយបង្គំឲ្យមានក្រុមខ្លាំង ដែលអាចនាំឲ្យមានការថ្វាយបង្គំក្នុងលក្ខណៈជាការចូលរួម តាមរយៈការមានថ្នាក់រៀនលើប្រព័ន្ធអនឡាញ ធនធាន ការណែនាំ។ ល។ លោកអ្នកអាចមើលបន្ថែមទៀតនៅក្នុងគេហទំព័ររបស់គាត់៖ WorshipTeamCoach.com

## ការរៀបចំផែនការនៃការថ្វាយបង្គំ

៦១. ខ្ញុំបានសម្របសម្រួល និងដកស្រង់ចេញពីការនិពន្ធរបស់លោកគ្រូ Pastor Scott Christensen, How to Evaluate Songs for Congregational Worship. Summit Lake Community Church, Mancos, Colorado.

៦២. លោក Mike Harland, "Can We Sing 'Their' Songs," Renewing Worship, https://www.renewingworshipnc.org/can-we-sing-their-songs.

៦៣. ក្នុងសៀវភៅដូចគ្នា។

៦៤. លោក David Manner, នៅក្នុងការបញ្ចេញមតិយោបល់លើការនិពន្ធរបស់លោក Kenny Lamm ក្នុងគេហទំព័ររបស់គាត់ "Should My Church Sing

Songs from Bethel and Hillsong?" Renewing Worship. https://www.renewingworshipnc.org/should-my-church-sings-songs-from-bethel-hillsong-and-elevation-church.

៦៥. លោក Don Chapman, "Linking Praise Songs," WorshipIdeas, https://www.worshipideas.com/linking-praise-songs.

៦៦. លោក Constance Cherry, The Music Architect: Blueprints for Engaging Worshipers in Song (United States, Baker Publishing Group, ឆ្នាំ២០១៦), ទំព័រ៦០។

៦៧. លោក James White, Introduction to Christian Worship, ការកែសម្រួលលើកទី៣ (Nashville: Abingdon, ឆ្នាំ២០០០), ទំព័រ១១៤។

៦៨. ខ្ញុំបានអានអំពីគំនិតនេះជាច្រើនឆ្នាំមុន នៅក្នុងសៀវភៅមួយដែលខ្ញុំមិនអាចរកឃើញប្រភពទៀត។

៦៩. លោក John Piper, Desiring God: Meditations of a Christian Hedonist (United States: Multnomah Books, ឆ្នាំ១៩៩៦), ទំព័រ៨១-៨២។

៧០. ខ្ញុំបានឮអំពីគំនិតនេះនៅក្នុងសេចក្តីអធិប្បាយមួយជាច្រើនឆ្នាំមុន ប៉ុន្តែខ្ញុំមិនអាចរកឃើញប្រភពដើមឡើយ។

៧១. លោក Steven Brooks, Worship Quest, ទំព័រ៧៦។ការដឹកនាំការថ្វាយបង្គំ

៧២. លោក Kenny Lamm, "9 Reasons People Aren't Singing in Worship," Renewing Worship, https://www.renewingworshipnc.org/nine-reasons-people-arent-singing-in-worship. ខ្ញុំបានដកស្រង់គំនិតមួយចំនួនក្នុងដើមកថាខណ្ឌនេះពីអត្ថបទរបស់លោក David Murrow, Why men have stopped singing in church. https://www.patheos.com/blogs/churchformen/2013/05/why-men-have-stopped-singing-in-church/.

៧៣. លោក Alex Enfiedjian, "Eight Tricks to Improve Your Stage Presence," WorshipMinistryTraining.com, https://www.worshipministrytraining.com/8-tricks-to-improve-your-stage-presence.

៧៤. លោក Dave Williamson, God's Singers: A Guidebook for the Worship Leading Choir in the 21st Century (United States: In: Ciite Media, ឆ្នាំ២០១០) ទំព័រ១២៤។